


# ទស្សនាវដ្ដី
# វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម



ឆ្នាំទី៤
លេខ១

ចេញផ្សាយប្រចាំឆមាស
ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែមិថុនា
ឆ្នាំ២០២៥

# និពន្ធនាយក

*ដោយៈ ឯកឧត្តមបណ្ឌិត* **ផុន កសិកា**

# រៀបចំចងក្រង

*ដោយៈ លោក* **ប៉ាន់ សំណាង**

# រចនាក្រប

*ដោយៈ លោក* **ហ៊ាង សុចិត្រា**


*អាសយដ្ឋាន* : *មហាវិថីសហព័ន្ធរុស្សី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ*
*(ជាប់បរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២)*

*គេហទំព័រ* (Website) : https://ihss.rac.gov.kh

*ហ្វេសប៊ុក*(Facebook) : https://web.facebook.com/
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

# កថាមុខ

រាជបណ្ឌិត្យសភាកម្ពុជា ជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។

រាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ ដើម្បីផ្តល់ធាតុចូលជូនរាជរដ្ឋាភិបាលសម្រាប់បម្រើដល់កិច្ចការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះដែរ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងគោលបំណងរួមចំណែក អភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមបានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។ **ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម** ប្រមូលផ្តុំដោយអត្ថបទទាក់ទងទៅនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជា អ្នកអានទូទៅផងដែរ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់សិស្ស និស្សិត អ្នកស្រាវជ្រាវទូទៅ ធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

**ប្រធានវិទ្យាស្ថាន**

**បណ្ឌិត ផុន កសិកា**

# មាតិកា

*ទំព័រ*

១- ការលួចស្នាដៃនិពន្ធ....................................................................................................១

លោកស្រីបណ្ឌិត ព្រុំ ទេវី

២-អត្ថិភាពនិយមតាមរយៈគតិលោករបស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទ........................................................៨

បណ្ឌិត អ៊ុំ ប៉ុម

៣-ស្វែងយល់ពីទស្សនវិជ្ជាអប់រំរបស់សាសនាព្រាហ្មណ៍...................................................................១៨

បណ្ឌិត អ៊ុំ ប៉ុម

៤- ស្វែងយល់ពីពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆ្នាំ២០២៤...........................................២៦

លោកស្រីបណ្ឌិត ជា វណ្ណី

៥- ព្រះរាជជីវប្រវត្តិព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះបរមរតនកោដ្ឋ និងព្រះស្នាព្រះហស្ត..៤០

លោក សួ ប៉ុណ្ណារ៉ាត់

៦-យន្តការច្បាប់ស្តីពីការគ្រប់គ្រងដីធ្លីនៅកម្ពុជា(១៩៩៣-២០០៨) ..................................................៧៣

បណ្ឌិត ឈឿន សាវន

៧-កិច្ចការរដ្ឋបាលទូទៅ.......................................................................................................១០២

បណ្ឌិត ហែម ឡាច

៨-លិខិតបទដ្ឋានគតិយុត្ត.....................................................................................................១១៩

បណ្ឌិត ហែម ឡាច

៩-.តម្លៃមនុស្សក្នុងទស្សនៈរបស់សាសនវិទូ ទស្សនវិទូ និងអ្នកវិទ្យាសាស្ត្រ........................................១៣៥

បណ្ឌិត ប៉ាន់ វុត្ថា

១០-វិបត្តិមហាអំណាចសេដ្ឋកិច្ចបស្ចិមលោក.............................................................................១៤៥

បណ្ឌិត ឈឿន សាវន បណ្ឌិត តូច សុធារី និងលោកសាន ចេង

១១-ការឡើងកម្តៅកពផែនដី..........................................................................................១៥៤

លោក ហៃ សុគន្ធា

១២-ជំនាញសង្គមជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍបុគ្គល...................................................................១៦៦

បណ្ឌិត ទុយ យូឃីម

១៣-គំនិតបង្រួបបង្រួមខ្មែរសម័យមហាអង្គរ.......................................................................................១៧៩

បណ្ឌិត ក្លាន់ ធុល

១៤-ទស្សនៈប្រធានវិស័យនិយម........................................................................................................១៩៥

បណ្ឌិត ក្លាន់ ធុល

១៥-គូបដិបក្ខនៃអង្គវត្ថុ.................................................................................................................២០៤

បណ្ឌិត ក្លាន់ ធុល

១៦-ប្រភពនៃទស្សនវិជ្ជាអប់រំៈ បច្ចានវនិយម....................................................................................២១៦

បណ្ឌិត សូ សុធីរ

១៧-ប្រភពនៃទស្សនវិជ្ជាអប់រំៈ ប្រតិបត្តិនិយម និងអត្ថិភាពនិយម..........................................................២២៥

បណ្ឌិត សូ សុធីរ

១៨-ប្រភពនៃទស្សនវិជ្ជាអប់រំៈ មនោនិយម និងតថនិយម...................................................................២៣៧

បណ្ឌិត សូ សុធីរ

១៩-ប្រភពនៃទស្សនវិជ្ជាអប់រំៈ សច្ចសកលនិយម និងសារវន្តនិយម........................................................២៥០

បណ្ឌិត សូ សុធីរ

២០-ប្រភពនៃទស្សនវិជ្ជាអប់រំៈ ការអភិវឌ្ឍនិយម និងការរិះគន់និយម.....................................................២៦១

បណ្ឌិត សូ សុធីរ

២១-ទ្រឹស្តីវិទូ ចន ឌូវី.....................................................................................................................២៧២

លោក ប៉ាន់ សំណាង

២២-ការស្វែងយល់ពីមូលធនមនុស្ស.................................................... ................................២៨៣

លោក ប៉ាន់ សំណាង

២៣-ទស្សនវិជ្ជាសង្គម និងទស្សនវិជ្ជានយោបាយខ្មែរ តាមរយៈរឿងធម្មបាលកុមារ..............................២៩១

លោក ឈុន ផារ៉េង

២៤-ទស្សនវិជ្ជាសង្គម និងទស្សនវិជ្ជានយោបាយខ្មែរ តាមរយៈរបាំត្រុដិ...........................................៣០៤

លោក ឈុន ផារ៉េង

២៥-និមិត្តកម្មទស្សនវិជ្ជាខ្មែរ(«ក្បួនអ» និមិត្តសញ្ញាទស្សនវិជ្ជាខ្មែរ និងនិយមន័យទស្សនវិជ្ជាខ្មែរ)........៣១៦

លោក ឈុន ផារ៉េង

២៦-ទិដ្ឋភាពទូទៅអ្នកនិពន្ធខ្មែរ..................................................................................................៣២៤

លោក នេត ចំរើន

# ការលួចស្នាដៃនិពន្ធ

## Plagiarism

ដោយ៖ **លោកស្រីបណ្ឌិត ព្រំ ទេវី**
*អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*
Email: promtevy@rac.gov.kh

### សេចក្តីផ្តើម

*និស្សិតនិងអ្នកស្រាវជ្រាវភាគច្រើនតែងត្រូវការទិន្នន័យពីឯកសារដែលមានស្រាប់ដើម្បីឱ្យដឹងថាការស្រាវជ្រាវមុនៗបានធ្វើដល់ណាហើយមុននឹងចាប់ផ្តើមប្រមូលទិន្នន័យបឋម។ ក្នុងការសរសេរកិច្ចការគរុកោសល្យមួយ សេចក្តីស្មោះត្រង់ជាការចាំបាច់បំផុត។ ជាក់ស្តែងគ្រឹះស្ថានបណ្តុះបណ្តាលនានា តែងតម្រូវឱ្យនិស្សិតធ្វើការអះអាងជាសំណេរភ្ជាប់ជាមួយ កិច្ចការរបស់ខ្លួនថា ពិតជាស្នាដៃរបស់ខ្លួនពិតប្រាកដ ហើយពុំបានលួចចម្លងពីអ្នកដទៃឡើយ។ យោងតាមវចនានុក្រមអនឡាញ* Cambridge *បានកំណត់ថា*[1]៖

*ការលួចស្នាដៃនិពន្ធគឺជាការប្រើប្រាស់គំនិតឬអត្ថបទរបស់អ្នកដទៃ យកមកធ្វើជារបស់ខ្លួន។ អត្ថបទនៅទីនេះសំដៅដល់ទាំងអត្ថបទបោះពុម្ពផ្សាយ ទាំងមិនទាន់បោះពុម្ពផ្សាយ សំណៅសរសេរដៃ ទម្រង់អេឡិចត្រូនិច ឬផ្នែកណាមួយដែលបានមកពីបញ្ញាសិប្បនិម្មិតរួមទាំង អត្ថបទផ្ទាល់ខ្លួនផងដែរ។*

*ហេតុអ្វីបានជាអ្នកស្រាវជ្រាវនិងនិស្សិតត្រូវចៀសវាងការលួចស្នាដៃនិពន្ធ? ការសរសេរកិច្ចការឧត្តមសិក្សាក៏ដូចជាកិច្ចការស្រាវជ្រាវផ្សេងទៀតដែរតែងមានក្បួនច្បាប់ពិតប្រាកដ ។ ការបញ្ជាក់ភាពស្មោះត្រង់នេះមានន័យថា និស្សិតនិងអ្នកស្រាវជ្រាវលើកតម្កើងស្នាដៃរបស់ខ្លួន ហើយក៏ជាការដឹងគុណដល់ម្ចាស់ស្នាដៃដើមដែរ។*

### ១- ទម្រង់ផ្សេងៗនៃការលួចស្នាដៃនិពន្ធ

*ការលួចស្នាដៃនិពន្ធមានច្រើនបែបយ៉ាងណាស់។ ខាងក្រោមនេះជាចំណុចមួយចំនួនដែលរាប់បញ្ចូលថាជាការលួចស្នាដៃនិពន្ធ៖*

#### ១. ១- ការលួចចម្លងដោយចេតនា

*ការលួចចម្លងប្រភេទនេះកើតឡើងញឹកញាប់ជាងគេ គឺជាសកម្មភាព ចម្លងយកកិច្ចការអ្នកដទៃទាំងស្រុងឬផ្នែកណាមួយមកធ្វើជារបស់ផ្ទាល់ខ្លួន ហើយនិស្សិតក៏ដឹងដែរថាខ្លួនមានភាពមិនស្មោះត្រង់បែបនេះអាចមានផលប៉ះពាល់ដល់អាជីពរបស់និស្សិតនាពេលអនាគត។*

---

[1] https://dictionary.cambridge.org/dictionary/english/plagiarism. Retrieved on 06-04-2024

អតីតរដ្ឋមន្ត្រីការពារជាតិអាល្លឺម៉ង់ឈ្មោះ Karl-Theodor Freiherr zu Guttenberg បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅឆ្នាំ២០០៧។ ខែកុម្ភៈ ឆ្នាំ ២០១១ គេបានរកឃើញថា គាត់បានលួចស្នាដៃនិពន្ធរបស់គេចំនួន១២១៨ករណីមក ពី១៣៥ ប្រភពផ្សេងៗគ្នា ត្រូវជា៣៧១ទំព័រនៃ៣៩៣ទំព័រ (៩៤,៤%) និង១០ ៤២១បន្ទាត់(៦៣,៨%)នៃនិក្ខេបបទរបស់គាត់សរុប[2]។ ក្រៅពីការដកហូតសញ្ញាបត្រថ្នាក់បណ្ឌិត ខែមីនាក្នុងឆ្នាំដដែល មុខតំណែងក៏ត្រូវបានបញ្ចប់ដែរ[3]។

### ១. ២- ការលួចចម្លងពីអ៊ីនធឺណិត

តាមរយៈ search engine ដូចជា google, Microsoft edge, Chrom នាពេលបច្ចុប្បន្ននេះអ្នកស្រាវជ្រាវនិងនិស្សិតអាចទាញយកទិន្នន័យយ៉ាងសំបូរបែប។ ការប្រើប្រាស់ទិន្នន័យទាំងនោះ បើមិនមានបញ្ជាក់ប្រភពនិងកាលបរិច្ឆេទនៃការដកស្រង់ទេ ចាត់ទុកថាជាការលួចស្នាដៃនិពន្ធ។

ឧទាហរណ៍ : អត្ថបទមានចំណងជើងថា SMEs in Asia and the Pacific ដែលមានក្នុងអ៊ីនធឺណិតពុំមានភ្ជាប់ឈ្មោះអ្នកនិពន្ធអ្វីទាំងអស់។ ដូច្នេះ ដើម្បីបង្ហាញប្រភពត្រូវប្រើគេហទំព័រនិងកាលបរិច្ឆេទនៃការដកស្រង់ភ្ជាប់ជាមួយផងដូចនេះ : https://www.unescap.org/sites/ default/files/7 - SMEs in Asia and the Pacific.pdf. Retrieved on 06-04-2024។

### ១. ៣- ឃ្លាប្រយោគអ្នកដទៃ

ការយកឃ្លាប្រយោគរបស់អ្នកដទៃមកប្រើ ដោយគ្រាន់តែប្តូរ២ទៅ៣ពាក្យឬប្តូរលំដាប់នៃឃ្លាប្រយោគនោះ ចាត់ទុកថាជាការលួចស្នាដៃនិពន្ធ។ ត្រង់ចំណុចនេះ បើសិនជាអ្នកស្រាវជ្រាវឬនិស្សិតដាក់បង្ហាញត្រឹមប្រភព នោះមិនគ្រប់គ្រាន់ទេ ប្រសិនបើម្ចាស់ឃ្លាប្រយោគបានអានអត្ថបទយើង នោះគេនឹងដឹងថាជាឃ្លាប្រយោគរបស់គេ ជាពិសេសឃ្លាប្រយោគជាទ្រឹស្តី ក្នុងអត្ថបទមេរៀនរបស់គ្រូ អត្ថបទគោលនយោបាយជាតិឬអន្តរជាតិ ឬ លិខិតបទដ្ឋានគតិយុត្តណាមួយ។

ឧទាហរណ៍ : និស្សិត **ក** សរសេរនៅក្នុងអត្ថបទស្រាវជ្រាវមួយថា : សហគ្រាសទាំងឡាយនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គួររួសរាន់រៀបចំចុះបញ្ជីដើម្បីប្រែក្លាយជាសហគ្រាសក្នុងប្រព័ន្ធ។ នេះជាលួចស្នាដៃនិពន្ធ។ អ្វីដែលត្រឹមត្រូវនោះគួរសរសេរថា៖

រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧នេះបានជម្រុញឱ្យសហគ្រាសទាំងឡាយនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គួររួសរាន់រៀបចំចុះបញ្ជីដើម្បីប្រែក្លាយជាសហគ្រាសក្នុងប្រព័ន្ធ ដូចបានបញ្ជាក់ក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨។

### ១. ៤- ការលួចស្នាដៃរួម

ក្នុងកំលុងពេលនៃការសិក្សា និស្សិតអាចទទួលបានការងារស្រាវជ្រាវជាក្រុម។ អត្ថបទស្រាវជ្រាវនេះគឺជាកម្មសិទ្ធរួមរបស់សមាជិកក្រុម

[2] GuttenPlag Wiki/English | GuttenPlag Wiki | Fandom. Retrieved on 06-04-2024

[3] https://en.wikipedia.org/wiki/Guttenberg plagiarism scandal. Retrieved on 06-04-2024

បើមានសមាជិកមួយ យកអត្ថបទនោះទៅប្រើធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួនដោយមិនបង្ហាញឈ្មោះសមាជិកផ្សេងទៀត ចាត់ទុកថាជាការលួចស្នាដៃរួម។ ឧទាហរណ៍៖ អត្ថបទស្រាវជ្រាវមានចំណងជើងថាគម្រោងស្តីពីការកែលម្អបណ្ណាល័យនិងបំពាក់សៀវភៅអំណានកុមារនៅសាលាបឋមសិក្សារស្មីសាមគ្គីនៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ជាស្នាដៃស្រាវជ្រាវរបស់ ៖

១) លីឈាង សីហា ២) រិទ្ធ លក្ស្មី

៣) ណែម សុភក្តិ ៤) សាន ច័ន្ទនីរ័ត្ន

និង ៥) សោម វណ្ណារ៉ាក់ដាលី ។

ឧបមាថា នរណាម្នាក់ក្នុងចំណោមអ្នកទាំង៥ យកខ្លឹមសារនៃកិច្ចការស្រាវជ្រាវទៅប្រើក្នុងកិច្ចការស្រាវជ្រាវណាមួយទៀត ត្រូវដាក់ឈ្មោះអ្នកនិពន្ធឱ្យបានគ្រប់គ្នា មិនមែនតែម្នាក់ឯងទេ។

**១. ៥- ការលួចចម្លងដោយស្វ័យប្រវត្តិ**

មុននឹងឈានដល់ដំណាក់កាលសរសេរកិច្ចការគរុកោសល្យ និស្សិតភាគច្រើនអាចធ្លាប់បានសរសេរកិច្ចការអ្វីមួយផ្ទាល់ខ្លួន។ នៅពេលសរសេរ សារណាឬនិក្ខេបបទ ក៏យកកិច្ចការនោះអាចជាផ្នែកខ្លះមកប្រើហើយពុំបានបញ្ជាក់ប្រភពទេព្រោះអាងថាជាកម្មសិទ្ធរបស់ខ្លួន ចាត់ទុកថាជាការលួចចម្លងដោយស្វ័យប្រវត្តិ។

ឧទាហរណ៍: ឆ្នាំ២០០៨ ឈ្មោះ **ក** បានសរសេរសៀវភៅមួយមានចំណងជើងថាការរៀបចំគម្រោងស្រាវជ្រាវដោយខ្លួនឯង លុះដល់ឆ្នាំ ២០១៩អ្នកនិពន្ធដដែលសរសេរអត្ថបទថ្មីមួយទៀត មានចំណងជើងថាវិធីសាស្ត្រស្រាវជ្រាវ។ បើសិនជាមានការប្រើប្រាស់ខ្លឹមសារ ឬ ទិន្នន័យក្នុងរូបភាពណាក៏ដោយចេញពីសៀវភៅដែលបានផ្សព្វផ្សាយហើយ ត្រូវបញ្ជាក់ប្រភពក្នុងកំណត់សម្គាល់ផ្នែកខាងក្រោមនៃទំព័រនិង/ឬក្នុងគន្ថនិទ្ទេស។

**១. ៦- ដាក់ឈ្មោះអ្នកនិពន្ធមិនគ្រប់គ្រាន់**

ករណីខ្លះឯកសារដែលយកមកប្រើមានអ្នកនិពន្ធលើសពី១នាក់។ ដោយខ្វះខាតពេលវេលា ឬមិនបានយកចិត្តទុកដាក់ អ្នកស្រាវជ្រាវឬនិស្សិតបានកត់ត្រាតែឈ្មោះអ្នកនិពន្ធទី១ ហើយអ្នកផ្សេងទៀតមិនបានកត់ត្រា។

ឧទាហរណ៍: សៀវភៅដែលមានចំណងជើងថា អាទិទេពក្រុងអង្គរ ជាស្នាដៃនិពន្ធរបស់ ថាច់ រ៉ាន់ផាត និង កែវ សូកុន បោះពុម្ពដោយរោងពុម្ពរាស្ត្រសច្ចៈ នៅក្រុងភ្នំពេញនាឆ្នាំ១៩៧៣។ នៅក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រនិងគន្ថនិទ្ទេស ចាំបាច់ណាស់ត្រូវសរសេរឈ្មោះអ្នកនិពន្ធ២នាក់ មិនអាចបំភ្លេចមួយណាបានឡើយក្នុងទម្រង់បែបនេះ៖

ថាច់ រ៉ាន់ផាត និង កែវ សូកុន៖ អាទិទេពក្រុងអង្គរ ភ្នំពេញ រោងពុម្ព រាស្ត្រសច្ចៈ ឆ្នាំ១៩៧៣។

**១. ៧- ឈ្មោះនិពន្ធមិនច្បាស់លាស់**

អត្ថបទស្រាវជ្រាវមួយចំនួនធំមានការដកស្រង់ឃ្លាប្រយោគ ហើយមានដាក់ឈ្មោះម្ចាស់អត្ថបទដើម។ ឈ្មោះម្ចាស់អត្ថបទដើម ចំណងជើង អត្ថបទ ទីកន្លែងនិងកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយអត្ថបទនោះ អាចមាននៅក្នុងអត្ថបទឬនៅក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រ។ បើ

អ្នកស្រាវជ្រាវនិងនិស្សិតចង់ដកស្រង់ឃ្លាប្រយោគដដែលនោះ ត្រូវដាក់ឈ្មោះម្ចាស់អត្ថបទដើម មិនមែនឈ្មោះអ្នកនិពន្ធអត្ថបទដែលកំពុងអានទេ។ បើពុំមានលទ្ធភាពរកឃើញអត្ថបទទី១ទេ គួរបន្ថែមពាក្យថា នៅក្នុង អត្ថបទទី២ ដែលកំពុងអាន។

ឧទាហរណ៍៖ ក្នុងអត្ថបទមានចំណងជើងថា គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ចេញផ្សាយពីខែឧសភា ឆ្នាំ២០១៩ ឈ្មោះ ក បានលើកឡើងថាគោលការណ៍គន្លឹះសម្រាប់គំនិតផ្តួចផ្តើមផ្លូវនិងខ្សែ ក្រវាត់ចំនួន៥គឺ៖ ១) ជាវិថីដើម្បីសន្តិភាព ២) ជាវិថីដើម្បីភាពរីចម្រើន ៣) ជាវិថីសម្រាប់ការបើកចំហរ ៤) ជាវិថីសម្រាប់នវានុវត្តន៍ និង៥) ជាវិថីផ្សារភ្ជាប់អរិយធម៌។ ជាក់ស្តែងចំណុចនេះ មិនមែនជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ទេ តែបានស្រង់ពី Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for Internatio-nal Cooperation, 14 May 2017។ ក្នុងន័យនេះ បើសិនមានការយកគំនិតដដែលនេះទៅប្រើបន្ត ត្រូវដាក់ឈ្មោះម្ចាស់ដើមគឺ Xi Jinping ហើយមិនមែនឈ្មោះ **ក** ទេ ក្នុងទម្រង់បែបនេះ៖

Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for International Cooperation, 14 May 2017

តែបើមិនមានលទ្ធភាពទទួលបានអត្ថបទដើមខាងលើនេះទេ ត្រូវសរសេរថា៖

Xi Jinping: Speech at the Opening Ceremony of the Belt and Road Forum for International Cooperation, 14 May 2017 **នៅ**ក្នុង៖ **ក**៖ គំនិតផ្តួចផ្តើមផ្លូវនិងខ្សែក្រវាត់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ភ្នំពេញ ឆ្នាំ២០១៩។

**១.៨- មិនដាក់ឈ្មោះម្ចាស់ដើមអត្ថបទបកប្រែ**

អត្ថបទមួយចំនួនជាស្នាដៃបកប្រែ បើនិស្សិតនិងអ្នកស្រាវជ្រាវមិនបានសរសេរឈ្មោះអ្នកនិពន្ធទេ តែសរសេរឈ្មោះអ្នកបកប្រែ នោះជាការលួចស្នាដៃនិពន្ធ។

ឧទាហរណ៍ : សៀវភៅមានចំណងជើងថា ហ៊ុន សែន បុរសខ្លាំងរបស់កម្ពុជា ជាស្នាដៃបកប្រែដោយលោកកែ សឿងនិងជួន នឿន ហើយម្ចាស់អត្ថបទដើមគឺ Harh C. Mehta & Julie B. Mehta ដែលមានចំណងជើងដើមថា ***Hun Sen. Strongman of Cambodia***។ កាលណាសរសេរត្រឹមតែ៖

កែ សឿង និង ជួន នឿន : ហ៊ុន សែន បុរសខ្លាំងរបស់កម្ពុជា ភេងពុម្ពបាយ័ន ក្រុងតាខ្មៅ ឆ្នាំ២០០០

ជាការលួចស្នាដៃនិពន្ធ បើសរសេរដូចនេះ៖

-Harh C. Mehta & Julie B. Mehta : ហ៊ុន សែន បុរសខ្លាំងរបស់កម្ពុជា បកប្រែពីភាសាអង់គ្លេស ដោយ កែ សឿង និងជួន នឿន ក្រុងតាខ្មៅ ភេងពុម្ពបាយ័ន ឆ្នាំ២០០០ (ចំណងជើងដើម : Hun Sen.

Strongman of Cambodia. Graham Brash, Singapore,1999.) *ជាការត្រឹមត្រូវ។*

### ១. ៩- មិនបានបញ្ជាក់ឈ្មោះអ្នកជួយ

*ក្នុងការសរសេរកិច្ចការគរុកោសល្យមួយ និស្សិតមានគ្រូណែនាំនិងអាចមានអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ។ ទាំងគ្រូណែនាំ ទាំងអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ និស្សិតតែងរំលឹកឈ្មោះនៅក្នុងសេចក្ដីថ្លែងអំណរគុណ។ ក៏ប៉ុន្ដែនៅក្នុងគម្រោងស្រាវជ្រាវធំៗ ដូចជាការសរសេរនិក្ខេបបទថ្នាក់បណ្ឌិតជាដើម បេក្ខជនបណ្ឌិតអាចទទួលបានគំនិតយោបល់ពីមិត្តភក្ដិ បុគ្គលិកបណ្ណាល័យ អ្នកបច្ចេកទេសមន្ទីរពិសោធន៍ សាស្ត្រាចារ្យអាជ្ញាធរមូលដ្ឋាន និងអ្នកផ្សេងទៀត ហើយនិងខ្លឹមសារនៃមតិយោបល់នោះបានក្លាយជាខ្លឹមសារនៃកិច្ចការស្រាវជ្រាវដូច្នេះ ឈ្មោះរបស់អ្នកទាំងនោះគួរបញ្ជាក់ក្នុងនិក្ខេបបទផង។*

## ២- វិធីសាស្ត្រចៀសវាងការលួចស្នាដៃនិពន្ធ

*ការស្រាវជ្រាវឯកសារដែលមានស្រាប់ដើម្បីឱ្យយល់ដឹងពីខ្លឹមសារនៃការស្រាវជ្រាវពីមុនៗ ការដកស្រង់គំនិត...ជាផ្នែកមួយដ៏សំខាន់នៃការសិក្សាស្រាវជ្រាវ។ ដូចបានបង្ហាញខាងលើ អ្នកស្រាវជ្រាវ ឬនិស្សិត ងាយក្លាយ ទៅអ្នកលួចស្នាដៃនិពន្ធ។ ខាងក្រោមនេះ ជាវិធីសាស្ត្រ មួយចំនួន ដើម្បីចៀសវាងការលួចស្នាដៃនិពន្ធ៖*

### ២. ១- កុំចម្លង

*ការចម្លងឃ្លាប្រយោគឬកថាខណ្ឌណាមួយមកដាក់ក្នុងអត្ថបទរបស់យើងជាការមិនល្អឡើយ ទោះអត្ថបទដើមនោះជារបស់យើងផ្ទាល់ក៏ដោយ។ និស្សិតនិងអ្នកស្រាវជ្រាវអាចដកស្រង់ឃ្លាល្បះខ្លីបាន ហើយដាក់ក្នុងអព្តន្តរសញ្ញា ដោយមានបញ្ជាក់ប្រភពឱ្យបានច្បាស់លាស់។ សម្រង់ឃ្លាប្រយោគដោយមានការបង្ហាញបែបនេះមិនមែនបានសេចក្ដីថាជាការលួចស្នាដៃនិពន្ធដោយឥតលាក់លៀមនោះទេ តែជារឿងកើតមានជាធម្មតាក្នុងការសិក្សាស្រាវជ្រាវ។*

### ២. ២- ប្រើពាក្យផ្ទាល់ខ្លួន

*ការប្រើពាក្យផ្ទាល់ខ្លួនគឺជាការប្រសើរ ណាស់ដើម្បីចៀសវាងការប្រើរបស់អ្នកដទៃ។ បានន័យថានិស្សិតនិងអ្នកស្រាវជ្រាវគួរចៀសវាងការសរសេរតាមឬចម្លងពីគេឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ការសរសេរតាមឬចម្លងដោយ បន្ថែមពាក្យដូចជា* ***របស់ នៅក្នុង*** *ជាការអនុគ្រោះ នៅក្នុងអត្ថបទស្រាវជ្រាវក្នុងកម្រិតតិចតួចប៉ុណ្ណោះ ដោយមានបញ្ជាក់ប្រភពក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រឬ/និងនៅក្នុងគន្ថនិទ្ទេស ក៏ប៉ុន្ដែវិធីសាស្ត្រដែលល្អបំផុតដូចបានបញ្ជាក់ខាងលើអីចឹងគឺ ប្រើពាក្យផ្ទាល់ខ្លួន។*

### ២. ៣- ចម្លងដើម្បីឱ្យច្បាស់សេចក្ដី

*ក្នុងករណីខ្លះ បើប្រើពាក្យផ្ទាល់ខ្លួន ហាក់ដូចជាមិនអស់សេចក្ដី និងសម្រេចចិត្តធ្វើការដកស្រង់ឃ្លាប្រយោគ។ ការដកស្រង់នេះ មិនមែនស្រង់របស់គេ យកមកដាក់ក្នុងអត្ថបទយើងទាល់តែរក*

ពាក្យផ្ទាល់ខ្លួន មិនឃើញនោះទេ ពាក្យឬឃ្លាប្រយោគមិនចាំបាច់ខ្វះ មិនគួរយកមកសរសេរឡើងវិញដោយដាក់ក្នុងអព្ភន្តរសញ្ញាទេ តែការពិភាក្សាអំពីគំនិតឬទស្សនៈនោះ គឺជាការប្រសើរបំផុត ហើយមានការបញ្ជាក់ប្រភពក្នុងកំណត់ចំណាំផ្នែកខាងក្រោមនៃទំព័រឬ/និងនៅក្នុងគន្ថនិទ្ទេស។

**២. ៤- កុំប្រើឡើងវិញនូវអត្ថបទផ្ទាល់ខ្លួន**

អ្នកស្រាវជ្រាវនិងនិស្សិតមិនត្រូវប្រើឡើងវិញនូវអត្ថបទដែលខ្លួនបាន ផ្សព្វផ្សាយម្តងរួច ហើយដោយពុំមានបញ្ជាក់ប្រភពនោះទេ ក្នុង នោះរាប់បញ្ចូលទាំងរូបភាព តារាងផងដែរ។ បើសិនជាបានយកមកប្រើ នោះមានឈ្មោះថា លួចស្នាដៃនិពន្ធខ្លួនឯង។

**២. ៥- សុំការអនុញ្ញាតិ**

ការប្រើប្រាស់តារាង រូបភាព ឬ ទិន្នន័យប្រភេទណាក៏ដោយដែលមិនទាន់បាន ផ្សព្វផ្សាយពីមុនមក ឬមួយទិន្នន័យ នោះ បានរៀបចំដោយអ្នកណាម្នាក់ដែលមិនមែន សហនិពន្ធ ត្រូវតែសុំការអនុញ្ញាតិសិន។

**សេចក្តីសន្និដ្ឋាន**

ការលួចស្នាដៃនិពន្ធជាអំពើមិនស្មោះត្រង់និងអយុត្តិធម៌។ កាលណាស្នាដៃនិពន្ធមួយត្រូវបានគេលួច ម្ចាស់ស្នាដៃនោះជាជនរងគ្រោះ រីអ្នកលួចស្នាដៃរបស់គេជាអ្នកសាងភាពអយុត្តិធម៌។ ប្រការនេះធ្វើឱ្យអ្នកលួចគេលែងចង់រៀនសិក្សាស្រាវជ្រាវអ្វីទាំងអស់។ ការលួចស្នាដៃនិពន្ធគឺជាការបញ្ឈប់នូវការរីកចម្រើននៃចំណេះដឹងនិងគំនិត។

# គន្ថនិទ្ទេស


- Vinayak Bairagi and Mousami V. Munoy(ed.): Research Methodology, A Practical and Scientific Approach
- https://dictionary.cambridge.org/dictionary/ english/plagiarism
- https://en.wikipedia.org/wiki/Guttenberg plagiarism_ scandal
- GuttenPlag Wiki/English | GuttenPlag Wiki | Fandom
- https://libguides.usc.edu/writingguide/literaturereview
- https://www.scanmyessay.com/plagiarism/types-of-plagiarism.php
- https://www.ox.ac.uk/students/academic/guidance/skills/plagiarism
- How to Avoid Plagiarism: 5 Easy Methods | Grammarly

# អត្ថិភាពនិយមតាមរយៈគតិលោករបស់ឧកញ៉ា សុត្តន្តប្រីជាឥន្ទ

*ដោយៈ ឯកឧត្តមបណ្ឌិត* **អ៊ុំ ម៉ុម**
*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្ដីផ្ដើម

*ប្រសិនបើគេអានគតិលោករបស់ឧកញ៉ា សុត្តន្តប្រីជាឥន្ទ ដោយយកចិត្តទុកដាក់តាំងពីភាគទីមួយ រហូតដល់ភាគទីដប់ គេអាចកត់សម្គាល់ឃើញថាស្នាដៃនេះសុទ្ធតែបានលើកយកបញ្ហានៃការរស់នៅរបស់មនុស្សមកឆ្លុះបញ្ចាំងទាំងបញ្ហាល្អក៏ដូចជាបញ្ហាខុសឆ្គងព្រមទាំងមានជាគតិនៅទីបញ្ចប់នៃរឿងនីមួយៗទុកសម្រាប់អ្នកអានត្រិះរិះពិចារណាថែមទៀតផង។ ផ្អែកលើសក្ខីកម្មទាំងនេះមានសំណួរមួយចោទសួរឡើងថាតើគតិលោកអាចចាត់ចូលទៅក្នុងកម្រងទស្សនវិជ្ជាបែបអត្ថិភាពនិយមបានដែរឬទេ?*

*ដើម្បីឆ្លើយតបបានទៅនឹងសំណួរនេះគេគប្បីសិក្សាស្វែងយល់ពីន័យពិតនៃពាក្យអត្ថិភាពនិយមតាមន័យទូទៅក៏ដូចជាតាមន័យបែបទស្សនវិជ្ជាហើយទន្ទឹមនឹងនេះគេគប្បីសិក្សាបន្តទៀតទៅលើគោលទ្រឹស្ដីអត្ថិភាពនិយមរបស់ទស្សនៈវិទូមួយចំនួនហើយលើកយកមកប្រៀបធៀបនឹងគោលទ្រឹស្ដី ដែលមានចែងក្នុងគតិលោក ទើបអាចឱ្យគេវាយតម្លៃបានជាចុងក្រោយថាស្នាដៃគតិលោកពិតជាស្ថិតក្នុងចរន្តទ្រឹស្ដីបែបអត្ថិភាពនិយមឬមួយយ៉ាងណានោះទៅបាន។*

## ១-និយមន័យស្ដីពីអត្ថិភាពនិយម

### ១.១. និយមន័យទូទៅ

- *តាមវចនានុក្រមសម្ដេចសង្ឃរាជជួនណាតត្រង់ទំព័រ១៥៩៩ បានពន្យល់ពាក្យ «អត្ថិភាព» ថាជាភាពនៃអ្វីៗដែលមាន, ជាភាវៈ ដែលមាន។ បើតាមនិយមន័យនេះភាវៈដែលសំខាន់ជាងគេក្នុងចំណោមភាវៈទាំងឡាយនៅលើផែនដីគឺមនុស្សនេះឯង។ ដូច្នេះអត្ថិភាពនិយម គឺការនិយមទៅលើអ្វីៗដែលមានពិតហើយសំខាន់បំផុតទៅលើការមានវត្តមានរបស់មនុស្សនៅលើផែនដីនេះឯង។*

### ១.២. និយមន័យតាមបែបទស្សនវិជ្ជា

និយាយរួម បើតាមន័យបែបទស្សនវិជ្ជា "អត្ថិភាពនិយម" ជាចរន្តទស្សនវិជ្ជាមួយបែបដែលពួកទស្សនវិទូបច្ចឹមប្រទេសបានបង្កើតឡើងដោយសង្កត់ធ្ងន់ទៅលើការស្ថិតនៅឬការមានវត្តមានរបស់មនុស្សព្រមទាំងស្ថានភាពការរស់នៅរបស់មនុស្សដែលជាភាវៈរស់សំខាន់ជាងគេនៅលើផែនដីយកមកធ្វើជាកម្មវត្ថុនៃការពិចារណា។ ទន្ទឹមនឹងនេះគេក៏សង្កេតឃើញថាបញ្ញត្តិស្តីពី «អត្ថិភាព» ត្រូវបានទស្សនវិទូទាំងនោះឲ្យនិយមន័យប្លែកៗគ្នាទៅតាមស្ថានភាពនៃការរស់នៅដែលមនុស្សបានជួបប្រទះ។ ប៉ុន្តែសំខាន់បំផុតកម្មវត្ថុជារួមរបស់អត្ថិភាពនិយម គឺបានយកអត្ថិភាពរបស់មនុស្សនិងការរស់នៅរបស់មនុស្សមកចុះបញ្ជាំងឬយកមកធ្វើជាប្រធានវិស័យហើយព្រមជាមួយនេះគេបានខិតខំស្វែងរកនូវមធ្យោបាយផ្សេងៗដើម្បីធ្វើឲ្យការរស់របស់មនុស្សបានប្រកបដោយសុភមង្គល។ មកដល់ត្រង់ចំណុចនេះ គេអាចនិយាយម្យ៉ាងទៀតថាអត្ថិភាពនិយមគឺជាទស្សនវិជ្ជាស្តីពីអត្ថិភាពរបស់មនុស្សនៅលើផែនដីហើយអត្ថិភាពនេះជាអត្ថិភាពប្រកបដោយបញ្ហាដែលគេគប្បីដោះស្រាយទៅតាមមធ្យោបាយណាមួយដែលសមស្របទៅនឹងគុណធម៌ហើយដែលមនុស្សមិនមែនជាអាទិទេពអាចទទួលយកបាន។

តទៅនេះគឺជាអត្ថន័យខ្លឹមសាររបស់ "អត្ថិភាពនិយម" ដែលទស្សនវិទូមួយចំនួនបានលើកឡើង៖

## ២. អត្ថិភាពនិយមរបស់ទស្សនវិទូមួយចំនួន

### ២.១ អត្ថិភាពនិយមរបស់លោកឃឺអ៊ែរឃឺហ្គាត (Kierkegaard) ១៨១៣-១៨៥៥

លោកត្រូវបានគេចាត់ទុកថា ជាអ្នកអត្ថិភាពនិយមបែបសាសនា។ ទស្សនវិជ្ជាសំខាន់របស់លោកគឺការស្គាល់ពីតម្លៃខ្លួនឯងរបស់មនុស្សម្នាក់ៗ ហើយធ្វើយ៉ាងណាខិតខំច្នៃជីវិតរស់នៅរបស់ខ្លួនឲ្យមានតម្លៃ។ លោកមិនចង់ឲ្យមនុស្សរស់នៅដូចជា

ស្មៅ[1]ឬរស់នៅដូចជាសត្វជាតុឡើយ។ ជីវិតរស់នៅដែលផ្សារភ្ជាប់នឹងសាសនាជាជីវិតដែលមានសច្ចភាពពិតប្រាកដ។លោកបានបន្តទៀតថាក្នុងជីវិតរស់នៅរបស់ខ្លួនមនុស្សត្រូវចេះខ្នើមបាបខ្លាចបាបនិងចេះលះបង់អំពើបាបបើលះបង់អំពើបាបបានហើយពេលស្លាប់ទៅគេនឹងបានទៅជួបអាទិទេព។

## ២.២. អត្ថិភាពនិយមរបស់នីតឆេ (Nietzsche) ១៨៤៤-១៩០០

នីតឆេត្រូវបានគេចាត់ទុកថាជាបិតារបស់ទស្សនវិទូអត្ថិភាពនិយមអទេវៈ។

លោកបានបង្កើតទស្សនវិជ្ជាអត្ថិភាពនិយមថ្មីមួយដែលគេឲ្យឈ្មោះថា «ការស្តាបនាតម្លៃជាថ្មី»។ ជាក់ស្តែងលោកបានបដិសេធអត្ថិភាពរបស់អាទិទេពតែទទួលស្គាល់អត្ថិភាពរបស់មនុស្ស ហើយអត្ថិភាពរបស់មនុស្សនៅលើលោកយើងនេះមានតម្លៃប្រសើរខ្ពង់ខ្ពស់ជាងតម្លៃឯទៀតដូចជាទ្រព្យសម្បត្តិមាសប្រាក់ដែលគ្រាន់តែជាតម្លៃបន្ទាប់បន្សំប៉ុណ្ណោះ។ លោកបានអំពាវនាវឲ្យមនុស្សទាំងអស់ជឿជាក់ទៅលើសមត្ថភាពរបស់ខ្លួនហើយចំពោះអ្នកក្រីក្រលំបាកវិញកុំឲ្យគិតតែពីរឿងទៅបន់ស្រន់អាទិទេព ប៉ុន្តែត្រូវគិតពីការខិតខំប្រឹងប្រែងប្រកបការងារដោយខ្លួនឯងទើបជីវិតបានសុខសប្បាយនិងមានភាពរុងរឿងទៅបាន។

## ២.៣. អត្ថិភាពនិយមរបស់ហៃដេហ្គឺ (Heidegger)១៨៨៩-១៩៧៦

ទស្សនវិជ្ជាអត្ថិភាពនិយមជាមូលដ្ឋានរបស់លោកត្រូវបានចុះបញ្ចាំងតាមរយៈស្នាដៃមួយស្តីពី«ភាវៈនិងពេលវេលា» ដោយក្នុងនោះលោកបានអំពាវនាវឲ្យមនុស្សលះបង់នូវជំនឿមិនសមហេតុផលហើយងាកមកខិតខំធ្វើការដើម្បីកសាងជីវិតរបស់ខ្លួននិងសង្គមឲ្យបានប្រសើរ។ លោកបានឲ្យតម្លៃខ្ពស់ទៅលើមនុស្សដោយគូសបញ្ជាក់ថាមនុស្សមិនមែនគ្រាន់តែជាអ្នករស់នៅក្នុងពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែជាអ្នកកសាងពិភពលោកថែមទៀត។ មនុស្សជាអ្នកបង្កើតពេលវេលាព្រោះពេលវេលាជាបច្ចុប្បន្នភាពរបស់មនុស្ស។ ដូច្នេះយើងរស់

១- ប្រហែលជាលោកចង់និយាយថាស្មៅត្រូវមនុស្សដើរជាន់រាល់ថ្ងៃប៉ុន្តែតាមទស្សនៈខ្មែរស្មៅអាចខ្ពស់ជាងភ្នំឬអាចយកទៅធ្វើជាឱសថបាន។

នៅបានសុខស្រួលហើយត្រូវកសាងជីវិតរបស់យើងឲ្យកាន់តែសុខស្រួលថែមទៀត។

### ២.៤. អត្ថិភាពនិយមរបស់ហ្សង់ប៉ូលសាត្រ (Jean Paul Sartre) ១៩០៥-១៩៨០

លោកក៏ជាទស្សនវិទូមួយរូបដែលបានលើកយកបញ្ហាមនុស្សមកធ្វើជាកម្មវត្ថុដើម្បីត្រិះរិះពិចារណាដូចទស្សនវិទូមុនៗដែរ។ ស្នូលនៃទស្សនវិជ្ជាអត្ថិភាពនិយមរបស់លោក គឺមានជីវិតមានអត្ថិភាព[2]ហើយអត្ថិភាពប្រសើរជាងខ្លឹម[3]។ ជាងនេះទៅទៀតលោកបានបញ្ជាក់បន្ថែមថាសេចក្ដីសុខរបស់មនុស្សបានមកពីមនុស្សខ្លួនឯងជាអ្នកស្វែងរកពុំមែនជាអំណោយរបស់អាទិទេពណាមួយឡើយ។ ក្នុងការរស់នៅមនុស្សត្រូវមានសេរីភាពគឺសេរីភាពនៃការធ្វើអ្វីមួយដោយមានលក្ខខណ្ឌ។ ទន្ទឹមនឹងមានសេរីភាពក្នុងការរស់នៅមនុស្សត្រូវមានការទទួលខុសត្រូវចំពោះ ទង្វើរបស់ខ្លួន។ លោកបានបញ្ចប់ទស្សនៈរបស់លោកត្រង់ចំណុច ថាមនុស្សកើតមកហើយត្រូវតែស្លាប់ទៅវិញ ជាធម្មតា។ ប៉ុន្តែនៅចន្លោះការកើតនិងការស្លាប់គឺជាពេលវេលាមួយដែលមនុស្សត្រូវខិតខំរៀបចំធាកជីវិតរបស់ខ្លួនខិតខំកសាងខ្លួនឲ្យមានតម្លៃ ប៉ុន្តែក៏កុំប្រាថ្នាអ្វីដែលខ្ពង់ខ្ពស់ហួសហេតុពេកពោលគឺគិតប្រាថ្នាត្រឹមតែមួយរស់សមរម្យបានហើយ។

ទាំងអស់នេះគឺជាអ្វីដែលទស្សនវិទូអត្ថិភាពនិយមបច្ចឹមប្រទេសបានលើកឡើង។ ឥឡូវនេះយើងត្រឡប់ទៅគិតពិចារណាពី"គតិលោក"វិញម្ដង តើមានគោលគំនិតអត្ថិភាពនិយមដែរឬទេ? ប៉ុន្តែមុននឹងពិចារណាទៅដល់រឿងនេះយើងគួរចោទសួរថាតើអ្វីទៅជាគតិលោក?

## ៣.អត្ថិភាពនិយមក្នុងគតិលោក

### ៣.១-តើគតិលោកជាអ្វី?

គតិលោកមកពីរពាក្យពីរម៉ាត់ គឺពាក្យ «គតិ» និងពាក្យ «លោក»

• បើតាមវចនានុក្រមសម្ដេចសង្ឃរាជជួនណាតត្រង់ទំព័រ១២៧ ពាក្យ «គតិ» ជានាមសព្ទ ដែលមានប្រភពចេញមកពីពាក្យបាលី-សំស្ក្រឹតមានន័យជាខ្មែរថា៖ ការទៅ; ការដើរទៅ; ដំណើរ; ផ្លូវគន្ទង; ទីកើតផ្សេងៗ; និស្ស័យ; អធ្យាស្រ័យ; ប្រាជ្ញាញាណ; ទីទៅ;

---

២- ប្រហាក់ប្រហែលគ្នានឹងទស្សនៈខ្មែរថា «ខ្លួនរស់របស់បាន» ដូច្នេះដែរ។

៣- អ្វីដែលខ្ពង់ខ្ពស់ដូចជាទ្រព្យសម្បត្តិស្តុកស្តម្ភ។

បរិសុទ្ធ។ រីឯពាក្យ «លោក» ក៏ជានាមស័ព្ទដែរ ជាពាក្យចេញមកពីភាសាបាលីសំស្ក្រឹត ប្រែមកជាភាសាខ្មែរ ដោយវចនានុក្រមសម្តេចសង្ឃរាជជួនណាត ត្រង់ទំព័រ១១២០ ថាជាសភាវៈធម៌ ដែលតែងតែវិនាសរឿយៗ គឺដែលកើតមានហើយបាត់ៗហើយមានឡើងវិញតាមកាលសម័យ។ បើនិយាយដោយរៀបរាប់គឺដីទឹកភ្លើងខ្យល់អាកាសនេះឯង។ បើតាមវចនានុក្រមដដែល "លោក" មានន័យថាជាមនុស្សសត្វទូទៅទាំងអស់។ ដូច្នេះបើតាមន័យក្នុងវចនានុក្រម «គតិលោក» គឺជាកន្លងផ្លូវជាដំណើរដើរទៅរបស់មនុស្សសត្វទូទៅ។

- ប៉ុន្តែបើតាមន័យពន្យល់ដោយផ្ទាល់របស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ប្រាប់កូនសិស្សរបស់លោកក្នុងភាគទី១ វិញ «គតិលោក» មានន័យថា «ដំណើរប្រព្រឹត្តទៅរបស់ជនក្នុងលោកិយ៍»។ តើដំណើរប្រព្រឹត្តទៅរបស់ជនក្នុងលោកីយ៍ជាដំណើរប្រវត្តិទៅបែបណា? យើងអាចឆ្លើយបានថា ជាដំណើប្រព្រឹត្តទៅរបស់ជនក្នុងលោកីយ៍ដែល តែងតែជាប់ទាក់ទងទៅនឹងសកម្មភាពប្រព្រឹត្តទៅចំពោះខ្លួនឯងផ្ទាល់និងសកម្មភាពជាមួយអ្នកដទៃ គេហៅម្យ៉ាងទៀតថា ជាទំនាក់ទំនងសង្គម។ ជាទូទៅទំនាក់ទំនងសង្គមអាចមានភាពល្អប្រសើរផងនិងគ្រោះថ្នាក់ផង។

### ៣.១.២. និយមន័យគតិលោកតាមបែបអក្សរសិល្ប៍

បើតាមន័យនេះគតិលោកគឺជាកម្រងស្នាដៃតែងនិពន្ធរបស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ដែលមានទាំងអស់១០ ភាគ ហើយគេអាចឲ្យតម្លៃគតិលោកប្រហែលគ្នាទៅនឹងសីលធម៌សម្រាប់ទូន្មានខ្លួនដ៏សំខាន់និងសម្បូរបែបរបស់ប្រជាជនខ្មែរគ្រប់កាលសម័យហើយដែលតិចឬច្រើនគេបានជ្រើសរើសយកទៅធ្វើជាទស្សនវិជ្ជាប្រតិបត្តិប្រចាំជីវិតដើម្បីជៀសវាងពីគ្រោះថ្នាក់ជាយថាហេតុផ្សេងៗក្នុងដំណើរជីវិត។ ស្នាដៃនេះមានលំនាំជាអក្សរសិល្ប៍បែបនិទានដែលក្នុងនោះមានតួអង្គជាមនុស្សដូចគ្នា ឬមានតួអង្គជាសត្វផងមនុស្សផងហើយមានទំនាក់ទំនងនឹងគ្នា។ ដោយឡែកនៅចុងបញ្ចប់នៃរឿងនីមួយៗក្នុងភាគតែងរំលេចឲ្យឃើញនូវគតិមួយចំនួនដែលអាចឲ្យសាធារណជនទទួលយកទៅធ្វើជាសីលធម៌សម្រាប់អប់រំទូន្មានខ្លួនក្នុងទំនាក់ទំនងសង្គមដើម្បីកុំឲ្យធ្លាក់ក្នុងឧបាយកលឬអំពើអកុសលផ្សេងៗ។

## ៣.២. តើគោលគំនិត «អត្ថិភាពនិយម» បែបណាខ្លះដែលទទួលបានពីគតិលោក?

មុននឹងឆ្លើយបាននូវសំណួរនេះ គេត្រូវចោទសួរថា តើលោកឧកញ៉ា សុត្តន្តប្រីជាឥន្ទ ជាអ្នកអត្ថិភាពនិយមមួយរូបដែរឬយ៉ាងណា?

បើគេប្រៀបធៀបទៅនឹងអ្វីដែលជានិយមន័យផ្តល់ឲ្យក៏ដូចជាគោលគំនិតអត្ថិភាពនិយមរបស់ទស្សនវិទូបច្ចឹមប្រទេសមួយចំនួនដូចជា នីតឆេ, ហៃដេហ្គឺ, ហ្សង់ប៉ូលសាត្រ គេអាចសន្និដ្ឋានបានថាលោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ក៏ជាអ្នកអត្ថិភាពនិយមក្នុងបូព៌ាប្រទេសមួយរូបដែរ ដែលបានឲ្យតម្លៃទៅលើជីវិតរបស់មនុស្សហើយបានប្រើប្រាស់នូវគោលគំនិតមួយចំនួនសម្រាប់ដោះស្រាយបញ្ហាមនុស្សទាក់ទងទៅនឹងអំពើប្រព្រឹត្តជាបុគ្គលផ្ទាល់ក៏ដូចជាអំពើប្រព្រឹត្តរបស់បុគ្គលជាមួយបុគ្គលផ្សេងទៀតតាមរូបភាពជាទំនាក់ទំនងសង្គម។

ចំពោះគំនិតជាគោលនៃអត្ថិភាពនិយមក្នុងគតិលោកវិញគឺមានច្រើនប៉ុន្តែនៅពេលនេះសូមលើកយកតែគោលគំនិតសំខាន់ពីរមកបង្ហាញជូនគឺចំណេះដឹងនិងបញ្ញារបស់មនុស្សហើយនិងលោកធម៌ទាំងប្រាំបីទាក់ទងទៅនឹងអំពើប្រព្រឹត្តក្នុងជីវិតរស់នៅជាមនុស្ស។

### ៣.២.១ ចំណេះដឹងនិងបញ្ញា

លោកបានបង្ហាញតាមរយៈស្នាដៃគតិលោកអំពីតួនាទីបំពេញឲ្យគ្នាទៅវិញទៅមករវាងចំណេះដឹងនិងបញ្ញាដែលបានលើកយកមកបង្ហាញទាក់ទងទៅនឹងជីវិតជាអ្នកប្រាជ្ញ។ លោកបានសង្កត់ធ្ងន់ថាអ្នកប្រាជ្ញទាំងឡាយបើមានតែចំណេះដឹងហើយខ្វះបញ្ញានោះក៏មិនញុំាំងដំណើរជីវិតជាអ្នកប្រាជ្ញរបស់ខ្លួនឲ្យទទួលបានជោគជ័យដែរ។ ជាក់ស្តែងដោយសារចំណេះដឹងនិងបញ្ញាធ្វើឲ្យធនញ្ជ័យជាអ្នកប្រាជ្ញស្រុកខ្មែរទទួលបានជោគជ័យនិងយកឈ្នះលើអ្នកប្រាជ្ញស្រុកលង្កាជាគូចោទប្រស្នាដោយគ្មានឧបសគ្គព្រមទាំងធ្វើឲ្យអ្នកប្រាជ្ញនោះផ្លាស់ប្តូរឥរិយាបថពីការចោទប្រស្នាក្នុងគម្ពីរសាសនាមកជាការចោទតាមបែបទូទៅវិញហើយអាចឆ្លើយបានត្រឹមត្រូវដោយយកបញ្ញាមកត្រិះរិះធ្វើឲ្យអ្នកប្រាជ្ញស្រុកលង្កាទទួលស្គាល់នូវបញ្ញាដ៏ខ្ពង់ខ្ពស់របស់អ្នកប្រាជ្ញស្រុកខ្មែរ ហើយឈប់សួរដេញដោលតទៅទៀត។ ចំពោះមនុស្សធម្មតាវិញលោកបានគូសបញ្ជាក់ថាបើខ្វះបញ្ញាងាយធ្វើឲ្យមនុស្សធ្លាក់ទៅក្នុងអំពើឡើង

បញ្ញោរ (ភាសាសាមញ្ញហៅថាឡើងជំនោរឬជោរ) អាស្រ័យដោយការបញ្ចើចបញ្ចើរបស់អ្នកដទៃឬមួយក៏ធ្លាក់ទៅក្នុងអំនួតអួតអាងរហូតដល់មើលស្រាលនិងមិនទទួលស្គាល់ការចេះរបស់អ្នកដទៃ។ ម្យ៉ាងទៀតដោយសារបញ្ញាធ្វើឲ្យមនុស្សអាចស្គាល់ពីខ្លួនឯងស្គាល់ពីអ្នកដទៃបានច្បាស់លាស់អាចយកឈ្នះលើអវិជ្ជាក៏ដូចជាអបិយជំនឿទាំងឡាយដែលស្ថិតនៅក្រៅវង្វង់នៃសមត្ថភាពរបស់មនុស្សដែលជាហេតុបច្ច័យធ្វើឲ្យមនុស្សងាយធ្លាក់ទៅក្នុងសភាវគតិ អត្តទត្តនិងចំណង់បាត់បង់អស់នូវឆន្ទៈប្រយុទ្ធបាត់បង់នូវមនសិការការទទួលខុសត្រូវក៏ដូចជាសេចក្តីព្យាយាមដើម្បីញ៉ាំងឲ្យដំណើរជីវិតប្រព្រឹត្តទៅបានល្អប្រសើរ។

### ៣.២.២. លោកធម៌ទាំងប្រាំបីប្រការ

ក្រៅពីចំណេះដឹងនិងបញ្ញាដែលអ្នកប្រាជ្ញគប្បីមានលោកបានបង្ហាញពីគោលគំនិតអត្ថិភាពនិយមមួយទៀតទាក់ទងទៅនឹងលោកធម៌ទាំងប្រាំបីប្រការដែលជាលោកធម៌ស្ថិតនៅជាប់ជិតស្និទ្ធជាមួយមនុស្សទាំងលោកធម៌ល្អទាំងលោកធម៌មិនល្អ។ លោកបានចាត់ទុកលោកធម៌ទាំងប្រាំបីនេះជាសភាវៈទ្រទ្រង់លោកមួយបែបដែលមានចលនាវិលវង់មិននៅទ្រឹងស្ងៀមមួយកន្លែងឡើយ។ ជាងនេះទៅទៀតលោកធម៌ទាំងនោះតែងមានដំណើរប្រព្រឹត្តទៅជាគូប្រសប់គ្នាក្នុងជីវភាពរស់នៅរបស់មនុស្សម្នាក់ៗ វិស័យដូចស្រមោលអន្ទោលតាមប្រាណមនុស្សដែលជារូបភាពពិតដូច្នេះដែរហើយដែលតម្រូវឱ្យមនុស្សម្នាក់ៗរំលឹកចងចាំក្នុងសតិរបស់ខ្លួនប្រយោជន៍ កុំឲ្យងាយធ្លាក់ទៅក្នុងអំពើឈ្លក់វង្វេងដោយប្រការណាមួយក្នុងអំពើប្រព្រឹត្តរបស់ខ្លួន។ តើលោកធម៌ទាំងប្រាំបីនោះមានអ្វីខ្លះ? តាមទស្សនៈផ្ទាល់របស់អ្នកនិពន្ធលោកធម៌ទាំងប្រាំបីនោះរួមមាន: លាភ១, អលាភ១, យស១, អយស១, សុខ១, ទុក្ខ១, សរសើរ១, និន្ទា១

<u>ដំណើរប្រព្រឹត្តជាគូប្រសព្វ</u>

- លាភ ⟷ អលាភ
- យស ⟷ អយស
- សុខ ⟷ ទុក្ខ
- សរសើរ ⟷ និន្ទា

លោកបានធ្វើការកត់សម្គាល់តទៅទៀតថាក្នុងចំណោមលោកធម៌ទាំងប្រាំបីនោះលោកធម៌បួន ខាងដើមគឺលាភយសសុខសរសើរជាលោកធម៌ដ៏គាប់ប្រសើរដែលបុគ្គលទូទៅស្រឡាញ់និងប្រាថ្នាចង់បាន

ហើយមានបំណងចង់ឲ្យលោកធម៌ទាំងបួននេះស្ថិតនៅជារៀងរហូតក្នុងជីវិតប្រចាំថ្ងៃរបស់គេរហូតដល់ពេលខ្លះដោយសារតែចិត្តស្រឡាញ់បែបនេះគេបានបណ្តោយខ្លួនឱ្យសភាវគតិញាំញីហើយប្រថុយប្រថានធ្វើសកម្មភាពផ្ទុយពីសីលធម៌ដោយមិនខ្លាចរអាចំពោះពាក្យរិះគន់ពេបជ្រាយពីសាធារណជន។ រីឯលោកធម៌បួន ទៀតនោះគឺអលាភអយសទុក្ខនិងនិន្ទាជាលោកធម៌ដែលមនុស្សមិនស្រឡាញ់ពេញចិត្តនិងយល់ថាជាធម៌មិនគាប់ប្រសើរឡើយជាធម៌អវិជ្ជមានអពមង្គលដែលមនុស្សភាគច្រើនពុំចង់ឲ្យកើតមានព្រមទាំងរកវិធីទប់ស្កាត់មិនឲ្យចូលមកយាយីចំពោះរូបកាយរបស់គេថែមទៀតផង។

សំណួរសួរថាតើលទ្ធផលដែលជាការពិតនៃអំពើប្រព្រឹត្តទាក់ទងទៅនឹងលោកធម៌ទាំងប្រាំបីនោះមានដូចម្តេចខ្លះ?

ចម្លើយស្ថិតនៅក្នុងការពន្យល់តាមរយៈរឿងនិទានទាំង១៤ ក្នុងភាគទី៣ ក៏ដូចជារឿងនិទានដទៃទៀតក្នុងគតិលោក។ ជាក់ស្តែងលោកបានស្វែងរកហេតុផលគួសបញ្ជាក់ឲ្យឃើញថាដរាបណាគេមិនអាចបញ្ឈប់ស្រមោលឱ្យផ្អាកធ្វើសកម្មភាពដើរតាមខ្លួនប្រាណទៅមករបស់មនុស្សដរាបនោះគេក៏មិនអាចបញ្ឈប់ឬទប់ស្កាត់លោកធម៌៤ទៀត គឺអលាភ, អយស, ទុក្ខនិងនិន្ទា ដែលជាគ្រឿងស្មៅហ្មង សម្រាប់ជីវិតកុំឲ្យធ្លាក់មកលើខ្លួនមនុស្សម្នាក់ៗបានដែរ ព្រោះជាហេតុបច្ច័យទៀងទាត់ជៀសមិនផុត។ លោកបានពន្យល់ហេតុផលតទៅទៀតថា បើមនុស្សម្នាក់ៗចង់បានតែលាភ អលាភមិនចង់បានបើចង់បានតែយស អយសមិនចង់បានបើចង់បានតែសុខទុក្ខមិនចង់បានបើចង់បានតែសរសើរហើយមិនចង់បាននូវពាក្យនិន្ទានោះបុគ្គលម្នាក់ៗអាចនឹងងាយធ្លាក់ទៅក្នុងអំពើឆោតពីរប្រការគឺ :

- ទីមួយ៖ អំពើឆោតព្រោះតែ «ការឃ្លាន» បួនយ៉ាងគឺឃ្លានអាហារឃ្លានមានឃ្លានស្រលាញ់ឃ្លានសរសើរ ដែលសុទ្ធតែជាសភាវគតិកើតមាននៅក្នុងអំពើប្រព្រឹត្តរបស់មនុស្ស។
- ទីពីរ៖ អំពើឆោតព្រោះ «មានះ» ធ្វើកិច្ចការអ្វីៗពុំបានស្វែងយល់ពីហេតុបច្ច័យច្បាស់លាស់ពុំបានពិចារណាមើលចុងមើលដើមឲ្យបានសព្វគ្រប់ពុំបានយកហេតុទៅប្រៀបធៀបនឹងផលឲ្យបានច្បាស់លាស់ ដូច

អ្វីដែលលោកបានរៀបរាប់ក្នុងរឿងនិទានទាំងដប់បួន[4] នៃគតិលោកភាគទីបីនោះឯង។

## សេចក្តីសន្និដ្ឋាន

«អត្ថិភាពនិយម» គឺជាគោលគំនិត ឬជាគោលទ្រឹស្តីដែលពួកទស្សនវិទូទាំងបស្ចិមប្រទេសទាំងបូព៌ាប្រទេសបានគិតគូរយកចិត្តទុកដាក់បង្កើតឡើងដោយលើកយកអ្វីជាបញ្ហាកើតមានពិតក្នុងអត្ថិភាពរបស់មនុស្សនៅលើផែនដីមកធ្វើជាប្រធានវិស័យក្នុងនោះមានទាំងបញ្ហាចោទនិងដោះស្រាយទៅលើរឿងរ៉ាវកើតមានក្នុងជីវិតរស់នៅរបស់មនុស្សដែលមានលក្ខណៈផ្ទុយទាំងស្រុងពីជីវិតរស់នៅបែបអមតៈរបស់ពួកអាទិទេព។ ដោយឡែកទៅក្នុងរឿងរ៉ាវអស់ទាំងនោះ មនុស្សសុទ្ធតែមានលទ្ធភាពនិងសមត្ថភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាដោយខ្លួនឯងស្របទៅនឹងអ្វីដែលលោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ អ្នកអត្ថិភាពនិយមរបស់ខ្មែរក្នុងសតវត្សទី២០ បានខិតខំបង្ហាញតាមរយៈស្នាដៃគតិលោកនេះស្រាប់ដើម្បីញ៉ាំងឲ្យមនុស្សខ្មែរចាកផុតពីអាកប្បកិរិយាខ្វះទំនុកចិត្តលើសមត្ថភាពខ្លួនឯងពឹងផ្អែកតែទៅលើអ្វីដែលជាកម្លាំងក្រៅខ្លួន បាត់បង់អស់នូវសេរីភាពអធិបតេយ្យភាព សិទ្ធិស្វ័យសម្រេច ការទទួលខុសត្រូវនិងតម្លៃជាមនុស្សហើយឃ្លាតកាន់តែឆ្ងាយពីតថភាពជាក់ស្តែងរបស់សង្គម៕

៤- រឿងទាំង ១៤ នេះរួមមាន ១រឿងធ្វើសក្ការៈបូជាទឹកបឹង ២រឿងធ្វើសក្ការៈបូជាដើមជង្ហោ, ៣រឿងធ្វើសក្ការៈបូជាគោស្នារ, ៤រឿងធ្វើសក្ការៈបូជាយាយទេព, ៥ រឿងភ្នំក្រោមខេត្តសៀមរាបនិងភ្នំត្រងិលស្រុកជើងព្រៃ, ៦រឿងតាហ៊ូឡាននិងកូនប្រសារពីរនាក់,៧រឿងចៅឆោតជិះក្របីទូលស្រូវមួយល្អី, ៨រឿងសឹងគោចង់បានកូនជង្ហោម្នាក់, ៩រឿងនាងអមរានិងអាចារ្យទាំងបួន, ១០រឿងក្រពើនិងអ្នករទេះ, ១១រឿងក្រពើផើមចង់ស៊ីថ្លើមស្វា, ១២រឿងក្អែកនិងសំពោច, ១៣រឿងចចកនិងរាជសីហ៍, ១៤រឿងព្រានព្រៃនិងសត្វសេក។

**គន្ថនិទ្ទេស**

- *ខ្វូតជីតាមូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោកភ្នំពេញ ឆ្នាំ ២០០៣។*
- *គឹមសែត ទស្សនវិជ្ជាអត្ថិភាពនិយមភ្នំពេញ ឆ្នាំ១៩៧៣*
- *ជួនណាតវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧*
- *សរសោរុនអធិប្បាយទស្សនវិជ្ជាភ្នំពេញឆ្នាំ១៩៧៤*
- *សន្ទនាជាមួយទស្សនវិជ្ជាការផ្សាយរបស់ផ្នែកទស្សនវិជ្ជានិងសង្គមវិទ្យាភ្នំពេញឆ្នាំ២០១០*
- *សុត្តន្តប្រីជាឥន្ទគតិលោកភាគទី១-១០ បោះពុម្ពឡើងវិញ ឆ្នាំ២០១៤*
- *គតិលោកអត្ថបទវិភាគថ្មីការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៤។*

# ស្វែងយល់ពីទស្សនវិជ្ជាអប់រំរបស់សាសនាព្រាហ្មណ៍

( Understanding of Educational Philosophy of Brahmanism )

ដោយៈ ឯកឧត្តមបណ្ឌិត **អ៊ឹំ ប៉ុម**
ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

*សាសនាព្រាហ្មណ៍ឬព្រហ្មញ្ញសាសនា ឬហៅម្យ៉ាងទៀត ជាសាសនារបស់ព្រះព្រហ្ម ត្រូវបាននាំចូលមកប្រទេសឥណ្ឌាដោយពួកអារ្យ៉ន (Aryan) ដែលកាលនោះមានទីតាំងក្នុងភូមិភាគកូកាស (caucase), ប៉ាមៀ (pamir) និងឆ្នេរសមុទ្រអារ៉ាល់ (Aral)។ នៅឆ្នាំ១៥០០ មុនគ.ស. ពួកអារ្យ៉នបានចូលមកលុកលុយប្រទេសក្នុងទ្វីបអឺរ៉ុបនិងភាគខាងជើងប្រទេសឥណ្ឌាហើយបានគ្រប់គ្រងលើពួកដ្រាវីឌីយាង (Dravidien) ដែលជាម្ចាស់ស្រុកនៃទឹកដីឥណ្ឌា។ ពួកព្រាហ្មណ៍ដែលបានចាត់ទុកខ្លួនគេថាជាបុត្ររបស់ព្រះព្រហ្មគឺជាអ្នកថែរក្សានិងផ្សព្វផ្សាយសាសនាព្រាហ្មណ៍របស់ពួកអារ្យ៉ន។ គេអាចចែកសាសនាព្រាហ្មណ៍ជាបីសម័យកាលធំៗរួមមានៈ*

*-សម័យវេទនិយមពីឆ្នាំ១៥០០មុនគ.ស. ដល់ ៥៥០មុនគ.ស.*

*-សម័យព្រាហ្មណ៍និយមពីឆ្នាំ៥៥០មុនគ.ស. ដល់សតវត្សរ៍ទី១០ នៃគ.ស. និង*

*-សម័យហិណ្ឌូនិយមពីសតវត្សរ៍ទី១០ នៃគ.ស. រហូតដល់បច្ចុប្បន្ន។*

*ខាងក្រោមនេះគឺជាទស្សនៈអប់រំដ៏សំខាន់ៗរបស់សាសនាព្រាហ្មណ៍ដែលអ្នករៀបរៀងអត្ថបទបានរកឃើញ។*

### *១-ទស្សនៈអប់រំស្តីពីអាទិទេព*

*ពួកព្រាហ្មណ៍មានទស្សនៈថា ពិភពលោកយើងនេះត្រូវបានបង្កើតឡើងដោយទេវៈ ឬអាទិទេព។ មនុស្សនៅលើផែនដីយើងនេះ និងភាវៈដទៃទៀតក៏ត្រូវបានបង្កើតឡើងដោយអាទិទេពដូចគ្នាដែរ។*

*ដូច្នេះមនុស្សចាំបាច់ត្រូវគោរពចំពោះអាទិទេព។ អាទិទេពសំខាន់ៗក្នុងសាសនា*

ព្រាហ្មណ៍មានបីអង្គគឺព្រះព្រហ្ម ព្រះវិស្ណុ ឬព្រះនារាយណ៍ និងព្រះសិវៈឬព្រះឥសូរ។

### ១.១.ព្រះព្រហ្ម

ព្រះព្រហ្មជាទេវៈមួយអង្គក្នុងចំណោមទេវៈទាំងបីរបស់សាសនាព្រាហ្មណ៍ ហើយមានតួនាទីសំខាន់ ជាងអាទិទេពដទៃទៀត។ ព្រះព្រហ្មជាអ្នកបង្កើតលោកឋានសំខាន់ទាំងពីរគឺ ឋានទេវលោក (នៅលើមេឃ) និងឋានមនុស្សលោក (នៅលើផែនដី)។ ដោយឡែកនៅឋានមនុស្សលោក ព្រះព្រហ្មបានបង្កើតទឹកនិងភ្លើង បន្ទាប់មកព្រះព្រហ្មបានបង្កើតឱ្យមានជាជ្រោះ ជ្រលងជងអូរ ទន្លេសមុទ្រ ព្រមទាំងភាវៈមានជីវិតដទៃទៀត ដូចជារុក្ខជាតិមនុស្សនិងសត្វនានា។ កាលដើមឡើយព្រះព្រហ្មជាអាទិទេពគ្មានរូបកាយគ្មានប្រពន្ធកូនដូចមនុស្សលោកឡើយ។ ប៉ុន្តែក្រោយមកដើម្បីឱ្យរឹតតែមានជំនឿនិងស្របទៅតាមកាលៈទេសៈក៏ដូចជាតម្រូវការរបស់ប្រជាជនពួកព្រាហ្មណ៍ បានកែប្រែទស្សនៈដើមដោយធ្វើឱ្យព្រះព្រហ្មមានរូបរាងពិតប្រាកដមានប្រពន្ធកូនដូចមនុស្សលោកយើងនេះដែរព្រមទាំងមានព្រះភ័ក្ត្រ (មុខបួន) អាចក្រឡេកមើលទៅទិសទាំងបួនក្នុងពេលជាមួយគ្នាបាន។

### ១.២.ព្រះវិស្ណុឬព្រះនារាយណ៍

ព្រះវិស្ណុឬព្រះនារាយណ៍ជាអាទិទេពទី២ ក្នុងសាសនាព្រាហ្មណ៍មានតួនាទីជាអ្នកគ្រប់គ្រងនិងថែរក្សាលោក (conservator God)។ ដើម្បីបំពេញនូវតួនាទីទាំងពីរនេះព្រះវិស្ណុតែងតែបែងភាគជាអវតារចុះមកឋានមនុស្សលោកហើយបំផ្លាញសភាវៈអាក្រក់ដែលបៀតបៀនបំផ្លិចបំផ្លាញសេចក្ដីសុខនិងរបៀបរៀបរយរបស់ពិភពលោកដែលព្រះព្រហ្មបានខិតខំបង្កើតឡើង។

### ១.៣.ព្រះសិវៈឬព្រះឥសូរ

ព្រះសិវៈឬព្រះឥសូរជាអាទិទេពមានតួនាទីបង្កើតលោកផងនិងបំផ្លាញលោកផង (creator and destructor God)។ ព្រះសិវៈជាតំណាងកម្លាំងបំផ្លិចបំផ្លាញឱ្យអន្តរាយទៅវិញដូចជាមរណភាពនិងការផ្ដាច់អាត្មនពីរូបកាយចាស់ដែលត្រូវវិនាសទៅដើម្បីបង្កើតនូវរូបកាយថ្មីទៀតដែលជាភាវៈមានជីវិត។ គេសាងរូបព្រះសិវៈឬព្រះឥសូរដោយសិវលិង្គឬ

លិង្គព្រះឥសូរ[1] ក្រៅពីនេះគេឃើញមានសាង រូបព្រះសិវៈឬព្រះឥសូរជាសិវលិង្គដាក់តម្កល់លើយោនីនាងឧមាដែលជានិមិត្តរូបនៃការបង្កើតលោករបស់ព្រះសីវៈ។

ក្រៅពីអាទិទេពទាំងបីអង្គ គេឃើញមានអាទិទេពបន្ទាប់បន្សំជាច្រើនទៀតដូចជាព្រះឥន្ទ្រជាទេវៈបង្កើតផ្គររន្ទះ។

ព្រះអគ្គីឬព្រះអគ្និជាទេវៈបង្កើតភ្លើងដែលជានិមិត្តរូបនៃអំពើល្អឬភាពស្មោះត្រង់របស់មនុស្ស។

ព្រះសូរ្យជាទេវៈបង្កើតកម្ដៅនិងពន្លឺជាថៅក្រមកាត់ក្ដីឱ្យមនុស្សលោក។ ព្រះចន្ទឬព្រះសោមៈជាទេវៈតំណាងសោភ័ណភាពព្រោះព្រះចន្ទមានរូបឆោមលោមពណ៌ល្អហើយជាអ្នកថែរក្សារុក្ខជាតិនៅលើផែនដី។

ព្រះយមៈជាទេវៈតំណាងសេចក្ដីស្លាប់ជាអ្នកធ្វើទោសមនុស្សដែលស្លាប់ទៅហើយដែលបានប្រព្រឹត្តអំពើអាក្រក់កាលពីពេលនៅរស់។ ព្រះវាយុជាទេវៈបង្កើតខ្យល់ជាទេវៈតំណាងកម្លាំងនិងល្បឿន។

## ២ ទស្សនៈស្ដីពីការគ្រប់គ្រងរដ្ឋនិងសង្គម

### ២.១ ទស្សនៈស្ដីពីវណ្ណៈ

សាសនាព្រាហ្មណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែករៀបចំសណ្ដាប់ធ្នាប់សង្គម ដឹកនាំសង្គមដោះស្រាយទំនាស់ក្នុងសង្គម។ ជាក់ស្ដែងដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ពួកព្រាហ្មណ៍បានបែងចែកមនុស្សក្នុងសង្គមជាវណ្ណៈបួនប្រភេទ វណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវេស្យ វណ្ណៈសូទ្រៈ។ ក្នុងចំណោមវណ្ណៈទាំងបួនវណ្ណៈសូទ្រៈជាវណ្ណៈទាបជាងគេបំផុត។ ជាវណ្ណៈបម្រើវណ្ណៈដទៃអស់មួយជីវិតនិងតកូនតចៅ។ ដោយឡែក ចំពោះកិច្ចការដឹកនាំរដ្ឋវិញត្រូវស្ថិតក្រោមវណ្ណៈព្រាហ្មណ៍និងវណ្ណៈក្សត្រដែលជាវណ្ណៈខ្ពស់បំផុតអាចទាក់ទងផ្ទាល់ជាមួយអាទិទេពនិងជាតំណាងអាទិទេព។ គួរកត់សម្គាល់ថាមនុស្សស្ថិតក្នុងវណ្ណៈនីមួយៗមិនអាចផ្លាស់ប្ដូរវណ្ណៈរបស់ខ្លួនបានឡើយ លើកលែងតែបុគ្គលនោះស្លាប់ទៅហើយបាន

---

១ -លិង្គព្រះឥសូរដើមឡើយជាតំណាងសសរភ្លើងកើតឡើងដោយឯកឯង។

ប្រព្រឹត្តអំពើល្អកាលពីពេលនៅរស់។ ដោយសារតែអាទិទេពមានតួនាទីបង្កើតលោក ពួកព្រាហ្មណ៍បានផ្តល់ឱ្យអាទិទេពនូវអំណាចមួយក្នុងការកំណត់ជោគវាសនារបស់មនុស្សម្នាក់ៗ ពោលគឺមនុស្សម្នាក់ៗមិនអាចគេច រើបម្រាស់ខ្លួនពីវណ្ណៈដើមឬធ្វើអ្វីឱ្យហួសពីការកំណត់របស់អាទិទេពបានឡើយ។ ជំនឿបែបនេះបានជះឥទ្ធិពលគ្របដណ្តប់ទៅលើនយោបាយដឹកនាំនិងគ្រប់គ្រងសង្គម ពោលគឺធ្វើឱ្យការដឹកនាំនិងគ្រប់គ្រងសង្គមប្រព្រឹត្តទៅដោយរលូននិងគ្មានឧបសគ្គឬការប្រឆាំងជំទាស់អ្វីឡើយ។

## ២.២.ច្បាប់មនុ (Manu′s law)

"ច្បាប់មនុ" ជាច្បាប់ពួកព្រាហ្មណ៍បង្កើតឡើងដើម្បីធ្វើឱ្យរដ្ឋមួយអាចដំណើរការទៅបាន។ ចំពោះមនុវិញគឺជានាមរបស់ព្រះព្រហ្មដែលជាអាទិទេពបង្កើតលោកនិងភាវៈទាំងឡាយក្នុងលោក។តាមទស្សនៈរបស់ពួកព្រាហ្មណ៍មនុជានាមរបស់បុរសជាបិតាដើមរបស់មនុស្សលោកស្ថិតក្នុងបឋមកប្បដែលជាពេលវេលាយូរអង្វែង ដើមដំបូងនៃអាយុកាលផែនដី។

ម្យ៉ាងទៀតដើម្បីដឹកនាំនិងគ្រប់គ្រងរដ្ឋមួយឱ្យបានល្អ រដ្ឋនោះត្រូវមានជាបឋមនូវអំណាច។ អំណាចនេះជាអំណាចដឹកនាំនិងគ្រប់គ្រងរដ្ឋឬរាជាណាចក្ររបស់ព្រះមហាក្សត្រតែមួយអង្គឯង (One king rule) ប៉ុណ្ណោះ។

ទន្ទឹមនឹងនេះក្នុងការដឹកនាំនិងគ្រប់គ្រងអាណាចក្រ ព្រះមហាក្សត្រត្រូវស្តាប់ឱវាទនិងការណែនាំរបស់សាមណព្រាហ្មណ៍ដែលជាអ្នកបួសនិងជាព្រះរាជគ្រូវិស័យដូចជាសិស្សគណត្រូវស្តាប់បង្គាប់គ្រូអាចារ្យ ក៏ដូចជាស្តាប់បង្គាប់ឪពុកម្តាយដូច្នេះដែរ។ ប្រការដែលសំខាន់ជាងនេះទៅទៀតរដ្ឋត្រូវដំណើរការក្រោមធាតុទាំងប្រាំពីរ (Seven Elements) ពោលគឺត្រូវមានព្រះមហាក្សត្រដែលតំណាងឱ្យអំណាចដឹកនាំនិងគ្រប់គ្រងរដ្ឋដូចបានបញ្ជាក់រួចមកហើយ បន្ទាប់មកត្រូវមានទីប្រឹក្សាដែលជាអ្នកផ្តល់យោបល់ចំពោះកិច្ចការធំៗ ជាអាយុជីវិតរបស់ជាតិ។ បន្ទាប់មកទៀតរដ្ឋត្រូវមានទីតាំងឈរជើងតំណាងបូរណភាពទឹកដីទាំងមូល។ ទន្ទឹមនឹងនេះរដ្ឋត្រូវមានធនធានរួមទាំងធនធានមនុស្សធនធានក្រោមដីលើដី...។ រដ្ឋត្រូវមាន"មាស"

ដែលជារូបិយវត្ថុដ៏សំខាន់ទ្រទ្រង់ខឿនពាណិជ្ជកម្មរបស់ប្រទេសត្រូវមានទាហានឬកងទ័ពខ្លាំងក្លាសម្រាប់ការពារខឿនឯករាជ្យអធិបតេយ្យនិងបូរណភាពដែនដី ហើយជាចុងក្រោយរដ្ឋត្រូវមានជាចាំបាច់នូវសម្ព័ន្ធមិត្តអន្តរជាតិធ្វើជាទីបង្អែកដ៏រឹងមាំនិងជួយឧបត្ថម្ភរដ្ឋនោះពីខាងក្រៅ។

## ៣ ទស្សនៈស្តីពីលទ្ធិ

ដូចបានបញ្ជាក់ពីខាងដើមរួចខ្លះមកហើយ ទន្ទឹមនឹងការបង្កើតអាទិទេព ព្រះព្រហ្មដែលជាអាទិទេពសំខាន់ទី១ពួកព្រាហ្មណ៍នូវបានបង្កើតឱ្យមានជាលទ្ធិចំនួនបួននៅអមជាមួយព្រះព្រហ្ម រួមមានលទ្ធិព្រហ្មចារ្យឬលទ្ធិព្រហ្មចារីយ៍ លទ្ធិអាត្ម័ន លទ្ធិឧបនិស័ទ និងលទ្ធិកម៌នសម្រាប់ធ្វើជាមូលដ្ឋានទ្រទង់ជំនឿប្រជាជនឥណ្ឌាចំពោះសាសនាព្រាហ្មណ៍ឱ្យកាន់តែមុតមាំថែមទៀត។

### ៣.១ លទ្ធិព្រហ្មចារ្យ (ព្រហ្មចារីយ៍)

ជាលទ្ធិសម្រាប់ប្រព្រឹត្តនិងធ្វើចិត្តឱ្យបានល្អដូចព្រះព្រហ្មទើបអាចតំណាងព្រះព្រហ្មបាន ហើយដើម្បីសម្រេចនូវគោលបំណងដ៏ល្អនេះបានពួកសាវ័កដើរតាមសាសនាព្រាហ្មណ៍ត្រូវហ៊ានលះបង់ប្រពន្ធកូនទ្រព្យសម្បត្តិនិងអ្វីៗទាំងអស់ទៅបួសជាសាមណព្រាហ្មណ៍ក្នុងព្រៃស្មសានឋានស្ងាត់។

### ៣.២ លទ្ធិអាត្ម័ន

ពាក្យអាត្ម័ន (Soul) មានឫសគល់មកពីពាក្យសំស្ក្រឹត "អាត្ម័ន" ត្រូវនឹងពាក្យបាលី អត្ត ឬ អាត្មា ប្រែជាខ្មែរថាខ្លួន ចិត្តឬព្រលឹងក៏បាន។ ពួកព្រាហ្មណ៍ចាត់ទុកអាត្ម័ន (ព្រលឹង) ជាធាតុពិសេសមួយ (Special Element) ដែលនៅជាប់នឹងព្រហ្ម័នជាឯកធាតុ។ អាត្ម័នអាចបែកចេញពីព្រហ្ម័នទៅកើតជាភាវៈផ្សេងទៀត (ភាវៈជាសត្វឬភាវៈជាមនុស្ស) ហើយជាចុងក្រោយ ត្រឡប់មកជួបនឹងព្រហ្ម័នវិញនៅពេលដែលអាត្ម័នអស់កម៌នមានន័យថា អស់កម្ម លែងវិលវល់ ក្នុងការកើតស្លាប់តទៅទៀត ហើយស្ថិតក្នុងបរមសុខឬមោក្សៈ[2]ជារៀងរហូត។ ម្យ៉ាងទៀតលទ្ធិអាត្ម័នជាលទ្ធិសម្រាប់អប់រំមនុស្សឱ្យចេះសម្គិតសម្គាំងអាត្ម័នរបស់

---

២ -បើតាមព្រះពុទ្ធសាសនាថានិព្វាន។

ខ្លួនឱ្យបានស្អាតផូរផង់ប្រាសចាកនូវអំពើអាក្រក់ដែលជាគ្រឿងមន្ទិលសៅហ្មងទាំងឡាយដើម្បីឆាប់បានវិលត្រឡប់ទៅជួបនឹងព្រហ្មន៍វិញ។ ដោយសារតែលទ្ធិអាត្ម័ននេះបានធ្វើឱ្យមនុស្សខិតខំដោយខ្លួនឯងប្រព្រឹត្តអំពើល្អដ៏មានប្រយោជន៍ចំពោះសង្គម ចៀសវាងអំពើអាក្រក់ពីព្រោះអំពើដែលខ្លួនប្រព្រឹត្តជាតំណាងអំពើរបស់ព្រះព្រហ្មដែលជាអំពើស្អាតបរិសុទ្ធបំផុត។

### ៣.៣ លទ្ធិឧបនិស័ទ

គោលសំខាន់របស់លទ្ធិឧបនិស័ទគឺការស្វែងរកវិធីធ្វើឱ្យអាត្ម័នឬព្រលឹងរបស់មនុស្សឆាប់បានវិលត្រឡប់ទៅជួបព្រហ្មន៍វិញ។ មានវិធីពីរយ៉ាងដែលធ្វើឱ្យអាត្ម័នឆាប់បានវិលត្រឡប់ទៅជួបអាត្ម័នវិញគឺវិធីតបៈនិងយោគៈ។

- តប : មានន័យបីយ៉ាងៈ

- នៅដើមសម័យវេទតបៈមានន័យថាព្យាយាមបន់ស្រន់ឱ្យអាទិទេពអាណិតអាសូរហើយពេញចិត្តនឹងជួយឱ្យសម្រេចអ្វីៗគ្រប់យ៉ាងទៅតាមបំណងប្រាថ្នា។

- នៅចុងសម័យវេទ តបៈមានន័យថាធ្វើឱ្យអាទិទេពក្តៅអន្ទះអន្ទែងទ្រាំពុំបានត្រូវតែចុះមកជួយមនុស្សលោក។

- នៅសម័យព្រាហ្មណ៍និយម តបៈមានន័យថា ធ្វើឱ្យខ្លួនក្តៅក្រហាយលំបាកវេទនាដោយប្រការផ្សេងៗ ដូចជាអង្គុយកណ្តាលថ្ងៃក្តៅ ដេកលើបន្លាឬដែកគោលស្រួចៗឬធ្វូន់ធ្ងរជាងនេះទៅទៀតគឺអត់អាហារជាដើម។

- **យោគ** : ដោយមើលឃើញវិធីនេះ ពុំសូវមានប្រសិទ្ធភាព ពិបាកនឹងប្រព្រឹត្តផងនោះ ពួកព្រាហ្មណ៍បានបង្កើតឱ្យមានវិធីមួយផ្សេងទៀតគឺវិធីយោគ : (Yoga Method)។ យោគៈជាវិធីអប់រំចិត្តឱ្យនឹងនស្អាតបរិសុទ្ធដឹងខុសត្រូវល្អអាក្រក់ ដោយផ្តើមចេញពីវិធីធ្វើលំហាត់ដកដង្ហើមចេញចូលឱ្យបានស្រួលឬហៅម្យ៉ាងទៀតថាវិធីធ្វើ "សមាធិ"[3]។

### ៣.៤ លទ្ធិកម៌ន(Karma doctrine)

---

[៣] –សមាធិក្នុងព្រះពុទ្ធសាសនាក៏មានដែរ។

"កម៌ន"ជាពាក្យសំស្ក្រឹតត្រូវនឹងពាក្យបាលីថាកម្មត្រូវនឹងពាក្យខ្មែរថា "អំពើ" រួមទាំងអំពើល្អឬអាក្រក់តាមផ្លូវកាយវាចានិងផ្លូវចិត្ត។

ក្នុងសាសនាព្រាហ្មណ៍[4] ពាក្យកម៌នមានន័យបីយ៉ាង ៖

*__ន័យទីមួយ__ កម៌នជាបុព្វហេតុនាំឱ្យមានការកើត ស្លាប់ដែលជាសកម្មភាពប្រព្រឹត្តទៅបន្តបន្ទាប់គ្នាហើយជាសកម្មភាពទៀងទាត់សម្រាប់ភាវៈរស់ទាំងអស់។

*__ន័យទីពីរ__ កម៌នជាទំនាក់ទំនងរវាងអំពើនិងផល។ ផលចេញមកពីអំពើដែលបានសាងហើយមិនចេះសាបសូន្យឡើយ។ កម៌នធ្វើឱ្យមនុស្សឬសត្វដែលជាភាវៈមានចលនាហើយត្រូវវិនាសឬស្លាប់ទៅវិញនៅទីបំផុត។ ពេលស្លាប់ទៅរូបកាយត្រូវបាត់បង់មែនប៉ុន្តែអាត្ម័នឬព្រលឹងមិនស្លាប់ឡើយ។ អាត្ម័នចេញពីរូបកាយដែលស្លាប់ទៅរករូបកាយថ្មីមួយទៀតតាមកម្រិតនៃអំពើឬកម្ម (កម៌ន) ដែលបានប្រព្រឹត្តកាលពីពេលនៅរស់។

*__ន័យទីបី__ កម៌នសម្គាល់ការផ្តល់ផលជារង្វាន់ឬ ក៏ជាទោសទណ្ឌកំណត់ដោយអាទិទេពហើយដែលបុគ្គលមិនអាចហាមឃាត់ឬប្រកែកប្រណាំងពុំព្រមទទួលយកនោះបានឡើយ វិស័យដូចជាព្រេងវាសនារបស់មនុស្សម្នាក់ៗនោះឯង។ សង្ខេបមកលទ្ធិព្រហ្ម័ន អាត្ម័ននិងកម៌នជាទ្រឹស្តីដ៏សំខាន់បីក្នុងចំណោមទ្រឹស្តីទាំងបួនរបស់សាសនាព្រាហ្មណ៍ ហើយលទ្ធិទាំងបីនេះជាចំណងចងភ្ជាប់មនុស្សទៅនឹងជំនឿយ៉ាងមុតមាំចំពោះអាទិទេព។

## សេចក្តីសន្និដ្ឋាន

រួមសេចក្តីមកសាសនាព្រាហ្មណ៍ជាសាសនាមួយដែលត្រូវបាននាំចូលមកប្រទេសឥណ្ឌាដោយពួកអារ្យ័ន តាំងពីឆ្នាំ១៥០០មុន គ.ស. ហើយសាសនានេះមានការវិវត្តនិងរីកចម្រើនទៅតាមដំណាក់កាលនីមួយៗរហូតមកដល់ពេលបច្ចុប្បន្នក្រោមរូបភាពជាសាសនាហិណ្ឌូព្រមជាមួយនេះសាសនាព្រាហ្មណ៍ក៏មានបង្កប់ទៅដោយទស្សនៈអប់រំ

---

[4] -ព្រេងវាសនាតាមសាសនាព្រាហ្មណ៍ គឺជាការកំណត់របស់អាទិទេពដែលមនុស្សត្រូវទទួលយក។

មួយចំនួនដូចបានរៀបរាប់រួចមកហើយ ក្នុងគោលលទ្ធិទាំងបួនរបស់សាសនានេះទាក់ទងទៅនឹងហេតុផលនៃការកើតស្លាប់របស់មនុស្ស វិធីអប់រំតាមផ្លូវកាយវាចាចិត្តឱ្យស្អាតបរិសុទ្ធដូចព្រះព្រហ្មព្រមទាំងគោលទ្រឹស្តីមួយចំនួនទៀតដែលមានសារប្រយោជន៍ចំពោះការគ្រប់គ្រងរដ្ឋនិងសង្គមក៏ដូចជាធ្វើឱ្យរដ្ឋមួយមានដំណើរប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពហើយទាំងអស់នេះគឺជាចំណងទាក់ទងយ៉ាងជិតស្និទ្ធរវាងសាសនានិងការប្រព្រឹត្តដើម្បីញុំាងឱ្យមនុស្សជាសាវ័កកាន់តែមានជំនឿជឿជាក់យ៉ាងមុតមាំទៅលើតួនាទីកំណត់សម្រេចដោតវាសនារបស់មនុស្សពីសំណាក់អាទិទេព។




គំនូសបំព្រួញស្តីពីលទ្ធិព្រហ្ម័នក្នុងសាសនាព្រាហ្មណ៍

## គន្ថនិទ្ទេស

១ សុខ គាង វិទ្យាសាស្ត្រនយោបាយ ភ្នំពេញ ឆ្នាំ២០០៥
២ សែម សូរ វប្បធម៌ខ្មែរតណ្ហា ភ្នំពេញ ឆ្នាំ១៩៧១
៣ សោម ងន ពន្លឺពុទ្ធសាសនា បោះពុម្ពលើកទី៣ ភ្នំពេញ ឆ្នាំ២០០៥។

# ស្វែងយល់ពីពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆ្នាំ២០២៤

*ដោយៈ* ***បណ្ឌិត ជា ចណ្ណី***
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

*នៅលើលើកយើងនេះ មិនថាប្រទេសណាជាប្រទេសណាទេ គឺគ្រប់ជាតិសាសន៍ទាំងអស់ តែងតែមានការប្រារព្ធពិធីចូលបុណ្យឆ្នាំថ្មីដែលជាប្រពៃណីរបស់ប្រជាជាតិរៀងៗខ្លួន គ្រាន់តែថាគេនិយមកំណត់ពេលវេលានៃការរៀបចំបុណ្យនេះផ្សេងៗគ្នា ដោយស្របទៅតាមជំនឿទំនៀមទម្លាប់និងប្រពៃណីរបស់គេប៉ុណ្ណោះ។*

*យ៉ាងណាមិញជនជាតិខ្មែរយើងក៏បានប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំតាំងពីបុរាណកាលជារៀងរាល់ឆ្នាំរហូតមក ដ្បិតពិធីបុណ្យនេះជាពិធីបុណ្យប្រពៃណីជាតិដ៏ធំមួយដែលដក់ជាប់ក្នុងចិត្ត និងជីវភាពប្រជាពលរដ្ឋខ្មែរតាំងពីយូរលង់មកហើយ ដែលពិធីបុណ្យនេះមិនមែនចេះតែប្រារព្ធធ្វើឡើងនៅពេលវេលាណាក៏បាននោះទេ គឺប្រវត្តិសាស្ត្រនិងកាលវេលានៃពិធីបុណ្យចូលឆ្នាំត្រូវបានបុព្វបុរសខ្មែរកំណត់យ៉ាងជាក់លាក់និងត្រឹមត្រូវ។*

## ១. ពេលវេលាចូលឆ្នាំខ្មែរ

*ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនាឆ្នាំនេះ គឺត្រូវនឹងថ្ងៃសៅរ៍ ៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធស័ករាជ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ១៤ ១៥ ១៦ ខែមេសា ឆ្នាំ២០២៤ (វេលាម៉ោង១០និង១៧នាទីយប់) ជាសរុបចំនួន៤ គឺថ្ងៃទី**១៣** ជាថ្ងៃ**មហាសង្ក្រាន្ត** ថ្ងៃទី**១៤ ១៥** ជាថ្ងៃ**វិរៈវ័នបត** និងថ្ងៃទី**១៦** ជាថ្ងៃ**ឡើងស័ក**។*

*កាលដើមឡើយប្រទេសខ្មែរប្រារព្ធធ្វើបុណ្យចូលឆ្នាំនៅក្នុងខែ**មិគសិរ** ព្រោះដូនតាខ្មែរកំណត់យកខែនេះជាខែដើមឆ្នាំ។ កាលពីសម័យដើម ឆ្នាំនីមួយៗចែកចេញជាបីរដូវគឺ **ហេមន្តរដូវ គិម្ហរដូវ** និង**វស្សានរដូវ**។ បុរាណាចារ្យលោកគិតថា **ហេមន្តរដូវ** ជារដូវត្រជាក់*

ត្រូវចាត់ទុកជា**ដើមឆ្នាំ** ដែលប្រៀបបាននឹងពេលព្រឹកផុតពីរាត្រី គឺជា**ដើមថ្ងៃ**។ **គិម្ហរដូវ**ជា**រដូវក្តៅ** ត្រូវចាត់ទុកជា**កណ្តាលឆ្នាំ** ប្រៀបដូចជា **ពេលថ្ងៃត្រង់**។ ចំណែកឯ **វស្សានរដូវ** ជារដូវដែលមេឃមីរងងឹតមានភ្លៀងផ្គរ ត្រូវចាត់ទុកជា**ចុងឆ្នាំ** ប្រៀបបាននឹង**ពេលយប់**។

បើតាមអត្ថបទរបស់លោក **ជីវ តាក្វាន់**[1] ខ្មែរយើងបានប្រារព្ធពិធីបុណ្យនៅក្នុងខែចេត្រ ដោយមានល្បែងចោលឈូងផង និងមានទទួលទឹកមន្តព្រះពុទ្ធពីគ្រប់ទីកន្លែងក្នុងអាណាចក្រ។ ក្រៅពីនេះ យើងមានសិលាចារឹកមួយនៅប្រាសាទព្រះខ័ន បញ្ជាក់ថា នៅថ្ងៃទី១៤ និង១៥កើត ខែចេត្រ ក៏មានប្រារព្ធពិធីបុណ្យមួយដូចបានរៀបរាប់ខាងលើ ហើយទោះបីជាឯកសារទាំងពីរពុំបានចែងថាពិធីបុណ្យខាងលើនេះមានឈ្មោះហៅថាបុណ្យចូលឆ្នាំក៏ដោយ ក៏តាមរយៈនៃឯកសារទាំងនេះ យើងអាចសន្និដ្ឋានបានថា តាំងពីបុរាណកាលមក ខ្មែរយើងតែងតែមានប្រារព្ធធ្វើពិធីបុណ្យយ៉ាងសំខាន់នៅក្នុងខែចេត្រ។

## ២. ប្រវត្តិនៃពិធីបុណ្យចូលឆ្នាំខ្មែរ

នៅដើមនៃភទ្ទកប្ប មាន**សេដ្ឋី**ម្នាក់មានបុត្រមួយឈ្មោះ**ធម្មបាលកុមារ** ជាអ្នកមានចំណេះវិជ្ជាដ៏វិសេស បានរៀនចេះចប់**គម្ពីរត្រៃវេទ** តាំងពីអាយុបាន**៧ឆ្នាំ**។ **សេដ្ឋីបិតា**បានសាងប្រាសាទឱ្យធម្មបាល នៅទៀបដើមជ្រៃមួយដើមធំ នៅឆ្នេរទន្លេ ដែលជាទីស្នាក់អាស្រ័យនៃបក្សីទាំងឡាយ។ ធម្មបាលចេះទាំងភាសាបក្សាបក្សីទាំងពួងផង ព្រមទាំងអាចធ្វើជាអាចារ្យសម្តែងមង្គលផ្សេងៗដល់មនុស្សទាំងពួងផង។

គ្រានោះ មនុស្សលោករមែងរាប់អាន**មហាព្រហ្ម** និង**កបិលមហាព្រហ្ម**១អង្គទៀត ដែលជាអ្នកសម្តែងមង្គលដល់មនុស្សទាំងពួង។ ពេលនោះកបិលមហាព្រហ្មជ្រាបព័ត៌មាននេះក៏ចុះមកល្បងបញ្ហានឹងធម្មបាលចំនួន៣ប្រស្នា ដោយសន្យាថា ប្រសិនបើធម្មបាលអាចដោះប្រស្នាបាន នោះកបិលមហាព្រហ្មនឹងកាត់ព្រះសិរសាទ្រង់ដើម្បីបូជាចំពោះធម្មបាល ប៉ុន្តែប្រសិនបើធម្មបាលចាញ់ កបិលមហាព្រហ្មនឹងកាត់ក្បាលធម្មបាលវិញ។

កាលនោះ ធម្មបាលបានសុំឱ្យពន្យារពេលចំនួន៧ថ្ងៃ ដើម្បីគិតប្រស្នានេះ។ លុះកន្លងទៅបាន៦ថ្ងៃហើយ ធម្មបាលនៅតែគិតមិនឃើញចម្លើយ និងដឹងខ្លួនថា ព្រឹកនេះច្បាស់ជានឹងត្រូវស្លាប់ដោយអាជ្ញា កបិលមហាព្រហ្មជាប្រាកដ ធម្មបាលក៏សម្រេចចិត្ត

[1] ជីវ តាក្វាន់ បានដល់ទឹកខ្មែរនាឆ្នាំ១២៩៧។

*វត់ទៅលាក់ខ្លួនពួនអាត្មាឱ្យស្ងាប់ដោយខ្លួនឯង វាប្រសើរជាង។ គិតហើយ ធម្មបាលបានចុះពីប្រាសាទទៅពួននៅក្រោមដើមត្នោតមួយគូ។ ចៃដន្យនៅលើដើមត្នោតនោះ មានសត្វឥន្ទ្រីញីឈ្មោល១គូ ធ្វើសំបុកអាស្រ័យនៅទីនោះ។ វេលាយប់ **សត្វឥន្ទ្រីញី** សួរសត្វ **ឥន្ទ្រីឈ្មោល** ថា ព្រឹកនេះយើងបានអាហារអ្វីធ្វើជាចំណី? ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងស៊ីសាច់ធម្មបាលកុមារ ដែលនឹងត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះធម្មបាលដោះប្រស្នានោះមិនរួចទេ។*

*ឥន្ទ្រីញីសួរថា ប្រស្នានោះដូចម្ដេច? ឥន្ទ្រីឈ្មោលឆ្លើយថា **វេលាព្រឹក** សិរីសួស្ដីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថា **នៅលើផ្ទៃមុខ** ហេតុនេះទើបមនុស្សទាំងឡាយត្រូវយកទឹកលប់មុខ។ ប្រស្នាទី២ ចោទថា **ថ្ងៃត្រង់** សិរីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថា **នៅលើទ្រូង** ហេតុនោះទើបមនុស្សត្រូវយកទឹកលាងទ្រូង។ ប្រស្នាទី៣ ចោទថា **វេលាល្ងាច** សិរីស្ថិតនៅត្រង់ណា? ត្រូវឆ្លើយថា **នៅនឹងជើង** ហេតុនោះហើយទើបមនុស្សទាំងឡាយត្រូវយកទឹកលាងជើង។ ធម្មបាលបានឮដូច្នេះ ក៏ត្រឡប់ទៅប្រាសាទវិញ។ លុះព្រឹកឡើងកបិលមហាព្រហ្ម ក៏មកសួរចម្លើយពីធម្មបាល។ ធម្មបាល ឆ្លើយដោះប្រស្នាតាមដែលបានឮ ហើយកបិល មហាព្រហ្មក៏ទទួលថាពិតជាត្រឹមត្រូវ និងព្រមចុះចាញ់ ដោយសុខចិត្តធ្វើតាមពាក្យសន្យារបស់ខ្លួន។*

*កបិលមហាព្រហ្ម ហៅទេពធីតាទាំង៧អង្គជាបុត្រីមកប្រាប់ថា ឥឡូវបិតាត្រូវកាត់ព្រះសិរសា ដើម្បីបូជាចំពោះធម្មបាល តែបើដាក់ក្បាលនោះលើផែនដី នោះនឹងកើតជាភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាស នឹងនាំឱ្យរាំងភ្លៀង បើចោលក្នុងមហាសមុទ្រ នោះទឹកនឹងរីងស្ងួតហួតអស់។ ដូច្នេះសូមឱ្យកូនទាំង៧អង្គ យកពានមកទទួលព្រះសិរសាបិតា។ ពោលរួច ព្រះអង្គក៏កាត់ព្រះសិរសាហុចទៅឱ្យព្រះនាងទុង្សា ជាបុត្រីច្បង។ ព្រះនាងទុង្សា ក៏បានយកពានមកទទួលព្រះសិរសាបិតា រួចហែប្រទក្សិណភ្នំព្រះសុមេរុចំនួន៦០នាទី ទើបយាងទៅប្រតិស្ឋានទុកក្នុងមណ្ឌលនៃគុហាគន្ធមាលី នាភ្នំកៃលាស និងបូជាគ្រឿង ទិព្វផ្សេងៗ។ កាលនោះព្រះ **វិស្សកម្មទេវបុត្រ** ក៏និមិត្ត**រោងទិព្វ**ធ្វើពី**កែវ៧ប្រការ** ឈ្មោះថា "**ភគវតីសភាសាលា**" ឱ្យជាទីប្រជុំនៃទេវតា។*

*លុះដល់គម្រប់១ឆ្នាំជាសង្ក្រាន្ត ទេពធីតាទាំង៧អង្គ ក៏ផ្លាស់វេនគ្នា មកអញ្ជើញព្រះសិរសាកបិល មហាព្រហ្ម ចេញមកហែប្រទក្សិណភ្នំព្រះសុមេរុជារៀងរាល់ៗឆ្នាំ រួចហើយយាងត្រឡប់ទៅស្ថានទេវលោកដើម្បីយកទៅតម្កល់វិញ។*

ដោយមាននិទានបែបនេះហើយ ទើបខ្មែរយើងមានជំនឿ ហើយបានរៀបចំជាពិធីបូជាទេវតាដែលត្រូវវេនដង្ហែក្បាលកបិលមហាព្រហ្ម និងត្រូវអភិបាលពិភពលោករៀងរាល់ឆ្នាំថ្មីចូលមកដល់ពុំដែលអាក់ខានឡើយ ហើយកិរិយាជិះជំនិះ គឺ**ពេលព្រឹកគង់ឈរលើខ្នង ពេលថ្ងៃគង់អង្គុយពាក់ចៀង ពេលយប់ផ្ទុំ(ដេក)បើកភ្នែក និងធ្មេញចភ្នែកពីកណ្តាលអាធ្រាត្រ**។

១. បើសង្ក្រានចំ**ថ្ងៃអាទិត្យ** ត្រូវវេននាង**ទុង្សាទេវី** សម្លៀកបំពាក់ពណ៌ក្រហម សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទម្ពរ(ល្វា) ព្រហស្តស្តាំកាន់កងចក្រ ព្រះហស្តឆ្វេងកាន់ស័ង្ខ និងមានពាហនៈគ្រុឌ។

២. បើសង្ក្រានត្រូវចំ**ថ្ងៃច័ន្ទ** ត្រូវវេននាង**គោរាគៈទេវី** សម្លៀកបំពាក់ពណ៌លឿង សៀតផ្កាអង្គាបុស្ប គ្រឿងប្រដាប់មុក្តា (គជ់ខ្យង) ភក្សាហារប្រេង ព្រហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ឈើច្រត់ និងមានពាហនៈព្យគ្ឃ(ខ្លា)។

៣. បើសង្ក្រានត្រូវចំថ្ងៃ**អង្គារ** ត្រូវវេននាង**រាក្សសាទេវី** សម្លៀកបំពាក់ខ្មៅ សៀតផ្កាឈូក គ្រឿងប្រដាប់មោរា ភក្សាហារលោហិត ព្រហស្តស្តាំកាន់ត្រីសូល៍ ព្រះហស្តឆ្វេងកាន់ធ្នូនិងពាហនៈអស្សតរៈ។

៤. បើសង្ក្រានត្រូវចំ**ថ្ងៃពុធ** ត្រូវវេននាង**មណ្ឌាទេវី** សម្លៀកបំពាក់ផ្ទៃមេឃ សៀតផ្កាចំប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះ ព្រហស្តស្តាំកាន់ម្ជុល ឆ្វេងកាន់ឈើច្រត់ និងមានពាហនៈលា។

៥. បើសង្ក្រានត្រូវចំ**ថ្ងៃព្រហស្បត៍** ត្រូវវេននាង**កិរិណីទេវី** សម្លៀកបំពាក់បៃតង សៀត ផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារ សណ្តែក ល្ង ព្រហស្តស្តាំកាន់កង្វេរ ព្រះហស្តឆ្វេងកាន់ធ្នូ និងមានពាហនៈដំរី។

៦. បើសង្ក្រានត្រូវចំ**ថ្ងៃសុក្រ** ត្រូវវេននាង**កិមិរាទេវី** សម្លៀកបំពាក់ស សៀតផ្កាចង្កុលណី(ប្រភេទពួកឈូកមានច្រើនស្រទាប់) គ្រឿងប្រដាប់បុស្បរាគ័ម(ថ្មើមថ្ម) ភក្សាហារចេកណាំវ៉ា ព្រហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ពិណ និងមានពាហនៈក្របី។

៧. បើសង្ក្រានត្រូវចំ**ថ្ងៃសៅរ៍ ត្រូវវេន**នាងម**ហោទរាទេវី** សម្លៀកបំពាក់ខៀវចាស់ សៀត ផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ ព្រហស្តស្តាំកាន់ចក្រ ព្រះហស្តឆ្វេងកាន់ត្រីសូល៍ និងមានពាហនៈក្ងោក។

## ៣. ទំនៀមចូលឆ្នាំ

ជាទូទៅទំនៀមពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន**៣ថ្ងៃ**។ **ថ្ងៃដំបូងជាថ្ងៃមហាសង្ក្រាន្ត ថ្ងៃទី២**ជាថ្ងៃ**វិរៈវ័នបត** និង**ថ្ងៃទី៣** ជា**ថ្ងៃឡើងស័ក**។ រីឯការកំណត់ខែ ថ្ងៃ ម៉ោង នាទី ដែលឆ្នាំចាស់ត្រូវផុតកំណត់ ហើយទេព្តាឆ្នាំថ្មីត្រូវចុះមកទទួលតំណែងពីទេព្តាឆ្នាំចាស់នោះ គេអាចដឹងបានដោយប្រើក្បួនហោរាសាស្ត្របុរាណ គឺក្បួនមហាសង្ក្រាន្ត ហើយនៅសល់តែប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរនឹងចូលមកដល់។ តាមមហាសង្ក្រាន្តឆ្នាំនេះ ចូលឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨ គ.ស.២០២៤។ ដោយឡែកបុណ្យចូលឆ្នាំឆ្នាំនេះប្រព្រឹត្តទៅរយៈពេល**បួនថ្ងៃ** គឺនៅថ្ងៃ ៥កើត ៦កើត ៧កើត និង៨កើត ខែចេត្រ ត្រូវនឹង**ថ្ងៃសៅរ៍ ទី១៣** ខែមេសា វេលាម៉ោង២២និង១៧នាទី (**ថ្ងៃមហាសង្ក្រាន**) **អាទិត្យទី១៤** និង**ចន្ទទី១៥** (**ថ្ងៃវីរវ័នបត**) និង**អង្គារ៍ទី១៦** (**ថ្ងៃវីរៈឡើងស័ក**)។

. ពេលមុនចូលឆ្នាំ គេនាំគ្នាប្រុងប្រៀបរកស្បៀងអាហារ សំអាតផ្ទះសម្បែង រែកទឹកដាក់ពាង រកឧសទុក និងកាត់សំលៀកបំពាក់ថ្មីៗជាដើម។

. ថ្ងៃចូលឆ្នាំមកដល់ គេរៀបគ្រឿងសក្ការៈបូជាសម្រាប់ទទួលទេវតាឆ្នាំថ្មីមានៈ បាយសី១គូ ស្លាធម៌១គូ ធូប៥ ទៀន៥ ទឹកអប់ ១គូ ផ្កាភ្ញី លាជ ទឹក១ផ្តិល ភេសជ្ជៈ នំចំណីនិងផ្លែឈើច្រើនមុខៗចំណែកផ្ទះសម្បែង គេតុបតែងរំលេចដោយអំពូលអគ្គិសនីខ្សែតូចៗចម្រុះពណ៌ ឬចង្កៀងគោមគ្រប់ពណ៌សម្រាប់ទទួលទេព្តាថ្មី។

. លុះដល់វេលាកំណត់ ទេព្តាឆ្នាំថ្មីយាងមក គេនាំកូនចៅអង្គុយជុំគ្នា អង្គុយនៅកន្ទែងរៀបគ្រឿងសក្ការៈនោះ ហើយអុជទៀន ធូប បាញ់ទឹកអប់ បន់ស្រន់ សុំសេចក្តីសុខចម្រើន គ្រប់ប្រការ ពីទេព្តាឆ្នាំថ្មី។ ចំពោះគ្រឿងសក្ការៈ និងក្រយាស្ងោយដាក់ថ្វាយទេព្តានោះ គេនិយមតម្រូវតាមចិត្តទេវតាដែលនឹងចុះក្នុងឆ្នាំនីមួយៗ។ ឧទាហរណ៍ៈ ឆ្នាំនេះទេវតាដែលត្រូវចុះមកនោះ គឺថ្ងៃសៅរ៍ ត្រូវចំព្រះនាងមណ្ឌាទេវី សោយសាច់ទ្រាយ គេអាចដាក់សាច់ទ្រាយថ្វាយ (តែបើមិនមានយើងអាចផ្លាយជផ្លាយផ្សេងៗបាន)។

. ពិធីទាំង៣ថ្ងៃ នៃថ្ងៃចូលឆ្នាំ

**ថ្ងៃទី១**ៈ គេយកចង្ហាន់ទៅប្រគេនភិក្ខុទាំងឡាយនៅតាមវត្តអារាម។ ពេលល្ងាច គេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយដែលមាននៅជុំវិញព្រះវិហារ ឬនៅជុំវិញដើមពោធិ៍ណាមួយនៅក្នុងវត្តនោះៗ នៅពេលព្រលប់ គេប្រគេនភេសជ្ជៈដល់ភិក្ខុ និមន្តភិក្ខុសូត្រចម្រើនព្រះបរិត្ត និងសំដែងធម៌ទេសនា។

**ថ្ងៃទី២៖** កូនចៅជូនសម្លៀកបំពាក់ នំចំណី លុយកាក់ ដល់អ្នកមានគុណ មានឪពុកម្តាយ ជីដូនជីតា ជាដើម។ ជូនកាលគេធ្វើទានដល់មនុស្សបម្រើ ឬអ្នកក្រីក្រទៀតផង។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចចូឡាមនីចេតិយ ហើយនិមន្តភិក្ខុបង្សុកូលចេតិយ បញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានចែកឋានទៅ។

**ថ្ងៃទី៣៖** ពេលព្រឹកនិមន្តភិក្ខុសូត្រធ្វងភ្នំខ្សាច់។ ពេលល្ងាច និមន្តភិក្ខុស្រង់ទឹក និងស្រង់ព្រះពុទ្ធរូប (តាមការនិយមនៃស្រុកខ្លះ)។ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គេនាំគ្នាលេងល្បែងប្រជាប្រិយកម្សាន្តសប្បាយជាច្រើន ដូចជាលេង បោះអង្គញ់ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ដណ្តើមស្លឹកឈើ ស្តេចចង់ ឱបត្រឡាច ចាប់កូនខ្លែង ជាដើម និង មានរបាំត្រុដិ (ច្រើនមាននៅខេត្តបាត់ដំបង សៀមរាប) ជាពិសេសទៀតគឺរាំវង់អាស្រ័យទៅតាមការនិយមចូលចិត្តរបស់បុគ្គលម្នាក់ៗ ហើយអ្នកខ្លះក៏និយមនាំគ្នាដើរកម្សាន្តតាមរមណីយដ្ឋាន អ្នកខ្លះនិយមធ្វើបុណ្យទានតាមវត្តអារាមនានា។

## ៤.អត្ថន័យនៃពិធីបុណ្យចូលឆ្នាំ

ឆ្នាំចាស់បានកន្លងផុតទៅ ឆ្នាំថ្មីបានឈានចូលមកដល់ ជាគតិឱ្យយើងពិចារណានូវធម៌សង្វេកថា ពេលវេលាចេះតែកន្លងទៅជារៀងរាល់ឆ្នាំ ហើយអាយុកាលរបស់យើងគ្រប់គ្នាក៏អស់ទៅតាមឆ្នាំចាស់ដែលបានរសាត់បាត់ទៅ ដូច្នេះយើងមិនគួរប្រមាថ មិនគួរប្រព្រឹត្តិអាក្រក់ មិនគួរឈ្លោះទាស់ទែងខ្វែងគំនិតគ្នា មិនគួរប្រកួតប្រជែងគ្នា មិនគួរលោភលន់ មិនគួរកាប់សម្លាប់គ្នា ឬដណ្តើមគ្នារស់នោះទេ គួរតែយើងចេះចែកគ្នារស់ លះបង់នូវ ទង្វើអាក្រក់ ប្រព្រឹត្តិតែទង្វើល្អ បណ្តុះនូវព្រហ្មវិហារធម៌ សាមគ្គីធម៌ នៅក្នុងដួងចិត្តប្រកបដោយក្តីមេត្តា ករុណា កតញ្ញូតា ឧបត្ថម្ភដល់ជីដូនជីតាមាតាបិតា ក៏ដូចជាព្រះសង្ឃ និងចែករំលែកទានដល់ជនដែលមានការខ្វះខាត ទីទាល់ក្រ ដែលជាទុរគតជន ក៏ដូចជាអ្នកកំព្រីកំព្រាគ្មានទីពឹងប្រកបដោយក្តីអាណិតអាសូរ។

ដើម្បីអបអរសាទរចំពោះមរតកកេរដំណែលរបស់បុព្វការីជន ក៏ដូចជាឱ្យចេះថែរក្សាការពារនូវប្រពៃណី ទំនៀមទម្លាប់នៃពិធីបុណ្យចូលឆ្នាំ របាំនិងល្បែងប្រជាប្រិយ កុំឱ្យបាត់បង់ដោយប្រការផ្សេងៗ។

ដើម្បីបង្ហាញពីភាពសប្បាយរីករាយរបស់ប្រជាជនខ្មែរ បន្ទាប់ពីប្រមូលផលរួច ក៏

ដូចជាអបអរសាទរចំពោះធម្មជាតិ និងផលិតផលកសិកម្មដោយបណ្តុះនូវក្តីសង្ឃឹមនាឆ្នាំបន្តៗទៀត។

ដើម្បីឧទ្ទិសបុណ្យកុសលដល់បុព្វការីជន មាតាបិតា ជីដូនជីតា ញាតកាសាច់សាលោហិត មិត្តសម្លាញ់ និងសព្វសត្វទាំងអស់ដែលបានចែកឋានទៅ និងដើម្បីបានសេចក្តីសុខចម្រើនសម្រាប់ខ្លួនឯង សម្រាប់ក្រុមគ្រួសារនិងសង្គមជាតិ ទាំងបច្ចុប្បន្នកាលនិងអនាគតកាល។

## ៥. ស្វែងយល់ពីល្បែងប្រជាប្រិយមួយចំនួន និងរបាំត្រុដិក្នុងទំនៀមចូលឆ្នាំ

ល្បែងប្រជាប្រិយជាទូទៅគេច្រើនតែលេងនៅក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចូលឆ្នាំខ្មែរ គឺជាពិធីបុណ្យចូលឆ្នាំថ្មីរបស់កម្ពុជា ដែលកំណត់តាមប្រតិទិនពុទ្ធសាសនា តាមដំណើរគោចររបស់ព្រះចន្ទ ដែលរាប់តាមរង្វាស់នៃឆ្នាំចន្ទគតិ នៅក្នុងវប្បធម៌ខ្មែរ។ ពិធីបុណ្យនេះត្រូវបានគេហៅថា **ពិធីបុណ្យគិម្ហៈរដូវ** "បុណ្យរដូវក្តៅ" នៃវិស្សមកាលតូច ដែលបានមកពីអរិយធម៌នៃវប្បធម៌ប្រទេសឥណ្ឌា ដែលហៅថ្ងៃចូលឆ្នាំថ្មីថា "**សង្ក្រាន្ត** " (Sangkranta)។ ពាក្យ **សង្ក្រាន្ត** ជាភាសាដើមនៃពាក្យ (សំស្ក្រឹត) ដែលប្រជាជនខ្មែរឱ្យនិយមន័យថា (សង្ក្រាន្តខ្មែរ)។ សង្ក្រាន្ត គឺជាថ្ងៃចូលឆ្នាំថ្មី ដែលប្រារព្ធឡើងរៀងរាល់ថ្ងៃទី១៣ឬថ្ងៃទី១៤ ខែមេសា ជារៀងរាល់ឆ្នាំ ដែលប្រជាពលរដ្ឋខ្មែរគ្រប់រូបឈប់សម្រាកពីការងារដើម្បីចូលរួមអបអរថ្ងៃចូលឆ្នាំថ្មី។ ជាទូទៅមុនថ្ងៃចូលឆ្នាំខ្មែរមកដល់ប្រជាជនខ្មែរគ្រប់រូបនឹងធ្វើដំណើរនិវត្តពីគ្រប់ទិសទីមកស្រុកកំណើតរបស់ខ្លួនវិញ ដើម្បីជួបជុំក្រុមគ្រួសាររៀងរាល់មួយឆ្នាំម្តង។ នៅមុនថ្ងៃចូលឆ្នាំ ប្រជាជនខ្មែរតែងតែរៀបចំសម្អាតនិងតុបតែងលម្អផ្ទះសម្បែង ដោយផ្ទះខ្លះក៏ព្យួរគោមផ្កាយ ផ្ទះខ្លះក៏ដាក់ភ្លើងពណ៌ ដែលគេមានជំនឿថា ពន្លឺគោមផ្កាយនិងភ្លើងពណ៌ទាំងនោះ នឹងនាំមកនូវសិរីសួស្តី លាភសំណាង និងភាពមានបានផងដែរ។ ក្រៅពីនេះទៀតមានលេងល្បែងកម្សាន្តប្រជាប្រិយខ្មែរនៅតាមភូមិស្រុករបស់ពួកគេផងដែរ ដូចជា៖ *បោះឈូង បោះអង្គុញ លាក់កន្សែង ទាញព្រ័ត្រ ស្តេចចង់ រាំយក្ខ ដណ្តើមស្លឹកឈើ ក្លែងចាប់កូនមាន់* ជាដើម ហើយក្រៅពីល្បែងកម្សាន្តទាំងនេះ ក៏នៅមានលេងល្បែងកម្សាន្តមួយប្រភេទទៀតហៅថា ពិធីលេងជះទឹក តាមទីលំនៅនីមួយៗ តែងមានធុងទឹកនៅពីមុខផ្ទះរបស់ពួកគេ ដើម្បីជះទឹកទៅលើអ្នកដំណើរ ដែលពួកគេមានជំនឿថា ភាពមិនល្អដែលតោងទាមយើងគ្រប់គ្នាតាំងពីឆ្នាំចាស់និងត្រូវលាងសម្អាតជម្រះចេញក្នុងឆ្នាំថ្មីនេះ

ដែលជាទំនៀមមួយមិនអាចចោលបានទូវក្នុង វប្បធម៌ប្រពៃណីខ្មែរ ដែលទាក់ទងនឹងកិច្ច ពិធីស្រង់ព្រះពុទ្ធអង្គ និងស្រង់ព្រះរស់ដែល ជាឪពុកម្ដាយ ជីដូនជីតារបស់យើងផងដែរ។

ល្បែងប្រជាប្រិយខ្មែរ បានកកើតឡើង តាមរយៈជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋខ្មែរ តាមសម័យកាលនីមួយៗ ពោលគឺមានប្រភព ចេញពីកម្លាំងពលកម្ម ការរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋ និងជាការចេះចាំតៗគ្នា។ ដោយនៅរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ ប្រទេសកម្ពុជានឹងរៀបចំនូវពិធីបុណ្យចូលឆ្នាំ ថ្មី ប្រពៃណីជាតិ ខ្មែរ ដែលក្នុងនោះប្រមុខរាជ រដ្ឋាភិបាលកម្ពុជា បានជំរុញលើកទឹកចិត្តឱ្យ គ្រប់បណ្ដាខេត្ត-រាជធានី ដឹកនាំពលរដ្ឋ ឱ្យ លេងល្បែងប្រជាប្រិយខ្មែរ ដើម្បីការពារ ថែ រក្សា វប្បធម៌ប្រពៃណីដូនតាខ្មែរ។

. **ល្បែងឈូង** ជាល្បែងម្យ៉ាងរបស់ មនុស្សប្រុសស្រីទូទាំងកម្ពុជរដ្ឋនិយមលេង ហើយគេតែងលេងនៅពេលយប់ ខែភ្ជី ក្នុងរដូវ ចូលឆ្នាំថ្មី (ខែចេត្រ ពិសាខ)។ គេចែកគ្នាជា ២ ក្រុម គឺប្រុស១ក្រុម និងស្រី១ក្រុម។ ក្នុង១ក្រុមៗ មានគ្នាចំនួនពី១០នាក់ ឬ២០នាក់ឡើងទៅ ដោយឈរត្រៀមជា២ជួរ ទល់មុខគ្នា ឃ្លាតពី គ្នាប្រមាណជា៨ ឬ១០ ម៉ែត្រ។ គេយកក្រមា ឬកន្សែងមកធ្វូលឱ្យមូល ចងរិតឱ្យតឹងណែន ល្អ ទុកឱ្យមានកន្ទុយបន្តិចហៅថា «ឈូង» សម្រាប់កាន់បោះ ឬចោលទៅមករកគ្នា។ ឈូងមាន ២បែប គឺឈូងច្រៀងរាំ និងឈូង លោះខ្ញុំ។ ល្បែងនេះគេលេងដើម្បីហាត់ក្មេក ឱ្យវៃ ដៃឱ្យរហ័ស តម្រង់ឱ្យត្រង់ ឱ្យមានស្មារតី ប្រុងប្រយ័ត្ន ហាត់ទម្លាប់ខ្លួនឱ្យចេះប្រុងស្មារតី។

. **ល្បែងបោះអង្គុញ** គឺជាល្បែងមួយ ដែលគេឱ្យឈ្មោះទៅតាមវត្ថុដែលគេយកមក លេង គឺផ្លែអង្គុញដែលក្រៀមស្ងួត។ ល្បែង នេះ គេលេងបានទាំងប្រុសទាំងស្រី ទាំងចាស់ ទាំងក្មេង នៅវេលាថ្ងៃ ឬយប់ខែភ្លឺ នារដូវចូល ឆ្នាំ។ ល្បែងនេះ គេលេងបានចាប់ពីគ្នា២នាក់ ឡើងទៅ រហូតដល់១០នាក់ ដោយចែកចេញ ជាពីរក្រុមមានចំនួនស្មើគ្នា។ អង្គុញដែលគេ យកមកលេង គេឱ្យឈ្មោះថា កោយ ដែល ចែកចេញជាពីរផ្នែក គឺកោយដាំ និងកោយ បោះ។ បើកោយដាំនោះមានចំនួន៣ ឬចំនួន ៥ គឺថាកោយបោះក៏មានចំនួនតាមកោយដាំ ដែរ និងអាស្រ័យលើអ្នកលេង មានតិច ឬច្រើ ន។ លុះសន្មត់គ្នាហើយ ក្រុមនីមួយៗក៏នាំគ្នា បោះអង្គុញតម្រង់ទៅកោយដែលដាំឱ្យត្រូវ។ ក្រុមណាបោះត្រូវច្រើនជាង ក្រុមនោះគឺជា អ្នកឈ្នះ ហើយអ្នកឈ្នះគេយកអង្គុញពីរមក ដាក់ផ្គោបគ្នាដោយ ដាក់អង្គុញមួយផ្ដេក ១ ទៀតបញ្ឈរ ទុកចន្លោះឱ្យឃ្លាតគ្នាបន្តិចដើម្បី ជួសទៅនឹងជង្គង់អ្នកចាញ់ឱ្យឮ បើជួសមិនឮ នោះអ្នកចាញ់មានសិទ្ធិជួសអ្នកឈ្នះវិញ។

**.ល្បែងលាក់កន្សែង** ជាល្បែងម្យ៉ាងរបស់ក្មេងខ្មែរក្នុងបុរាណកាល តែងលេងសម្រាប់ជាទីកម្សាន្តសប្បាយនៅពេលរាត្រីខែភ្លឺ ក្នុងរដូវចូលឆ្នាំ ឬនៅពេលចន្លោះការហត់នឿយម្តងៗ។ មុនដំបូង គេបបួលគ្នាបានចំនួនពី ៦-៧ នាក់ឡើងទៅ ឱ្យអង្គុយច្រហោង ដំកង់ជារង្វង់មូល ដាក់ដៃទាំងពីរទៅមុខលើក្បាលជង្គង់ នាទីកន្លែងណាមួយ ដែលជាទីស្រឡះរាបស្មើល្អ ហើយគេយកកន្សែង ឬក្រមាតូចមួយមករុំមូរធ្វើលរឹតឱ្យតឹងណែនល្អ ទុកជាយបន្តិចសម្រាប់កាន់យួរបាន សន្មតហៅថា «កន្សែង» ដោយមានម្នាក់ក្រោកចេញទៅក្រៅរង្វង់ កាន់កន្សែងនោះ ដើរព័ទ្ធជុំវិញយ៉ាងលឿនពីខាងក្រោយខ្នងអ្នកអង្គុយ បញ្ឆោតអ្នកអង្គុយមិនឱ្យដឹងខ្លួនថាគេលាក់កន្សែងក្រោយខ្នងអ្នកណាម្នាក់ទេ ហើយអ្នកដែលត្រូវគេដាក់កន្សែងនោះ បើបានដឹងហើយ ត្រូវតែក្រោកឡើងឱ្យរវាសដេញវាយអ្នកអង្គុយបន្ទាប់ ហើយអ្នកអង្គុយបន្ទាប់នោះត្រូវក្រោករត់១ជុំ គេចពីការដេញវាយនោះ មកអង្គុយកន្លែងខ្លួនវិញ ទើបអ្នកវាយនោះដើរលាក់កន្សែងជាបន្ត។

**. ល្បែងទាញព្រ័ត្រ** ជាល្បែងលេងកម្សាន្តសប្បាយរបស់យុវជនខ្មែរទាំងបុរស ទាំងស្ត្រី។ ល្បែងនេះគេលេងដោយប្រើកម្លាំងកាយ ហើយគេលេងតែក្នុងរដូវចូលឆ្នាំខ្មែរ គឺខែចេត្រ ពិសាខប៉ុណ្ណោះ។ មុនដំបូងគេចែកអ្នកលេងជា២ក្រុម ១ក្រុមពី១០ទៅ២០នាក់ ដោយរើសរកប្រុសម្នាក់ ស្រីម្នាក់ មានមាឌធំមាំ កម្លាំងខ្លាំង ឱ្យជាអ្នកឈរកាន់ចុងព្រ័ត្រ គឺប្រុសកាន់ម្ខាង ស្រីកាន់ម្ខាង ហើយឱ្យប្រុសម្នាក់ ស្រីម្នាក់ទៀតមានមាឌធំ មានកម្លាំងឈរកណ្តាលព្រ័ត្រ ត្រង់កន្លែងដែលពួកទាំងពីរឈរ សម្រាប់នាំពួកខ្លួនឱ្យខំទាញតែរៀងខ្លួន ឯមនុស្សដែលមានមាឌតូចៗស្គមៗកម្លាំងខ្សោយៗ គេឱ្យឈរកណ្តាលគេ។ លុះរៀបចំរួចហើយ គេឱ្យមនុស្សប្រុសម្នាក់កាន់សំភោរ ឬគង់ម៉ង់ ឬក៏រគាំងឈរត្រង់កណ្តាលទីជិតអ្នកទាំងពីរដែលកាន់ខ្សែឈរប្រទល់មុខគ្នានោះ ផ្តើមស្រែកឡើងព្រមគ្នាថា **យក្សអរ**!..! ឮយ៉ាងខ្លាំងៗ ធ្វើសំឡេងវែងៗ រលាក់រលែកយ៉ាងគ្រលួចៗ ឯអ្នកប្រុងទាញព្រ័ត្រទាំងប៉ុន្មានជួយស្រែកទទួលឡើងព្រមគ្នា ហ៊ោ៣ដង ទើបនាំគ្នាទាញយកជ័យជម្នះរៀងៗខ្លួន។

**. របាំត្រុដិ**

របាំត្រុដិ ជារបាំមួយដែលគេរាំក្នុងពេលចូលឆ្នាំ ដែលកើតឡើងពីជនជាតិសំរែ ដែលជាជនជាតិដើមមួយនៅលើទឹកដីយើងក្នុងអំបូរខ្មែរ-មន។ ជនជាតិសំរែរស់នៅត្រង់ម្តុំក្បែរអង្គរ ខេត្តសៀមរាប។ របាំត្រុដិផ្សារភ្ជាប់នឹងជំនឿបន់ស្រន់ទឹកភ្លៀង។ ក្នុងរបាំនេះ គេនិយមប្រើកន្ទុយក្ងោក ដែលគេយល់ថា ក្ងោក

ជាតំណាងព្រះអាទិត្យ។ មនុស្សបន់ស្រន់អង្វរកព្រះអាទិត្យឱ្យធ្វើអំណោយទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ នៅពេលគ្មានភ្លៀងធ្លាក់ គេលេងត្រុដិសុំទឹកភ្លៀង។ របាំត្រុដិលេងនៅពេលចូលឆ្នាំ គឺគេលេងថ្វាយព្រះអាទិត្យអង្វរកឱ្យហើយស្រេចតាំងពីដើមឆ្នាំទៅ សុំទឹកភ្លៀងសម្រាប់វស្សារដូវខាងមុខនេះ។

ពាក្យថា **ត្រស្តិ** ក្លាយមកពីភាសាសំស្ក្រឹតថា **ត្រុដ** កិ. "**កាត់ ផ្តាច់**" ត្រុដិ ន. "**ដំណើរកាត់ ការផ្តាច់**" ក្នុងព្រះរាជពិធីនេះសំដៅយកសេចក្តីថា "**ដំណើរផ្តាច់ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី**។

ប្រភព របាំត្រុដិជារបាំមួយកើតឡើងពីជនជាតិសំរែ ដែលជាជនជាតិដើមមួយផ្នែកនៅលើទឹកដីយើងក្នុងអំបូរខ្មែរ-មន។ ជនជាតិសំរែរស់នៅត្រង់ម្តុំក្បែរអង្គរ ខេត្តសៀមរាប។

របាំត្រុដិផ្សារភ្ជាប់នឹងជំនឿបន់ស្រន់ទឹកភ្លៀង។ ក្នុងរបាំនេះគេនិយមប្រើកន្ទុយក្ងោក ដែលគេយល់ថា ក្ងោកជាតំណាងព្រះអាទិត្យ។ មនុស្សបន់ស្រន់អង្វរកព្រះអាទិត្យឱ្យធ្វើអំណោយទឹកភ្លៀងគ្រប់ គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ នៅពេលគ្មានភ្លៀងធ្លាក់គេលេងត្រុដិសុំទឹកភ្លៀង។ របាំត្រុដិលេងនៅពេលចូលឆ្នាំគឺគេលេងថ្វាយព្រះអាទិត្យអង្វរឱ្យហើយស្រេចតាំងពីដើមឆ្នាំទៅសុំទឹកភ្លៀងសម្រាប់វស្សានរដូវខាងមុខ។

ការរាំរបាំត្រុដិនាពេលចូលឆ្នាំថ្មី គឺគេកំណត់យកដំណើរផ្តាច់ឆ្នាំនីមួយៗដើម្បីដេញឧបទ្រពចង្រៃដែលកើតមានក្នុងឆ្នាំចាស់ហើយនិងប្រសិទ្ធពរសព្វសាធុការក្នុងឱកាសឆ្នាំថ្មីវិញ។ តាមរយៈការសម្តែងគឺប្រជាពលរដ្ឋយើងតែងតែមានសេចក្តីសប្បាយរីករាយណាស់ព្រោះអ្នករាំរបាំត្រុដិបានចូលទៅដល់មុខផ្ទះឬក្នុងភូមិ ខណៈពេលដែលពួកគាត់មានជំនឿប្រកបដោយក្តីសង្ឃឹមថាក្នុងឆ្នាំថ្មីនេះសុភមង្គលលាភសក្ការៈ នឹងកើតមានក្នុងក្រុមគ្រួសារឬភូមិស្រុករបស់គាត់មិនខាន។ ជាទូទៅគេសម្តែងរបាំត្រុដិនេះពាសពេញភូមិតែម្តង ប្រសិនបើជាមានសត្វព្រៃរត់ចូលភូមិស្រុករបស់គេ ព្រោះគេមានជំនឿថា ពេលណាមានសត្វព្រៃដូចជាឈ្លូស ប្រើស រមាំងជាដើម រត់ចូលភូមិក្នុងករណីណាក៏ដោយពួកគេនឹងចាត់ទុកថានោះគឺជាអព្វូតហួតហេតុអាក្រក់ឬចង្រៃ ហើយត្រូវអញ្ជើញក្រុមរបាំត្រុដិមកលេងដើម្បីបណ្តេញភាពចង្រៃនោះចេញ។ ប៉ុន្តែប្រសិនបើគេចាប់បានពពួកសត្វព្រៃនោះវិញ គឺគេយកវាទៅលាបប្រេងម្សៅ ហើយធ្វើពិធីលែងឱ្យមានសេរីភាពវិញដោយបួងសួងសុំសេចក្តីសុខសប្បាយប្រជាពលរដ្ឋក្នុងភូមិ ស្រុក ពេលដែលគេមានជំនឿ

ថា សត្វព្រៃទាំងនោះបានមករំដោះគ្រោះមហន្តរាយដល់ពួកគេ។

**ឧបករណ៍សម្តែង**

**- ឧបករណ៍តន្ត្រី**

**កញ្ចារះ** ដងធ្វើពីពីងពង់ប្រវែង២ម៉ែត្រ មានបន្ទះរនាបតូចផ្ចារភ្ជាប់នៅចុងហើយខ្វែងពីចុងមួយ ទៅចុងមួយ ហើយត្រង់កណ្តាលខ្សែខ្វែងនេះមានបន្តោងផ្លែអង្គុញដែលចោះយកគ្រាប់ចេញអស់ ហើយដាក់គ្រាប់គ្រួស ឬដែកទៅក្នុងនោះ ប្រយោជន៍ឱ្យឮសូរ កាលណាគេបុកដងវានឹងដីតាមចង្វាក់ស្គរ។

**ចង្រង់ដំបែះ** ចង្រង់បន្តោងនឹងខ្សែទាមគោហើយចងភ្ជាប់ដងឫស្សីដែរ។ កាលណាគេបុកនឹងដី ក៏លាន់សូរច្រាវៗតាមចង្វាក់។

**ចង្រង់រ៉ូងះ** ចង្រង់នេះចងព្យួរនឹងចង្កេះមនុស្សតែម្តង ដោយចងគួបជាចង្កោមៗ។

**ស្គរះ** ស្គរធ្វើពីដីដុតពាសស្បែកថ្ងាន់។

**ប៉ីពក ទ្រអ៊ូ ទ្រសោ។**

**សន្ទូចះ** ដងពីងពង់វែងមានសណ្ឋានដូចសន្ទូច ចុងដូចចន្ទោលរទេះ ដោយមានព្យួរចង់មួយនៅចុង សម្រាប់ទទួលវត្ថុជាទាន។

**- ឧបរណ៍តែង**

**មុខត្លុកះ** ធ្វើពីធ្លីងឫស្សី ពាសក្រដាស ឬ ស្នាច់ ឬ ខ្នុក។

**មកុដះ** ធ្វើពីក្រដាសលាបការ និងបិទឱ្យតម្រូវគ្នាទៅជារឹង គឺស្នាច់ ឬ ខ្នុក ហើយផាត់ពណ៌។

ស្នែងប្រើសស្នែងទន្សោងកន្ទុយក្ងោក។

**ក្របកះ** យកផ្តៅប្រវែង០,២ម៉ែត្រ បិតចុងឱ្យស្រួច រោលភ្លើងឱ្យង យកអំបោះចងគល់ភ្ជាប់នឹងម្រាម៤ ឯមេដៃមិនពាក់ទេ។

**+ តួសម្តែង**

- អ្នកពាក់មុខខ្មៅ ធ្វើមនុស្សព្រៃ
- អ្នកពាក់មុខត្លុក ធ្វើព្រានព្រៃ
- អ្នកពាក់ស្នែងប្រើស ស្នែងទន្សោង
- តួរាំ (តួឯក តួនាង)
- អ្នកពាក់ក្របក
- អ្នកកាន់គ្រឿងភ្លេង

តួសម្តែងក្នុងរបាំត្រុដិជាមធ្យមមានម្ភៃប្រាំនាក់។

**+ របៀបសម្តែង**

- ដំបូងបង្អស់តួសំដែងទាំងអស់ត្រូវបន្ទន់កាយរំលឹកគុណគ្រូ។ អ្នកពាក់មុខទាំងអស់(មនុស្សព្រៃ ព្រានព្រៃ) ចេញមកមានកិរិយាមិននឹងធឹងច្រើនរត់រឆ្វេងស្តាំ ចេញក្រៅពីវង់ ហើយច្រើនរត់ទៅមុខគេ។ ដងខ្លួនធ្វើផេកផោកយោលទៅតាមចង្វាក់ស្គរ ដៃគ្រាន់តែពត់បន្តិចមិនពេញជារាំទេ។ តួព្រានស្មៀកស្ទឹកចេកច្រៀក ចងព័ទ្ធចង្កេះ លាបខ្លួនខ្មៅ។

អ្នកពាក់ស្នែង (ប្រើស ទន្សោង) ចាក់ក្បាច់ប្រហែលព្រាននិងមនុស្សព្រៃដែរ។ ដៃទាំងពីរជួនយកទៅកាន់ស្នែង ជួនលូកទៅមុខទំនងធ្វើជាជើងម្រឹគ ដោយឱ្យបង្អោនខ្លួន។ គេរាំលោតៗតាមចង្វាក់ ស្គរផ្ទៀងផ្ទង់ដូចម្រឹគផ្អើលម្ដងៗ។ យូរៗប្រើសនិងទន្សោងធ្វើជារត់ចេញខាងក្រៅរង្វង់ម្ដងៗដែរ។

តួឯក និង តួនាងច្រើនជាតួរាំនារី។ តួឯកពីរនាក់ស្លៀកចងក្បិនពណ៌ ពាក់អាវពណ៌ ពាក់របៃ គ្មានសង្វារ ហើយបង់កន្សែងពណ៌សំយុង។ តួរាំពីរគូនេះ មានក្បាច់ទន់ភ្លន់ជាងគេ ដោយមានឫកជានារីក្រមុំអែនអន កែក្រាយ។

អ្នកពាក់ក្រចក និង អ្នកកាន់គ្រឿងភ្លេង ជាតួបន្ទាប់បន្សំ។ អ្នកពាក់ក្រចកជួយច្រៀង និង ឱ្យចង្វាក់ជួយបង្កើនទស្សនីយភាពនៃរង់របាំ។ អ្នកកាន់គ្រឿងភ្លេង ជាពិសេសអ្នកបុកកញ្ជារ និង អ្នកកាន់ចង្រ្គងដំបែជួយចង្វាក់ស្គរ និង យោលខ្លួនចុះឡើងតាមចង្វាក់ស្គរ និង កញ្ជារ។

**+ ទំនុកច្រៀង**

*ហាអើយ វង់ត្រុដិស្រុកអាយ វង់ត្រុដិស្រុកអាយ លំឱនអង្គកាយ សូមពរឆ្នាំថ្មី។*

*បន្ទរ ៖ ឱណា នាងណា សូមពរឆ្នាំថ្មី!*

*ហាអើយ ផ្គរលាន់ឯត្បូង ត្រយូងចេកជ្វា អ្នកអើយត្រុដិលា ឈប់លេងត្រឹមណេះ។*

*បន្ទរ ៖ ឱណានាងណា ឈប់លេងត្រឹមណេះ!*[2]

កំណត់សម្គាល់៖ ចំពោះទំនុកច្រៀង ទោះបីមានគំលាតពីន័យដើមពីសំណូមពរសុំទឹកភ្លៀង ក៏យើងឃើញទំនុកច្រៀងក្នុងរបាំនេះនៅមានសំណល់ជាតុខ្លះដែលមានក្នុងអាជីវកម្ម កសិកម្ម គឺបញ្ហាទឹក។ យើងយល់ថា របាំត្រុដិត្រូវបានជនជាតិសំរែប្រើប្រាស់សម្រាប់ដោះស្រាយសំណូមពរកសិកម្ម ដើម្បីទ្រទ្រង់ជីវិតរស់នៅ។ ប៉ុន្តែឆ្លងកាត់ដំណាក់កាលវិវត្តនៃប្រវត្តិសាស្រ្តសង្គមមនុស្ស របាំត្រុដិត្រូវបានទទួលឥទ្ធិពលខ្លាំងពីសាសនា ហើយត្រូវបានគេយកមកប្រើក្នុងបំណងផ្សេងទៅវិញ។

ចំពោះការសម្ដែងរបាំត្រុដិនៅតាមភូមិណាមួយៗកាលពីសម័យដើមវិញ គឺមានការតុបតែងខ្លួនជាលក្ខណៈសាមញ្ញ ហើយគេដើរដង្ហែជាក្បួនទៅមុខ ដោយមានអ្នកកាន់ដងចន្ទោលដែលមានការចងកំណាត់លម្អ

[2] ពេលខ្លះក៏ច្រៀងខុសពីទំនុកនេះខ្លះដែរ អាស្រ័យទៅតាមការកាឡៃនៃក្រុមសម្ដែង។

និងមានសិល្បករម្នាក់ជាអ្នករាំនាំផ្លូវផង។ តាមអ្វីដែលយើងបានឃើញពិធីរាំនោះ គឺមើលទៅហាក់ដូចជាអ្នករាំ ឬអ្នកហែទាំងនោះកំពុងតែជិះលើរទេះមួយដូច្នេះដែរ។ ចំណែកនៅខាងចុងនៃដងចន្ទោលនោះ មានចងកូនថង់មួសម្រាប់ជាការរៃអង្គាសប្រាក់ ហើយអ្នកផ្ទះឬអ្នកភូមិ ដែលមកឈរមើលការរាំរបាំត្រុដិនិងមានសទ្ធាជ្រះថ្លា ពួកគេនឹងដាក់ប្រាក់ក្នុងថង់នោះ ព្រោះគេមានជំនឿថាបុណ្យកុសលដែលបានដាក់ទាននាពេលនេះនឹងបានចម្លងគ្រោះកាចចង្រៃនៃឆ្នាំចាស់ទៅអស់ ហើយចូលឆ្នាំថ្មីសិរីសួស្តីសុភមង្គលនឹងមកដល់ ។

ជាសរុបសេចក្តីទៅពិធីបុណ្យចូលឆ្នាំជាពិធីបុណ្យមួយដែលល្អនៅក្នុងប្រពៃណីខ្មែរ ជាពិធីបុណ្យផ្តាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី ជាពិធីបុណ្យនៃការវិលមកត្រលប់ជួបជុំគ្នា សួរសុខទុក្ខគ្នា ដើម្បីទទួលទេវតាឆ្នាំថ្មីឆ្នាំថ្មី បួងសួងសុំពរជ័យសិរីមង្គលវិបុលសុខ និងជាប្រពៃណីបណ្តុះនូវស្មារតីស្រឡាញ់រាប់អានគ្នាមិនត្រឹមតែជាបងប្អូនសាច់ញាតិ គឺរវាងអ្នកភូមិស្រុកជិតខាងគ្នា ដែលជាកត្តាបង្កើតសាមគ្គីភាពជាតិផងដែរ ដ្បិតពេលចូលឆ្នាំ គេមិនត្រឹមតែជួបជុំគ្នាក្នុងគ្រួសារប៉ុណ្ណោះទេ តែគេនាំគ្នាទៅធ្វើបុណ្យនៅវត្តអារាម ដែលជាមជ្ឈមណ្ឌលអប់រំឱ្យមានមនុស្សធម៌ និងសាមគ្គីធម៌។ ហេតុដូច្នេះហើយ ទើបពិធីបុណ្យចូលឆ្នាំថ្មី មានអត្ថន័យយ៉ាងជ្រាលជ្រៅ ដែលធ្វើឱ្យខ្មែរយើងនិយមរាប់អានទុកជា ប្រពៃណីជាតិតាំងពីដើមរហូតមកដល់បច្ចុប្បន្នយើងនេះ។

ក្នុងនាមនាងខ្ញុំជាប្រជាពលរដ្ឋខ្មែរម្នាក់ នាងខ្ញុំសូមសំណូមពរឱ្យប្រជាជនខ្មែរទាំងអស់នាំគ្នាចូលរួមថែរក្សានូវប្រពៃណីនៃពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរឱ្យបានគង់វង់ និងអភិរក្សនូវរាល់ល្បែងក៏ដូចជារបាំប្រជាប្រិយខ្មែរដែលមាន ដើម្បីបន្តនូវមរតកល្បែងទាំងនេះទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយៗទៀត បានស្វែងយល់ បានលេងកម្សាន្ត ដ្បិតល្បែងប្រជាប្រិយទាំងនេះ មិនត្រឹមតែនាំមកនូវភាពសប្បាយរីករាយប៉ុណ្ណោះទេ គឺបានបង្កប់នូវអត្ថន័យនិងគោលបំណងច្បាស់លាស់សម្រាប់កូនចៅខ្មែរដូចជាឱ្យមានសាមគ្គីភាព មិត្តភាព ស្រឡាញ់រាប់អានគ្នា មានទឹកចិត្តក្លាហាន ទន់ភ្លន់តែមិនទន់ជ្រាយ រហ័សរហួន ឈ្លាសវៃ និងដើម្បីពង្រឹងកាយសម្បទាឱ្យរឹងមាំជាដើម ហើយអ្វីដែលពិសេសនិងមានតម្លៃមិនអាចកាត់ថ្លៃបាននោះ គឺជាមរតកវប្បធម៌ នៃប្រជាជាតិខ្មែរជាអត្តសញ្ញាណជាតិខ្មែរតាំងពីយូរលង់ណាស់មកហើយ៕

## ឯកសារពិគ្រោះ


- ក្រសួងអប់រំ ***អក្សរសិល្ប៍ថ្នាក់ទី១០*** ភ្នំពេញ ឆ្នាំ១៩៩៧-៩៨។
- ខឹម សំឳ ***មូលដ្ឋានស្វែងយល់អក្សរសាស្ត្រខ្មែរ*** ភ្នំពេញ ឆ្នាំ១៩៦៣។

. ជា វណ្ណី & ទុយ យូឃីម ***អក្សរសិល្ប៍ប្រជាប្រិយខ្មែរ*** ឆ្នាំ២០១៧។

- ពុទ្ធសាសនបណ្ឌិត្យ ***ប្រជុំរឿងព្រេងខ្មែរ*** ភាគ១ដល់៩ ភ្នំពេញ ឆ្នាំ១៩៩៤។
- ពុទ្ធសាសនបណ្ឌិត្យ ***ល្បែងប្រជាប្រិយខ្មែរ*** ភ្នំពេញ ឆ្នាំ១៩៩៤។
- ពុទ្ធសាសនបណ្ឌិត្យ ***របាំប្រជាប្រិយខ្មែរ*** ភ្នំពេញ ឆ្នាំ១៩៩៤។
- ពុទ្ធសាសនបណ្ឌិត្យ ***ពិធីបុណ្យទ្វារទសមាស*** ភ្នំពេញ ឆ្នាំ១៩៩៤។
- ពៅ សាមី ***លក្ខណៈពិសេសនៃអក្សរសិល្ប៍ និងសិល្បៈ*** ភ្នំពេញ ឆ្នាំ១៩៩២។
- ហ៊ុន គឹមសៀ ***មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ*** គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ១៩៥៨។

# ព្រះរាជជីវប្រវត្តិព្រះករុណា
# ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ
# និងស្នាព្រះហស្ត

*ដោយៈ* **លោក សូ ប៉ុណ្ណារ៉ាត់**

*ប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*អត្ថបទស្តីអំពី ព្រះរាជជីវប្រវត្តិព្រះករុណាព្រះបាទសម្តេចព្រះ* ***នរោត្តម សីហនុ*** *ព្រះបរមរតនកោដ្ឋ អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានិងស្នាព្រះហស្ត គឺជាការសិក្សាស្រាវជ្រាវ រៀបចំឡើងវិញ ដើម្បីទុកជាឯកសារ។ តាមទិដ្ឋភាពប្រវត្តិសាស្ត្រ ករុណាព្រះបាទសម្តេចព្រះ* ***នរោត្តម សីហនុ*** *ជាព្រះមហាក្សត្រទី២ ដែលបានឡើងគ្រងរាជ្យសម្បត្តិនៅក្នុងសម័យអាណាព្យាបាលបារាំងនាឆ្នាំ១៩៤១ ហើយព្រះអង្គគឺជាព្រះមហាក្សត្រ ដែលមានព្រះជន្មក្មេងជាងគេ ក្នុងចំណោមព្រះមហាក្សត្រផ្សេងៗទៀត។ ព្រះអង្គត្រូវបានអ្នកផងទាំងពួងចាត់ទុកជាបុព្វការីដ៏ឧដុង្គឧត្តម ប្រកបដោយព្រហ្មវិហារខ្ពង់ខ្ពស់យ៉ាងជ្រាលជ្រៅបំផុត និងជាអ្នកនយោបាយយ៉ាងចំណាន នៅប្រទេសកម្ពុជា នាសម័យថ្មី។ ជាព្រះមហាក្សត្រដែលមានព្រះបញ្ញាវាងវៃ ពូកែទាក់ទាញសមានចិត្តគាំទ្រ យ៉ាងទូលំទូលាយ ព្រះអង្គជាអ្នកនិពន្ធដ៏ឆ្នើម ថែមទាំងមានស្នាព្រះហស្តនិពន្ធសៀវភៅដែលមានរាប់សិបចំណងជើង និងជាសិល្បករភាពយន្តជាដើម។ ផ្នែកទំនាក់ទំនងការទូតព្រះអង្គមានព្រះទ័យទូលំទូលាយ និងមានមិត្តភក្តិធំៗ ជាច្រើននៅលើសាកលលោកទាំងសេរីនិងកុម្មុយនីស្ត។ គុណបំណាច់ដ៏ធំធេងរបស់ព្រះអង្គ ដែលប្រជាពលរដ្ឋទូទាំងប្រទេសមិនអាចបំភ្លេចបានគឺការទាមទារឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣។ បន្ទាប់មកទៀតក្រោយពីឯករាជ្យ ព្រះអង្គបានរៀបចំប្រទេសនិងដឹកនាំប្រទេស ប្រកបដោយភាពរុងរឿងយ៉ាងត្រចះត្រចង់ ពិសេសក្នុងសម័យសង្គមរាស្ត្រនិយម។ នរណាៗក៏ទទួលស្គាល់ថាសង្គមរាស្ត្រនិយមបានធ្វើឱ្យប្រទេសជាតិរីកចម្រើនគ្រប់វិស័យ ហើយថែមទាំងមានការកសាងសមិទ្ធផលយ៉ាងច្រើនសន្ធឹកសន្ធាប់តាំងពីទីក្រុងរហូតដល់ទីជនបទ គឺសម្រាប់ជា*

ប្រយោជន៍ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ។ បច្ចុប្បន្នយើងសង្កេតឃើញសមិទ្ធផលដែលជាស្នាព្រះហស្តរបស់ព្រះអង្គមួយចំនួននៅបន្តប្រើប្រាស់នៅឡើយ ហើយមួយចំនួនទៀតក៏ត្រូវបានបាត់រូបរាងក្រោមភ្លើងសង្គ្រាម និងភាពចាស់ទ្រុឌទ្រោម។

## ២.ព្រះកុមារភាព

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គទ្រង់ព្រះប្រសូត្រនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ព.ស. ២៤៦៦ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩២២ នៅឯព្រះបរមរាជវាំងក្រុងចតុមុខមង្គលរាជធានីភ្នំពេញ នៃព្រះរាជាអាណាចក្រកម្ពុជា។ ព្រះនាមពេញគឺព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** (ព្រះនាមដើម)។ ព្រះអង្គ មានព្រះអនុជមាតាទីទៃបីព្រះអង្គគឺស្តេចក្រុមឃុន **នរោត្តមសិរីវុឌ្ឍ** ព្រះអង្គម្ចាស់ **នរោត្តម អុីយ៉ា សុជម** និងអ្នកអង្គម្ចាស់ **នរោត្តម វិជ្ជារ៉ា**។ តាំងពីកុមារភាព ព្រះអង្គទ្រង់មានព្រះរាជបញ្ញាឈ្លាសវៃមានភាពតស៊ូអំណត់នូវរាល់ការងារ និងមានភាពព្យាយាមនូវរាល់គ្រប់ការងារទាំងឡាយ។ នៅក្នុងវ័យកុមារព្រះអង្គត្រូវបានព្រះបិតាផ្ទុកដាក់ការអប់រំរបស់ព្រះអង្គទៅលើលោកយាយទូត គឺអ្នកម្នាង **ចៅ ឃុនប៉ាត** ដែលជាគ្រួសារអភិជនមួយ។



ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** និង ព្រះអយ្យិកាទូត (យាយទូត)

រឿងទាំងអស់នេះមិនមែនមាតាបិតារបស់ព្រះអង្គចង់ដោះដៃលោកចោលទេ គឺលោកទាំងពីរស្រឡាញ់ព្រះអង្គខ្លាំងណាស់ តែដោយហោរាក្នុងព្រះបរមរាជវាំង បានទាមទារយ៉ាងប្តូរផ្តាច់ត្រូវតែបំបែកព្រះអង្គពីព្រះមាតា និងព្រះបិតាបើពុំដូចច្នេះទេព្រះអង្គនិងសុគតទាំងវ័យក្មេង។ នៅពេលព្រះអង្គព្រះជន្ម៥វស្សា ព្រះអង្គបានរក្សាសីល៥នៃព្រះពុទ្ធសាសនា។ រីឯសីលផ្សេងៗទៀត មិនសម្លាប់ មិនលួច មិនប្រមាថមនុស្សចាស់ និងមិនផឹកស្រា។ បន្ទាប់ពីព្រះអយ្យិកាទូត **ទូត**

**ប៉ាត** អនិច្ចកម្មព្រះអង្គបានបួសជាសង្ឃរយៈ ពេល២៤ម៉ោង។ ក្នុងពេលជាសង្ឃលោកត្រូវ តមអាហារពេលល្ងាច ដោយឆាន់ស្ករពីរឬបី ដុំជំនួសវិញ។ លុះស្អែកឡើងពេលបូជាសព លោកយាយទួតរួច ព្រះអង្គចាកពីចីវរដើម្បី ត្រឡប់មកកាន់ជីវភាពគ្រហស្ថវិញ។ ក្រោយ មកព្រះអង្គត្រូវព្រះមាតាព្រះបិតារបស់ព្រះ អង្គ បានបញ្ជូនព្រះអង្គទៅអប់រំបន្តជាមួយ ព្រះអយ្យកា ព្រះអយ្យកោ ខាងព្រះបិតាវិញ គឺព្រះអង្គម្ចាស់ **នរោត្តម សុទ្ធារតន៍** ដែលទ្រង់ ជាកវី និងជាអ្នកអក្សរសាស្ត្រជាតិដ៏ល្បីទៀត ផង។ ក្នុងពេលនោះដែរព្រះអយ្យកោ បាន ជំរុញឱ្យព្រះអង្គចាប់ចិត្តនិងអក្សរសិល្ប៍ខ្មែរ តែព្រះអង្គពុំមានឧប្បនិស្ស័យពោលគឺព្រះ អង្គចូលចិត្តខាងកីឡាបាល់ទាត់ បាល់បោះ បាល់ទះ កីឡាប្រណាំងសេះ ឯកីឡាបាល់ ទាត់ ជារឿយៗព្រះអង្គតែងលេងជាមួយក្មេងៗ មកពីភូមិជិតខាង។ កាលព្រះអង្គនៅជាព្រះ រាជកុមារ ក្រុមហោរារបស់ហ្លួងមុនីវង្សបាន ទោះទាយថា ព្រះអង្គនិងកាន់មុខដំណែង មួយដ៏ធំនៅក្នុងព្រះរាជាណាចក្រ ប៉ុន្តែព្រះ អង្គត្រូវប្រយុទ្ធនឹងសត្រូវដ៏គ្រាក់ៗដោយគេច ពុំផុត។ ព្រះអយ្យកោ(ជីតា) ខាងព្រះបិតាព្រះ អង្គម្ចាស់ **នរោត្តម សុទ្ធារតន៍** ដែលលោកមាន ជំនាញជ្រៅជ្រះខាងភាសាបាលី បានប្រទាន ព្រះនាមដល់ព្រះអង្គ ដោយជ្រើសរើសយក ព្រះនាមរបស់ក្សត្រមួយព្រះអង្គ ក្នុងរឿងពុទ្ធ និទាននៅប្រទេសឥណ្ឌា។ ការប្រទានព្រះ នាមនេះហាក់ដូចជាមានភាពអស្ចារ្យណាស់ សំរាប់ព្រះអង្គគឺ **សីហៈ** (សិង្ហឬសិង្គៈ)ជា ភាសាបាលីប្រែថា **សត្វតោ**។ ប៉ុន្តែព្រះអង្គ ម្ចាស់ **នរោត្តម សុទ្ធារតន៍** ព្រះអង្គឆ្ងៃងយល់ ថាយ៉ាងហោចណាស់ **សីហនុ** ក៏នឹងទៅជា រីស្ហាបេះដូងសិង្ហ (Richard Coeur de Lion)ខ្មែរ ដែរ។ រីឯព្រះអយ្យកោ គឺព្រះមហាក្សត្រ **ស៊ីសុវត្ថិ មុនីវង្ស** ព្រះអង្គបានប្រទានព្រះនាម មួយទៀត ថ្វាយព្រះអង្គកាលព្រះអង្គនៅ កុមារភាពគឺ **នរោត្តមថុល**ព្រះនាមនេះព្រះអង្គ ធ្លាប់ប្រើក្នុងអត្ថបទរបស់ព្រះអង្គកាលព្រះ អង្គនៅក្នុងក្រុមអ្នកនិពន្ធ។ ក្នុងខ្សែជីវិតរបស់ ព្រះករុណាព្រះបាទ **នរោត្តម សីហនុ** មាន ភាពប្លែក អស្ចារ្យខុសពីមនុស្សសាមញ្ញ។ ពេញមួយជីវិតរបស់ព្រះអង្គតែងមានសត្រូវ តាមប្រចាំង និងជំទាស់យ៉ាងបូផ្ដាច់។ ប៉ុន្តែបើ តាមហោរាបានបញ្ជាក់ថាព្រះអង្គ និងឆ្លងផុត ព្រមទាំងឈ្នះអស់មាសត្រូវទាំងខ្មែរនិង បរទេស។ ក្នុងពេលដែលព្រះអង្គឡើងសោយ រាជ្យព្រះអង្គទទួលបានព្រះបរមនាមក្នុងរាជ្យ មួយទៀតគឺ ***ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្សអគ្គមហាបុរសរតន៍ និករោត្តមធម្មិក មហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅ ក្រុងកម្ពុជាធិបតី***។

## ៣.ការសិក្សា

ចាប់ពីឆ្នាំ១៩៣០ ដល់ ឆ្នាំ១៩៤០ ព្រះអង្គបានចូលសិក្សានៅសាលាបឋមសិក្សា FRANÇOIS BAUDOIN នឹងវិទ្យាល័យព្រះស៊ីសុវត្ថិរាជធានីភ្នំពេញ។ បន្ទាប់មកទៀតព្រះអង្គក៏បានបន្តការសិក្សានៅវិទ្យាល័យបារាំងសាសលូឡូបា (CHASSELOUP LAUBAT) នៅព្រៃនគរ (វៀតណាមខាងត្បូង) ក៏ធ្លាប់បានសិក្សាយ៉ាងល្អប្រពៃនៅទីនោះដែរ។ ការសិក្សានៅទីនោះបានបន្សល់នូវអនុស្សាវរីយ៍ដ៏សប្បាយរីករាយបំផុតក្នុងជីវិតរបស់ព្រះអង្គ។

នៅឆ្នាំ១៩៤៦ និង១៩៤៨ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់ នៅសាលាអនុវត្តទ័ពសេះ និងកងទ័ពរថពាសដែកនៅសូមៀរ (Saumur) ប្រទេសបារាំង។ រាល់ការសិក្សា និងការបណ្តុះបណ្តាល ព្រះអង្គតែងមានភាពព្យាយាម រហូតទទួលបានជោគជ័យជាបន្តបន្ទាប់ដូចជាផ្នែកប្រវត្តិសាស្ត្រ នីតិសាស្ត្រ ភាសាបរទេស សេដ្ឋកិច្ច នយោបាយ ជាដើម។ កាលពីព្រះអង្គនៅជាយុវសិស្សនៅវិទ្យាល័យ ព្រះអង្គបានទទួលជោគជ័យផ្នែកអក្សរសាស្ត្រក្រិច និងឡាតាំង។ ទោះស្ថិតក្នុងពេលកំពុងសោយរាជ្យ ក៏ព្រះអង្គនៅបន្តវិជ្ជាជាមួយសាស្ត្រាចារ្យជាច្រើន ដើម្បីពង្រីកចំណេះវិជ្ជាឱ្យកាន់តែទូលាយថែមទៀត។ កាលនៅបឋមសិក្សានៅរាល់ដំណាច់ឆ្នាំនីមួយៗ ព្រះអង្គតែងទទួលបាននូវរង្វាន់ល្អប្រសើរបំផុតពីការសិក្សា។ នៅក្នុងដំណើរនៃឆាកជីវិតរបស់ព្រះអង្គចំពោះការសិក្សា គឺព្រះអង្គគ្រងរាជ្យបណ្តើរសិក្សាបណ្តើរ ដែលនេះជាការលំបាកមួយយ៉ាងខ្លាំងចំពោះព្រះអង្គ ប៉ុន្តែព្រះអង្គយកព្រះទ័យទុកដាក់ដោយសេចក្តីព្យាយាម រហូតទទួលបានជោគជ័យយ៉ាងត្រចះត្រចង់សម្រាប់ក្នុងឆាកជីវិតរបស់ព្រះអង្គ។ ក្រោយកាបញ្ចប់ថ្នាក់បឋមសិក្សា ព្រះបិតាព្រះអង្គម្ចាស់ **នរោត្តម សុរាម្រិត** បានចាត់សកម្មភាពក្រៅសាលារបស់ព្រះអង្គគឺសេចក្តីស្នេហាចំពោះ វិស័យភាពយន្ត ហើយបន្តយូរទៅទៀតអាចធ្វើឱ្យព្រះអង្គរាយមាយចំពោះការសិក្សានៅមធ្យមសិក្សា ទន្ទឹមពេលដែលព្រះអង្គមានព្រះតម្រិះថាព្រះអង្គ ត្រូវប្រឹងប្រែងដោយហ្មត់ចត់បំផុតដើម្បីទទួលបានជោគជ័យក្នុងជីវិត។

## ៤.សន្តតិវង្ស

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គជាព្រះរាជបុត្រដ៏ឆ្នើមរបស់ព្រះបាទ **នរោត្តម សុរាម្រិត** និងព្រះមហាក្សត្រីយានី ***ស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្នសិរីវឌ្ឍនា***។ ព្រះអង្គត្រូវជាព្រះរាជនត្តាទួត(ចៅទួត)របស់ព្រះបាទនរោត្តមខាងព្រះបិតា និង ត្រូវជាព្រះរាជនត្តាទួតរបស់ព្រះបាទស៊ីសុវត្ថិខាងព្រះមាតា។ សូមបញ្ជាក់ផងដែរសន្តតិវង្សខ្មែរយើងបច្ចុប្បន្នទាំងព្រះ

**ស៊ីសុវត្ថិ** និងព្រះ **នរោត្តម** គឺមានប្រភពតាំងពីព្រះអង្គអេង រហូតបន្តមកព្រះរាជបុត្រពៅរបស់ព្រះអង្គគឺព្រះអង្គដួង។ ព្រះអង្គដួងក៏បានបន្តមកព្រះរាជបុត្ររបស់ព្រះអង្គ មានដូចជាព្រះបាទ **នរោត្តម** និងព្រះបាទ **ស៊ីសុវត្ថិ** ជាដើម ហើយក្នុងចំណោមសន្តិវង្សទាំងពីរ សន្តតិវង្សនរោត្តម បានឡើងសោយរាជ្យមុន បន្ទាប់មកសន្តតិវង្សស៊ីសុវត្ថិ។ សន្តតិវង្សស៊ីសុវត្ថិ បានឡើងសោយរាជ្យបានពីរជំនាន់ (ពីព្រះបាទ **ស៊ីសុវត្ថិ** មកព្រះបាទ**ស៊ីសុវត្ថិ មុនីវង្ស**)បន្តបន្ទាប់គ្នាគឺពីព្រះបិតា មកព្រះរាជបុត្រ។ កាលដែលបារាំងលើកព្រះអង្គឱ្យឡើងគ្រងរាជ្យ ដោយសារបារាំងយល់ថាព្រះអង្គគឺជាអ្នកសិល្បៈមានអាកប្បកិរិយាល្អ ចរិកលក្ខណៈជាមនុស្សមិនឆេវឆាវ ហើយនិងមានការចង់ដោះដូរពីខ្សែនៃសន្តតិវង្សស៊ីសុវត្ថិ មកសន្តតិវង្សនរោត្តមវិញ។ ម្យ៉ាងទៀតបារាំងមានបំណងលុបបំបាត់អនុស្សាវរីយ៍ដ៏អាក្រក់រវាងបារាំងជាមួយព្រះអង្គ **យុគន្ធរ** ម្យ៉ាងទៀតបារាំងយល់ច្បាស់អំពីព្រះរាជសកម្មភាពរបស់របស់ព្រះអង្គ ថែមទាំងមានយុទ្ធសាស្ត្រទន់ភ្លន់ជាមួយបារាំង ជាមនុស្សធ្លាតវ័យ រហ័សរហួនពោលគឺមានភាពហ្មត់ចត់នៅពល់កាងារ។



ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ជាមួយព្រះមាតា និងព្រះបិតា

## ៥.រាជាភិសេកឡើងសោយរាជ្យ

កាលដែលព្រះអង្គឡើងគ្រងរាជ្យសម្បត្តិ ព្រះអង្គពុំដែលនឹកស្រម័យម្តងណាឡើយ ហើយពេលនោះស្របពេលដែលពិភពលោកជួបនិងសង្គ្រាមលោកលើកទី២ កំពុងឆាបឆេះ។ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ជាព្រះមហាវីរក្សត្រដ៏ឆ្នើម ដែលបានរំដោះប្រទេសឱ្យរួចផុតពីរបបអាណាព្យាបាលបារាំង ប្រកបដោយឯករាជ្យបរិបូណ៌ ប្រទេសឈានទៅរកភាពរុងរឿងរីកចម្រើនគ្រប់វិស័យ ថែមទាំងមានកិត្តិនាមល្បីល្បាញលើឆាកអន្តរជាតិ។ ព្រះអង្គបានឡើង

គ្រងរាជ្យសម្បត្តិបន្តពីព្រះអយ្យកោ(ជីតា)គឺ ព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ មុនីវង្ស ដែលបានយាងសោយទីវង្គតនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៤១ ក្នុងព្រះជន្ម១៩ព្រះវស្សា។ ការឡើងគ្រងរាជ្យរបស់ព្រះអង្គ នាំឱ្យមានការមិនសប្បាយចិត្តច្រើនពីសំណាក់រាជវង្សទាំងអស់នៅក្នុងព្រះបរមរាជវាំង ដោយគេផ្តោតទៅលើវ័យក្មេងខ្ចីរបស់ព្រះអង្គ។ ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានឡើងគ្រងរាជ្យសម្បត្តិពីរដង។

## ក.ការសោយរាជ្យលើកទី១

នៅខែមេសា ឆ្នាំ១៩៤១ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើសតាំង និងថ្វាយព្រះរាជឋានៈព្រះអង្គជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញបន្តពីព្រះករុណាព្រះបាទសម្តេចព្រះ **ស៊ីសុវត្ថិ មុនីវង្ស** (សិរីសុវត្ថិ មុនីវង្ស)។ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គឡើងគ្រងរាជ្យសម្បត្តិនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤១ ក្នុងព្រះជន្ម១៩ព្រះវស្សា[1]។

ប្រទេសកម្ពុជាតាំងពីបុរាណកាលមករហូតដល់សព្វថ្ងៃតែងតែប្រកាន់យកនូវរបបរាជានិយម។ ប្រការនេះហើយពីមួយជំនាន់ទៅមួយជំនាន់ គេឃើញមានព្រះមហាក្សត្របានឡើងសោយរាជ្យ បន្តរាជវង្សរបស់ខ្លួនជាបន្តបន្ទាប់ ដើម្បីគ្រប់គ្រងប្រទេសរហូតសម័យក្រោយៗទៀត។ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក៏ជាអតីតព្រះមហាក្សត្រមួយអង្គ ក្នុងចំណោមព្រះមហាក្សត្រខ្មែរជាច្រើនអង្គទៀតដែលធ្លាប់បានគ្រងរាជ្យសម្បត្តិពីមុនមក។ ព្រះរាជាអង្គនេះ ក្នុងសម័យកាលដែលទ្រង់គ្រប់គ្រងប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍១៩៦០ មានប្រជាប្រិយខ្លាំងណាស់ដោយមានប្រជារាស្ត្រខ្មែរប្រុសស្រី ចាស់ក្មេងបានគាំទ្ររហូតដល់នាំគ្នាហៅព្រះអង្គថា “**សម្តេចឪ**”។ ការថ្វាយព្រះបរមងារ ឬហៅយ៉ាងដូច្នោះពីព្រោះតែគេបានឃើញការដឹកនាំរបស់ព្រះអង្គ បានធ្វើឱ្យប្រទេសនិងប្រជារាស្ត្រនៅក្នុងសម័យនោះមានសេចក្តីសុខ សន្តិភាព មានឯករាជ្យអព្យាក្រឹត មានសេចក្តីថ្លៃថ្នូរមិនស្ថិតនៅក្រោមចំណុះប្រទេសដទៃជាដើម។ ការផ្តល់ព្រះកិត្តិយសទំនុកទុកចិត្តពីសំណាក់ប្រជារាស្ត្រ បានធ្វើឱ្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ប្រឹងប្រែងបញ្ចេញស្នាព្រះហស្តក្នុងការកសាងជាតិមាតុភូមិ។ បើទោះបីជាមានការលើកសរសើរនូវគុណសម្បត្តិរបស់ព្រះអង្គ យ៉ាងនេះក៏ដោយប៉ុន្តែទន្ទឹមគ្នានោះក៏មានប្រជាពលរដ្ឋនិងអ្នកនយោបាយធំៗ ជាច្រើននាក់ទៀតដែលនៅ

[1] រោងពុម្ពពន្លឺខ្មែរ ឆ្នាំ២០១៣ *ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឥស្សរជនអមតៈ* ទំព័រ៣៥

ក្រោមការគ្រប់គ្រងរបស់ព្រះអង្គក្នុងសម័យនោះ ខ្លះក៏មិនបានពេញចិត្ត និងគោលនយោបាយដឹកនាំប្រទេសរបស់ព្រះអង្គទេ ពិសេសគឺនៅក្នុងអំឡុងទសវត្សរ៍១៩៧០ រហូតដល់មានការធ្វើរដ្ឋប្រហារដែលដឹកនាំដោយលោកសេនាប្រមុខ **លន់ នល់** និងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរិមតៈ** ដើម្បីទម្លាក់ព្រះអង្គចេញពីតំណែងព្រះប្រមុខរដ្ឋនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ចាប់តាំងពីពេលនោះមកវិបត្តិនយោបាយរបស់អ្នកដឹកនាំប្រទេសកម្ពុជា ដែលគេដៅយ៉ាងសំខាន់ទៅលើសម្តេចព្រះ **នរោត្តម សីហនុ** ពេលនោះបានធ្វើឱ្យប្រទេសជាតិធ្លាក់ទៅក្នុងភ្នក់ភ្លើងសង្គ្រាមពុំរ៉ែផងដែរ។ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** មានប្រជាពលរដ្ឋខ្មែរខ្លះបានសរសើរព្រះអង្គថា គឺជាអ្នកដឹកនាំប្រទេសមួយមានលក្ខណៈខុសប្លែកពីបណ្តាអ្នកដឹកនាំប្រទេសដទៃនៅក្នុងសកលលោក។ លក្ខណៈខុសប្លែកនោះគឺព្រះអង្គត្រូវបានគេធ្វើរដ្ឋប្រហារទម្លាក់ចេញពីតំណែង ប៉ុន្តែទ្រង់នៅតែមានមធ្យោបាយអាចធ្វើឱ្យព្រះកាយព្រះអង្គបានវិលត្រឡប់មកគ្រងរាជ្យសម្បត្តិនៅប្រទេសកម្ពុជា សារជាថ្មីឡើងវិញពិសេសនៅឆ្នាំ១៩៩៣។ ប្រជាពលរដ្ឋដែលសរសើរនោះបានបញ្ជាក់ទៀតថា បើគេងាកទៅមើលអ្នកដឹកនាំ ក្នុងបណ្តាប្រទេសផ្សេងៗ លើសកលលោកដូចជានៅអារ៉ាប់ជាដើមនោះ តែកាលណាមានរដ្ឋប្រហារទម្លាក់ចេញពីដំណែងហើយ គឺកម្រឃើញវិលត្រឡប់មកកាន់តំណែងវិញណាស់។ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ត្រូវបានប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ និងមិត្តភក្តិបរទេសរបស់ព្រះអង្គជាច្រើនទទួលព្រះអង្គជាព្រះមហាក្សត្រមួយព្រះអង្គ ដែលមានសមត្ថភាពនិងមានព្រហ្មវិហារធម៌ដូចនឹងព្រះមហាក្សត្រីយានីមាតាព្រះអង្គដែរ។ ពុំនោះសោធព្រះអង្គពុំមានការរើសអើងចំពោះប្រជាពលរដ្ឋ គឺ ព្រះអង្គចូលចិត្តមនុស្សសាមញ្ញធម្មតា ហើយពួកគេក៏គោរពស្រឡាញ់ព្រះអង្គវិញដែរ។ ជាទូទៅព្រះអង្គមានការអធ្យាស្រ័យ ចេះអត់ឱនសណ្តោសប្រណី មិនយកទោសពៃរ៍អ្វីចំពោះការប្រមាថផ្សេងៗ ឬមានឥរិយាបទតឹងតែងទៅលើបុគ្គលណា ដែលមើលងាយដល់របបរាជាធិបតេយ្យរបស់ព្រះអង្គ។



ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**
ក្នុងពិធីគ្រងរាជ្យលើកទី១

## *ខ.ការសោយរាជ្យលើកទី២*

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានឡើងគ្រងរាជ្យសម្បត្តិសារជាថ្មីជាលើកទីពីរនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់ព្រះអង្គពីតំណែងកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បានធ្វើឱ្យព្រះអង្គឃ្លាតព្រះកាយឆ្ងាយពីរាជ្យបល្ល័ង្កអស់រយៈពេលច្រើនឆ្នាំ។ លុះក្រោយមកតាមរយៈជំនួបជំបូងរវាងព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** និងសមមិត្ត **ហ៊ុន សែន** ស្តីពីដំណោះស្រាយបញ្ហាកម្ពុជា ដើម្បីស្វែងរកសន្តិភាពដែលបានចាប់ផ្តើមនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ នៅហ្វែរអង់តាដឺន័រ (Fere-en-Taradenois) នៃប្រទេសបារាំង រហូតទទួលបានលទ្ធផលជាផ្លែផ្កាឈានទៅការបង្កើតកិច្ចព្រមព្រៀងក្រុងប៉ារីសនៅថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១។ ក្រោយមកនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ស្តេចយាងនិវត្តន៍មកកាន់រាជធានីភ្នំពេញវិញ ដើម្បីជួបជុំ កូនចៅ ចៅទួត របស់ព្រះអង្គ បន្ទាប់ពីព្រះអង្គបានឃ្លាតព្រះកាយយ៉ាងច្រើនឆ្នាំចេញពីប្រទេស។ ចាប់តាំងពីពេលនោះមកព្រះអង្គបានគង់នៅយ៉ាងសុខក្សេមក្សាន្ត ជាមួយកូនចៅ ប្រជានុរាស្ត្ររបស់ព្រះអង្គ រហូតដល់ពេលព្រះអង្គយាងសោយទៅវង្គត។ មុនពេលដែលព្រះអង្គយាងសោយទីវង្គត ដោយសារព្រះអង្គមានព្រះរាជសុខភាពមិនសូវល្អ ពិសេសដោយព្រះអង្គមានវ័យកាន់តែជរា ទើបព្រះអង្គសម្រេចព្រះទ័យយាងចូលនិវត្តន៍នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤។ ដោយសារគុណបំណាច់ដ៏ធំធេងរបស់ព្រះអង្គចំពោះជាតិ មាតុភូមិ ទើបរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានថ្វាយព្រះឋានៈព្រះអង្គជា «***ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ***»។



ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក្នុងពេលគ្រងរាជ្យលើកទី២

## ៦.ស្នេហា និងអាពាហ៍ពិពាហ៍

ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** មានមហេសីចំនួន៦ អង្គ និងមានព្រះរាជបុត្រា និងព្រះរាជបុត្រីចំនួន១៤ព្រះអង្គ។

១.អ្នកម្នាង**ផាតកាញ៉ុល** ជាមហេសីដំបូងដែលព្រះអង្គបានលង់ស្នេហ៍យ៉ាងងប់ងុល ព្រះនាងជាអតីតនាដការនីឯកនៃរបាំព្រះរាជទ្រព្យ បានរៀបអភិសេកជាមួយព្រះអង្គនៅឆ្នាំ១៩៤២ មានបុត្រ២ព្រះអង្គ៖




អ្នកម្នាង**ផាតកាញ៉ុល** (រូបភាពប្រភព: Colorise and Old Photo of  Cambodia)

•នរោត្តម បុប្ផាទេវី ប្រសូត្រឆ្នាំ១៩៤៣ និងសោយទីវង្គតនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៩



សម្តេចព្រះរាម **នរោត្តម បុប្ផាទេវី**

•នរោត្តម រណឫទ្ធិ ប្រសូត្រឆ្នាំ១៩៤៤និងសោយទីវង្គតនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១



សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ**

អ្នកម្នាង ផាតកាញ៉ុល បានបង្កដល់ក្តីអស់សង្ឃឹមដល់ព្រះអយ្យកោ និងដល់លោកជីបូដូ ដែលអង្វរឱ្យព្រះអង្គផ្តាច់ការទាក់ទងដើម្បីបញ្ចប់នូវស្ថានការមួយដែលពួកបារាំងនិងពួកគហបតីមួយចំនួនធំកំពុងចំអកឡកឡឺយ។ ប៉ុន្តែសេចក្តីស្នេហារបស់ព្រះអង្គត្រូវបានការពារដោព្រះមាតា ក៏ដូចជារូបព្រះអង្គដែរ។ ព្រះអង្គស្រឡាញ់រាប់អានអ្នកម្នាង**កាញ៉ុល** ហើយការពារនាងរហូតមួយជីវិតព្រះអង្គ ព្រមទាំងចិញ្ចឹមបីបាច់ចៅតូចៗ **បុប្ផាទេវី** និង**រណឫទ្ធិ** ដែលក្លាយទៅសំណព្វព្រះទ័យជាងគេក្នុងចំណោមបុត្រាបុត្រីទាំង១៤ របស់ព្រះអង្គ។

២.ព្រះអង្គម្ចាស់ក្សត្រី **ស៊ីសុវត្ថិ ពង្សាមុនី** រៀបអភិសេកនៅឆ្នាំ១៩៤២ មានបុត្រ៧ព្រះអង្គ៖



ព្រះអង្គម្ចាស់ក្សត្រី **ស៊ីសុវត្ថិ ពង្សាមុនី**(រូបភាពប្រភព: Colorise and Old Photo of  Cambodia)

•សម្តេចព្រះបរមរាមា **នរោត្តម យុវនាថ** ប្រសូត្រឆ្នាំ១៩៤៣និងសោយទីវង្គតនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២១



សម្តេចព្រះបរមរាមា **នរោត្តម យុវនាថ**

•សម្តេចក្រុមឃុន នរោត្តម រក្សវីវង្ស ប្រសូត្រឆ្នាំ១៩៤៤-១៩៧៣

•សម្តេចក្រុមព្រះ **នរោត្តម ចក្រពង្ស** ប្រសូត្រឆ្នាំ១៩៤៥



សម្តេច នរោត្តម ចក្រពង្ស (រូបភាពប្រភព Colorise and Old Photo of  Cambodia)

•ព្រះអង្គម្ចាស់ក្សត្រិយ៍ **នរោត្តម សុរិយារង្សី** ប្រសូត្រឆ្នាំ១៩៤៧-១៩៧៦



ព្រះអង្គម្ចាស់ក្សត្រិយ៍ **នរោត្តមសុរិយារង្សី**(ប្រភព: Colorise and Old Photo of  Cambodia)

•ព្រះអង្គម្ចាស់ក្សត្រិយ៍ **នរោត្តម គន្ធរបុប្ផា** ប្រសូត្រឆ្នាំ១៩៤៨-១៩៥២



ព្រះអង្គម្ចាស់ក្សត្រិយ៍ **នរោត្តម គន្ធរបុប្ផា**

•សម្ដេចក្រុមឃុន **នរោត្តម ខេមមានុរក្ស** ប្រសូត្រឆ្នាំ១៩៤៩-១៩៧៥?



សម្ដេចក្រុមឃុន **នរោត្តម ខេមមានុរក្ស** (រូបភាពប្រភព: Colorise and Old Photo of  Cambodia)

•ព្រះអង្គម្ចាស់ក្សត្រី **នរោត្តម បទុមបុប្ផា** ប្រសូត្រឆ្នាំ១៩៥១-១៩៧៦



ព្រះអង្គម្ចាស់ក្សត្រី **នរោត្តម បទុមបុប្ផា** (រូបភាពប្រភព: Colorise and Old Photo of  Cambodia)

ព្រះអង្គម្ចាស់ក្សត្រី **ស៊ីសុវត្ថិ ពង្សាមុនី** ត្រូវជាម្ដាយមីងរបស់ព្រះករុណាព្រះបាទ សម្ដេចព្រះ **នរោត្តម សីហនុ** ការជាប់សាច់ញាតិនេះពុំមានជាឧបសគ្គ ដល់អាពាហ៍ពិពាហ៍នៅក្នុងព្រះរាជវង្សានុវង្សកម្ពុជាឡើយ។ ព្រះអង្គម្ចាស់ក្សត្រី **ស៊ីសុវត្ថិ ពង្សាមុនី** ពេលត្រូវបាននាំខ្លួនមកបង្ហាញនៅក្នុងព្រះបរមរាជវាំង ដោយអ្នកស្រីណាត ក្នុងលេសថាមកថ្វាយបង្គំព្រះមាតាព្រះអង្គ ដែលធម្មតាជាអ្នកឃុំគ្រងកូនៗរបស់ស្ដេចមុនីវង្ស ដែលកាលនោះព្រះនាងទើបមានព្រះជន្ម ១៣ឆ្នាំកន្លះប៉ុណ្ណោះ។ នៅក្នុងវ័យនេះព្រះនាងធំពេញរូបរាងទៅហើយ។ រូបសម្ផស្សដ៏ស្រស់ល្អូតល្អន់របស់ព្រះនាង បានធ្វើឱ្យបេះដូងរបស់ព្រះអង្គ ញាប់ញ័រមួយរំពេច។ ដោយមិនឱ្យព្រះមាតាដឹង ព្រះអង្គបានតាមចែចង់ព្រះនាងជាបន្ទាន់។ រីឯព្រះនាងក៏ព្រមប្រគល់សេចក្ដីស្នេហាថ្វាយព្រះអង្គ ដោយមិនចាំបាច់ខាតពេលតុបតែងខ្លួនឡើយ។ សេចក្ដីស្នេហានោះមានរយៈពេល៩ឆ្នាំ(១៩៤២-១៩៥១) រហូតមានបុត្រាបុត្រី៧ព្រះអង្គ។ ស្នេហានេះមិនអាចឈានដល់អាពាហ៍ពិពាហ៍ទេ ដោយមានការជំទាស់ពីមហាក្សត្រីយានីចំណែកបារាំងក៏ប្រឆាំងនិងអាពាហ៍ពិពាហ៍នេះដែរ រហូតធ្វើឱ្យព្រះអង្គអស់សង្ឃឹមនិងមានបំណងដាក់រាជ្យទៀតផង។

៣.ព្រះអង្គម្ចាស់ក្សត្រីយ៍ **ស៊ីសុវត្ថិ មុនីកេសន** រៀបអភិសេកនៅឆ្នាំ១៩៤៣ មានបុត្រមួយព្រះអង្គ៖



*ព្រះអង្គម្ចាស់ក្សត្រីយ៍ស៊ីសុវត្ថិ មុនីកេសន (រូបភាព ប្រភព: ដំណើរខ្មែរ អតីតកាល)*

•***នរោត្តម ណារ៉ាទិប៉ូ*** *ប្រសូត្រថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៤៦(មិនដឹងឆ្នាំសោយទីវង្គត)*



*សម្តេច* ***នរោត្តម ណារ៉ាទិប៉ូ***

*ព្រះអង្គម្ចាស់ក្សត្រីយ៍* ***ស៊ីសុវត្ថិ មុនីកេសន*** *ព្រះអង្គជាបុត្រីរបស់ព្រះអង្គម្ចាស់* ***ស៊ីសុវត្ថិ មុនីវង្ស*** *និងស្នំម្នាក់គឺអ្នកស្រីតាត។*

*៤.ព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ*** *រៀបអភិសេកនៅឆ្នាំ១៩៥៥ពុំមានបុត្រទេ ព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ*** *ត្រូវជាប្អូនជីដូនមួយរបស់ព្រះករុណាព្រះបាទសម្តេចព្រះ* ***នរោត្តម សីហនុ*** *និងជាបុត្រីពៅរបស់ព្រះអង្គម្ចាស់ក្សត្រីយ៍ស៊ីសុវត្ថិ ថាវេត ដែលជាបងស្រីបង្កើតរបស់មាតាព្រះអង្គ។ រវាងព្រះអង្គ និង ព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ*** *អ្នកទាំងពីរធ្លាប់ស្គាល់រួមរស់ជាមួយគ្នាតាំងពីកុមារភាពម្ល៉េះ។ ព្រះមាតាអ្នកទាំងពីរ ជាបងប្អូនបង្កើតនឹងគ្នារស់នៅជាមួយគ្នាសឹងមិនអាចបំបែកពីគ្នាបាន។ ទ្រង់* ***នរោត្តម វាគ្រីវណ្ណ*** *ធ្លាប់បាននិយាយចែចូវព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ*** *និងព្រះមាតារបស់ម្ចាស់ក្សត្រីយ៍ ដើម្បីសុំរៀបអាពាហ៍ពិពាហ៍រវាងទ្រង់និងព្រះនាង។ ទ្រង់វាគ្រីវណ្ណ ធ្លាប់បានផ្សងព្រេងស្នេហាក្នុងរឿងស្នេហាច្រើនណាស់មុននិងរៀបអាពាហ៍ពិពាហ៍ជាមួយព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ*** *បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍មកទ្រង់ក៏មានស្នេហាផ្សេងទៀត។ នេះជាការមិនស្មោះត្រង់មិនគម្បីពិបាកទ្រាំទ្រយ៉ាងខ្លាំង។ ចំពោះព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ*** *ដែលជាម្ចាស់ក្សត្រីយ៍មួយព្រះអង្គ ប្រកបដោយគុណសម្បត្តិ ទាំងកាយនិងចិត្ត។ ទ្រង់វាគ្រីវណ្ណ និង ព្រះករុណាព្រះបាទសម្តេចព្រះ* ***នរោត្តម សីហនុ*** *ជាមិត្តជិតស្និទ្ធនិងគ្នាហើយនៅតែស្រឡាញ់រាប់អានគ្នាដដែលបន្ទាប់ពីការលែងលះគ្នាមក។ នាទសវត្សរ៍ឆ្នាំទី៥០ ព្រះករុណាព្រះបាទសម្តេចព្រះ* ***នរោត្តម***

***សីហនុ*** បានតែងតាំងទ្រង់ជាចាងហ្វាងពិធីការនៃព្រះបរមរាជវាំង ហើយជាញឹកញាប់ទ្រង់បានតាមហែរហម ព្រះករុណា ព្រះបាទសម្តេចព្រះ ***នរោត្តម សីហនុ*** ពេលព្រះអង្គយាងទៅប្រទេសបារាំង និងប្រទេសដទៃទៀត។ ដូចច្នេះព្រះករុណាព្រះបាទសម្តេចព្រះ ***នរោត្តម សីហនុ*** និងទ្រង់វាគ្រីវណ្ណមានការហួសចិត្តនៅពេលលឺគេ ពោលពាក្យអាក្រក់មួលបង្កាច់ថាទ្រង់វាគ្រីវណ្ណ លក់កិរិយាដើម្បីដូរយកកិត្តិយសធំៗ។ វាគ្រីវណ្ណជាព្រះអង្គម្ចាស់មួយអង្គដ៏ខ្ពង់ខ្ពស់ និងជាអ្នកមានទ្រព្យសម្បត្តិសំបូរហូរហៀរ ដូចច្នេះទ្រង់មិនត្រូវការកិត្តិយសថែមទៀត ឬលុយកាក់អ្វីទៀតឡើយ។

ព្រះអង្គម្ចាស់ក្សត្រីយ៍ ***នរោត្តម នល័ក្ខ*** ជាស្ត្រីមេម៉ាយ បានលែងលះស្វាមីរបស់ព្រះនាងគឺព្រះអង្គម្ចាស់ ***នរោត្តម វាគ្រីវណ្ណ*** នៅឆ្នាំ១៩៤៥។ ក្រោយមកបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះករុណាព្រះបាទសម្តេចព្រះ***នរោត្តម សីហនុ*** តែដោយព្រះករុណាព្រះបាទសម្តេចព្រះ ***នរោត្តម សីហនុ*** នៅតែទំនាក់ទំនងជាមួយ ***ម៉ូនិច អ៊ីហ្សូហ្ស៊ី*** និងក្រោយពីការចូលសោយទីវង្គត របស់ព្រះមហាក្សត្រីយ៍យានីកុសមៈជាព្រះមាតុច្ឆានាខែមេសា ឆ្នាំ១៩៧៥ ព្រះអង្គម្ចាស់ក្សត្រីយ៍ក៏បានដកថយព្រះកាយទៅរស់នៅក្នុងមជ្ឈមណ្ឌលសំរាប់ចូលនិវត្តន៍នៅប្រទេសបារាំង។



*ព្រះអង្គម្ចាស់ក្សត្រីយ៍* ***នរោត្តម នល័ក្ខ***
*(ប្រភព: ដំណើរខ្មែរ អតីតកាល)*

*៥.អ្នកម្នាង* ***ម៉ានីវណ្ណ ផានុវង្ស*** *រៀបអភិសេកនៅឆ្នាំ១៩៤៩ មានបុត្រ២ព្រះអង្គ៖*



*អ្នកម្នាង* ***ម៉ានីវណ្ណ ផានុវង្ស*** *(រូបភាពប្រភព:* Colorise and Old Photo of Cambodia)

- *នរោត្តម សូហ្សាតា ប្រសូត្រឆ្នាំ ១៩៥៣-១៩៧៥*

•នរោត្តម អរុណរស្មី ប្រសូត្រឆ្នាំ ១៩៥៥



អ្នកអង្គម្ចាស់ **នរោត្តម អរុណរស្មី**

នៅឆ្នាំ១៩៤៩ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ បានយាងសំរាកវិស្សមកាលនារដូវក្តៅនៅទីក្រុងវៀងច័ន្ទនៃប្រទេសឡាវ ដោយមានព្រះមាតុច្ឆា ព្រះអង្គម្ចាស់ក្សត្រីយ៍ **រស្មី** និងប៉ុំ (ម្ចាស់ក្សត្រីយ៍ប៉ុំ ជាប្អូនជីដូនមួយរបស់ព្រះមាតារបស់ព្រះអង្គ) បានយាងទៅជាមួយ និងមិត្តភក្តិបារាំងគឺលោក **ស៊ីគុពានី** ជាស្នងការនៃសាធារណរដ្ឋបារាំងប្រចាំនៅកម្ពុជា និងភរិយាបានទៅជាមួយដែរ។ នៅប្រទេសឡាវនារាត្រីមួយមានការប្រគុំតន្ត្រីរាំវង់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានបាក់ចិត្តស្រឡាញ់សិស្សនារីដ៏ស្អាតផូរផង់ម្នាក់មានអាយុ១៥ឆ្នាំនាងឈ្មោះ **ម៉ានីវណ្ណ ផានីវង្ស**។ ពួកក្រុមយុវជន យុវនារី ទាំងនោះតែងនាំគ្នាមកលេងនៅដំណាក់ព្រះអង្គពល់ល្ងាចដោយនាំយកឧបករណ៍ភ្លេងមកជាមួយផងពិសេសឧបករណ៍ភ្លេងគែន។ ក្នុងពេលនោះដែរព្រះអង្គបានលន្ទង់លន្ទោចទៅតាមបទភ្លេងដ៏ទន់ភ្លន់យ៉ាងពិរោះដក់ចិត្តស្តាប់គ្មានជិនណាយឡើយ ហើយរឹតគួរឱ្យសរសើរដែលជនជាតិឡាវមាននិស្ស័យខាងតូរ្យតន្ត្រីជាងជនជាតិខ្មែរយើង។ ព្រះអង្គឆ្ងល់យល់ថា **ម៉ានីវណ្ណ ផានីវង្ស** គឺជាបុប្ផាដែលស្រស់ជាងគេក្នុងចំណោមបុប្ផាមួយបាច់នោះ។ក្នុងខណៈនោះព្រះអង្គបានបេះយកបុប្ផានោះនិងនាំមកទីក្រុងភ្នំពេញ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍គឺព្រះមាតា បិតា របស់ព្រះអង្គមានការទទួលរាប់រកនាងដោយក្តីសោះអង្គើយ។

នៅក្រុងវៀងច័ន្ទឯនោះវិញ អ្នកស្រុករាប់បញ្ចូលទាំងព្រះសង្ឃ ដែលព្រះអង្គឧស្សាហ៍ទៅបង្គំគាល់ ពួកគេបានថ្លែងថាគេមានចិត្តសោមនស្សរីករាយ និងមានកិត្តិយសដោយឃើញព្រះអង្គបានចងភ្ជាប់ចំណងអាពាហ៍ពិពាហ៍ជាមួយយុវតីឡាវ ដែលមានដើមកំណើតជាកសិករ។ គេមិនមានការទាមទារឱ្យព្រះអង្គចុះឈ្មោះនាងជាភរិយាក្នុងបញ្ជីនៃព្រះបរមរាជវាំងឡើយ។ ប៉ុន្តែគេបានទូលព្រះអង្គអំពីជំនឿជនជាតិឡាវ ចំពោះទំនាក់ទំនងរវាងព្រះអង្គជាមួយនិង**ម៉ានីវណ្ណ ផានីវង្ស** នឹងនាំឱ្យគ្រួសាររបស់នាងជួបអពមង្គលប្រសិនបើព្រះអង្គពុំបានរៀបអាពាហ៍ពិពាហ៍នោះទេ យ៉ាងហោចណាស់ក៏រៀបចំជានិមិត្តរូបដែរ។ ដោយជាអ្នកគោរពប្រពៃណី

តាំងពីដើមមក ក៏ដូចជាការលើកតម្កើងកិត្តិយសដល់ព្រះបរមរាជវាំងនៃព្រះមហាក្សត្រខ្មែរ ព្រះមាតុច្ឆារបស់ព្រះអង្គ គឺព្រះអង្គម្ចាស់ក្សត្រីយ៍ **រស្មី** និងបុំ ក៏បានចាត់ចែងក្នុងក្តីរំភើបរីករាយយ៉ាងខ្លាំងរបស់ម្តាយនាងម៉ា**នីវណ្ណ ផានីវង្ស**(នាងជាកូនកំព្រាឪពុក) នូវពិធីអាពាហ៍ពិពាហ៍ជានិមិត្តរូបមួយ។ ពិធីនេះប្រព្រឹត្តិទៅដោយគ្មានវត្តមានព្រះអង្គ ព្រោះព្រះមហាក្សត្រពុំអាចលុតជង្គង់លើកន្ទេលក្បែររាស្ត្រសាមញ្ញឡើយ។ តាមក្បួនខ្លួនព្រះអង្គត្រូវបានតោងដោយព្រះរាជពស្ត្រ (អាវកុ តមានប៉ានប៉ាក់គ្រឿងតែងលំអ) ដែលលោកអាចារ្យលាតយ៉ាងស្អាតដាក់នៅលើខ្នើយ រំលេចជរក្បែរកូនក្រមុំ។ នៅឆ្នាំ១៩៧០ ព្រះអង្គហាក់បីដូចយកព្រះទ័យទុកដាក់តែលើ **ម៉ូនិច អ៊ីហ្សូហ្ស៊ី** ធ្វើឱ្យនាងសម្រេចចិត្តចូលទៅខាងពួកសាធារណៈរដ្ឋ។

៦.អ្នកម្នាង **ម៉ូនិច អ៊ីហ្សូហ្ស៊ី** រៀបអភិសេកនៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៥២



សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថសីហនុ** និងសម្តេចព្រះ **នរោត្តម សីហនុ** មានព្រះរាជបុត្រ២ព្រះអង្គ៖

•**នរោត្តម សីហមុនី** ប្រសូត្រឆ្នាំ ១៩៥៣



ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**

•**នរោត្តម ណារិន្ទ្រពង្ស** ប្រសូត្រឆ្នាំ ១៩៥៤-២០០៣



សម្តេចព្រះ **នរោត្តម សីហនុ** និងសម្តេច **នរោត្តម ណារិន្ទ្រពង្ស**

នៅខែមេសាឆ្នាំ១៩៥២ គឺជាការចាប់ផ្តើមនៃសេចក្តីស្នេហាដ៏ធំមួយរវាង ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** និង **ប៉ូល ម៉ូនិក អ៊ីហ្សហ្ស៊ី**(Paule Monique Izzi) ជាឈ្មោះដើម រហូតសំរេចបានជោគជ័យក្នុងការអូសទាញបេះដូង **ម៉ូនិច អ៊ីហ្សហ្ស៊ី** មកធ្វើជាភរិយា។ ព្រះអង្គបានទតឃើញម៉ូនិចអ៊ីហ្សហ្ស៊ី នាឱកាសនៃពិធីជ្រើសរើសបវរកញ្ញា ធ្វើឱ្យព្រះអង្គជាប់ហឫទ័យនិងសម្រស់នាងមួយរំពេច។ គ្រួសារព្រះអង្គ និងគ្រួសារ **ម៉ូនិច អ៊ីហ្សហ្ស៊ី** មានទំនាក់ទំនងគ្នាយូរណាស់មកហើយ។ ម្តាយរបស់ម៉ូនិចអ៊ីហ្សហ្ស៊ី គឺលោកស្រី **ប៉ុម ពាង** ឪពុករបស់លោកស្រី **ប៉ុម ពាង** ជាកូនចៅដ៏ជិតដិតស្និតស្នាល របស់ព្រះអង្គម្ចាស់ **នរោត្តម សុទ្ធារតន៍** ដែលជាព្រះអយ្យកោខាងព្រះបិតា ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ដែលជាដៃគូប្រកួត(គ្មានសំលេង)ដើម្បីរាជបល្ល័ង្កជាមួយនិងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ មុនីវង្ស** ជាព្រះអយ្យកោខាងព្រះមាតា។ ឪពុករបស់ **ម៉ូនិច អ៊ីហ្សហ្ស៊ី** គឺលោក **ហ្សង់ ហ្វ្រង់ស្វ័ អ៊ីហ្សហ្ស៊ី** (Jean François Izzi)ដែលឪពុករបស់លោកជាជនជាតិអ៊ីតាលីម្នាក់ចូលសញ្ជាតិបារាំង និងម្តាយជាតិបារាំងនៅប្រីតាញ។ លោក **ហ្សង់ ហ្វ្រង់ស្វ័ អ៊ីហ្សហ្ស៊ី** ជាមិត្តរបស់ព្រះអង្គម្ចាស់ **នរោត្តម សុរាម្រិត** តាំងពីយូរណាស់មកហើយ។ នៅឆ្នាំ១៩៣៩ លោកត្រូវបានកេណ្ឌជាអនុសេនីយ៍ទោបំរុងបន្ទាប់មកត្រូវបានបាត់ខ្លួន ក្នុងពេលពួកអាល្លឺម៉ង់វាយលុកប្រទេសបារាំងនាឆ្នាំ១៩៤០។ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានស្គាល់ម៉ូនិចបងប្រុសនិងបងស្រីរបស់នាង តាំងពីកំណើតរបស់ពួកគេម្ល៉េះ។ ម៉ូនិច ព្រះអង្គស្គាល់នាងជាយុវតីស្រស់ស្អាត រូសរាយកែវភ្នែករបស់នាងបានផ្តិតនូវពន្លកនៃសម្ផស្សស្អាតមានមន្តស្នេហ៍។ និយាយដោយស្មោះព្រះអង្គនឹកក្នុងចិត្តថា និងក្លាយទៅជាគូស្នេហ៍របស់នាងនៅថ្ងៃណាមួយមិនខាន។ សម្រស់ទឹកមុខញញឹមនិងភាពអំណត់អត់ធ្មត់របស់ ម៉ូនិច បានក្លាយជាចំណងឃាត់ឃាំង មិនឱ្យព្រះអង្គធ្វើការផ្សងព្រេងស្នេហាផ្សេងទៀតឡើយ ថ្វីត្បិតមានឱកាសនិងចំណង់ចេតនាច្រើនបានហុចឱ្យព្រះអង្គក៏ដោយ។ រហូតព្រះអង្គបានបង្ហាញពីសញ្ចេតនាស្នេហានេះថា: ព្រះអង្គនៅតែ ស្មោះត្រង់ទាំងស្រុងចំពោះ ម៉ូនិច ដែលប្រកបដោយគុណសម្បត្តិទាំងអស់ ស័ក្តិសមឱ្យព្រះអង្គក្លាយជាស្វាមីមួយដ៏មានគុណធម៌ត្រឹមត្រូវឬងាយនឹងស្តាប់បង្គាប់ក៏ថាបាន។ ព្រះអង្គបានសំរេចលាតត្រដាងឱ្យឃើញនូវទឹកចិត្តនេះ នៅក្រោយពិធីជ្រើសរើសបវរកញ្ញាដែលរៀបចំឡើង ក្រោមការឧបត្ថម្ភនៃអង្គការយូណេស្កូ(UNESCO)នៅវិទ្យាល័យស៊ីសុវត្ថិ។ ក្នុងចំណោមយុវនារីសិក្សា ឬធ្លាប់បានសិក្សានៅវិទ្យាល័យនេះ និងនៅវិទ្យាល័យបារាំងដេកាត៏ក្នុងក្រុងភ្នំពេញ។ ម៉ូ**និចអ៊ីហ្សហ្ស៊ី** ជានារីប្រកបដោយការអប់រំល្អ សុភាព

រាបសារ រមទម មានវប្បធម៌និងប្រាជ្ញាស្មារតីដ៏វៀងវៃ លើសពីនេះទៀតមានភាពស្រស់សង្ហារឥតខ្ចោះពីធម្មជាតិ ជាស្ត្រីបវរកញ្ញាកម្រជួបដែលរដ្ឋបុរសនិងអ្នកការទូតឧស្សាហ៍ ដើរហើរមាន មោទនភាព និងនាំជាប់តាមខ្លួនទាំងនៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស។ គ្រប់ទីកន្លែងដែលធ្វើដំណើរទៅសូម្បីតែប្រទេសកុម្មុយនីស្តក្តី ម៉ូនិច នាំឱ្យមានការកោតសរសើរឥតដាច់ចាប់តាំងពីអ្នកដឹកនាំជាន់ខ្ពស់បំផុតរហូតដល់មនុស្សសាមញ្ញបំផុត។ នៅឆ្នាំ១៩៥២ ម៉ូនិច មានបរមនាមជា **អ្នកម្នាង** ដោយសារ អ្នកម្នាង ម៉ូ**និច អ៊ីហ្សូហ្ស៊ី** មានលក្ខណៈល្អវិសេសវិសាលទើបនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩២ ព្រះអង្គបានប្រគល់ព្រះបរមនាមជា **ព្រះរាជជាយា** រហូតដល់ឆ្នាំ១៩៩៣ ព្រះអង្គមានព្រះបរមនាមជា **សម្តេចព្រះមហេសីនរោត្តម មុនិនាថ សីហនុ** និង ក្រោយមកទៀតព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានថ្វាយព្រះបរមនាមថ្មីមួយទៀតតែងតាំងព្រះមហេសីដ៏ជាទីស្នេហាដ៏មានភក្តីភាពរបស់ព្រះអង្គជា **សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ** នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៩៦ នេះជាការសមរម្យណាស់សំរាប់សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថសីហនុ** ដែលតាមដង្ហែព្រះអង្គដោយភក្តីភាព។ ចាប់ពីឆ្នាំ២០០៤រហូតមកដល់បច្ចុប្បន្នព្រះអង្គមានព្រះបរមនាមជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាពសេចក្តីថ្លៃថ្នូរនិងសុភមង្គល។**

## ៧.ការដាក់រាជ្យ

**-លើកទី១**

បន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យបរិបូណ៌ពីប្រទេសបារាំង មិនបានប៉ុន្មានឆ្នាំព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានដាក់រាជ្យសម្បត្តិនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥ ថ្វាយព្រះបិតារបស់ព្រះអង្គគឺព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សុរាម្រិត** ឱ្យឡើងគ្រងរាជ្យសម្បត្តិជំនួស ហើយពេលនោះព្រះអង្គក៏បានទទួលព្រះបរមនាមជា«**សម្តេចព្រះឧបយុវរាជ**»[2]។ ការដាក់រាជ្យសម្បត្តិនេះដើម្បីឱ្យព្រះអង្គមានពេលវេលាគ្រប់គ្រាន់ ក្នុងការដឹកនាំនិងស្តារប្រទេសជាតិឡើងវិញបន្ទាប់ពីទទួលឯករាជ្យពីបារាំង។ ម្យ៉ាងទៀតក្នុងសភាពការណ៍បែបនេះ គឺបានធ្វើឱ្យព្រះអង្គមានឱកាសចុះជាប់ផ្ទាល់ជាមួយប្រជានុរាស្ត្រគ្រប់មជ្ឈដ្ឋាន ដើម្បីជំរុញឱ្យសង្គមរាស្ត្រនិយមមានដំណើរល្អនិងរីកចំរើន។ ចាប់ពីពេលនោះមកទ្រង់ក៏បានបង្កើតនូវចលនាមួយហៅថា «**សង្គមរាស្ត្រ**

[2] BIOGRAPHIE de S.A.R. LE PRINCE NORODOM SIHANUK CHEF D'ETAT DU CAMBODGE

**និយម**» ដែលត្រូវបានបង្កើតនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៥៥ ដែលមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជារាស្ត្រខ្មែរ។ សង្គមរាស្ត្រនិយម គឺជាអង្គការតែមួយគត់ ដែលមានប្រជាប្រិយភាពក្នុងការគ្រប់គ្រងនិងដឹកនាំប្រទេស ហើយសង្គមរាស្ត្រនិយមបានបន្តដឹកនាំប្រទេសរហូតដល់ឆ្នាំ១៩៧០។ នៅពេលនោះ ដោយសារពួកគេមានការគោរព និងចូលចិត្ត គឺគេបាននាំគ្នាបោះឆ្នោតថ្វាយដើម្បីឱ្យព្រះអង្គធ្វើជាព្រះប្រមុខរដ្ឋ ដឹកនាំប្រទេសកម្ពុជា គឺនៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៥៥ (ព្រះអង្គក្លាយជាប្រមុខរដ្ឋនៃរាជរដ្ឋាភិបាលកម្ពុជា)។ ការផ្តល់ព្រះកិត្តិយសទំនុកទុកចិត្តពីសំណាក់ប្រជារាស្ត្រ បានធ្វើឱ្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ប្រឹងប្រែងបញ្ចេញស្នាព្រះហស្តក្នុងការកសាងជាតិមាតុភូមិ។ ស្នាព្រះហស្តដែលលេចធ្លោជាងគេហើយដែលប្រជាពលរដ្ឋពោលសរសើរគុណសម្បត្តិរបស់ព្រះអង្គនោះ គឺការទាមទារឯករាជ្យ រំដោះប្រទេសចេញពីនឹមត្រួតត្រាអាណាព្យាបាលបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ក្នុងពេលនោះព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានក្លាយទៅជាវីរបុរសស្នេហាជាតិដ៏ឆ្នើមមួយព្រះអង្គ និងជាតារាឯកកំពូល នៅក្នុងប្រទេស ក៏ដូចជានៅលើឆាកអន្តរជាតិ។ គោលនយោបាយនោះហើយបានធ្វើឱ្យប្រជារាស្ត្រខ្មែរនាសម័យនោះថ្វាយព្រះបរមនាមព្រះអង្គបន្ថែមទៀតថា «**ព្រះមហាវីរបុរសជាតិនិងជាព្រះបិតាឯករាជ្យជាតិ**» ពីព្រោះទ្រង់បានរក្សាការពារបូរណភាពទឹកដីកម្ពុជា និងធ្វើឱ្យសង្គមរាស្ត្រនិយមកាន់តែរីកចំរើននៅគ្រប់វិស័យ។

**-លើកទី២**

ដោយសារមានបញ្ហាផ្នែកព្រះរាជសុខភាព ព្រះអង្គបានសម្រេចព្រះទ័យដាក់រាជ្យសម្បត្តិនាថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៤ ឱ្យទៅបុត្រារបស់ព្រះអង្គគឺសម្តេចក្រុមឃុន **នរោត្តម សីហមុនី**។ ជាញឹកញាប់ព្រះអង្គតែងយាងទៅពិនិត្យព្រះរាជសុខភាព ជាមួយក្រុមគ្រូពេទ្យដ៏ចំណានៗនៅឯទីក្រុងប៉េកាំង។ សម្តេចក្រុមឃុន **នរោត្តម សីហមុនី** បានអភិសេកឡើងគ្រងរាជ្យសម្បត្តិនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤។ ពេលនោះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានថ្វាយព្រះឋានៈព្រះអង្គជា «***ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមមហាក្សត្រ ខេមរជនាសម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី***»។ រហូតមកដល់បច្ចុប្បន្ន ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះអង្គនៅរក្សា និងធ្វើតាមគំរូព្រះបិតារបស់ព្រះអង្គជាដរាប។

## ៨.ការសាងព្រះផ្នួស

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក្នុងដំណើរឆាកជីវិតរបស់ព្រះអង្គបានពុះពារឆ្លងកាត់គ្រប់ដំណាក់កាលនិងគ្រប់ឧបសគ្គ។ ការសាងព្រះផ្នួសតាមផ្លូវព្រះពុទ្ធសាសនា គឺជាទំនៀមទម្លាប់ប្រពៃណីខ្មែរដែលកូនប្រុស តែងតែបួសសងគុណមាតា បិតា។ ក្រោយពីការបញ្ចប់ពីការសាងព្រះផ្នួសយុវជនជនខ្មែរទទួលបាននូវការអប់រំល្អ សីលធម៌ ពីព្រះសង្ឃធ្វើឱ្យពួកគេក្លាយជាមនុស្សល្អរស់នៅក្នុងសង្គម ហើយមានអ្នកខ្លះទៀតដែលមានចិត្តជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាបួសរហូតក៏មាន។ ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះអង្គបានសាងព្រះផ្នួសនៅខែមិថុនា ឆ្នាំ ១៩៤៧ ដោយគង់នៅវត្តបុទុមវត្តី ព្រះអង្គបានលាពីព្រះផ្នួសវិញនៅខែកញ្ញា ឆ្នាំ ១៩៤៧ បន្ទាប់បានរៀនសូត្រយ៉ាងច្រើន ពីសំណាក់ព្រះគ្រូទាំងឡាយដូចជា ព្រះតេជគុណ **កែវ អ៊ូច** សម្តេចព្រះសង្ឃរាជជួនណាត ព្រះតេជគុណទេស និងព្រះតេជគុណ **ហ៊ួត តាត** ដែលព្រះអង្គទាំងអស់សុទ្ធតែជាអ្នកមានចំណេះវិជ្ជាជ្រៅជ្រះ។ បីខែជារយៈពេលមួយយ៉ាងខ្លីណាស់ពុំគ្រប់គ្រាន់ឡើយ គេគប្បីត្រូវចំណាយពេលសិក្សា និងសមាធិ៣០ឆ្នាំដើម្បីឱ្យបានជ្រួតជ្រាបពិតប្រាកដ នូវសច្ចៈធម៌ដ៏ជ្រាលជ្រៅ និងគាស់កកាយរកឱ្យឃើញនូវធនធានកេមរតក៌ នៃធម៌របស់ព្រះពុទ្ធ។ ទោះយ៉ាងណាក្តី រយៈពេលមួយខែនៃការសិក្សាក្នុងសាសនា និងដោយមានមូលដ្ឋានលើចំណេះចេះដឹងទូទៅ លើមេរៀនទស្សនវិជ្ជារបស់អធិការនាយក **ក័របេត៍** និងលើការសិក្សាស្តីពីពុទ្ធសាសនារបស់លោក **សឺដែស** និងលោក **ហ្គូលូបេវ** នៅសាលាបាពាំងចុងបូព៌ា ព្រះអង្គក៏សំរេចបាននូវការតាក់តែងអត្ថបទដ៏សមសួន សំរាប់ការទេសនារបស់ព្រះអង្គប្រចាំសប្តាហ៍ដែលទ្រង់សំដែងឡើងនៅចំពោះមុខអ្នកស្តាប់ដ៏ច្រើន និងយកចិត្តទុកដាក់។ ធម៌ទេសនារបស់ព្រះអង្គត្រូវបានធ្វើឡើងនៅថ្ងៃសីល ដោយឡែកថ្ងៃសីលក្នុងមួយខែមានមានបួនដង ហើយថ្ងៃសីលដែលសំខាន់ ជាងគេ គឺពិសាខបូជាថ្ងៃពេញបូណ៌មីនៃខែឧសភា ជាថ្ងៃរំលឹកខួបកំណើតពេលត្រាស់ដឹង និងថ្ងៃយាងចូល ព្រះបរិនិព្វាន របស់ព្រះសម្មាសម្ពុទ្ធ។ រាល់ពេលព្រះអង្គទ្រង់សំដែងធម្មទេសនា បានទាក់ទាញ យកចិត្តទុកដាក់ ពិសេសពេលទេសនាតាមរបៀបមិនសូវតាមគម្ពីរដើមពេក និងស្រដៀងរបៀបក្វាស៊ីកបាពាំងដែលគេបានបង្រៀនព្រះអង្គនៅវិទ្យាល័យបាពាំងសាសលូឡូបា (CHASSELOUP LAUBAT)។ ធម៌ទេសនាទាំងនោះបានរំលេចនូវភាពត្រឹមត្រូវ នៃទ្រឹស្តីរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ហើយក្នុងធម្មទេសនានោះដែរព្រះអង្គបានបញ្ចេញបញ្ចូលដោយសមហេតុផល នូវរឿងដំណាលអ្វីៗនិយាយអ្នកបួសនៅប្រទេសចិន ពិសេស

នៅទីបេដែលបានដកស្រង់ចេញពីសៀវភៅទាំងឡាយរបស់ **ហ្គូលូបេវ** ដោយពុំមានគេដឹងឡើយ ក្នុងចំណោមពុទ្ធសាសនិកខ្មែរ។ សាលាបារាំងចុងបូព៌ា ដើម្បីសំដែងនូវអំណរគុណចំពោះការដកស្រង់ ផ្សព្វផ្សាយយ៉ាងទូលំទូលាយ នូវស្នាដៃស្រាវជ្រាវដោយសមាជិកថ្មីៗរបស់គេ ពួកគេបានថ្វាយព្រះឋានៈជូនព្រះអង្គ ជាសមាជិកកិត្តិយសរបស់សាលានោះ។ នៅរាល់សកម្មភាពរបស់ព្រះអង្គ ទាំងការគ្រងស្បង់ចីពរការកោរព្រះកេសកោរចិញ្ចើម ដំណើរដើងទទេគ្រប់ពេលវេលា និងសព្វទីកន្លែង ការបិណ្ឌបាត្រក្នុងក្រុងជារៀងរាល់ថ្ងៃជាមួយបព្រះសង្ឃដ៏ទៃទៀត នាំឱ្យគេចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស។ ការសែតបរទេសបានចុះផ្សាយរូបថតនានា និងធ្វើអត្ថាធិប្បាយផ្សេងៗស្ដីពី ព្រះសង្ឃស្ដេចពុទ្ធសាសនិកទាំងឡាយ នៅទ្វីបអាស៊ីក៏មានបីតិសោមនស្សរីករាយ។ ប្រជារាស្ត្រដែលប្រកបដោយទឹកមេត្តាមេត្តាសប្បុរស ក៏បង្ហាញឱ្យឃើញនូវសមាណចិត្តយ៉ាងក្លៀវក្លាសទ្ធាជ្រះថ្លាមិនធ្លាប់ដែលមានពីមុនមក។ នៅពេលដែលព្រះនិមន្តបិណ្ឌបាទម្ដងៗ ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈប្រដែងគ្នាដណ្ដើមដាក់ចង្ហាន់ដ៏មានឱជារស មានទាំងនំចំណីនិងបាយនៅក្នុងបាត្ររបស់ព្រះអង្គ។ រៀងរាល់ថ្ងៃព្រះអង្គទទួលបានចង្ហាន់ យ៉ាងច្រើនលើសលប់ពីសំណាក់ប្រជាពលរដ្ឋ រហូតមានរថយន្តព្រះបរមរាជវាំងដឹកយកទៅចែកចាយប្រគេនដល់ព្រះសង្ឃដ៏ទៃទៀតដែលព្រះអង្គមិនសូវបិណ្ឌបាតបាន។ ដោយសាចិត្តសទ្ធាជ្រះថ្លាបែបហ្នឹង ព្រះអង្គមានការព្រួយបារម្ភដល់ការរៀបចំចង្ហាន់ដ៏មានឱជារស យ៉ាងច្រើនលើសលប់នេះ ព្រមទាំងការចំណាយនូវធនធានយ៉ាងច្រើន ក្នុងការរៀបចំចង្ហាន់ទាំងនេះសំរាប់ព្រះអង្គ។ បន្ទាប់មកអ្វីៗក៏ស្រួលបួលឡើងវិញ ហើយវស្សាក៏បានមកដល់ទីបញ្ចប់។ ព្រះអង្គបានត្រឡប់មកជីវភាពជាគ្រហស្ថវិញក្នុងក្ដីត្រេកត្រអាលផ្សេងៗដែលនាំឱ្យកាន់តែឃ្លាតឆ្ងាយពីនិព្វាន្ត។



ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ**
ក្នុងពេលសាងព្រះផ្នួស

## ៩.ព្រះរាជសកម្មភាព

ចាប់តាំងពីឆ្នាំ១៩៤១ រហូតពេលព្រះអង្គយាងសោយទីវង្គត ពិសេសក្នុងពេល

ដែលព្រះអង្គដឹកនាំប្រទេស ព្រះអង្គបាន បន្សល់ទុកនូវព្រះរាជសកម្មភាពនិងសមិទ្ធផល យ៉ាងច្រើនសន្ធឹកសន្ធាប់ជូនជាតិមាតុភូមិ។ ព្រះរាជសកម្មភាពរបស់ព្រះអង្គ មានតាំងពី ក្នុងប្រទេសរហូតដល់ក្រៅប្រទេស ជាញឹក ញាប់ព្រះអង្គតែងចូលរួមប្រជុំ និងពិភាក្សា ជាមួយថ្នាក់ដឹកនាំកំពូលៗ ថែមទាំងមានវ័យ ចាស់ៗទៀតផង។

នៅឆ្នាំ១៩៤៦ ព្រះអង្គបានយាង ទស្សនកិច្ចជាលើកដំបូងនៅប្រទេសបារាំង តាមការអញ្ជើញរបស់លោកប្រធានាធិបតី FELIX GOUIN និងបានជួបលោកឧត្តម សេនីយ៍ **សាល ដឺហ្គោល** (CHARLES de GAULLE) នៅ COLOMBEY។

ក្នុងឆ្នាំ១៩៤៧ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គមានមហាជោគជ័យ ក្នុងការទាមទារឱ្យរាជាណាចក្រថៃឡង់ដ៍ សងមកព្រះរាជាណាចក្រកម្ពុជាវិញជាដាច់ ខាតនូវខេត្តខ្មែរ ដែលក្នុងពេលមាន សង្គ្រាម លោកលើកទី២ ថៃឡង់ដ៍បានយកពីកម្ពុជា ទៅ គឺខេត្តបាត់ដំបង សៀមរាប កំពង់ធំ ស្ទឹងត្រែង។

ឆ្នាំ១៩៤៩ ព្រះករុណា ព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ** បានទាមទារឱ្យប្រទេស បារាំងបញ្ឈប់នូវសន្ធិសញ្ញាអាណាព្យាបាល ដែលបានចុះហត្ថលេខានៅឆ្នាំ១៨៦៣ និងឆ្នាំ ១៨៨៤។ នៅឆ្នាំ១៩៤៩ ដដែលព្រះអង្គបាន ឡាយព្រះហស្ថលេខា លើសន្ធិសញ្ញាឯករាជ្យ ដែលប្រទេសបារាំងព្រមទទួលស្គាល់តាមផ្លូវ ច្បាប់នូវឯករាជ្យរបស់ប្រទេសកម្ពុជា។ សន្ធិ សញ្ញាឆ្នាំ១៩៤៦ នេះលុបចោលនូវសន្ធិ សញ្ញាអាណាព្យាបាលឆ្នាំ១៨៦៣ និងឆ្នាំ ១៨៨៤។

ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៣ ព្រះ ករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានយាង បំពេញព្រះរាជបូជនីយ កិច្ចទាមទារកេតនភណ្ឌឯករាជ្យទាំងស្រុង ១០០% ជូនជាតិមាតុភូមិ ។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយ ស្នាព្រះហស្ថដ៏ឧត្តុងឧត្តមរបស់ព្រះអង្គ ព្រះ រាជាណាចក្រកម្ពុជាបានទទួលឯករាជ្យ ទាំងស្រុងពីសាធារណរដ្ឋបារាំង។ ប្រជារាស្ត្រ ទូទាំងប្រទេស សូមថ្វាយព្រះកិត្តិនាមព្រះអង្គ ជា " ***ព្រះមហាវីរបុរសជាតិ ព្រះបិតាឯករាជ្យជាតិ*** "។

នៅឆ្នាំ១៩៥៤ ព្រះអង្គបានបញ្ជូនរាជគ ណៈប្រតិភូ ជាតំណាងរបស់ព្រះអង្គទៅចូល រួមនៅក្នុងសន្និសីទអន្តរជាតិស្តីពីបញ្ហា ឥណ្ឌូចិននៅទីក្រុងហ្សឺណែវ (GENEVE) ដែលមានប្រទេសកម្ពុជាចូលរួមក្នុងឋានៈជា រដ្ឋឯករាជ្យឯកភាពជាតិ។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥ ព្រះ ករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបាន ដាក់រាជ្យថ្វាយព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សុរាម្រិត** ជា ព្រះរាជបិតា។ ព្រះករុណា ព្រះបាទសម្តេច

*ព្រះ **នរោត្តម សុរាម្រិត** ព្រះអង្គបានប្រទាន ចំពោះព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** នូវព្រះបរមងារជា "**សម្តេចព្រះឧបយុវរាជ នៃព្រះរាជាណាចក្រកម្ពុជា**"។*

*ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៥៥ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបាន បង្កើតចលនាសង្គមរាស្ត្រនិយម ដែលមានគណបក្សជាច្រើនចូលរួមក្នុងចលនានេះ។*

*ពីថ្ងៃទី១៨ ដល់ ២៤ ខែមេសា ឆ្នាំ ១៩៥៥ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានយាងចូលរួមក្នុងសន្និសីទកំពូលអាហ្វ្រិក-អាស៊ីលើកទី១ នៅទីក្រុងបាន់ឌុង (ប្រទេសឥណ្ឌូណេស៊ី) ហើយនៅទីនោះ ព្រះអង្គបានប្រកាសពីនយោបាយអព្យាក្រឹតក្នុងឯករាជ្យទាំងស្រុង និងសន្តិសហវិជ្ជមាន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសទាំងអស់ដោយមិនគិតពីមនោគមវិជ្ជាឡើយ។ ព្រះអង្គបានជួបជាលើកដំបូងជាមួយនឹងលោក **ហ្សាវ៉ាហារឡាល់ នេរូ** (JAWAHARLAL NEHRU) នាយករដ្ឋមន្ត្រីឥណ្ឌា, លោក **ហ្គាម៉ាល់ អាប់ដែលណាស៊ែរ** (GAMAL ABDEL NASSER) ប្រធានាធិបតីសាធារណៈរដ្ឋអារ៉ាប់រួម, លោក **អាម៉េត ស៊ូការណូ** (AHMED SUKARNO) ប្រធានាធិបតីឥណ្ឌូណេស៊ី, លោក **ជូ អេនឡាយ** (ZHOU EN LAI) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន។ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានទទួលមហាជោគជ័យក្នុងការបោះឆ្នោតសភាជាតិ ដោយបានទទួលការគាំទ្រពីប្រជារាស្ត្រខ្មែរច្រើនលើសលុប។ ព្រះអង្គបានទទួលព្រះរាជឋានៈជានាយករដ្ឋមន្ត្រី ហើយក្នុងព្រះឋានៈជាប្រមុខនៃ ប្រជារាស្ត្រខ្មែរព្រះអង្គបានបំពេញព្រះរាជកិច្ចដឹកនាំដើម្បីអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា។ ជាទូទៅក្នុងគ្រប់វិស័យនៃការកសាងជាតិរបស់ព្រះអង្គ ជាពិសេសការលើកស្ទួយនារីឱ្យមានសិទ្ធិស្មើភាព នឹងបុរសក្នុងការងារ។*

*ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៥៥ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ។*

*ឆ្នាំ១៩៥៦នៅប្រីយ៉ូនី (BRIONI) នៃសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានក្លាយជាបិតាស្ថាបនិកទី៥ ចលនាមិនចូលបក្សសម្ព័ន្ធ ដោយបានឡាយព្រះហស្ថលេខា លើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ បន្ទាប់ពីអ្នកផ្តួចផ្តើមគំនិតដ៏សំខាន់ ៤រូបទៀត: លោក **ហ្សូស៊ីប ប្រូស ទីតូ** (JOSIP BROZ TITO) ប្រធានាធិបតីយូហ្គោស្លាវី,លោក **ហ្សាវ៉ាហារឡាល់ នេរូ** (JAWAHARLAL NEHRU) នាយករដ្ឋមន្ត្រីឥណ្ឌា, លោក **ហ្គាម៉ាល់ អាប់ដែលណាស៊ែរ***

(GAMAL ABDEL NASSER) ប្រធានាធិបតីសាធារណៈរដ្ឋអារ៉ាប់រួម និង លោក **អាម៉ែត ស៊ូការណូ** (AHMED SUKARNO) ប្រធានាធិបតីឥណ្ឌូណេស៊ី ។

នៅខែកុម្ភៈ ឆ្នាំ១៩៥៦ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក្នុងព្រះឋានៈជានាយករដ្ឋមន្ត្រី ព្រះអង្គបានយាងទៅបំពេញទស្សនៈកិច្ចជាផ្លូវរដ្ឋនៅ សាធារណរដ្ឋប្រជាមានិតចិន នឹងបានជួបជាមួយថ្នាក់ដឹកនាំចិនជាច្រើនរូប មានឯកឧត្តមលោកប្រធាន **ម៉ៅ សេទុង** (MAO TSE-TUNG) ហើយព្រះអង្គក៏បានឡាយព្រះហស្ថលេខាលើសេចក្តីប្រកាសរួមស្តីពីមិត្តភាព កម្ពុជា-ចិន។



ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**និងលោកប្រធាន **ម៉ៅ សេទុង**

នៅឆ្នាំ១៩៦០ ក្នុងខណៈដែលព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សុរាម្រិត** ទ្រង់សោយព្រះទីវង្គត ពេលនោះព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ត្រូវបានសមាជិកសភាខ្មែរបានសម្រេចជាឯកច្ឆ័ន្ទ ជ្រើសតាំងព្រះអង្គជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងព្រះឋានៈនេះ ព្រះអង្គបានបន្តការដឹកនាំប្រជារាស្ត្រខ្មែរ ក្នុងព្រះរាជកិច្ចកសាងជាតិមាតុភូមិយ៉ាងសកម្មជាទីបំផុត។

ខែកញ្ញា ឆ្នាំ១៩៦០ នៅមហាសន្និបាតអង្គការសហប្រជាជាតិព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានលើកឡើងនូវផែនការបង្កើតនៅអាស៊ីអាគ្នេយ៍ជាតំបន់អព្យាក្រឹត រវាងប្លុកមហាអំណាចទាំងពីរ ។

នៅខែឧសភា ឆ្នាំ១៩៦១ តាមព្រះរាជតម្រិះផ្តួចផ្តើមរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** សន្និសីទអន្តរជាតិមួយត្រូវបានបង្កើតឡើងនៅទីក្រុងហ្សឺណែវ (GENEVE) ដើម្បីដោះស្រាយទំនាស់ រវាងភាគីទាំង៣នៅប្រទេសឡាវ។



សម្តេចព្រះ **នរោត្តម សីហនុ** នៅទីក្រុងហ្សឺណែវ

*ចាប់ពីខែ ឧសភា ឆ្នាំ ១៩៦១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបាន បំពេញព្រះរាជបេសកកម្មនយោបាយការទូត ដើម្បីទាមទារប្រាសាទព្រះវិហារជាសម្បត្តិវប្បធម៌បេតិកភណ្ឌជាតិខ្មែរមកវិញពីប្រទេសថៃ ដោយតុលាការក្រុងឡាអេ* (LA HAYE) *បានសម្រេចប្រគល់មកព្រះរាជាណាចក្រកម្ពុជាវិញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២។*

*នៅខែវិច្ឆិកា ឆ្នាំ១៩៦១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានយាង ចូលរួមក្នុងសន្និសីទកំពូលលើកទី១ នៃចលនាមិនចូលបក្សសម្ព័ន្ធនៅបែលក្រាដ* (BEILGRADE) *នៃប្រទេសយូហ្គោស្លាវីដែលក្នុងនោះមាន២៩ប្រទេសចូលរួម។ នៅទីនោះព្រះអង្គបានថ្កោលទោសចំពោះអំពើរបស់ពួកអាណានិគមនិយមចក្រពត្តិនិយមនិងការប្រកាន់ពូជសាសន៍។*

*នៅខែមិថុនា ឆ្នាំ១៩៦៤ លោកឧត្តមសេនីយ៍ **សាលដឺហ្គោល*** (CHARLES de GAULLE) *ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង បានរៀបចំបដិសណ្ឋារកិច្ចជាឱឡារិកថ្វាយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** នៅទីក្រុងប៉ារីស។ លោកប្រធានាធិបតីបានទទួលដោយស្មោះស នូវសំណើររបស់ភាគីកម្ពុជា ស្តីពីការទទួលស្គាល់អព្យាក្រឹតភាពនៃព្រះរាជាណាចក្រកម្ពុជា។*

*នៅចុងខែសីហា និងដើមខែកញ្ញា ឆ្នាំ១៩៦៦ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានរៀបចំបដិសណ្ឋារកិច្ចទទួលជាឱឡារិក លោកឧត្តមសេនីយ៍ **សាលដឺ ហ្គោល*** (CHARLES de GAULLE) *ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ដែលបានមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។*

*ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៦៦ នៅក្នុងសុន្ទរកថាដែលថ្លែងនៅពហុកីឡាដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ លោកប្រធានាធិបតីបានគាំទ្រព្រះរាជាណាចក្រកម្ពុជា ដែលការពារឯករាជ្យ បូរណភាពទឹកដីអព្យាក្រឹតសន្តិភាព នៃខ្លួន។*



*សម្តេចព្រះ **នរោត្តម សីហនុ** និងលោកឧត្តមសេនីយ៍ **សាលដឺហ្គោល*** (ឆ្នាំ១៩៦៦)

ពីថ្ងៃទី២៦ ខែវិច្ឆិកា ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ ១៩៦៦ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានយាងជាព្រះរាជធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសព្រះរាជពិធីបើកនិងបិទការប្រកួតកីឡា GANEFO អាស៊ីលើកទី១។

## ១០.សមិទ្ធផល

ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ក្នុងសម័យសង្គមរាស្ត្រនិយម ដែលប្រជារាស្ត្រខ្មែរបានថ្វាយព្រះនាមព្រះអង្គថាជា ***ព្រះបិតាឯករាជជាតិ ព្រះបិតាសិក្សាធិការជាតិ ព្រះបិតាសុខាភិបាលជាតិ ព្រះបិតាកីឡាជាតិ និងព្រះបិតាស្ថាបនាជាតិ***។ ព្រះកិត្តិនាមរបស់ព្រះអង្គបានល្បីសុះសាយខ្ទាំងនាសម័យសង្គមរាស្ត្រនិយម ហើយគេក៏ចាប់ស្គាល់ព្រះនាមរបស់ព្រះអង្គកាន់តែច្បាស់ គឺនៅពេលដែលប្រទេសកម្ពុជាទទួលជ័យជម្នះលើរឿងក្តីជាមួយសៀមអំពីប្រាសាទព្រះវិហារ។ សង្គមរាស្ត្រនិយមរីកចម្រើនរុងរឿងដល់ចំណុចកំពូលនៅឆ្នាំ១៩៦៣ នៅក្នុងសម័យនោះយើងឃើញមានសមិទ្ធផលធំៗនានាជាច្រើនបានត្រូវកសាងឡើងព្រោងព្រាត និងហើយក៏ឃើញមានការប្រារព្ធព្រះរាជពិធីសម្ពោធជាបន្តបន្ទាប់សម្រាប់ដាក់ឱ្យប្រជារាស្ត្រប្រើប្រាស់នៅតាមបណ្តាខេត្ត-ក្រុងនានា។ សមិទ្ធផលទាំងនោះមានជាដូចជា ៖

- វិមានឯករាជ្យ
- វិមានរដ្ឋចំការមន
- ចំណតអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង
- ចំណតអាកាសយានដ្ឋាអន្តរជាតិសៀមរាប
- ចំណតអាកាសយានដ្ឋាន បែកចានខេត្តបាត់ដំបង
- ផ្លូវជាតិលេខ ៤ ភ្នំពេញ - ក្រុងព្រះសីហនុ
- ផ្លូវដែកក្រុងភ្នំពេញ-ក្រុងព្រះសីហនុ
- កំពង់ផែអន្តរជាតិ ក្រុងព្រះសីហនុ
- សណ្ឋាគារ "ឯករាជ្យ" ក្រុងព្រះសីហនុ
- សាលមហោស្រពជាតិ "ព្រះសុរាម្រិត" ភ្នំពេញ
- សាលសន្និសីទ "ចតុមុខ"
- ពហុកីឡាដ្ឋានជាតិ អូឡាំពិក ភ្នំពេញ
- ស្ពានព្រះមុនីវង្សទី ២
- ស្ពាន "សង្គមរាស្ត្រនិយម" ឆ្លងកាត់ទន្លេសាប(ស្ពានជ្រោយចង្វារ)។
- សាកលវិទ្យាល័យ "សង្គមរាស្ត្រនិយម" ភ្នំពេញ (Université "SangkumReastrNiyum")
- សាកលវិទ្យាល័យ ភូមិន្ទបច្ចេកទេស (Université Technique Royale)

- សាលាភូមិន្ទរដ្ឋបាល (Ecole Royale d' administration)
- មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច(Faculté de Droit et des Sciences Economiques)
- មហាវិទ្យាល័យ គរុកោសល្យ(Faculté de pédagogie)
- ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ (UniversitéBouddhiquepreahsihanoukrij)
- មហាវិទ្យាល័យសិល្ប:ស្ថាបនា(Faculté de Génie Civil)
- មហាវិទ្យាល័យ សិល្ប: និង មុខរបរ (Faculté des arts et Métiers)
- សាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្ប: (Université Royale des beaux arts)
- សាកលវិទ្យាល័យ ភូមិន្ទកសិកម្មសាស្ត្រ (Université Royale des Sciences Agronomiques)
- សាកលវិទ្យាល័យកំពង់ចាម(Université Royale des Kompongcham)
- សាកលវិទ្យាល័យភូមិន្ទបាត់ដំបង (Université Royale des Battambang)
- សាកលវិទ្យាល័យ ភូមិន្ទ តាកែវ - កំពត (Université Royale Takeo-Kampot)
- រោងភាពយន្តរដ្ឋ(Cinémad'Etat)
- ស្ថានីទូរទស្សន៍ខេមរភូមិន្ទ(Station de la Télévision Royale)
- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត(Hopital de l' amitiéKhmero-soviétique)
- រោងចក្រចម្រាញ់ប្រេងកាតក្រុងព្រះសីហនុ (RaffineriedePétrole)
- រោងចក្រស្រាបៀរក្រុងព្រះសីហនុ(Brasscrie de sihanoukville)
- រោងចក្រ "ព្រះនរោត្តម" តម្លើងត្រាក់ទ័រ និង រថយន្តធំ ក្រុងព្រះសីហនុ
- រោងចក្រ ស្ករស កំពង់ត្រាំ ខេត្តកំពង់ស្ពឺ
- រោងចក្រ វាយនភ័ណ្ឌ ខេត្តកំពង់ចាម
- រោងចក្រ វាយនភ័ណ្ឌ ខេត្តបាត់ដំបង
- រោងចក្រ បាវក្រចៅ ដូនទាវ ខេត្តបាត់ដំបង
- រោងចក្រ ស៊ីម៉ង់ត៍ចក្រីទីងខេត្តកំពត
- រោងចក្រកែវជើងឯក រាជធានីភ្នំពេញ
- រោងចក្រក្តារបន្ទះដីឥដ្ឋខេត្តកណ្តាល ( Usine de Contre –Plaques)
- រោងចក្រ ក្រដាស ឆ្លូងខេត្តក្រចេះ ( Usine de Papier)
- រោងចក្រ ជីហ្វូសស្វាត ទូកមាស ខេត្តកំពត( Usine de Phosphates)
- រោងចក្រ កង់ឡានតាខ្មៅ ខេត្តកណ្តាល ( Usined'Etat de Pheumatiues)
- រោងចក្រ ត្រីខប្រអប់ខេត្តកោះកុង ( Conserverie de Poissons)
- រោងចក្រ ផលិតជ័រកៅស៊ូជប់ខេត្តកំពង់ចាម( Usine de Latex a Chup)
- រោងចក្រវារីអគ្គិសនីគិរីរម្យខេត្តកំពង់ស្ពឺ( Usine Hydro-electrique de Kirirom)

ក្រៅពីនោះនៅមាន សមិទ្ធផលនានាជាច្រើនទៀតតាមបណ្តាស្រុក ខេត្ត ក្រុង ដូចជាសាលារៀន មន្ទីរពេទ្យ ទំនប់ទឹក ស្រះទឹក ប្រឡាយទឹក ផ្លូវថ្នល់ ស្ពាន ជាដើម ។ល។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងពេលដែលព្រះអង្គកំពុងបំពេញព្រះរាជទស្សនកិច្ចជាផ្លូវ ការនៅសហភាពសូវៀត ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ត្រូវបានទទួលរងនូវរដ្ឋប្រហារមិនស្របច្បាប់មួយនៅភ្នំពេញ គឺជារដ្ឋប្រហារយោធាដែលមាន **លន់ នល់** ជាមេក្លោង និងឈានទៅការបង្កើតរបបមួយមានឈ្មោះថា របបសាធារណរដ្ឋខ្មែរ។ របបសាធារណរដ្ឋខ្មែររបស់ លោកសេនាប្រមុខ **លន់ នល់** ត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ១៩៧០។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះ អង្គបានក្លាយជាព្រះប្រធានចលនាតស៊ូកម្ពុជាឈ្មោះថា ***រណសិរ្សរួបរួមជាតិកម្ពុជា*** (FUNC)ព្រមជាមួយនោះ ក៏មានបង្កើតនូវរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK)។

នៅខែមេសា ឆ្នាំ១៩៧០ នៅកង់តុង (សាធារណរដ្ឋប្រជាមានិតចិន) ព្រះអង្គជាអ្នកផ្តួចផ្តើម នៃសន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិន ក្នុងពេលនោះមានការចូលរួមពីអ្នកដឹកនាំពីប្រទេសកម្ពុជាពីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី **ផាំ វ៉ាន់ដុង** (PHAM VAN DONG) មកពីរណសិរ្សរំដោះវៀតណាមខាងត្បូងដឹកនាំដោយលោក **ង្វៀន ហ៊ីវ ថ** (NGUYEN HUU THO) និងមកពី ណេវ ឡាវ ហាក់សាត (NEO LAO HAKSAT) ដឹកនាំដោយព្រះអង្គម្ចាស់ប្រធាន សុផានុវង្ស (SOUPHANOUVONG)។ ភាគីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងនិងភាគី ណេវ ឡាវ ហាក់សារ (NEO LAO HAKSAT) បានប្រកាសជាឧឡារិកថា ប្រទេសរបស់ខ្លួនទទួលស្គាល់ និងគោរពជាដ៏ពបបូរណភាពទឹកដីក្នុងព្រំដែនបច្ចុប្បន្នរបស់កម្ពុជា ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពប្រជាជនរំដោះជាតិ នៃរណសិរ្សរួបរួមជាតិកម្ពុជា (FUNC) ដណ្តើមបានជ័យជំនះទាំងស្រុងនៅកម្ពុជា។ របបថ្មីមួយត្រូវបានបង្កើតឡើង គឺ"កម្ពុជាប្រជាធិបតេយ្យ" ដែលមានព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ជាព្រះប្រធាន។ ប៉ុន្តែនៅខែមេសា ឆ្នាំ១៩៧៦ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានសព្វព្រះរាជហឫទ័យលាលែងមុខងារជាព្រះប្រធាននៃកម្ពុជាប្រជាធិបតេយ្យនេះ ហើយត្រូវពួកខ្មែរក្រហមឃុំឃាំងព្រះអង្គ និង សម្តេចព្រះរាជអគ្គមហេសីនៅក្នុងគេហដ្ឋាននៅក្នុងព្រះបរមរាជវាំង ព្រមទាំងមិនអនុញ្ញាតឱ្យព្រះអង្គចាកចេញពីប្រទេស ធ្វើសេចក្តីថ្លែងការណ៍ ឬជួបពិភាក្សាជាមួយអង្គទូតបរទេសណាមួយឡើយ។ ព្រះរាជបុត្រា បុត្រី របស់ព្រះអង្គមួយចំនួនក៏ត្រូវពួកខ្មែរក្រហមធ្វើគតផងដែរ។

នៅឆ្នាំ១៩៨២ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ត្រូវបានជ្រើស

តាំងជា ព្រះប្រធានកម្ពុជាប្រជាធិបតេយ្យជាលើទី២ ។

ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩០ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គជាព្រះប្រធាននៃចលនាតស៊ូជាតិកម្ពុជា (RNC) ។

ចាប់តាំងពីឆ្នាំ១៩៨៧ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានខិតខំ អស់ពីព្រះកាយពល ដើម្បីបង្រួបបង្រួមភាគីជម្លោះកម្ពុជាទាំងអស់ រិះរកនូវដំណោះស្រាយនយោបាយសមស្របបញ្ចប់ជម្លោះនៅកម្ពុជា។ ព្រះអង្គតែងតែប្រទានចំពោះ ឯកឧត្តម **ហ៊ុន សែន**(កាលនោះហៅសមមិត្ត ហ៊ុន សែន) និងគណៈប្រតិភូនៃរដ្ឋកម្ពុជាចូលក្រាបថ្វាយបង្គំគាល់ ជាបន្តបន្ទាប់នៅប្រទេសបារាំង ៖

- ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨៧ ជំនួបលើកទី១ នៅ ហ្វែអង់តាដឺណ័រ (Fere-en-Taradenois)។
- ចាប់ពីថ្ងៃទី ២០ - ២១ ខែមករា ឆ្នាំ១៩៨៨ ជំនួបលើកទី២ នៅ សាំងហ្សេម៉ាំង(Saint-Germain-en) ចក្រភពអង់គ្លេស និងមានជំនួបជាបន្តបន្ទាប់នៅកន្លែងផ្សេងៗច្រើនដងទៀត។

នៅថ្ងៃទី២៤ ខែមិថុនាឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានទទួលពីមេដឹកនាំនៃកម្ពុជាទាំង៤ភាគីដើម្បីប្រកាសជាឱឡារិកនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហើយទទួលស្គាល់ការបញ្ឈប់ជាបណ្តោះអាសន្ននូវការបាញ់គ្នា នៅក្នុងប្រទេសកម្ពុជាទាំងមូល និងបញ្ឈប់ការផ្តល់ជំនួយយោធា"អាវុធ"ពីប្រទេសដ៏ទៃដល់កងទ័ពកម្ពុជាទាំង៤។ ទីក្រុងភ្នំពេញត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC) ក្រោមព្រះរាជធិបតីដ៏ខ្ពង់ខ្ពស់របស់ ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ** ជាទីស្នាក់ការផ្លូវការអចិន្ត្រៃយ៍ និងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC)។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានយាងចាកចេញពីប្រធាននៃកម្ពុជាប្រជាធិបតេយ្យ និង ចលនាតស៊ូជាតិកម្ពុជា (CNR) ដើម្បីដាក់ព្រះកាយព្រះអង្គនៅពីលើភាគី និងទស្សនៈនយោបាយកម្ពុជានានា។ ព្រះអង្គត្រូវបានសមាជិកទាំង១១នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC) ជ្រើសតាំងជាឯកច្ឆ័ន្ទ ជាព្រះប្រធាន " **អព្យាក្រឹត** " នៃក្រុមប្រឹក្សានេះ ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុងប៉ារីស ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានឡាយព្រះហស្តលេខា " ***លើកិច្ចព្រមព្រៀង ស្តីពី ដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា*** " ជាមួយសមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់

នៃកម្ពុជា ១១រូបទៀតជាមួយតំណាងរដ្ឋាភិបាល ១៨ ប្រទេស និងជាមួយលោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ។

ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** យាងនិវត្តន៍មកកាន់រាជធានីភ្នំពេញវិញ ប្រកបដោយជោគជ័យនិងសុវត្ថិភាព។ ក្រោយពីមាតុភូមិនិវត្តន៍របស់ព្រះអង្គ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាដែលមានឯកឧត្តម **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី និង ឯកឧត្តម **ជា ស៊ីម** ជាប្រធានគណៈបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច ដែលមាន ព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** ជាព្រះប្រធានគណបក្ស គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ដែលមានសម្តេចបវរសេដ្ឋា **សឺន សាន** ជាប្រធានគណបក្ស និងភាគីកម្ពុជាប្រជាធិបតេយ្យ ដែលមានលោក **ខៀវ សំផន** ជាប្រធានបានប្រកាសជាបន្តបន្ទាប់ជាផ្លូវការ និងជាលាយលក្ខណ៍អក្សរថា ព្រះករុណាព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ** នៅតែជាព្រះប្រមុខរដ្ឋពេញលក្ខណៈច្បាប់ នៃប្រទេសកម្ពុជាទាំងមូល ម៉្យាងទៀត ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ជាផ្លូវការនៅតែរក្សាទុកជាតួនាទីជាព្រះប្រមុខរដ្ឋរហូតដល់មានការបោះឆ្នោតនៅកម្ពុជា ឆ្នាំ១៩៩៣ ។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ នូវរដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញកម្ពុជាបានអនុម័ត ។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិជ្រើសតាំងជា " ***ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា*** " ។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មហាមិទ្ទិងមហាជនមួយ ក៏ត្រូវបានរៀបចំឡើងដោយមានមហាជនយ៉ាងច្រើនកុះករចូលរួម ដើម្បីសម្តែងមនោសញ្ចេតនាអបអរ គាំទ្រស្វាគមន៍ចំពោះរដ្ឋធម្មនុញ្ញថ្មី និងព្រះឋានៈព្រះអង្គជា " ***ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា*** " ។

ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានបំពេញព្រះរាជកិច្ចដ៏ឧត្តុង្គ ឧត្តមជាទីបំផុតក្នុងការបង្រួបបង្រួមផ្សះផ្សាជាតិតាំងពីដើមរហូតមក។ ព្រះអង្គបានធ្វើឱ្យចេញ ជារូបរាងរាជរដ្ឋាភិបាលចំរុះដែលមានសហនាយករដ្ឋមន្ត្រីនៅឆ្នាំ ១៩៩៣ ហើយជាពិសេសព្រះអង្គបានបំពេញព្រះរាជកិច្ចធ្វើឱ្យថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និង គណបក្សហ៊្វុនស៊ិនប៉ិច ចុះហត្ថលេខាលើសេចក្តីប្រកាសរួមអំពីគោលការសហប្រតិបត្តិការ ដែលបានសំរេចក្នុងកិច្ចប្រជុំកំពូល ក្រោមព្រះរាជធិបតេយ្យ

*ភាពនៃព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅប្រាសាទខេមរិន្ទព្រះបរមរាជវាំងពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨។ ប្រជារាស្ត្រកម្ពុជាទូទាំងព្រះរាជាណាចក្រកម្ពុជា សូមថ្វាយអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះរាជកិច្ច ព្រះរាជតួនាទី ដ៏ឧត្តុង្គឧត្តមនេះ។*

*នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៤ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានសព្វព្រះរាជហឫទ័យប្រកាសយាងចូលនិវត្តន៍។ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤ ក្រុមប្រឹក្សារាជសម្បត្តិបានកោះប្រជុំ និងបោះឆ្នោតជាឯកច្ឆ័ន្ទជ្រើសរើស សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ជាព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា។*

*រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានព្រមព្រៀងថ្វាយជូន ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** នូវព្រះគោរមងារផ្លូវការជា ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវរបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ** ជាមួយនឹង ព្រះរាជបុព្វសិទ្ធិពិសេស ក៏ដូចជាព្រះរាជអភ័យឯកសិទ្ធិ ដូចកាលដែលព្រះអង្គនៅគ្រងរាជ្យ។*

*ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ជាទីសក្ការៈ ជាព្រះមហាវីរក្សត្រ មួយព្រះអង្គ ដែលតែងតែប្រកាន់ខ្ជាប់នូវព្រះរាជកិច្ចប្រកបដោយព្រះព្រហ្មវិហារធម៌ដ៏ឧត្តុង្គឧត្តម ចំពោះប្រជានុរាស្ត្រកូនចៅ ចៅទួតរបស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ តាំងពីដើមរៀងមករហូតដល់បច្ចុប្បន្នព្រះអង្គតែងតែបំពេញព្រះរាជសកម្មភាពសង្គមកិច្ចដូចជា ការកសាងព្រះវិហារ, កុដិ , សាលាបុណ្យ, សាលារៀន, មន្ទីរពេទ្យ, ផ្ទះសម្បែង,ផ្លូវថ្នល់, ទំនប់, ប្រឡាយ, អណ្តូងទឹក, ស្រះទឹក សំរាប់ប្រគេន និងជូនប្រជារាស្ត្រ។ ព្រះអង្គបានប្រោសព្រះរាជទាន និងបន្តនូវការព្រះរាជទានរៀងរាល់សប្តាហ៍ នូវព្រះរាជអំណោយ ដល់ប្រជានុរាស្ត្រទីទ័លក្រ និងជីវភាពខ្វះខាតខ្លាំង។*

*ព្រះរាជសកម្មភាពដ៏ថ្លៃថ្លា ខាងលើនេះ បានបង្ហាញឱ្យឃើញនូវសច្ចធម៌ នៃទសពិធរាជធម៌ របស់ ព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ជាទីសក្ការៈ ដែលព្រះអង្គបាននឹងកំពុងប្រោសព្រះរាជទានដល់ប្រជារាស្ត្រកម្ពុជាដោយមិនប្រកាន់ជាតិកំណើតជំនឿសាសនា ពណ៌សម្បុរឡើយ។ ដោយសារសច្ចភាពនេះហើយទើបប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស បានគាំទ្រនិងថ្វាយព្រះរាជ្យសម្បត្តិដល់ព្រះអង្គ ក្នុងការយាងគ្រងរាជ្យសម្បត្តិសារជាថ្មីនៅឆ្នាំ១៩៩៣ ពិតជាព្រឹត្តិការណ៍ដ៏អស្ចារ្យដែលពុំធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពិភពលោកកន្លងមក។*

*ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គទ្រង់ជាព្រះមហាវីរក្សត្រ ដ៏ឆ្នើមបំផុតក្នុងមួយព្រះជន្មវស្សារបស់*

របស់ព្រះអង្គ ព្រះអង្គបានបូជាព្រះកាយពល ព្រះបញ្ញាញាណ ក្នុងព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តមថែរក្សាបូរណភាពទឹកដី ឱបព្រះនគរ ព្រះសាសនា ឱ្យបានគង់វង្ស និងរីកចម្រើនរុងរឿងសម្បូរសប្បាយមានកេរ្តិ៍ឈ្មោះល្បីរន្ទឺទូទាំងពិភពលោកតាំងពីដើមរហូតមកដល់បច្ចុប្បន្ន ។

## ១១.ការសោយទិវង្គត

ព្រះករុណាព្រះបាទ **នរោត្តម សីហនុ** ព្រះវរបិតាឯករាជជាតិទ្រង់បានយាងសោយព្រះទីវង្គតនៅថ្ងៃច័ន្ទ ទី១៥ ខែតុលា ឆ្នាំ២០១២ ត្រូវនឹងថ្ងៃ១៥កើត ខែកត្តិក ឆ្នាំរោង ចត្វាស័ក វេលាម៉ោង១ និង២០នាទីយប់ (ម៉ោងនៅរាជធានីភ្នំពេញ) នៅទីក្រុងប៉េកាំងប្រទេសចិនដោយជរាពាធក្នុងព្រះជន្មាយុ៩០ព្រះវស្សា។ ព្រះបរមសពរបស់ទ្រង់ត្រូវបានដង្ហែពីទីក្រុងប៉េកាំង មកកាន់រាជធានីភ្នំពេញដោយព្រះករុណាព្រះបាទព្រះបរមនាថ **នរោត្តម សីហមុនី** និង សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅថ្ងៃទី ១៧ ខែតុលា វេលាម៉ោង ២:៣០ រសៀលតាមជើងយន្តហោះពិសេសរបស់សាធារណរដ្ឋប្រជាមានិតចិន។ ការដង្ហែព្រះបរមសពពីប្រលានយន្តហោះអន្តរជាតិភ្នំពេញមកព្រះបរមរាជវាំង កាត់តាមវិមានឯករាជ្យបានបញ្ចប់នៅម៉ោង៥និង៣០នាទីល្ងាច ដោយមានប្រជានុរាស្ត្រជាកូនចៅ ចៅទួត ប្រមាណជាង ១ ០០០ ០០០ (មួយលាន) ទៅជាង ១ ២០០ ០០០ (មួយលានពីរសែន) នាក់មកចាំដង្ហែដែលមានទាំងបព្វជិត និងគ្រហស្ថ ឈរតាមសងខាងផ្លូវ។ ព្រះបរមសពរបស់ទ្រង់នឹងដំកល់នៅព្រះបរមរាជវាំងក្នុងប្រាសាទទេវាវិនិច្ឆ័យរយៈពេល៣ខែនិងក៏មានថ្វាយព្រះមរណនាមថា «**ព្រះករុណាព្រះបរមរតនកោដ្ឋ**»។



ក្បួនដង្ហែព្រះបរមសពព្រះករុណាព្រះបរមរតនកោដ្ឋ

បន្ទាប់មកនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០១៣ ព្រះបរមរតនកោដ្ឋ និងត្រូវដង្ហែយកមកដំកល់នៅទីវាលព្រះមេរុរយៈពេលបីថ្ងៃ។ លុះដល់ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៣ ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** និងត្រូវធ្វើពិធីបូជាព្រះភ្លើង នៅទីវាលព្រះមេរុ។ រីឯទីកន្លែងតំកល់ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ត្រូវបានរៀបចំឡើងយ៉ាងល្អប្រណិតបំពាក់ដោយ ក្បាច់ចម្លាក់យ៉ាងល្អវិចិត្រតាមបែបរចនាបថខ្មែរ ប្រកបដោយភាពអស្ចារ្យ ពោល

*គឺមានភាពវិសេសវិសាល និងមានភាព អធិកអធមជាងព្រះមហាក្សត្រមុនៗទៅទៀត។*



*វិមានតំកល់ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ **បរមរតនៈកោដ្ឋ***

*ការយាងសោយទីវង្គតរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **បរមរតនកោដ្ឋ** បានធ្វើឱ្យកូន ចៅ ចៅទួត របស់ព្រះអង្គទូទាំងប្រទេស មានភាពអាឡោះអាល័យយ៉ាងខ្លាំងពន់ពេករក គឺបានចាក់ចូលយ៉ាងជ្រៅក្នុងក្រអៅបេះដូងកូនខ្មែរ និងប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនអាចបំភ្លេចបាន។ បទចម្រៀង **លាហើយកម្ពុជា** ដែលជាស្នាព្រះហស្តនិពន្ធរបស់ព្រះអង្គ ពិតជាបានបង្កប់នូវអត្ថន័យយ៉ាងជ្រាលជ្រៅ ធ្វើឱ្យកូន ចៅ ចៅទួត ដែលជាប្រជាពលរដ្ឋពេលស្តាប់ម្តងៗ មានភាពក្តុកក្តួលដោយហូរទឹកនេត្រាដោយពុំដឹងខ្លួន។*




*បទចំរៀង **លាហើយកម្ពុជា** ដែលជាស្នាព្រះហស្តនិពន្ធរបស់ព្រះអង្គ*

*ដើម្បីជាការតបស្នងសងគុណដល់ព្រះអង្គ ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិ និងមាតុភូមិកន្ធងមកពិសេសក្នុងពេលដែលព្រះអង្គនៅមានព្រះជន្ម រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកសាងវិមានព្រះបរមរូប និងព្រះបរមបដិមាព្រះបរមរតនកោដ្ឋ សម្តេចព្រះ **នរោត្តម សីហនុ** ទុកជាទីសក្ការៈ។ វិមាននេះត្រូវបើកសម្ពោធជាផ្លូវការនៅព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ ដើម្បីទុកឱ្យកូនចៅ ចៅទួត ដាក់កម្រងផ្កា*

គោរពបូជា បន្ទាប់ពីព្រះអង្គបានសោយទិវង្គតកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ទៅនោះ។ ព្រះបរមរូបព្រះរតនកោដ្ឋ ត្រូវបានចំណាយទឹកប្រាក់សរុប ចំនួន ១.២២៩.៨២០ ដុល្លារ។

ព្រះរាជពិធីសម្ពោធ និងរាជាភិសេក ក្រោមព្រះរាជាធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** និងសម្តេចម៉ែ សម្តេចយាយ **មុនិនាថ សីហនុ** សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃរាជរដ្ឋាភិបាលកម្ពុជា និងព្រះរាជវង្សានុវង្សជាច្រើនអង្គផ្សេងទៀត។



វិមានព្រះបរមរូប និងព្រះបរមបដិមាព្រះបរមរតនកោដ្ឋ សម្តេចព្រះ **នរោត្តម សីហនុ**

<u>**ឯកសារយោង**</u>

១.ប្រវត្តិសង្ខេប នៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ ១៩៥៦

២.សម្តេចព្រះ **នរោត្តម សីហនុ** (ឆ្នាំ២០០៥) រាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជា ពីទស្សវត្សរ៍១៩៤០-១៩៥០ បោះពុម្ពលើកទី២ ឆ្នាំ២០០៥ (ផ្សាយរបស់ឥន្ទ្រទេវី)

៣.ព្រះរាជជីវប្រវត្តិសង្ខេប របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ ឆ្នាំ១៩៩៣

៤.នរោត្តម សីហនុ អនុស្សាវរីយ៍ ផ្អែមល្ហែមនិងល្វីងជូរចត់ ភ្នំពេញ ឆ្នាំ១៩៩៣

៥.រោងពុម្ពពន្លឺខ្មែរ ឆ្នាំ២០១៣ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឥស្សរជនអមតៈ

៦ . Boigraphie de Son Altesse Royale Samdech Preah NORODOM SIHANUK Upayuvareach Ex-Roi du Cambodge

៧ . BIOGRAPHIE de S.A.R. LE PRINCE NORODOM SIHANUK CHEF D'ETAT DU CAMBODGE

# យន្តការច្បាប់ស្តីពីការគ្រប់គ្រងដីធ្លីនៅកម្ពុជា (១៩៩៣ - ២០០៨)

**ដោយ៖ បណ្ឌិត ឈឿន សាវឌន**

*ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទេសចរណ៍*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១. ស្ថានភាពទូទៅ

ដើម្បីឲ្យការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព មានសមធម៌ ចីរភាព ដោយគ្រាន់តែមានរចនាសម្ព័ន្ធដឹកនាំ មានធនធានមនុស្សមានសម្ភារបរិក្ខារ វាមិនទាន់គ្រប់គ្រាន់សម្រាប់អនុវត្តនោះទេ បើសិនជាខ្វះនូវយន្តការច្បាប់ដែលជាកាតាលីករដ៏ចាំបាច់ក្នុងការជំរុញឲ្យមាននូវកម្រងច្បាប់ កម្មវិធីការងារនិងការសម្របសម្រួលពីស្ថាប័ននានា ដែលពាក់ព័ន្ធនឹងការងារដីធ្លី ជាពិសេសពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានផងនោះ។ ជាមួយនឹងខ្លឹមសារនេះការសិក្សាស្រាវជ្រាវ បានលើកយកនូវចំណុចចម្បងៗចំនួន៣ ដែលពាក់ព័ន្ធទៅនឹងយន្តការច្បាប់គ្រង់គ្រងដីធ្លីមកបកស្រាយ ដែលក្នុងនោះទី១ យន្តការពាក់ព័ន្ធនឹងច្បាប់ភូមិបាល ទី២ ច្បាប់ពាក់ព័ន្ធនឹងសម្បទានដី និងទី៣ នីតិវិធីក្នុងការរៀបចំដីធ្លី។

## ២. យន្តការពាក់ព័ន្ធនឹងច្បាប់ភូមិបាល

ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១ បានចែងថា «ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជា ដែលជាគោលដៅធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត លើអចលនវត្ថុស្របតាមច្បាប់បទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា»។ ដោយឡែកមាត្រា២ នៃច្បាប់នេះ បានចាត់ទុកជាអចលនវត្ថុ តាមន័យនៃច្បាប់នេះមានអចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ពវាសនា តាមការកំណត់របស់ច្បាប់។ អចលនវត្ថុពីកំណើតមានដីពីធម្មជាតិ ដូចជាដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬដីមិនអាចដាំដុះ ដីលេចទឹកដោយទឹកនៅនឹង ឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន។ ចំពោះអចលនវត្ថុពីភ័ពវាសនាមានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយ ដែលមិនអាចបំបែកចេញបានដោយធ្វើមិនឲ្យមានការខូចខាត ឬមិនដូរសភាព ដើមដូចជា ដើមឈើ ឧបករណ៍តែងលំអជាដើម។ អចលនវត្ថុតាមការកំណត់ មានសិទ្ធិភណ្ឌិក

(សិទ្ធិប្រត្យក្ស) ទាំងឡាយលើអចលនវត្ថុ និង អចលវត្ថុ ដែលបានកំណត់ដោយច្បាប់ជា អចលនវត្ថុ។ ដោយឡែកមាត្រា ៣ក៏បានចែងផង ដែរថា ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់ រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាល សុរិយោដីលើ អចលនវត្ថុ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការ ចេញប័ណ្ណកម្មសិទ្ធិ លើអចលនវត្ថុទូទាំងព្រះ រាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួង រៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ ដើម្បី ឲ្យកាន់តែស៊ីជម្រៅថែមទៀត ការសិក្សា ស្រាវជ្រាវក៏បានផ្តោតទៅលើចំណុចជាចម្បងៗ ចំនួន៤ដែលក្នុងនោះរួមមាន ទី១ គោលការណ៍ នៃកម្មសិទ្ធិ ទី២ លទ្ធកម្ម នៃកម្មសិទ្ធិ និងរបប កម្មសិទ្ធិ ទី៣ ទម្រង់នៃកម្មសិទ្ធិ និងប្រាតិ ភោគ អចលនវត្ថុ និងទី៤ លក្ខណៈសុរិយោ ដី។

## ២.១. គោលការណ៍នៃកម្មសិទ្ធិដីធ្លី

សិទ្ធិនៃកម្មសិទ្ធិដែលមានចែងក្នុងមាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានសំដៅទៅ លើ អចលនវត្ថុទាំងអស់នៃព្រះរាជាណាចក្រ កម្ពុជា តាមលក្ខខណ្ឌដែលបានកំណត់ដោយ ច្បាប់ភូមិបាល។ មាត្រា៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ បានចែងថា «គ្មានបុគ្គលណាមួយត្រូវ បានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះ មិនមែនដើម្បី ប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅ តាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និង បទបញ្ញា បន្ទាប់ពីបានផ្តល់សំណងជាមុន ដោយសមរម្យនិងយុត្តិធម៌»[1]។ មានតែភោគៈ ត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះដែលអាចនាំឲ្យបាន កម្មសិទ្ធិ។ រដ្ឋក៏អាចផ្តល់កម្មសិទ្ធិ នៃទ្រព្យជា អចលនវត្ថុដែលជារបស់រដ្ឋក្នុងព្រំដែនជាក់ លាក់ ដែលបានកំណត់ដោយច្បាប់ សម្រាប់រូប មន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជា ខ្មែរ។ រាល់ការផ្ទេរ ឬផ្លាស់ប្តូរសិទ្ធិនៃកម្មសិទ្ធិ ត្រូវធ្វើឡើងតាមវិធាននៃនីតិរួមដូចជាការលក់ ការបន្តមរតក ការដូរ ឬការប្រទានកម្ម ឬតាម សេចក្តីសម្រេចរបស់តុលាការ ហើយរបបកម្ម សិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវ បានទទួលស្គាល់។

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែល មានសញ្ជាតិជាខ្មែរ ទើបមានសិទ្ធិជាម្ចាស់កម្ម សិទ្ធិលើដី នៃព្រះរាជាណាចក្រកម្ពុជា។ អ្នក មានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៅកម្ពុជា គឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសហគមន៍ ឬ សហគមន៍កម្ពុជា សហគ្រាសសាធារណៈ និង ក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងគ្រប់ អង្គការកម្ពុជា ដែលបានទទួលស្គាល់ដោយ

[1] ព្រះរាជក្រមលេខ នស/រកម/០៨០១ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ភូមិបាលដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១។

ច្បាប់ថាជានីតិបុគ្គល។ ដោយឡែកជនបរទេស ដែលបានក្លែងបន្លំបណ្ណសញ្ជាតិ ដើម្បីឲ្យក្លាយជាកម្មសិទ្ធិករលើដីកម្ពុជា នឹងត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា២៥១ នៃច្បាប់ភូមិបាល។ ទ្រព្យដែលបានមកកនុងលក្ខខណ្ឌនេះ ត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឲ្យឡើយ។ ចំពោះក្រុមហ៊ុនដែលបានចុះបញ្ជីនៅកម្ពុជា ហើយ ដែលមានភាគហ៊ុនចាប់ពី៥១% ឡើងទៅកាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា អាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។ មានចំនួនភាគរយនៃភាគហ៊ុន ដែលមានចែងក្នុងលក្ខណៈឯកជន រវាងអ្នកចូលហ៊ុនទាំងឡាយដែលមានន័យថាពីនេះត្រូវទុកជាមោឃៈនិងគ្មានអានុភាព។ ប្រសិនបើចំនួនភាគរយ ដែលមានចែងក្នុងលក្ខន្តិកៈបានប្រែប្រួលបណ្តាលឲ្យក្រុមហ៊ុនមានសញ្ជាតិជាខ្មែរ ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការផ្លាស់ប្តូរលក្ខន្តិកៈឲ្យបានសមស្របតាមស្ថានភាពជាក់ស្តែង ហើយត្រូវផ្តល់ព័ត៌មានទៅស្ថាប័នមានសមត្ថកិច្ចអំពីការប្រែប្រួលនេះដោយអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន។ ជាមួយគ្នានេះដែរកម្មសិទ្ធិរបស់បុគ្គលតែម្នាក់ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី គឺជាកម្មសិទ្ធិឯកជន។ កម្មសិទ្ធិរបស់បុគ្គលមួយក្រុមដែលមានបុព្វសិទ្ធិរៀងៗខ្លួនតាមរយៈច្បាប់ដែលបានបញ្ញត្តិអំពីកម្មសិទ្ធិនេះ គឺជាកម្មសិទ្ធសមូហភាព។ កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ដែលអនុវត្តសិទ្ធិរបស់ខ្លួន ដោយសាមគ្គីគ្នាទៅលើទ្រព្យទាំងមូលគឺកម្មសិទ្ធិអវិភាគ។ កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ ដែលអនុវត្តនូវសិទ្ធិឯកជនផ្តាច់មុខលើភាគខ្លះនៃទ្រព្យហើយភាគដទៃទៀត ហៅថាភាគរួមត្រូវដាក់នៅក្រោមបទបញ្ញានីត្យានុកូល ឬតាមការព្រមព្រៀងគឺសហកម្មសិទ្ធិ។ ប្រភេទនៃកម្មសិទ្ធិនីមួយៗត្រូវបានកំណត់ តាមបញ្ញត្តិដោយឡែករបស់កម្មសិទ្ធិទាំងអស់នោះ។ ក្រៅពីនេះរបបគតិនៃកម្មសិទ្ធិអចលនវត្ថុ ប្រែប្រួលទៅតាមតម្រូវការរបស់សង្គមខ្មែរ ដូចជាដីកសិកម្មព្រៃឈើ ផ្លូវទឹកត្រពាំងបឹងបួរ ឬជាទឹកត្រើយសមុទ្រ ឬច្រាំទន្លេ អចលនវត្ថុក្នុងទីក្រុងនិងសំរាប់សាងសង់តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម[2]។ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ថែមទៀត យើងសូមលើកយកនូវចំណុចជាចម្បងចំនួន២ ដែលទាក់ទងនឹងគោលការណ៍នៃកម្មសិទ្ធិមកបកស្រាយដែលក្នុងនោះមានដូចជាអំពីកម្មសិទ្ធសាធារណៈ និងកម្មសិទ្ធិរបស់សមូហភាព។

**អំពីកម្មសិទ្ធិសាធារណៈ៖** រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងក្នុងមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣និងទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ ប្រគល់ឲ្យរដ្ឋ

[2] ច្បាប់ភូមិបាល.មាត្រា១១, ភ្នំពេញ ឆ្នាំ ២០០១

ដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬមិនមែនជាទ្រព្យ ដែលកំពុងកាន់កាប់ជារបស់ឯកជន។ក្រៅពីរដ្ឋ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ និងនីតិបុគ្គលនៃនីតិសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថា ជា នីតិបុគ្គលអាចជាកម្មសិទ្ធិករនៃទ្រព្យអចលនវត្ថុ ក្នុងលក្ខខណ្ឌដែលបានកំណត់។ ទ្រព្យសម្បត្តិមួយចំនួនទៀតត្រូវគ្រប់គ្រង ដូចកម្មសិទ្ធិឯកជន និងអាចជាកម្មវត្ថុនៃកិច្ចការជំនួញគឺជាទ្រព្យសម្បត្តិឯកជនរបស់នីតិបុគ្គលសាធារណៈ។ ការរាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ មានដូចជា ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិ ដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបានបណ្តែតបាន បឹងធម្មជាតិ ប្រាំងទន្លេ ដែលនាវាឬក្បូនចេញចូលបានបណ្តែតបាន និងឆ្នេរសមុទ្រ ទ្រព្យសម្បត្តិទាំងឡាយដែលជាកម្មវត្ថុ នៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅដូចជា កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និង ព្រលានយន្តហោះ ព្រមទាំងទ្រព្យទាំងឡាយ ដែលត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីការបានរៀបចំ ដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងសួនឧទ្យានសាធារណៈ និងដីចំណី។ ក្រៅពីនេះ មានទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជាសាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។ ទ្រព្យទាំងឡាយដែលបង្កើតឡើង ជាដែនបម្រុងធម្មជាតិ ការពារដោយច្បាប់បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ជាព្រះរាជទ្រព្យដែលមិនមែន ជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។អចលនវត្ថុព្រះរាជទ្រព្យត្រូវបានកំណត់ បែងចែក ដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាជ្ញាយុកាល[3]បានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចឋិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសនៃច្បាប់ភូមិបាលដែលមានចែងក្នុងជំពូក៤បានទេ។ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរដ្ឋ អាចជាកម្មវត្ថុ នៃការអនុញ្ញាតឲ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀងហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាត តាមជំពូកទី៣នៃច្បាប់ភូមិបាលផងដែរ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធិ

[3] អាជ្ញាយុកាលសំដៅលើពេលវេលាមួយជាកំណត់ដែលត្រូវបានទទួលស្គាល់ដោយច្បាប់ជាធរមាន។

ភណ្ឌិប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំង នោះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរដ្ឋ អាចជាកម្មវត្ថុ នៃការលក់ ការដូរ ការបែង ចែក ឬការផ្ទេរសិទ្ធិតាមការកំណត់របស់រដ្ឋ ដោយច្បាប់។ ទ្រព្យទាំងនោះអាចផ្ដល់ឲ្យ តាមរយៈភតិសន្យា[4] និងជាកម្មវត្ថុនៃកិច្ច សន្យាដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់។ លក្ខខណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ ណាមួយអាចត្រូវបានសម្រេច ដោយគ្មាន អនុក្រឹត្យនេះឡើយ។ ដីជាទ្រព្យសម្បត្តិរបស់រដ្ឋ អាចជាកម្មវត្ថុ នៃសម្បទាន។ គ្មានការយកដីតាម ទំនើងចិត្តណាមួយ អាចកើតឡើងទៅលើ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គល សាធារណៈបានឡើយ។ ប៉ុន្តែដីទំនេរនៃទ្រព្យ សម្បត្តិឯកជនរដ្ឋ អាចត្រូវបានបែងចែកទៅ ឲ្យបុគ្គលដែលត្រូវការដីក្នុងគោលដៅសង្គម កិច្ច។ ត្រូវទុកជាមោឃៈ និងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនីយ័តកម្ម ទោះតាមរូប ភាពណាក៏ដោយនូវរាល់ការចូលកាន់កាប់ទ្រព្យ សាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គល សាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់ និងការបំប្លែងនេះកើតមាន នៅពេលណាក៏ដោយ ដែលមិនស្របតាម លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបាន កំណត់កន្លងមក។ រាល់ការបំប្លែងទៅជាសិទ្ធិនៃ ដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើង មុនពេលច្បាប់នេះចូលជាធរមានក៏ដោយលើក លែងតែសម្បទាន ដែលឆ្លើយតប ទៅនឹង ប្រយោជន៍សង្គម។ ចំពោះបុគ្គលទាំងឡាយ ដែលមានបណ្ណ ឬមានស្ថានភាពជាក់ស្ដែងបិត នៅក្រោមឥទ្ធិពលនៃមាត្រា១៨ នៃច្បាប់ ភូមិបាល មិនអាចទាមទារសំណងទូទាត់ ឬសោហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំ ដែល បានធ្វើនៅលើអចលនវត្ថុ ដែលបានកាន់កាប់ ដោយខុសច្បាប់ បានឡើយ។ លទ្ធកម្មណាមួយ ដោយខុសច្បាប់ និងដោយចេតនា ឬដោយ បោកប្រាស់លើទ្រព្យសម្បត្តិ សាធារណៈរដ្ឋ ឬ របស់នីតិបុគ្គលសាធារណៈ ត្រូវផ្ដន្ទាទោសដូច មានចែងក្នុងមាត្រា២៥៩ នៃច្បាប់ភូមិបាលផង ដែរ។ ចំពោះការកាន់កាប់ទ្រព្យសម្បត្តិ សាធារណៈ ដែលបណ្ដាលឲ្យខូចខាតឬធ្វើឲ្យ យឺតយ៉ាវដល់ការងារ ដែលជាប្រយោជន៍ទូទៅ ពិសេសចំពោះការកាន់កាប់ដីចំណីផ្លូវកម្រិត ទោសនឹងត្រូវកំណត់ជាទ្វេរៗក្នុងគ្រប់ករណី បើជនល្មើសមិនបញ្ឈប់ការកាន់កាប់របស់ខ្លួន ក្នុងរយៈពេលដែលបានកំណត់ ដោយ អាជ្ញាធរមានសមត្ថកិច្ចទេ អាជ្ញាធរអាចដំណើរ ការបណ្ដេញជនល្មើសចេញ។

[4] *ភតិសន្យា* គឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគី ម្ខាងឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផល។

***អំពីកម្មសិទ្ធិរបស់សម្ហូហភាព៖*** ក្នុងន័យនេះការសិក្សាស្រាវជ្រាវបានផ្តោតលើកយកមកពិភាក្សាអំពីកម្មសិទ្ធរបស់ សមូហភាពដែលអចលនវត្ថុរបស់វត្ត និងជារបស់សហគមន៍ជនជាតិដើមភាគតិច។

***អំពីអចលនវត្ថុរបស់វត្ត៖*** អចលនវត្ថុជាដី និងជាសំណង់ដែលមាននៅក្នុង និងក្រៅបរិវេណវត្តអារាមនៃពុទ្ធសាសនាជាបេតិកភណ្ឌប្រើប្រាស់ជានិច្ចកាលសម្រាប់ព្រះពុទ្ធសាសនា និងដាក់ ឲ្យពុទ្ធសាសនិកប្រើប្រាស់ ក្រោមការថែទាំរបស់គណៈកម្មការវត្ត។អចលនវត្ថុរបស់វត្តមិនអាចលក់ដូរ ឬធ្វើអំណោយ ហើយគ្មានកំណត់អាជ្ញាយុកាលឡើយ។អចលនវត្ថុរបស់វត្តអាចជួល ឬប្រវាសបាន តែផលទុនដែលបានមកពីការជួល ឬប្រវាសនេះត្រូវទុកសម្រាប់តែកិច្ចការក្នុងសាសនាប៉ុណ្ណោះ។កិច្ចការពារទ្រព្យទាំងនេះត្រូវធានាដោយតំណាងគណៈកម្មការវត្ត។នីតិវិធី នៃការជ្រើសរើសគណៈកម្មការនិងតំណាងដើម្បីការពារផលប្រយោជន៍វត្ត ត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា។ចំពោះទីកន្លែងសក្ការបូជានិងទ្រព្យសម្បត្តិនៃជំនឿសាសនាដទៃទៀតមិនស្ថិតនៅក្រោមរបបដែលបញ្ញត្តិក្នុងមាត្រា២០ និងមាត្រា ២១ នៃច្បាប់ភូមិបាលឡើយ។ទ្រព្យទាំងនោះត្រូវគ្រប់គ្រងដោយសមាគមនៃសាសនិកដែលបង្កើតឡើងទៅតាមបញ្ញត្តិនៃច្បាប់។

***អំពីអចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច៖*** សហគមន៍ជនជាតិដើមភាគតិចគឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែមានសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់ នៃការប្រើប្រាស់ ជាសមូហភាព។ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់ នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់។ ចំពោះជនជាតិដើមភាគតិចទាំងនោះគឺជាជនជាតិដែលកើតនិងរស់នៅយូរអង្វែងលើទឹកដីកម្ពុជា ដោយពុំមានដើមកំណើតមកពីប្រជាជាតិដទៃ ឬប្រទេសផ្សេងៗព្រមទាំងមានវប្បធម៌ប្រពៃណី និងទំនៀមទម្លាប់របស់ខ្លួនដូចជាជនជាតិ គួយ ព្នង ចារ៉ាយ ទំពួន មិល ក្រោល ស្ទូច។ល។ នៅក្នុងលក្ខខណ្ឌនេះដែរជនជាតិភាគតិចទាំងអស់ គឺមានសិទ្ធិគោរពវប្បធម៌ដែលទាក់ទងនឹងជំនឿ ព្រមទាំងប្រពៃណីទំនៀមទម្លាប់របស់ខ្លួន។រីឯអ្នកដឹកនាំ ទាំងព្រឹទ្ធាចារ្យស្ត្រី និងបុរសនៃជនជាតិដើមភាគតិចត្រូវបានចូលរួមនៅក្នុងដំណើរការអភិវឌ្ឍន៍ និងការថែរក្សាវប្បធម៌ ជាពិសេសការចូលរួមស្វែងយល់អំពីច្បាប់ និងស្ថាប័នច្បាប់ ដោយមានការគាំទ្រពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ចំពោះកត្តាចាំបាច់នោះគឺចំណេះដឹងដើមប្រពៃណី វប្បធម៌ និងការប្រើប្រាស់ដីធ្លី

តាមប្រពៃណីរបស់ជនជាតិដើមភាគតិចដោយត្រូវគោរពផ្អែកតាមច្បាប់របស់រដ្ឋ និងពង្រឹងសមត្ថភាព ដើម្បីធានាការអភិវឌ្ឍន៍វប្បធម៌ប្រកបដោយនិរន្តរភាពសមស្របតាមកាលៈទេសៈ[5]។

ការចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ អំពីវប្បធម៌ និងសង្គមរបស់សហគមន៍ដែលទទួលស្គាល់ ដោយមតិភាគច្រើននៃសមាជិកដទៃទៀតនិងដោយព្រមទទួលនូវសាមគ្គីភាពនិងភាពចំណុះដែលនាំឲ្យ មានការចូលក្នុងសហគមន៍។ ចំពោះដីសហគមន៍ជនជាតិដើមភាគតិចគឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី។ ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ ការវាស់វែងនិងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ ទាំងនោះត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែង ដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង និងដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី៦ នៃច្បាប់ភូមិបាល និងអនុក្រឹត្យពាក់ព័ន្ធ ហើយកម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិឯកជនដែរ។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឲ្យទៅបុគ្គលឬក្រុមណាមួយបានឡើយ។ ការអនុវត្តនូវកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដី ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឲ្យនៅក្រោមច្បាប់នៃការអនុវត្ត ទូទៅ ទាក់ទងនឹងអចលនវត្ថុ ដូចជាការពារបរិស្ថានជាដើម។ បញ្ញត្តិនេះមិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការបន្ទាន់របស់ជាតិ ឡើយ ហើយដើម្បីសម្រួលការវិវត្តន៍វប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសមាជិកសហគមន៍ជនជាតិ ដើមភាគតិចនិងដើម្បីអនុញ្ញាតឲ្យពួកគេចេញដោយសេរីពីសហគមន៍ ឬរួចផុតពីការបង្ខិតបង្ខំ។ រីឯសិទ្ធិនៃ

5 ក្រសួងអភិវឌ្ឍន៍ជនបទ (នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច) សេចក្តីព្រាងតាមគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច. ភ្នំពេញ ឆ្នាំ២០០៥។

កម្មសិទ្ធិឯកជនអាចនឹងត្រូវផ្ទេរជាពិសេសឲ្យពួកគេទទួលបានលើចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍។ប៉ុន្តែ ដីដែលជាកម្មវត្ថុ នៃការយកធ្វើឯកជននោះមិនអាចជាដីដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទេ។គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ។

ដូច្នេះ សរុបមក យើងឃើញថា គោលការណ៍ នៃកម្មសិទ្ធិរបស់ច្បាប់ភូមិបាលឆ្នាំ ២០០១នេះមានបំណងការពារនូវកម្មសិទ្ធិដែលជាអចលនវត្ថុរបស់រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ហើយជាមួយគ្នានេះដែរក៏មានបំណងការពារសិទ្ធិសាធារណៈដែលជាអចលនវត្ថុរបស់រដ្ឋផងដែរ។ ផ្ទុយទៅវិញ ចំពោះជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិ ដើម្បីឲ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជា នឹងត្រូវផ្តន្ទាទោស ហើយទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះ ត្រូវបានរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋមិនចេញសំណងឲ្យឡើយ។

**២.២. កម្មសិទ្ធិ និងរបបកម្មសិទ្ធិឯកជន**

*ក. លទ្ធកម្មនៃកម្មសិទ្ធិ*

មានកត្តាជាចម្បងចំនួន៥ដែលទាក់ទងនឹងខ្លឹមសារនៃលទ្ធកម្មនៃកម្មសិទ្ធិនេះគឺ (ទី១) ការបង្កើតឡើងនូវកម្មសិទ្ធិលើអចលនវត្ថុតាមលទ្ធកម្មពិសេសនៃភោគៈ(ទី២)របៀបលទ្ធកម្មនៃកម្មសិទ្ធិ (ទី៣) លទ្ធកម្មដោយការដូរអចលនវត្ថុ (ទី៤) លទ្ធកម្មដោយសង្គតិកម្ម (ទី៥) លទ្ធកម្មដោយប្រទានកម្ម។

ការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុតាមលទ្ធកម្មពិសេសនៃភោគៈក្នុងក្របខណ្ឌនៃការបង្កើតឡើងវិញនូវកម្មសិទ្ធិលើអចលនវត្ថុនៅកម្ពុជា ក្រោយសម័យមានវិបត្តិពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ដោយមិនចំណុះទៅនឹងវិធានទូទៅនៃអាជ្ញាយុកាល ស្តីពីកម្មសិទ្ធលើអចលនវត្ថុ ភោគៈនៃអចលនវត្ថុដែលត្រូវបានទទួលស្គាល់ចាប់ពីឆ្នាំ១៩៧៩អាចបង្កើតជាពិសេសនូវសិទ្ធិកណ្ឋិកលើអចលនវត្ថុ និងនាំទៅដល់លទ្ធកម្ម នៃកម្មសិទ្ធិ ដោយអ្នកកាន់កាប់ទ្រព្យក្នុងលក្ខខណ្ឌ ដែលបានកំណត់ដោយច្បាប់ភូមិបាល។ការចូលកាន់កាប់ភោគៈត្រូវបញ្ចប់នៅពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ បានចូលជាធរមាន។បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី៥ឆ្នាំយ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើប្រាស់ច្បាប់ភូមិបាលលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ប៉ុន្តែប្រសិនបើក្នុងករណីមានការជំទាស់ដល់ការផ្តល់កម្មសិទ្ធិស្ថាពរនេះអ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី៥ឆ្នាំ នៅលើអចលនវត្ថុដែលជំទាស់

នោះ ឬយកកស្តុតាងដែលថាខ្លួនបានទិញ អចលនវត្ថុនោះពីភាគីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន ហើយបុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្ទ្រឹងមក គិតមកដល់កាលបរិច្ឆេទដែលស្របច្បាប់ភូមិបាល ចូលជាធរមានប្រសិនបើបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយ ដើម្បីក្លាយទៅជាកម្មសិទ្ធិករដែលអាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច ឲ្យបន្ថែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលសរបច្បាប់ ៥ឆ្នាំ និងបានបណ្ណកម្មសិទ្ធិស្ថាពរ។ ការអនុញ្ញាតឲ្យបន្តរយៈពេលមិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ច ឡើយប្រសិនបើភោគៈបានមកដោយសន្តិវិធី និងមិនមានការជំទាស់។ អាជ្ញាធរមានសមត្ថកិច្ច ដែលបដិសេធដោយរំលោភពីអាជ្ញាធរមានសមត្ថកិច្ច នូវភោគៈដែលមិនបំពេញលក្ខខណ្ឌ នៃច្បាប់ ត្រូវចាត់ទុកជាមោឃៈ និងគ្មានអនុភាព។ អាជ្ញាធរដែលបានទទួលស្គាល់ដោយរំលោភលក្ខខណ្ឌ នៃច្បាប់ត្រូវចាត់ទុកជាមោឃៈ និងគ្មានអនុភាព។ អាជ្ញាធរដែលបានទទួលស្គាល់ដោយរំលោភនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខច្បាប់។ ដោយឡែកអចលនវត្ថុទាំងឡាយដែលមិនអាចក្លាយទៅជាកម្មសិទ្ធិនៃអ្នកកាន់កាប់ស្របតាមច្បាប់នេះក្នុងករណីភោគីបំពេញមិនបាននូវលក្ខខណ្ឌ នៃច្បាប់ដោយហេតុមកពីលក្ខណៈសម្បត្តិរបស់ខ្លួន ជាភោគីកេងបន្ទំ ឬដោយឥរិយាបថរបស់ខ្លួនជាភោគី ដែលលួចលាក់នឹងច្បាប់ ឬដែលមិនច្បាស់លាស់ ឬជាភោគីដោយប្រើហិង្សា។ អចលនវត្ថុនោះត្រូវទុកជាសម្បត្តិរដ្ឋ ហើយមិនអាចឲ្យជនណាចូលកាន់កាប់ជាភោគីថ្មីសម្រាប់លទ្ធកម្មនៃកម្មសិទ្ធិបានឡើយ។ ចំពោះក្នុងករណីមានការដកហូតអចលនវត្ថុដោយហិង្សា ឬដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុត្រូវបានបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុ នៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្ដឹងទាមទារពីភោគីស្របច្បាប់ នៃអចលនវត្ថុ ដែលត្រូវដកហូត។ បណ្ដឹងទាមទារនេះមានរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត។

អ្នកកាន់កាប់ថ្មី លើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានបណ្ណ ក្រោយច្បាប់ភូមិបាលចូលជាធរមានត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១។ មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឲ្យអ្នកកាន់កាប់អចលនវត្ថុគ្មាន បណ្ណ ឬមានបណ្ណមិនគ្រប់គ្រាន់ ចាកចេញពីទីតាំងអចលនវត្ថុនោះ។ សាមញ្ញជន ឬអាជ្ញាធរដែលមិនតាងនាមរដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាព និង មានបណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ។ ការដេញអាចធ្វើបានតែតាមការបង្គាប់របស់តុលាការយោង

តាមបណ្ដឹងរបស់បុគ្គលដែលបានប្ដឹងទាមទារទ្រព្យ។ តុលាការត្រូវពិនិត្យបញ្ជាក់រូបភាពប្រភពកាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃបណ្ណដែលបានបង្ហាញ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឲ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គលដែលបង្ហាញបានត្រឹមត្រូវ និង ពេញលេញរបស់សុរិយោដីបានឡើយ។ បើវិធានការបណ្ដេញចេញ បង្គាប់ដោយតុលាការអាចបណ្ដាលឲ្យមានភាពវឹកវរ ឬមានផលវិបាកធ្ងន់ធ្ងរដល់សង្គម អាជ្ញាធរមានសមត្ថកិច្ចអាចសុំព្យួរការអនុវត្តន៍ជាបណ្ដោះអាសន្នបាន។ នៅក្នុងខ្លឹមសារនេះដែរលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ ស្របតាមលក្ខខណ្ឌច្បាប់ភូមិបាល។ លទ្ធកម្មនេះមិនអាចជាគុណប្រយោជន៍ដល់ភាគីកេងបន្លំឡើយ។ ដើម្បីក្លាយទៅជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ ដោយពិតប្រាកដ គ្មានហឹង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត្ត។ ភាគីត្រូវកាន់កាប់អចលនវត្ថុ ដោយពិតប្រាកដ គឺថា ភាគីភោគៈកាន់កាប់ដោយខ្លួនឯងក្ដី ឲ្យអ្នកដទៃធ្វើឲ្យក្ដី ត្រូវកាន់កាប់ឲ្យឃើញថា នោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលដៅខ្លួនជាភាគី យ៉ាងផ្ដាច់មុខកុំឲ្យឃើញថាការដែលធ្វើនោះគឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៀតវិញ។ ប្រសិនបើភោគីពិតប្រាកដមិនចេញមុខ នៅពីក្រោយភោគីមិនប្រាកដ ភោគីនោះមិនអាចទាមទារបណ្ណភោគៈ ដើម្បីលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ។ ភោគៈនោះត្រូវចាត់ទុកជាមោឃៈ ហើយភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានហិង្សា គឺថា ភោគៈដែលបានមកដោយហិង្សាមិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ក៏ប៉ុន្តែ បើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជន[6] ឥតសិទ្ធិ សោះមកដណ្ដើមនោះហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានដោយសន្តិភាព តាំងពីដើមមកនោះទេ។ ភោគី ត្រូវកាន់កាប់អចលនវត្ថុដោយដឹងឮជាសាធារណៈ គឺថា ភោគីត្រូវកាន់កាប់ដោយឥតលាក់បាំងអ្នក ទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះទេ។ ភាគីត្រូវកាន់កាប់អចលនវត្ថុដោយសុចរឹត គឺថាភោគីមិនដឹង ពិសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញត្តិនៃច្បាប់ភូមិបាលបង្កើតបានជា កម្មសិទ្ធិភណ្ឌិកលើអចលនវត្ថុ។ ភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្ដូរ ផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួញ។ ការរង់ចាំការរៀបចំឡើងវិញនូវប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី អាជ្ញាធរសមត្ថកិច្ច ត្រូវបន្តចេញបណ្ណសម្គាល់

[6] តតិយជន សំដៅដល់ជនទីបី ឬជនដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត។ ជនដែលមិនមែនជាភាគីក្នុងរឿងក្ដី។

សិទ្ធិកាន់កាប់អចលនវត្ថុ ចំពោះភោគៈដែលមានកន្លងមក មុខច្បាប់ភូមិបាលចូលជាធរមាន។ បណ្ណសម្គាល់សិទ្ធិនេះជាវត្ថុតាងនៃសិទ្ធិកាន់កាប់ ប៉ុន្តែមិនមែនជាបណ្ណកម្មសិទ្ធិទេ ហើយក៏មិនមែនជាលិខិតដែលតវ៉ាមិនបាននោះទេដែរ។ បណ្ណសម្គាល់សិទ្ធិនេះអាចនឹងបង្កើតជាបណ្ណស្ថាពរ នៃកម្មសិទ្ធិ ដែលមានលក្ខណៈមិនអាចតវ៉ាបាន លុះត្រាតែគ្មានការជំទាស់នៅពេលបង្កើតសៀវភៅគោលបញ្ជីដី។ ប៉ុន្តែក្នុងករណីមានការជំទាស់ទាមទារការកំណត់ ថានរណាជាភោគីស្របច្បាប់នៃអចលនវត្ថុនោះត្រូវផ្អែកលើការស៊ើបអង្កេតបន្ថែមនូវរាល់ភស្តុតាងដែលពាក់ព័ន្ធទាំងអស់។ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ គឺជាភស្តុតាងមួយប៉ុន្តែមិនអាចកំណត់តែឯកឯងបានទេ។ ត្រូវហាមឃាត់ការចេញបណ្ណ សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលមិន អាចយកធ្វើជារបស់ឯកជនបាន ឬដែលមិនបានកាន់កាប់ តាមលក្ខខណ្ឌស្របច្បាប់។ ចំពោះបុគ្គលទាំងឡាយដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹង ឬដោយ ធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា ៣០ និងមាត្រា៣១ នៃច្បាប់ភូមិបាល។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃលទ្ធកម្មសិទ្ធិបានឡើយ ទោះក្នុងករណីណាក៏ដោយ។ ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅតែមិនទៀងទាត់ និងខុសច្បាប់ដដែល ប្រសិនជាស្ថានភាពនោះ មិនកើតចេញពីការអនុញ្ញាត តាមបែបផែន ដែលបានកមណត់ដោយច្បាប់ទេនោះ។ បុគ្គលកាន់កាប់ខុសច្បាប់ត្រូវបង្ខំឲ្យចាកចេញជាបន្ទាន់ ហើយត្រូវទទួលទណ្ឌកម្ម ដែលបានកំណត់ក្នុងមាត្រា ៣៥៩ នៃច្បាប់ភូមិបាល។ បុគ្គលកាន់កាប់ ខុសច្បាប់ គ្មានសិទ្ធិទាមទារសំណងសម្រាប់ចំណាយលើការងារ និងការកែលំអដែលខ្លួនបានធ្វើ នៅលើអចលនវត្ថុនោះឡើយ។ រីឯបណ្ណ ឬឯកសារសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុជាទ្រព្យ សម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ឲ្យដល់បុគ្គលឯកជន ត្រូវទុកជាមោឃៈនិងគ្មានតម្លៃគតិយុត្ត។ ភ្នាក់ងារដែលចេញបណ្ណ ឬឯកសារសម្គាល់សិទ្ធិកាន់កាប់នេះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ទាំងខាងស៊ីវិលនិងព្រហ្មទណ្ឌ។ អាជ្ញាធរដែលព្រងើយកន្តើយចំពោះការរំលោភខុសច្បាប់តាមរបៀបនេះ ដែលខ្លួនបានដឹងច្បាស់ ទុកជាអ្នករួមគំនិត ហើយត្រូវទទួលទោសដូចគ្នានឹងចារីដែរ[7]។

ក្នុងករណី ដែលអាជ្ញាធរមានសមត្ថកិច្ចមិនព្រមចេញបណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុនោះអាចធ្វើពាក្យបណ្តឹងទៅក្រសួងរៀបចំដែនដីនគរូប

[7] ច្បាប់ភូមិបាល មាត្រា ៤៤, ភ្នំពេញ, ឆ្នាំ ២០០១

នីយកម្ម និងសំណង់។ ការចេញបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ដោយអាជ្ញាធរមានសមត្ថកិច្ច ឲ្យបុគ្គលក្រៅពី ភោគីពិតប្រាកដ ដែលបានកាន់កាប់អចលនវត្ថុ គឺជាបទល្មើស ដែលត្រូវទទួលទោសតាមបញ្ញត្តិនៃមាត្រា២៦១ នៃច្បាប់ភូមិបាល ហើយវិវាទរវាងភោគីចំពោះអចលនវត្ថុមួយ នឹងត្រូវឲ្យធ្វើការស៊ើបអង្កេត និងដោះស្រាយតាមនីតិវិធី ដែលបានកំណត់។ ចំពោះលទ្ធផល នៃការស៊ើប អង្កេតត្រូវដាក់ជូនគណៈកម្មការសុរិយោដី ដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះត្រូវធ្វើសេចក្តីសម្រេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ របៀបលទ្ធកម្មនៃកម្មសិទ្ធិៈការផ្ទេរសិទ្ធិអចលនវត្ថុ រវាងបុគ្គលឯកជនតាមរយៈការលក់ ការដូរការធ្វើអំណោយ ឬតាមរយៈសន្តតិកម្មត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់។ នៅក្នុងខ្ទឹមសារនេះ ការសិក្សាស្រាវជ្រាវបានផ្តោតទៅលើចំណុចជាចម្បងចំនួន៤រួមមាន(ទី១) លទ្ធកម្មដោយការលក់ អចលនវត្ថុ (ទី២) លទ្ធកម្មដោយការដូរអចលនវត្ថុ (ទី៣) លទ្ធកម្មដោយសន្តតិកម្ម និង (ទី៤) លទ្ធកម្មដោយប្រទានកម្ម។ លទ្ធកម្មដោយការលក់អចលនវត្ថុ: ការលក់អចលនវត្ថុ គឺជាកិច្ចសន្យា ដែលអនុញ្ញាតឲ្យផ្ទេរសិទ្ធិកម្មសិទ្ធិ នៃអចលនវត្ថុពីអ្នកលក់ទៅឲ្យអ្នកទិញ ដោយអ្នកទិញត្រូវបង់ប្រាក់ថ្លៃអចលនវត្ថុនោះឲ្យទៅអ្នកលក់។ ការផ្ទេរកម្មសិទ្ធិមិនអាចជំទាស់ពីតតិយជនបាន លុះត្រាតែកិច្ចសន្យាលក់អចលនវត្ថុត្រូវបានធ្វើជាលាយលក្ខណអក្សរ តាមទម្រង់លិខិតយថាភូតធ្វើដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។ កិច្ចសន្យាលក់តែឯកឯងមិនអាចចាត់ទុកជាការផ្ទេរកម្មសិទ្ធិទ្រព្យនោះ ដោយពេញលក្ខណៈច្បាប់បានឡើយ។ បុគ្គលដែលមិនអាចលក់បានគឺៈបុគ្គលដែលមិនមែនជាកម្មសិទ្ធិករនៃទ្រព្យដែលត្រូវលក់ កម្មសិទ្ធិករនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករអវិភាគផ្សេងទៀត បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស។

### ខ. របបកម្មសិទ្ធិឯកជន

នៅក្នុងខ្ទឹមសារនេះ ការសិក្សាស្រាវជ្រាវបានលើកយកមកបង្ហាញនូវចំណុចជាចម្បងចំនួន ៥ ដែលមានដូចជា(ទី១) ការអាស្រ័យផលនៃកម្មសិទ្ធិ (ទី២) ឧបាគមន៍ផលិតផលនិងផលទុននៃកម្មសិទ្ធិ (ទី៣) ការកើនឡើងនៃកម្មសិទ្ធិ (ទី៤) ការជួលអចលនវត្ថុ និង(ទី៥) វិធានដី។

-ការអាស្រ័យផលនៃកម្មសិទ្ធិឬកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុ មានសិទ្ធិប្រើប្រាស់ អាស្រ័យផលនិងចាត់ចែងទ្រព្យរបស់ខ្លួនផ្តាច់មុខ និងទូលំទូលាយ កុំតែយកទ្រព្យនោះទៅប្រើប្រាស់ក្នុងបទណាមួយ ដែលច្បាប់បានហាមឃាត់។ កម្មសិទ្ធិករនៃទ្រព្យមិនអាចប្រើប្រាស់ទ្រព្យនោះក្នុងគោលដៅព្យាបាទ ឬរំខានដល់តតិយជនជាពិសេសដល់អ្នកជិតខាងរបស់ខ្លួនឡើយ ហើយកម្មសិទ្ធិករនៃដីអាចធ្វើនៅ

លើដី រាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួន លើកលែងតែមានច្បាប់ហាមឃាត់។ការរៀបចំ ឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់។ ជាមួយគ្នានេះដែរ កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចរៀបចំ ឬកែប្រែបានដោយសេរីនូវប្រភេទ និងរចនាសម្ព័ន្ធ ដើមនៃទ្រព្យសម្បត្តិរបស់ខ្លួន សរបតាមការប្រើប្រាស់ដែលខ្លួនចង់ធ្វើតាមការកំណត់នៃច្បាប់។ ចាត់ទុកជាការកែប្រែប្រភេទ ឬរចនាសម្ព័ន្ធដើម នៃទ្រព្យជាអចលនវត្ថុក្នុងន័យច្បាប់ភូមិបាលមាន ជាអាទិ៍ ការគាស់រានដី ការកាប់ព្រៃឈើ ការដាំដំណាំលើដីនោះ ការចាក់បំពេញដី ការឈូសពង្រាបភ្នំ ការជីករុករក ការជីកយកដីចេញ ការជីកអណ្តូងរ៉ែ ឬកន្ទេងយកថ្ម ការរៀបចំ ឬការធ្វើឲ្យស្ងួតដែនវារីជាតិ ការរៀបចំដីកសិកម្មទៅជាទីប្រជុំ ការបង្កើតទីតាំងរោងចក្រ។ចំពោះកម្មសិទ្ធិករនៃផ្ទៃដី គឺជាកម្មសិទ្ធិការនៃផ្នែកក្រោមដី និងរាល់អ្វីៗដែលអាចទាញកផលបានកុំឲ្យតែផ្ទុយនឹងបញ្ញត្តិ នៃមាត្រា៨៨និងមាត្រា៨៩នៃច្បាប់ភូមិបាល។ប៉ុន្តែកម្មសិទ្ធិករមិនអាចទាមទារយកជាកម្មសិទ្ធិ ជាបដិមាករ ចម្លាក់ ក្រឡោត ឬបុរាណវត្ថុគ្រប់ប្រភេទដែលបានរកឃើញ។ ស្នាដៃទាំងនេះ ជាចំណែកនៃបេតិកភណ្ឌជាតិ ហើយត្រូវតែប្រគល់ឲ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។កម្មសិទ្ធិករនៃលំហអាកាសនិងវត្ថុធាតុអចិន្ត្រៃយ៍ដែលស្ថិតនៅចំពីលើដីជាកម្មសិទ្ធិរបស់ខ្លួន លើកលែងតែបណ្ដាញខ្សែអគ្គីសនី និងទូរគមនាគមន៍ ដែលត្រូវអនុវត្តតាមច្បាប់ដោយឡែក។ជាពិសេសកម្មសិទ្ធិករអាចកាប់មែកឈើ អ្នកជិតខាងដែលលយចូលមកលើកម្មសិទ្ធិរបស់ខ្លួន ឬបេះយកផលផ្លែឈើនោះបាន។ប៉ុន្តែកម្មសិទ្ធិករមិនអាចហាមឃាត់ការហោះហើរដោយអាកាសយានគ្រប់ ប្រភេទបានឡើយ ហើយកម្មសិទ្ធករនៃទ្រព្យជាអចលនវត្ថុ អាចបង្កើតបានជាប្រាតិភោគនៃកិច្ច សន្យាស្របតាមបញ្ញត្តិ ដែលបានដាក់កំណត់ក្នុងច្បាប់ភូមិបាល។ជាមួយគ្នានេះដែរកម្មសិទ្ធិករនៃទ្រព្យអាចចាត់ចែងផលិតផលនិងការកើនឡើងតាមធម្មជាតិ ឬតាមសម្បនិម្មិត្តដែលផ្សំគ្នា។

- ឧបាគមន៍[8] ផលិតផល និងផលទុននៃកម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុ មានសិទ្ធិទទួលផលគ្រប់បែបយ៉ាងពីទ្រព្យនោះមានផលធម្មជាតិ និងផលស៊ីវិលតាមសិទ្ធិឧបាគមន៍។ផលធម្មជាតិគឺផលដែលកើតពីដី ដោយឯកឯង ឬ ដោយអំពើរបស់មនុស្ស។ចំណែកផលស៊ីវិល គឺផលទុនធនលាភ និងការប្រាក់។ផលដែលកើតចេញពីដំណាំលើទ្រព្យ ជាដីរបស់កម្មសិទ្ធិករនៃទ្រព្យនោះលុះត្រាតែកម្មសិទ្ធិករនោះបានសង

[8] *ឧបាគមន៍* (ការបានជាកម្មសិទ្ធិនូវវត្ថុរណប) (សទ្ធានុក្រមសេដ្ឋកិច្ច វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បោះពុម្ពនៅខែតុលា ២០០៦)

តម្លៃ នៃការក្តួររាស់ ពលកម្ម និងពូជដែលបាន ធ្វើជាយថាហេតុដោយគតិយថន។

- ការកើននៃកម្មសិទ្ធិ ការកើននៃកម្មសិទ្ធិ ចែកចេញជាពីរសំខាន់ៗ គឺ (ទី១) ការកើនដោយអំពើរបស់មនុស្ស និង (ទី២) ការកើនដោយធម្មជាតិ។

+ ការកើនដោយអំពើរបស់មនុស្ស៖ សំណង់ដំណាំនិងការណ៍ទាំងឡាយ ដែលបានធ្វើនៅលើដី ឬនៅក្រោមដីត្រូវបានចាត់ទុកថា បានធ្វើដោយកម្មសិទ្ធិករដោយសោហ៊ុយផ្ទាល់ខ្លួនហើយជារបស់កម្មសិទ្ធិករនោះលើកលែងតែមានកស្តុតាងផ្ទុយពីនេះ។កម្មសិទ្ធិករ នៃដីដែលបានធ្វើការសាងសង់ដាំដុះឬរៀបចំ ដោយប្រើសម្ភារដែលមិនមែនជារបស់ខ្លួនត្រូវចេញថ្លៃសម្ភារៈទាំងនោះឲ្យម្ចាស់គេវិញ។

កាលបើដំណាំ សំណង់ និងការរៀបចំទាំងឡាយ ត្រូវបានធ្វើឡើងដោយបំពានពីតតិយជននិងដោយសម្ភាររបស់ខ្លួនកម្មសិទ្ធិករ នៃដីមានសិទ្ធិរក្សាទុករបស់ទាំងនោះ ឬបង្ខំឲ្យតតិយជននោះដកយកចេញបាន។ប្រសិនបើកម្មសិទ្ធិករនៃដីសុំដកយកចេញនូវដំណាំ និងសំណង់ដែលបានធ្វើ ដោយបំពាន សោហ៊ុយនៃការដកចេញជាបន្ទុករបស់តតិយជន ហើយគ្មានសំណងណាមួយសម្រាប់អ្នកនោះទេ។ តតិយជននោះក៏អាចត្រូវផ្តន្ទាទោសឲ្យសងជម្ងឺចិត្តផងដែរ ប្រសិនបើមានទ្រព្យសវនកម្មជាយថាហេតុដល់កម្មសិទ្ធិករនៃដី។ប្រសិនបើកម្មសិទ្ធិករចង់រក្សាទុកដំណាំ និង ការណ៍ទាំងនោះកម្មសិទ្ធិករនោះត្រូវសងថ្លៃសម្ភារនិងថ្លៃការងារដោយមិនគិតដល់តម្លៃលើសតិច ឬច្រើនដែលអាចនិងកើនតម្លៃនោះទេ។ចំពោះដំណាំ សំណង់ ឬការណ៍ទាំងឡាយ ដែលបានធ្វើ ដោយតតិយជន ដោយសុចរិត ដូចមានចែងក្នុងមាត្រា៣៨នៃច្បាប់ភូមិបាលកម្មសិទ្ធិករមិនអាចសុំដកយកចេញនូវការណ៍ដំណាំ ឬការរៀបចំទាំងនោះបានឡើយ។ កម្មសិទ្ធិករមានជម្រើសពីរ ឬមួយសងថ្លៃសម្ភារនិងថ្លៃពលកម្ម ឬមួយសងជាទឹកប្រាក់ស្មើនិងតម្លៃលើសដែលដីបានកើនតម្លៃ ក៏បាន។

+ការកើនដោយធម្មជាតិ៖ដីដុះដែលកើនឡើងជាបន្តបន្ទាប់ បន្តិចម្តងៗលើដីជាប់មាត់ទន្លេ ឬស្ទឹង ព្រែកហៅថាល្បាប់។ ល្បាប់ត្រូវបានជាប្រយោជន៍ដល់កម្មសិទ្ធិករដែលមានដីជាប់មាត់ទឹកដែលនាវា ឬក្បូនចេញចូលបានបណ្តែតបាន ឬមិនបាន។ក្នុងករណីនាវា ឬក្បូនចេញចូលបានបណ្តែតបានកម្មសិទ្ធិករត្រូវទុកផ្លូវសម្រាប់ទាញពួរនាវាស្របទៅតាមបទបញ្ញាទាំងឡាយ។ ចំពោះដី ដែលកើនឡើងដោយសារចរន្តទឹកហូរនាំល្បាប់បន្តិចម្តងៗមើលមិនដឹងពីច្រាំងម្ខាងទៅគរនៅច្រាំងម្ខាងទៀតជាប់ជាមួយនិងដីអ្នកផ្សេងកម្មសិទ្ធិករនៃដីដែលជាប់នឹងដីដុះនោះ ទទួលបានគុណប្រយោជន៍នៃល្បាប់នេះដោយមិនអាចឲ្យអ្នកមានដីនៅច្រាំងម្ខាងដែលបាត់ដីមកតវ៉ា យកដីដែលបាត់នោះបានឡើយ។ ប្រសិនជាទន្លេ ឬស្ទឹង ព្រែកដែលនាវាចេញចូលបាន ឬមិនបាន

នាំយកចេញដោយកម្លាំងទឹកជំនន់ភ្លាមៗនូវចំណែកដីដ៏ធំ និងអាចស្គាល់បានពីច្រាំងម្ខាងទៅភ្ជាប់ នឹងដីខាងក្រោមខ្សែទឹក ឬនឹងច្រាំងម្ខាងទៀត,កម្មសិទ្ធិករនៃដីដែលបាក់ចេញអាចតវ៉ាយកជាកម្មសិទ្ធិរបស់ខ្លួនបាន តែត្រូវដាក់ពាក្យបណ្ដឹងក្នុងរយៈពេលយ៉ាងយូរមួយឆ្នាំ គិតពីថ្ងៃកើតហេតុ នៃព្រឹត្តិការណ៍នោះ បើហួសរយៈពេលនោះ បណ្ដឹងទាមទារមិនត្រូវបានយកមកដោះស្រាយឡើយ។ ចំពោះកោះធំ កោះតូចនិងដីចុះទាំងឡាយដែលនឹងកកើតថ្មីក្នុងផ្ទៃទន្លេ ឬស្ទឹងព្រែក ដែលនាវាឬក្បូនចេញចូល បាន បណ្ដែតបាន គឺជារបស់រដ្ឋ។ កោះធំ កោះតូចនិងដីដុះទាំងឡាយ ដែលនឹងកកើតថ្មីក្នុងស្ទឹង ព្រែក ដែលនាវា ឬក្បូនចេញចូលមិនបាន បណ្ដែតមិនបាន ត្រូវបានមកកម្មសិទ្ធិករនៃដីជាប់ច្រាំង ដែលសងខាង គិតពីបន្ទាត់ពុះពាក់កណ្ដាលស្ទឹង។ ប្រសិនបើស្ទឹង ព្រែក ឬទន្លេបង្កើតជាផ្លូវទឹកថ្មីមួយ កាត់យកដីកម្មសិទ្ធិអ្នកនៅជាប់មាត់ទឹកណាម្នាក់ ហើយបង្កើតបានជាកោះមួយកម្មសិទ្ធិករ នោះរក្សាបានសិទ្ធិជាកម្មសិទ្ធិ នៃដីរបស់ខ្លួន ដែលដាច់នោះដដែល ទោះបីជាកោះនោះដុះក្នុងទន្លេ ឬស្ទឹងព្រែក ដែលនានាក្បូន ចេញចូលបានបណ្ដែតបានក៏ដោយ។ ប៉ុន្តែប្រសិនជាទន្លេ ឬស្ទឹងព្រែកណាមួយដែលនាវា ឬក្បូនចេញចូលបានបណ្ដែតបានបង្កើតជាផ្លូវទឹកថ្មីមួយ ដោយបោះបង់ចោលនូវផ្លូវទឹកចាស់ កម្មសិទ្ធិករដែលមានដីជាបើច្រាំងនោះអាចធ្វើលទ្ធកម្មសិទ្ធិក្នុងផ្ទៃទន្លេ ឬស្ទឹងព្រែកចាស់ដែលគោកនោះបាន ហើយម្នាក់ៗត្រូវបានតាមសិទ្ធិរបស់ខ្លួនរហូតដល់ខ្សែបន្ទាត់ ដែលពុះពាក់កណ្ដាលទន្លេ ឬស្ទឹងព្រែកនោះ។ ថ្លៃដីនៃផ្លូវទឹកចាស់នោះត្រូវបានកំណត់ដោយអ្នកជំនាញ ដែលតែងតាំងដោយតុលាការខេត្ត-ក្រុងនៅទីនោះតាមពាក្យស្នើសុំពី អាជ្ញាធរ ខេត្ត-ក្រុង ឬ ភាគី ដែលមានប្រយោជន៍ក្នុងរឿងនោះ។ បើកម្មសិទ្ធិករ នៅមាត់ទឹកនោះមិនចង់បានដីនោះតាមថ្លៃដែលអ្នកជំនាញកំណត់ទេ អាជ្ញាធរត្រូវលក់ឡាយឡុងផ្លូវទឹកចាស់នោះឲ្យសាធារណៈជន។ ថ្លៃដែលបានមកពីការលក់នោះ ត្រូវយកទៅចែកឲ្យកម្មសិទ្ធិករ ដែលមានដីដាច់ទៅនោះ តាមសមាមាត្រនៃដីដែលខូចខាតរៀងៗខ្លួន។

-**ការជួលអចលនវត្ថុ៖** កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុ អាចជួលទ្រព្យរបស់ខ្លួនឲ្យអ្នកដទៃបាន។ ការជួលជាកិច្ចសន្យាដែលកម្មសិទ្ធិករនៃទ្រព្យមួយប្រគល់កម្មសិទ្ធិនោះឲ្យជនណាម្នាក់ប្រើប្រាស់ក្នុងរយៈពេលណាមួយ ដោយយកជាប្រាក់ឈ្នួលមកវិញយ៉ាងទៀងទាត់ តាមសមាមាត្រនៃរយៈពេលប្រើប្រាស់។ កិច្ចសន្យានៃការជួលអចលនវត្ថុហៅថាភតិសន្យា។ កិច្ចសន្យាជួលអចលនវត្ថុមានពីរយ៉ាងគឺ ការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលកំណត់។ ការជួលរយៈពេលកំណត់មានការជួលរយៈពេលខ្លី អាចបន្តជាថ្មីបាន និងការជួលរយៈពេលវែង ១៥ (ដប់ប្រាំ) ឆ្នាំ ឬលើស។ កិច្ចសន្យាជួលរយៈពេលមិនកំណត់ ឬរយៈពេលខ្លី

ហើយអាចបន្តជួលជាថ្មីបាន បង្កើតជាទំនាក់ទំនងផ្ទាល់ខ្លួនរវាងភតិសន្យាបតីនិងអ្នកជួល។ ការជួលបន្តតតិយជនអាចធ្វើទៅបានលុះត្រាតែមានការព្រមព្រៀងដោយជាក់លាក់ ឬការអនុញ្ញាតតិកម្មសិទ្ធិករ។

កិច្ចសន្យាជួលរយៈពេលវែងបង្កើតបានជាកម្មសិទ្ធិកណ្ដិកលើអចលនវត្ថុ។ សិទ្ធិនេះអាចត្រូវបានប្រគល់ឲ្យដោយមានថ្លៃ ឬផ្ទេរបន្តតាមរយៈសន្តិកម្ម។ ទ្រព្យដែលបានជួលរយៈពេលវែង អាចជាកម្មវត្ថុនៃការរៀបចំ និងការបំប្លែងកុំឲ្យតែការងារនោះមានអានុភាពបំផ្លាញ ឬ បំប្លែងជាសារវន្តនូវសភាពដើមនៃវត្ថុនោះ ឬលើកលែងក្នុងករណីមានចែងដោយឡែកក្នុងភតិសន្យា។ នៅពេលផុតកំណត់នៃការជួលភតិសន្យាបតី ឬទាយាទទាំងឡាយរបស់ជននេះទទួលបានមកវិញនូវកម្មសិទ្ធិពេញលេញនៃសំណង់ ដោយគ្មានការសងសោហ៊ុយក្នុងការរៀបចំ ឬការកែលម្អទាំងឡាយដែលបានធ្វើដោយអ្នកជួល។ ភតិសន្យាបតី ឬទាយាទ មិនអាចបង្ខំអ្នកជួលឲ្យប្រគល់អចលនវត្ថុតាមស្ថានភាពដើមបានឡើយ បើសិនជាអ្នកជួលគោរពបទបញ្ញត្តិ។

**-វិធានដី៖** សិទ្ធិ និងកាតព្វកិច្ចនៃកម្មសិទ្ធិត្រូវបានកម្រិតដោយវិធានដីទាំងឡាយដោយសំដៅជានាការពារផលប្រយោជន៍ទូទៅដែលកំណត់ដោយច្បាប់។ បែបបទសំណង់និងលក្ខខណ្ឌនៃការរៀបចំដែនដី និងនគរូបនីយកម្ម ចំពោះកម្មសិទ្ធិករនឹងកំណត់ដោយអនុក្រឹត្យ។ ការប្រើប្រាស់កម្មសិទ្ធិ ដែលមិនស្របតាមវិធានដី តែជាប់កិច្ចសន្យាមុនប្រកាសឲ្យប្រើប្រាស់នេះមិនអាចប៉ះពាល់បានឡើយ។ ប៉ុន្តែការប្រើប្រាស់នោះមិនអាចពង្រីកថែម នៅក្រោយពេលប្រកាសឲ្យប្រើវិធានដីបានកម្រិតឬហាមឃាត់បានឡើយ។ ក្នុងករណីបន្ទាន់ ឬត្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈ ច្បាប់អាចបញ្ញត្តិថែមទៀត នូវការអនុវត្តន៍បន្ទាន់នៃវិធានដីកម្រិតពីការប្រើប្រាស់កម្មសិទ្ធិដី ដែលមានលក្ខណៈជាសណ្ដាប់ធ្នាប់សាធារណៈ។

សរុបមកយើងឃើញថា យន្តការពាក់ព័ន្ធនឹងច្បាប់ភូមិបាល បានឆ្លុះបញ្ចាំងឲ្យឃើញពីធន្ទៈនៃច្បាប់ភូមិបាលក្នុងការជួយពង្រឹងដល់ការអនុវត្តន៍ការគ្រប់គ្រងដីធ្លីឲ្យមានប្រសិទ្ធិភាពជាពិសេសការបង្កឲ្យមានលទ្ធកម្មនៃកម្មសិទ្ធិលើអចលនទ្រព្យសាធារណៈរបស់រដ្ឋ និងឯកជនរបស់រដ្ឋ ប្រកបដោយសុវត្ថិភាព ទំនុកចិត្ត និងបានធ្វើឲ្យកម្មសិទ្ធិករបានយល់ច្បាស់ថា អចលនវត្ថុដែលខ្លួនកំពុង កាន់កាប់ប្រើប្រាស់ ស្នាក់នៅអាស្រ័យផល ឬបម្រុងលក់ទិញ យកមកធ្វើជាកម្មសិទ្ធិ ថាពិតជាស្របច្បាប់ឬយ៉ាងណា?

### ២.៣. ទម្រង់នៃកម្មសិទ្ធិ និងប្រាតិភោគអចលនវត្ថុ

#### ក. ទម្រង់កម្មសិទ្ធិ

នៅក្នុងខ្លឹមសារនេះការសិក្សាស្រាវជ្រាវបានផ្ដោតលើដីដែលមានចំណុចចម្បងចំនួន

៣គឺ (ទី១)កម្មសិទ្ធិអវិភាគ(ទី២)សហកម្មសិទ្ធិ និង(ទី៣)អឌ្ឍសិទ្ធិភាព។

-កម្មសិទ្ធិអវិភាគៈគឺជាកម្មសិទ្ធិលើទ្រព្យតែមួយដែលជារបស់បុគ្គលច្រើននាក់។បុគ្គលទាំងនោះគឺជាកម្មសិទ្ធិករអវិភាគ ហើយដែលម្នាក់ៗមានចំណែករបស់ខ្លួនក្នុងទ្រព្យនោះ ប៉ុន្តែទ្រព្យនោះមិនអាចពុះចែកគ្នាបានឡើយ។ ភាគបែងនៃកម្មសិទ្ធិអវិភាគចាត់ទុកថាស្មើគ្នា។ ក្នុងករណី ដែលការបែងចែកទ្រព្យមិនស្មើគ្នា កម្មសិទ្ធិករម្នាក់ៗមានសិទ្ធិ និងបន្ទុកសមាមាត្រទៅនឹងចំណែករបស់ខ្លួន។កម្មសិទ្ធិករអាចលក់ចំណែក ឬចុះកិច្ចសន្យាផ្សេងៗលើចំណែករបស់ខ្លួនបាន ហើយម្ចាស់បំណុលគេម្នាក់ៗអាចរឹបអូសចំណែកនៃទ្រព្យរបស់អ្នកនោះបាន។ ដូច្នេះ កម្មសិទ្ធិករគ្រប់គ្រងរួមលើកម្មសិទ្ធិអវិភាគ លើកលែងតែមានកិច្ចព្រមព្រៀងផ្ទុយពីនេះ។ កម្មសិទ្ធិករម្នាក់ៗមានតួនាទីគ្រប់គ្រងជាធម្មតា ដូចជាការជួសជុលថែទាំ និងការដាំដុះ។ចំពោះកិច្ចការសំខាន់ ដូចជាការប្ដូរដំណាំ និងការជួសជុលធំៗអាចសម្រេចបាន លុះត្រាតែភាគច្រើននៃកម្មសិទ្ធិករអវិភាគ ដែលមានចំណែករួមគ្នាលើសពីពាក់កណ្ដាលនៃទ្រព្យនោះ បានយល់ព្រម ហើយយកកម្មសិទ្ធិករម្នាក់ៗត្រូវយកចិត្តទុកដាក់ថែទាំ និងការពារប្រយោជន៍រួម។ កម្មសិទ្ធិករអវិភាគអាស្រ័យផលពីទ្រព្យ និងប្រើប្រាស់ទ្រព្យក្នុងព្រំដែនដែល មិនប៉ះពាល់ដល់សិទ្ធិ ការបង្កើតសិទ្ធិកណ្ដិកកម្ម ការផ្លាស់ប្ដូរគោលដៅនៃទ្រព្យ លើកលែងតែមាន វិធានផ្សេងពីនេះ ហើយការចំណាយលើការគ្រប់គ្រងការបង់ពន្ធ និងបន្ទុកផ្សេងៗទៀតលើទ្រព្យអវិភាគ ត្រូវទទួលរ៉ាប់រងដោយកម្មសិទ្ធិករអវិភាគទាំងអស់ តាមសមាមាត្រនៃចំណែករៀងៗខ្លួន លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ។ គ្មានជនណាមួយ អាចត្រូវបានបង្ខំឲ្យនៅក្នុងអវិភាគកម្ម បានទេ។ កម្មសិទ្ធិករអវិភាគម្នាក់ៗអាចទាមទារឲ្យបែងចែកទ្រព្យអវិភាគនោះបាន។ កម្មសិទ្ធិករ អវិភាគទាំងឡាយអាចរក្សាទុកជាបណ្ដោះអាសន្ននូវស្ថានភាពនៃអវិភាគកម្ម ប៉ុន្តែស្ថានភាពបែបនេះមិនអាចចាប់បង្ខំឲ្យលើសពីរយៈពេល៥ឆ្នាំបានឡើយ ហើយលើកលែងតែមានកិច្ចព្រមព្រៀងថ្មី។

អវិភាគកម្មត្រូវចប់ដោយការបែងចែកទ្រព្យតាមរូបភាពដើម ឬដោយការលក់ទ្រព្យ ហើយចែកថ្លៃគ្នា ឬដោយយកកម្មសិទ្ធិករវិភាគម្នាក់ ឬច្រើននាក់ទទួលយកចំណែករបស់អ្នកដទៃ។ប្រសិនបើជាកម្មសិទ្ធិករអវិភាគមិនយល់ព្រមពីរបៀបនៃការចែកអ្នកទាំងនោះត្រូវប្ដឹងទៅតុលាការ ដែលនឹងរៀបចំចែកទ្រព្យ ឬបើទ្រព្យនោះកាលបើចែកទៅនាំឲ្យថយថ្លៃច្រើន តុលាការអាចបង្គាប់ឲ្យលក់ទ្រព្យទាំងមូលទៅឲ្យតតិយជន ឬទៅឲ្យកម្មសិទ្ធករអវិភាគណាម្នាក់ក៏បាន។

- សហកម្មសិទ្ធិ៖ សហកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់ បែងចែកតាមឡូតិ៍ ដែលម្នាក់ៗបានមួយចំណែកជាឯកជន ហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម។

ក្នុងករណីនេះសហកម្មសិទ្ធិទាំងឡាយអាចរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រង និងវិធាននៃការថែទាំ ព្រមទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករជាពិសេសចំពោះផ្នែករួមមួយដោយគោរពតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់ភូមិបាល ហើយប្រសិនបើគ្មានបទបញ្ជានេះទេ សហកម្មសិទ្ធិត្រូវស្ថិតនៅក្រោមបទបញ្ញត្តិទាំងឡាយដែលបានកំណត់ពីមាត្រា១៧៧ ដល់ ១៨៥ នៃច្បាប់ភូមិបាល ហើយសហកម្មសិទ្ធិករទាំងឡាយ មានសិទ្ធិពេញលេញលើចំណែករបស់ ខ្លួន ដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួម ដោយសហកម្មសិទ្ធិករដទៃទៀត។ សហកម្មសិទ្ធិករទាំងនោះអាចផ្ទេរសិទ្ធិដោយសេរី ជួល ឬបង្កើតផលុបភោគ រៀបចំសិទ្ធិប្រើប្រាស់និងអាស្រ័យនៅ ដាក់ហ៊ីប៉ូតែក[9] ដាក់បញ្ចាំនូវចំណែកឯកជនរបស់ខ្លួន។ ប៉ុន្តែ សហកម្មសិទ្ធិករមិនអាចបង្កើតសេវភាពលើចំណែកឯកជនរបស់ខ្លួននោះបានទេ។ ចំពោះរាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់ផ្តាច់មុខនៃសហកម្មសិទ្ធិករណាមួយ បង្កើត បានជាចំណែកនៃអាគារ ឬដីសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងឡាយ ឬសហកម្មសិទ្ធិករខ្លះក្នុងចំណោមនោះបង្កើតបានជាចំណែករួម។

គួរកត់សម្គាល់ថាទ្រព្យរួមមានជាអាទិ៍ : ដី ទីធ្លា ឧទ្យាននិងសួនច្បារ ផ្លូវច្រកចេញចូល ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្តាញទឹក ភ្លើង បណ្តាញឧស្ម័នដែលអាចឆ្លងកាត់ចំណែកឯកជន រួមមានបំពង់ និងក្បាលបំពង់ផ្សេង និងទីកន្លែង នៃសេវារួមដទៃទៀត។ ចំណែកឯកសិទ្ធិបន្ទាប់បន្សំខាងក្រោមនេះក៏ត្រូវទុកជាកម្មសិទ្ធិរួមដែរ ដូចជា សិទ្ធិជីករុករកវត្ថុដែលមានក្នុងដី សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យាន ឬសួនច្បារដែលជាចំណែករួម សិទ្ធិជីករុករកក្នុងធីធ្លា ឧទ្យាន ឬសួនច្បារទាំងនោះ សិទ្ធិនៃអឡ្ឋសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ សិទ្ធិលើកបន្តឲ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើនបង្កើតបានជាចំណែកឯកជនផ្សេងគ្នា។ គ្មានករណីណាមួយដែលកម្មសិទ្ធិករ នៃអគារ

[9] ហ៊ីប៉ូតែក គឺជាពាក្យកម្ចីពីពាក្យបារាំង HYPOTHEQUE ដែលមានក្នុងក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ១៩៧០។

សហកម្មសិទ្ធិករដាន់លើបំផុតអាចលើកបន្ត សម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើបន្តនេះឡើយ។ ផ្ទុយមកវិញ បើសហកម្មសិទ្ធិករដែលធ្វើឲ្យរៀបចំដូចដើមវិញ។ សហកម្មសិទ្ធិករនោះត្រូវទទួលទណ្ឌកម្មដូចក្នុងមាត្រា២៥៧ នៃច្បាប់ភូមិបាល។ ចំណែកជនក្រៅពីសហកម្មសិទ្ធិ ដែលដណ្តើមយកចំណែករួមសម្រាប់ជាលំនៅឯកជនរបស់ខ្លួននឹងត្រូវបង្ខំឲ្យសងកន្លែងដែលកាន់កាប់ខុសច្បាប់ ហើយត្រូវធ្វើឲ្យមានសភាពដូចដើមវិញ។ ក្នុងករណីណាក៏ដោយ អាជ្ញាធរ មានសមត្ថកិច្ច មិនអាចចេញបណ្ណសម្គាល់សិទ្ធិឲ្យបុគ្គលនោះបានឡើយ ពុំនោះទេនឹងត្រូវចាត់ទុកជាអ្នកសមគំនិត នឹងត្រូវទទួលខុសត្រូវរួមជាមួយផងដែរ។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវបង្ខំឲ្យអ្នកកាន់កាប់ខុសច្បាប់រុះរើចេញ។

ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធិករ។ សហកម្មសិទ្ធិករត្រូវធានាការថែទាំចំណែករួម ហើយបន្ទុកនៃការថែទាំងនេះត្រូវចែកគ្នាតាមសមាមាត្រនឹងតម្លៃនៃតឡ្បូតិ៍នីមួយៗ។ រីឯជញ្ជាំងដែលខណ្ឌចំណែកឯកជនត្រូវចាត់ទុកជាជញ្ជាំងអឌ្ឍសិទ្ធិ ហើយចំណែករួមនិងសិទ្ធិបន្ទាប់បន្សំទាំងឡាយមិនអាចជាកម្មសិទ្ធិនៃការបែងចែក ឬបង្ខំឲ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ។ សហកម្មសិទ្ធិករអាចបង្កើតអង្គការគ្រប់គ្រងដែលអាចជាក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងដើម្បីទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ។ អង្គការគ្រប់គ្រងនេះត្រូវជ្រើសរើសដោយមហាសន្និបាតដែលមានការចូលរួមពីសហកម្មសិទ្ធិករទាំងអស់ ដោយគិតតាមសមាមាត្រនៃសារៈសំខាន់នៃឡូតិ៍រៀងៗខ្លួន។ អង្គការគ្រប់គ្រងធ្វើការសម្រេចចិត្តទាក់ទងទៅនឹងការថែទាំសហកម្មសិទ្ធិតាមមតិភាគច្រើន។

-អឌ្ឍសិទ្ធិភាព៖ អឌ្ឍសិទ្ធិភាព គឺជាទម្រង់មួយនៃកម្មសិទ្ធិរួមអនុវត្តទៅលើជញ្ជាំង និងកំពែងដែលនៅត្រង់ព្រំខណ្ឌចែកកម្មសិទ្ធិពីរជាប់គ្នា។ អឌ្ឍសិទ្ធិភាពនៅទីនេះគឺសំដៅទៅលើជញ្ជាំងអឌ្ឍសិទ្ធិ និងស្នាមភ្លោះរបងភ្លឺអឌ្ឍសិទ្ធិ។

-ជញ្ជាំងអឌ្ឍសិទ្ធិ៖ ការជួសជុលនឹងការសាងសង់ជញ្ជាំងអឌ្ឍសិទ្ធិឡើងវិញជាបន្ទុកនៃអ្នកដែលមានសិទ្ធិលើទ្រព្យនោះតាមសមាមាត្រទៅនឹងសិទ្ធិនៃកម្មសិទ្ធិករម្នាក់ៗ។ រាល់កម្មសិទ្ធិករ ដែលពាក់ព័ន្ធអាចឲ្យរួចពីការចេញថ្លៃជួសជុល ឬសាងសង់ជញ្ជាំងអឌ្ឍសិទ្ធិឡើងវិញ ដោយលះបង់ សិទ្ធិនៃអឌ្ឍសិទ្ធិរបស់ខ្លួន លើកលែងតែជញ្ជាំងអឌ្ឍសិទ្ធិទល់ទ្រអគារដែលជារបស់ខ្លួនប៉ុណ្ណោះ។ ចំពោះកម្មសិទ្ធិករណាម្នាក់នៃជញ្ជាំងអឌ្ឍសិទ្ធិ ដោយគ្មានការព្រមព្រៀងពីកម្មសិទ្ធិករម្ខាងទៀតឡើយ។ បើក្នុងករណីគ្មានការព្រមព្រៀងគ្នា តម្រូវឲ្យមានអាជ្ញាកណ្តាលជាអ្នកជំនាញ ដែលនឹង កំណត់មធ្យោបាយចាំបាច់សម្រាប់ការណ៍ថ្មី ដែលមិនរំខានដល់សិទ្ធិរបស់កម្មសិទ្ធិករណាម្នាក់។ កម្មសិទ្ធិករម្នាក់ៗអាចសង់ជាប់នឹងជញ្ជាំងអឌ្ឍ

សិទ្ធិ និងដាក់ធ្នឹមនិងរនូតចូលក្នុងជញ្ជាំងអឡ្ឍសិទ្ធិ ដោយទុកឲ្យសល់ប្រាំសង់ទីម៉ែត្រ តែការងារនេះមិនត្រូវធ្វើឲ្យខូចដល់សិទ្ធិរបស់អ្នកម្ខាងទៀតឡើយ។ ប្រសិនបើកម្មសិទ្ធិករម្ខាងទៀតនោះមានបំណងសង់ពីម្ខាងត្រង់កន្លែងនោះមកវិញដែរកម្មសិទ្ធិករនោះអាចមានសិទ្ធិទាមទារឲ្យបន្ថយធ្នឹមនិងរនូតនោះមកត្រឹមពាក់កណ្ដាលនៃកម្រាស់ជញ្ជាំងវិញ។ ចំពោះកម្មសិទ្ធិករនៃអចលនវត្ថុដែលនៅជាប់ជញ្ជាំងណាមួយរបស់កម្មសិទ្ធិករដទៃ មានសិទ្ធិធ្វើជញ្ជាំងនោះឲ្យទៅជាប់ជញ្ជាំងអឡ្ឍសិទ្ធិទាំងស្រុង ឬមួយចំណែកដោយសងទៅកម្មសិទ្ធិករជញ្ជាំងនោះនូវតម្លៃពាក់កណ្ដាលនៃចំណែកដែលខ្លួនចង់ធ្វើ ឲ្យទៅជាអឡ្ឍសិទ្ធិ បូកនឹកពាក់កណ្ដាលតម្លៃ ដីដែលសង់ជញ្ជាំងពីលើនោះ។ កម្មសិទ្ធិករម្នាក់ៗ អាចសង់បន្តជញ្ជាំងអឡ្ឍសិទ្ធិឲ្យខ្ពស់ជាងមុនបានប៉ុន្តែត្រូវចេញសោហ៊ុយក្នុងការសង់ ការជួសជុលថែទាំជញ្ជាំងដែលខ្ពស់ហួសកំណត់ដើមនោះតែម្នាក់ឯង។ ក្រៅពីនេះកម្មសិទ្ធិនេះកម្មសិទ្ធិករនោះត្រូវចេញសោហ៊ុយសម្រាប់បន្ទុកដែលកើតមកពីការលើកកម្ពស់ហួសទៅលើនោះឲ្យសមតាមតម្លៃផង។ ប្រសិនបើជញ្ជាំងអឡ្ឍសិទ្ធិមិនមាំ មិនអាចទ្រទង់កម្ពស់ដែលលើកទៅនោះបានអ្នកដែលចង់លើកឲ្យខ្ពស់នោះអាចរុះរើធ្វើថ្មីទាំងអស់ ឡើងវិញ ដោយសោហ៊ុយផ្ទាល់ខ្លួន។ រីឯរាល់ជញ្ជាំងដែលត្រូវធ្វើលើសពីកម្រាស់ដើមត្រូវសង់ដាក់ខាង លើដីរបស់ខ្លួនឯង ហើយកម្មសិទ្ធិករម្ខាងទៀតដែលមិនបានជួយកនុងការសាងសង់ឲ្យឡើងខ្ពស់ បើត្រូវការយកសំណង់នោះទុកជារបស់អឡ្ឍសិទ្ធិនៃខ្លួនដែរត្រូវចេញថ្លៃសំណង់ដែលលើកឲ្យខ្ពស់ បូកនឹងពាក់កណ្ដាលនៃផ្ទៃដីដែលសង់ជញ្ជាំងលើសពីកម្រាស់ដើមនោះ។

អំពីស្នាមភ្លោះរបងភ្លឺអឡ្ឍសិទ្ធិ៖ កំពែងអឡ្ឍសិទ្ធិដែលបានបង្កើតឡើងដោយស្នាមភ្លោះក្តី ដោយរបងក្តី ដោយភ្លឺក្តី ត្រូវតែថែទាំដោយសោហ៊ុយរួម។ តែបើកម្មសិទ្ធិករណាម្នាក់ចង់ដកខ្លួនចេញពីកាតព្វកិច្ចនេះកម្មសិទ្ធិករនោះអាចធ្វើបានដោយគ្រាន់តែលះបង់អឡ្ឍសិទ្ធិភាពរបស់ខ្លួនចោលប៉ុណ្ណោះ។ ប៉ុន្តែបើស្នាមភ្លោះភ្លឺនោះជាកន្លែងសម្រាប់បង្ហូរទឹកធម្មតា សហកម្មសិទ្ធិករមិនអាចលះបង់អឡ្ឍសិទ្ធិរបស់ខ្លួនបានឡើយ។ កម្មសិទ្ធិករដែលមានដីជាប់នឹងស្នាមភ្លោះរបង ឬភ្លឺណាដែលមិនមែនជារបស់អឡ្ឍសិទ្ធិទេមិនអាចតម្រូវឲ្យម្ចាស់ស្នាមភ្លោះម្ចាស់របងម្ចាស់ភ្លឺ នោះដាក់ស្នាមភ្លោះរបង ឬភ្លឺនោះជារបស់អឡ្ឍសិទ្ធិឲ្យខ្លួនបានឡើយ ហើយកម្មសិទ្ធិករនៃរបងអឡ្ឍសិទ្ធិអាចជួសជុលកែលម្អ ឬរុះរើរបងនោះរហូតដល់ព្រំប្រទល់កម្មសិទ្ធិរបស់ខ្លួនបាន តែត្រូវធ្វើរបងត្រឹមដីរបស់ខ្លួនឡើងវិញ។ សិទ្ធិនេះអាចប្រើបានក្នុងករណីបើស្នាមភ្លោះ ឬភ្លឺអឡ្ឍសិទ្ធិនោះគ្រាន់ តែប្រើប្រាស់ជារបងប៉ុណ្ណោះ។

### ខ. ប្រាតិភោគអចលនវត្ថុ

ទ្រព្យជាអចលនវត្ថុអាចបង្កើតជាប្រាតិភោគ សម្រាប់ដាក់ធានាសងបំណុលដោយកម្មសិទ្ធិ នៃទ្រព្យនោះតាមរយៈហ៊ីប៉ូតែក ឬការបញ្ចាំ ឬការដាក់ធានា។ ហ៊ីប៉ូតែក គឺជាប្រាតភោគកណ្ឋិកដែលបើកឲ្យម្ចាស់បំណុលប្តឹងឲ្យលក់អចលនវត្ថុនោះ នៅពេលដល់កំណត់សងទោះជាអចលនវត្ថុនោះនៅលើដៃជនណាក៏ដោយ ដើម្បីយកប្រាក់មកសងខ្លួននឹងម្ចាស់បំណុលដទៃទៀតដែលជាអ្នកមានបុព្វសិទ្ធិនិងបុរិមា(បុរិមា គឺជាសិទ្ធិដែលបើកឲ្យជនណាម្នាក់បានអ្វីមួយមុនជនឯទៀត) ដោយមិនដកអចលនវត្ថុនោះពីកម្មសិទ្ធិករទេហើយមាន តែអចលនវត្ថុដែលបានចុះបញ្ជីសុរិយោដីទេ ទើបអាចជាកម្មសិទ្ធិនៃហ៊ីប៉ូតែកបាន។ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យដែលបានដាក់ហ៊ីប៉ូតែកជំនួសការសងបំណុលបានឡើយ។ កិច្ចសន្យាហហ៊ីប៉ូតែកត្រូវរៀបចំតាមរូបមន្តយថាភូតចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ឬអ្នកច្បាប់ណាម្នាក់ ដែលមាននីតិសម្បទាក្នុងរឿងនេះកិច្ចសន្យាត្រូវតែចុះបញ្ជីនៅអង្គភាពសុរិយោដី ។ អាជ្ញាធរមានសមត្ថកិច្ចក្នុងការតាក់តែងកិច្ចសន្យាហ៊ីប៉ូតែក និងទម្រង់ នៃការចុះបញ្ជីនឹងកំណត់ដោយអនុក្រឹត្យ។ កិច្ចសន្យាហ៊ីប៉ូតែកត្រូវសរសេរបញ្ជាក់ឲ្យ ច្បាស់ពីស្ថានភាព ឬបន្ទុកដែលកំណត់ដោយបទបញ្ជាទាំងឡាយនិងតម្លៃនៃទ្រព្យនោះ ហើយប៉ូតែកច្រើនបន្តបន្ទាប់គ្នា អាចត្រូវបានបង្កើតនៅលើទ្រព្យតែមួយ។ ម្ចាស់បំណុលម្នាក់ៗប្រើសិទ្ធិតាមលំដាប់អាទិភាពនៃការចុះហត្ថលេខាចារិកហ៊ីប៉ូតែករបស់ខ្លួន។ ប្រសិនបើកម្មសិទ្ធិករនៃទ្រព្យដាក់ហ៊ីប៉ូតែកមិនសងបំណុលនៅពេលដល់កំណត់ ត្រូវសងម្ចាស់បំណុលម្នាក់ អាចប្តឹងសុំឲ្យលក់ ទ្រព្យនោះបាន ដោយមិនគិតពីលំដាប់នៃហ៊ីប៉ូតែករបស់គេឡើយ។ ម្ចាស់បំណុលនានានឹងត្រូវទទួលសំណងនៅពេលនោះដែរ តាមលំដាប់នៃហ៊ីប៉ូតែកនីមួយៗ។ ទ្រព្យដែលកំពុងដាក់បញ្ចាំមិន អាចដាក់ហ៊ីប៉ូតែកបានឡើយ។

ការដាក់បញ្ចាំ ការដាក់បញ្ចាំអចលនវត្ថុ គឺជាកិច្ចសន្យាដែលតាមកិច្ចសន្យានោះកូនបំណុលប្រគល់ឲ្យម្ចាស់បំណុលរបស់ខ្លួននូវទ្រព្យមួយ ដើម្បីធានាការសងបំណុល។ ម្ចាស់បំណុលមានសិទ្ធិសុំឲ្យលក់ទ្រព្យនោះ ដើម្បីសងបំណុលតាមបុព្វសិទ្ធិ និងបុរិមាដែលខ្លួនមានជាងម្ចាស់ បំណុលដទៃទៀត។ ការប្រើប្រាស់ទ្រព្យដាក់បញ្ចាំ ដោយម្ចាស់បំណុលអាចជំនួសការសងបំណុល នេះជាការប្រាក់តែមួយមុខ ឬជាប្រាក់ដើមនិងការប្រាក់ផងក៏បាន បើសិនមានចែងក្នុងកិច្ចសន្យាបញ្ចាំ។ កិច្ចសន្យាបញ្ចាំអចលនវត្ថុ ត្រូវធ្វើលាយលក្ខណអក្សរតាមរូបមន្តលិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី។ ចំពោះការបញ្ចាំអចលនវត្ថុចាត់ទុកជាបានការហើយតតិយជនមិនអាចជំទាស់

បាន លុះត្រាតែកិច្ចសន្យាបញ្ចាំនោះបានធ្វើតាមបញ្ញត្តិ ដូចមានចែងក្នុងមាត្រា២០៧ នៃច្បាប់ភូមិបាល។ រីឯការមិនបានចុះបញ្ជីនៅអង្គភាពសុរិយោដី នូវកិច្ចសន្យាបញ្ចាំ បណ្តាលឲ្យថ្ងៃះសិទ្ធិប្រាតិភោគណ្ឌិក ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ជាធរមានប៉ុណ្ណោះ។ ចំណែកទ្រព្យដាប់កិច្ចសន្យាបញ្ចាំអចលនវត្ថុ នឹងត្រូវសងមកកូនបំណុលវិញជាចាំបាច់ ចាប់ពីពេលដែលកូនបំណុលបានសងបំណុលទាំងស្រុងរួចហើយ។ ចំពោះកិច្ចសន្យាដែលមិនបានដាក់បញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់សងក្នុងរយៈពេល១០ឆ្នាំ គិតពីថ្ងៃដែលបានចុះកិច្ចសន្យាបញ្ចាំមក បើម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីទាមទារឲ្យសងបំណុលទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានានៃការដាក់បញ្ចាំ។ ដោយឡែក ចំពោះកិច្ចសន្យាដែលបានបញ្ជាក់ថ្ងៃកំណត់ឲ្យសងក្នុងរយៈពេល១០ឆ្នាំ គិតពីថ្ងៃផុតកំណត់រយៈពេលសងបំណុល បើម្ចាស់បំណុលមិនដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីទាមទារឲ្យសងបំណុល ទេ ម្ចាស់បំណុលនោះត្រូវបាត់បង់ការធានា នៃការដាក់បញ្ចាំដែរ ហើយការបាត់បង់ការធានាការដាក់បញ្ចាំនេះ តម្រូវឲ្យម្ចាស់បំណុលប្រគល់អចលនវត្ថុ និងបណ្តាឲ្យកូនបំណុលវិញ តែកូនបំណុលពុំបានរួចពីការសងបំណុលឡើយ ហើយម្ចាស់បំណុលមានសិទ្ធិត្រឹមប្តឹងទារសំណងតាមច្បាប់ធរមានប៉ុណ្ណោះ។ ការលើកលែងបញ្ចាំ ឬការលប់បន្ទុកបញ្ចាំត្រូវធ្វើលេខាចារិកក្នុងបញ្ជីសុរិយោដី តាមការស្នើសុំរបស់កូនបំណុល ឬដោយឯកឯង។ ក្នុងករណីណាក៏ដោយ ម្ចាស់បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យដាប់កិច្ចសន្យាបញ្ចាំបានឡើយ ខណៈណាដែលផ្ទុយពីនេះត្រូវចាត់ទុកជាមោឃៈ។

កិច្ចសន្យាបញ្ចាំអចលនវត្ថុអនុញ្ញាតឲ្យម្ចាស់បំណុលមានសិទ្ធិត្រឹមតែប្តឹងទៅតុលាការឲ្យ ដាក់លក់អចលនវត្ថុ ដោយបង្ខំប៉ុណ្ណោះ ដើម្បីសងខ្លួនជាអាទិភាព ដោយបុរិមានិងបុព្វសិទ្ធិមុនម្ចាស់ បំណុលដទៃទៀត។ បើសិនជាក្នុងរយៈពេលនៃកិច្ចសន្យាបញ្ចាំ ម្ចាស់បំណុលដែលទទួលបញ្ចាំ ទិញអចលនវត្ថុ ដែលដាក់បញ្ចាំ កិច្ចសន្យាទិញនេះត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី ពុំនោះទេនឹងត្រូវទុកជាមោឃៈ។ ម្ចាស់បំណុលដែលបានកាន់កាប់ទ្រព្យដាក់បញ្ចាំ អាចមានសិទ្ធិអាស្រ័យផលពីទ្រព្យនោះ ដូចជាផលភោគីដែរ លុះត្រាតែបានចែងក្នុងកិច្ចសន្យាដាក់បញ្ចាំ។ ម្ចាស់បំណុលមានកាតព្វកិច្ចថែរក្សាទុកទ្រព្យនោះឲ្យដូចជាទ្រព្យរបស់ខ្លួន។ បើទ្រព្យនោះខូចខាត ដោយអំពើ ឬកំហុសណាមួយរបស់ខ្លួន ខ្លួនត្រូវសងតម្លៃខូចខាតនោះដោយកាត់ប្រាក់ក្នុងបំណុលបាន។

នៅពេលផុតរយៈពេលនៃកិច្ចសន្យាបញ្ចាំ ដោយកូនបំណុលបានសងប្រាក់អស់វិញក្តី ឬដោយផុតរយៈពេលប្តឹងដូចមានចែងក្នុងមាត្រា ២០៥ នៃច្បាប់ភូមិបាលក្តី ម្ចាស់

បំណុលត្រូវសងមកកូនបំណុលវិញនូវទ្រព្យឬ តម្លៃនៃទ្រព្យប្រសិនបើទ្រព្យនេះត្រូវបានវិនាស ដោយអំពើ ឬកំហុសណាមួយរបស់ម្ចាស់ បំណុល។ នៅថ្ងៃចប់កិច្ចសន្យាបញ្ចាំ ហើយកូន បំណុលមកសុំលោះទ្រព្យវិញ តែម្ចាស់ បំណុលមិនព្រមឲ្យលោះម្ចាស់បំណុលត្រូវ ជំពាក់កូនបំណុលវិញនូវផលឬផលទុនដែល បានមកពីទ្រព្យដាក់បញ្ចាំ ដោយគិតចាប់តាំង ពីថ្ងៃដែលកូនបំណុលសុំលោះមក។ បើទ្រព្យ ជាដី ហើយកិច្ចសន្យាបញ្ចាំមិនបានចែងឲ្យ ច្បាស់លាស់ពីថ្ងៃកំណត់សងទេ ម្ចាស់ បំណុលនៅតែមានសិទ្ធិយកផលឬផលទុន ដែលជាផលកើតមកពីការយកចិត្តទុកដាក់ របស់ខ្លួនពីការងាររបស់ខ្លួន និងពីទុនរបស់ខ្លួន ក្នុងរដូវដែលកូនបំណុលសុំលោះ។ ប៉ុន្តែបើ ទ្រព្យជាផ្ទះវិញ ហើយកិច្ចសនយាបញ្ចាំ មិន បានចែងឲ្យច្បាស់លាស់ពីថ្ងៃផុតកំណត់ទេ ម្ចាស់បំណុលត្រូវប្រគល់ទ្រព្យដាក់បញ្ចាំនេះ ឲ្យកូន បំណុល គិតពីថ្ងៃដែលកូនបានសង បំណុលរួច ហើយបើកូនបំណុលបានសង បំណុលគ្រប់ចំនួន ហើយម្ចាស់បំណុលមិន អាចរក្សាទុកទ្រព្យដែលបានដាក់បញ្ចាំ ដោយ យកលេសថាកូនបំណុល នៅជំពាក់បំណុល មួយផ្សេងទៀតបានទេ ទោះជាបំណុលក្រោយ នេះដល់កំណត់ទារហើយក៏ដោយ លើកលែង តែមានកិច្ចសន្យាបញ្ចាំថ្មីមួយទៀតលើទ្រព្យ ដដែលនេះ ហើយបានរៀបចំតាមទម្រង់ នៃ ច្បាប់ទៀតផង។ ចំណែកកូនបំណុលអាចប្រើ សិទ្ធិខាងលើនេះ លើទាយាទឬលើសិទ្ធិវន្តនៃ ម្ចាស់បំណុលបាន។

ការដាក់ធានា ការដាក់ធានា គឺជាកិច្ច សន្យាមួយដែលបានសម្រេចឡើង ដើម្បីធានា ការសងបំណុលដែលក្នុងនោះកូនបំណុល ប្រគល់ទៅឲ្យម្ចាស់បំណុលរបស់ខ្លួន មិនមែន ជាទ្រព្យទេ តែជាបណ្ណកម្មសិទ្ធិនៃទ្រព្យនោះ ដែលបានចុះនិទ្ទេសក្នុងបញ្ជីសុរិយោដី។ កិច្ច សន្យាដាក់ធានាត្រូវធ្វើឡើងជាលាយលក្ខអក្សរ តាមរូបមន្តយថាភូតនិងត្រូវចុះលេខាចារិកក្នុង បញ្ជីសុរិយោដី។ ក្នុងករណីណាក៏ដោយម្ចាស់ បំណុលមិនអាចក្លាយជាកម្មសិទ្ធិករនៃទ្រព្យ ជាប់កិច្ចសន្យាដាក់ធានា បានឡើយ។ ខសន្យា ណាដែលផ្ទុយនឹងបទបញ្ញត្តិនេះត្រូវទុកជា មោឃៈ។

កិច្ចសន្យាដាក់ធានាអនុញ្ញាតឲ្យម្ចាស់ បំណុលមានសិទ្ធិត្រឹមត្រូវប្ដឹងទៅតុលាការឲ្យ ដាក់លក់អចលនវត្ថុដោយបង្ខំប៉ុណ្ណោះ ដើម្បី សងខ្លួនជាអាទិភាពដោយបុរិមានិងបុព្វសិទ្ធិ មុនម្ចាស់ បំណុលដទៃទៀត។ បើកូនបំណុល បានសងបំណុល និងការប្រាក់រួចហើយ តាម ពេលកំណត់ ឬមុនពេលកំណត់ ម្ចាស់បំណុល ត្រូវវង្វិលបណ្ណកម្មសិទ្ធិមកកូនបំណុលវិញ ដោយធ្វើលេខាចារិកលើកលែងបន្ទុកក្នុងបញ្ជី សុរិយោដី។ ចំពោះកូនបំណុលត្រូវរក្សាទុក គ្រប់គ្រងនិងប្រើប្រាស់ទ្រព្យរបស់ខ្លួន ប៉ុន្តែមិន អាចធ្វើអ្វីដែលនាំឲ្យបន្ថយតម្លៃទ្រព្យនោះទេ។ សិទ្ធិវន្តនៃកូនបំណុល និងសិទ្ធិវន្តនៃម្ចាស់

បំណុលមានកាតព្វកិច្ចនិងសិទ្ធិដូចគ្នានឹងកូនបំណុលឬម្ចាស់បំណុលរបស់ខ្លួនដែរ[10]។

ទាយាទឬប្រតិសិទ្ធិនៃកូនបំណុលព្រមទាំងសមាជិកទាំងឡាយនៃគ្រួសារដែលអាចប្រកាសថាជាសហកម្មសិទ្ធិករនៃទ្រព្យដាក់ធានាមានកាតព្វកិច្ចនិងសិទ្ធិដូចគ្នានឹងកូនបំណុលដែរ។

ដូច្នេះសរុបសេចក្តីមកយើងឃើញថាទម្រង់នៃកម្មសិទ្ធិ និងប្រាតិភោគអចលនវត្ថុ គឺជាបញ្ញត្តិមួយដ៏សំខាន់ក្នុងការរួមចំណែកដល់ការធ្វើឲ្យមានសុវត្ថិភាព មានសណ្តាប់ធ្នាប់សាធារណៈល្អប្រសើរសម្រាប់កម្មសិទ្ធិករក្នុងការប្រើប្រាស់នូវអចលនទ្រព្យទាំងឡាយដែលមានទម្រង់ជាសហកម្មសិទ្ធិ អឌ្ឍសិទ្ធិជាដើមអាចមានលទ្ធភាពចាត់ចែងប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួនក្តីឬជាប្រយោជន៍រួមក្តី ក្នុងលក្ខណៈហ៊ីប៉ូតែកក្តី ការបញ្ចាំក្តី និងការធានាអចលនវត្ថុក្តី នឹងបានទទួលឧត្តមប្រយោជន៍ពិតប្រាកដ ប្រសិនបើកកម្មសិទ្ធិករ ឬម្ចាស់បំណុលបានយល់ដឹងច្បាស់លាស់ និងគោរពទៅតាមគោការណ៍នៃបញ្ញត្តិទាំងនេះ។

### ២.៤. លក្ខណៈសុរិយោដី

ផ្តោតទៅលើចំណុចជាចម្បងៗចំនួន៤ គឺ (ទី១) រដ្ឋបាលសុរិយោដី (ទី២) សម្រង់សុរិយោដី (ទី៣) បញ្ជី និងឯកសារសុរិយោដី និង(ទី៤) ប័ណ្ណ និងព័ត៌មានសុរិយោដី។

#### ក. រដ្ឋបាលសុរិយោដី

ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា២២៦ បានចែងថា «កម្មសិទ្ធិលើអចលនវត្ថុ ត្រូវបានធានាដោយរដ្ឋ។ តាមគោលដៅនេះ រដ្ឋបាលសុរិយោដី ក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចធ្វើអត្តសញ្ញាណកម្មទ្រព្យកសាងប្លង់សុរិយោដី ចេញបណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗដែលអាចមានលើក្បាលដីនោះ»។ ក្បាលដី ឬឯកសារសុរិយោដី គឺជាផ្ទៃដីមួយជាក់លាក់ស្ថិតនៅក្នុងឃុំ ឬសង្កាត់តែមួយ មិនពុះបំបែកដោយព្រំដាប់មិនដាច់ជារបស់ជនម្នាក់ ឬច្រើននាក់ក្នុងករណីអវិភាគកម្ម ហើយប្រើប្រាស់ក្នុងរូបភាពតែមួយ។ ចាត់ទុកជាព្រំដាប់ មិនដាច់ដែលនាំឲ្យបំបែកក្បាលដីជាច្រើនក្បាលនោះ គឺរបងផ្លូវសាធារណៈ ប្រឡាយ និងផ្លូវទឹក ដែលមានទទឹងយ៉ាងតិចពីរម៉ែត្រ។

រដ្ឋបាលសុរិយោដីមានភារកិច្ច ធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធតាមបញ្ញត្តិ នៃអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។ ធ្វើការពង្រឹងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ តាមនីតិវិធីដែលនឹងបញ្ញត្តិដោយអនុក្រឹត្យ។

[10] ច្បាប់ភូមិបាល . ភ្នំពេញ.ឆ្នាំ២០០១

អនុវត្តការវាស់វែង សុរិយោដី នៃក្បាលដីរួមមាន ការកំណត់ព្រំដី ការបំបែកក្បាលដី ការបង្រួមក្បាលដី និងការកែតម្រូវព្រំប្រទល់នៃក្បាលដី និងជាទូទៅរាល់ការប្រែប្រួលអំពីទំហំដែលបណ្តាលមកពីធម្មជាតិ ឬដោយស្ម័គ្រចិត្ត។ការកសាងសៀវភៅគោលបញ្ជីដីធ្លី ហើយធ្វើលេខាចារិកឈ្មោះកម្មសិទ្ធិករ និងរាល់ ទិន្នន័យដែលប្រមូលបានទាក់ទងទៅនឹងលក្ខណៈរូប ទំហំ និងអត្តសញ្ញាណនៃអចលវត្ថុទាំងនោះ ធ្វើចរន្តការនូវរាល់ការផ្លាស់ប្តូរប្រែប្រួលទាក់ទងទៅនឹងសិទ្ធិដែលកើតឡើងដោយកិច្ចសន្យាផ្ទេរដូចជាការលក់ ការឲ្យការដូរ សន្តិកម្ម ឬពាក់ព័ន្ធនឹងការដូរប្រភេទ ឬស្ថានភាពនៃដីដូចជាការសាងសង់ ការចាក់បំពេញដី ការជីកកកាយយកដីជាដើម។

ក្រៅពីភារកិច្ចទាំងនេះ រដ្ឋបាលសុរិយោដីក៏មានកាតព្វកិច្ចអភិរក្សនូវរាល់ឯកសារសុរិយោដី ដែលមានដូចជាប្លង់សុរិយោដី បញ្ជីឈ្មោះកម្មសិទ្ធិករ សៀវភៅគោលបញ្ជីដីធ្លី និងរាល់ឯកសារគតិយុត្តទាក់ទងទៅនឹងក្បាលដីនីមួយៗ និងចេញវិញ្ញាបនបត្រសម្គាល់អចលនវត្ថុជូនកម្មសិទ្ធិករ និងលិខិតបញ្ជាក់ផ្សេងៗទៀតទាក់ទងទៅនឹងក្បាលដី ហើយនិងការប្រគល់ជូនជនដែលបានដាក់ពាក្យស្នើសុំប្លង់ថតចម្លង និងឯកសារព័ត៌មានទាក់ទងទៅនឹងទីតាំងអត្តសញ្ញាណព្រំដីនិងសិទ្ធិដែលទាក់ទងទៅនឹងក្បាលដីព្រមទាំងមានកាតព្វកិច្ចធ្វើលេខាចារិកនូវរាល់ហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា និងការជួលរយៈពេលវែង ឬសេវាភាពដែលបានបង្កើតឡើងលើទ្រព្យជាអចលនវត្ថុ ហើយផ្តល់ព័ត៌មានទៅគ្រប់ជនដែលសាកសួរមករដ្ឋបាលសុរិយោដីអំពីស្ថានភាពនៃកម្មសិទ្ធិដែលជាកម្មវត្ថុនៃការដាក់ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា និងការដាក់ជួលរយៈពេលវែង ឬសេវភាពនោះ ជាដើម។ សោហ៊ុយសេវាផ្សេងៗដែលទាក់ទងទៅនឹងការបំពេញភារកិច្ចខាងលើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រដ្ឋបាលសុរិយោដីថ្នាក់កណ្តាលជាអគ្គនាយកសុរិយោដី និងភូមិសាស្រ្តទទួលបន្ទុករៀបចំ សម្របសម្រួលនិងត្រួតពិនិត្យប្រតិបត្តិការទាំងឡាយនៃការវាស់វែងសុរិយោដីដែលធ្វើលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា និងរាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី កសាងបញ្ជីឈ្មោះកម្មសិទ្ធិករ កសាងសៀវភៅគោលបញ្ជីដី និងចេញវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។ ក្រៅពីនេះ អគ្គនាយកដ្ឋានសុរិយោដីនឹងភូមិសាស្រ្តត្រូវកំណត់វិធី និងស្តង់ដាទាក់ទងទៅនឹងឯកសារ។ ចំណែកឯរដ្ឋបាលសុរិយោដីខេត្ត-ក្រុង ស្រុក-ខណ្ឌនីមួយៗត្រូវប្រតិបត្តិការណែនាំពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលទទួលធ្វើសម្រង់សុរិយោដី ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដទៃទៀតកាន់កាប់

សៀវភៅគោលបញ្ជី ធ្វើអន្តការជាប្រចាំ ក្រោមការត្រួតពិនិត្យពីរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលរក្សាទុកឯកសារនិងផ្តល់ព័ត៌មានដល់អ្នកស្នើសុំ ហើយរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ត្រូវផ្ញើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ ឃុំ-សង្កាត់ដែលពាក់ព័ន្ធ។ ចំណែកមេឃុំ-ចៅសង្កាត់ ត្រូវអនុញ្ញាតឲ្យជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌនូវការផ្លាស់ប្តូរដែលទាក់ទងទៅនឹងស្ថានភាពនៃសិទ្ធិ និងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន។

### ខ. សម្រង់សុរិយោដី

សម្រង់សុរិយោដី ត្រូវធ្វើតាមបច្ចេកទេសនិងវិធីសាស្ត្រច្បាស់លាស់។ ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដី អាចស្នើសុំអាជ្ញាធរដែនដី ឬអង្គភាពយោធា ឬនគរបាលឲ្យជួយជ្រោមជ្រែងដល់កិច្ចប្រតិបត្តិការធ្វើសម្រង់សុរិយោដីនៅនឹងកន្លែង។ គ្មានសមត្ថកិច្ចណាក្រៅពីរដ្ឋបាលសុរិយោដី មានសិទ្ធិកំណត់កម្មសិទ្ធិករនៃក្បាលដីប្រភេទដី ឬទំហំដីបានឡើយ។

នៅក្នុងមាត្រា២៣១ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ បានចែងថា «ជនទាំងឡាយជាពិសេសកម្មសិទ្ធិករនិងជនដែលពាក់ព័ន្ធមានកាតព្វកិច្ចចូលរួមនិងសហការក្នុងការធ្វើទម្រង់សុរិយោដី។ ជនទាំងនោះត្រូវធ្វើកិច្ចសហប្រតិបត្តិការក្នុងការវាស់វែងសុរិយោដី និងធ្វើអត្តសញ្ញាណកម្មកម្មសិទ្ធិ ហើយត្រូវរាយការណ៍អំពីការផ្លាស់ប្តូរទាំងអស់ដែលកើតពីក្បាលដីរបស់ខ្លួន និងស្ថានភាពនៃទីតាំងនិងរាល់ការផ្ទេរសិទ្ធិនៃកម្មសិទ្ធិ។

ក្នុងករណីមានវិវាទកម្មអំពីទំហំក្បាលដី ឬឈ្មោះនៃកម្មសិទ្ធិករកើតឡើង ក្នុងពេលប្រតិបត្តិការធ្វើសម្រង់សុរិយោដីអ្នកទទួលខុសត្រូវនៃរដ្ឋបាលសុរិយោដី ត្រូវអញ្ជើញសាមីខ្លួនមកសម្រុះសម្រួល។ ចំពោះវិវាទកម្មដែលកើតឡើងក្នុងតំបន់កំពុងធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ គណៈកម្មការរដ្ឋបាលមានភារៈសម្រុះសម្រួលវិវាទកម្មនេះ។ បើការព្រមព្រៀងមិនអាចប្រព្រឹត្តទៅបាន អ្នកទទួលខុសត្រូវបន្តធ្វើអង្កេតវាស់វែងសុរិយោដី ហើយកសាងកំណត់ហេតុនៃវិវាទនោះ តែមិនមានសិទ្ធិអារកាត់ទេ។ ចំពោះវិវាទកម្មកើតមាននៅពេលប្រគល់បណ្ណរដ្ឋបាលសុរិយោដីត្រូវប្រកាន់យកតែឈ្មោះកម្មសិទ្ធិករ ដែលបានចុះក្នុងបញ្ជីរបស់ខ្លួនប៉ុណ្ណោះ។ គ្មានករណីណាដែលរដ្ឋបាលសុរិយោដីអាចកែប្រែ ឬប្រគល់បណ្ណឲ្យបុគ្គលផ្សេងទៀតឡើយ។

### គ. បញ្ជី និងឯកសារសុរិយោដី

រដ្ឋបាលសុរិយោដីមានកាតព្វកិច្ចកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី។ ប្លង់សុរិយោដីគ្របដណ្តប់តំបន់ដែលបានធ្វើការវិនិច្ឆ័យ ដោយមានកំណត់ព្រំប្រទល់កម្មសិទ្ធិសាធារណៈ និងកម្មសិទ្ធិឯកជនទាំងអស់ ហើយមានបញ្ជាក់អំពីប្រភេទដីដូចជាដីដាំដុះ ដីព្រៃ ដីលិចទឹក ដី សម្រាប់សំណង់ឧស្សាហកម្មជាដើម។ ការកសាងប្លង់សុរិយោដី ត្រូវអនុវត្តតាម

នីតិវិធីដែលត្រូវចែងក្នុងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី ហើយក្បាលដីកម្មសិទ្ធិនីមួយៗត្រូវមានលេខរបស់វា។

ចំពោះសៀវភៅបញ្ជីដីបង្ហាញចំពោះលេខក្បាលដីកម្មសិទ្ធិមួយៗនូវឈ្មោះកម្មសិទ្ធិករ និងមធ្យោបាយនៃការធ្វើអត្តសញ្ញាណកម្មក្បាលដី ការពិពណ៌នាអំពីកម្មសិទ្ធិ ទំហំ ក្បាលដី សេវភាព និងបន្ទុកផ្សេងៗលើក្បាលដី។រាល់ការកែប្រែទិន្នន័យទាំងឡាយត្រូវបានចុះបញ្ជីនៅពេលដែលរដ្ឋបាលសុរិយោដីបានទទួលដំណឹងនេះ។បញ្ជីនេះត្រូវបានកាន់កាប់ជាបី (៣)ច្បាប់ ដែលមួយច្បាប់ត្រូវបានរក្សាទុកនៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល និងពីរច្បាប់ទៀតរក្សាទុកនៅរដ្ឋបាលសុរិយោដីខេត្ត-ក្រុង និងស្រុក-ខណ្ឌ។ចំពោះសៀវភៅគោលបញ្ជីដីបង្ហាញអំពីលេខបណ្ណកម្មសិទ្ធិ នូវហ៊ីប៉ូតែក ការបញ្ចាំ ការដាក់ធានា និងការជួលរយៈពេលវែងដែលអាចដាក់បន្ទុកលើកម្មសិទ្ធិ នោះ។ ចំណែកប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី មានតម្លៃត្រឹមត្រូវតាមច្បាប់ និងមានអនុភាពច្បាស់លាស់។ ប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីមិនត្រូវមានការធូតលុប ការសរសេរត្រួត ការកែ លើកលែងតែមានការបញ្ជាក់ច្បាស់លាស់។រដ្ឋបាលសុរិយោដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការកាន់កាប់នូវបញ្ជី និងភាពដាក់លាក់នៃប្រតិបត្តិការសម្រេចសុរិយោដី និងកិច្ចការអភិរក្សឯកសារ ហើយចំពោះការសាកសួរព័ត៌មានសុរិយោដី មិនអាចត្រូវបាន ប្រកែកចំពោះជនដែលមានការទាក់ទងឡើយ។ ព័ត៌មានដែលបានចុះក្នុងសៀវភៅគោលបញ្ជីដីជាកម្មវត្ថុនៃការប្រគល់ច្បាប់ចម្លងដោយត្រូវបង់ប្រាក់ដែលបានកំណត់ក្នុងមាត្រា២៣០ នៃច្បាប់ភូមិបាល។

### ឃ.បណ្ណ និងព័ត៌មាន

រដ្ឋបាលសុរិយោដីអាចចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់ កាប់អចលនវត្ថុ វិញ្ញាបនបត្របញ្ជាក់ហ៊ីប៉ូតែក សាលាកបត្រព័ត៌មាន និងលិខិតបញ្ជាក់សុរិយោដី អំពីប្រភេទស្ថានភាពគតិយុត្ត លក្ខណៈរូប និងបន្ទុកនៃក្បាលដីដោយផ្អែកលើឯកសារនិងសៀវភៅគោលបញ្ជីដី។ចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់ អចលនវត្ថុ ត្រូវចេញឲ្យចំពោះតែកម្មសិទ្ធិករ ឬអ្នកមានសិទ្ធិស្របច្បាប់លើអចលនវត្ថុនោះតែប៉ុណ្ណោះ ហើយសាលាកបត្រព័ត៌មានសុរិយោដី អាចត្រូវបានផ្តល់ឲ្យជនដែលបានស្នើសុំ។ភ្នាក់ងារដែលផ្តល់ឲ្យមិននាំឲ្យជាប់ការទទួលខុសត្រូវដល់រដ្ឋបាលសុរិយោដីទេ។

លិខិតបញ្ជាក់សុរិយោដី គឺជាមូលដ្ឋាននៃការអះអាងផ្លូវការមួយនៃលិខិតគតិយុត្ត។កម្មសិទ្ធិ អចលនវត្ថុកើតឡើងដោយលិខិតលក់ ដូរ ឬជំរះមរតក ដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមាននីតិសម្បទាដូច

មានចែងក្នុងមាត្រា៦៥ នៃច្បាប់ភូមិបាល។ លិខិតទាំងនោះត្រូវតែតម្កល់ទុកនៅរដ្ឋបាលសុរិយោដី។ ចំណែកឯលិខិតលក់ដូរ ឬជំរះមរតក បានធ្វើឡើងតាមរូបមន្តយថាភូតដោយបុគ្គលដែលមាននីតិសម្បទា ប៉ុន្តែមិនបានចុះបញ្ជីនៅសុរិយោដីទេ លិខិតនោះនៅតែតតិយជនអាចជំទាស់បាន ហើយកម្មសិទ្ធិករ និងសិទ្ធិវន្តត្រូវទទួលខុសត្រូវដោយខ្លួនឯងក្នុងការខកខានចុះបញ្ជីនេះ។

ដូច្នេះសរុបមកយើងឃើញថាលក្ខណៈសុរិយោដី គឺជាអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រមួយដែលចំណុះឲ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយមានភាតព្វកិច្ច ធ្វើសញ្ញាណកម្មទ្រព្យកសាងប្លង់សុរិយោដី ចេញបណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដី ទាក់ទងទៅនឹងប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងៗ ដែល មាននៅលើក្បាលដីនោះ។ មានន័យថា សិក្សាស្រាវជ្រាវកសាងគម្រោងលិខិតបទដ្ឋានទាំងឡាយ ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងដីធ្លី និងប្រើប្រាស់ដីធ្លីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធ្វើយ៉ាងណាឲ្យវិស័យដីធ្លីនៅព្រះរាជាណាចក្រកម្ពុជា មានការគ្រប់គ្រងប្រកបដោយលក្ខណៈសុក្រឹតត្រឹមត្រូវ ហើយអាចទាញយកផលពីដីធ្លីនេះបានយ៉ាងមានប្រសិទ្ធិភាព តាមរយៈការប្រើប្រាស់ដីធ្លីនូវមធ្យោបាយ សមស្របទៅតាមបទដ្ឋានច្បាប់ដែលមានជាធរមាន។

## គន្ថនិទ្ទេស


១. ក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០២

២. ក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី រាជរដ្ឋាភិបាលកម្ពុជា, ភ្នំពេញ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០២

៣. ក្រសួងអភិវឌ្ឍន៍ជនបទ (នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច) សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច, ភ្នំពេញ ឆ្នាំ២០០៥

៤. ច្បាប់ភូមិបាល ភ្នំពេញ ឆ្នាំ២០០១

៥. ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ភ្នំពេញ.១៩៩៩

៦. ជួន ណាត វចនានុក្រមខ្មែរ ភ្នំពេញ ឆ្នាំ ១៩៦៧

៧. បទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ភ្នំពេញ ឆ្នាំ ២០០៤

៨. របាយការណ៍សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៤ឆ្នាំ (២០០៤-២០០៧) ទីស្តីការគណៈរដ្ឋមន្ត្រី.ភ្នំពេញ ឆ្នាំ ២០០៨
៩. រាជរដ្ឋាភិបាលកម្ពុជា «ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី» ភ្នំពេញ ឆ្នាំ២០០២
១០. វចនានុក្រម Black's Law ឆ្នាំ១៩៩៩
១១. សារាចរស្តីពីការកាន់កាប់ដីធ្លីរដ្ឋដោយខុសច្បាប់ ភ្នំពេញ ឆ្នាំ ២០០៧
១២. សេចក្តីណែនាំស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ភ្នំពេញឆ្នាំ ២០០៥
១៣. សេចក្តីប្រកាសស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី ភ្នំពេញ ឆ្នាំ ១៩៩៩
១៤. សេចក្តីសម្រេចស្តីពីការកំណត់ក្រមសីលធម៌សម្រាប់អនុវត្តគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ភ្នំពេញ ឆ្នាំ២០០៦
១៥. សេចក្តីសម្រេចស្តីពីការបង្កើតប្រព័ន្ធទទួល និងដោះស្រាយបណ្តឹង សម្រាប់គម្រោងរៀបចំ ដែនដី និងរដ្ឋបាលដីធ្លី ភ្នំពេញ.២០០៦
១៦. អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ភ្នំពេញ. ឆ្នាំ២០០២។

# កិច្ចការរដ្ឋបាលទូទៅ

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលបានប្រសូតចេញពីការបោះឆ្នោតជាសកល កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ យុទ្ធសាស្ត្រនេះជាគោលនយោបាយដ៏សំខាន់របស់រដ្ឋាភិបាលដើម្បីកសាងជាជំហានៗនូវសង្គមកម្ពុជាមួយប្រកបដោយសុខសន្តិភាព ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម មានការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស។*

*រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តអភិក្រម « **ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**» ។*

*ការបំពេញការងារជូនរាជរដ្ឋាភិបាលនិងការបម្រើប្រជាពលរដ្ឋជាកាតព្វកិច្ចរបស់មន្ត្រីរាជការ។ កិច្ចការរដ្ឋបាលទូទៅ គឺជាការងារដ៏សំខាន់មួយដែលមន្ត្រីរាជការត្រូវសិក្សាស្វែងយល់ដឹង ជាពិសេសមន្ត្រីទទួលបន្ទុកការងាររដ្ឋបាលនិងលេខាធិការ ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។*

## ១-លិខិតរដ្ឋបាល

### ១.១-និយមន័យ ការតាក់តែង និងទម្រង់លិខិតរដ្ឋបាល

#### ក-និយមន័យលិខិតរដ្ឋបាល

*លិខិតរដ្ឋបាល គឺជាលិខិតដែលសរសេរជាលាយលក្ខណ៍អក្សរ មានលក្ខណៈច្បាស់លាស់ ខ្លឹមសារងាយយល់ និងធ្វើតាមទម្រង់បែបបទត្រឹមត្រូវ សម្រាប់ទាក់ទងការងារផ្សេងៗជាផ្លូវការរវាងក្រសួង ស្ថាប័ន ឬអង្គភាពមួយជាមួយនឹងក្រសួង ស្ថាប័ន ឬអង្គភាពមួយទៀត ឬជាមួយផ្នែកឯកជន ក្រុមហ៊ុន សហគ្រាស និងសមាគមផ្សេងៗ។*

#### ខ-ការតាក់តែងលិខិតរដ្ឋបាល

*របៀបសរសេរលិខិតរដ្ឋបាល គឺគេត្រូវរៀបចំប្រយោគឱ្យងាយយល់ មានខ្លឹមសារសមរម្យ ដែលអាចបញ្ជាក់នូវបំណង និងគំនិតដែលគេចង់បង្ហាញ ឬចង់និយាយ។ គេត្រូវចៀសវាងនូវការសរសេរ សេចក្តីឱ្យវែងហួសហេតុ ឥតប្រយោជន៍*

និងមិនត្រូវនិយាយសាឡើងច្រំដែល ធ្វើឱ្យបញ្ហាទៅជាស្មុគ្រស្មាញពិបាកក្នុងការពិនិត្យ ការសម្រេចចំពោះលិខិតនោះ។ គេត្រូវប្រើពាក្យសាមញ្ញ ជៀសវាងការប្រើពាក្យពិបាកយល់ ដូចជា ពាក្យបាលី សំស្ក្រឹត ឬពាក្យបរទេស។ ក្នុងការធ្វើលិខិតរដ្ឋបាល បើអ្នកសរសេរខ្វះការប៉ិនប្រសប់ អាចនាំឱ្យស្ទះការងាររបស់ក្រសួង ស្ថាប័ន ឬអង្គភាពផ្សេងៗបានដែរ។

ការិយាល័យជំនាញនីមួយៗ ឬអ្នកដែលមានភារកិច្ចសរសេរលិខិតរដ្ឋបាលអ្វីមួយ ជាអ្នករៀបរៀងដោយត្រូវគិតទៅតាមប្រភេទលិខិត គោលបំណងដែលចង់បាន ទម្រង់បែបបទពាក្យពេចន៍ អក្ខរាវិរុទ្ធឱ្យបានត្រឹមត្រូវ។[1]

***ការផ្តើមគំនិត៖*** អ្នកធ្វើលិខិតត្រូវផ្អែកតាមគោលគំនិតរបស់អ្នកប្រគល់ ឬការងារ ឬអ្នកដែលយើងសរសេរទៅ តើគេចង់បានអ្វី ចង់ធ្វើអ្វី និងត្រូវយល់នូវសភាពការណ៍ផ្សេងៗទៀត ដោយសហការផ្លាស់ប្តូរយោបល់ជាមួយបុគ្គល ឬជាមួយការិយាល័យដែលពាក់ព័ន្ធ។ អ្នករៀបចំលិខិតត្រូវធ្វើការស្រាវជ្រាវព័ត៌មានចាំបាច់បន្ថែមទៀតដើម្បីសរសេរឱ្យក្លាយជាលិខិតរដ្ឋបាលដែលមានខ្លឹមសារល្អ និងត្រឹមត្រូវតាមទម្រង់បែបបទ ត្រូវសរសេរដើម្បីឱ្យគេយកទៅមើល និង អនុវត្តងាយយល់ ដោយមិនត្រូវសរសេរសម្រាប់យល់តែខ្លួនយើងឡើយ ហើយត្រូវពិនិត្យប្រភេទលិខិតថា ជាប្រភេទលិខិតអ្វី ឱ្យចំបញ្ហា ចំសមត្ថកិច្ចព្រមទាំងត្រូវចេះរក្សាការសម្ងាត់ដែលខ្លួនបានដឹង។

***ការវាយអត្ថបទ៖*** អ្នកវាយលិខិតត្រូវ ពិនិត្យអត្ថបទ ពាក្យពេចន៍ឱ្យបានច្បាស់លាស់ កន្លែងមិនច្បាស់ត្រូវសួរបញ្ជាក់។ មុននឹងចាប់ផ្តើមវាយអត្ថបទត្រូវអានសេចក្តីព្រាងមួយចប់ ដោយយកចិត្តទុកដាក់ ស្វែងយល់ន័យសេចក្តី ចៀសវាងការវាយដោយប្រថុយប្រថាន។ ចំពោះទំព័រវាយកុំព្យូទ័រត្រូវទុកឱ្យសល់ខាងឆ្វេង ខាងស្តាំ ខាងលើ ខាងក្រោម តាមគំរូបែបបទដែលបានកំណត់។ លិខិតវាយរួចហើយត្រូវផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវដោយខ្លួនឯងមុននឹងប្រគល់ទៅឱ្យមន្ត្រីជំនាញ ឬអ្នកដែលមានសមត្ថកិច្ចចុះហត្ថលេខា។ បន្ទាប់ពីវាយអត្ថបទរួចត្រូវភ្ជាប់ឯកសារយោង ឬឯកសារពាក់ព័ន្ធមកជាមួយផង បើសិនជាមាន ត្រូវដាក់ទៅក្នុងសឺមី ដើម្បីបញ្ជូនទៅថ្នាក់លើ ឬអ្នកដែលមានសិទ្ធិចុះហត្ថលេខា ដើម្បីសុំការសម្រេច ដោយត្រូវខ្ទាស់សេចក្តីព្រាងនៅខាងស្តាំផ្ទៃក្នុងនៃសឺមី ឯនៅខាងឆ្វេងត្រូវខ្ទាស់សំណុំឯកសារដែលពាក់ព័ន្ធ។

***ការចុះហត្ថលេខា៖*** អ្នកមានសមត្ថកិច្ចចុះហត្ថលេខាលើលិខិត ឬសំណុំឯកសារផ្សេងៗ គួរចុះហត្ថលេខាលើលិខិតដើមចំនួនពីរ ឬបីច្បាប់ ដើម្បីមានឯកសារដើមសម្រាប់តម្កល់ទុក និងសម្រាប់ផ្ញើទៅក្រសួង ស្ថាប័ន ឬអង្គភាពដែលត្រូវទទួល។ ក្រោយពេលដែលថ្នាក់លើបានចុះហត្ថលេខារួចហើយគេត្រូវបញ្ជូនទៅការិយាល័យ

[1] *សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច*

ដែលមានសិទ្ធិបោះត្រា ចុះលេខ និងចុះកាលបរិច្ឆេទ។ គ្រប់លិខិតស្នាមរបស់ក្រសួង អង្គភាព ឬស្ថាប័ន គឺត្រូវមានហត្ថលេខា ព្រោះលិខិតដែលគ្មានហត្ថលេខាចាត់ទុកជាគ្មានតម្លៃក្នុងការអនុវត្ត។

ដើម្បីកុំឱ្យមានកំហុសឆ្គងក្នុងខ្លឹមសារ ឬទម្រង់បែបបទមុននឹងដាក់ជូនថ្នាក់ដឹកនាំ ឬប្រធានស្ថាប័នអង្គភាពចុះហត្ថលេខា គេត្រូវពិនិត្យលិខិតនោះឡើងវិញ ដោយអ្នកមានសមត្ថកិច្ច ជៀសវាងការកែ ឬលុបបន្ទាប់ពីការចុះហត្ថលេខារួចហើយ។ ថ្នាក់អនុ ឬរង អាចចុះហត្ថលេខាជំនួសប្រធាន ឬនាយកបាន លុះត្រាតែប្រធានបានផ្ទេរសិទ្ធិឱ្យចុះហត្ថលេខាជំនួសដោយត្រូវសរសេរពីមុខតួនាទីរបស់ប្រធានអង្គភាព (នៅពីលើកន្លែងចុះហត្ថលេខា) ដោយអក្សរកាត់ថា "ជ"។ ការផ្ទេរសិទ្ធិចុះហត្ថលេខាមានប្រយោជន៍ គឺចៀសវាងមិនចាំបាច់យកកិច្ចការណាដែលធម្មតា ឬមានប្រយោជន៍តិចតួចទៅសុំហត្ថលេខាថ្នាក់ដឹកនាំទេ ពិសេសដើម្បីឱ្យចំណេញពេលវេលាក្នុងដំណើរការគ្រប់គ្រងក្រសួង ឬអង្គភាពនីមួយៗ។ មានឯកសារខ្លះត្រូវចុះហត្ថលេខាក្នុងនាម និងតាមបញ្ជារបស់ថ្នាក់ដឹកនាំដែលបានចង្អុល និងអនុញ្ញាតឱ្យធ្វើនៅពេលចុះហត្ថលេខាត្រូវសរសេរអក្សរថា "តប"។ សិទ្ធិក្នុងការទទួលចុះហត្ថលេខានេះ មិនអាចផ្ទេរទៅឱ្យអ្នកចុះហត្ថលេខាផ្សេងទៀតបានឡើយ លុះណាតែមានការយល់ព្រមពីថ្នាក់ដឹកនាំដែលមានសមត្ថកិច្ច។

ការចុះហត្ថលេខា មិនត្រូវប្រើប៊ិចក្រហម ឬខ្មៅដៃ ឬត្រាហត្ថលេខាឡើយលើកលែងករណីខ្លះដែលថ្នាក់ដឹកនាំអនុញ្ញាតឱ្យប្រើត្រាហត្ថលេខាដើម្បីចុះលើឯកសារ លិខិតស្នាមចំនួនច្រើនដែលមានជាប្រចាំ។

**គ-ទម្រង់លិខិតរដ្ឋបាល**

ទម្រង់នៃលិខិតរដ្ឋបាលចែកជា បីផ្នែកគឺៈ ផ្នែកដើម ផ្នែកអត្ថបទ និងផ្នែកបញ្ចប់។ ក្នុងការសរសេរគេត្រូវគោរព និងធ្វើទៅតាមទម្រង់នេះ ដើម្បីឱ្យមានខ្លឹមសារ អត្ថន័យសោភណភាព និងរបៀបរបបល្អក្នុងការទាក់ទងគ្នា តាមរយៈលិខិតនេះ។

**ផ្នែកដើមៈ**

•របបនយោបាយ៖ គឺឈ្មោះហៅជាផ្លូវការ នៃប្រទេសរបស់យើងគឺ "ព្រះរាជាណាចក្រកម្ពុជា" និងបាវចនានៃជាតិ "ជាតិ សាសនា ព្រះមហាក្សត្រ" ត្រូវសរសេរនៅចំកណ្តាលទំព័រខាងលើបង្អស់ជាតួអក្សរធំៗបន្តិច ឬនៅចំហៀងខាងស្តាំទំព័រតាមសភាពជាក់ស្តែងរបស់ស្ថាប័នអង្គភាពនីមួយៗ។

•សញ្ញាសំគាល់៖ ក្រសួងស្ថាប័ន ឬអង្គភាពនីមួយៗតែងមានសញ្ញាសំគាល់ដែលគេបង្កើតឡើងតាមការរចនាផ្សេងៗ ប្រកបទៅដោយអត្ថន័យដោយឡែកៗ។ សញ្ញានេះគេហៅថា សញ្ញាក្រសួង ឬស្ថាប័ន ដែលមានការកំណត់ឱ្យប្រើក្នុងលិខិតបទដ្ឋានគតិយុត្ត ដូចជានៅក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសជាដើម។ ជាទូទៅគេច្រើនតែបោះពុម្ពសញ្ញាសំគាល់នេះរួចតែម្តង។ សញ្ញាសំគាល់នេះខ្លះគេដាក់ចំកណ្តាលផ្នែកខាងលើនៃទំព័រ ខ្លះគេដាក់នៅខាងឆ្វេងពី

លើឈ្មោះក្រសួងស្ថាប័ន ឬអង្គភាព ប៉ុន្តែទាបជាងឈ្មោះជាផ្លូវការនៃប្រទេស។

•*ឈ្មោះក្រសួងស្ថាប័ន ឬប្រភព៖* គឺក្រសួង ស្ថាប័ន អង្គភាព ដែលត្រូវចេញលិខិតនោះ ដែលគេត្រូវសរសេរឈ្មោះនេះនៅផ្នែកខាងលើ ខាងឆ្វេងដៃ។ គេត្រូវសរសេរឈ្មោះក្រសួងដែលជាប្រភពនេះទាបជាងបាវចនាចុះមួយបន្ទាត់។ នៅក្រោមឈ្មោះក្រសួង ស្ថាប័ន ឬអង្គភាព គេសរសេរលេខរៀងចាប់ពីថ្ងៃដំបូងនៃឆ្នាំនិងប្រភេទលិខិតដែលត្រូវចេញដែលមានអក្សរកាត់នៅក្នុងលេខនោះ។

ឧទាហរណ៍៖ លេខ០០១ សជណ គឺជាលេខដំបូងដែលចេញសេចក្តីជូនដំណឹងនៅក្នុងឆ្នាំថ្មី។

•*ទីកន្លែង និងកាលបរិច្ឆេទ៖* សរសេរទីកន្លែង និងកាលបរិច្ឆេទនៅខាងលើ ផ្នែកខាងស្តាំជាមួយ បន្ទាត់ដែលសរសេរលេខសំគាល់ និងអក្សរកាត់។ តាមធម្មតាសេចក្តីព្រាងនៃលិខិតមិនទាន់មានចុះកាលបរិច្ឆេទទេ ប៉ុន្តែគេត្រូវចុះទីកន្លែងឱ្យហើយ។ មានលិខិតរដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តខ្លះ គេដាក់ថ្ងៃខែពីលើកន្លែងចុះហត្ថលេខានៅផ្នែកខាងក្រោមវិញ ខ្លះទៀតសំគាល់ថា ថ្នាក់តូចសរសេរទៅកាន់ថ្នាក់ធំ ត្រូវដាក់ថ្ងៃខែនៅខាងក្រោម។

**ផ្នែកអត្ថបទ៖**

•*អ្នកផ្ញើ៖* គឺត្រូវសរសេរមុខងាររបស់អ្នកផ្ញើ ហើយមិនបាច់ដាក់ឈ្មោះចំទេដោយត្រូវដាក់ឱ្យចំកណ្តាលទំព័រក្រោមបន្ទាប់ពីឈ្មោះផ្លូវការនៃប្រទេស មានគម្លាតសមរម្យ។

ឧទាហរណ៍៖ រដ្ឋមន្ត្រីក្រសួង អគ្គនាយកនៃអគ្គនាយដ្ឋាន អភិបាលនៃគណៈអភិបាលខេត្ត ប្រធាននាយករដ្ឋបាល ប្រធានការិយាល័យ ប្រធានមន្ទីរ។ល។

•*ពាក្យស្វាគមន៍៖* ដូចជា សូមក្រាបបង្គំទូលថ្វាយ សូមគោរពជូន សូមជម្រាបជូន គោរពជូន ជម្រាបជូន គោរពមក ជម្រាបមក ជាដើម ទៅតាមឋានៈ តួនាទីតូច ធំ ខ្ពស់ ទាប ឬប្រហាក់ប្រហែលគ្នា គេដាក់ចំកណ្តាលបន្ទាប់ពីដាក់មុខងារម្ចាស់លិខិតរួចហើយ។

•*អ្នកទទួល៖* ជាឈ្មោះអ្នកដែលត្រូវទទួលលិខិតអំពីម្ចាស់លិខិត (អ្នកចុះហត្ថលេខា) ដោយមានប្រើពាក្យតាមឋានៈ ដូចជា សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី បន្ទាប់មកដាក់តួនាទីរបស់អ្នកទទួល ឬ (ឋានន្តរស័ក្តិ) និងឈ្មោះក្រសួង ស្ថាប័ន អង្គភាពផង ដោយត្រូវសរសេរចន្លោះពីពាក្យស្វាគមន៍ប្រហែលមួយបន្ទាត់។ ឧទាហរណ៍៖ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ឯកឧត្តមអគ្គលេខាធិការ...ឯកឧត្តមអគ្គនាយក...ឯកឧត្តម/លោកសាកលវិទ្យាធិការ... លោកប្រធានមន្ទីរ... លោកនាយកវិទ្យាល័យ...។ល។

មានប្រភេទលិខិតខ្លះ គេសរសេរដាក់ឈ្មោះចំអ្នកដែលត្រូវទទួលតែម្តង។ ការសរសេរមុខងាររបស់អ្នកទទួលត្រូវសរសេរឱ្យបានត្រឹមត្រូវតាមមុខងារ និងក្រសួង ស្ថាប័ន អង្គភាពរបស់គេ។ ដូចនេះនៅតាមការិយាល័យនីមួយៗ គប្បីមានបញ្ជីឈ្មោះថ្នាក់ដឹកនាំពជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អង្គភាពនិងត្រូវស្គាល់ឈ្មោះអ្នក

ទទួលលិខិត (អ្នកត្រូវគោរពជូន) ឱ្យបានច្បាស់លាស់ផង។ បើសិនជាអ្នកដែលត្រូវទទួលលិខិតមានច្រើន ត្រូវរៀបតាមលំដាប់ពីធំមកតូច។

•កម្មវត្ថុ៖ គឺជាសេចក្តីសង្ខេបនូវខ្លឹមសារអំពីរឿងអ្វីមួយ ដោយពាក្យមួយឃ្លា (បើអាចធ្វើបាន)ច្បាស់លាស់ ខ្លី ងាយយល់។ កម្មវត្ថុ ត្រូវសរសេរនៅក្រោមឈ្មោះអ្នកទទួលចំនួនពីរឬបីបន្ទាត់។ កម្មវត្ថុមានលក្ខណៈសំខាន់បីគឺ៖

-ភាពតែមួយនៃកម្មវត្ថុ៖ មានន័យថា លិខិតមួយច្បាប់ត្រូវមានកម្មវត្ថុ និងបញ្ហាតែមួយ។ បើសិនជារឿង ឬកិច្ចការដោយឡែកពីគ្នាត្រូវធ្វើលិខិតផ្សេងទៀត។

-ការសង្ខេបខ្លីនៃកម្មវត្ថុ៖ ត្រូវតែរៀបរាប់ឱ្យខ្លី មានខ្លឹមសារច្បាស់លាស់ ងាយយល់។ តាមធម្មតា មិនត្រូវសរសេរឱ្យលើសពីមួយបន្ទាត់ឡើយ លើកលែងតែក្នុងករណីចាំបាច់។

-ភាពច្បាស់លាស់នៃកម្មវត្ថុ៖ មានន័យច្បាស់លាស់ ហើយត្រូវស្របនឹងសេចក្តីអធិប្បាយ សំណូមពរ នៅក្នុងលិខិតដែលត្រូវសរសេរអធិប្បាយខ្លឹមសារនៅផ្នែកខាងក្រោម។

•ការចុះយោង៖ ត្រូវសរសេរយោងពីក្រោមកម្មវត្ថុ ឱ្យស្មើគ្នាពីលើមកក្រោម។ ជាទូទៅគេត្រូវចុះនូវឯកសារយោងដែលជាការយោងទៅលិខិតបទដ្ឋានគតិយុត្ត ឬយោងលិខិតរបស់ក្រសួងស្ថាប័ន អង្គភាពផ្សេងៗឬយោងតាមស្មារតីអង្គប្រជុំជាដើម ដោយត្រូវមានចុះលេខថ្ងៃខែឆ្នាំនិងខ្លឹមសារឬប្រភពនៃលិខិតដែលត្រូវយោងឱ្យបានច្បាស់។

•លិខិតភ្ជាប់៖ សរសេរនៅក្រោមការចុះយោង ឱ្យស្មើគ្នាពីលើចុះក្រោម។ គេប្រើលិខិតភ្ជាប់ក្នុងករណីដែលចង់បញ្ជាក់បញ្ហាដែលពាក់ព័ន្ធអ្វីមួយជូនអ្នកទទួលលិខិតដើម្បីបានឃើញឯកសារនោះផ្ទាល់ ងាយស្រួលក្នុងការពិចារណាសម្រេចឬស្វែងយល់ ខ្លះគេដាក់បន្ទាប់ពីបានអធិប្បាយនូវខ្លឹមសារលិខិតរួចហើយដោយដាក់ថា សូមជូនភ្ជាប់មកជាមួយនូវឯកសារ...ចំនួន...ច្បាប់។

•ផ្នែកអធិប្បាយខ្លឹមសារ៖ ជាផ្នែកកណ្តាលនៃលិខិតដែលត្រូវសរសេររៀបរាប់ឱ្យបានច្បាស់លាស់ដោយមានបញ្ជាក់អំពីគោលបំណង ហេតុផល ឬសំណូមពរមានលក្ខណៈងាយយល់ ងាយស្តាប់ និងខ្លឹមសារល្អ ងាយស្រួលក្នុងការពិនិត្យពិចារណា ដោះស្រាយ ប៉ុន្តែគេត្រូវចៀសវាងសេចក្តីវែងអន្លាយ ឬប្រើពាក្យដែលពិបាកយល់។ មុននឹងអធិប្បាយនូវខ្លឹមសារគេច្រើនផ្តើមថា សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ឬតបតាមខ្លឹមសារដូចមានចែងក្នុងកម្មវត្ថុខាងលើ ឬតាមកម្មវត្ថុ និងយោងខាងលើរួចបន្តឃ្លាថា ខ្ញុំបាទ ឬនាងខ្ញុំមានកិត្តិយលសូមជម្រាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឬ... មេត្តាជ្រាបថា ឬខ្ញុំមានកិត្តិយសជម្រាបជូនឯកឧត្តមជ្រាបថា ឬខ្ញុំសូមជម្រាបជូនលោក... មេត្តាជ្រាបថា...(គេត្រូវស្វែងយល់ការប្រើពាក្យពេចន៍ ឱ្យបានសមរម្យតាមឋានៈ និងតួនាទី រវាងម្ចាស់

លិខិតដែលជាអ្នកចុះហត្ថលេខា និងអ្នកដែលទទួលលិខិតនោះ)។

•ការបញ្ជាក់៖ ជាការលើកសំណូមពរឱ្យសម្រេច ឬសុំវិធានការដោះស្រាយ។

ឧទាហរណ៍៖ អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ ឬហេតុនេះ សូមឯកឧត្តម មេត្តាជ្រាបដោយក្តីអនុគ្រោះ(អ្នកតូចទៅអ្នកធំ) ឬ ស្រ័យហេតុនេះ សូមលោកពិនិត្យ និងសម្រេចតាមការគួរ ឬអាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាបតាមការគួរ (អ្នកធំទៅអ្នកតូច)។ គេអាចដាក់តួនាទីបន្ថែមពីមុខពាក្យឯកឧត្តម ដូចជា ឯកឧត្តមអគ្គលេខាធិការ ឯកឧត្តមមេបញ្ជាការជាដើម។

នេះជាឧទាហរណ៍ខ្លះៗ នៃការសរសេរបញ្ជាក់នូវសំណូមពរអ្វីមួយ តាមគោលបំណងរបស់ម្ចាស់លិខិត។

•ពាក្យសម្តែងការគួរសម៖ ក្រោយអំពីបានរៀបរាប់នូវខ្លឹមសារ និងប្រើពាក្យបញ្ជាក់សំណូមពរ គោលបំណង អ្នកចុះហត្ថលេខាត្រូវប្រើពាក្យសម្តែងនូវការគោរព ឱ្យបានសមរម្យទៅតាមតួនាទី ឋានៈរៀងខ្លួន។

ឧទាហរណ៍៖ សូមសម្តេច ឬឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ឬសូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ ឬសូមលោកទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ផ្នែកបញ្ចប់៖**

•ពាក្យសម្តែងការគួរសម៖ ត្រូវបញ្ជាក់អំពីមុខតំណែងអ្នកដែលមានសិទ្ធិចុះហត្ថលេខា។ ឧទាហរណ៍៖ រដ្ឋមន្ត្រី អគ្គលេខាធិការ អគ្គនាយក នាយក ប្រធានមន្ទីរ... ជាដើម។

•ហត្ថលេខាឈ្មោះនិងត្រាៈម្ចាស់លិខិតត្រូវចុះហត្ថលេខាខាងក្រោមមុខងារ ឱ្យចំកណ្តាល។ ចំណែកក្នុងការបោះត្រា មិនត្រូវបោះត្រាពីលើហត្ថលេខានោះទេ ពីព្រោះនាំឱ្យមើលហត្ថលេខាមិនបានច្បាស់លាស់ ក្នុងករណីមានការក្លែងបន្លំហត្ថលេខានោះ ជួបការលំបាកក្នុងការធ្វើកោសល្យវិច្ច័យ ដូចនេះគេត្រូវបោះត្រា នៅប៉ែកខាងឆ្វេង ដោយភ្ជាប់ហត្ថលេខាប្រហែលមួយភាគបី ទើបសមស្របជាង។ គេបោះត្រាឈ្មោះ ឬសរសេរឈ្មោះអ្នកចុះហត្ថលេខា ហើយចៀសវាងសរសេរឈ្មោះ ឬបោះត្រាឈ្មោះអ្នកចុះហត្ថលេខានៅលើត្រា ឬឃ្លាតឆ្ងាយពីត្រាខ្លាំងពេកដែលមើលទៅមិនសមរម្យ។

•ចម្លងជូន៖ មានលិខិតខ្លះមិនត្រឹមតែមានន័យទៅដល់អ្នកដែលទទួលលិខិតនោះទេ ថែមទាំងមានការពាក់ព័ន្ធដល់ក្រសួង ស្ថាប័នអង្គភាពផ្សេងៗទៀតផង ដូចនេះគេត្រូវចម្លងជូននូវលិខិតនោះដោយបញ្ជាក់ឈ្មោះទីកន្លែងដែលត្រូវទទួលនៅប៉ែកខាងឆ្វេង ខាងក្រោមម្ចាស់លិខិតដែលជាកន្លែងចុះហត្ថលេខាប្រហែល១ ឬ២បន្ទាត់ដោយសរសេរអក្សរទំហំតូចៗ ហើយក៏ត្រូវបញ្ជាក់បន្ថែមនូវសំណូមពរ និងគោលបំណងនៃការចម្លងជូននោះផងដែរ ដូចជាដើម្បីជូនជ្រាប ឬដើម្បីអនុវត្ត ឬដើម្បីមុខការ...បន្ទាប់មកដាក់ថា

ឯកសារកាលប្បវត្តិ នៅចុងក្រោយកន្ទែងចម្លងជូនផង។

**១.២-ប្រភេទលិខិត**

**ក-លិខិតស្នើសុំ**

ជាប្រភេទលិខិតមួយ ដែលគេប្រើសម្រាប់ស្នើសុំថវិកា ឬវត្ថុសម្ភារ ឬសុំអនុញ្ញាតធ្វើអ្វីមួយពីក្រសួង ស្ថាប័ន អង្គភាពដែលមានសមត្ថកិច្ចសម្រេច ឬផ្តល់ឱ្យ។ របៀបសរសេរមានដូចក្នុងទម្រង់នៃលិខិតខាងលើដែរ។

**ខ-លិខិតអញ្ជើញ**

គេធ្វើលិខិតនេះ ក្នុងគោលបំណងដើម្បីអញ្ជើញមន្ត្រីតាមក្រសួងស្ថាប័ន អង្គភាពផ្សេងៗចំណុះក្នុងក្រសួង ស្ថាប័ន ឬក្រសួងខាងក្រៅដើម្បីមកចូលរួមប្រជុំ ជូនដំណើរ ឬទទួលដំណើរគណៈប្រតិភូចូលរួមក្នុងពិធីសម្ពោធ ឬពិធីអ្វីផ្សេងទៀត។ លិខិតអញ្ជើញនេះត្រូវបានផ្តើមគំនិតដោយអ្នកមានសមត្ថកិច្ចក្នុងការអញ្ជើញ។ ជាការគួរសម និង ឱ្យមានលក្ខណៈសមស្របអ្នកដែលអញ្ជើញត្រូវមានឋានៈស្មើ ឬខ្ពស់ជាងនឹងឋានៈភ្ញៀវដែលត្រូវអញ្ជើញមកចូលរួម។

**គ-លិខិតបេសកកម្ម**

ជាលិខិតអនុញ្ញាត ឱ្យបំពេញបេសកកម្មតាមបណ្តាគោលដៅដែលឆ្ងាយពីក្រសួង ស្ថាប័នរបស់ខ្លួនដូចជា ទៅបំពេញការងារនៅតាមខេត្ត ឬនៅបរទេសមានការកំណត់អំពីពេលវេលា មធ្យោបាយធ្វើដំណើរ និងសម្ភារដែលត្រូវភ្ជាប់ទៅជាមួយ។ ការបំពេញបេសកកម្មជាផ្លូវការនៅបរទេស គឺត្រូវក្រសួងការបរទេសជាអ្នកចេញលិខិត។ ប៉ុន្តែកន្លងមកការអនុវត្តក្នុងការចេញលិខិតបញ្ជាបេសកកម្ម ឬលិខិតបង្គាប់ការមិនទាន់មានការឯកភាពគ្នានៅឡើយទេ ដូចជាករណីចាត់តាំងមន្ត្រីឱ្យទៅបំពេញបេសកកម្មនៅតាមខេត្ត ខ្លះចេញលិខិតបង្គាប់ការក្រសួង ខ្លះទៀតចេញលិខិតបញ្ជាបេសកកម្ម ចំពោះករណីដូចគ្នានេះ។

**ឃ-លិខិតឧទ្ទេសនាម**

ជាលិខិតដែលមានលក្ខណៈទាបជាងលិខិតបេសកកម្ម ដោយចេញឱ្យមន្ត្រីរាជការណាមួយទៅបំពេញការងារនៅកន្លែងណាមួយ ឱ្យទទួលខុសត្រូវផ្ទាល់លើកិច្ចការនោះ (តាមឯកសារមូលដ្ឋានគ្រឹះរដ្ឋបាល ដោយលោក ជា ចំរើន ភ្នំពេញ ២០០១ ទំព័រ ៨៧)។

**ង-លិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររដ្ឋបាល**

ជាលិខិតដែលអាជ្ញាធររដ្ឋបាល ចេញដើម្បីកត់ត្រា ឬរៀបរាប់អំពីស្ថានភាព បញ្ជាក់ពីការងាររបស់មន្ត្រីណាម្នាក់តាមសំណើ ដើម្បីឱ្យមន្ត្រីនោះអាចយកទៅប្រើជាផលប្រយោជន៍អ្វីមួយក្នុងសង្គម ដែលគេតម្រូវឱ្យមានការបញ្ជាក់ពីប្រធានស្ថាប័នអង្គភាព។

**ច-របាយការណ៍**

គេធ្វើដើម្បីរាយការណ៍អំពីលទ្ធផលដែលសម្រេចបាន ឬមិនទាន់សម្រេចបានដើម្បីតម្លៃ ដកបទពិសោធន៍ស្វែងរកចំណុចខ្លាំង ចំណុចខ្សោយ និងលើកទិសដៅអនុវត្តឱ្យមានប្រសិទ្ធភាព។ ក្នុងការគ្រប់គ្រងដំណើរការការងារ

[2] សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ជ.ឯ.ម.

របស់ក្រសួង ស្ថាប័ន អង្គភាព ទាមទារ ឱ្យមានការធ្វើសេចក្តីរាយការណ៍ ដើម្បីថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព ក្តាប់បាននូវសភាពការណ៍និងព័ត៌មានក្នុងការណែនាំ និងលើកទិសដៅ ឱ្យថ្នាក់ក្រោមអនុវត្ត។ ដូច្នេះរបាយការណ៍ត្រូវឆ្លុះបញ្ចាំងអំពីសភាពការណ៍ ហេតុការណ៍ និងតួលេខពិតប្រាកដ ចៀសវាងការមិនពិត ឬបន្ថយជាដើម ដែលអាចធ្វើ ឱ្យខូចដល់ដំណើរការការងាររបស់ក្រសួង ស្ថាប័ន អង្គភាព ព្រោះតែរាយការណ៍អំពីរឿងមិនពិត និងពុំមានប្រយោជន៍។

**ឆ-កំណត់ហេតុ**

ជាប្រភេទលិខិតសម្រាប់កត់ត្រានូវរឿងហេតុផ្សេងៗ ដូចជា កំណត់ហេតុក្នុងពេលប្រជុំ ឬព្រឹត្តិការណ៍អ្វីមួយ។ កំណត់ហេតុប្រជុំ អ្នកដែលទទួលបន្ទុកធ្វើកំណត់ហេតុ គឺជាលេខាធិការរបស់អង្គភាព ឬរបស់គណៈកម្មការ បើសិនជាគ្មានលេខាទេ គេត្រូវចាត់តាំងសមាជិកគណៈកម្មការមួយរូប ដើម្បីធ្វើជាលេខាកត់ត្រា។ លេខាកត់ត្រា ត្រូវសរសេរ ឱ្យបានសព្វគ្រប់នូវខ្លឹមសារនៃការប្រជុំ ឬការពិភាក្សា នូវមតិទាំងអស់របស់សមាជិកអង្គប្រជុំ។ ក្រោយពេលដែលសម័យប្រជុំត្រូវបានបញ្ចប់ លេខាត្រូវធ្វើសេចក្តីព្រាងនៃកំណត់ហេតុ រួចយកសេចក្តីព្រាងនោះទៅឆ្លងប្រធានអង្គប្រជុំ ឬប្រធានអង្គភាពតាមការជាក់ស្តែង ហើយត្រូវចុះហត្ថលេខាដោយលេខាកត់ត្រានិងប្រធានអង្គប្រជុំ។ កំណត់ហេតុប្រជុំត្រូវបានចែកជូនមន្ត្រី និងអង្គភាពពាក់ព័ន្ធ ដើម្បីជ្រាប ឬដើម្បីមុខការ។

ចំណែកកំណត់ហេតុនៃព្រឹត្តិការណ៍ គេត្រូវធ្វើនៅពេលដែលមានព្រឹត្តិការណ៍ណាមួយដែលតម្រូវឱ្យមានសរសេរជាលាយលក្ខណ៍អក្សរ ហើយធ្វើឡើងដោយមន្ត្រីដែលបានឃើញព្រឹត្តិការណ៍នោះ ឬកត់ត្រាតាមសេចក្តីរាយការណ៍របស់អ្នកដែលបានឃើញព្រឹត្តិការណ៍នោះពិតផ្ទាល់។

**ជ-កំណត់បង្ហាញ**

គឺជាឯកសាររដ្ឋបាលផ្ទៃក្នុង ដែលគេធ្វើឡើងសម្រាប់ជួយ ឱ្យថ្នាក់ដឹកនាំជ្រាបបានច្បាស់លាស់នូវខ្លឹមសារ និងដំណោះស្រាយនៃកិច្ចការអ្វីមួយដែលជាសំណើ ឬការជូនព័ត៌មាន។ កំណត់បង្ហាញរឿងគឺជាឯកសារដែលចេញពីថ្នាក់ក្រោមទៅថ្នាក់លើ ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេចដែលអាចជាការសុំយោបល់ និងការសុំសេចក្តីសម្រេចឬគោលការណ៍អនុវត្តជាដើម។

**ឈ-ដីកាអម**

គឺជាឯកសាររដ្ឋបាលប្រើសម្រាប់អមសំណុំលិខិតដែលត្រូវដាក់បញ្ជូនផ្ញើទៅក្រសួង ស្ថាប័ន អង្គភាពមួយ។ គេប្រើដីកានេះដើម្បីដឹងចំនួន និងខ្លឹមសារសំណុំលិខិតត្រូវផ្ញើមក និងបញ្ជាក់នូវការបញ្ជូនឯកសារផ្លូវការជាលាយលក្ខណ៍អក្សរ ចៀសវាងការបាត់បង់ ឬមិនគ្រប់ចំនួនឯកសារដោយប្រការណាមួយ និងដឹងពីប្រភព ក្រសួង ស្ថាប័ន អង្គភាពដែលជាអ្នកផ្ញើមក។ នៅក្នុងជួរសេចក្តីផ្សេងៗ គេច្រើនបញ្ជាក់អំពីគោលបំណងនៃការផ្ញើដូចជា ដើម្បីជ្រាបជាព័ត៌មាន ដើម្បីមុខការ ដើម្បីសហការ ឬដើម្បីអនុវត្ត។

**ញ-ដីកាបញ្ជូន**

ក្រសួង ស្ថាប័នមួយមានសិទ្ធិទទួលនូវសំណុំឯកសារនោះពីប្រភពផ្សេងទៀត ប៉ុន្តែក្រសួង ស្ថាប័ននោះ ពុំមានសមត្ថកិច្ចសម្រេច ដូច្នេះគេត្រូវបញ្ជូនបន្តមកក្រសួង ស្ថាប័ន អង្គភាព ដែលមានសមត្ថកិច្ចដើម្បីសម្រេច ឬដើម្បីជ្រាបជាដើម ដោយអ្នកចុះហត្ថលេខា ច្រើនជាប្រធាននាយកដ្ឋានរដ្ឋបាល ហើយមានអក្សរ ត.ប រដ្ឋមន្ត្រី មានន័យថា តាមបញ្ជារដ្ឋមន្ត្រី។

**ដ-លិខិតផ្ទេរសិទ្ធិ**

គឺជាលិខិតលាយលក្ខណ៍អក្សរ ដែលប្រធានក្រសួង ស្ថាប័ន អង្គភាព ប្រគល់ភារកិច្ចក្នុងក្រសួង ស្ថាប័ន អង្គភាព អោយថ្នាក់រង ឬអនុណាម្នាក់ ដែលអាចចាត់ចែងកិច្ចការងារ និងចុះហត្ថលេខាជំនួសក្នុងពេលអនុវត្តមានប្រធាន ឬនាយកនៅទីកន្លែងធ្វើការ ដោយសារជាប់បំពេញបេសកកម្មនៅឆ្ងាយ ឬទៅបរទេស ជាដើម។ គេផ្ទេរសិទ្ធិ ឱ្យចំឈ្មោះដោយបញ្ជាក់អំពីពេលវេលាច្បាស់លាស់ទៅអ្នកដែលមានសិទ្ធិចុះ ហត្ថលេខាក្នុងនាមប្រធានក្រសួង ស្ថាប័ន អង្គភាព មានន័យថាគ្រាន់តែផ្តល់សិទ្ធិចុះហត្ថលេខា អ្នកចុះហត្ថលេខាមិនមែនជាអ្នកសម្រេច គឺធ្វើក្នុងនាមនិងការទទួលខុសត្រូវរបស់អ្នកធ្វើប្រតិភូកម្ម(អ្នកផ្ទេរសិទ្ធិ) ចំណែកអ្នកដែលទទួលសិទ្ធិ គឺអ្នកទទួលប្រតិភូកម្មត្រូវទទួលខុសចំពោះអ្នកប្រគល់សិទ្ធិចុះហត្ថលេខាមកឱ្យខ្លួន។

**ឋ-សិទ្ធិប្រទាន**

គេប្រើសិទ្ធិប្រទាននេះ នៅពេលណាដែលប្រមុខរដ្ឋ ប្រមុខរាជរដ្ឋាភិបាលបានប្រគល់សិទ្ធិពេញសមត្ថភាព ពោលគឺជាតំណាង ទស្សនៈ និង ការសម្រេច ព្រមទាំងការចុះហត្ថលេខាទៅជូនមន្ត្រីជាន់ខ្ពស់ ឬរដ្ឋជនណាមួយឱ្យអនុវត្ត ឬបំពេញភារកិច្ចជំនួសខ្លួនក្នុងពេលទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពាណិជ្ជកម្ម សហប្រតិបតិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងការពារប្រទេសជាមួយបណ្តាប្រទេស ឬអង្គការអន្តរជាតិផ្សេងៗ ដោយនាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាលណាម្នាក់ជាអ្នកចរចារ និងជាអ្នកចុះហត្ថលេខា (មានចែងនៅក្នុងមាត្រា១២នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី)។

## ២-លិខិតឯកជន

### ២.១-និយមន័យ

ជាលិខិត ដែលគេសរសេរក្នុងនាមបុគ្គលផ្ទាល់ទៅកាន់បុគ្គលណាម្នាក់ឬស្ថាប័នណាមួយក្នុងកិច្ចការឬផលប្រយោជន៍របស់ខ្លួនផ្ទាល់ គឺមិនពាក់ព័ន្ធនឹងការងារឬផលប្រយោជន៍អង្គភាពឡើយ។

### ២.២-ប្រភេទលិខិតឯកជន

លិខិតឯកជនមានច្រើនប្រភេទដូចជាៈ

-ពាក្យស្នើសុំអ្វីមួយ

-ពាក្យបណ្តឹង

-លិខិតជូនពរ

-លិខិតចូលរួមរំលែកទុក្ខ

-លិខិតសរសើរ

-លិខិតអបអរសាទរ

-លិខិតថ្លែងអំណរគុណ ជាដើម។

**៣-ការខាររបៀប**

*ក្រសួង ស្ថាប័ន នីមួយៗមានភារកិច្ច ឬបេសកកម្មចម្បងពីរគឺ៖*

*ទី១-អនុវត្តនូវមុខជំនាញឯកទេស ដោយគោរពតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានា ឬបេសកកម្ម និងគោលនយោបាយរបស់ស្ថាប័នខ្លួន។*

*ទី២-ដឹកនាំគ្រប់គ្រងការងាររដ្ឋបាលទូទៅដោយឈ្លាសវៃ គោរពតាមឋានានុក្រម។ កិច្ចការនេះទាមទារឱ្យយើងចេះដឹងបានច្បាស់លាស់នូវការងាររដ្ឋបាល ដូចជាការធ្វើលិខិតរដ្ឋបាល បានត្រឹមត្រូវតាមទម្រង់បែបបទ ខ្លឹមសារល្អ ត្រឹមត្រូវតាមប្រភេទឯកសាររដ្ឋបាលនីមួយៗ ការទទួលលិខិត ការបញ្ជូនលិខិត ការរៀបចំកិច្ចប្រជុំ ការងារតម្កល់ឯកសារ ការងារពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់ អនាម័យ រួមទាំងការងារផ្សេងៗ ទៀតជាច្រើន។*

*យើងឃើញថាការងារតាមបណ្តាស្ថាប័នមានទំនាក់ទំនងគ្នាទៅវិញទៅមក មានប្រសិទ្ធភាព និងដំណើរការល្អ អាស្រ័យលើការងាររដ្ឋបាលនេះ ដែលជាខ្សែរយៈទាក់ទងសម្របសម្រួលនូវសកម្មភាពការងារទាំងឡាយពីថ្នាក់ក្រោម ទៅថ្នាក់លើ ឬពីថ្នាក់លើមកថ្នាក់ក្រោមពីស្ថាប័នមួយទៅស្ថាប័ន អង្គភាពមួយទៀត។ ការងាររដ្ឋបាលជាការងារមួយដែលជួយសម្រួលដល់ការងារជំនាញដទៃទៀត ឬអាចហៅថាជា កន្លែងប្រសព្វមួយ សម្រាប់សម្របសម្រួល និងជំរុញ ការងារជំនាញផ្សេងនៅក្នុងក្រសួង ស្ថាប័ន ឬក្រុមហ៊ុនឱ្យមានដំណើរការល្អ។*

*កិច្ចការរដ្ឋបាលតាមក្រសួង ស្ថាប័នអង្គភាពនីមួយៗ ដែលមានភាពរលូន ទាន់ពេលវេលា ព្រមទាំង ប្រសិទ្ធភាពជោគជ័យ អាចចៀសវាងបាននូវបញ្ហាអសកម្ម ផ្សេងៗ អាស្រ័យលើការមានចំណេះដឹង និងជំនាញ យល់ហេតុផលការងារច្បាស់លាស់ រួមទាំងការប្រុងប្រយ័ត្ន ជាពិសេស ការទំនាក់ទំនង សាមគ្គីល្អ ជាមួយគ្នា ក្នុងការិយាល័យតែមួយ ឬជាមួយការិយាល័យផ្សេងទៀត និងមានទំនាក់ទំនងល្អផងដែរ រវាងស្ថាប័នមួយ ជាមួយស្ថាប័នមួយផ្សេងទៀត ចេះតាមដានរាល់ការងាររបស់ការិយាល័យ របស់ស្ថាប័ន ព្រមទាំងខិតខំ ពង្រឹងពង្រីកដោយខ្លួនឯងនូវសមត្ថភាព និងមនសិការវិជ្ជាជីវៈរបស់ខ្លួនជាប់ជាប្រចាំ គឺត្រូវឧស្សាហ៍ព្យាយាម ស្វែងយល់ការងារ ខិតខំរៀនសូត្របន្ថែម ចេះដកស្រង់បទសោធន៍។ បន្ថែមលើនេះ ត្រូវចេះមានគំនិតច្នៃប្រឌិត រស់រវើក ដោះស្រាយការងារតាមស្ថាប័ន អង្គភាពឱ្យបានល្អ។ ក្រៅអំពីនេះ ត្រូវមានឧបករណ៍ មធ្យោបាយសម្ភារសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ និងការងាររដ្ឋបាលបានសមស្របទៅតាមលក្ខណៈនិងទំហំនៃកិច្ចការងារ។*

*ចំណេះដឹង បទពិសោធន៍ និងបុគ្គលិកលក្ខណៈ គឺជាមុំចង្ក្រានបី ដែលផ្តល់ការគាំទ្រ និងការពារឱ្យគ្នាទៅវិញទៅមក ដែលមិនអាចមានមួយខ្វះមួយបានឡើយ។ ការលើកកម្ពស់ឆន្ទៈ និងមនសិការវិជ្ជាជីវៈ ព្រមទាំងការគោរពការអនុវត្តច្បាប់ វិន័យរបស់ក្រសួង ស្ថាប័នអង្គភាព*

រមែងធ្វើឱ្យដំណើរប្រព្រឹត្តទៅនៃការងារបានល្អ និងទទួលជោគជ័យ។

ផ្អែកតាមបេសកកម្មខាងលើនេះ យើងអាចកំណត់បានថាការងារគ្រប់គ្រងរដ្ឋបាល ជាគ្រឹះសម្រាប់ទ្រទ្រង់ ដំណើរការប្រព្រឹត្តទៅនៃតួនាទីមុខជំនាញឯកទេសនីមួយៗឱ្យមានដំណើរការ និងទទួលបានលទ្ធផលល្អ តាមផែនការ ជាបន្តបន្ទាប់របស់ក្រសួង អង្គភាព ឬក្រុមហ៊ុននីមួយៗ។

ខាងក្រោមនេះ ជារបៀបអនុវត្តជាក់ស្តែង និងបទពិសោធន៍មួយចំនួនដែលមន្ត្រីទទួលបន្ទុកផ្នែកត្រូវយល់ដឹងជាជំនួយស្មារតីក្នុងការប្រតិបត្តិ សំដៅចៀសវាងនូវចំណុចអវិជ្ជមានខ្លះដែលបានកើតឡើង ដោយប្រការផ្សេងៗ ឬការភ្លាំងភាត់អចេតនា ជាពិសេសការងារនៅការិយាល័យរបៀប (ផ្នែកលិខិតចូល និងផ្នែកលិខិតចេញ)។

**៣.១-លិខិតចូល និងលិខិតចេញ**

ជាធម្មតាការិយាល័យរបៀបមានពីរផ្នែក គឺ ផ្នែកលិខិតចូល និងផ្នែកលិខិតចេញ។ មន្ត្រីភ្នាក់ងារទទួលបន្ទុកផ្នែកទាំងពីនេះ ត្រូវក្តាប់ឱ្យបានរាល់លិខិតទាំងអស់ ទោះចូលក្តី ឬចេញក្តី ត្រូវជានាវ៉ាប់រងឱ្យបាននូវលក្ខណៈ៣ គឺ គុណភាព សុវត្ថិភាព និងប្រសិទ្ធភាព។

-គុណភាពៈ រាល់លិខិតចេញ ត្រូវត្រួតពិនិត្យឡើងវិញអំពីៈ អក្ខរាវិរុទ្ធត្រឹមត្រូវ និងច្បាស់ មិនជាម រលុប ព្រាលៗ អានមិនដាច់ រំលងជួរបន្ទាត់ មិនខុសន័យសេចក្តី ច្រឡំទំព័រ។ល។

-សុវត្ថិភាពៈ រាល់លិខិតចេញក្តី ឬចូលក្តី ត្រូវផ្ទៀងផ្ទាត់មិនបាត់ទំព័រ មិនរហែក មិនបត់ជាផ្នត់ត្រូវរក្សាឱ្យបានល្អនូវភាពដើមរបស់វា មិនខ្ទីខ្ទុកជ្រីវជ្រួញ ឬទទឹកជាមដោយប្រការណាមួយ។ល។

-ប្រសិទ្ធភាពៈ រាល់លិខិតត្រូវបានចុះលេខ ថ្ងៃ ខែ ឆ្នាំ ត្រឹមត្រូវ ជាច្បាប់ដើម (ករណីតម្រូវ) មានហត្ថលេខា និងត្រាត្រឹមត្រូវទាន់ពេលវេលា មិនហួសកាលកំណត់ ឬយឺតយ៉ាវពេលគឺមានសុពលភាពគ្រប់គ្រាន់សម្រាប់អនុវត្ត។ល។

**ក-ផ្នែកលិខិតចូល**

មន្ត្រីទទួលបន្ទុកផ្នែកនេះត្រូវមានសៀវភៅសម្រាប់កត់ត្រាពលើលិខិតឯកសារចូល ដោយចែកចេញជាប្រភេទរបស់វាដូចជាៈ

-ប្រភេទលិខិតស្នាមធម្មតា

-ប្រភេទលិខិតជាសំណើ

-ប្រភេទលិខិតជាបទដ្ឋានរួមមានៈ ច្បាប់ ព្រះរាជក្រម ព្រះរាជក្រឹត្យ ប្រកាស

-ប្រភេទរបាយការណ៍ និងកំណត់ហេតុ។ល។

ឯកសារចូលគ្រប់ប្រភេទ ដូចបានរៀបរាប់ខាងលើ មន្ត្រី ឬបុគ្គលិក អ្នកទទួលបន្ទុកត្រូវចុះក្នុងបញ្ជីចូលភ្លាមៗតាមប្រភេទ មានលេខរៀង ចំនួនច្បាប់ ចំនួនសន្លឹក និងថ្ងៃ ខែ ម៉ោង ដើម្បីងាយស្រួលស្រាវជ្រាវ នៅពេលដែលត្រូវការ។ ពេលចុះរួចហើយ ត្រូវសរសេរលេខ និងថ្ងៃ ខែ ចូល លិខិតនោះ (បើសិនជាមានត្រាកាលបរិច្ឆេទបោះកាន់តែល្អ ព្រោះចំណេញពេល)។

ជាសារៈសំខាន់ក្នុងការបែងចែកលិខិតនោះ ជូនទៅផ្នែកជំនាញណាមួយ គួរអ្នកប្រគល់កត់ត្រាចំណាំទុក ក្នុងសៀវភៅមួយ ហើយជាការប្រសើរ គួរឱ្យអ្នកទទួលយកចុះហត្ថលេខាផង។

**ខ-ផ្នែកលិខិតចេញ**

មន្ត្រីទទួលបន្ទុកផ្នែកនេះក៏តម្រូវឱ្យមានសៀវភៅផ្សេងៗសម្រាប់ចុះលេខរៀង កាលបរិច្ឆេទ និងកន្លែង ឬអង្គភាពទទួលទៅតាមប្រភេទលិខិតផ្សេងៗ ដូចមានរៀបរាប់ខាងលើ។ ក្នុងករណីមានអ្នកនាំយកទៅជូនបុគ្គលិក ឬអង្គភាព មន្ទីរក្រសួងណាមួយនោះ ត្រូវមានសៀវភៅបញ្ជូនឯកសារ១ សម្រាប់ឱ្យអ្នកទទួលចុះហត្ថលេខា នៅពេលទទួលដោយមានបញ្ជាក់កាលបរិច្ឆេទត្រឹមត្រូវ។

សៀវភៅកត់ត្រាលិខិតចូល-ចេញ មានខ្លឹមសារ និងលក្ខណៈដូចខាងក្រោម៖

| ល.រ. | ខ្លឹមសារលិខិត | លេខលិខិត | ថ្ងៃខែ... | ចំនួនច្បាប់ | ចំនួនសន្លឹក | គម្រូជន | ហត្ថលេខា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

ចំណាំ៖ សៀវភៅកត់ត្រាខាងលើនេះ ត្រូវបើកនៅថ្ងៃទី១ ខែមករា ដើមឆ្នាំ ហើយបិទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៅចុងឆ្នាំ។ លេខរៀងត្រូវបន្តគ្នាក្នុងមួយឆ្នាំ ទោះបីប្តូរសៀវភៅក៏ដោយ។ ឆ្នាំថ្មីត្រូវប្រើលេខថ្មី។

-ត្រូវរក្សាទុកឯកសារគ្រប់សៀវភៅចូល និងចេញ។

-គេអាចដុតចោលនូវសៀវភៅបញ្ជូនលិខិតចេញនៅមុខគណៈកម្មការមួយ ក្រោយពីរក្សាទុករយៈពេល៣ឆ្នាំកន្លងមក។

ដូច្នេះ រាល់លិខិតបទដ្ឋាន និងរដ្ឋបាលទាំងអស់ពាក់ព័ន្ធនឹងស្ថាប័ន ឬអង្គភាពនីមួយៗ ចាំបាច់ត្រូវចូល និង ចេញតាមច្រកនៃការិយាល័យនេះ ទើបប្រធានអង្គភាពរដ្ឋបាលក្តាប់បានគ្រប់ជ្រុងជ្រោយ ងាយស្រួលចាត់ចែងតាមដានការងារ។

**៣.២-របៀបប្រើពណ៌ក្របសីមី**

- ពណ៌ខៀវ ៖ សាមញ្ញ ឬ ធម្មតា
- ពណ៌ពងក្រសា/ផ្ទៃមេឃ ៖ ប្រញាប់
- ពណ៌ក្រហមស្លេក ៖ ប្រញាប់ណាស់
- ពណ៌ក្រហម ៖ ប្រញាប់បំផុត
- ពណ៌លឿង ៖ សម្ងាត់
- ពណ៌លឿងទុំ ៖ សម្ងាត់បំផុត

## ៤-ការងារពិធីការ

### ៤.១-និយមន័យ

-ពិធីការ គឺទំនៀមទម្លាប់ និងបទបញ្ញត្តិទាំងឡាយសម្រាប់ប្រើប្រាស់ក្នុងពិធីនានា ឬជាក្រមសីលធម៌របស់អង្គទូត និងជនដទៃទៀត។

-ពិធីការ គឺជាកិច្ចការនៃរបៀប ឬការរៀបចំពិធីផ្សេងៗឱ្យមានរបៀបរៀបរយសណ្ដាប់ធ្នាប់ល្អប្រកប ដោយក្បួន ខ្នាតជាក់លាក់។

ឧទាហរណ៍៖ របៀបរៀបចំជប់លៀង ប្រជុំ សិក្ខាសាលា សន្និសីទជាតិ អន្តរជាតិ របៀបរៀបចំតុ សម្ភារៈលើតុជប់លៀង ឬតុប្រជុំ របៀបប្រើប្រាស់ភាសាក្នុងការទាក់ទង (និយាយ សរសេរ កាយវិការ) របៀបធ្វើការក្នុងការិយាល័យ។ល។[3]

**៤.២-សារប្រយោជន៍របស់ពិធីការ**

•បង្ហាញទំនៀមទម្លាប់ប្រពៃណីជាតិ៖ ទោះបីមានការហត់នឿយយ៉ាងណា ក៏ពិធីការមិនត្រូវសម្ដែងភាពនឿយ ឬអាការៈមួហ្មងឱ្យភ្ញៀវឃើញជាដាច់ខាត ព្រោះភ្ញៀវគេមិនចង់ឃើញជាដាច់ខាត ឬមិនចង់បានអ្វីក្រៅពីភាពសប្បាយរីករាយនោះទេ។ ម្យ៉ាងទៀតពិធីការក៏មិនត្រូវសម្ដែងចេញនូវភាពប្រាថ្នាចង់បានរង្វាន់ ឬលាភការអ្វីពីភ្ញៀវឡើយ។ ពិធីការខ្មែរតែងតែបង្ហាញភ្ញៀវឱ្យស្គាល់នូវ៖

-គារវកិច្ចខ្មែរ គឺ ការសំពះ

-អត្តចរិតខ្មែរ គឺ ទន់ភ្លន់ សុភាពរាបសា

-ប្រពៃណីខ្មែរ គឺ ការស្លៀកហូល ផាមួង អាវប៉ាក់ ពានាកន្សែងពណ៌តាមថ្ងៃ

•បង្ហាញនូវសេចក្ដីថ្លៃថ្នូររបស់ជាតិ៖ ពិធីការដើរតួនាទីសំខាន់ណាស់ក្នុងទំនាក់ទំនងការទូត ពិធីការមានឱកាសពិសេស សម្រាប់បញ្ចាញសេចក្ដីថ្លៃថ្នូររបស់ជាតិ (តាមរយៈថ្នាក់ដឹកនាំ) ជំរុញឱ្យទំនាក់ទំនងការទូតមានដំណើរការល្អធ្វើឱ្យភ្ញៀវពេញចិត្ត កក់ក្ដៅចាប់អារម្មណ៍។

•បង្ហាញនូវភាពទន់តែរឹង៖ ពិធីការជាអ្នកទន់ភ្លន់រួសរាយរាក់ទាក់ ប៉ុន្តែរឹងប៉ឹង ម៉ឺងម៉ាត់ ប្រាកដនិយម គោរពពេលវេលា និងគោលការណ៍ជាក់លាក់។

•បង្ហាញនូវសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន (សុជីវធម៌ សីលធម៌)

•បង្ហាញនូវប្រសិទ្ធភាពក្នុងទំនាក់ទំនង (ក្បួនច្បាប់ វិធានក្នុងទំនាក់ទំនង)

•បង្ហាញនូវវិសេសភាពរបស់ជាតិ (ទំនៀមទម្លាប់ ប្រពៃណី សិល្បៈ)

**៤.៣-ប្រភេទពិធីការផ្សេងៗ**

**ក-ពិធីការក្នុងទំនាក់ទំនង**

•ទំនាក់ទំនងផ្ទៃក្នុង (ទំនាក់ទំនងក្នុងស្ថាប័ន អង្គភាពរបស់ខ្លួន)

លេខាធិការត្រូវមានសេចក្ដីឆ្លាតវាងវៃធ្វើយ៉ាងណា រក្សាទំនាក់ទំនងផ្ទៃក្នុង ឱ្យបានល្អពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតពីផ្នែកមួយទៅផ្នែកមួយទៀត។ លេខាធិការត្រូវ៖

-ចេះធ្វើយ៉ាងណាឱ្យការងារមានប្រសិទ្ធភាព

-ចេះគោរពឋានានុក្រមការងារ

-ចេះសម្របខ្លួនដើម្បីទំនាក់ទំនងការងារឱ្យបានល្អ។

•ទំនាក់ទំនងការងារខាងក្រៅ(ទំនាក់ទំនងខាងក្រៅស្ថាប័ន អង្គភាព) លេខាធិការត្រូវ៖

-ស្គាល់ឱ្យបានច្បាស់លាស់អំពីបុគ្គលិកលក្ខណៈអ្នករួមការងាររបស់ខ្លួន និងភ្ញៀវមកពីខាងក្រៅ

[3] កុក រស់៖ ពិធីការទូទៅ គ. ស. ២០១០

-ឆ្លាតវាងវៃក្នុងការទំនាក់ទំនងជាមួយភ្ញៀវ (ទោះបីជាភ្ញៀវប្រភេទណាក៏ដោយ)។ ប្រសិនបើយើងទទួលភ្ញៀវបានល្អ នោះការងាររបស់យើងនឹងរីកចម្រើន។

វិធីសាស្ត្រខ្លះៗក្នុងការទំនាក់ទំនង៖

-ក្នុងការទំនាក់ទំនងការងារអ្វីមួយត្រូវគិតដល់ទីកន្លែង ពេលវេលា ត្រូវមានឯកសារសំអាងហេតុផលច្បាស់លាស់។

-ពេលធ្វើទំនាក់ទំនង លេខាធិការត្រូវអញ្ជើញភ្ញៀវចូលការិយាល័យ ឬបន្ទប់ទទួលភ្ញៀវទើបជាការសមរម្យ។

-អាចទាក់ទងនៅខាងក្រៅការិយាល័យ ករណីភ្ញៀវ ជាមិត្តភ័ក្តិ ឬជាមនុស្សដែលជិតស្និទ្ធបំផុត។

• ទំនាក់ទំនងជាផ្លូវការ ឬពាក់កណ្ដាលផ្លូវការ (រវាងអង្គភាពជាមួយក្រសួង ប្រជារាស្ត្រ)

-ក្នុងការទំនាក់ទំនងត្រូវមានការកោតសរសើរ និងការលើកទឹកចិត្ត

-ក្នុងការធ្វើទំនាក់ទំនង ត្រូវមានគោលដៅប្រាកដនិយមមួយក្នុងសកម្មភាពការងារឆ្ពោះទៅរកការអភិវឌ្ឍយូរអង្វែង។ ការគូសវាសគោលដៅ ត្រូវមានការពិចារណាឱ្យបានល្អិតល្អន់បំផុត។

-ដំណាក់កាលទំនាក់ទំនង ការទទួល ទីកន្លែង ពេលវេលា លេខាជាអ្នកចាត់ចែង។

-ការទទួល៖ ពេលមានការទទួលស្វាគមន៍រាក់ទាក់ល្អ នាំឱ្យមានការកក់ក្ដៅ ការបញ្ចេញមតិយោបល់ ក៏មានលក្ខណៈល្អប្រពៃដែរ (បង្ហាញភាពស្និទ្ធស្នាល)។

-ទីកន្លែង៖ ត្រូវរៀបចំទីកន្លែងសមរម្យ មានរបៀបរៀបរយ ផ្ដល់ផាសុកភាពក្នុងការទំនាក់ទំនង ធ្វើឱ្យភ្ញៀវយកចិត្តទុកដាក់ជាមួយយើង។

-ពេលវេលា៖ គឺជាចំណុចមួយចាំបាច់ក្នុងការទំនាក់ទំនង លេខាធិការ (ពិធីករ) ត្រូវចេះកំណត់ឱ្យច្បាស់លាស់(កុំយូរពេក)។

សរុបមកគ្រប់ទំនាក់ទំនង ត្រូវចេះផ្ទៀងស្ដាប់ តាមដាន យកចិត្តទុកដាក់ រួមទាំងកត់ត្រាចំណុចសំខាន់ៗ ឬថតចម្លងជាកស្តុតាង (បើភ្ញៀវផ្ដល់លទ្ធផលឱ្យ)។

**ខ-ពិធីការក្នុងការប្រើប្រាស់ភាសា**

ជាធម្មតា កើតមកជាមនុស្ស តែងតែរស់នៅជាសង្គមជាមួយនឹងមនុស្សដទៃទៀត។ ក្នុងការប្រាស្រ័យទាក់ទងរវាងគ្នានឹងគ្នា គេតែងបញ្ចេញនូវមនោសញ្ចេតនា ដើម្បីទាញយកផលប្រយោជន៍អ្វីមួយតាមរយៈភាសាគឺការប្រើប្រាស់ពាក្យសំដី។ ក្នុងសង្គមពាក្យសម្ដី មានសារប្រយោជន៍គ្រប់វិនាទី។

-ការប្រើប្រាស់ភាសានិយាយ៖ ការនិយាយ គឺជាការសម្ដែងចេញនូវពាក្យឬសម្ដីតាមរយៈការប្រើភាសា ហើយជាក្លោងទ្វារមួយសម្រាប់ឈានទៅរកជោគជ័យឬបរាជ័យក្នុងទំទាក់ទំទង។

-ការប្រើប្រាស់ភាសាតាមលិខិត៖ ការប្រើប្រាស់ភាសាតាមលិខិតត្រូវមានក្បួនខ្នាត (រូបមន្ត) ច្បាស់លាស់ក្នុងការសរសេរ។

-ភាសាកាយវិការ៖ ភាសាកាយវិការ គឺជាការប្រើប្រាស់សញ្ញាជំនួសការនិយាយ។

**គ-ពិធីការក្នុងការងារ**

**•ពីអ្នកធំទៅអ្នកតូច៖**

***ប្រការគួរធ្វើ៖***

*-និយាយដោយបោរីភាពជានិច្ច*

*-ចេះស្ដាប់យោបល់អ្នកក្រោមបង្គាប់*

*-និយាយតែសាច់ការ*

*-លើកទឹកចិត្តដោយការសរសើរនិងជូនរង្វាន់។*

***ប្រការមិនគួរធ្វើ៖***

*-ស្និទ្ធស្នាលហួសប្រមាណ*

*-ប្រើប្រាស់ភាសាមិនសមរម្យ*

*-ជជែកខ្វែងយោបល់ជាមួយអ្នកតូចជាង*

*-រំខានដល់ការងារអ្នកក្រោមបង្គាប់។*

**•ពីអ្នកតូចទៅអ្នកធំ៖**

***ប្រការគួរធ្វើ៖***

*-ប្រកាន់សេចក្ដីគោរពជានិច្ច*

*-គោរពការសម្រេចចុងក្រោយរបស់ចៅហ្វាយនាយ*

*-និយាយតែការណាមានប្រយោជន៍ច្បាស់លាស់ ខ្លី ។*

***ប្រការមិនគួរធ្វើ៖***

*-តវ៉ា ប្រឆាំង ជំទាស់ដោយឥតហេតុ-ផល*

*-សួរដេញដោលអ្នកធំច្រើនពេក*

*-រំខានពេលវេលារបស់ចៅហ្វាយនាយ ។*

**•រវាងអ្នកមានឋានៈ(ឋានន្តរស័ក្តិ) ស្មើគ្នា៖**

*-សហប្រតិបត្តិការ ជួយគ្នា*

*-សោមនស្សភាព ភាតរភាព*

*-មិនរំលោភបំពានការងារគ្នា*

*-បុរសត្រូវសន្ដោសនារី ។*

**វិន័យផ្ទៃក្នុងរបស់អ្នកធ្វើការងារទូទៅ**

*១-គោរពពេលម៉ោងធ្វើការងារ*

*២-ចុះវត្តមានរាល់ពេលបំពេញការងារ*

*៣-ប្រកាន់កន្លែងផ្ទាល់ខ្លួន*

*៤-ខិតខំបំពេញការងារដោយយកចិត្តទុកដាក់*

*៥-សាមគ្គីភាពទូលាយ ស្មោះត្រង់ជានិច្ច*

*៦-ការពារសន្តិសុខ សណ្ដាប់ធ្នាប់*

*៧-គោរពការចាត់តាំង*

*៨-ធ្វើតាមបញ្ជាប្រធាន*

*៩-រក្សាការសម្ងាត់របស់កិច្ចការ*

*១០-ប្រកាន់អត្តចរិតស្លូតបូត សុភាពរាបសា*

*១១-មិនត្រូវយកឯកសារទៅធ្វើនៅផ្ទះ*

*១២-មិនត្រូវធ្វើកិច្ចការឯកជនក្នុងម៉ោងការងារ*

*១៣-មិនត្រូវយកទ្រព្យរួមធ្វើជាទ្រព្យផ្ទាល់ខ្លួន*

*១៤-មិនត្រូវហូបចុកនៅកន្លែងធ្វើការ*

*១៥-មិនត្រូវអង្គុយច្រងេងច្រងាងឬអង្គុយលើតុ*

*១៦-មិនត្រូវលេងល្បែងគ្រប់ប្រភេទនៅកន្លែងធ្វើការ*

*១៧-មិនត្រូវចាក់ម៉ាញ៉េឬស្ដាប់ភ្លេងលេងកម្សាន្ត*

*១៨-មិនត្រូវរំខានដល់អ្នកធ្វើការក្បែរគ្នា*

*១៩-មិនត្រូវវាយឫកក្នុងការងារ*

២០-មិនត្រូវចូលការិយាល័យគេពេលគេកំពុងធ្វើការ (បើមិនចាំបាច់)[4]

**ឃ-ពិធីការក្នុងការប្រជុំ**

ការប្រជុំគឺជាការដែលមនុស្សមួយក្រុមមកជួបជុំគ្នាដើម្បីផ្លាស់ប្តូរនូវគំនិត មតិយោបល់ ពិភាក្សា រហូតដល់ការវិនិច្ឆ័យដើម្បីចេញសេចក្តីសម្រេច។

ក្នុងអង្គប្រជុំទូទៅមានសមាសភាព(ធាតុ) សំខាន់៣គឺ:

-ប្រធានអង្គប្រជុំ

-លេខាធិការ

-អ្នកចូលរួម។

ក្រៅពីធាតុទាំងបីខាងលើ ពិធីការ ក៏ជាធាតុមួយយ៉ាងសំខាន់ណាស់ដែរ សម្រាប់ចូលរួមដំណើរការសម្របសម្រួល និងចាត់កម្មវិធី ព្រមទាំងរៀបចំកម្មវិធីឱ្យមានសកម្មភាពរស់រវើក។

•មុនពេលប្រជុំ៖

-កំណត់ឱ្យច្បាស់ពីគោលដៅនៃការប្រជុំ (កម្មវត្ថុ)

-រៀបចំរបៀបវារៈឱ្យបានត្រឹមត្រូវ (ពេលវេលា)

-ត្រូវចេះជ្រើសរើសអ្នកចូលរួម (លិខិតអញ្ជើញ)

-ជ្រើសរើសនិងរៀបចំទីកន្លែងឱ្យបានសមរម្យ

-រៀបចំសម្ភារៈដែលពាក់ព័ន្ធការប្រជុំ(តុ កៅអី កម្រាល ផ្កា ឯកសារពាក់ព័ន្ធ ប្រដាប់បំពងសំឡេង ប្រដាប់ថត ភេសជ្ជៈ បង្អែម ផ្លែឈើ។ល។

•ពេលប្រជុំ៖

-ពិធីករត្រូវតែដឹងនូវទិន្នន័យទូទៅដែលទាក់ទងនឹងពិធីប្រជុំឱ្យបានច្រើន

-ពិធីករជាអ្នកចាត់តាំងនិងសម្របសម្រួលកម្មវិធី

-ត្រូវធ្វើឱ្យដំណាក់កាលមួយទៅដំណាក់កាលមួយប្រព្រឹត្តទៅបានល្អ

-ត្រូវមានភាពស្មោះត្រង់ រឹងប៉ឹងនិងមានភាពឱនលំទោនជានិច្ច។

**•ក្រោយពេលប្រជុំ៖**

-ការជួបជុំសំណេះសំណាល

-ពិសាភេសជ្ជៈឬអាហារមិត្តភាព

-ត្រឡប់ទៅលំនៅដ្ឋានវិញ។

[4] កុក រស់៖ ពិធីការទូទៅ ដ.ឯ.ម.

**ឯកសារពិគ្រោះ**

*១-កុក រស់៖ ពិធីការទូទៅ គ. ស. ២០១០*

*២-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧*

*៣-សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ៖ រដ្ឋបាលសាធារណៈ ២០០៦-២០០៧*

*៤-សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២*

*៥-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣*

# លិខិតបទដ្ឋានគតិយុត្ត

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*លិខិតបទដ្ឋានគតិយុត្ត គឺជាវិធានច្បាប់ ឬវិធានគតិយុត្តទាំងឡាយណាដែលចេញដោយស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចតាមលំដាប់ថ្នាក់ដើម្បីដឹកនាំ គ្រប់គ្រងទំនាក់ទំនងរបស់មនុស្សក្នុងសង្គម គ្រប់វិស័យឱ្យមានរបៀបរៀបរយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខមាលភាព ការអភិវឌ្ឍ និងភាពសុខសាន្តក្នុងសង្គមជាតិ។*

*លិខិតបទដ្ឋានគតិយុត្ត មានតាមលំដាប់ដូចជា រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងដីកា។*

*វិធានគតិយុត្ត ទាំងនេះគឺជាវិធានច្បាប់ដែលបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចចំពោះប្រជាពលរដ្ឋ និងមន្ត្រីរាជការ ហើយមានទណ្ឌកម្មចំពោះជនដែលប្រព្រឹត្តខុស។*

*វិធានខ្លះមិនមែនជាវិធានគតិយុត្តទេ ដូចជាវិធានសីលធម៌ វិធានសាសនា ឬវិធានសុជីវធម៌ ជាដើម។ វិធានទាំងនេះមិនបង្កើតនូវសិទ្ធិ ឬកាតព្វកិច្ចអ្វីខាងផ្លូវច្បាប់ដល់បុគ្គលណាមួយឡើយ បើសិនជាអ្នកណាមិនគោរព អ្នកនោះក៏គ្មានទោសពៃរ៍អ្វីដែរ (គឺគ្មានសំណង ពិន័យ ឬទោសព្រហ្មទណ្ឌពីអាជ្ញាធរចំពោះការមិនគោរព)។ វាទាក់ទងទៅនឹងផ្លូវចិត្ត និងជំនឿផ្ទាល់របស់បុគ្គល គឺថាមិនដូចវិធានគតិយុត្តទេ។*

*លិខិតបទដ្ឋានគតិយុត្តមានប្រភពចេញមកពីស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។*

## ១-ប្រភពពីស្ថាប័ននីតិបញ្ញត្តិ

### ១.១-រដ្ឋធម្មនុញ្ញ

*រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញ ជាប្រភពដើមនៃអំណាចដែលចេញមកពីប្រជាពលរដ្ឋ។ ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។*

*ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ មានការបោះឆ្នោតជាសកលលើកដំបូងនៅកម្ពុជា ជ្រើសតាំងសមាជិកសភាធម្មនុញ្ញ៦៧រូប ដែលមានបេសកកម្មតាក់តែងរដ្ឋធម្មនុញ្ញទី១*

នៃព្រះរាជាណាចក្រកម្ពុជា ហើយព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជា ទ្រង់ប្រោសព្រះរាជទានរដ្ឋធម្មនុញ្ញនេះដល់ប្រជារាស្ត្រខ្មែរនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧។

រដ្ឋធម្មនុញ្ញបច្ចុប្បន្ន ត្រូវបានអនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃអង្គារ ៦កើត ខែកទ្រុបទ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៧ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមនៅថ្ងៃសុក្រ ៩កើត ខែកទ្រុបទ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៧ ត្រូវនឹងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។

រដ្ឋធម្មនុញ្ញនេះ មាន១៧ជំពូក និង ១៦០មាត្រា។ ជំពូកទី១ ចែងអំពីអធិបតេយ្យ ជំពូកទី២ អំពីព្រះមហាក្សត្រ ជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ជំពូកទី៤ អំពីរបបនយោបាយ ជំពូកទី៥ អំពីសេដ្ឋកិច្ច ជំពូកទី៦ អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច ជំពូកទី៧ អំពីរដ្ឋសភា ជំពូកទី៨ថ្មី អំពីព្រឹទ្ធសភាជំពូកទី៩ថ្មី អំពីសមាជរដ្ឋសភា និងព្រឹទ្ធសភា ជំពូកទី១០ថ្មី អំពីរាជរដ្ឋាភិបាល ជំពូកទី១១ថ្មី អំពីអំណាចតុលាការ ជំពូកទី ១២ថ្មី អំពីក្រុមប្រឹក្សាធម្មនុញ្ញ ជំពូកទី១៣ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល ជំពូកទី១៤ថ្មី អំពីសមាជជាតិ ជំពូកទី១៥ថ្មី(ពីរ) អំពីអង្គការរៀបចំការបោះឆ្នោត ជំពូកទី១៦ថ្មី (ពីរ) អំពីអានុភាពការសើរើនិងវិសោធនកម្មរដ្ឋធម្មនុញ្ញ និងជំពូកទី១៧ថ្មីអំពីអន្តរបញ្ញត្តិ។[1]

### ១.២-សន្ធិសញ្ញា

សន្ធិសញ្ញា (Treaty) ឬអនុសញ្ញា (Convention) ឬធម្មនុញ្ញ (Charter) ឬកតិកាសញ្ញា (Pact) ឬកិច្ចព្រមព្រៀង (Agreement/Accord) មានន័យដូចគ្នា គឺជាច្បាប់អន្តរជាតិដែលជាកិច្ចព្រមព្រៀងធ្វើឡើងរវាងរដ្ឋនិងរដ្ឋ (អាចទ្វេភាគីឬពហុភាគី) ក្នុងទង្វើជាលាយលក្ខណ៍អក្សរសម្រាប់គ្រប់គ្រងទំនាក់ទំនងអន្តរជាតិ និងដោះស្រាយបញ្ហារវាងប្រទេសនានាក្នុងពិភពលោក។ ប៉ុន្តែការប្រើពាក្យនីមួយៗ អាស្រ័យនឹងប្រភេទនៃវិស័យនីមួយៗ ឬបរិបទ ឬតាមតំបន់ពុំមានពាក្យណាធំជាងឬតូចជាងពាក្យណាទេ។

**ឧទាហរណ៍៖**

-ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

-កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

-អនុសញ្ញា ស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍

-សន្ធិសញ្ញា ស្តីពីតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ

[1] អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣*

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង ស្ដីពីការជំរុញ និងការការពារ វិនិយោគ។ល។

ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មាត្រា១២ បានចែង "នាយករដ្ឋមន្ត្រីដឹកនាំ ការចរចា និងចុះហត្ថលេខារាល់កិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស និងការពារប្រទេស។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាលណាម្នាក់ ជាអ្នកចរចា និងជាអ្នកចុះហត្ថលេខា។

មាត្រា២៦ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា "ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា"។

**១.៣-ច្បាប់**

ច្បាប់ គឺជាវិធានសរសេរមានលក្ខណៈទូទៅ និងអចិន្ត្រៃយ៍ ដែលផ្ដួចផ្ដើមដោយសមាជិកសភា (សេចក្ដីស្នើច្បាប់) ឬដោយរាជរដ្ឋាភិបាល (សេចក្ដីព្រាងច្បាប់) ហើយត្រូវបានអនុម័តដោយសភា បន្ទាប់មកត្រូវប្រកាសឱ្យប្រើដោយព្រះមហាក្សត្រតាមរយៈព្រះរាជក្រម។

ច្បាប់មានលក្ខណៈទូទៅ ដាច់ខាត អចិន្ត្រៃយ៍ និងមានទណ្ឌកម្មដែលត្រូវអនុវត្តដោយអាជ្ញាធរ សាធារណៈ។

***-លក្ខណៈទូទៅ ដាច់ខាត៖*** គឺអនុវត្តទៅលើជនគ្រប់រូបទូទៅ និងគ្រប់ទីកន្លែងទូទាំងប្រទេសដូចៗគ្នា មិនរើសអើង ទោះជាអ្នកមាន ឬអ្នកក្រ មន្ត្រី ឬរាស្ត្រ។

***-លក្ខណៈអចិន្ត្រៃយ៍៖*** មានន័យថាពេលដែលវានៅជាធរមានត្រូវអនុវត្តជារហូតលុះត្រាមានការធ្វើវិសោធនកម្ម ឬមានច្បាប់ថ្មីមកជំនួស។

***-មានទណ្ឌកម្ម៖*** ចំពោះជនដែលបំពាន មិនគោរព ឬរំលោភច្បាប់ គឺត្រូវតែដាក់ទណ្ឌកម្មចំពោះជននោះដែលអាចជាសំណង ពិន័យ ឬ/និងទោសព្រហ្មទណ្ឌ(ជាប់ពន្ធនាគារ)។

***•ព្រះរាជក្រម៖***

ព្រះរាជក្រម គឺជាលិខិតបទដ្ឋានមួយដែលឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រ សម្រាប់ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់នានា ដែលអនុម័តដោយអង្គការនីតិបញ្ញត្តិ។

***ឧទាហរណ៍៖***

-ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤

ប្រកាសប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

-ព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ប្រកាសប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## ២-ប្រភពពីស្ថាប័ននីតិប្រតិបត្តិ

### ២.១-ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ គឺជាលិខិតបទដ្ឋានមួយដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រតាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី) ឬតាមព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រ។ ព្រះរាជក្រឹត្យមានទម្រង់ជា៖

***ក-ព្រះរាជក្រឹត្យបទបញ្ញា៖*** ច្បាប់បានកំណត់នូវកិច្ចការឬវិស័យមួយចំនួនរបស់ប្រទេសជាតិ ថាត្រូវធ្វើជាព្រះរាជក្រឹត្យដើម្បីជាលិខិតបទដ្ឋាន(បទបញ្ញា)បន្តសម្រាប់អនុវត្តច្បាប់(ពីព្រោះច្បាប់គ្រាន់តែចែងចំណុចគោលៗដោយទុកឱ្យរដ្ឋាភិបាលរៀបចំធ្វើជាព្រះរាជក្រឹត្យចែងលម្អិតនូវខ្លឹមសារបន្ត) សម្រាប់មន្ត្រី ឬប្រជាពលរដ្ឋយកទៅគោរពអនុវត្ត។

***ឧទាហរណ៍៖***

-ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការប្តូរក្រុងប៉ៃលិន ទៅជា ខេត្តប៉ៃលិន។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខេត្តត្បូងឃ្មុំ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៥២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

មាត្រា៧ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញចែងថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ"។ ដូច្នេះ ព្រះអង្គពុំអាចចេញសេចក្តីសម្រេចជាបទបញ្ញាបានឡើយ។ រាល់សេចក្តីសម្រេចធ្វើបទបញ្ញា ជាភារកិច្ចរបស់រាជរដ្ឋាភិបាល។ ព្រះមហាក្សត្រជាអ្នកផ្តល់នីត្យានុកូលភាពដល់រាល់បទបញ្ញាដែលសម្រេចឡើងដោយគណៈរដ្ឋមន្ត្រី(គឺផ្តល់នូវភាពស្របច្បាប់ដល់ព្រះរាជក្រឹត្យ ពីព្រោះរដ្ឋធម្មនុញ្ញបានចែងថាព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី)។

***ខ-ព្រះរាជក្រឹត្យឯកត្តភូតៈ*** *ព្រះរាជក្រឹត្យឯកត្តភូតមានពីរបែប គឺព្រះរាជក្រឹត្យចាត់តាំង និង ព្រះរាជក្រឹត្យតែងតាំង។*

*-តាមសេចក្ដីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រ ទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល(មាត្រា១១៩ថ្មីនៃរដ្ឋធម្មនុញ្ញ)។*

*-សមាជិកព្រឹទ្ធសភាចំនួន* ***២រូប*** *ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ (មាត្រា១០០ថ្មី)។*

*-ព្រះមហាក្សត្រ ទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និង ទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា១១៩ថ្មី។*

*-នាយករដ្ឋមន្ត្រី លើកសំណើថ្វាយព្រះមហាក្សត្រតែងតាំងផ្លាស់ប្ដូរបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យចំពោះអគ្គទេសាភិបាល អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី អគ្គលេខាធិការ អគ្គនាយក អគ្គាធិការក្រសួង សាកលវិទ្យាធិការ ប្រតិភូរាជរដ្ឋាភិបាល អភិបាលរាជធានី ខេត្ត ឯកអគ្គរាជទូតប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ ព្រមទាំងមុខតំណែងប្រហាក់ប្រហែលមួយចំនួនទៀត។*

*-តាមសេចក្ដីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ប្ដូរ ឬដកចៅក្រមផ្នែកយុត្តាធិការ។*

***ឧទាហរណ៍ៈ***

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៧៧២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការចាត់តាំងឯកឧត្តមបណ្ឌិត* **ហ៊ុន ម៉ាណែត** *ជា នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៣៩ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការតែងតាំង ឯកឧត្តម* **ជីវ កេង** *ជាប្រធានតុលាការកំពូល នៃព្រះរាជាណាចក្រកម្ពុជា។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការតែងតាំង លោកជំទាវ* **ជា សិរី** *ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា។*

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨២៣/២០២១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងឯកឧត្តមនាយឧត្តម សេនីយ៍ **ស ថេត** ជា អគ្គស្នងការ នៃអគ្គស្នង ការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ១១២៣/២៣៩០ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០២៣ ស្តីពីការ តែងតាំងឧត្តមសេនីយ៍ឯក **ដោក សុផា** ជា សាកលវិទ្យាធិការ សាកល វិទ្យាល័យការពារជាតិ។

តាមធម្មតា ព្រះរាជក្រឹត្យត្រូវមានការ ស្នើសុំពីគណៈរដ្ឋមន្ត្រី ប៉ុន្តែ ព្រះរាជក្រឹត្យខ្លះ ពុំមានការស្នើសុំពីគណៈរដ្ឋមន្ត្រីទេ ដូចជា ព្រះរាជក្រឹត្យតែងតាំងសមាជិកនៃក្រុមប្រឹក្សា ធម្មនុញ្ញ ព្រះរាជក្រឹត្យតែងតាំងគោរមងារ និង ឋានៈក្នុងព្រះរាជវង្សានុវង្ស ព្រះរាជក្រឹត្យ តែងតាំងសមាជិកនៃព្រះរាជខុទ្ទកាល័យព្រះ មហាក្សត្រ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ព្រះរាជក្រឹត្យតែងតាំងគោរមងារឥស្សរជន ដែលជាព្រះរាជបុព្វសិទ្ធិ អនុញ្ញាតឱ្យព្រះ មហាក្សត្រចេញព្រះរាជក្រឹត្យប្រភេទនេះ តាមបវេណីព្រះមហាក្សត្រ។

**ឧទាហរណ៍៖**

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៣២៣/៤៨២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២៣ ស្តីពីការប្រគេនគោរមងារ ព្រះអរិយ មុនី **កែវ ឌីម៉ង់** សមាជិកគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណា ចក្រកម្ពុជា និងជាព្រះរាជលេខាធិការផ្ទាល់ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត **ប៊ួរ គ្រី** សម្តេចព្រះមហា សង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរា ជាណាចក្រកម្ពុជា ជា **សម្តេចព្រះពុទ្ធវង្សរាជ វង្សា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៤២៣/៦១៤ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២៣ ស្តីពីការប្រោសព្រះរាជទាន គោរមងារ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ជា **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៥២៣/៨០៦ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងគោរមងារ ព្រះ មហាវិមលធម្ម **ពិន សែម** ព្រះរាជាគណៈ ថ្នាក់ទោ ឱ្យឡើងទីជា **សម្តេចព្រះព្រហ្មរតន មុនី** គណៈមហានិកាយ នៃព្រះរាជាណាចក្រ កម្ពុជា ។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៧២៣/១៦៣៩ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២៣ ស្តីពីការដំឡើងឋានៈ **ព្រះអង្គម្ចាស់ នរោត្តម ច្រឹយសោភ័ណ្ឌ** ជា **ស្តេចក្រុម ឃុន នរោត្តម ច្រឹយសោភ័ណ្ឌ** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨២៣/២០៣៧ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការផ្តល់គោរមងារដល់ ឯកឧត្តម បណ្ឌិត **ស សុខា** ជា **អភិសន្តិបណ្ឌិត** នៃ បណ្ឌិត្យសភានគរបាលកម្ពុជា ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១០៩ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២៣ ស្តីពីការប្រោសព្រះរាជទានគោរមងារ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** ជា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១១០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២៣ ស្តីពីការប្រោសព្រះរាជទានគោរមងារ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** ជា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២២០២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងគោរមងារ ព្រះមុនីកោសលបណ្ឌិត **យ៉ន សេងយៀត** ព្រះរាជាគណៈថ្នាក់ទោ ឱ្យឡើងទីជា **សម្តេចព្រះមហាអរិយវង្ស** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៤៣០ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងគោរមងារ ព្រះមហាវិមលធម្ម **ហ៊ូ ឈីវនាថ** ព្រះរាជាគណៈថ្នាក់ទោ ឱ្យឡើងទីជា **សម្តេចព្រះមង្គលមុនីវង្ស** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា។

គោរមងារ "**សម្តេច**" គឺជាងារដែលខ្ពស់ជាងគេបំផុតក្នុងថ្នាក់មន្ត្រីរាជការជាន់ខ្ពស់ ឬឥស្សរជននយោបាយ ដែលព្រះមហាក្សត្រអាចធ្វើព្រះរាជក្រឹត្យតែងតាំងប្រទានឱ្យ យោងតាមគុណបំណាច់ដ៏ធំធេងដែលមន្ត្រីរាជការជាន់ខ្ពស់ ឬឥស្សរជននយោបាយនោះមានចំពោះប្រទេសជាតិ ចំពោះរាជបល្ល័ង្ក៕[2]

គោរមងារនេះក៏អាចត្រូវបានព្រះមហាក្សត្រធ្វើព្រះរាជក្រឹត្យតែងតាំងប្រទានឱ្យចំពោះព្រះសង្ឃជាន់ខ្ពស់ និងរាជវង្សានុវង្សយោងតាមគុណបំណាច់ដ៏ធំធេងផងដែរ។

គោរមងារ "**សម្តេច**" មិនផ្តល់សិទ្ធិដល់អ្នកទទួល ឱ្យក្លាយទៅជាស្តេច ឬជាសមាជិកនៃព្រះរាជវង្សានុវង្សបានឡើយ។

គោរមងារ "**ឧកញ៉ា**" សំដៅដល់ងារកិត្តិយសដែលព្រះមហាក្សត្រទ្រង់ព្រះរាជទានដោយព្រះរាជក្រឹត្យ ទៅតាមលំដាប់ថ្នាក់ដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលមានគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ។ គោរមងារ "**ឧកញ៉ា**"មាន៣ លំដាប់ថ្នាក់ គឺ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និង ឧកញ៉ា។ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិប្រោសព្រះរាជទានគោរមងារឧកញ៉ាដល់រូបវន្តបុគ្គលដែលមានគុណសម្បត្តិ គុណបំណាច់ និងមានស្នាដៃដ៏ធំធេងក្នុងបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ។ នាយករដ្ឋមន្ត្រីតែម្នាក់គត់ មានសិទ្ធិលើកសំណើទូល

[2] សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២

ថ្វាយព្រះមហាក្សត្រក្នុងការស្នើសុំគោរមងារឧកញ៉ានិងការបញ្ចប់គោរមងារឧកញ៉ា[3]

**ឧទាហរណ៍៖**

-ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៦/៨៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការផ្តល់គោរមងារ **លោក យោគ រាជ** ជា **លោកអ្នកឧកញ៉ា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩១១/៨៦៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការផ្តល់គោរមងារ **លោកព្រឹទ្ធាចារ្យមហាឧបាសក ហ៊ុន នាង** ជា **អ្នកឧកញ៉ា មហាភក្តី សប្បុរិសភោគាធិបតី ហ៊ុន នាង** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១១១៩/១៧៩៣ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់គោរមងារ **មហាឧបាសិកា ប៊ុន ស៊ាងលី** ជា **អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា ប៊ុន ស៊ាងលី** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥០៩ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ ឯកឧត្តម **ហ៊ុន សាន** ជា **អ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥១០ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ ឯកឧត្តម **គ្រី ទូច** ជា **អ្នកឧកញ៉ា ឧត្តមមង្គលសោភ័ណត្រី គ្រី ទូច** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០២២១/១៨៣ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការផ្តល់គោរមងារ ឧកញ៉ា **គិត ម៉េង** ជា **អ្នកឧកញ៉ា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៣៨៤ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ ឧកញ៉ា **ម៉ៅ ចំណាន** ជា **អ្នកឧកញ៉ា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៣៨៥ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ លោក **គិត ស៊ីវឡា** ជា **ឧកញ៉ា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥៧ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ កញ្ញា **ឡាយ ម៉ូនីកា** ជា **ឧកញ៉ា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ លោកជំទាវ **ឡាយ ឈុននី** ជា **ឧកញ៉ា** ។

ឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ ឧត្តមមន្ត្រី និងឋានន្តរស័ក្តិទី១ នៃក្របខណ្ឌប្រភេទ ក (ក១)ក៏ត្រូវដំឡើងដោយព្រះរាជក្រឹត្យផងដែរ។

**ឧទាហរណ៍៖**

-ព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៤៥៤ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ

[3] ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្តីពី គោរមងារឧកញ៉ា

*២០២៣ ស្ដីពីការដំឡើង ឋានន្តរស័ក្តិ* **នាយឧត្តមសេនីយ៍** *ដល់ ឧត្តមសេនីយ៍ឯក* **ហ៊ុន ម៉ាណែត** *អត្តលេខ ០៣៣៨៨៣ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៦២៣/១០៥២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០២៣ ស្ដីពីការដំឡើងថ្នាក់និងឋានន្តរស័ក្តិក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន* ***១៤៤****រូប ។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/៤៥៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២៣ ស្ដីពីការដំឡើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ (ឧត្តមសេនីយ៍ឯក* ***៤****រូប និងឧត្តមសេនីយ៍ទោ* ***១****រូប)។*

### ២. ២-អនុក្រឹត្យ

*អនុក្រឹត្យ គឺជាលិខិតបទដ្ឋាន ឬសេចក្ដីសម្រេចមួយដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ អនុក្រឹត្យ មានទម្រង់ជា៖*

***ក-អនុក្រឹត្យបទបញ្ជា៖*** *ច្បាប់បានកំណត់នូវកិច្ចការឬវិស័យណាមួយរបស់ប្រទេសជាតិ ថា ត្រូវធ្វើជាអនុក្រឹត្យដើម្បីជាលិខិតបទដ្ឋាន (បទបញ្ជា) បន្តសម្រាប់អនុវត្ត (ពីព្រោះច្បាប់គ្រាន់តែចែងចំណុចគោលៗ ដោយទុកឱ្យ ឬតម្រូវឱ្យរដ្ឋាភិបាលរៀបចំធ្វើជាអនុក្រឹត្យចែងលម្អិតនូវខ្លឹមសារបន្ត) សម្រាប់មន្ត្រី ឬប្រជាពលរដ្ឋយកទៅគោរពអនុវត្ត។*

***ឧទាហរណ៍៖***

*-អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។*

*-អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ។*

*-អនុក្រឹត្យលេខ ២៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការបង្កើត* ***ក្រុងសំពៅពូន*** *នៃខេត្តកណ្ដាល ។*

*-អនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការបង្កើត* ***ស្រុកអូរគ្រៀងសែនជ័យ*** *នៃខេត្តក្រចេះ ។*

*-អនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការបំបែក* ***ស្រុកឧដុង្គ*** *នៃខេត្តកំពង់ស្ពឺ ។*

*-អនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្ដីពីការបង្កើត* ***ក្រុងអរិយក្សត្រ*** *នៃខេត្តកណ្ដាល ។*

***ខ-អនុក្រឹត្យឯកត្តភូត៖*** *សម្រាប់តែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ច ដំឡើងឋានន្តរស័ក្តិ ថ្នាក់មន្ត្រីរាជការ នគរបាល*

*យោធា នៅតាមក្រសួង ស្ថាប័ន និងអង្គភាពនីមួយៗរបស់រដ្ឋ។*

*នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ដូចជា អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង សាកលវិទ្យាធិការរង ព្រឹទ្ធបុរសមហាវិទ្យាល័យ ប្រធាននាយកដ្ឋាន និងមុខតំណែងផ្សេងទៀតដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។*

***ឧទាហរណ៍៖***

*-អនុក្រឹត្យលេខ ៣៦១ អនុក្រ.តត ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ ស្តីពីការតែងតាំងលោក* **មួច ធី** *ជាអភិបាល នៃគណៈអភិបាល* ***ស្រុកសាមគ្គីមុនីជ័យ*** *និងលោក* **ព្រាប កុយចឡុន:** *ជាអភិបាល នៃគណៈអភិបាល* ***ក្រុងឧដុង្គម៉ែជ័យ*** *។*

*-អនុក្រឹត្យលេខ ១០៥៥ អនុក្រ.តត ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងឧត្តមសេនីយ៍ឯក* **ស រដ្ឋា** *និងឧត្តមសេនីយ៍ទោ* **ជួន ណារិន្ទ** *ជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ។*

*-អនុក្រឹត្យលេខ ១០៥៦ អនុក្រ.តត ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងលោក* **កែ សួនសុភាព** *ជាអភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ។*

*-អនុក្រឹត្យលេខ ១១៥១ អនុក្រ.តត ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការតែងតាំងឧត្តមនាវីទោ* **ម៉ី ឌីណា** *អត្តលេខ ០១៥១០៦ ជាមេបញ្ជាការ មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក។*

*-អនុក្រឹត្យលេខ ១២៣៥ អនុក្រ.តត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់* **២៩**រូប *មានឋានៈស្មើ* ***អគ្គនាយករង*** *។*

*-អនុក្រឹត្យលេខ ១២៦៤ អនុក្រ.តត ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការតែងតាំងឧត្តមសេនីយ៍ទោ* **ប៉ាន់ សុវណ្ណារិទ្ធ** *អត្តលេខ ៨៤៦៤០ ជាប្រធាននាយកដ្ឋាននីតិកម្ម ផែនការ និងបណ្តុះបណ្តាល នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។*

*ឋានន្តរស័ក្តិ ថ្នាក់ វរសេនីយ៍ឯក (ស័ក្តិ ៥) វរមន្ត្រី និងឋានន្តរស័ក្តិទី២ នៃក្របខណ្ឌប្រភេទ ក (ក២) ក៏ត្រូវដំឡើងដោយអនុក្រឹត្យផងដែរ។*

***ឧទាហរណ៍៖***

*-អនុក្រឹត្យលេខ ១០៦១ អនុក្រ.តត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការដំឡើងឋានន្តរស័ក្តិ* **ថ្នាក់វរសេនីយ៍ឯក** *នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដល់ វរសេនីយ៍ទោ* **ស៊ូ កណ្ណារដ្ឋ** *អត្តលេខ ០២៨៥៣៤ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តសៀមរាប។*

*-អនុក្រឹត្យលេខ ៦១៣ អនុក្រ.តត ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការចំនួន*

១៣៦រូប នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល។

-អនុក្រឹត្យលេខ ៩៤០ អនុក្រ.តត ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ចំនួន **១៣៥៥**រូប ក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងអប់រំ យុវជន និងកីឡា។

អនុក្រឹត្យឯកត្តកូត មានចេញចំពោះបុគ្គលចំណោះផ្សេងៗទៀត ក្រៅពីពួកមន្ត្រីរាជការ ដូចជា ការជូនមេដាយស្ថាបនាជាតិជាដើម ដល់សប្បុរសជនដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ក្នុងវិស័យស្ថាបនាជាតិ។[4]

## ២.៣-ប្រកាស

ប្រកាស គឺជាលិខិតបទដ្ឋាន ឬសេចក្តីសម្រេចមួយដែលចេញ និងចុះហត្ថលេខាដោយសមាជិករាជរដ្ឋាភិបាលដែលជាប្រធានស្ថាប័ន (រដ្ឋមន្ត្រី) សម្រាប់គ្រប់គ្រង និងដឹកនាំកិច្ចការដែលជាសមត្ថកិច្ច នៃក្រសួង ស្ថាប័នរបស់ខ្លួន។ ប្រកាសរបស់ប្រធានស្ថាប័នត្រូវស្របជាមួយលិខិតបទដ្ឋាននានា ដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ជាដើម។ ប្រកាសមានទម្រង់ជា៖

***ក-ប្រកាសបទបញ្ញា៖*** ច្បាប់បានកំណត់នូវកិច្ចការឬវិស័យណាមួយរបស់ប្រទេសជាតិថាត្រូវធ្វើជាប្រកាសដើម្បីជាលិខិតបទដ្ឋាន(បទបញ្ញា)បន្តសម្រាប់មន្ត្រី ឬប្រជាពលរដ្ឋយកទៅគោរព និងអនុវត្ត។

**ឧទាហរណ៍៖**

-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៤២៧៤ ប្រ.ក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។

-ប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣៩ កយ.ប្រក/១០ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១០ ស្តីពីការបង្កើតមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ ក្រុង ខណ្ឌ។

-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ១២៣ ប្រ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ ស្តីពី ការបង្កើត និងបំបែកភូមិ នៃខេត្តកំពង់ចាម។

ប្រកាស អាចមានទម្រង់ជាប្រកាសអន្តរក្រសួង ដែលមានចុះហត្ថលេខាដោយរដ្ឋមន្ត្រីច្រើនក្រសួងសម្រាប់ដាក់បញ្ញាដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រសួងហត្ថលេខី។

**ឧទាហរណ៍៖**

-ប្រកាសអន្តរក្រសួង លេខ ៤៥៧ សហវ.ប្រក.ចមព ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ ស្តីពី កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា។

[4] សាយ បូរី៖ នីតិរដ្ឋបាលទូទៅ ដ.ឯ.ម.

-ប្រកាសអន្តរក្រសួង លេខ ១៤១២ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៩ ស្តីពីការផ្តល់សេវាព័ត៌មានសុរិយោដី តាមប្រព័ន្ធអេឡិចត្រូនិក។

-ប្រកាសអន្តរក្រសួង លេខ ២៥២/២៣ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការអនុវត្តកម្មវិធី ផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់សមាជិកប.ស.ស.ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ។

**ខ-ប្រកាសឯកត្តភូតៈ** សម្រាប់តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចរបស់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ន អង្គភាពនីមួយៗរបស់រដ្ឋ ឬសម្រាប់អនុញ្ញាត ដកអាជ្ញាប័ណ្ណ និងតែងតាំងគណៈកម្មការផ្សេងៗ ជាដើម។

រដ្ឋមន្ត្រី(ប្រធានស្ថាប័ន) មានសិទ្ធិចេញប្រកាសតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ ដូចជា អនុប្រធាននាយដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យ (ថ្នាក់កណ្តាល) ព្រឹទ្ធបុរសរង អភិបាលរងក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីររាជធានី ខេត្ត នាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្មៀនឃុំ សង្កាត់ និងមុខតំណែងផ្សេងៗទៀតដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

**ឧទាហរណ៍ៈ**

-ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ៣០៧ អយក.ប្រក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងលោក **ខាត់ សារ៉ាល់** ជាប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី នៃក្រសួងអប់រំ យុវជន និងកីឡា ។

-ប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៩៦ ប្រក.បល. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៨ ស្តីពី ការតែងតាំងមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន **៦៩**រូប ជាអនុប្រធាននាយកដ្ឋាន។

-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៤៦៦២ ប្រ.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ស្តីពី ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន **១០**រូប ជា នាយករដ្ឋបាល នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនានា នៃរាជធានីភ្នំពេញ។

-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៥៤៤៤ ប្រ.ក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ស្តីពី ការតែងតាំងមន្ត្រីរាជការចំនួន **២០**រូប ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលក្រុង ស្រុក នៅក្នុងខេត្តតាកែវ។

ឋានន្តរស័ក្តិ ថ្នាក់ វរសេនីយ៍ទោ (ស័ក្តិ ៤កន្ទុះ)ចុះ អនុមន្ត្រី និងឋានន្តរស័ក្តិទី៣ នៃក្របខណ្ឌប្រភេទ **ក**(ក៣) ក្របខណ្ឌប្រភេទ **ខ** និងក្របខណ្ឌប្រភេទ **គ** ក៏ត្រូវដំឡើងដោយប្រកាសផងដែរ។

**ឧទាហរណ៍ៈ**

-ប្រកាសរបស់ក្រសួងមុខងារសាធារណៈ លេខ ១៦៦១/២២ មស.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ស្តីពី ការដំឡើងឋានន្តរ

*ស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការចំនួន**១៩**នាក់ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌលេខាធិការរដ្ឋបាល នៅក្រសួងទេសចរណ៍។*

*-ប្រកាសរបស់ក្រសួងមុខងារសាធារណៈ លេខ ១៣០៩/២៣ មស.ប្រក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ស្តីពី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ២០២៣ ជូនមន្ត្រីរាជការចំនួន **២៣៩**នាក់ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌលេខាធិការរដ្ឋបាល របស់ទីស្តីការគណៈរដ្ឋមន្ត្រី។*

*-ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ១០១០ អយក.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពី ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនបុគ្គលិកអប់រំចំនួន **១៩៤៨០** នាក់ នៃក្រសួងអប់រំ យុវជន និងកីឡា ។*

### ២.៤-សេចក្តីសម្រេច

*សេចក្តីសម្រេច មានពីរ គឺសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី និងសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន។*

***ក-សេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រី៖*** *រាជរដ្ឋាភិបាលអាចចេញសេចក្តីសម្រេចដែលមានលក្ខណៈជាបទបញ្ញាឬឯកត្តភូតដោយយកទម្រង់សាមញ្ញជា "**សេចក្តីសម្រេច**"។ "សេចក្តីសម្រេច" ជាធម្មតាច្រើននៅក្រោមអនុក្រឹត្យដើម្បីអនុវត្តក្នុងកិច្ចការរដ្ឋបាលលម្អិតបន្តទៅទៀត ហើយពុំអាចមានខ្លឹមសារផ្ទុយពីអនុក្រឹត្យបានឡើយ។*

***ឧទាហរណ៍៖***

*-សេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។*

*-សេចក្តីសម្រេចលេខ ៩៨ សសរ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងសមាសភាពអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។*

*-សេចក្តីសម្រេចលេខ ១៦១ សសរ ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារនិងការបញ្ចប់គោរមងារឧកញ៉ា។*

***ខ-សេចក្តីសម្រេចរបស់ប្រធានស្ថាប័ន*** *៖ ប្រធានស្ថាប័ន ដែលជារដ្ឋមន្ត្រីនៃក្រសួងស្ថាប័ននីមួយៗ ច្រើនធ្វើសេចក្តីសម្រេចតាមទម្រង់ជា "**ប្រកាស**" ប៉ុន្តែក៏អាចចេញបទបញ្ញាដែលមានទម្រង់ ជា "**សេចក្តីសម្រេច**" បានដែរ ហើយមិនអាចមានខ្លឹមសារផ្ទុយ ឬខុសនឹងខ្លឹមសាររបស់លិខិតបទដ្ឋានថ្នាក់លើ ដូចជាសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល អនុក្រឹត្យ ព្រះរាជក្រឹត្យ ព្រះរាជក្រមបានឡើយ។*

***ឧទាហរណ៍៖***

*-សេចក្តីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការ*

កំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី។

-សេចក្ដីសម្រេចលេខ ៤៦៨៦ សសរ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពី ការផ្អាកសកម្មភាព ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបផលិតផលក្លែងក្លាយ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

-សេចក្ដីសម្រេចលេខ ០២០៥ ផក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពី ការបង្កើតក្រុមការងារព័ត៌មាននិងបណ្ដាញទំនាក់ទំនងសង្គមរបស់ក្រសួងផែនការ។

## ២.៥-សារាចរ/សារាចរណែនាំ

សារាចរ គឺជាអត្តបទសម្រាប់បំភ្លឺកិច្ចការ និងធ្វើការណែនាំ។ សារាចរ មានគោលដៅបំភ្លឺចំណុចខ្វះនៃអត្តបទច្បាប់ ឬបទបញ្ញា ដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដែលរាជរដ្ឋាភិបាល ឬប្រធាន ស្ថាប័នចង់ឱ្យមានការយល់ច្បាស់ និងឱ្យមានការអនុវត្តដូចៗគ្នាដោយភ្នាក់ងារសាធារណៈដែលស្ថិតនៅក្រោមបង្គាប់របស់រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន។ សារាចររបស់រាជរដ្ឋាភិបាល មានឋានៈខ្ពស់ជាងសារាចររបស់ស្ថាប័ន ហើយសារាចររបស់ស្ថាប័នត្រូវតែស្របជានិច្ចជាមួយនឹងសារាចររបស់រាជរដ្ឋាភិបាល។

**ឧទាហរណ៍៖**

-សារាចររបស់រាជរដ្ឋាភិបាលលេខ៥៨ សរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ស្ដីពី ការទប់ស្កាត់ការរាំយកម្ទេចនិងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ។

-សារាចររបស់ក្រសួងទេសចរណ៍ លេខ ០០៤ សរច ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ស្ដីពី ការប្រើប្រាស់ប្រព័ន្ធបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍។

-សារាចរណែនាំរបស់ក្រសួងធម្មការ និង សាសនា លេខ ១៩/២៣ ក.ធ.ស. សរណន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពី ការអនុវត្តគោលការណ៍ប្រណិប័តន៍លើជំនឿ សាសនា និងប្រពៃណីទំនៀមទម្លាប់ខ្មែរ។

## ២.៦-ដីកា

ដីកា គឺជាសេចក្ដីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ដីកា របស់ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវនៅក្រោមប្រកាស និងលិខិតបទដ្ឋានថ្នាក់លើនានាដូចជា អនុក្រឹត្យ ព្រះរាជក្រឹត្យ ជាដើម។

**ឧទាហរណ៍៖**

-ដីការបស់សាលាខេត្តកណ្ដាល លេខ ០៤៤ ដ.ក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៦ ស្ដីពីការកែសម្រួល សមាសភាពគណៈបញ្ជាការឯកភាពខេត្តកណ្ដាល។

-ដីការបស់រដ្ឋបាលខេត្តតាកែវ លេខ ០៦៤/២៣ ដក.តត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំងលោក **នុត ម៉ូរ៉ា** អត្តលេខ ១៨២២១០០៣៧៥ ឋានន្តរស័ក្តិ

គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ២៥ ឱ្យកាន់មុខតំណែងជា អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ។

-ដីការបស់រដ្ឋបាលខណ្ឌច្បារអំពៅ លេខ ០០៣/២៣ ដក.ចអព.អណា៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី ការលើកលែងការបង់តម្លៃសេវាលើការបញ្ជាក់វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ និងវិញ្ញាបនបត្របញ្ជាក់កាសិក្សាថ្នាក់ទី១២ សម្រាប់ឆ្នាំ២០២៣ ។

យើងសង្កេតឃើញថា លិខិតបទដ្ឋានគតិយុត្តខាងលើនេះ នៅត្រង់មាត្រា ប្រការ ឬវាក្យខណ្ឌ ចុងក្រោយគេតែងដាក់ថា "អនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា ឬចុះហត្ថលេខាតទៅ"៕

# ឯកសារពិគ្រោះ


១-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

២-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្ដីពី គោរមងារឧកញ៉ា

៣-លិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០០១

៤-សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២

៥-ហួត វុទ្ធី៖ ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៧-២០០៧

៦-ហែម ឡាច៖ ស្ថាប័ននយោបាលកម្ពុជាបច្ចុប្បន្ន ឆ្នាំ២០២៣

៧-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* ឆ្នាំ១៩៩៣

# តម្លៃមនុស្ស
## ក្នុងទស្សនៈរបស់សាសនវិទូ ទស្សនវិទូ និងអ្នកវិទ្យាសាស្ត្រ

*ដោយៈ* **បណ្ឌិត ប៉ាន់ ឌុត្ថា**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

### ១. សេចក្ដីផ្ដើម

*តម្លៃ មានន័យថា ជាគុណភាព ជាគុណសម្បត្តិ ជាអត្ថប្រយោជន៍ប្រើប្រាស់ ជាថ្លៃក្នុងការដោះដូរ ...។ តម្លៃមាននៅក្នុងគ្រប់អ្វីៗទាំងអស់ ៖ មនុស្ស សត្វ រុក្ខជាតិ វត្ថុអវិញ្ញាណកៈ កាល លំហ មុខវិជ្ជាសិក្សានានា គំនិត ទ្រឹស្ដី បាតុភូតធម្មជាតិ ព្រឹត្តិការណ៍សង្គម ... សុទ្ធតែមានតម្លៃនៅក្នុងនោះ។ តម្លៃមានច្រើនប្រភេទ ៖ តម្លៃប្រើប្រាស់(តម្លៃមានស្រាប់ពីធម្មជាតិ និងតម្លៃដែលកើតមានក្រោយការកែច្នៃ) តម្លៃដោះដូរ តម្លៃលើស តម្លៃបន្ថែម តម្លៃឱកាស កុសលតម្លៃ ...។ នៅពេលដែលប្រធានវិស័យភាពមានអំណាចពុទ្ធិទៅលើវត្ថុវិស័យភាពមួយ នោះអំណាចពុទ្ធិរបស់គេនឹងមានសមត្ថភាពរំលេចចេញនូវតម្លៃពីក្នុងវត្ថុវិស័យភាពក្នុង កាល និង លំហ ណាមួយ។*

*ខណៈដែលគេយល់ដឹងអំពីតម្លៃនៅក្នុងវត្ថុវិស័យភាព គេនឹងប្រើប្រាស់វាអស់សក្ដានុពល និងចំណេញជាអតិបរមា។ ហេតុនេះ ការសិក្សាស្វែងយល់អំពី តម្លៃ គឺមានសារសំខាន់។ តែក្នុងការសិក្សាពិចារណាពីតម្លៃនេះ ក៏មានការយល់ឃើញខុសៗគ្នាដែរ គឺ ៖*

***ក- ទ្រឹស្ដីអត្តនោម័តិ*** *អះអាងថាៈ តម្លៃ គឺអាស្រ័យលើមនុស្សជាអ្នកកំណត់។ មនុស្សជារង្វាស់នៃអ្វីៗទាំងអស់។ ផ្អែកលើទ្រឹស្ដីនេះ តម្លៃមិនមានលក្ខណៈជាសាកលទេ ព្រោះអ្វីមួយមានតម្លៃដោយសារយើងស្រលាញ់ យើងត្រូវការ យើងចង់បានវា ហើយអ្វីមួយគ្មានតម្លៃដោយសារយើងស្អប់ យើងមិនត្រូវការ យើងមិនចង់បានវា។ វាប្រែប្រួលទៅតាម វេទនារម្មណ៍ ការគិត ជំនឿ ... របស់ប្រធានវិស័យភាព។*

***ខ- ទ្រឹស្ដីបរានុម័តិ*** *អះអាងថា ៖ តម្លៃ គឺជាខ្លឹម ជាអត្ថប្រយោជន៍ប្រើប្រាស់ ជាគុណសម្បត្តិ ... កប់នៅក្នុងវត្ថុ និងបាតុភូត មានលក្ខណៈសាកល មិនចំណុះទៅនឹងការគិតរបស់នរណាម្នាក់ទេ។ គុណភាព ខ្លឹម គុណសម្បត្តិ សារប្រយោជន៍*

ស្តែងឡើងពីក្នុងវត្ថុ និងបាតុភូត ទើបបណ្តាលចិត្តគំនិតរបស់ប្រធានវិស័យភាពឱ្យមានចំណង់ស្រលាញ់ ចង់បាន ត្រូវការវត្ថុ និងបាតុភូតនោះ។

*គ- ទ្រឹស្តីទំនាក់ទំនងនិយម* អះអាងថា៖ តម្លៃកើតចេញពីប្រសព្វនៃអន្តរទំនាក់ទំនងនៃធាតុសំខាន់៤គឺ៖ ប្រធានវិស័យភាព+វត្ថុវិស័យភាព+បទដ្ឋានតម្លៃ+បរិបទកាលនិងលំហ។

## ២. ការពិចារណាអំពីតម្លៃមនុស្ស

ការពិចារណាអំពីមនុស្ស យើងរកឃើញថា មនុស្ស ជាភាវៈមានជីវិតដែលផ្គុំដោយធាតុ២ខុសគ្នាគឺ ៖ រាងកាយ+ព្រលឹង (ថាមពលជីវិត+ចិត្ត/គំនិត) ដែលប្រៀបដូចជា Hard-ware និង Soft-ware របស់ Computer។ ផ្តើមចេញពីនិយមន័យនេះធ្វើឱ្យ សាសនវិទូ ទស្សនវិទូ និង អ្នកវិទ្យាសាស្ត្រ គិតពិចារណាពីតម្លៃមនុស្សក្នុងន័យផ្សេងៗគ្នា ដោយផ្អែកលើទ្រឹស្តីអត្តនោម័តិ ឬ ទ្រឹស្តីបរានុម័តិ ឬ ទ្រឹស្តីទំនាក់ទំនងនិយម ហើយបុគ្គលឬក្រុមខ្លះអោយតម្លៃលើរាងកាយ បុគ្គលឬក្រុមខ្លះអោយតម្លៃលើព្រលឹងឬចិត្តគំនិត បុគ្គលឬក្រុមខ្លះអោយតម្លៃទាំងរាងកាយ ទាំងព្រលឹងឬចិត្តគំនិត។




**២.១. សាសនវិទូ** (ព្រហ្មញ្ញសាសនា គ្រិស្តសាសនា ឥស្លាមសាសនា) អះអាងថា មនុស្សត្រូវបានបង្កើតឡើងដោយព្រះអាទិទេព។ ព្រលឹង របស់មនុស្សម្នាក់ៗ ជាបំណែកតូចល្អិតនៃបំណែកភាគព្រលឹងសាកល ហើយត្រូវបានព្រះបញ្ជូនមកចាប់កំណើតក្នុងរាងកាយ (ជាជម្រករបស់ព្រលឹង) របស់មនុស្សម្នាក់ៗ។ ការតាំងនៅក្នុងរាងកាយមួយរយៈ រាងកាយនោះក៏ចាស់ សិករិចរិល ខូច ស្អុយរលួយ ព្រលឹងក៏ចាកចេញពីរាងកាយនោះ ហើយអាចវិលទៅជួប ព្រលឹងសាកល ឬវិលវល់ក្នុងសង្សារវដ្ត អាស្រ័យទៅតាមកម្មដែលរាងកាយបានប្រព្រឹត្តក្នុងជីវិត។ គោលជំហររបស់សាសនវិទូ (ទស្សនៈពួកមនោនិយម) ជឿជាក់ថា ព្រលឹងនៅរស់អមតៈ អាចចេញចូលពីរាងកាយមួយទៅរាងកាយមួយ អាចទៅតាំងនៅកន្លែងសុគតិភព អាចទៅតាំងនៅកន្លែងអសុគតិភព អាចនៅវិលវល់មិនមានភពច្បាស់លាស់ ទើបគេជឿថា មានខ្មោចលង

ខ្មោចចូល មានការចាប់ជាតិ មានការចាំជាតិ ជឿបុណ្យ ជឿបាប និងមានការយល់ច្រលំថា អំឡុងពេលគេកំពុងរស់នៅ គឺជីវិតមិនសូវមាន ន័យទេ គេខិតខំធ្វើបុណ្យ ធ្វើទុក្ករកិរិយា ដើម្បី ឱ្យព្រលឹងរបស់គេទៅកាន់ឋានសួគ៌ ឬទទួល បានអត្ថន័យពេញលេញ ឬព្រលឹងមានជីវិត ឧត្តុង្គឧត្តមក្រោយពេលគេស្លាប់ទៅ។ ជាក់ស្តែងៈ ហិណ្ឌូសាសនិក ធ្វើទុក្ករកិរិយា ដោយការអត់ អាហារ ដេកហាលថ្ងៃ ដេកលើអំបែង ដេកលើ ដែកគោល រមៀលខ្លួន ដុតខ្លួន ... ដើម្បីបន្សុទ្ធ ព្រលឹង ដោយគេសង្ឃឹមថា ក្រោយពេលគេ ស្លាប់ទៅ ព្រលឹងរបស់គេបានទៅនៅឋានសួគ៌។ ឥស្លាមសាសនិក បានប្រកាន់នូវបទបញ្ញត្តិទាំង ៥(១-ប្រកាសប្រាប់ដំណឹងអំពីព្រះនិងនគរព្រះ តៗគ្នា។ ២-ថ្វាយបង្គំព្រះ១ថ្ងៃ៥ដង និងទៅព្រះ វិហាររាល់ថ្ងៃសុក្រ។ ៣-កាន់តំណមរ៉ាម៉ាដង់។ ៤-បង់ហ្សាកាតនិងសាដាកា។ ៥-ចូលរួមបុណ្យ ហាជី។) យ៉ាងតឹងរឹង ដើម្បីបន្សុទ្ធព្រលឹង និង ចង់ឱ្យព្រលឹងរបស់គេបានទៅនៅឋានសួគ៌ ជាមួយព្រះអាឡាហ៍ ជៀសផុតពីការទទួលរង កម្មវេទនានៅឋាននរក ក្រោយពេលគេស្លាប់ទៅ។ លើសពីនេះទៅទៀត បុគ្គលខ្លះធ្វើទុក្ករកិរិយា ដោយឱបគ្រាប់បែកទៅធ្វើអត្តឃាតក្នុងហ្វូង សត្រូវ ដោយគេមានជំនឿថា ការស្លាប់ក្នុងបុព្វ ហេតុការពារសាសនា ការពារព្រះ (ជីហាត) នោះព្រលឹងរបស់គេត្រូវបានព្រះបញ្ជូនទៅកាន់ ឋានសួគ៌ដោយមិនចាំបាច់មានការជំនុំជំរះ។

តម្លៃនៃភាពជាមនុស្ស គឺអាស្រ័យលើ ព្រលឹងល្អ បរិសុទ្ធ មិនមានបាប។ ដើម្បីឱ្យ ព្រលឹងល្អ បរិសុទ្ធ មិនមានបាប តាមសាសនា ហិណ្ឌូ គឺមនុស្សត្រូវប្រកាន់នូវយោគៈ៤យ៉ាង បានហ្មត់ចត់គឺ ៖ បញ្ញាយោគៈ ករុណាឬភក្តី យោគៈ កម៌យោគៈ និងសមាធិ។ តាមឥស្លាម សាសនា មនុស្សមានតម្លៃ គឺមនុស្សដែលប្រកាន់ បានខ្ជាប់ខ្ជួន និងមានភក្តីភាពជំនឿលើបញ្ញត្តិ ៥ខ+១ខ។ តាមគ្រិស្តសាសនា មនុស្សមានតម្លៃ គឺមនុស្សមានភក្តីភាពលើព្រះជាម្ចាស់និង ដឹកនាំជីវិតតាមព្រះបន្ទូល។ តាមពុទ្ធសាសនា មនុស្សមានតម្លៃ គឺមនុស្សដែលប្រកាន់បានខ្ជាប់ នូវ សីល សមាធិ បញ្ញា។

***ដូចនេះយើងឃើញថា សាសនវិទូ ឱ្យតម្លៃ លើព្រលឹង។ ខ្លឹមនៃភាពជាមនុស្សគឺព្រលឹង។***

**២.២. អ្នកវិទ្យាសាស្ត្រ** (ជីវវិទូ រូបវិទូ គីមីវិទូ កាយវិភាគវិទូ...) អះអាងថា មនុស្សកើតចេញពី បន្សំសារធាតុគីមី ៖ O2, H2, Fe, Mg, Zn, K, Na, ...(ទឹក ដី ភ្លើង ខ្យល់)។ មនុស្សកើតឡើងពីបន្សំ ចុណ្ណភាគដែលជា រូបធាតុ ផ្គុំគ្នាទៅជា ទម្រង់ មនុស្សរូបវន្ត។ ក្រៅពី រូបធាតុ គេសិក្សា ស្រាវជ្រាវទៅ មិនឃើញមានធាតុព្រលឹងទេ។ កាយវិភាគវិទូ រូបវិទូ គីមីវិទូ ជីវវិទូ ចិត្តវិទូដែល

ផ្អែកការសិក្សាស្រាវជ្រាវលើមូលដ្ឋានសរីរៈ បានអះអាងថាៈ បាតុភូតមានសិកនានាដែលលេចឡើង កើតចេញពីអន្តរកម្មនៃចុណ្ណភាគនៅក្នុងប្រព័ន្ធសរីរាង្គ។ អារីស្តូត ពន្យល់ថា បាតុភូតមានសិក កើតឡើងដោយសារចុណ្ណភាគធ្វើចលនា ហើយវាខុសគន្លង មិនចូលទៅក្នុងលំដាប់ធម្មជាតិរបស់វាវិញ។ អ៊ីប៉ូក្រាត ពន្យល់ថា បាតុភូតមានសិក កើតឡើងដោយសារបំរែបំរួលសន្ទនីយវត្ថុនៅក្នុងប្រព័ន្ធសរីរាង្គ។ ហ្គាលេន ពន្យល់ថា បាតុភូតមានសិក គ្រប់គ្រងដោយអន្តរទំនាក់ទំនងដែលមានតុល្យភាពមួយក្នុងចំណោមសន្ទនីយវត្ថុផ្សេងៗគ្នានៃរាងកាយ ៖ មនុស្សមានសុទិដ្ឋិនិយម បណ្តាលមកពីមានឈាមច្រើនជាងធម្មតា។ មនុស្សដែលមិនចេះរំភើបចិត្តដោយងាយ បណ្តាលមកពីមានស្លេះច្រើនពេក។ មនុស្សដែលឆាប់ខឹង បណ្តាលមកពីមានទឹកប្រម៉ាត់ពណ៌លឿងខ្លាំងពេក។ មនុស្សដែលមានអារម្មណ៍អន្ទង់អន្ទោចឬស្រងេះស្រងោចច្រើន បណ្តាលមកពីមានទឹកប្រមាត់ពណ៌ខ្មៅខ្លាំងពេក។ ដូចនេះ យើងជួបនូវគំនិតក្រិកបុរាណស្តីពី ៖ តុល្យភាព ភាពចុះសម្រុង និងការកំណត់ទីតាំងច្បាស់លាស់នៃចុណ្ណភាគរូបធាតុនៅក្នុងខ្លួនមនុស្ស។ ធម្មជាតិនៃវេទនារម្មណ៍ ចិត្ត-គំនិត ការគិត ការយល់សប្តិ ... គឺជាផលិតផលដែលកើតចេញពីដំណើរអន្តរកម្មនៃសារធាតុ រូបធាតុនៅក្នុងរចនាសម្ព័ន្ធរូប-គីមី ដែលកើតឡើងឯកឯងជាធម្មជាតិ។

កាយវិភាគវិទូ គីមីវិទូ រូបវិទូ ជីវវិទូ ... ធ្វើពិសោធន៍រកសារធាតុ និងសារជាតិរបស់ព្រលឹង (មនោធាតុ) ដោយស្នើសុំយកអ្នកទោសត្រូវប្រហារជីវិតមកពិសោធន៍។ គេដាក់អ្នកទោសត្រូវប្រហារជីវិតទៅក្នុងប្រអប់កញ្ចក់មួយយ៉ាងមាំ និងបិទយ៉ាងជិត ដើម្បីខ្ទប់ចាប់យកព្រលឹងរបស់មនុស្ស ដែលអ្នកកាន់សាសនាអះអាងថា ព្រលឹងជាសារធាតុមួយមិនស្លាប់ (រស់អមតៈ) នឹងចាកចេញពីរាងកាយនៅពេលរាងកាយស្លាប់។ អ្នកពិសោធន៍ដាក់ឧបករណ៍រង់ចាំថតឧបករណ៍សម្រាប់ពង្រីកមើល និងខំបើកភ្នែករង់ចាំមើលដោយផ្ចង់អារម្មណ៍ និងយកចិត្តទុកដាក់បំផុត តែជាការឥតប្រយោជន៍សោះ ព្រោះនៅពេលអ្នកទោសដាច់ខ្យល់ស្លាប់ដោយថប់ដង្ហើមទៅ គេមិនឃើញមានអ្វីដែលអាចសំគាល់ថាជា ព្រលឹងបាន ក្រៅតែពីសាកសពឡើយ គេក៏នាំគ្នាសន្និដ្ឋានថាគ្មានព្រលឹងទេ បើមានក៏ស្លាប់ជាមួយនិងរាងកាយនោះតែម្តង។ ចេញពីមូលដ្ឋានពិសោធន៍នេះ យើងឃើញថា គោលជំហររបស់អ្នកវិទ្យាសាស្ត្រ (ទស្សនៈពួករូបធាតុនិយម) មិនជឿថា មានអត្ថិភាពនៃព្រលឹងទេ។ ផ្នត់គំនិតនេះធ្វើឱ្យគេជឿថា ក្រោយពេលមនុស្សស្លាប់ទៅ គឺគ្មាននៅសល់អ្វីទៀតទេ។ គេជឿថា គ្មានព្រលឹងខ្មោចនៅលង

*មនុស្សរស់ គ្មានព្រលឹងខ្មោចដែលរសាត់អណ្ដែតនៅក្នុងលំហហើយអាចចូលទៅសណ្ឋិតក្នុងរាងកាយមនុស្សស្នង គ្មានការចាប់ជាតិ គ្មានការចាំជាតិ គ្មានបាប គ្មានបុណ្យ គ្មានឋានសួគ៌ គ្មានឋាននរក គ្មានព្រះអាទិទេពទេ។ អ្នកប្រកាន់តាមទស្សនៈនេះ មិនខ្វាយខ្វល់យកចិត្តទុកដាក់ទៅលើអ្វីដែលកើតមានចំពោះខ្លួនគេក្រោយពេលគេស្លាប់ទៅទេ គឺគេគិតតែធ្វើអ្វីៗដើម្បីបំពេញតម្រូវការ បំពេញចំណង់ ខណៈពេលគេនៅរស់តែប៉ុណ្ណោះ ដោយមិនគិតពីបុណ្យ ពីបាប ពីនរក ពីសួគ៌ទេ។*

***ជាសារុបមកគឺ អ្នកវិទ្យាសាស្ត្រ ឱ្យតម្លៃលើរាងកាយ។ មនុស្សមានតម្លៃ គឺមនុស្សមានការសម្បទាគ្រប់លក្ខណៈ ប្រព័ន្ធសរីរាង្គទាំងអស់ដំណើរការល្អ(មិនមានជំងឺ) សមត្ថភាព អវៈយវៈមានទេពកោសល្យ និងរាងកាយមានសោភ័ណ។***

**២.៣. ទស្សនវិទូ** *យល់ថា មនុស្សជាសត្វមានវិចារណញាណ ជាសត្វមានសីលញាណ ជាសត្វចេះធ្វើនយោបាយ និងជាសត្វចេះរស់នៅជាសង្គម។ មានទ្រឹស្ដីទស្សនវិជ្ជាផ្សេងៗឱ្យតម្លៃនៃភាពជាមនុស្ស ៖*

***ក. ទ្រឹស្ដីវិចារណញាណនិយម*** *បានអះអាងថា៖ មនុស្សមានតម្លៃ គឺមនុស្សប្រកបដោយវិចារណញ្ញាណ។ តាមរយៈវិចារណញ្ញាណ មនុស្សចេះគិតរិះគន់ និងចេះគិតប្រឌិតញាណ ដែលការគិតទាំង២បែបនេះធ្វើឱ្យគេមានគតិបណ្ឌិត ហើយគេធ្វើសកម្មភាពឃ្លាតចេញពីទំលាប់ និងសភាវគតិ ហើយមានកំណែទម្រង់និងអភិវឌ្ឍការរស់នៅជាប្រចាំ។ ការគិតរិះគន់ជាមូលដ្ឋានសម្រាប់មនុស្សធ្វើអ្វីៗមានភាពប្រាកដប្រជា ជឿជាក់លើទង្វើរបស់ខ្លួន និងមានទំនួលខុសត្រូវលើទង្វើរបស់ខ្លួន។ ការគិតប្រឌិតញាណធ្វើឱ្យមនុស្សមានគំនិតច្នៃបង្កើតឧបករណ៍ និងសំភារៈប្រើប្រាស់ថ្មីៗ។ វិចារណញ្ញាណនាំមនុស្សឱ្យចេះចងក្រងប្រវត្តិសាស្ត្រ ទំនៀមទំលាប់ ប្រពៃណីសាសនា ច្បាប់ របៀបគ្រប់គ្រង ចេះធ្វើនយោបាយ និងរស់នៅជាសង្គម។ វិចារណញ្ញាណនាំមនុស្សឱ្យយល់ដឹងពីសោភ័ណ មានសមត្ថភាពបង្កើតសោភ័ណ ហើយរីករាយនឹងសោភ័ណ។ វិចារណញ្ញាណ ណែនាំមនុស្សឱ្យដឹងពីអ្វីដែលត្រូវ និងអ្វីដែលខុស។ វិចារណញ្ញាណ ញែកមនុស្សជាភាវៈមានសតិសម្បជញ្ញៈ មានមនសិការ មានទំនួលខុសត្រូវលើទង្វើរបស់ខ្លួន ជាភាវៈមានសីលធម៌ ដែលខុសពីសត្វ។ វិចារណញ្ញាណបើកគំនិតមនុស្សយល់ដឹងអំពីតម្លៃ និងទាញយកតម្លៃមកបំពេញគោលបំណង និងអត្ថន័យនៃជីវិត។*

***ខ. ទ្រឹស្ដីមនោនិយម*** *អះអាងថា ៖ មនុស្សមានតម្លៃ គឺមនុស្សប្រកបដោយពុទ្ធិ បញ្ញា ប្រាជ្ញា វិចារញ្ញាណ មានសុក្រិតភាពនូវធម្មជាតិនៃ*

អំណាច មានឧត្តមគតិ មានគុណធម៌ និងមានកក្តីភាពជំនឿ។

**គ.ទ្រឹស្តីអត្តសមិទ្ធផល** និង **ទ្រឹស្តីផលប្រយោជន៍និយម** អះអាងថា៖ មនុស្សមានតម្លៃ គឺមនុស្សដែលគិត និងធ្វើអ្វីសុទ្ធតែនាំមកនូវប្រយោជន៍។

**ឃ.ទ្រឹស្តីសីលវិជ្ជា** អះអាងថា៖ មនុស្សមានតម្លៃ មនុស្សមានគុណធម៌ គឺមនុស្សមានសីលធម៌ក្នុងខ្លួន។ សីលធម៌ ជាប្រភពនៃអ្វីៗទាំងអស់៖ ជាប្រភពនៃវិន័យ ជាប្រភពនៃជោគជ័យក្នុងការងារ និងជាប្រភពនៃការលើកតម្កើងសេចក្តីថ្លៃថ្នូរ។

**ង.ទ្រឹស្តីអត្ថិភាពនិយម** អះអាងថា ៖ ពីកំណើតមកបុគ្គលម្នាក់ៗគ្មានសារជាតិ គ្មានអត្តសញ្ញាណផ្ទាល់ខ្លួនទេ គឺគេមិនទាន់មានអត្ថិភាពទេ អត្ថិភាពនឹងកើតមាននៅពេលគេបង្កើតសារជាតិ បង្កើតអត្តសញ្ញាណដោយខ្លួនឯង និងដោយជំរើសរបស់ខ្លួន។

Soren Kierkegaard បង្ហាញថា មានដំណាក់នៃវិធីរស់នៅបីដំណាក់គឺ៖ ដំណាក់ទី១ គឺដំណាក់សោភ័ណវិជ្ជា (Aesthetic stage) ជាតំណាក់ដែលមនុស្សប្រព្រឹត្តការយល់ដឹងតិចតួចឬមិនស្គាល់ស្តង់ដាសីលធម៌សកល។ គេធ្វើការប្តេជ្ញាចិត្តណាមួយដោយចចេស និងបដិសេធអ្វីដែលចង់រឹតឬកំរិតការគិតគូ និងអំពើរបស់ខ្លួន។ ដំណាក់ទី២ គឺដំណាក់សីលធម៌ (Ethical stage) ជាតំណាក់ដែលមនុស្សមិនត្រឹមតែទទួលស្គាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់ខ្លួនឱ្យនៅក្រោមច្បាប់សីលធម៌សកល និងឈានទៅយល់ដឹង។

ដំណាក់ទី៣ គឺតំណាក់សាសនា ជាតំណាក់ដែលមនុស្សឈានទៅយល់ដឹង មានជំនឿនិងយល់ថា ខ្លួនជាភាវៈមានព្រំដែន(finite being) ត្រូវឈរនៅផ្នែកម្ខាងទៀតនៃភាវៈគ្មានព្រំដែន(Infinite Being) គឺអាទិទេព ដែលជា អ្នកបង្កើតខ្លួន។ ហ្វ្រេឌ្រិចនីតឆេ (Friedrech Nietzshe) ធ្វើការវិភាគលើលក្ខខ័ណ្ឌទូទៅ ដែលបន្ថយកិត្តិយសរបស់មនុស្ស។ គាត់បានមើលឃើញពីការធ្លាក់ចុះ និងភាពទន់ខ្សោយរបស់មនុស្សដែលត្រូវកែប្រែ ដើម្បីបង្កើតនូវពូជសាសន៍ខ្ពង់ខ្ពស់មួយ។ គាត់ក៏បានប្រឆាំងនឹងការអប់រំសីលធម៌បុរាណដែលធ្វើឱ្យពូជសាសន៍មនុស្សអន់ថយ។

Nietzsche ជឿជាក់ថា ហេតុផលជំរុញជាមូលដ្ឋាន និងខ្លាំងក្លាបំផុតចំពោះមនុស្ស មិនមែនសេចក្តីស្នេហាដូចពួកគ្រីស្តសាសនាបានបង្រៀននោះទេ ប៉ុន្តែជាឆន្ទៈដើម្បីអំណាច។ ឆន្ទៈដើម្បីអំណាចពន្យល់នូវការតស៊ូរបស់មនុស្សដើម្បីអត្ថិភាព។ ប្រសិនបើគ្មានឆន្ទៈតស៊ូដើម្បីអត្ថិភាព គឺគ្មានន័យទេ។ ចលកររបស់មនុស្សគឺឆន្ទៈដើម្បីអំណាច ទីបំផុតបានបង្កើតនូវមនុស្សថ្មី ដែលមានសីលធម៌ផ្ទាល់ខ្លួន។ សីលធម៌របស់មនុស្សថ្មី គឺធ្វើជាម្ចាស់លើ

ជីវភាពផ្ទាល់ខ្លួន ធ្វើជាម្ចាស់លើចំណង់ មានសេរីភាព មានមេត្តា មិនគិតតែប្រយោជន៍សួនតួ(អត្តទត្ថ) មិនថ្នើងថ្នៃ មិនប្រឆាំងសង្គ្រាម។

ហ្សង់ប៉ូលសាត្រ (Jean Paul Sartre) គាត់ជឿជាក់ថា ពេលមនុស្សកើតឡើងក្នុងលោក មនុស្សគ្មានខ្លឹមឬសារជាតិ (Essence) គ្មានន័យ គ្មានតម្លៃជាក់ស្ដែងទេ។ ជាអាទិមនុស្សគ្មានអត្ថិភាព ដូច្នេះហើយ គេមិនអាចកំណត់ន័យបាន។ មនុស្សនឹងមានអត្ថិភាព មានន័យ មានតម្លៃលុះត្រាតែ គេធ្វើអ្វីៗឱ្យសមស្របនឹងខ្លួនគេ។ មនុស្សមិនគ្រាន់តែមានសេរីភាពជ្រើសរើសប្រភេទមនុស្សដែលគេចង់បានប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងជាលក្ខខណ្ឌដើម្បីអភិវឌ្ឍភាវៈរបស់ខ្លួនដែលចង់បានឱ្យកើតឡើងដែរ។ ចំពោះ Sartre ទំនួលខុសត្រូវមិនកំរិតត្រឹមតែទំនួលខុសត្រូវផ្ទាល់ខ្លួនប៉ុណ្ណោះទេ វាក៏មានន័យថា ទំនួលខុសត្រូវចំពោះការអភិវឌ្ឍន៍ និងការរីកចំរើនរបស់មនុស្សទាំងអស់ផងដែរ។ គោលដៅនៃការតស៊ូរបស់មនុស្ស គឺបង្កើនការយល់ដឹង និងការភ្ញាក់រលឹក ដែលអាចជាមនុស្សមានសេរីភាព មានទំនួលខុសត្រូវ។

## ៣. តម្លៃនៃជីវិតរបស់មនុស្ស

ការស្គាល់ពី តម្លៃនៃជីវិត វាពាក់ព័ន្ធនឹងបញ្ញត្តិ៣គឺ ជីវិត កាល និង លំហ។

**ជីវិត ៖** ជាព្រឹត្តិការណ៍រស់នៅ ជាលក្ខណៈពិសេសសារវន្តនៃភាវៈដែលមានសរីរាង្គ ដែលវិវត្តតាំងពីថ្ងៃកើតរហូតដល់មរណៈ ដោយត្រូវឱ្យភាវៈបំពេញមុខងារផ្សេងៗសម្រាប់ជីវិតនោះ។

**កាល ៖** ជាដំណើរពេលវេលាឥតទីបញ្ចប់ ដែលមានអត្ថិភាពក្នុងបំលាស់ប្តូរជាបន្តបន្ទាប់នៃវត្ថុនិងបាតុភូតនានាដែលហាក់ដូចជាឈានទៅមុខជានិច្ចឥតវិលត្រលប់វិញឡើយ។

**លំហ ៖** ជាមជ្ឈដ្ឋានដែលត្រូវកំណត់តិចឬច្រើនដោយមានវត្ថុអ្វីមួយស្ថិតនៅក្នុងនោះ។

បញ្ញត្តិ ជីវិត មិនអាចផ្ដាច់ចេញពី កាល និង លំហ បានទេ។ ការបើកទូលាយ លំហ នៃសកម្មភាពរបស់មនុស្ស គឺការពង្រីកកំរិតប្រវែងរបស់ កាល។ រីឯការរារាំង លំហ នៃសកម្មភាពរបស់មនុស្ស គឺការពន្រួញកំរិតប្រវែងរបស់កាល។ ឧទាហរណ៍៖ លោក ក មានអាយុ៧០ឆ្នាំ (កាល) លោករស់នៅក្នុងភូមិដាច់ស្រយាលមួយ ហើយពុំធ្លាប់ដើរចេញផុតពីភូមិនោះទេ(លំហ)។ ចំណែកឯលោក ខ វិញមានអាយុតែ២៥ឆ្នាំប៉ុណ្ណោះ (កាល)។ លោកបានធ្វើដំណើរទៅដល់ប្រទេសជាច្រើន (លំហ)។ លោក ក ឥតបានបើកទូលាយ លំហនៃសកម្មភាពរបស់ខ្លួនទេ។ ចំណែកឯលោក ខ បានបើកទូលាយ លំហ នៃសកម្មភាពរបស់ខ្លួន។ ហេតុនេះ ពុទ្ធិរបស់លោក ក មានកម្រិតតិចជាងកំរិតប្រវែងនៃជីវិតរបស់

ខ្លួនៗ ឯពុទ្ធិរបស់លោក ខ វិញមានកម្រិតច្រើនជាងកម្រិតប្រវែងនៃជីវិតរបស់ខ្លួនៗ ឆ្លងតាមឧទាហរណ៍នេះ យើងឃើញថា ការបើកទូលាយ លំហ គឺបើកទូលាយក្របខ័ណ្ឌនៃសកម្មភាព គឺការបើកទូលាយ ក្របខ័ណ្ឌនៃសកម្មភាពនេះហើយ ដែលបណ្តាលឱ្យពុទ្ធិរបស់មនុស្សកាន់តែរីកចំរើនទៅមុខៗ

នៅពេលដែលគេរស់នៅតាមរបៀបដដែលៗ ដែលពោរពេញទៅដោយសេចក្តីទុក្ខព្រួយ ឬនៅពេលដែលគេរង់ចាំអ្វីមួយដោយទន្ទឹង គេយល់ថា កាល ដើរយឺតខ្លាំងណាស់ៗ នៅពេលដែលគេរស់នៅប្រកបដោយសេចក្តីរីករាយ គេបែរជាយល់ថា កាល ដើរលឿនខ្លាំងទៅវិញៗ តាមពិត ដំណើររបស់ កាល តែងប្រព្រឹត្តទៅជាធម្មតា គឺអារម្មណ៍របស់មនុស្សទេដែលយល់ថា កាល ដើរយឺត ឬដើរលឿន នេះហើយជាកំហុសនៃស្មារតីរបស់មនុស្សៗ

ម៉្យាងទៀត នៅពេលគេកំពុងមានជីវិតរស់នៅ គេហាក់ដូចជាពុំសូវចាប់អារម្មណ៍អ្វីសោះចំពោះការបាត់បង់ពេលវេលា តែនៅពេលគេចាស់ជរាទៅ គេបែរជារំលឹកជាញឹកញាប់ថា ពេលវេលានៃអាយុរបស់គេមានកម្រិតខ្លីណាស់ៗ ហេតុនេះហើយ បានជាសីលវិទូជាច្រើនទូន្មានថា ត្រូវពិចារណាឱ្យបានល្អិតល្អន់អំពីតម្លៃនៃពេលវេលាឬពេលវេលាជាមាសប្រាក់ៗ ខ្ជិលច្រអូស មានន័យថា ខ្ជះខ្ជាយពេលវេលា បណ្តាលឱ្យពេលវេលាដើរកន្លងផុតទៅដោយឥតបានធ្វើសកម្មភាពល្អប្រសើរសម្រាប់ខ្លួនឯង សម្រាប់គ្រួសារ សម្រាប់ជាតិមាតុភូមិ គឺធ្វើឱ្យជីវិតធ្លាក់ទៅក្នុងសភាពឥតប្រយោជន៍ៗ ឧស្សាហ៍ព្យាយាម តស៊ូពុះពារ គ្រប់ឧបសគ្គបំពេញការងារមានប្រយោជន៍សម្រាប់ខ្លួនឯង សម្រាប់គ្រួសារ សម្រាប់ជាតិមាតុភូមិ គឺធ្វើឱ្យជីវិតមានប្រយោជន៍ ហើយមានអារម្មណ៍ស្ងប់ស្ងាត់មុនពេលស្លាប់ទៅៗ គួរចងចាំថា តម្លៃនៃជីវិតរបស់មនុស្ស ត្រូវបានកំណត់ច្បាស់ដោយសកម្មភាពរបស់គេ ៗ ជាធម្មតា មនុស្សតែងយកចិត្តទុកដាក់បើកទូលាយព្រំដែននៃ លំហ និង កាល សម្រាប់ជីវិតរបស់ខ្លួនៗ វិទ្យាសាស្ត្រ និងបច្ចេកទេសដែលមនុស្សកំពុងពង្រីក សុទ្ធតែកើតឡើងដោយសារការបើកទូលាយព្រំដែននេះៗ ជីវិតរបស់មនុស្សមាន តម្លៃ លុះត្រាតែខ្លឹមសារនៃជីវិតផ្អែកលើ លំហ និង កាល របស់វានោះៗ

មុនដំបូង បណ្តើមនៃជីវិតមនុស្សប្រៀបបាននឹងជីវិតសត្វ ដែលរស់នៅដោយសភាវៈគតិងងឹតងងល់ ប៉ុន្តែ ទន្ទឹមនឹងការរីកចំរើនខាងរាងកាយ បញ្ញារបស់មនុស្សក៏កាន់តែរីកចំរើនឡើងដែរៗ តម្រូវការរបស់សត្វ ជាតម្រូវការខាងសំភារៈជាធំៗ តម្រូវការរបស់មនុស្សជាតម្រូវការសំភារៈផង និងខាងស្មារតីផង សត្វគ្មានសមត្ថភាពបង្កើនពុទ្ធិទេៗ មនុស្សមានសមត្ថភាពបង្កើន

ពុទ្ធិឥតឈប់ឈរ ពុទ្ធិចេះតែកើនឡើងពីជំនាន់មួយទៅជំនាន់មួយ ឯតម្រូវការរបស់មនុស្សក៏កើនឡើងឥតឈប់ឈរដែរ។ បើប្រៀបធៀបតម្រូវការទាំងពីរ តម្រូវការខាងសំភារៈមានលក្ខណៈងាយស្រួលបំពេញជាង ឯតម្រូវការខាងស្មារតី មានលក្ខណៈពិបាកបំពេញជាង។ ផលប្រយោជន៍ស្មារតី មានលក្ខណៈសំខាន់ជាងផលប្រយោជន៍សំភារៈ។ សេចក្តីរីករាយខាងស្មារតីដែលមនុស្សរស់នៅប្រកបដោយសីលធម៌ មានលក្ខណៈយូរអង្វែង និងមានលក្ខណៈខ្ពស់បំផុត ព្រោះសង្គមមួយដែលខ្វះសីលញាណ គឺជាសង្គមដែលពោរពេញដោយអនាធិបតេយ្យ និយាយបែបនេះ មិនមែនមានន័យថា ត្រូវទាត់ចោលតម្រូវការខាងសំភារៈទេ។ បើគ្មានសំភារៈ ក៏គ្មានស្មារតីដែរ។ ហេតុនេះ ដើម្បីឱ្យជីវិតមានតម្លៃ មនុស្សត្រូវខិតខំពង្រីកទាំងតម្រូវការសំភារៈ ទាំងតម្រូវការស្មារតី ដែលប្រកបដោយសីលធម៌ គុណធម៌ យុត្តិធម៌។ កាយពលកម្ម និងបញ្ញាពលកម្ម ជាម៉ែតវាស់តម្លៃនៃជីវិតមនុស្ស។ ការពង្រីកពង្រឹងកាយពលកម្មតាមលទ្ធភាព និងការជុសខាត់បញ្ញាពលកម្ម គឺពិតជានាំខ្លួនឯង នាំគ្រួសារ នាំជាតិមាតុភូមិ ឈានទៅរកសេចក្តីរុងរឿង។

## សន្និដ្ឋាន

មនុស្សចូលប្រឡូកគ្រប់វិញ្ញាសាសង្គមទាំងអស់ ដូចជា នយោបាយ ច្បាប់ សេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ ...។ ហេតុនេះ ការសិក្សាពិចារណាអំពី តម្លៃមនុស្ស ពិតជាមានសារសំខាន់ ដើម្បីយកមនុស្សទៅប្រើឱ្យចំទិសដៅ អស់សក្តានុពល និងចំណេញអតិបរមា។

## ឯកសារពិគ្រោះ


១. ខៀវសារ៉េន ឈត ប៊ុនថង និងអ្នកផ្សេងទៀតៈ គ្រឹះរបស់ទស្សនវិជ្ជា ភ្នំពេញ បោះពុម្ពនៅរោងពុម្ព ជោគជ័យ(សុខ លាភ) បោះពុម្ពលើកទី២ ឆ្នាំ២០០៨។

២. ខ្ញូត ធីតាៈ ជំនឿសាសនាលើសាកលលោក ភ្នំពេញ បោះពុម្ពនៅរោងពុម្ពពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពឆ្នាំ១៩៩៩។

៣. ខ្ញូត ធីតាៈ មូលដ្ឋានគ្រឹះនៃសីលវិទ្យាសាកលលោក ភ្នំពេញ បោះពុម្ពនៅរោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពឆ្នាំ២០០២។

៤. ខ្ញូត ធីតាៈ អរិយទ្រព្យដ៏ប្រសើររបស់មនុស្ស ភ្នំពេញ បោះពុម្ពនៅរោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពឆ្នាំ២០០៨។

៥. ប៉ាន់ វុត្ថា៖ ទស្សនវិជ្ជា(ការគិត មនុស្ស និង ច្បាប់សង្គម) ភ្នំពេញ ពេជពុម្ព ជីវ៉ាយ ២០១៤។

៦. វិទ្យាល័យ បៀលប្រាយ៖ ***មនុស្ស និង សង្គម*** (មេរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) ភ្នំពេញ ឆ្នាំសិក្សា២០១៣។

៧. Ardales B. Venancio, Introductory Text to Philosophy, Manila : Cubao, Quezon: Greatbook Trading, Inc., 2nd ed, 1987.

៨. Gunner SkirbbeK ang Nils Gilje : ***A History of Western Thought*** *(from ancient Greece to the twentieth century)*, New York, London, Routledge, English translation, first published, 2001.

៩. Stevenon Leslio, The study of Human Nature, Oxford University Press, London, 1981.

# វិបត្តិមហាអំណាចសេដ្ឋកិច្ចបស្ចិមលោក

The Crisis of Western Economic Power

*ដោយៈ បណ្ឌិត* **ឈឿន សាវន** *បណ្ឌិត* **តូច សុធារី** *និង លោក* **សាន ចេង**

*នាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ចនិងទេសចរណ៍*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*វិបត្តិមហាអំណាចសេដ្ឋកិច្ចលោកខាងលិចសំដៅលើ "បញ្ហាប្រឈម និងការថយចុះឥទ្ធិពលដែលប្រទេសលោកខាងលិចបានកំពុងជួបប្រទះនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោក"។ វិបត្តិនេះបានកើតឡើងដោយសារកត្តាមួយចំនួនដែលបានធ្វើឱ្យខូច និងបាត់បង់អំណាចសេដ្ឋកិច្ច និងការដឹកនាំរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចបស្ចិមលោក។*

*កត្តាសំខាន់មួយដែលរួមចំណែកដល់វិបត្តិនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិចគឺការកើនឡើងនៃក្រុមប្រទេសសេដ្ឋកិច្ចលូតលាស់ខ្លាំង ជាពិសេសនៅអាស៊ី។ ឧទាហរណ៍ប្រទេសនៅអាស៊ីដូចជា សាធារណរដ្ឋប្រជាមានិតចិន និងឥណ្ឌា បានឆ្លងកាត់និងស្គាល់នូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ហើយបានក្លាយជាតួអង្គសំខាន់ក្នុងពាណិជ្ជកម្ម និងការវិនិយោគសកល។ ការលេចឡើងរបស់ប្រទេសទាំងនេះបានផ្លាស់ប្តូរតុល្យភាពអំណាចសេដ្ឋកិច្ចចេញពីមហាអំណាចលោកខាងលិច ដូចជាសហរដ្ឋអាមេរិក និងបណ្តាប្រទេសនៅអឺរ៉ុបខាងលិចបន្តិចម្តងៗ។*

*កត្តាមួយទៀតគឺការកើនឡើងនៃទំនាក់ទំនង និងភាពពឹងផ្អែកគ្នារវាងប្រទេសនិងប្រទេសក្នុងបរិបទសាកលភាវូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោកទាំងមូល។ នៅពេលដែលសេដ្ឋកិច្ចពិភពលោកកាន់តែមានសមាហរណកម្ម និងមានលក្ខណៈពឹងផ្អែកគ្នាទៅវិញទៅមក បណ្តាប្រទេសលោកខាងលិចបានប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងពីប្រទេសដែលមានតម្លៃកម្លាំងពលកម្មទាប និងប្រទេសដែលមានសមត្ថភាពពង្រីកឧស្សាហកម្មរបស់ខ្លួនដើម្បីប្រកួតប្រជែងក្នុងប្រព័ន្ធសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល។ ប្រការនេះបាននាំឱ្យមានការបាត់បង់ឧស្សាហកម្ម និងការងារនៅប្រទេសលោកខាងលិចសន្ទឹកសន្ធាប់ ដោយសារក្រុមហ៊ុននានាបានផ្លាស់ប្តូរផលិតកម្មនិងការវិនិយោគរបស់ពួកគេទៅកាន់តំបន់ ដែលមានការចំណាយទាបហើយអាចបង្កើនប្រាក់ចំណេញកាន់តែច្រើន។*

*បច្ចេកវិជ្ជា និងនវានុវត្តន៍ក៏ដើរតួសំខាន់ក្នុងដំណើរការនៃវិបត្តិរបស់មហាអំណាចសេដ្ឋកិច្ចលោកខាងលិចដែរ។ តាំងពីដើមមក*

ក្រុមបណ្តាប្រទេសលោកខាងលិចតែងតែឈានមុខគេក្នុងការអភិវឌ្ឍនិងការរីកចម្រើនលើផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ (Technology and Innovation)។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងការសាយភាយនៃបច្ចេកវិទ្យា និងចំណេះដឹងយ៉ាងទូលំទូលាយនៅទូទាំងពិភពលោក ប្រទេសផ្សេងទៀត ជាពិសេសនៅអាស៊ីបានអភិវឌ្ឍខ្លួនឱ្យដើរទាន់ប្រទេសលោកខាងលិច ហើយឥឡូវនេះកំពុងប្រជែងយកឧត្តមភាពក្នុងវិស័យបច្ចេកវិទ្យានេះមួយចំនួន ជាមួយប្រទេសលោកខាងលិច។

វិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ ជះឥទ្ធិពលយ៉ាងខ្លាំងដល់មហាអំណាចសេដ្ឋកិច្ចលោកខាងលិច។ វិបត្តិនេះបានលាតត្រដាងភាពងាយរងគ្រោះ និងគុណវិបត្តិនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុលោកខាងលិច ហើយនាំឱ្យបាត់បង់ទំនុកចិត្តនៅក្នុងស្ថាប័នសេដ្ឋកិច្ចលោកខាងលិច។ នេះជាលទ្ធផលដែលបានបំផ្លាញភាពជឿជាក់ និងឥទ្ធិពលនៃសេដ្ឋកិច្ចលោកខាងលិច។

លើសពីនេះ មានការប្រឈមផ្នែកសង្គម និងនយោបាយ ដែលបណ្តាប្រទេសលោកខាងលិចបាននិងកំពុងជួបប្រទះផ្ទៃក្នុង ដូចជាវិសមភាពប្រាក់ចំណូល (Income Inequality) ការបែងចែកនយោបាយ (Political Parity) និងការកើនឡើងនៃប្រជានិយម (Populism)។ កត្តាទាំងនេះអាចរារាំងការបង្កើតគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងរាំងសមត្ថភាពក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច។

ទោះជាយ៉ាងណាក៏ដោយ វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា វិបត្តិនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិច មិនមែនមានន័យថា ការធ្លាក់ចុះឬការដួលរលំនៃសេដ្ឋកិច្ចលោកខាងលិចនោះទេ។ ប្រទេសលោកខាងលិចនៅតែមានភាពខ្លាំងឈានមុខគេខាងសេដ្ឋកិច្ចសំខាន់ៗដូចជា ការច្នៃប្រឌិតបច្ចេកវិទ្យា (Technological Creativity) ស្ថាប័នរឹងមាំ (Strong Institution) និងបណ្តាញសកលដែលបានបង្កើតឡើង (Global Networks)។ បញ្ហាប្រឈមគឺស្ថិតនៅក្នុងការសម្របខ្លួន និងសម្របទៅនឹងការផ្លាស់ប្តូរទិដ្ឋភាពសេដ្ឋកិច្ចពិភពលោក និងការស្វែងរកប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែង។

## ២.បច្ច័យនៃអំណាចយោធា និងហិរញ្ញវត្ថុរបស់មហាអំណាចបស្ចិមលោក

បច្ច័យនៃអំណាចយោធានិងហិរញ្ញវត្ថុរបស់មហាអំណាចលោកខាងលិចគឺមានលក្ខណៈចម្រុះ ហើយបានវិវត្តជាច្រើនសតវត្សរ៍មកហើយ។ មានកត្តាសំខាន់ៗមួយចំនួនច្រើនដែលបានរួមចំណែកដល់ការអភិវឌ្ឍអំណាចទាំងនេះនិងអនុត្តរភាពរបស់បស្ចិមលោកក្នុងការក្តោបក្តាប់ និងត្រួតត្រាពិភពលោក។ អំណាចសេដ្ឋកិច្ចនៃលោកខាងលិចមានប្រភពដើមនៅក្នុងប្រព័ន្ធប្រមូលផ្តុំធនធានហិរញ្ញវត្ថុ និងការប្រើប្រាស់កម្លាំងយោធាបង្កើតដោយមហាអំណាចអឺរ៉ុបនៅក្នុងកំឡុងសតវត្សរ៍ទី១៨ និងទី១៩។ ការអភិវឌ្ឍ

សេដ្ឋកិច្ចអឺរ៉ុបគឺផ្អែកលើការកេងប្រវ័ញ្ចនិងទទួលបានធនធានធម្មជាតិ និងធនធានពីបណ្ដាប្រទេសក្រោមអាណានិគមរបស់ខ្លួនដាច់ការទទួលបានពីការរីកចម្រើនផ្នែកឧស្សាហកម្មរបស់ខ្លួន (Arrighi, 2009)។

ទី១៖ ភូមិសាស្ត្រ និងធនធានធម្មជាតិនៃប្រទេសលោកខាងលិច ជាពិសេសនៅអឺរ៉ុប និងអាម៉េរិកខាងជើងមានអំណោយទានខាងភូមិសាស្ត្រដ៏សំខាន់។ ការទទួលបានធនធានធម្មជាតិដ៏ច្រើន ទន្លេនិងសមុទ្រដែលជាផ្លូវនាវាចរយ៉ាងសំខាន់និងឆ្នេរសមុទ្របានជួយសម្រួលដល់សកម្មភាពពាណិជ្ជកម្ម កំណើនសេដ្ឋកិច្ច និងសមត្ថភាពយោធាដល់ប្រទេសលោកខាងលិច។ កត្តាទាំងនេះបានជួយឱ្យបង្កើតបានសេដ្ឋកិច្ចដ៏មានអំណាចនិងកម្លាំងទ័ពជើងទឹកដ៏ខ្លាំងក្លា ដែលអាចឱ្យពួកគេដណ្ដើម និងពង្រីកអំណាចនៅទូទាំងពិភពលោកបាន។

ទី២៖ នយោបាយអាណានិគមនិយមនិងចក្រពត្តិនិយមរបស់បស្ចិមលោក ជាពិសេសក្នុងសម័យអាណានិគម បានឱ្យពួកគេបង្កើតអាណាចក្រដ៏ធំជុំវិញពិភពលោក។ ការកេងប្រវ័ញ្ចលើប្រទេសក្រោមអាណានិគម និងធនធានជាច្រើនបានផ្ដល់នូវទ្រព្យសម្បត្តិ និងមូលធនសេដ្ឋកិច្ច ព្រមទាំងការបង្កើតទីផ្សារថ្មីសម្រាប់ផលិតផលរបស់មហាអំណាចលោកខាងលិចដ៏លើសលប់លើទឹកដីអាណានិគម។ លើសពីនេះទៀត ប្រទេសក្រោមអាណានិគមទាំងនោះជាកន្លែងបម្រើនូវមូលដ្ឋានយុទ្ធសាស្ត្រសម្រាប់ប្រតិបត្តិការយោធា ដោយផ្ដល់ឱ្យមហាអំណាចលោកខាងលិចនូវអត្ថប្រយោជន៍យុទ្ធសាស្ត្រយ៉ាងសំខាន់។

ទី៣៖ ភាពជឿនលឿននៃបច្ចេកវិទ្យាជាកត្តាមួយផ្សេងទៀត។ ប្រទេសលោកខាងលិចបានឈានមុខគេក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ក៏ដូចជាការបង្កើតថ្មី អស់ជាច្រើនសតវត្សរ៍មកហើយ។ ពួកគេអាចទាញយកការច្នៃប្រឌិតបច្ចេកវិទ្យានៅក្នុងឧស្សាហកម្មផ្សេងៗ ដូចជាការផលិត ការដឹកជញ្ជូន និងការធ្វើទំនាក់ទំនង ដែលបានប្រែក្លាយទៅជាគុណសម្បត្តិ និងអំណោយទានសេដ្ឋកិច្ចនិងយោធាដ៏អស្ចារ្យ។ ប្រទេសលោកខាងលិចបានវិនិយោគឥតឈប់ឈរនៅក្នុងការស្រាវជ្រាវ និងការអភិវឌ្ឍ (R&D) ដែលនាំទៅរកការបង្កើតថ្មីក្នុងវិស័យសំខាន់ៗដូចជា សព្វាវុធ ការដឹកជញ្ជូន និងវិស័យបច្ចេកវិទ្យាព័ត៌មាន។

ទី៤៖ កម្លាំងសេដ្ឋកិច្ច និងស្ថាប័នហិរញ្ញវត្ថុក៏ជាបច្ច័យនៅពីក្រោយអំណាចពួកបស្ចិមលោកផងដែរ។ បណ្ដាប្រទេសលោកខាងលិច ជាពិសេសសហរដ្ឋអាម៉េរិក បានបង្កើតសេដ្ឋកិច្ចមូលធននិយមដ៏រឹងមាំ ដែលគាំទ្រដោយប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ រូបិយប័ណ្ណដែលមានស្ថិរភាព (Stable Currency) ទីផ្សារហិរញ្ញវត្ថុដែលមានការគ្រប់គ្រងល្អប្រសើរ (Well-Managed Financial Market) ប្រព័ន្ធធនាគារទំនើប (Modern Banking System) ព្រមទាំងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (International Financial Institutions) ដូចជា ធនាគារពិភពលោក (World

Bank) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Funds) បានរួមចំណែកដល់ការគ្រប់គ្រងហិរញ្ញវត្ថុពិភពលោករបស់បស្ចិមលោក។ កត្តាទាំងនេះបានផ្តល់ឱ្យប្រទេសលោកខាងលិចនូវលទ្ធភាពក្នុងការក្តោបក្តាប់ និងពង្រីកអំណាចសេដ្ឋកិច្ច ប្រើប្រាស់ឥទ្ធិពលលើពាណិជ្ជកម្ម និងការវិនិយោគសកល ព្រមទាំងបង្កើតបទដ្ឋាននិងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដែលអាចបម្រើផលប្រយោជន៍របស់ខ្លួនទាំងមូលក្នុងកិច្ចការសកល។

ទី៥៖ លើសពីនេះ សម្ព័ន្ធភាពយោធានិងការចំណាយលើវិស័យការពារជាតិក៏ជាកត្តាសំខាន់មួយដែរ។ មហាអំណាចលោកខាងលិចបានរៀបចំ និងបង្កើតសម្ព័ន្ធភាពយោធាដ៏រឹងមាំដូចជាអង្គការណាតូ (NATO) ដែលបានបង្កើនសមត្ថភាពយោធារួមរបស់ពួកគេ។ សម្ព័ន្ធភាពទាំងនេះបានផ្តល់ការធានាសន្តិសុខ អនុញ្ញាតឱ្យមានប្រតិបត្តិការយោធារួមគ្នា និងសម្របសម្រួលការចែករំលែកបច្ចេកវិទ្យាយោធា និងការស៊ើបការណ៍សម្ងាត់។ លើសពីនេះ ប្រទេសលោកខាងលិចបានវិនិយោគធនធានសំខាន់ៗច្រើនទៀតក្នុងប្រវត្តិសាស្ត្រនៃក្របខ័ណ្ឌវិស័យការពារជាតិដែលអាចឱ្យពួកគេរក្សាបាននូវកងកម្លាំងប្រដាប់អាវុធដ៏មានឥទ្ធិពល និងមានបច្ចេកវិទ្យាទំនើប។

ទី៦៖ អំណាចទន់ (Soft power)និងឥទ្ធិពលវប្បធម៌ក៏ជាកត្តាជួយឱ្យអំណាចបស្ចិមលោកកាន់តែមានឥទ្ធិពលដែរ។ បណ្តាប្រទេសលោកខាងលិចក៏បានប្រើអំណាចទន់ដ៏សំខាន់ផងដែរតាមរយៈការផ្សព្វផ្សាយនិងបញ្ជ្រាបវប្បធម៌ តម្លៃ និងស្ថាប័នរបស់ពួកគេ។ តន្ត្រី ចម្រៀង ភាពយន្ត អក្សរសិល្ប៍ ភាសា សិល្បៈ និងម៉ូដសម្លៀកបំពាក់ដែលមានភាពទាក់ទាញជាសកល បានរួមចំណែកដល់ការរីកពលដាលនៃឧត្តមភាព និងឥទ្ធិពលព្រមទាំងអំណាចរបស់បស្ចិមលោក។ ស្ថាប័នអប់រំ គំរូអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងការឱ្យតម្លៃជាសាកលចំពោះមនុស្សទូទៅដូចជាសិទ្ធិមនុស្ស និងសេរីភាពបុគ្គល ក៏ជាមូលដ្ឋានសំខាន់ក្នុងការពង្រីកនិងទ្រទ្រង់អំណាច ព្រមទាំងឥទ្ធិពលរបស់មហាអំណាចបស្ចិមលោកផងដែរ។

វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថាប្រភពនៃអំណាចយោធានិងហិរញ្ញវត្ថុរបស់បស្ចិមលោកមិនបិតថេរនោះទេ។ ពួកមហាអំណាចបស្ចិមលោកទាំងនោះបានវិវត្តនិងបន្តវិវត្តនៅពេលដែលទិដ្ឋភាពភូមិសាស្ត្រនយោបាយសាកលផ្លាស់ប្តូរ។ អំណាចដែលកំពុងកើនឡើងការផ្លាស់ប្តូរគំរូសេដ្ឋកិច្ចពិភពលោក វឌ្ឍនភាពបច្ចេកវិទ្យា និងការផ្លាស់ប្តូរបទដ្ឋានអន្តរជាតិ សុទ្ធតែមានសក្តានុពលសម្រាប់ប្រទេសផ្សេងទៀតក្នុងការប្រជែងនឹងការត្រួតត្រារបស់ប្រទេសមហាអំណាចលោកខាងលិចនាពេលបច្ចុប្បន្ននិងអនាគត។

### ៣.វិបត្តិមហាអំណាចសេដ្ឋកិច្ចបស្ចិមលោកក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រ

យើងអាចមើលឃើញវិបត្តិនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិចក្នុងទិដ្ឋភាព

ប្រវត្តិសាស្ត្របាន។ បណ្តាប្រទេសលោកខាងលិច ជាពិសេសមហាអំណាចនៅអឺរ៉ុប មានប្រវត្តិគ្រប់គ្រងលើប្រព័ន្ធសេដ្ឋកិច្ចពិភពលោកភាគច្រើន ដោយសារយុទ្ធសាស្ត្រអាណានិគមនិយម និងចក្រពត្តិនិយមរបស់ខ្លួន។

ក្នុងអំឡុងពេលនៃអាណានិគមអឺរ៉ុបពីសតវត្សរ៍ទី១៦ ដល់សតវត្សរ៍ទី២០ មហាអំណាចបស្ចិមលោកបានបង្កើតនយោបាយអាណានិគមជាច្រើនជុំវិញពិភពលោកដូចជានៅទ្វីបអាស៊ី អាហ្វ្រិក និងអាម៉េរិកឡាទីន។ នេះមិនត្រឹមតែផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានធនធានធម្មជាតិដ៏សម្បូរបែបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុញ្ញាតឱ្យពួកគេបង្កើតបណ្តាញពាណិជ្ជកម្មជាមួយប្រទេសក្រោមអាណានិគមរបស់ខ្លួនយ៉ាងរឹងមាំទៀតផង។អត្ថប្រយោជន៍សេដ្ឋកិច្ចនេះបានជំរុញឱ្យប្រទេសលោកខាងលិចឈានមុខគេក្នុងឧត្តមភាពនៃមហាអំណាចសេដ្ឋកិច្ចពិភពលោក។

ទោះជាយ៉ាងណាក៏ដោយ ការបញ្ចប់នៃអាណានិគមនិយម និងការកើនឡើងនៃចលនាឯករាជ្យនៅពាក់កណ្តាលសតវត្សរ៍ទី២០ គឺជាចំណុចរបត់មួយ។ អតីតប្រទេសអាណានិគមចាប់ផ្តើមទទួលបានឯករាជ្យនយោបាយនិងទទួលបានស្វ័យភាពសេដ្ឋកិច្ចរបស់ពួកគេឡើងវិញ។ ពួកគេបានចាប់ផ្តើមអភិវឌ្ឍឧស្សាហកម្មផ្ទាល់ខ្លួនរបស់ពួកគេ និងប្រើប្រាស់ធនធានរបស់ពួកគេ ដោយប្រជែងនឹងឧត្តមភាពរបស់មហាអំណាចលោកខាងលិច។ លើសពីនេះ សង្គ្រាមលោកទាំងពីរបានធ្វើឱ្យអំណាចសេដ្ឋកិច្ចរបស់ប្រទេសលោកខាងលិចចុះខ្សោយយ៉ាងខ្លាំង។

ការបំផ្លិចបំផ្លាញដែលបណ្តាលមកពីសង្គ្រាមគួបផ្សំនឹងការកើនឡើងនៃការចំណាយលើការកសាងឡើងវិញ បានបណ្តាលឱ្យមានការបែកអំណាច និងធនធានសេដ្ឋកិច្ចសកលឡើងវិញ។ សហរដ្ឋអាម៉េរិកបានលេចឡើងនិងក្លាយជាមហាអំណាចពិភពលោកដ៏សំខាន់ ដោយមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួនភាគច្រើនមិនបានប៉ះពាល់ដោយការបំផ្លិចបំផ្លាញដូចបណ្តាប្រទេសនៅអឺរ៉ុប។ ពេលនោះហើយដែលប្រទេសទាំងអស់មើលឃើញថា សហរដ្ឋអាម៉េរិកបានវ៉ាដាច់អឺរ៉ុបហើយក្លាយជាតួអង្គចម្បងនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិចបច្ចុប្បន្ន។

ប្រព័ន្ធ ប្រេតតុនវូដស៍ (Bretton Woods) ដែលបានបង្កើតឡើងនៅក្រោយសង្គ្រាមលោកលើកទី២ បានពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ចរបស់លោកខាងលិចបន្ថែមទៀត។ បណ្តាប្រទេសលោកខាងលិច ដែលដឹកនាំដោយសហរដ្ឋអាម៉េរិក បានបង្កើតស្ថាប័នសេដ្ឋកិច្ចអន្តរជាតិដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងផ្តល់ហិរញ្ញប្បទានដល់សកម្មភាពសេដ្ឋកិច្ចពិភពលោក។

ទោះជាយ៉ាងណាក៏ដោយ ចុងសតវត្សរ៍ទី២០ បានឃើញការផ្លាស់ប្តូរអំណាចសេដ្ឋកិច្ចឆ្ពោះទៅរកអាស៊ី។ ប្រទេសដូចជាជប៉ុន កូរ៉េខាងត្បូង និងក្រោយមកទៀត ចិនបានចាប់ផ្តើមជួប

ប្រទះនឹងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងឧស្សាហូបនីយកម្ម។ ភាពជោគជ័យរបស់ពួកគេក្នុងការផលិត និងកំណើនសេដ្ឋកិច្ចដោយការនាំចេញបានបង្កឱ្យមានបញ្ហាប្រឈមដល់មហាអំណាចសេដ្ឋកិច្ចលោកខាងលិច ជាពិសេសនៅក្នុងវិស័យសំខាន់ៗដូចជា ការផលិតរថយន្ត និងគ្រឿងអេឡិចត្រូនិក។ល។

ដំណើរការនៃសកលភាវូបនីយកម្ម និងការរីកចម្រើនផ្នែកបច្ចេកវិទ្យាបានរួមចំណែកបន្ថែមទៀតដល់ការធ្វើឱ្យបាត់បង់អំណាចសេដ្ឋកិច្ចលោកខាងលិច។ ជាមួយនឹងវត្តមាននៃបច្ចេកវិទ្យាព័ត៌មាន និងការរីករាលដាលនៃអ៊ីនធឺណិត ឱកាសសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគសកលបានកើនឡើង។ ប្រការនេះបានអនុញ្ញាតឱ្យប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន ជាពិសេសនៅអាស៊ីអាចចូលទៅក្នុងទីផ្សារពិភពលោក និងប្រកួតប្រជែងជាមួយក្រុមហ៊ុនលោកខាងលិចបានទៀតផង។

សរុបមក យើងអាចមើលឃើញនូវវិបត្តិនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិចក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រចាប់ពីការបញ្ចប់នៃអាណានិគមនិយម ឥទ្ធិពលនៃសង្គ្រាម ការកើនឡើងសេដ្ឋកិច្ចនៃបណ្តាប្រទេសនៅអាស៊ី ឥទ្ធិពលសាកលភាវូបនីយកម្ម និងវឌ្ឍនភាពបច្ចេកវិទ្យា។ កត្តាទាំងនេះបាន និងកំពុងធ្វើឱ្យអនុត្តរភាពរបស់បណ្តាប្រទេសលោកខាងលិចកាន់តែធ្លាក់ចុះ និងបានបង្កើតឱ្យមាននិន្នាការ និងផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចពិភពលោកពហុប៉ូល។

### ៤. វិបត្តិមហាអំណាចសេដ្ឋកិច្ចបស្ចិមលោកក្នុងទិដ្ឋភាពបច្ចុប្បន្ន

វិបត្តិនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិចក្នុងពេលបច្ចុប្បន្នអាចបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម:

***ក.ការផ្លាស់ប្តូរនិន្នាការសេដ្ឋកិច្ច និងប្រជាសាស្ត្រ៖*** បណ្តាប្រទេសលោកខាងលិចកំពុងជួបប្រទះនឹងកំណើនប្រជាជនយឺតហើយចំនួនប្រជាជនវ័យចំណាស់កើនឡើង ដែលអាចរារាំងកំណើនសេដ្ឋកិច្ច។ ទន្ទឹមនឹងនោះ ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើននៅទ្វីបអាស៊ី ជាពិសេសប្រទេសចិន និងឥណ្ឌា មានប្រជាជនវ័យក្មេងច្រើន នាពេលបច្ចុប្បន្នដែលជាកម្លាំងសេដ្ឋកិច្ច និងកំពុងជួបប្រទះនឹងកំណើនសេដ្ឋកិច្ចខ្លាំង និងឆាប់រហ័ស។ ការផ្លាស់ប្តូរនេះបានបណ្តាលឱ្យមានការបែងចែកឡើងវិញនូវតុល្យភាពអំណាចសេដ្ឋកិច្ចពិភពលោកចេញពីប្រទេសលោកខាងលិច។

***ខ.ការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងបដិវត្តន៍ឌីជីថល៖*** ការកើនឡើងនៃបច្ចេកវិទ្យា និងសេដ្ឋកិច្ចឌីជីថលបានរំខានដល់ឧស្សាហកម្មប្រពៃណីនិងគំរូអាជីវកម្មនានា ហើយផ្តល់តម្លៃដល់ក្រុមហ៊ុនដែលមានការច្នៃប្រឌិតនិងបង្កើតថ្មីជាងក្រុមហ៊ុនលោកខាងលិចដែលមានស្រាប់។ ក្រុមហ៊ុនបច្ចេកវិទ្យាយក្សមកពីប្រទេសចិនដូចជា ក្រុមហ៊ុន អាលីបាបា (Alibaba) ក្រុមហ៊ុនធិនសេន (Tencent) និង ក្រុមហ៊ុន ហួវេ (Huawei) ។ល។ បានលេចចេញជាតួអង្គសំខាន់នៅក្នុងទីផ្សារ

ពិភពលោក ដោយប្រកួតប្រជែងឧត្តមភាពជាមួយក្រុមហ៊ុនប្រទេសលោកខាងលិចក្នុងវិស័យដូចជា ពាណិជ្ជកម្មអេឡិចត្រូនិកនិងទូរគមនាគមន៍ជាដើម។

***គ.ការកើនឡើងគោលនយោបាយគាំពារនិយម និងជម្លោះពាណិជ្ជកម្ម៖*** *ភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិក និង ប្រទេសចិន ក៏ដូចជាជម្លោះលើពន្ធនាំចេញនាំចូលផលិតផលផ្សេងទៀតបានរំខានដល់ខ្សែប្រវាក់ផ្គត់ផ្គង់និងតម្រូវការក្នុងផលិតកម្មពិភពលោក និងរាំងដល់ដំណើរការប្រក្រតីរបស់ពាណិជ្ជកម្មអន្តរជាតិ។ ប្រទេសលោកខាងលិច ជាពិសេសសហរដ្ឋអាម៉េរិក បានអនុម័តនិងប្រើប្រាស់វិធានការការពារនិយមកាន់តែខ្លាំងឡើង កំណត់ដែនកំណត់សម្រាប់ប្រទេសដទៃទៀតក្នុងការចូលទៅកាន់ទីផ្សារពិភពលោក និងរាំងមិនឱ្យមានកំណើនសេដ្ឋកិច្ច។*

***ឃ.វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖*** *ប្រទេសលោកខាងលិចបានប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដូចជាវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨ វិបត្តិបំណុលនៅក្នុងតំបន់អឺរ៉ូ ព្រមទាំងវិបត្តិក្នុងកំឡុងក្រោយការរាតត្បាតជំងឺកូវីដ-១៩ ដែលរុញច្រានដោយសង្គ្រាមរវាងអ៊ុយក្រែន និង រុស្ស៊ី និងសង្គ្រាមនៅមជ្ឈឹមបូព៌ារវាងអ៊ីស្រាអែល និងប៉ាលេស្ទីន នៅក្រោមឥទ្ធិពលការប្រកួតប្រជែងរបស់មហាអំណាច ជាពិសេស សហរដ្ឋអាម៉េរិក និង ចិន។ វិបត្តិទាំងនេះបានលាតត្រដាងពីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធ និងស្ថាប័នសេដ្ឋកិច្ចលោកខាងលិច ដែលបំផ្លាញទំនុកចិត្តលើស្ថិរភាពសេដ្ឋកិច្ច និងភាពធន់របស់ពួកគេ។ វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនេះដែលកើតឡើងបានកំពុងយាយីសេដ្ឋកិច្ចពិភពលោកផងដែរ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។*

***ង.វិសមភាព និងភាពចលាចលក្នុងសង្គម៖*** *ប្រទេសលោកខាងលិចកំពុងប្រឈមមុខនឹងការកើនឡើងនៃវិសមភាពប្រាក់ចំណូល និងភាពចលាចលសង្គមជាពិសេសបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ និងស្ថានភាពដ៏អាក្រក់បន្ទាប់ពីការរាតត្បាតជំងឺកូវីដ-១៩ និងក្រោយមកសង្គ្រាមនៅអ៊ុយក្រែន។ កត្តានេះបាននាំឱ្យមានអារម្មណ៍មិនសប្បាយចិត្ត និងការមិនពេញចិត្តក្នុងចំណោមប្រជាពលរដ្ឋ និងបានជំរុញឱ្យមានចលនាប្រជានិយម និងការប្រឆាំងតវ៉ានានា នៅស្ទើរតែគ្រប់ប្រទេសលោកខាងលិច។ បញ្ហាប្រឈមផ្ទៃក្នុងទាំងនេះអាចធ្វើឱ្យអំណាច និងស្ថិរភាពសេដ្ឋកិច្ចមហាអំណាចបស្ចិមលោកចុះខ្សោយថែមទៀតបន្តិចម្តងៗ។*

*ដើម្បីដោះស្រាយវិបត្តិនៃមហាអំណាចសេដ្ឋកិច្ចលោកខាងលិចក្នុងស្ថានភាពបច្ចុប្បន្ន បណ្តាប្រទេសលោកខាងលិចប្រហែលជាត្រូវផ្តោតលើការពង្រឹងឧស្សាហកម្មក្នុងស្រុក ការវិនិយោគលើការច្នៃប្រឌិត និងបច្ចេកវិទ្យា ការលើកកម្ពស់កំណើនប្រកបដោយបរិយាប័ន្ន និងការអនុម័តគោលនយោបាយដែលគាំទ្រដល់ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។*

លើសពីនេះ ប្រទេសលោកខាងលិចគួរតែខិតខំដោះស្រាយវិសមភាពប្រាក់ចំណូល និងវិសមភាពសង្គម ដើម្បីស្តារទំនុកចិត្ត និងស្ថិរភាពនៅក្នុងសង្គមរបស់ពួកគេ។

## សន្និដ្ឋាន

វិបត្តិមហាអំណាចសេដ្ឋកិច្ចបស្ចិមលោកអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចពិភពលោក និងអាចរុញស្ថានការណ៍ទៅជាវិបត្តិសេដ្ឋកិច្ចសកល។ នៅពេលដែលប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗនៅបស្ចិមប្រទេស ដូចជាសហរដ្ឋអាម៉េរិក ឬប្រទេសនានាក្នុងទ្វីបអឺរ៉ុប ជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ វាអាចមានផលប៉ះពាល់ជាខ្លាំងនៅទូទាំងពិភពលោក។

ភាពជាប់ទាក់ទង និងពឹងផ្អែកគ្នានៃសេដ្ឋកិច្ចពិភពលោកមានន័យថាវិបត្តិនៅក្នុងតំបន់មួយអាចរីករាលដាលយ៉ាងឆាប់រហ័សទៅកាន់ប្រទេសផ្សេងទៀតតាមរយៈបណ្តាញនិងរបៀបផ្សេងៗ។ ជាឧទាហរណ៍ ការថយចុះនៃតម្រូវការទំនិញ និងសេវាកម្មពីប្រទេសមហាអំណាចសេដ្ឋកិច្ចសំខាន់ៗលោកខាងលិចអាចជះឥទ្ធិពលអវិជ្ជមានដល់ប្រទេសនាំចេញដែលពឹងផ្អែកលើទីផ្សារទាំងនេះ។ ការធ្លាក់ចុះនៃតម្រូវការនេះអាចនាំឱ្យផលិតកម្មធ្លាក់ចុះ និងកាត់បន្ថយការងារនៅក្នុងប្រទេសនាំចេញទាំងនោះ ដែលបណ្តាលឱ្យមានការជាប់គាំងនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចរបស់ពួកគេ។

លើសពីនេះទៅទៀត ទំនាក់ទំនងហិរញ្ញវត្ថុរវាងសេដ្ឋកិច្ចលោកខាងលិច និងពិភពលោកទាំងមូលអាចធ្វើឱ្យមានផលប៉ះពាល់ពេលមានវិបត្តិកាន់តែធ្ងន់ធ្ងរ។ កម្រិតអស្ថិរភាពហិរញ្ញវត្ថុនៅក្នុងប្រទេសលោកខាងលិចកាន់តែខ្ពស់អាចបណ្តាលឱ្យមានលំហូរចេញមូលធនពីប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍ ដែលនាំឱ្យមានការធ្លាក់ថ្លៃរូបិយប័ណ្ណ ចំណាយលើកម្ចីប្រាក់កាន់តែខ្ពស់ និងការវិនិយោគធ្លាក់ចុះ។ នេះអាចរារាំងកំណើនសេដ្ឋកិច្ច និងរួមចំណែកធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ចសកលកាន់តែធ្ងន់ទៅៗ។

លើសពីនេះ វិបត្តិសេដ្ឋកិច្ចលោកខាងលិចក៏អាចប៉ះពាល់ដល់សក្តានុពលពាណិជ្ជកម្មពិភពលោកផងដែរ។ ប្រទេសលោកខាងលិចគឺជាតួអង្គសំខាន់ក្នុងពាណិជ្ជកម្មអន្តរជាតិ ហើយការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេអាចនាំឱ្យមានការរំខានពាណិជ្ជកម្ម និងកាត់បន្ថយទំហំពាណិជ្ជកម្មសកល។ នេះអាចបង្កើនឱ្យមានការធ្លាក់ចុះថាមភាពសេដ្ឋកិច្ច និងធ្វើឱ្យវិបត្តិសេដ្ឋកិច្ចសាកលកាន់តែផុងជ្រៅទៅៗ។

ដើម្បីឆ្លើយតបទៅនឹងវិបត្តិ និងហានិភ័យនៃវិបត្តិសេដ្ឋកិច្ចសកល រដ្ឋាភិបាល និងធនាគារកណ្តាលជុំវិញពិភពលោកតែងតែសម្របសម្រួលសកម្មភាពរបស់ពួកគេ ដើម្បីអនុវត្តវិធានការ និងគោលនយោបាយជំរុញសេដ្ឋកិច្ច។ វិធានការទាំងនេះអាចរួមបញ្ចូលកញ្ចប់ជំរុញសារពើពន្ធ ការកែសម្រួលគោលនយោបាយរូបិយវត្ថុ និងកិច្ច

*សហប្រតិបត្តិការអន្តរជាតិ ដើម្បីរក្សាស្ថិរភាពទីផ្សារហិរញ្ញវត្ថុ និងលើកកម្ពស់ការងើបឡើងវិញនៃសេដ្ឋកិច្ច។*

*ទោះជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពនៃវិធានការទាំងនេះអាស្រ័យលើភាពធ្ងន់ធ្ងរ និងរយៈពេលនៃវិបត្តិដែលបានកើតឡើង ក៏ដូចជាសមត្ថភាពរបស់ប្រទេសនានាក្នុងការសម្របសម្រួលការឆ្លើយតបរបស់ពួកគេ។ ការគ្រប់គ្រងវិបត្តិសេដ្ឋកិច្ចសកលទាមទារឱ្យមានការខិតខំប្រឹងប្រែងរួមគ្នា ព្រោះផលប៉ះពាល់មិនបានកំណត់ចំពោះតំបន់ជាក់លាក់ណាមួយទេ ប៉ុន្តែមានឥទ្ធិពលខ្លាំងក្លា ដែលសាយភាយទូទាំងពិភពលោក។*

## គន្ថនិទ្ទេស


1. Arrighi, G. (2009). *Adam Smith in Beijing: Lineages of the 21st century*. Verso books.
2. Cleaver, T. (2013) *Understanding the World Economy*, fourth edition, London: Routledge.
3. Dirlik, A. (2001) *Global Modernity: Modernity in the Age of Global Capitalism,*
   a. Boulder: Paradigm.
4. Eichengreen, B. (2008) *Globalizing Capital: A History of the International Monetary*
   a. *System,* Princeton: Princeton University Press.
5. Eichengreen, B. (2011) *Exorbitant Privilege: The Rise and Fall of the Dollar*, Oxford:
   a. Oxford University Press.
6. Fouskas, V. and Gökay, B. (2012) *The Fall of the US Order: Global Fault-Lines and the*
   a. *Shifting Imperial Order*, London: Pluto.
7. Friedman, J. and Kraus, W. (2011) *Engineering the Financial Crisis: Systemic Risk and*
   a. *the Failure of Regulation*, Philadelphia: University of Pennsylvania Press.
8. Garrison, R.W. (2000) *Time and Money: The Macroeconomics of Capital Structure,*
   a. London: Routledge.
9. Hendrickson, J.M. (2013*) Financial Crisis: The United States in the Early Twenty-first*
   a. *Century*, Basingstoke: Palgrave Macmillan.
10. Hung, H. (2008) *'Rise of China and the global accumulation crisis', Review of*
    a. *International Political Economy*, *15, 2:* 149–179.
11. Ikenberry, G.J. (2011) *Liberal Leviathan: The Origins, Crisis and Transformation of the*
    a. *American World Order*, Princeton: Princeton University Press.
12. Kearns, G. (2009) *Geopolitics and Empire: The Legacy of Halford Mackinder, Oxford:*
    a. Oxford University Press.
13. Rickards, J. (2011) *Currency Wars: The Making of the Next Global Crisis*, London:
    a. Penguin.

# ការឡើងកម្ដៅភពផែនដី

## Global Warming

*ដោយៈ* **លោក ហៃ សុគន្ធា**
*ប្រធានស្ដីទីនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
Email: haysokunthea@yahoo.com

### សេចក្ដីផ្ដើម

*សីតុណ្ហភាពមធ្យមនៅលើភពផែនដី នៅក្នុងពេលបច្ចុប្បន្ននេះកំពុងតែមានការកើនឡើងខ្លាំង និងលឿនជាងអ្វីដែលមនុស្សធ្លាប់បានសង្កេតតាមលក្ខណៈធម្មជាតិ បើធៀបទៅនឹងកាលពីពេលមុនៗ។ក្រុមអ្នកវិទ្យាសាស្ត្ររបស់អង្គការសហប្រជាជាតិ បានរកឃើញភស្តុតាងជាច្រើនទាក់ទងជាមួយនឹងការឡើងកម្ដៅនៃភពផែនដីនាពេលបច្ចុប្បន្ននេះ គឺបង្កឡើងជាចម្បងដោយសកម្មភាពរបស់មនុស្ស ពោលគឺ សីតុណ្ហភាពនៃភពផែនដី មានការកើនឡើងទៅតាមលក្ខណៈធម្មជាតិផង និងបន្ថែមយ៉ាងលឿនដោយសកម្មភាពរបស់មនុស្សផង។ ក្រុមអ្នក វិទ្យាសាស្ត្រ និងអ្នកត្រួតពិនិត្យផ្នែកអាកាសធាតុនៃរដ្ឋាភិបាលនានារាប់ពាន់នាក់ បានយល់ស្របអំពីការកំណត់នៃកំណើនសីតុណ្ហភាពរបស់ភពផែនដី ដែលអាចជាលទ្ធភាពដើម្បីជួយមនុស្ស ឱ្យជៀសផុតពីផលប៉ះពាល់អាកាសធាតុនិងរក្សាបាននូវបរិយាកាសសមស្រប ដែលអាចរស់នៅបាន។ គោលនយោបាយ ដែលកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះ គឺការចង្អុលបង្ហាញអំពីការកើនឡើងសីតុណ្ហភាព ប្រមាណ៣អង្សាសេ នៅចុងសតវត្សរ៍ទី២១។*

*ការកើនឡើងនៃកម្ដៅផែនដី គឺកើតឡើងនៅពេលដែលឧស្ម័នកាបូនិក (កាបូនឌីអុកស៊ីត) និងសារធាតុបំពុលផ្សេងៗទៀត បានធ្វើការប្រមូលផ្ដុំនៅក្នុងបរិយាកាស ហើយស្រូបយកពន្លឺព្រះអាទិត្យ និងវិទ្យុសកម្មព្រះអាទិត្យ (ថាមពលម៉ាញ៉េទិកដែលបញ្ចេញដោយព្រះអាទិត្យ) ដែលបានជះត្រឡប់ពីផ្ទៃផែនដី។ តាមដំណើរវិវត្តរបស់ផែនដី គឺវាមានការកើនកម្ដៅនិងចុះត្រជាក់ ម្ដងហើយម្ដងទៀត ពោលគឺអាកាសធាតុនៅលើផែនដី មានការផ្លាស់ប្ដូរ នៅពេលទទួលបានពន្លឺព្រះអាទិត្យច្រើនឬតិច ដោយសារការផ្លាស់ប្ដូរតិចតួចតាមគន្លងរបស់វា ។ ជាងនេះទៀត ក្នុងកំលុងពេលប្រមាណ ជាងមួយសតវត្សរ៍ចុងក្រោយនេះ*

មានឥទ្ធិពលមួយទៀត ដែលបានធ្វើឱ្យបរិយាកាសផែនដី មានការប្រែប្រួលជាខ្លាំង គឺសកម្មភាពរបស់មនុស្ស។ បើទោះបីជាដំណើរប្រែប្រួលរបស់ព្រះអាទិត្យ បានរួមចំណែកបង្កឱ្យមានកំណើនសីតុណ្ហភាព ក៏ពិតមែន ក៏ប៉ុន្តែកត្តាចម្បងនៃកំណើនសីតុណ្ហភាពមធ្យមនៅក្នុងបរិយាកាសផែនដី គឺកំណើនឧស្ម័នផ្ទះកញ្ចក់ដែលបង្កឡើយតាមរយៈសកម្មភាពរបស់មនុស្ស។ របាយការណ៍ របស់ក្រុមប្រឹក្សាស្រាវជាតិជាតិសហរដ្ឋអាមេរិក បានឱ្យដឹងថា នៅក្នុងរយៈពេលប្រមាណមួយសតវត្សរ៍ចុងក្រោយនេះ ផែនដីមានកម្តៅខ្ពស់ជាងពេលណាៗទាំងអស់ ពោលគឺសីតុណ្ហភាពកើនឡើងជាមធ្យមប្រមាណ ០.៣ ទៅ ០.៦ អង្សាសេ។ ជាការពិត បញ្ហានៃការឡើងកម្តៅផែនដីនេះ គឺបង្កឡើងដោយកត្តាពីរ គឺការផ្លាស់ប្តូរសកម្មភាព នៃដំណើរព្រះអាទិត្យដែលកើតឡើងដោយធម្មជាតិ និងកំណើនឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ដែលបង្កឡើងដោយសារសកម្មភាពនានារបស់មនុស្ស។

ជាធម្មតា កាំរស្មីព្រះអាទិត្យបាញ់ឆ្ពោះទៅផែនដី ហើយបន្ទាប់មកថាមពលនេះ នឹងត្រឡប់ទៅក្នុងបរិយាកាសវិញ ប៉ុន្តែដោយសារវត្តមានរបស់ឧស្ម័នផ្ទះកញ្ចក់ បានធ្វើឱ្យថាមពលកម្តៅព្រះអាទិត្យកាន់តែច្រើន មិនអាចត្រឡប់ទៅវិញបាន ពោលគឺត្រូវបានខ្ទប់នៅក្នុងបរិយាកាស។ ជាធម្មតា កម្តៅនៅលើផ្ទៃផែនដីត្រូវរក្សាជាចាំបាច់ដើម្បីទ្រទ្រង់ជីវិតរបស់មនុស្ស សត្វ និងរុក្ខជាតិ ប៉ុន្តែសកម្មភាពរបស់មនុស្ស បានធ្វើឱ្យតុល្យភាពធម្មជាតិ មានការប្រែប្រួលដោយសារតែការរាំងខ្ទប់កម្តៅច្រើននៅលើផ្ទៃផែនដី។ កាលពីអតីតកាលសីតុណ្ហភាពផែនដី មានការប្រែប្រួលតិចតួចគួរឱ្យកត់សម្គាល់ តាមរយៈបន្លាស់ប្តូរតាមគន្លងទ្រេតរបស់ផែនដី និងបន្លាស់ប្តូរកម្រិតឧស្ម័នធម្មជាតិក្នុងបរិយាកាស រួមទាំងសកម្មភាពនានារបស់មនុស្សផងដែរ គឺស្ទើរតែគ្មានឥទ្ធិពលទាល់តែសោះដល់បរិយាកាសផ្ទៃផែនដី។ ផ្ទុយទៅវិញ បច្ចុប្បន្ននេះ កត្តានេះ គឺពិតជាមិនអាចប្រៀបផ្ទឹមនឹងឧស្ម័នផ្ទះកញ្ចក់ ដែលបង្កឡើងដោយសារសកម្មភាពនានារបស់មនុស្សបាននោះទេ។ កម្តៅកពផែនដី "global warming" គឺជាការប្រែប្រួលសីតុណ្ហភាពខ្យល់លើផ្ទៃផែនដី ហៅថាសីតុណ្ហភាពកពផែនដី ដែលបានកើតឡើងដោយសារកំណើនផលផ្ទះកញ្ចក់ បង្កឡើយដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងខ្យល់[1]។

ការឡើងកម្តៅផែនដី គឺជាបាតុភូតមួយនៃការប្រែប្រួលអាកាសធាតុ ដែលកំណត់ដោយសារ

[1] ក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិភាសាខ្មែរៈ សទ្ទានុក្រម ការប្រែប្រួលអាកាសធាតុ ទំព័រទី៣

ការកើនឡើងទូទៅនៃសីតុណ្ហភាពជាមធ្យមរបស់ផែនដី។ វាបានកែប្រែតុល្យភាពអាកាសធាតុ និងប្រព័ន្ធអេកូឡូស៊ីក្នុងរយៈពេលយូរ ហើយត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងការកើនឡើង នៃឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស ដែលធ្វើឱ្យឥទ្ធិពលផ្ទះកញ្ចក់កាន់តែអាក្រក់ទៅៗ។

### ១. សីតុណ្ហភាពនិងកម្ដៅព្រះអាទិត្យ

ក្រុមអ្នកវិទ្យាសាស្ត្រ នៃអង្គភាពរដ្ឋបាលជាតិអាកាសចរណ៍ និងអវកាស (NASA) បានធ្វើកំណត់ត្រា ចាប់ពីទសវត្សរ៍ឆ្នាំ១៨៨០ ដល់ទសវត្សរ៍ឆ្នាំ២០២០ អំពីកម្រិតនៃការឡើងកម្ដៅនៃកពផែនដី ធៀបនឹងកម្រិតនៃថាមពលម៉ាញ៉េទិកផែនដី ក្នុងកំលុងពេលជាមួយគ្នា។ តាមរូបភាពខាងក្រោម(រូបភាពទី១) បង្ហាញថា ក្រាបពីរខ្សែ គឺជាការប្រៀបធៀប រវាងការប្រែប្រួលចុះឡើងរបស់កម្ដៅនៃជាតុវិទ្យុសកម្មជះពីព្រះអាទិត្យ និងការប្រែប្រួលកម្ដៅលើផ្ទៃផែនដីផ្ទាល់។ ក្រាបពណ៌លឿង គឺបង្ហាញថា សកម្មភាពកម្ដៅព្រះអាទិត្យមានភាពនឹងនរ លើកលែងតែពេលឈានចូលវដ្តនៃព្រះអាទិត្យ(១១ឆ្នាំម្តង) ទើបមានសកម្មភាពព្យុះព្រះអាទិត្យ (Solar Storm) បង្កឡើងដោយការជះចេញនូវដុំភ្លើង ដែលមានភាពកញ្ជ្រោលខ្លាំង។ ជាក់ស្តែង នៅក្នុងអំលុងទសវត្សរ៍ឆ្នាំ១៩៥០ គឺជាពេលដែលដុំភ្លើងព្រះអាទិត្យ (Solar Flare) មានសភាពខ្លាំងក្លាជាងគេបំផុត។ សម្រាប់ក្រាបពណ៌ក្រហមវិញ គឺបង្ហាញពីការប្រែប្រួលកម្ដៅលើផ្ទៃផែនដី ពោលគឺមានកម្រិតកើនឡើងរហូតជាពិសេស គឺចាប់តាំងពីអំលុងទសវត្សរ៍ឆ្នាំ១៩៨០ មកទល់នឹងទសវត្សរ៍ឆ្នាំ២០២០ នេះតែម្តង។ តាមការសន្និដ្ឋានរបស់អង្គភាពណាហ្សា បានបញ្ជាក់ថា កម្ដៅព្រះអាទិត្យ គឺពិតជាមិនអាចបង្កឱ្យកពផែនដី ឡើងកម្ដៅបានឡើយ នៅក្នុងរយៈពេលប្រមាណមួយសតវត្សរ៍ចុងក្រោយនេះ ប៉ុន្តែផ្ទុយទៅវិញ សកម្មភាពរបស់មនុស្ស គិតចាប់តាំងពីបដិវត្តន៍ឧស្សាហកម្មកើតឡើងនោះ ទើបជាកត្តាចម្បងបំផុត ក្នុងការបង្កឱ្យមានការឡើងកម្ដៅកពផែនដី រួមមាន ការដុតចំហេះឥន្ធនៈ ដូចជា ធ្យូងថ្ម ប្រេង និងឧស្ម័ន ជាដើម ដែលធ្វើឱ្យបរិយាកាសផែនដីអាប់អួ ដោយសារកំណើននៃឧស្ម័នពុល និងការបង្ខាំងទុកកម្ដៅកាន់តែច្រើនឡើងៗ។

***រូបភាពទី១៖ សីតុណ្ហភាពនិងសកម្មភាពព្រះអាទិត្យ***




*ប្រភព:* The National Aeronautics and Space Administration (NASA)

## ១.១- កត្តាធម្មជាតិ

តាមប្រវត្តិធរណីកាល ផែនដីមានអាយុប្រមាណជា ៤៥០០លានឆ្នាំ ដែលសីតុណ្ហភាពមធ្យមនៃភពផែនដី តែងតែមានការប្រែប្រួលជានិច្ច។ ពេលខ្លះសីតុណ្ហភាព មានការធ្លាក់ចុះ ហើយពេលខ្លះសីតុណ្ហភាពមានកើនឡើង អាស្រ័យទៅតាមគន្លងផែនដីខិតចូលទៅជិតព្រះអាទិត្យបន្តិច និងចាកឆ្ងាយចេញពីព្រះអាទិត្យបន្តិចវិញ ពោលគឺការប្រែប្រួលអាកាសធាតុនៃភពផែនដី អាចកើតឡើងតាមមូលហេតុធម្មជាតិ។ សីតុណ្ហភាពមធ្យមនៃភពផែនដី មានការប្រែប្រួលតិចតួចប៉ុណ្ណោះ ដោយសារដំណើររបស់ព្រះអាទិត្យ និងដំណើរនៃភាពទ្រេតតាមគន្លងរបស់ផែនដី និងបន្លាស់ប្តូរកម្រិតឧស្ម័នធម្មជាតិនៅក្នុងបរិយាសកាស ពោលគឺស្ទើរតែគ្មានការទទួលរងឥទ្ធិពលពីសកម្មភាពនានារបស់មនុស្សទាល់តែសោះ។

ការប្រែប្រួលបរិយាកាសផ្ទៃផែនដី មានកម្រិតតិចតួចបំផុត ដែលបណ្តាលមកពីឥទ្ធិពលធម្មជាតិ ដូចជា បន្លាស់ប្តូរភាពទ្រេតរបស់ផែនដី និងបន្លាស់ប្តូរកម្រិតឧស្ម័នធម្មជាតិ នៅក្នុងបរិយាកាស។ ការផ្លាស់ប្តូរកម្រិតឧស្ម័ន តាមរយៈសកម្មភាពព្រះអាទិត្យ និងកម្រិតថាមពលព្រះអាទិត្យ ដែលផែនដីទទួលបាន ក៏ជាកត្តាមួយធ្វើឱ្យផ្ទៃផែនដី កើនកម្តៅផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ឥទ្ធិពលពីកត្តាធម្មជាតិ ពិតជាមិនអាចប្រៀបផ្ទឹមនឹងឥទ្ធិពលរបស់ឧស្ម័នផ្ទះកញ្ចក់ដែលបង្កឡើង ដោយសកម្មភាពរបស់មនុស្សបាននោះទេ។

## ១.២- ឧស្ម័នផ្ទះកញ្ចក់

តម្រូវការគ្មានដែនកំណត់របស់មនុស្ស នាពេលបច្ចុប្បន្ន គឺបានផ្ទុះបញ្ចាំងអំពីដំណើរឥតឈប់ឈរនៃសកម្មភាពរបស់មនុស្ស ក្នុងការស្រាវជ្រាវនិងស្វែងរកនូវអ្វីដែលថ្មី និងកាន់តែងាយស្រួល សម្រាប់ជីវិតរស់នៅកាន់តែប្រសើរ។ ឧស្ម័នជាច្រើន ជាពិសេសឧស្ម័នកាបូនិក (កាបូនឌីអុកស៊ីត) និងមេតាន ដែលមាននៅក្នុងបរិយាកាស គឺបានមកអំពីសកម្មភាពនានារបស់មនុស្ស តាម រយៈការប្រើប្រាស់គ្រឿងម៉ាស៊ីនដែលប្រើប្រាស់ប្រេង និងធ្យូងថ្ម រួមមាន ឡាន ម៉ូតូ រថភ្លើង នាវាយន្តហោះ រោងចក្រ រោងចក្រប្រើប្រាស់ធ្យូងថ្ម និងការចិញ្ចឹមសត្វជាដើម។ ឧស្ម័នផ្ទះកញ្ចក់ ដែលបង្កឡើងដោយសកម្មភាពនានារបស់មនុស្ស ទៅក្នុងបរិយាកាស គឺជាកត្តាចម្បងបំផុត ដែលបង្កឱ្យមានការឡើងកម្តៅផែនដី។ បន្ថែមពីលើនេះទៀត ការកាប់បំផ្លាញព្រៃឈើ ក៏ជាមូលហេតុមួយនាំឱ្យផែនដីឡើងកម្តៅដែរ ព្រោះព្រៃឈើជួយស្រូបឧស្ម័នកាបូនិកពីក្នុងបរិយាកាស។ កាលណាបរិមាណព្រៃឈើធ្លាក់ចុះ សមត្ថភាពក្នុងការស្រូបឧស្ម័នកាបូនិកពីក្នុងបរិយាកាស ក៏ត្រូវធ្លាក់ចុះដែរ។ មានន័យថា កាលណាបរិមាណឧស្ម័នកាបូនិកនៅក្នុងបរិយាកាសមានការកើនឡើង កម្តៅនៅលើផ្ទៃផែនដី ក៏មានការកើនកម្តៅឡើងផងដែរ។ ជាធម្មតា កាំរស្មីព្រះ

អាទិត្យបាញ់ឆ្ពោះទៅផែនដី ហើយបន្ទាប់មក ថាមពលនេះនឹងវិលត្រឡប់ទៅក្នុងបរិយាកាសវិញ ប៉ុន្តែដោយសារវត្តមានរបស់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស បានធ្វើឱ្យកម្តៅព្រះអាទិត្យត្រូវបានរាំងផ្ទុបនៅនឹងផ្ទៃផែនដី ពោលគឺមិនអាចត្រឡប់ទៅវិញបាន។ បាតុភូតនេះហើយ ដែលធ្វើឱ្យកម្តៅផែនដីមានការកើនឡើង។

ការបំភាយឧស្ម័ន ដែលបណ្តាលឱ្យមានការប្រែប្រួលអាកាសធាតុ គឺបានមកពីគ្រប់ផ្នែកនៃពិភពលោក ហើយប៉ះពាល់ទៅដល់មនុស្សគ្រប់គ្នា ដោយប្រទេសខ្លះបញ្ចេញច្រើន ហើយប្រទេសខ្លះបញ្ចេញតិច។ អង្គការស្ថិតិសកល ស្តីអំពីការបំភាយឧស្ម័នកាបូនិកពិភពលោក បានបង្ហាញថា ប្រទេសធំៗចំនួន៧ បានបំភាយប្រមាណជាពាក់កណ្តាលនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ទូទាំងពិភពលោកក្នុងឆ្នាំ២០២០ រួមមាន ប្រទេសចិន សហរដ្ឋអាម៉េរិក ប្រទេសឥណ្ឌា សហភាពអឺរ៉ុប ប្រទេសឥណ្ឌូនេស៊ី សហព័ន្ធរុស្ស៊ី និងប្រទេសប្រេស៊ីល។

## ២-ការប្រែប្រួលអាកាសធាតុ

អ្នកវិទ្យាសាស្ត្រ ផ្នែកអាកាសធាតុសកល បានបង្ហាញថា មនុស្សគឺត្រូវតែមានទំនួលខុសត្រូវទាំងអស់ ចំពោះកំណើនកម្តៅភពផែនដី ក្នុងកំឡុងពេល ប្រមាណជាងមួយរយឆ្នាំចុងក្រោយនេះ។ សកម្មភាពនានារបស់មនុស្ស គឺកំពុងតែបង្កឱ្យមានឧស្ម័នផ្ទះកញ្ចក់ច្រើន ដែលបានធ្វើឱ្យកម្តៅភពផែនដី កើនលឿនជាងពេលណាៗទាំងអស់។ សីតុណ្ហភាពជាមធ្យមនៃផ្ទៃផែនដី នាពេលបច្ចុប្បន្ននេះ គឺប្រមាណជាងមួយអង្សាសេ ក្តៅជាងទសវត្សរ៍ឆ្នាំ១៨០០ មុនពេលបដិវត្តន៍ឧស្សាហកម្ម។ សីតុណ្ហភាព នាទស្សវត្សរ៍ឆ្នាំចុងក្រោយនេះ(២០១១-២០២០) គឺក្តៅបំផុតនៅក្នុងកំណត់ត្រាពិភពលោក។ ជាទូទៅ មនុស្សជាច្រើនបានគិតថា ការប្រែប្រួលអាកាសធាតុ គឺជាការប្រែសីតុណ្ហភាពទៅក្តៅជាងពេលមុនៗ។ ជាការពិត ការប្រែប្រួលអាកាសធាតុ គឺកើតឡើងដោយសារការឡើងកម្តៅនៃភពផែនដី។ ពេលខ្លះ ពាក្យទាំងពីរនេះត្រូវគេប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកក៏ប៉ុន្តែការពិត គឺវាមិនមានន័យដូចគ្នាទាំងស្រុងនោះទេ។ ទោះបីជាមនុស្សមានទំនោរប្រើពាក្យទាំងពីរនេះ ជំនួសគ្នាក៏ដោយ ក៏ការឡើងកម្តៅភពផែនដី គឺគ្រាន់តែជាទិដ្ឋភាពមួយនៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះ[2] ពោលគឺ "ការឡើងកម្តៅភពផែនដី" សំដៅលើការកើនឡើងនៃសីតុណ្ហភាពសកល ដោយសារតែការកើនឡើងនៃកំហាប់ឧស្ម័នផ្ទះកញ្ចក់ នៅក្នុងបរិយាកាស។ ដោយឡែក "ការប្រែប្រួលអាកាសធាតុ" គឺសំដៅ

[2] https://www.usgs.gov/faqs/what-difference-between-global-warming-and-climate-change ចូលអាន ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៤

ទៅលើការផ្លាស់ប្តូរការកើនឡើងនៃវិធានការណ៍អាកាសធាតុក្នុង រយៈពេលយូរ រួមមានទឹកភ្លៀង សីតុណ្ហភាព និងលំនាំខ្យល់។ ការប្រែប្រួលអាកាសធាតុ គឺជាការប្រែប្រួលស្ថានភាពអាកាសធាតុ ដែលអាចកំណត់អត្តសញ្ញាណបាន (តាមរយៈការវិភាគស្ថិតិ) តាមរយៈការប្រែប្រួលតួលេខមធ្យម និងតួលេខអថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះ បន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទសវត្សរ៍ ឬយូរជាងនេះ[3]។

ការប្រែប្រួលអាកាសធាតុ គឺសំដៅការផ្លាស់ប្តូរគំរូអាកាសធាតុ និងរដូវដាំដុះជុំវិញពិភពលោក ប៉ុន្តែការឡើងកម្តៅភពផែនដី គឺបណ្តាលឱ្យមានការប្រែប្រួលអាកាសធាតុ ដែលបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់អាយុជីវិតនៅលើផែនដី រាប់បញ្ចូលទាំងគ្រោះរាំងស្ងួត ទឹកជំនន់ រីករាលដាល និងអាកាសធាតុក្តៅខ្លាំង។ ការប្រែប្រួលអាកាសធាតុ អាចបណ្តាលមកពីដំណើរផ្ទៃក្នុងរបស់ធម្មជាតិ(កម្លាំងជំរុញពីខាងក្រៅ) ការប្រែប្រួលរយៈពេលវែងសមាសភាពបរិយាកាសឬសកម្មភាពមនុស្ស ដូចជា ការប្រើប្រាស់ដី ការបញ្ចេញឧស្ម័នពីពេងចក្រ ជាដើម។ ម្យ៉ាងទៀត ការប្រែប្រួលអាកាសធាតុ គឺជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងសកម្មភាពមនុស្ស ដែលធ្វើឱ្យមានការផ្លាស់ប្តូរ សមាសភាពបរិយាកាសពិភពលោក និងការបន្ថែមលើការប្រែប្រួលអាកាសធាតុ ដោយសារធម្មជាតិ ត្រូវបានសង្កេតឃើញក្នុងរយៈពេលប្រហាក់ប្រហែលគ្នា។ វាក៏សំដៅលើការផ្លាស់ប្តូរ រយៈពេលវែងនៃសីតុណ្ហភាព និងលំនាំអាកាសធាតុដែរ។ ការផ្លាស់ប្តូរបែបនេះ អាចជាធម្មជាតិ ដោយសារតែការផ្លាស់ប្តូរសកម្មភាពរបស់ព្រះអាទិត្យ ឬការផ្ទុះភ្នំភ្លើងធំៗ។ ផ្ទុយទៅវិញ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៨០០មក សកម្មភាពរបស់មនុស្ស គឺជាកត្តាជំរុញដ៏សំខាន់នៃការប្រែប្រួលអាកាសធាតុ ដែលភាគច្រើនដោយសារតែការដុតឥន្ធនៈហ្វូស៊ីល ដូចជា ធ្យូងថ្ម ប្រេងឥន្ធនៈ និងឧស្ម័ន ជាដើម។

### ៣. បាតុភូតអែលនីញ៉ូ (El Niño)

អែលនីញ៉ូ គឺជាបាតុភូតនៃចរន្តទឹកក្តៅដែលកើតឡើងជាខួប នៅតាមបណ្តោយឆ្នេរខាងលិចនៃទ្វីបអាម៉េរិក ប៉ែកខាងត្បូងជារៀងរាល់បីទៅប្រាំឆ្នាំ[4]។ វាគឺជាបាតុភូតធម្មជាតិ នៃចរន្តទឹកក្តៅ ដែលបានកើតមានឡើងជាខួបនៅតំបន់មហាសមុទ្រប៉ាស៊ីហ្វិក ជាពិសេសនៅតាមបណ្តោយឆ្នេរខាងលិច នៃទ្វីបអាម៉េរិកប៉ែកខាងត្បូង។ ខ្យល់ក្តៅនៅអេក្វាទ័រ លើមហាសមុទ្រប៉ាស៊ីហ្វិក បក់ពីកើតទៅលិចហើយបាននាំខ្យល់ក្តៅទាំងនោះ ទៅប៉ែកខាងលិច ពោលគឺបក់សំដៅទៅតំបន់អាស៊ី។ បាតុភូតអែលនីញ៉ូនេះ គឺមិនត្រូវបានព្យាករណ៍ប្រាកដថា វាលេចឡើងនៅពេលណា ម៉ោងណា និងក្នុងកម្រិតខ្លាំងប៉ុណ្ណានោះទេ ប៉ុន្តែអ្វីដែលគេ

[3] ក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិភាសាខ្មែរៈ សទ្ទានុក្រម ការប្រែប្រួលអាកាសធាតុ ទំព័រទី១៨

[4] គណៈកម្មាការបច្ចេកសព្ទភូមិវិទ្យា នៃក្រុមប្រឹក្សាជាតិភាសាខ្មែរៈ សម្រេចថ្ងៃទី ២៨ តុលា ឆ្នាំ២០១៩

ធ្លាប់បានដឹងកន្លងមក គឺខ្យល់ក្តៅ (បក់ចរន្តទឹកក្តៅ) នៃបាតុភូតអែលនីញ៉ូ បានបង្កឱ្យមានគ្រោះមហន្តរាយធម្មជាតិ និងផលវិបាកអាកាសធាតុខ្លាំង ពោលគឺបានបង្កើនកម្តៅនៃភពផែនដី និងធ្វើឱ្យមានការប្រែប្រួលអាកាសធាតុខ្លាំង នៅតាមតំបន់ជាច្រើន ដូចជា តំបន់ត្រូពិកអាស៊ីអាគ្នេយ៍ ឥណ្ឌា អាហ្វ្រិក និងភាពរាំងស្ងួតហួសហេតុនៅអូស្ត្រាលី ជាដើម។

តាមការសន្និដ្ឋាន របស់អង្គការឧតុនិយមពិភពលោក ដែលបង្កប់ដោយភាពប្រាកដប្រជាស្ទើរ១០០% (កម្រិតប្រូបាប៊ីលីតេ៩៨%) បង្ហាញថា យ៉ាងហោចណាស់ក៏មានមួយឆ្នាំ ក្នុងរយៈពេលពេលប្រាំឆ្នាំខាងមុខ នឹងមានអាកាសធាតុក្តៅខ្លាំងបំផុតដែលគេមិនធ្លាប់ជួបប្រទះពីមុន។ មានន័យថា ក្នុងចំណោមប្រាំឆ្នាំខាងមុខ មានយ៉ាងហោចណាស់ក៏មួយឆ្នាំដែរ ដែលសីតុណ្ហភាពមធ្យមប្រចាំឆ្នាំនៃផ្ទៃផែនដី នឹងឡើងលើស ១.៥ អង្សាសេ បើប្រៀបនឹងកម្រិតសីតុណ្ហភាពមុនសម័យបដិវត្តន៍ឧស្សាហកម្ម។ ទាំងនេះ មិនមែនមានន័យថា ផែនដីឡើងកម្តៅលើសពីកម្មវត្ថុដែលបានកំណត់ ក្នុងកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីសឆ្នាំ២០១៥ឡើយ[5] ប៉ុន្តែទិន្នន័យនេះគឺជាសារដាស់តឿនសកលថា ពិភពលោក មានសីតុណ្ហភាពហួសកម្រិតកំណត់ (១.៥អង្សា) ម្តងម្កាលញឹកញាប់។

បាតុភូតធម្មជាតិ អែលនីញ៉ូ បូកផ្សំជាមួយឧស្ម័នផ្ទះកញ្ចក់ ដែលកើតចេញមកពីសកម្មភាពរបស់មនុស្ស នឹងរុញច្រានសីតុណ្ហភាព នៅលើផែនដីក្តៅខ្លាំងឡើងៗ ក្នុងកម្រិតមួយខ្ពស់មិនធ្លាប់មាន។ ប្រទេសអូស្ត្រាលីបានប្រកាសទុកមុនរួចហើយថា បាតុភូតអែលនីញ៉ូនឹងបណ្តាលឱ្យថ្ងៃកាន់តែក្តៅ និងស្ងួតខ្លាំង ដែលអាចបង្កគ្រោះមហន្តរាយបណ្តាលឱ្យមានភ្លើងឆេះព្រៃ។ ចំណែកជប៉ុនវិញ អះអាងថា បាតុភូតអែលនីញ៉ូ បានធ្វើឱ្យរដូវផ្ការីកនៅក្នុងប្រទេសជប៉ុន មានសីតុណ្ហភាពក្តៅខ្លាំងខុសពីប្រក្រតី។ ចំពោះអឺរ៉ុបវិញ គឺហាក់ពុំសូវទទួលផលវិបាក ពីបាតុភូតអែលនីញ៉ូដោយផ្ទាល់នោះទេ ព្រោះទ្វីបនេះទទួលឥទ្ធិពលអាកាសធាតុ ពីមហាសមុទ្រអាត្លង់ទិកច្រើនជាង។ ទោះជាយ៉ាងនេះក្តី ផលប៉ះពាល់ក៏ច្រើនសម្បើមដែរ ព្រោះមហាសមុទ្រប៉ាស៊ីហ្វិកគឺមានទំហំធំ ហើយលាតសន្ធឹងល្វឹងល្វើយប្រមាណមួយភាគបីនៃផែនដី។ មានន័យថា ឱ្យតែមានការប្រែប្រួលសីតុណ្ហភាព នៅមហាសមុទ្រ

[5] នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋាភិបាលនៃប្រទេសចំនួន១៩៥ បានយល់ព្រមអនុម័តកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការរក្សាការឡើងកម្តៅផែនដី ក្រោម ២°C។ កិច្ចព្រមព្រៀងនេះ គឺបន្តពីអនុសញ្ញារួម ដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ។ វាគឺជាលទ្ធផលនៃការចរចាអន្តរជាតិ រយៈពេលជាងពីរទសវត្សរ៍ ដែលក្រុមប្រឹក្សាវិទ្យាសាស្ត្រអន្តរជាតិ និងអង្គភាពមុនរបស់ខ្លួនបានដើរតួនាទី ជាអ្នកសម្របសម្រួលនៃសហគមន៍វិទ្យាសាស្ត្រ ដើម្បីបញ្ជាក់ពីសារៈសំខាន់នៃការសម្រេចចិត្ត ផ្អែកលើភស្តុតាងនៅក្នុងដំណើរការនយោបាយ។

ប៉ាស៊ីហ្វិក សីតុណ្ហភាពពិភពលោកនឹងត្រូវប្រែប្រួលភ្លាមៗ។ អ្វីដែលគួរឱ្យព្រួយបារម្ភជាងនេះទៀត គឺនៅពេលសីតុណ្ហភាពពិភពលោកបានកើនឡើងដោយសារបាតុភូតអែលនីញ៉ូនេះហើយ គឺវាពិបាកនឹងចុះមកត្រជាក់ដល់កម្រិតដើមវិញណាស់។ បាតុភូតអែលនីញ៉ូ តែងតែធ្វើឱ្យសីតុណ្ហភាពមធ្យមពិភពលោក មានការកើនឡើងនៅឆ្នាំបន្ទាប់។

ម្យ៉ាងទៀត នៅតំបន់ដែលទទួលឥទ្ធិពលអែលនីញ៉ូ នឹងផ្លាស់ទៅជាឥទ្ធិពលឡានីញ៉ា (La Niña) វិញយ៉ាងលឿន ជាពិសេសតំបន់ត្រូពិក។ ឡានីញ៉ា គឺជាបាតុភូតនៃការចុះត្រជាក់របស់ផ្ទៃសមុទ្រខាងលើ ដែលកើតនៅតាមបណ្តោយឆ្នេរមហាសមុទ្រប៉ាស៊ីហ្វិកនៃតំបន់ត្រូពិក នៃទ្វីបអាម៉េរិកខាងត្បូង រៀងរាល់បីទៅប្រាំឆ្នាំ[6]។ ឡានីញ៉ា គឺបាតុភូតនៃការចុះត្រជាក់ ដែលអាចប៉ះពាល់ដល់សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ នៅតំបន់ជាច្រើនជុំវិញពិភពលោក។

**រូបភាពទី២៖ ឥទ្ធិពលបាតុភូតអែលនីញ៉ូនិងឡានីញ៉ា**




ប្រភព៖ National Oceanic and Atmospheric Administration (NOAA)

## ៤. កត្តាផ្សេងៗនៃការឡើងកម្តៅផែនដី

ការកើនឡើងនៃកម្តៅផែនដី គឺមានមូលហេតុច្រើនយ៉ាងជាជាតុផ្សំ ពោលគឺក្រៅអំពីដំណើរធម្មជាតិតាមគន្លងផែនដី គឺមានជាតុផ្សំផ្សេងៗទៀត បានរួមចំណែក ដូចជា៖

- ឥន្ធនៈហ្វូស៊ីល៖ ការប្រើប្រាស់ដ៏ធំនៃឥន្ធនៈហ្វូស៊ីល គឺជាប្រភពដំបូងនៃការឡើងកម្តៅផែនដី ដោយសារការដុតធ្យូងថ្ម ប្រេង និងឧស្ម័នបង្កើតឱ្យមានកាបូនឌីអុកស៊ីត ដែលជាឧស្ម័នផ្ទះកញ្ចក់ដ៏សំខាន់បំផុតនៅក្នុងបរិយាកាស។
- ការបាត់បង់ព្រៃឈើ៖ ការធ្វើអាជីវកម្មព្រៃឈើ គឺបានរួមចំណែកក្នុងការធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ។ ដើមឈើជួយគ្រប់គ្រងអាកាសធាតុ ដោយស្រូបយកឧស្ម័នកាបូនិកពីបរិយាកាស។ នៅពេលដែលព្រៃឈើបាត់បង់ ឥទ្ធិពលវិជ្ជមាននេះ ក៏ត្រូវបាត់បង់ដែរ។
- កសិកម្មអតិផល៖ មូលហេតុមួយទៀតនៃការឡើងកម្តៅផែនដី គឺការធ្វើកសិកម្មដែលមានគោលដៅទិន្នផលខ្ពស់(បែបប្រពលវប្បកម្ម)។កសិកម្មបែបនេះ បានប្រើប្រាស់នូវសារជាតុជាច្រើន ដើម្បីបង្កើន ការពារ គុណភាពដីសម្រាប់ដំណាំ និងរុក្ខជាតិ ហើយបានធ្វើឱ្យមានបំភាយឧស្ម័នផ្ទះកញ្ចក់ច្រើនៗ សកម្មភាពកសិកម្ម និងផលិតកម្មបសុសត្វ បានបញ្ចេញបរិមាណដ៏ច្រើន

[6] គណៈកម្មាការបច្ចេកសព្ទភូមិវិទ្យា នៃក្រុមប្រឹក្សាជាតិភាសាខ្មែរៈ សម្រេចថ្ងៃទី ២៨ តុលា ឆ្នាំ២០១៩

ទៅក្នុងបរិយាកាស ដែលជាកត្តាបង្កឱ្យមានជាតិពុលច្រើននៅក្នុងបរិយាកាស។

- ការចោលកាកសំណល់៖ វិធីសាស្ត្រគ្រប់គ្រងកាកសំណល់ ដូចជាកន្លែងចាក់សំរាម និងការដុតបំផ្លាញ និងឧស្ម័នពុល រួមទាំងឧស្ម័នមេតាន ដែលត្រូវបានបញ្ចេញទៅក្នុងបរិយាកាស ដី និងផ្ទៃទឹក សុទ្ធតែបានរួមចំណែកដល់ការបង្កើនឥទ្ធិពលឧស្ម័នផ្ទះកញ្ចក់។

## ៥- ផលប៉ះពាល់នៃការឡើងកម្ដៅផែនដី

ការកើនឡើងនៃកម្ដៅផែនដី គឺបណ្ដាលឱ្យមានការប្រែប្រួលអាកាសធាតុ ដែលបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដល់អាយុជីវិតនៅលើផែនដី ក្នុងទម្រង់ជាច្រើន ដូចជារីករាលដាលនៃទឹកជំនន់ ខ្យល់ព្យុះ និងអាកាសធាតុក្ដៅខ្លាំង ជាដើម។ ជាងនេះទៅទៀត ការកើនកម្ដៅផែនដី បានធ្វើឱ្យប្រជាជនមួយចំនួន នៅក្នុងប្រទេសនានា ទូទាំងសាកលលោក ជួបបញ្ហាលំបាកយ៉ាងខ្លាំង ជាពិសេស កង្វះទឹកសម្រាប់បង្កបង្កើនផល ពោលគឺសម្រាប់ផ្គត់ផ្គង់វិស័យកសិកម្ម។ ប្រការនេះបានជំរុញឱ្យតម្លៃស្បៀងអាហារ នៅប្រទេសជាច្រើនឡើងថ្លៃកាន់តែខ្លាំង ជាហេតុធ្វើឱ្យប្រជាជនមូលដ្ឋាន ប្រឈមនឹងការលំបាកក្នុងការចិញ្ចឹមជីវិត។ ការកើនឡើងកម្ដៅផែនដី បានធ្វើឱ្យស្ថានភាព បរិស្ថាន កាន់តែអាក្រក់ជាងមុន ហើយឱកាសការងារ ក៏មិនជាប់លាប់ ដោយសារកម្ដៅកើនឡើងខ្ពស់នៅក្នុងប្រទេស។ ស្ថានភាពការងារកាន់តែលំបាកខ្លាំង ជាពិសេស ពាក់ព័ន្ធនឹងការថយចុះនៃទិន្នផលកសិកម្ម។ ការកើនឡើងនៃសីតុណ្ហភាព និងការប្រែប្រួលអាកាសធាតុ រំខានដល់ប្រព័ន្ធអេកូឡូស៊ីដោយបានកែប្រែលក្ខខណ្ឌ និងវដ្ដនៃការបន្តពូជរបស់រុក្ខជាតិ រួមទាំងការផ្លាស់ប្ដូរទម្លាប់រស់នៅ និងវដ្ដនៃការធ្វើចំណាកស្រុករបស់សត្វ។

បឹងទឹកកក និងផែនទឹកកកនៅតំបន់ប៉ូលកំពុងរលាយយ៉ាងច្រើន ហើយបង្កើនកម្ពស់ទឹកសមុទ្រក្នុងកម្រិតមួយ ដែលមិនធ្លាប់មានពីមុន ដោយសារកំណើនកម្ដៅផែនដី។ បរិមាណដ៏ច្រើននៃឧស្ម័នកាបូនិក ដែលចាប់យកដោយមហាសមុទ្រ បានធ្វើឱ្យសមុទ្រមានជាតិអាស៊ីតខ្ពស់ អាចនាំទៅដល់ការប្រែប្រួលនៃពពួកផ្កាថ្ម មច្ឆា និងសត្វសំបកសមុទ្រផ្សេងៗ(លៀស គ្រំ ខ្យង ខ្ចៅ) ជាដើម។ ជាងនេះទៀត ការកើនកម្ដៅផែនដី បានអង្រួនតុល្យភាពសង្គម សុខភាព និងភូមិសាស្ត្រនយោបាយរួចទៅហើយ នៅក្នុងផ្នែកជាច្រើននៃពិភពលោក។ កង្វះខាតធនធាន ដូចជាអាហារ និងថាមពល តាមរយៈការកើនឡើងកម្ដៅផែនដី ក៏ អាចបង្កឱ្យមានជម្លោះដែរ។ ការកើនឡើងនៃកម្រិតទឹកសមុទ្រ និងទឹកជំនន់កំពុងបង្កឱ្យមានការធ្វើចំណាកស្រុក របស់ប្រជាពលរដ្ឋនៅតាមរដ្ឋមួយចំនួន ហើយចំនួនជនភៀសខ្លួនខាងអាកាសធាតុ ក៏មានកំណើនកាន់តែច្រើនដែរ។

ព្រះរាជាណាចក្រកម្ពុជា ក៏បានទទួលរងឥទ្ធិពលនៃការកើនកម្ដៅផែនដី និងការប្រែប្រួលអាកាសធាតុ ដូចប្រទេសមួយចំនួនដែរ ដោយបានបង្កឱ្យតំបន់មួយចំនួនក្ដៅហួតហែង រហូត

ដល់ខ្វះទឹកធ្វើស្រែ។ ជាក់ស្ដែង នៅក្នុងរដូវប្រាំង ឆ្នាំ២០២៤នេះ កម្ពុជាទទួលរងសីតុណ្ហភាពក្ដៅ ហើយទទួលបានបរិមាណទឹកភ្លៀង តិចជាងឆ្នាំ ២០២៣កន្លងទៅ ដោយសារតែបាតុភូតសកល អែលនីញ៉ូ។ ទឹកទន្លេមានកម្រិតទាប មិនអាចហូរ ចូលសព្វ គ្រប់អាង បឹងបួ និងព្រែកធម្មជាតិមួយ ចំនួន ដែលនៅអមសងខាងទន្លេមេគង្គលើ ទន្លេ មេគង្គក្រោម ទន្លេបាសាក់ និងទន្លេសាប បាន ច្រើនទេ។ លក្ខខណ្ឌនៃអាកាសធាតុបែបនេះ នឹង ធ្វើឱ្យទឹកដែលមាន នៅក្នុងអាងនៃផ្លូវទឹក ទាំងឡាយ ឆាប់រីងហួត ឬរីងស្ងួត បានយ៉ាងឆាប់ រហ័ស។ សីតុណ្ហភាពកាន់តែឡើងខ្ពស់ កង្វះទឹក ភ្លៀង និងកម្រិតជាតិប្រៃកាន់តែកើនឡើង ជា ពិសេសតំបន់ដីសណ្ដទន្លេ ព្រែក ស្ទឹង ជាប់នឹង ឆ្នេរសមុទ្រ បានបង្កបញ្ហាប្រឈមជាច្រើន តាមរយៈ លទ្ធភាពស្រោចស្រពដំណាំមានតិចតួច រួមទាំង ភាពស្ងួតហួតហែងនៃផ្ទៃដី សម្រាប់វិស័យកសិកម្ម ផងដែរ។

តាមការព្យាករណ៍ របស់ក្រសួងធនធាន ទឹក និងឧតុនិយម នៃព្រះរាជាណាចក្រកម្ពុជា បាន បង្ហាញថា ចន្លោះពីខែមេសា ដល់ ខែឧសភា ឆ្នាំ ២០២៤នេះ កម្ដៅបានកើនឡើងខ្លាំង ជាមួយនឹង សីតុណ្ហភាព៣៨អង្សាសេជាមធ្យម ប៉ុន្តែតំបន់ខ្លះ អាចកើនឡើងដល់៤៣អង្សាសេ។ ក្នុងពេលដែល មានកម្ដៅកើនឡើង បរិមាណទឹកភ្លៀងកក់ខែ ក៏ ធ្លាក់ក្នុងចំនួនតិចតួចជាងឆ្នាំកន្លងទៅដែរ ហើយ បាតុភូតផ្គររន្ទះ និងខ្យល់កន្ត្រាក់ ក៏អាចកើតមាន ច្រើនកន្លែងផងដែរ។ កម្ដៅ ដែលបានកើនឡើង នឹងអូសបន្លាយក្នុងរដូវប្រាំង គឺបណ្ដាលមកពី បាតុភូតសកល អែលនីញ៉ូ និងបាតុភូតសកល ឡានីញ៉ា (អែនសូ)។

## សេចក្ដីសន្និដ្ឋាន

ការឡើងកម្ដៅផែនដី គឺជាការកើនឡើង កម្ដៅរយៈពេលវែងនៃសីតុណ្ហភាពទាំងមូលរបស់ ភពផែនដី។ ទោះបីជានិន្នាការនៃការឡើងកម្ដៅ នេះ បានបន្តជាយូរយារណាស់មកហើយក៏ដោយ ប៉ុន្តែល្បឿនរបស់វាបានកើនឡើងយ៉ាងខ្លាំង ក្នុង រយៈពេល ប្រមាណជាងមួយសតវត្សរ៍ចុងក្រោយ នេះ ដោយសារតែការឆេះឥន្ធនៈហ្វូស៊ីល នៃ កំណើនសកម្មភាពផ្សេងៗរបស់មនុស្ស។ ផែនដី កំពុងតែកើនកម្ដៅនៅក្នុងល្បឿនមួយ គួរឱ្យព្រួយ បារម្ភណ៍ ជាពិសេសគឺការកើនឡើងនៃឧស្ម័នផ្ទះ កញ្ចក់ បង្កឡើងដោយសកម្មភាពរបស់មនុស្ស ដែលនាំឱ្យកើតមានវិបត្តិសុខភាព អេកូឡូស៊ី និង មនុស្សធម៌ ជាដើម។ ការឡើងកម្ដៅនៃភពផែនដី អាចបង្កនូវផលវិបាកធ្ងន់ធ្ងរ ទាំងចំពោះបរិស្ថាន សុខភាព និងសេដ្ឋកិច្ចរបស់ពិភពលោក។ នៅ ពេលដែលសីតុណ្ហភាពកើនឡើង ប្រទេសដែល មានសីតុណ្ហភាពក្ដៅស្រាប់ នឹងកាន់តែក្ដៅខ្លាំង ថែមទៀត។ ចំណែកកន្លែងខ្លះទៀត ដែលធ្លាប់តែ មានសីតុណ្ហភាពត្រជាក់ ហើយមានធ្លាក់ព្រិល ក៏ លែងធ្លាក់ព្រិល ឬធ្លាក់តិចតួច។ ការបាត់បង់ លំនឹងប្រព័ន្ធអេកូឡូស៊ី ដោយតំបន់ខ្លះគ្មានភ្លៀង សោះ រហូតបង្កទៅជាគ្រោះរាំងស្ងួត។ ចំណែក កន្លែងខ្លះទៀត មានភ្លៀងខ្លាំងហួសហេតុ បង្កទៅ

ជាទឹកជំនន់ ជន់លិចខូចដំណាំ និងផ្ទះសម្បែង ជាដើម។

សរុបជារួម តាមសម្មតិកម្មនានានៃការរកឃើញរបស់ក្រុមអ្នកវិទ្យាសាស្ត្រ បានគូសបញ្ជាក់យ៉ាងច្បាស់ថា ការប្រែប្រួលអាកាសធាតុនិងការកើនឡើងនៃកម្ដៅផែនដី ជាងមួយសតវត្សរ៍ចុងក្រោយនេះ គឺបណ្ដាលមកពីឥរិយាបថ និងទង្វើរបស់មនុស្សចំពោះធម្មជាតិទាំងស្រុង។ ផលវិបាកធំៗ ដែលបានបង្កឡើងពីការប្រែប្រួលអាកាសធាតុនេះ គឺមានសភាពធ្ងន់ធ្ងរឡើងៗ ហើយអ្នកដែលរងគ្រោះខ្លាំងជាងគេ គឺប្រជាជននៅតាមបណ្ដាប្រទេសក្រីក្រ ព្រោះថា ប្រទេសទាំងអស់នោះ មិនមានទុនបម្រុង និងបច្ចេកវិទ្យាខ្ពស់ៗ ដូចជាប្រទេសអ្នកមាន ដើម្បីយកមកទប់ទល់នឹងផលវិបាកអស់ទាំងនេះទេ។

អ្វីដែលមនុស្ស គួរបន្តចូលរួមដោះស្រាយវិបត្តិ ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដើម្បីអាចផ្ដល់ជាអត្ថប្រយោជន៍សេដ្ឋកិច្ចនិងធ្វើឱ្យជីវិតប្រសើរឡើង គឺការកាត់បន្ថយការបំភាយឧស្ម័ន ការសម្របខ្លួនទៅនឹងផលប៉ះពាល់អាកាសធាតុ និងការកែតម្រូវដែលមានហិរញ្ញប្បទាន។ ការប្ដូរប្រព័ន្ធថាមពលពីឥន្ធនៈហ្វូស៊ីលទៅជាថាមពលកកើតឡើងវិញ ដូចជាពន្លឺព្រះអាទិត្យ ឬខ្យល់ អាចនឹងកាត់បន្ថយការបំភាយឧស្ម័នដែលជំរុញឱ្យមានការប្រែប្រួលអាកាសធាតុ។ វិធីកាត់បន្ថយការឡើងកំដៅផែនដី មានដំណោះស្រាយច្រើន ដែលគួរពិចារណា និងអនុវត្តន៍ជាច្រើន ដូចជា៖

- ការផលិតថាមពលស្អាត គឺកត្តាចាំបាច់ក្នុងការជួយដល់ដំណើរការ កាត់បន្ថយកំណើនកម្ដៅផែនដី។

- ការលើកកម្ពស់ ដល់ដំណើរការដឹកជញ្ជូនសាធារណៈ ព្រោះវាពិតជាអាចជួយកាត់បន្ថយការបំភាយឧស្ម័នកាបូនិក ក្នុងបរិយាកាស ពោលគឺអាចប្រយុទ្ធប្រឆាំងនឹងការឡើងកម្ដៅផែនដី។

- ការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិឱ្យកាន់តែប្រសើរឡើង ដូចជាការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ការធ្វើឱ្យកសិកម្មកាន់តែបៃតង និងមានប្រសិទ្ធភាព។

- ការប្រកាន់យកទម្លាប់ នៃការប្រើប្រាស់ប្រកបដោយទំនួលខុសត្រូវ គឺមានសារៈសំខាន់ណាស់ មិនថាទាក់ទងទៅនឹងផលិតផលអ្វីនោះទេ ពោលគឺ ចុងក្រោយនៅតែអាចកែច្នៃឡើងវិញបាន និងជាភាពចាំបាច់បំផុត សម្រាប់ដោះស្រាយបញ្ហាកាកសំណល់ផងដែរ។

# គន្ថនិទ្ទេស


- *ក្រសួងបរិស្ថាន: សទ្ទានុក្រមប្រែប្រួលអាកាសធាតុ ឆ្នាំ២០២០*
- *ក្រុមប្រឹក្សាជាតិភាសាខ្មែរ: សទ្ទានុក្រមបច្ចេកសព្ទភូមិវិទ្យា និងប្រវត្តិវិទ្យា ឆ្នាំ២០១៨*
- *កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពី ការរក្សាការឡើងកម្តៅផែនដីក្រោម ២អង្សាសេ អនុម័ត នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥*
- *ក្រសួងអប់រំ យុវជន និងកីឡា: ផែនដី និងបរិស្ថានវិទ្យា ថ្នាក់ទី១២ ឆ្នាំ២០១១*
- *ក្រសួងអប់រំ យុវជន និងកីឡា: ផែនដី និងបរិស្ថានវិទ្យា ថ្នាក់ទី១០ ឆ្នាំ២០១០*
- https://education.nationalgeographic.org/resource/global-warming
- https://www.britannica.com/science/global-warming
- https://www.merriam-webster.com/dictionary/global%20warming
- https://www.nrdc.org/stories/global-warming-101#warming
- https://www.un.org/en/climatechange/what-is-climate-change
- https://www.usgs.gov/faqs/what-difference-between-global-warming-and-climate-change
- https://www.worldometers.info/co2-emissions/co2-emissions-by-country

# ជំនាញសង្គមជាមូលដ្ឋានគ្រឹះ នៃការអភិវឌ្ឍបុគ្គល

ដោយៈ **បណ្ឌិត ទុយ យូឃីម**
*អនុប្រធាននាយកដ្ឋានប្រវត្តិសាស្ត្រនិងនយោបាយ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*បុគ្គលម្នាក់ៗរស់នៅក្នុងសង្គមចាំបាច់ត្រូវមានអន្តរកម្មក្នុងសង្គម។ ការរស់នៅរបស់យើងក្នុងសង្គមត្រូវមានការប្រាស្រ័យទាក់ទង និងជំនាក់ទំនងជាមួយអ្នកដទៃ។ ប្រសិនបើយើងមិនមានការប្រាស្រ័យទាក់ទង និងទំនាក់ទំនងជាមួយអ្នកដទៃទេ យើងជាមនុស្សក្រៅសង្គម ចូលជំនុំនិងគេមិនចុះ គ្មានមិត្តភ័ក្តិ គ្មានអ្នកយល់ចិត្ត ពិបាកក្នុងការស្វែងរកការងារធ្វើ ជាពិសេសក្នុងការធ្វើអន្តរកម្មដោយជោគជ័យនៅក្នុងសង្គម។*

*ដើម្បីទទួលបានភាពជោគជ័យក្នុងការធ្វើអន្តរកម្មសង្គម យើងគប្បីត្រូវមានជំនាញសង្គម។ ជំនាញសង្គមយើងអាចរាប់បញ្ចូលទាំងការប្រាស្រ័យទាក់ទងគ្នាដោយពាក្យសំដីនិងមិនមែនពាក្យសំដី ដូចជា ការនិយាយ ការធ្វើកាយវិការ ទឹកមុខ និងការប្រើទំនាក់ទំនងដោយភ្នែកជាដើម។ មនុស្សម្នាក់មានជំនាញសង្គមខ្លាំង ប្រសិនបើពួកគេមានចំណេះដឹងអំពីរបៀបប្រព្រឹត្តក្នុងស្ថានភាពសង្គម ហើយយល់ទាំងរបៀបនៃការសរសេរនិងបង្កប់ន័យ នៅពេលមានទំនាក់ទំនងជាមួយអ្នកដទៃ។*

*ជំនាញសង្គម ជាជំនាញដែលជួយសម្រួលដល់ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងជាមួយអ្នកដទៃក្នុងបរិយាកាសណាមួយ។ ជំនាញសង្គមមានដូចជា ការទំនាក់ទំនង ការយល់ចិត្ត អន្តរបុគ្គល និងជំនាញស្តាប់ មានប្រយោជន៍មិនត្រឹមតែសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ជីវិតអាជីពរបស់យើងទៀតផង។ នៅកន្លែងធ្វើការ ជំនាញទាំងនេះអាចជាទិដ្ឋភាពសំខាន់នៃអន្តរកម្មបុគ្គលិក ការធ្វើផែនការ និងការសហការ។*

*ជំនាញសង្គមមានសារៈសំខាន់ក្នុងការធ្វើឱ្យបុគ្គលម្នាក់មាន និងរក្សាទំនាក់ទំនងវិជ្ជមានជាមួយអ្នកដទៃ។ ជំនាញទាំងនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើត និងរក្សាមិត្តភាព។ អន្តរកម្មសង្គមមិនតែងតែដំណើរការដោយរលូនទេ ហើយបុគ្គលម្នាក់*

ត្រូវមានលទ្ធភាពអនុវត្តយុទ្ធសាស្ត្រសមស្រប ដូចជាការដោះស្រាយបញ្ហា នៅពេលមានការលំបាកក្នុងអន្តរកម្មកើតឡើង។ វាក៏មានសារៈសំខាន់ផងដែរ សម្រាប់បុគ្គលម្នាក់ៗក្នុងការមាន «ការយល់ចិត្ត» (ពោលគឺ អាចដាក់ខ្លួនអ្នកទៅក្នុងអារម្មណ៍របស់អ្នកដទៃ និងទទួលស្គាល់អារម្មណ៍របស់ពួកគេ) ព្រោះវាអនុញ្ញាតឱ្យពួកគេឆ្លើយតបក្នុងការយល់ដឹង និងការយកចិត្តទុកដាក់ចំពោះអារម្មណ៍របស់អ្នកដទៃ។

***តើជំនាញសង្គមជាអ្វី?***

## ១- ជំនាញសង្គម

ជំនាញសង្គម គឺជាសមត្ថភាពណាមួយដែលសម្របសម្រួលដល់អន្តរកម្ម និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដែលច្បាប់ និងទំនាក់ទំនងសង្គម ត្រូវបានបង្កើតទំនាក់ទំនង និងផ្លាស់ប្តូរ តាមរយៈពាក្យសម្តី និងមិនមែនពាក្យសម្តី។ ដំណើរការនៃការរៀនជំនាញទាំងនេះ ត្រូវបានគេហៅថា ជំនាញសង្គម។ កង្វះជំនាញបែបនេះអាចបង្កឱ្យមានភាពតានតឹងក្នុងសង្គម។[១]

***ដើម្បីឱ្យជំនាញសង្គមមានភាពស្ទាត់ជំនាញ តើយើងគួរបណ្តុះមនុស្សក្នុងវ័យណា ព្រោះអ្វី?***

## ២- ជំនាញសង្គមសម្រាប់កុមារ

ជំនាញសង្គមគួរត្រូវបានបណ្តុះបណ្តាលមនុស្សតាំងពីកុមារភាព។ ព្រោះកុមារភាព ជាវ័យមួយដែលត្រូវរៀនសូត្រ និងទទួលបាននូវបទពិសោធន៍ពីអ្វីដែលមនុស្សធំបានធ្វើ។ មនុស្សម្នាក់ៗមានលក្ខណៈបុគ្គល សមត្ថភាព និងបញ្ហាប្រឈមដែលកើតចេញពីការប៉ះទង្គិច ការរៀនសូត្រ និងការអភិវឌ្ឍខុសៗគ្នា។ ទាំងនេះបង្ហាញថា ការច្នៃប្រឌិតរចនាបថ ការយល់ដឹង ការលើកទឹកចិត្ត និងសមត្ថភាពក្នុងការដំណើរការព័ត៌មានទំនាក់ទំនង និងការទាក់ទងនឹងអ្នកដទៃ មានភាពខុសគ្នារវាងបុគ្គលម្នាក់ៗនៅក្នុងសង្គម។

ទ្រឹស្តីនៃការអភិវឌ្ឍការយល់ដឹងរបស់លោក *ហ្សង់ ព្យាហ្សេត* (Jean Piaget) ដែលជាចិត្តវិទូជនជាតិស្វីស ណែនាំថា ភាពវៃឆ្លាតរបស់កុមារឆ្លងកាត់ការផ្លាស់ប្តូរនៅពេលពួកគេធំឡើង។ ការអភិវឌ្ឍការយល់ដឹងចំពោះកុមារគឺមិនត្រឹមតែទាក់ទងទៅនឹងការទទួលបានចំណេះដឹងប៉ុណ្ណោះទេ កុមារត្រូវកសាង ឬអភិវឌ្ឍគំរូផ្លូវចិត្តនៃពិភពលោកដែលនៅជុំវិញពួកគេ។ លោកបានសន្និដ្ឋានថា ការអភិវឌ្ឍការយល់ដឹងចំពោះកុមារ ត្រូវឆ្លងកាត់ដំណាក់កាលចំនួនបួននៃសមត្ថភាពក្នុងការយល់ដឹង។ លោកបានសន្មត់ថា កុមារមិនអាច

---

[១] https://childdevelopment.com.

មានសមត្ថភាពគិតគូរសមហេតុផលរហូតដល់ពួកគេមានអាយុច្រើនជាង១១ឆ្នាំ ដូច្នេះ កុមារតូចៗត្រូវការបង្រៀនដោយប្រើវត្ថុ និងឧទាហរណ៍ជាក់ស្តែង។ ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា ការផ្លាស់ប្តូរដូចជា ពីគំនិតមូលដ្ឋាន ទៅជាគំនិតសមហេតុសមផលមិនមានកើតឡើងក្នុងពេលតែមួយនៅក្នុងគ្រប់វិស័យឡើយ។

លោក ***វីហ្គូតស្គី*** (Vygotsky) បានអះអាងថា អន្តរកម្មសង្គមមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍការយល់ដឹង។ លោក ***វីហ្គូតស្គី***ជឿជាក់ថាការរៀនសូត្ររបស់កុមារតែងតែកើតឡើងនៅក្នុងបរិបទសង្គមដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរបស់អ្នកដែលមានចំណេះដឹងជាង។[២]

ដើម្បីឱ្យកុមារមានការប្រាស្រ័យទាក់ទងនិងទំនាក់ទំនងល្អ និងមានប្រសិទ្ធភាព កុមារគួរត្រូវបានអភិវឌ្ឍជំនាញសង្គមមួយចំនួនរួមមាន៖[៣]

***ការស្តាប់ដោយយកចិត្តទុកដាក់៖*** ការស្តាប់អ្នកដទៃ គឺជាគន្លឹះក្នុងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ កុមារត្រូវរៀនស្តាប់អ្នកដទៃដោយយកចិត្តទុកដាក់ ដោយមិនមានការរំខាន ឬធ្វើការវិនិច្ឆ័យពួកគេទេ។ ពួកគេត្រូវផ្តល់ការយកចិត្តទុកដាក់ពេញលេញ ជាជំហានមួយដើម្បីអនុវត្តការស្តាប់ដោយយកចិត្តទុកដាក់ និងបង្រៀនពួកគេឱ្យយកចិត្តទុកដាក់ពីអ្វីមួយដែលពួកគេកំពុងធ្វើ ហើយធ្វើដោយមានទំនាក់ទំនងដោយភ្នែក ដែលនេះនឹងធានាថា ពួកគេកំពុងផ្តល់ការយកចិត្តទុកដាក់ពេញលេញរបស់ពួកគេ និងព្យាយាមស្វែងយល់ពីការសន្ទនា។

***ការយល់ចិត្ត៖*** ជាសមត្ថភាពក្នុងការយល់ និងចែករំលែកនូវអ្វីដែលអ្នកដទៃមានអារម្មណ៍។ កុមារត្រូវរៀនស្គាល់ និងឆ្លើយតបទៅនឹងអារម្មណ៍របស់អ្នកដទៃក្នុងវិធីដែលមានចិត្តមេត្តា។យើងអាចជួយដល់សុខុមាលភាព និងសុខភាពផ្លូវចិត្តរបស់កុមារបាន ដោយការបង្រៀនអំពីការយល់ចិត្ត ការអាណិតអាសូរ សេចក្តីសប្បុរស និងសតិបញ្ញា។ ការធ្វើឱ្យកុមារ និងយុវជនដែលមានចិត្តមេត្តា ដើម្បីត្រៀមខ្លួនប្រឈមមុខនឹងបញ្ហានានារបស់ពិភពលោក នឹងផ្តល់អត្ថប្រយោជន៍ដល់សង្គមផងដែរ។

***កិច្ចសហប្រតិបត្តិការ៖*** ជាសមត្ថភាពក្នុងការធ្វើការជាមួយអ្នកដទៃ ឆ្ពោះទៅរក

---

[២] https://www.structural-learning.com/post/jean-piagets-theory-of-cognitive-development-and-active-classrooms

[៣] https://www.euroschoolindia.com/blogs/10social-skills-children-must-develop/

គោលដៅរួមមួយ។ កុមារត្រូវរៀនធ្វើការជាមួយអ្នកដទៃ សម្របសម្រួល និងដោះស្រាយបញ្ហាក្នុងលក្ខណៈវិជ្ជមាន។ នៅពេលពួកគេរៀនអំពីសិល្បៈនៃកិច្ចសហប្រតិបត្តិការ ពួកគេដឹងពីសារៈសំខាន់ និងតម្លៃនៃការធ្វើការងារជាក្រុម ហើយបង្ហាញពីការអត់ធ្មត់ក្នុងពេលមានបញ្ហា។

***ការគោរព៖*** ការគោរព គឺជាមូលដ្ឋានគ្រឹះដ៏ល្អនៃទំនាក់ទំនងទាំងអស់។ យើងអាចនិយាយបានថា កុមារមានជំនាញក្នុងការគោរពអ្នកដទៃ នៅពេលដែលពួកគេអាចប្រព្រឹត្តចំពោះអ្នកដទៃដោយចិត្តសប្បុរស និង មេត្តា ដោយមិនគិតពីភាពខុសគ្នារបស់ពួកគេឡើយ។ នៅពេលដែលយើងទទួលយកនរណាម្នាក់តាមរបៀបដែលពួកគេមាន ហើយដោយគ្មានការផ្លាស់ប្តូរណាមួយ នោះជាទង្វើរបស់យើងក្នុងការគោរពដល់ពួកគេ។ ការគោរព គឺជាអ្វីដែលយើងរៀន ហើយវាមិនមានមកជាមួយយើងពីធម្មជាតិឡើយ។

***ការប្រាស្រ័យទាក់ទង៖*** ជាគន្លឹះនៃទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ ដើម្បីអភិវឌ្ឍជំនាញសង្គមដល់កុមារ ពួកគេត្រូវរៀនបង្ហាញខ្លួនឱ្យច្បាស់ និងស្តាប់អ្នកដទៃដោយយកចិត្តទុកដាក់។ ជំនាញទំនាក់ទំនងល្អ ជួយយើងអភិវឌ្ឍ និងរក្សាទំនាក់ទំនងជាមួយអ្នកដែលនៅជុំវិញយើងបានល្អ។ ដូច្នេះ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព អនុញ្ញាតឱ្យកុមារបង្កើតចំណងដ៏រឹងមាំជាមួយមិត្តភ័ក្តិ និងគ្រូ ដែលនាំឱ្យពួកគេមានអារម្មណ៍ថា ពួកគេមានការគាំទ្រ និងមានទំនុកចិត្ត។

***ទំនួលខុសត្រូវ៖*** ជាសមត្ថភាពក្នុងការទទួលយកភាពជាម្ចាស់នៃសកម្មភាព និងការសម្រេចចិត្ត។ កុមារត្រូវរៀនទទួលខុសត្រូវចំពោះអាកប្បកិរិយា ការប្តេជ្ញាចិត្ត និងកាតព្វកិច្ចរបស់ពួកគេ។ វាមានន័យថា ពួកគេត្រូវរៀនឱ្យមានភាពជឿជាក់ បង្កើតជម្រើសល្អ និងទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ។ យើងអាចនិយាយបានថា កុមារបង្ហាញជំនាញដែលមានទំនួលខុសត្រូវល្អ នៅពេលដែលពួកគេចេះមើលថែសុខុមាលភាពរបស់អ្នកដទៃ។

***ការគ្រប់គ្រងខ្លួនឯង៖*** ជាសមត្ថភាពក្នុងការគ្រប់គ្រងអារម្មណ៍ និងកម្លាំងចិត្តរបស់មនុស្សម្នាក់ៗ។ កុមារត្រូវរៀនគ្រប់គ្រងអារម្មណ៍ និងការជំរុញរបស់ពួកគេ ហើយធ្វើការសម្រេចចិត្តដោយការគិតគូរ។ ឧទាហរណ៍មួយចំនួននៃការអនុវត្តការគ្រប់គ្រងខ្លួនឯង កុមារអាចធ្វើអ្វីមួយជំនួសឱ្យការធ្វើអ្វីមួយទៀតដែលគេចង់បង្រៀនកុមារឱ្យចេះរង់ចាំ កុំឱ្យអ្វីទៅតាមការស្នើសុំរបស់គេ ដូចជា គឺការញ៉ាំអ្វីមួយ ជំនួសឱ្យការញ៉ាំអ្វីមួយផ្សេងទៀត, ធ្វើកិច្ចការផ្ទះមុនពេលលេង ឬចំណាយពេលគិតបន្តិច ហើយសម្រាកមុនពេលនិយាយជាមួយមិត្តដែលធ្វើឱ្យអ្នកខកចិត្ត។

***ការដោះស្រាយបញ្ហា៖*** ជាសមត្ថភាពក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈម ឬជម្លោះ។ កុមារត្រូវរៀនកំណត់បញ្ហា បំផុសគំនិតដោះស្រាយ និងវាយតម្លៃប្រសិទ្ធភាពរបស់ពួកគេ។ នេះគឺជាជំនាញជីវិតដ៏សំខាន់មួយសម្រាប់កុមារ ព្រោះវាអនុញ្ញាតឱ្យពួកគេធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង និងមានសុខភាពល្អនៅក្នុងជីវិតរបស់ពួកគេនាអនាគត។ នៅពេលដែលកុមារត្រូវបានអនុញ្ញាតឱ្យដោះស្រាយបញ្ហាដោយខ្លួនឯង ពួកគេនឹងមានទំនុកចិត្ត មានភាពរីករាយ កាន់តែមានទំនុកចិត្ត និងមានឯករាជ្យកាន់តែច្រើនជាមុន។ ពួកគេក៏នឹងមិនមានអារម្មណ៍តានតឹង ឬបាក់ទឹកចិត្ត ដោយសារភាពគ្មានប្រសិទ្ធភាពរបស់ពួកគេដែរ។

***ការអះអាង៖*** ជាសមត្ថភាពក្នុងការពឹងលើខ្លួនឯងប្រកបដោយការគោរព និងទំនុកចិត្ត។ កុមារត្រូវតែរៀនបង្ហាញខ្លួនឯងតាមរបៀបត្រឹមត្រូវ នេះរួមបញ្ចូលទាំងតម្រូវការការចង់បាន និងព្រំដែនរបស់ពួកគេតាមរបៀបច្បាស់លាស់ និងមានអំណះអំណាងគ្រប់គ្រាន់។ វាបង្ហាញថា កុមារមានការអះអាងនៅពេលដែលពួកគេអាចធ្វើបាន និងឆន្ទៈក្នុងការក្រោកឈរឡើងដើម្បីផលប្រយោជន៍របស់ពួកគេ និងបង្ហាញពីគំនិត និងអារម្មណ៍របស់ពួកគេ វាបង្ហាញថា ពួកគេមានការអះអាងច្បាស់លាស់ ។ វាជួយកុមារប្រាស្រ័យទាក់ទងជាមួយអ្នកដទៃក្នុងលក្ខណៈផ្ទាល់ និងស្មោះត្រង់ ដោយមិនមានចេតនាធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់អ្នកណាម្នាក់។

***ភាពបត់បែន៖*** ជាសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរស្ថានភាព និងទស្សនៈផ្សេងៗគ្នារបស់មនុស្សក្នុងសង្គម។ វាជាផ្នែកនៃការអភិវឌ្ឍជំនាញសង្គម កុមារត្រូវតែត្រៀមខ្លួនទទួលយកការផ្លាស់ប្តូរ រៀនបើកចិត្តទូលាយ និងមានឆន្ទៈពិចារណាគំនិត និងទស្សនៈថ្មីៗ។ វាមានសារៈសំខាន់ណាស់ក្នុងការបង្រៀនកុមារនៅក្នុងជីវិតដំបូងថា ជីវិតមិនប្រាកដប្រជា ហើយផែនការ និងវិធីនៃដំណើរជីវិតនឹងមិនស្ថិតស្ថេរឡើយ។ ក្នុងស្ថានភាពបែបនេះ ប្រសិនបើកុមារចេះបត់បែន វាជួយឱ្យពួកគេសម្របខ្លួនបានលឿន។

ដូច្នេះ គ្រួសារ សាលារៀន សង្គម ត្រូវផ្តោតលើសារៈសំខាន់ និងអត្ថប្រយោជន៍នៃការអភិវឌ្ឍជំនាញសង្គមសម្រាប់កុមារ ហើយក៏ត្រូវដឹងថា ជំនាញសង្គមជួយកុមារបង្កើតទំនាក់ទំនងវិជ្ជមាន មានការសន្ទនា អភិវឌ្ឍភាសាកាយវិការ សហការ ចែករំលែក និងសូម្បីតែលេងជាមួយគ្នាក៏បានល្អ និងមានប្រសិទ្ធភាពដែរ។ យើងលើកទឹកចិត្តកុមារឱ្យអនុវត្តជំនាញសង្គមដែលបានរៀបរាប់ខាងលើ ជាផ្នែកនៃទម្លាប់ប្រចាំថ្ងៃរបស់ពួកគេ។ កុមារដែលមានជំនាញសង្គមល្អ ជារឿយៗត្រូវបានគេដឹងថា មានសមត្ថភាពផ្លូវចិត្ត

ប្រសើរឡើង និងសមត្ថភាពយល់ដឹង រួមជាមួយនឹងសុខភាពផ្លូវចិត្តទូទៅល្អ។

## ៣- ឧទាហរណ៍មួយចំនួនក្នុងជំនាញសង្គមសំខាន់ៗ

ជំនាញសង្គមអាចរួមបញ្ចូលនូវសំណុំជំនាញផ្សេងៗគ្នា វាអាចមានសារៈសំខាន់ក្នុងការអភិវឌ្ឍផ្នែកទាំងនេះ ជាពិសេសនៅកន្លែងធ្វើការ។ ឧទាហរណ៍ ការប្រើប្រាស់ជំនាញទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព គឺមានសារៈសំខាន់ក្នុងអាជីពដែលត្រូវការទំនាក់ទំនងទៀងទាត់ជាមួយអតិថិជន ទោះបីជាតួនាទីរបស់យើងមិនមែនជាមុខតំណែងដែលប្រឈមមុខនឹងអតិថិជនក៏ដោយ ក៏យើងត្រូវមានជំនាញទំនាក់ទំនងជាមួយក្រុមរបស់យើង អ្នកគ្រប់គ្រង និងបុគ្គលិកផ្សេងទៀត ដើម្បីធ្វើការងារឱ្យមានប្រសិទ្ធភាព។

ជំនាញសង្គមសំខាន់ៗ ដែលត្រូវអភិវឌ្ឍដើម្បីជួយសម្រួលដល់អន្តរកម្មកាន់តែប្រសើររួមមាន៖[4]

**ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព៖** សមត្ថភាពក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដទៃ គឺជាជំនាញសង្គមស្នូល។ ប្រសិនបើយើងមានជំនាញទំនាក់ទំនងខ្លាំង យើងនឹងអាចចែករំលែកគំនិត និងគំនិតរបស់យើងយ៉ាងច្បាស់ជាមួយអ្នកដទៃ។ យើងមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព អាចធ្វើឱ្យយើងក្លាយជាអ្នកដឹកនាំល្អ ពីព្រោះយើងអាចពន្យល់ពីគម្រោង និងគោលដៅក្នុងវិធីងាយយល់។

**ការដោះស្រាយជម្លោះ៖** ការមិនចុះសម្រុង និងការមិនពេញចិត្ត អាចកើតឡើងក្នុងស្ថានភាពណាមួយ។ ការដោះស្រាយជម្លោះ គឺជាសមត្ថភាពក្នុងការឈានទៅដល់ការយល់ដឹងពីប្រភពនៃបញ្ហា និងស្វែងរកដំណោះស្រាយដែលអាចធ្វើបាន។ ជំនាញដោះស្រាយជម្លោះល្អ គឺមានសារៈសំខាន់ក្នុងការងារណាមួយ វាអាចនឹងស័ក្តិសមជាពិសេសសម្រាប់មុខតំណែងនៅក្នុងធនធានមនុស្ស ដែលជារឿយៗ អ្នកនឹងដោះស្រាយការខ្វែងគំនិតគ្នារវាងបុគ្គលិក ឬក្នុងតួនាទីបម្រើអតិថិជន ដែលត្រូវដោះ

[4] https://www.indeed.com/career-advice/career-development/social-skills

ស្រាយបញ្ហាជម្លោះសម្រាប់អតិថិជន អំពីផលិតផលរបស់ក្រុមហ៊ុន សេវាកម្ម ឬគោល នយោបាយ។

**ការស្ដាប់ដោយយកចិត្តទុកដាក់៖** គឺជាសមត្ថភាពក្នុងការយកចិត្តទុកដាក់យ៉ាងជិតស្និទ្ធទៅនឹងមនុស្សដែលកំពុងទំនាក់ទំនងជាមួយនឹងអ្នក។ អ្នកស្ដាប់ដោយយកចិត្តទុកដាក់ ជាធម្មតាត្រូវបានរាប់អានដោយមិត្តរួមការងាររបស់ពួកយើង ដោយសារតែការយកចិត្តទុកដាក់ និងការគោរព ដែលយើងផ្ដល់ជូនអ្នកដទៃ។

យើងអាចបង្កើនជំនាញស្ដាប់របស់យើង ដោយផ្ដោតលើអ្នកនិយាយ ជៀសវាងការរំខាន ហើយរង់ចាំរៀបចំការឆ្លើយតបរបស់យើង លុះត្រាតែអ្នកផ្សេងទៀតបានបញ្ចប់ (ជាជាងពេលពួកគេកំពុងនិយាយ)។

**ការយល់ចិត្ត៖** ការយល់ចិត្ត គឺជាសមត្ថភាពក្នុងការយល់ និងកំណត់អត្តសញ្ញាណ ជាមួយនឹងអារម្មណ៍របស់មនុស្សម្នាក់ទៀត។ ប្រសិនបើយើងមានការយល់ចិត្តអ្នកដទៃ ធ្វើឱ្យអ្នកដទៃមានការជឿជាក់លើយើងកាន់ខ្លាំង។ ការចេះយល់ចិត្តកាន់តែច្រើន ត្រូវការការខិតខំប្រឹងប្រែងដោយមនសិការ ដើម្បីពិចារណាដោយប្រុងប្រយ័ត្នទូវអារម្មណ៍របស់អ្នកដទៃ។ ប្រសិនបើយើងពង្រឹងការយល់ចិត្ត និងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ យើងអាចបង្កើនទំនាក់ទំនងកាន់តែរឹងមាំ ដោយគោរព និងបើកចំហ។

**ការគ្រប់គ្រងទំនាក់ទំនង៖** ជាសមត្ថភាពក្នុងការរក្សាទំនាក់ទំនងដែលមានសុខភាពល្អ និងបង្កើតទំនាក់ទំនងសំខាន់ៗ។ ឧទាហរណ៍ ប្រសិនបើយើងមានការងារនៅក្នុងផ្នែកសេវាកម្មអតិថិជន យើងអាចនឹងទទួលខុសត្រូវចំពោះការចិញ្ចឹមបីបាច់ទំនាក់ទំនងរវាងក្រុមហ៊ុនរបស់យើង និងក្រុមអតិថិជនជាក់លាក់មួយ។ នាយកប្រតិបត្តិនៅអង្គការគ្រប់គ្រងភាពជាដៃគូ ជាមួយអ្នកពាក់ព័ន្ធ និងអ្នកវិនិយោគ។ ជំនាញសង្គមនេះ អនុញ្ញាតឱ្យទំនាក់ទំនងវិជ្ជាជីវៈរីកចម្រើន ហើយគ្រប់ភាគីពាក់ព័ន្ធអាចទទួលបានអត្ថប្រយោជន៍។

**គោរព៖** ទិដ្ឋភាពសំខាន់នៃការគោរព គឺដឹងពីពេល និងរបៀបចាប់ផ្ដើមទំនាក់ទំនង និងការឆ្លើយតប។ នៅក្នុងការកំណត់ក្រុមឬពួក ការអនុញ្ញាតឱ្យអ្នកដទៃនិយាយដោយគ្មានការរំខាន គឺជា

ជំនាញទំនាក់ទំនងចាំបាច់ដែលបង្ហាញពីការគោរព។

ការប្រាស្រ័យទាក់ទងគ្នាដោយការគោរព ក៏អាចមានន័យថា ប្រើប្រាស់ពេលវេលារបស់អ្នកជាមួយនរណាម្នាក់ផ្សេងទៀតដោយប្រាជ្ញាផងដែរ រក្សាប្រធានបទសួរសំណួរច្បាស់លាស់ និងឆ្លើយតបយ៉ាងពេញលេញចំពោះសំណួរដែលយើងបានសួរ។

## ៤- វិធីដើម្បីអភិវឌ្ឍ និងកែលម្អជំនាញសង្គម

នៅក្នុងចំណុចនេះ យើងពិភាក្សាអំពីវិធីមួយចំនួន ដើម្បីបង្កើនជំនាញសង្គមរបស់យើង ដោយមានជាឧទាហរណ៍នៃជំនាញសង្គម និងរបៀបអនុវត្តវានៅកន្លែងធ្វើការ។

ជំនាញសង្គមមានសារៈសំខាន់ព្រោះវាអាចជួយយើងក្នុងការប្រាស្រ័យទាក់ទងគ្នាកាន់តែមានប្រសិទ្ធភាព។ ជាលទ្ធផល អ្នកអាចបង្កើត រក្សា និងបង្កើនទំនាក់ទំនងដ៏មានអត្ថន័យជាមួយមិត្តរួមការងារ អតិថិជន និងទំនាក់ទំនងថ្មីដូចគ្នា។

### ៤.១- វិធីដើម្បីអភិវឌ្ឍជំនាញសង្គម

ដើម្បីធ្វើឱ្យការប្រាស្រ័យទាក់ទងនិងទំនាក់ទំនងបានល្អនិងមានប្រសិទ្ធភាពយើងត្រូវអនុវត្តវិធីមួយចំនួន មានដូចជា៖

**ចូលរួមជាមួយអ្នកដទៃ៖** ស្វែងរកវិធីដើម្បីសន្ទនាបន្ថែមទៀតជាមួយមិត្តភក្តិ ក្រុមគ្រួសារ និងមិត្តរួមការងារជិតស្និទ្ធ ឬអនុវត្តជំនាញសន្ទនារបស់អ្នកដោយសួរសំណួរបើកចំហ។ ស្រដៀងគ្នានេះដែរ កំណត់គោលដៅតូចមួយសម្រាប់ខ្លួនយើង ដើម្បីផ្តល់ជូននូវគម្រោង ឬយុទ្ធសាស្ត្រអាជីវកម្មយ៉ាងហោចណាស់មួយនៅឯកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់របស់យើង។

**ចាប់ផ្តើមតាមវិធីតូចៗ៖** ចាប់ផ្តើមអភិវឌ្ឍជំនាញសង្គមរបស់យើងតាមវិធីតូចៗ ដោយចូលរួមជាមួយមនុស្សដែលយើងប្រាស្រ័យទាក់ទងជាមួយជារៀងរាល់ថ្ងៃ។ អ្នកអាចស្វែងរកវិធីដើម្បីពង្រីកការសន្ទនាជាមួយអ្នកស្គាល់គ្នា ឬអនុវត្តជំនាញសន្ទនារបស់អ្នកជាមួយសាច់ញាតិឆ្ងាយ ដែលអ្នកនិយាយមិនសូវបានជួបញឹកញាប់។

***សួរសំណួរបើកចំហ៖*** *ការសួរសំណួរបើកចំហ អាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការធ្វើឱ្យអ្នកដទៃនិយាយ។ វាអាចជួយឱ្យយើងយល់ច្បាស់ និងការយល់ដឹងទៅកាន់មិត្តភក្តិ ក្រុមគ្រួសារ មិត្តរួមការងារ និងសូម្បីតែថ្នាក់លើរបស់យើង។ នៅពេលយើងចូលរួមជាមួយសំណួរបើកចំហ វាអាចជួយឱ្យពួកគេមានអារម្មណ៍ថា មានសុពលភាពនៅក្នុងគំនិតនិងអារម្មណ៍របស់ពួកគេ ហើយវាអាចមានឥទ្ធិពលវិជ្ជមានទៅលើរបៀបដែលអ្នកបង្កើតទំនាក់ទំនង។*

*ជារឿយៗ មិត្តរួមការងារអាចពេញចិត្តក្នុងការសួរសំណួរបើកចំហ ព្រោះវាបង្ហាញថា អ្នកចាប់អារម្មណ៍លើគំនិតរបស់ពួកគេ។ សាកល្បងសំណួរបើកចំហខាងក្រោម៖ "តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះ...?" "តើអ្នកអាចប្រាប់ខ្ញុំបន្ថែមអំពី ...?" "គិតម៉េច...?"*

***សង្កេតមើលជំនាញសង្គមរបស់មិត្តរួមការងាររបស់អ្នក៖*** *ជំហានមួយទៀតផ្តោះទៅរកការអភិវឌ្ឍជំនាញសង្គមរបស់យើង គឺការសង្កេតមើលសហសេវិករបស់យើង។ យកចិត្តទុកដាក់លើការប្រាស្រ័យទាក់ទងគ្នាដោយមិនប្រើពាក្យសំដី ភាសាកាយវិការ (ដូចជាការញញឹម និងងក់ក្បាល) និងវាក្យសព្ទដែលពួកគេប្រើដើម្បីធ្វើការសន្ទនា។ ពិចារណាពីអ្វីដែលធ្វើឱ្យជំនាញសង្គមរបស់មិត្តរួមការងាររបស់យើងមានប្រសិទ្ធភាព និងចូលរួម។ យើងអាចយោងទៅលើការសង្កេតទាំងនេះ ហើយបញ្ចូលវាទៅក្នុងជំនាញទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើង។*

***អនុវត្តការរក្សាទំនាក់ទំនងដោយភ្នែក៖*** *អនុវត្តការរក្សាទំនាក់ទំនងដោយភ្នែកអំឡុងពេលសន្ទនា។ ពិចារណាកំណត់គោលដៅដើម្បីធ្វើ ហើយប្រើទំនាក់ទំនងដោយភ្នែកយ៉ាងហោចណាស់៣ទៅ៥វិនាទី រាល់ពេលដែលយើងចាប់ផ្តើមនិយាយជាមួយនរណាម្នាក់។ យើងអាចហាត់ជាមួយមិត្តរួមការងារជិតស្និទ្ធ ជាមួយអ្នកដែលអ្នកមានអារម្មណ៍ស្រួល។ អនុញ្ញាតឱ្យពួកគេដឹងថា យើងកំពុងព្យាយាមកែលម្អសមត្ថភាពរបស់យើងក្នុងការរក្សាទំនាក់ទំនងដោយភ្នែក។ អនុវត្តការទំនាក់ទំនងដោយភ្នែកអំឡុងពេលចាប់ផ្តើមការ សន្ទនា នៅពេលស្តាប់មិត្តរួមការងាររបស់យើងនិយាយ និងពេលអរគុណពួកគេ ហើយនិងបិទការសន្ទនា។*

***អភិវឌ្ឍជំនាញស្តាប់៖*** *វាមានសារៈសំខាន់ស្មើគ្នា ដូចជាការអាចចែករំលែកគំនិតផ្ទាល់ខ្លួនរបស់យើងដែរ គឺជាអ្នកស្តាប់ដោយយកចិត្តទុកដាក់។ ក្នុងការធ្វើដូច្នេះ យើងអនុញ្ញាតឱ្យអ្នកដទៃមានអារម្មណ៍ស្រួលក្នុងការចែករំលែកគំនិត និងការចូលរួមរបស់ពួកគេ។ អនុវត្តជំនាញស្តាប់របស់យើងដោយរក្សាការទំនាក់ទំនងដោយភ្នែក ដោយប្រើការប្រាស្រ័យទាក់ទងដោយគ្មានពាក្យសំដី ដូចជា ងក់ក្បាលនៅពេលអ្នកយល់ព្រម ហើយសួរសំណួរឱ្យច្បាស់លាស់ ពេលឮអ្វីមួយដែលអ្នកយល់ខុស។*

***អញ្ជើញមិត្តរួមការងារមកទទួលទានអាហារថ្ងៃត្រង់ ឬកាហ្វេ៖*** *ការកសាងទំនាក់ទំនងជាមួយអ្នកដទៃអាចមើលទៅហាក់ដូចជាគួរឱ្យភ័យខ្លាច ប៉ុន្តែវាអាចជួយចាប់ផ្តើមជាមួយនឹងការបង្កើតទំនាក់ទំនងជាមួយមនុស្សម្នាក់ក្នុងពេលតែមួយ។ ជាដំបូង ស្វែងរកមិត្តរួមក្រុមដែលធ្វើការក្នុងតួនាទីស្រដៀងនឹងយើង ហើយអញ្ជើញពួកគេមកទទួលទានអាហារថ្ងៃត្រង់ ឬញ៉ាំកាហ្វេ។ ការមានតួនាទី ឬទំនួលខុសត្រូវការងារដូចគ្នា អាចផ្តល់ឱ្យយើងនូវប្រធានបទទូទៅដែលត្រូវនិយាយ ប៉ុន្តែនៅទីបំផុត ព្យាយាមសួរសំណួរដើម្បីស្គាល់ពួកគេឱ្យកាន់តែច្បាស់ក្នុងនាមជាបុគ្គល។ នៅពេលយើងភ្ជាប់នូវទំនាក់ទំនងកម្រិតមួយទល់និងមួយកាន់តែច្រើន ជាមួយមនុស្សដែលធ្វើការក្នុងផ្នែកផ្សេងៗនៃអាជីវកម្ម អាចជួយអ្នកឱ្យពង្រីកបាននូវបណ្តាញអាជីពរបស់យើង និងទទួលបានការយល់ដឹងកាន់តែច្បាស់អំពីរបៀបការងារដែលយើងធ្វើ ដែលមានឥទ្ធិពលលើអាជីវកម្មទាំងមូល។*

***ផ្តល់ការសរសើរពិតប្រាកដដោយសេរី៖*** *ការសរសើរអ្នកដទៃលើការងារដែលធ្វើបានល្អ គឺជាវិធីដ៏ល្អមួយដើម្បីបង្ហាញពីភាពរួសរាយរាក់ទាក់ និងការឱ្យតម្លៃចំពោះអ្នកដទៃ។ ពួកគេអាចបញ្ចេញសកម្មភាពក្នុងការសន្ទនាច្រើនជាងមុន ឬអាចនឹងបន្តការសន្ទនានោះបន្តទៅទៀត។ ចូរស្មោះត្រង់ ការសរសើរដែលមិនសមរម្យអាចប្រឆាំងនឹងយើងបាន។*

***ស្វែងរកធនធានជំនាញសង្គម៖*** *មានឧបករណ៍រៀនជាច្រើនដូចជា សៀវភៅ ផត-ខេស* (podcasts) *និងឧបករណ៍ជាច្រើនដែលមានទាំងនៅលើ និងក្រៅបណ្តាញ ដើម្បីជួយយើងបង្កើនជំនាញសង្គមរបស់យើង។ ព្យាយាមស្វែង*

រកធនធានដោយផ្អែកលើប្រធានបទជាក់លាក់ណាមួយ ដូចជាភាសាកាយវិការ បណ្តាញ ឬការស្តាប់ដោយយកចិត្តទុកដាក់។ ពីទីនោះ ដាក់ការរៀនសូត្ររបស់យើងទៅជាការអនុវត្ត។

**តាមដានព្រឹត្តិការណ៍បច្ចុប្បន្ន៖** ការបន្តធ្វើបច្ចុប្បន្នភាពលើនិន្នាការបច្ចុប្បន្ន ព្រឹត្តិការណ៍ និងព័ត៌មាន អាចផ្តល់ ឱ្យយើងនូវប្រធានបទដើម្បីនិយាយជាមួយអ្នកដទៃ។ ពិចារណាលើការទិញឬការជូនដំណឹងព័ត៌មានក្នុងស្រុកឬព្រឹត្តិប័ត្រព័ត៌មានសម្រាប់ឧស្សាហកម្មជាក់លាក់ដើម្បីមានខ្លឹមសារផ្ញើមកយើងដោយផ្ទាល់។ វាជាការអនុវត្តល្អបំផុត ដើម្បីជៀសវាងប្រធានបទចម្រូងចម្រាសដូចជានយោបាយ ឬសាសនា ដើម្បីរក្សាការសន្ទនាប្រកបដោយវិជ្ជាជីវៈ និងមិត្តភាព។

នៅពេលដែលយើងអភិវឌ្ឍជំនាញទាំងនេះបានល្អហើយ យើងមានសមត្ថភាពពេញលេញក្នុងការប្រើប្រាស់ជំនាញសង្គម និងធ្វើអន្តរកម្មសង្គមដោយជោគជ័យ។

### ៤.២- វិធីកែលម្អជំនាញសង្គម

យើងមានវិធីជាច្រើនដើម្បីបង្កើនជំនាញសង្គមរបស់យើង ដោយយើងចាប់ ផ្តើមពី៖[៥]

**ទទួលយកមតិកែលម្អ៖** សុំឱ្យមិត្តភក្តិ អ្នកណែនាំ ឬអ្នកគ្រប់គ្រង ដែលគួរឱ្យទុកចិត្តផ្តល់ឱ្យអ្នកនូវមតិកែលម្អដោយស្មោះត្រង់អំពីចំណុចខ្វះខាតរបស់យើងសម្រាប់ចំណុចដែលត្រូវកែលម្អ។

**ការកំណត់គោលដៅ៖** ប្រើមតិកែលម្អនេះ ដើម្បីចាប់ផ្តើមកំណត់គោលដៅដែលអាចវាស់វែងបាន ដើម្បីបង្កើតជំនាញសង្គមរបស់យើង។ គោលដៅនៃក្របខ័ណ្ឌ (ជាក់លាក់អាចវាស់វែងបាន សម្រេចបាន ពាក់ព័ន្ធ និងផ្អែកលើពេលវេលា) ប្រហែលជាមានប្រយោជន៍ក្នុងការតាមដានវឌ្ឍនភាពរបស់អ្នក។

**ការស្វែងរកធនធាន៖** មានថ្នាក់បណ្តុះបណ្តាលជំនាញសង្គមជាច្រើន មគ្គុទ្ទេសក៍សៀវភៅ និងឧបករណ៍ផ្សេងទៀតដែលអាចរកបាន ទាំងបង់ប្រាក់និងឥតគិតថ្លៃ។ អ្នកអាចស្វែងរកមេរៀនជំនាញសង្គមទូទៅ ឬវគ្គជំនាញជាក់លាក់ ដូចជាភាសាកាយវិការ ឬភាពដែលធ្វើឱ្យគេចូលចិត្តជាដើម។

---

[5] https://www.indeed.com/career-advice/career-development/social-skills

***កំណត់តំបន់សម្រាប់ការអនុវត្ត៖*** *នៅពេលដែលអ្នកបានរៀនយុទ្ធសាស្ត្រ និងគន្លឹះសម្រាប់ពង្រឹងជំនាញសង្គមរបស់យើងហើយ សូមយកវាទៅអនុវត្តនៅផ្ទះ និងកន្លែងធ្វើការ។ យើងក៏អាចស្វែងរកឱកាសស្ម័គ្រចិត្ត ឬសកម្មភាពក្រៅកម្មវិធីសិក្សា ដែលយើងអាចអនុវត្តជំនាញអន្តរបុគ្គល។*

## ៥- សារៈសំខាន់នៃជំនាញសង្គម

*ហេតុអ្វីបានជាជំនាញសង្គមមានសារៈសំខាន់?*

*ការរៀនជំនាញសង្គមមានសារៈសំខាន់មិនគួរឱ្យជឿ ព្រោះវាជាខ្លឹមសារនៃការកសាងទំនាក់ទំនងល្អជាមួយអ្នកដទៃ។ នៅពេលដែលយើងរីករាយនឹងទំនាក់ទំនងល្អ យើងអាចធ្វើបានក្នុងការមានអារម្មណ៍រីករាយ និងពេញចិត្តកាន់តែច្រើនជាមួយនឹងអ្វីដែលយើងមាន និងយើងជានរណា។ ទទួលបានការគាំទ្រពីមនុស្សជាទីស្រឡាញ់របស់យើងក្នុងពេលមានការលំបាក។ ជៀសវាងការធ្លាក់ចូលទៅក្នុងភាពនៅឆ្ងាយឬដាក់ពីគេ និងភាពឯកោ មានអារម្មណ៍ថាមានតម្លៃ និងមិនសូវតានតឹង។*

*ខាងក្រោមនេះគឺជាអត្ថប្រយោជន៍មួយចំនួននៃការអភិវឌ្ឍជំនាញសង្គម។*

***ការកសាងទំនាក់ទំនង៖*** *ជំនាញសង្គមគឺមានប្រយោជន៍ក្នុងការបង្កើតទំនាក់ទំនងវិជ្ជមានជាមួយមិត្តភក្តិ គ្រួសារ និងសហគមន៍របស់ពួកគេ។ បុគ្គលនីមួយៗត្រូវអភិវឌ្ឍជំនាញសង្គមនៃការកសាងទំនាក់ទំនងថ្មី ដោយបង្កើតមិត្ត និងរៀនទំនាក់ទំនងជាមួយអ្នកដទៃក្នុងវិធីអះអាង និងការគោរព។*

***អភិវឌ្ឍការយល់ចិត្ត៖*** *ជំនាញសង្គមមានប្រយោជន៍ក្នុងការយល់ដឹង និងឆ្លើយតបទៅនឹងអារម្មណ៍របស់អ្នកដទៃ។ នេះជួយយើងបង្កើតការយល់ចិត្ត ដែលជាធាតុផ្សំដ៏សំខាន់នៃទំនាក់ទំនងដែលមានសុខភាពល្អ។*

***ការប្រាស្រ័យទំនាក់ទំនង៖*** *ជំនាញសង្គមជួយយើងឱ្យរៀនពីរបៀបបង្ហាញខ្លួនយ៉ាងច្បាស់ និងមានប្រសិទ្ធភាព ដោយពាក្យសម្ដី និងមិនមែនពាក្យសម្ដី។ ជំនាញទំនាក់ទំនងល្អ គឺចាំបាច់សម្រាប់ការកសាងទំនាក់ទំនង និងរុករកស្ថានភាពសង្គម។*

***ការដោះស្រាយជម្លោះ៖*** *ជំនាញសង្គមជួយយើងឱ្យរៀនពីរបៀបគ្រប់គ្រងជម្លោះ និងការមិនចុះសម្រុងគ្នាតាមរបៀបវិជ្ជមាន។ ការរៀនពីរបៀបចរចា សម្រុះសម្រួល និងស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធភាពសម្រាប់មនុស្សគ្រប់រូប ត្រូវបានរួមបញ្ចូលជាផ្នែកនៃជំនាញនេះ។*

***ការគោរពខ្លួនឯង៖*** *ជំនាញសង្គមអាចបង្កើនការគោរពខ្លួនឯង និងទំនុកចិត្ត។ ជារឿយៗយើងនឹងមានអារម្មណ៍ល្អចំពោះខ្លួន*

ឯង និងសមត្ថភាពរបស់យើងនៅក្នុងបរិយាកាសដែលយើងមានអារម្មណ៍សុខស្រួលក្នុងស្ថានភាពសង្គម ហើយក្រោយមកអាចទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

ដូចដែលអ្វីបានបញ្ជាក់ខាងលើអំពីអត្ថប្រយោជន៍មួយចំនួននៃការអភិវឌ្ឍជំនាញសង្គម យើងអាចនិយាយជារួមបានថាវាជារឿងសំខាន់ក្នុងការអភិវឌ្ឍជំនាញសង្គមរបស់មនុស្សម្នាក់ៗតាំងពីតូច ព្រោះវាមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសង្គម និងផ្លូវចិត្តរបស់យើង ហើយវាអាចជួយយើង ក្នុងការសម្រេចបានជោគជ័យយ៉ាងមានប្រសិទ្ធភាពលើគ្រប់វិស័យនៃជីវិតរបស់យើង។

ប្រសិនបើបុគ្គលនីមួយៗរៀនវាតាំងពីតូច វានឹងកាន់តែងាយស្រួលសម្រាប់ពួកគេដូចជា បង្កើតមិត្តភាពជាមួយកុមារដទៃទៀត , ប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិរបស់ពួកគេ ការធ្វើបានល្អនៅសាលា មានអារម្មណ៍ទទួលយកនិងផ្តល់តម្លៃ ការកសាងទំនុកចិត្តលើខ្លួនឯង ការគិតនិងអានកាន់តែប្រសើរ ការចងចាំព័ត៌មានដែលពួកគេរៀន ការអភិវឌ្ឍការវែកញែក និងការយកចិត្តទុកដាក់ឬផ្តោតអារម្មណ៍។

ក្នុងរយៈពេលវែង យើងនឹងកាន់តែយល់ដឹងអំពីខ្លួនឯងនិងអ្នកដទៃ ផ្តល់និងទទួលការគាំទ្រពីអ្នកដទៃ ធ្វើការសម្រេចចិត្ត និងការសម្រេចចិត្តកាន់តែប្រសើរឡើងសម្រាប់ជីវិតរបស់យើង និងសម្រេចបាននូវក្តីសុបិនរបស់យើង។

សំខាន់ជាងនេះទៅទៀត បុគ្គលដែលមានជំនាញសង្គមល្អ អាចទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាពពីអារម្មណ៍ និងតម្រូវការរបស់ពួកគេទៅកាន់គ្រួសារ និងអ្នកដទៃជុំវិញយើង។

## ឯកសារពិគ្រោះ


1- Schneider, B.H. & Byrne, B.M. ***Children's social skills training***. New York: Springer-Verlag. 1985.

2- *Dowd, Tom P.; Tierney, Jeff.* ***Teaching Social Skills to Youth***. October 2017.

3- Uekermann J, Daum. ***"Social cognition in alcoholism: a link to prefrontal cortex dysfunction?"*** May 2008.

4- Gillis, J.M. & Butler, R.C. ***Social skills interventions for preschoolers with Autism Spectrum Disorder***: A descryprion of single – subject design studies. *Journal of Early and Intensive Behavior Intervention.* 2007.

5- Miller, P. H. ***Piaget's theory: Past, present, and future***. *2011.*

# គំនិតបង្រួបបង្រួមខ្មែរសម័យមហាអង្គរ

## The Idea of Unity during the Great Angkorian Period

*ដោយៈ បណ្ឌិត* **ភ្លាន់ ធុល**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

### ១. សេចក្តីផ្តើម

*មិនថាមនុស្ស, វត្ថុ រុក្ខជាតិ, ឬក៏ប្រទេស... ទោះមានជីវិតក្តី មិនមានជីវិតក្តី សុទ្ធតែមានអត្ថិភាពដោយការឯកភាពគ្នា នៅក្នុងនោះ។ បើមនុស្ស វត្ថុ រុក្ខជាតិ មានអត្ថិភាពដោយការឯកភាពគ្នារវាងលោកធាតុ៤ ឬខន្ធ ៥ នេះបើតាមទស្សនៈរបស់ព្រះពុទ្ធ។ បើគ្រួសារ សង្គម និង ស្ថាប័ន មានអត្ថិភាពដោយការឯកភាពគ្នារវាងអ្នកដឹកនាំគ្រួសារនិងសមាជិកគ្រួសារ រវាងអ្នកដឹកនាំសង្គមនិងសមាជិកសង្គម និង រវាងអ្នកដឹកនាំស្ថាប័ននិងសមាជិក។ ការបង្រួបបង្រួមគឺជាមូលហេតុដែលនាំឱ្យមានការ* ***ឯកភាព***។ *តើ****ការឯកភាព****ជាអ្វី? តើ****ការបង្រួបបង្រួម*** *ជាអ្វី? តើពួកវា មានសក្តានុពលដូចម្តេចខ្លះ? ហើយពួកវាមានលក្ខណៈចាំបាច់និងមានសារៈប្រយោជន៍អ្វីខ្លះ ដល់ការគិត ការរស់នៅប្រចាំថ្ងៃ និងសង្គមទាំងមូល?*

### ២. ខ្លឹមសារ

***ការឯកភាព*** *និង* ***ការបង្រួបបង្រួម*** *គឺជាបញ្ញត្តិពីរដែលបង្ហាញពីការចុះសម្រុងឬការឯកភាពគ្នានៃអង្គវត្ថុ។*

***ឯកភាព*** *គឺភាពតែមួយ ភាពត្រូវគ្នា ករណី ដូចជា ឯកភាពជាតិជាដើម។ ពាក្យនេះមានន័យត្រូវគ្នាជាមួយនឹងពាក្យ* ***ឯកច្ឆន្ទ*** *គឺជាការមានបំណងតែមួយ, មានបំណងត្រូវគ្នាតែមួយ ឬព្រមចិត្តគ្នា តែមួយ។ ករណីដូចជា ខំប្រឹងធ្វើការដោយឯកច្ឆន្ទ ព្រមគ្នាជាឯកច្ឆន្ទជាដើម។* ***ឯកភាព*** *ឬ****ឯកច្ឆន្ទ*** *កើតមកពីពាក្យ* ***ឯកទិដ្ឋិ*** *ដែលជាការមានទិដ្ឋិត្រូវគ្នា ឬអ្នកដែលមានសេចក្តីយល់ឃើញត្រូវគ្នា*[១]*។*

*ពាក្យ* ***ឯកភាព*** *ត្រូវគ្នានឹងពាក្យអង់គ្លេសថា* "consensus" *មានន័យថា ជាកិច្ចព្រមព្រៀង*

---

[១] *ជួនណាត "វចនានុក្រមខ្មែរ (អេឡិចត្រូនិច)" រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ២០០៨*

ទូទៅមួយអំពីបញ្ហាមតិអ្វីមួយ[២] ឬអាចនិយាយបានម្យ៉ាងទៀតថា ជាមតិ ឬការសម្រេចចិត្ត ដែលគេបានទទួលយកជាទូទៅក្នុងចំណោមមនុស្ស មួយក្រុម[៣]។

ចំពោះពាក្យ **ការបង្រួបបង្រួម** មកពីកិរិយាស័ព្ទ "បង្រួបបង្រួម" មានន័យថា ធ្វើឱ្យរួបរួម ឬឱ្យសះជារួមមូលគ្នាវិញ[៤]។ **ការបង្រួបបង្រួម**ត្រូវនឹងពាក្យអង់គ្លេសថា "unity" មានន័យថា សភាពនៃការរួបរួម ឬការព្រមព្រៀងគ្នា។ ពាក្យ "unity" នេះ មានកិរិយាស័ព្ទជា "unite" មានន័យថា ធ្វើឱ្យមនុស្សឬវត្ថុនានានៅរួមគ្នាមូលតែ មួយ[៥]។ ឧទាហរណ៍បុរសម្នាក់ បន្ទាប់ពីជាប់គុកបាន៣ឆ្នាំ គាត់ក៏បានរួបរួមគ្នាជាមួយប្រពន្ធ និងក្រុមគ្រួសារគាត់វិញ (A man, after three years in prison, was reunited with his wife and family)។ យើងគួររួបរួមគ្នាប្រយុទ្ធប្រឆាំងចំពោះភាពក្រីក្រហើយនិងជំងឺ (We should unite in fighting poverty and disease)។

ជារួម **ការឯកភាព** និង **ការបង្រួប បង្រួម** គឺជាបញ្ញត្តិពីរ ដែលបង្កប់ន័យរួមថារួបរួមគ្នា ចុះសម្រុងគ្នា ត្រូវគ្នា ឯកភាពគ្នា រួមចិត្ត រួមកាយស្លាប់រស់ជា មួយគ្នា។

## ៣. សាវតារនៃគំនិតបង្រួបបង្រួមជាតិខ្មែរ

នៅក្នុងការបង្កើតរាជវង្សខ្មែរដំបូង ផ្តើមឡើងដោយការពើបប្រទះគ្នាជា **ចម្បាំង** រវាង **ហ៊ុន ទៀន** ដែលមកពីប្រទេសឥណ្ឌា និងនាង **លីវយី** ដែលជាព្រះក្សត្រី នៃរដ្ឋហ្វូណន (ទំនាស់នៃអង្គបក្ខដិបក្ខ)។ ក្រោយពីច្បាំងគ្នាអស់ពេលដ៏យូរមក នាង **លីវយី** ត្រូវចាញ់ដៃនៅក្នុងការប្រយុទ្ធជាមួយ **ហ៊ុនទៀន** ដោយ **ហ៊ុន ទៀន** បាញ់ ទម្លាយសំពៅនាងពីម្ខាងទៅម្ខាង[៦] ។ នាង មានការភិតភ័យជាខ្លាំង ហើយក៏សុំចុះចាញ់ **ហ៊ុនទៀន** (អង្គបក្ខដិបក្ខមួយមានប្រៀបលើអង្គបក្ខដិបក្ខមួយ ហើយនិងអង្គបក្ខ ដិបក្ខដែលចាញ់ប្រៀបចំណុះអង្គបក្ខដិបក្ខដែលមានប្រៀប) ។ **ហ៊ុនទៀន** ក៏បានយកនាងធ្វើ ជាមហេសី (ការបង្រួបបង្រួមរបស់អង្គបក្ខដិបក្ខ ដែលមានប្រៀប ឬអង្គ បក្ខដិបក្ខទាំងពីរឯក ភាពគ្នា និងសំយោគ ចូលគ្នា)។ រួចហើយក៏នៅគ្រប់គ្រងរដ្ឋ ហ្វូណានជាតំណតទៅកូនចៅរៀង មក (ការរួបរួមនៃអង្គបក្ខដិបក្ខ)។

---

[២] A S Homby, *Oxford Advanced Learner´s Dictionary of Current English,* 5th Ed. Oxford University Press, New York, 1999, p 244

[៣] Cambridge *Advanced Learner´s Dictionary,* 3rd Ed., p consensus

[៤] ជួនណាត "*វចនានុក្រមខ្មែរ*(អេឡិចត្រូនិច)," រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨

[៥] A S Homby, *op. cit.*, p 1304

[៦] ត្រឹង ងា, "*ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)*", ភ្នំពេញ, គ.ស.១៩៧៣/ព.ស.២៥១៧, ទំព័រ ៤៩

*ប៉ុន្តែក្រោយ មកអាណាចក្រហ្វូណននេះត្រូវបានបញ្ចប់ ដោយការវាយយករបស់អាណាចក្រចេនឡា។ តែទោះជាយ៉ាងណាក៏ដោយ អាណាចក្រចេនឡានេះបានចុះខ្សោយឥទ្ធិពល នៅពេល ដែលបុត្រីរបស់ព្រះបាទជ័យវរ្ម័នទី១ នាម* ***ជ័យទេវី*** *ឡើងសោយរាជ្យស្នងព្រះអង្គ។ អំណាចរបស់ព្រះនាងមិនមានមូលដ្ឋានមាំទាំឡើយ ព្រោះអត្ថបទសិលាចារិកមួយនៅបារាយណ៍ទឹកថ្លា ព្រះនាងទ្រង់បានត្អូញត្អែពី "ភាពច្របូកច្របល់នៅក្នុងចិត្តគំនិត និងពីទុក្ខវេទនាក្នុងគ្រាកើតកលិយុគ។" គឺដោយសារតែអំណាចកណ្តាល ចុះខ្សោយ ដែល ស្ថិតនៅក្នុងកណ្តាប់ដៃមេដឹកនាំ ដែលជាស្ត្រីនេះហើយបានធ្វើឱ្យ* ***ចេនឡា*** *ត្រូវពុះចែកជាពីរ[៧]។ នេះគឺបណ្តាលមកពីនយោបាយខ្មែរនៅពេលនោះគ្មានស្ថេរភាព ព្រោះតែមានការបែកបាក់ផ្ទៃក្នុងយ៉ាងដំណំ ដែលជាហេតុនាំឱ្យប្រទេសទាំងមូលត្រូវធ្លាក់ចូលទៅក្រោមអំណាចត្រួតត្រារបស់ជ្វា។ តែក្រោយមកប្រទេសជាតិត្រូវបានបង្រួបបង្រួមឱ្យមានការឯកភាពជាតិមកវិញ ដោយព្រះបាទ* ***ជ័យវរ្ម័នទី២*** [៨] *គឺក្នុងឱកាសនោះហើយដែលអនុញ្ញាតិឱ្យប្រជាជនខ្មែរ មានលទ្ធភាពអាចចាប់ផ្តើមកសាងសម័យអង្គរឱ្យសម្បូររុងរឿងបន្តិចម្តងៗហូតដល់ក្លាយទៅជា* **មហានគរ**។

*តាមដំណើរ រឿងប្រវត្តិសាស្ត្រនេះ ប្រទេសខ្មែរត្រូវប្រព្រឹត្តទៅតាមដំណើរជម្លោះឈានទៅរកការបង្រួបបង្រួម ការបង្រួបបង្រួមឈានទៅរកជម្លោះ ជម្លោះឈានទៅរកការបង្រួបបង្រួម ដែលយើងអាចបំព្រួញខ្លីជាៈ*

**ជម្លោះ ⇆ បង្រួបបង្រួម**

*បើជម្លោះមានកម្លាំងខ្លាំង ការឯកភាពនិងការបង្រួបបង្រួមជាតិនឹងត្រូវចុះ ខ្សោយហើយក៏ដួលរលំបាត់។ ផ្ទុយទៅវិញ បើការឯកភាពជាតិនិងការបង្រួបបង្រួមជាតិមានកម្លាំងខ្លាំង ជម្លោះនឹងត្រូវ ចុះខ្សោយហើយក៏ដួលរលំបាត់ សន្តិភាព និងអភិវឌ្ឍន៍នឹងកើតមានឡើង។ ហេតុនេះ ការប្រកាន់យកគំនិតពីការកាត់បន្ថយ ជម្លោះ បានកាន់តែច្រើនកាន់តែល្អ ដើម្បី ឱ្យការឯកភាព និងការបង្រួបបង្រួមជាតិ កាន់តែរឹងមាំនិងមាននិរន្តរភាព។*

### ៣.១. គំនិតបង្រួបបង្រួមជាតិនិងទឹកដី

*ព្រះមហាក្សត្រសម័យអង្គរយល់ច្បាស់ពីន័យ* ***បង្រួបបង្រួមជាតិ ឯកភាពជាតិ សាសនាជំនឿ*** *ហើយក៏យល់ច្បាស់ផង ដែរពីអ្វីដែលហៅថា* ***អភិវឌ្ឍន៍*** *អ្វីទៅជា* ***ការរីកចម្រើន*** *ហើយនិងថា តើ**អភិវឌ្ឍន៍** និង **ការរីកចម្រើននេះ***

---

[៧] *ត្រឹង ងា, "ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)", ដ.ឯ.ម., ទំព័រ ៧០*

[៨] *ត្រឹង ងា, "ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)", ភ្នំពេញ, គ.ស.១៩៧៣/ព.ស.២៥១៧, ទំព័រ ៤៩, ៧០, ៧៧*

មានប្រភពមកពីណា។ ព្រះអង្គទ្រង់យល់ច្បាស់ថា **ការបង្រួបបង្រួម** នាំឱ្យកើតនូវ **ការឯកភាព** ដែលនាំទៅដល់ **អភិវឌ្ឍន៍**។ ជាតក្កវិជ្ជាគ្មាន **អភិវឌ្ឍន៍** ណាដែលកើតឡើងដោយជាតិបែកបាក់គ្នានោះទេ។ សន្តិភាពគឺជាបិតានៃអ្វីៗទាំងអស់ (peace is the father of all things)។ ដើម្បីទៅដល់ **អភិវឌ្ឍន៍** ត្រូវតែចាប់ផ្តើមពី **ការបង្រួបបង្រួមជាតិ** ឱ្យមានការឯកភាពគ្នាជាមុនសិន។

មុននឹងឡើងសោយរាជ្យ ព្រះបាទ **ជ័យវរ្ម័នទី២** ទ្រង់បានគិតជាស្រេចទៅដល់អម្រែករបស់ព្រះអង្គដែលត្រូវរែកពុន ថាតើអម្រែកនោះជាអម្រែកអ្វី ស្រាលឬធ្ងន់ មានប្រយោជន៍អ្វីខ្លះដល់ព្រះអង្គឯង ក៏ដូចជាដល់ជាតិរបស់ព្រះអង្គ។ បន្ទាប់មក ព្រះអង្គនឹងគិតទៅដល់សមត្ថភាពរបស់ព្រះអង្គថា តើព្រះអង្គអាចធ្វើបានអ្វីខ្លះ គិតទៅដល់អ្នកចូលរួមនៅក្នុងចលនាបង្រួបបង្រួមរបស់ព្រះអង្គ ថាតើមានអ្នកចូលរួម កម្រិតណា និងគិតទៅដល់កាលៈទេសៈ ថាតើវាអំណោយផលគ្រប់គ្រាន់ដល់ការបង្រួបបង្រួមជាតិឱ្យមានការឯកភាពគ្នាដែរឬទេ។ នៅក្នុងដំណើរគំនិតនេះ គេអាចនឹកឃើញទៅដល់ **គំនិតទស្សនវិជ្ជា** ដែលលើកឡើងទាក់ទងទៅនឹង **ការរស់នៅ**, **ការគ្រប់គ្រង**, និង **ការធ្វើសង្គ្រាម** ដោយជោគជ័យ ដែលតម្រូវឱ្យ **អ្នកដឹកនាំទាំងនេះ** ត្រូវដឹងទៅដល់ **គំនិតស្តម្ភ៤** ពោលគឺ **ត្រូវស្គាល់ខ្លួនឯង១**; **ត្រូវស្គាល់អ្នកដទៃ ១**[៩]; **ត្រូវស្គាល់ទីកន្លែង ១**; និង **ត្រូវស្គាល់ កាលៈទេសៈ ១**។

**ការត្រូវស្គាល់ខ្លួនឯង** មាន៣ចំណុចសំខាន់គឺត្រូវស្គាល់ពី **សមត្ថភាពខ្លួនឯង១**; ត្រូវស្គាល់ **សុខភាពខ្លួនឯង ១** និងត្រូវស្គាល់ **គុណធម៌ខ្លួនឯង១**។ ស្គាល់ពី **សមត្ថភាពខ្លួនឯង** គឺត្រូវស្គាល់ពីភាពដែលខ្លួនឯងអាចបំពេញបាន ទោះកិច្ចការនោះតូចក្តី ធំឱ្យដោយ ប្រើមធ្យោបាយគ្រប់បែប យ៉ាងទោះទាំងផ្លូវកាយ, ផ្លូវចិត្ត, ផ្លូវបញ្ញា, និងទាំងផ្លូវសម្ភារៈ[១០] ឬក៏ចំណេះដឹងទាំងខាងផ្លូវលោក និងទាំងខាងផ្លូវធម៌។ ស្គាល់ពី **សុខភាពខ្លួនឯង** គឺត្រូវស្គាល់ពីភាពសុខស្រួលទាំងខាងផ្លូវកាយនិងទាំងខាងផ្លូវចិត្តរបស់ខ្លួនឯង។ ការស្គាល់ពីសុខភាពខ្លួនឯងច្បាស់ គឺជាការស្គាល់ផ្លូវច្បាស់ទៅរកលាភសក្ការៈ ឬភាពជោគជ័យដ៏ប្រសើរបំផុត។ ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា *"គ្មានសេចក្តីសុខណាស្មើសេចក្តីស្ងប់(សុខភាពផ្លូវចិត្ត)"*។ គ្មានមានទ្រព្យណាល្អ ជាងមានសុខភាពល្អនោះឡើយ។ ការងារតូចធំ លំបាកស្មុគស្មាញយ៉ាងណា ឱ្យតែ មានសុខភាពល្អ ការងារទាំងនោះគង់នឹង សម្រេចបានដោយជោគជ័យគ្រាន់តែត្រូវការពេលវេលាបន្តិចប៉ុណ្ណោះ។

---

[៩] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974, p 6

[១០] ហ. មណីចិន្តា, *ព្រះបាទធម្មិក*, អន្ទង់វិល, បោះពុម្ព លើកទី៣, ១៩៩៦, ទំព័រ ៦៣

ចាស់ បុរាណលោកពោលទុកថា "ក្រក៏ក្រទៅ ចុះសុំកុំឱ្យតែឈឺ"។ ស្គាល់ពី **គុណធម៌ខ្លួនឯង** គឺជាការស្គាល់ពី **គុណភាពសីលធម៌ល្អ** ដែលមាននៅក្នុងខ្លួនឯង ឬ **គុណភាពទូទៅ នៃសេចក្តីល្អរបស់ខ្លួនឯង**[១១]។ គុណធម៌ គឺជាតម្លៃនៃភាពជាមនុស្សរបស់ខ្លួនឯង។ បុគ្គលត្រូវតែបណ្តុះឱ្យមាន **គុណធម៌** នៅ ចំពោះ **ខ្លួនឯង** ដើម្បីឱ្យ **គុណធម៌នេះ**បាន ជុះផាលទៅដល់អ្នកដទៃផង។ ពេលដែល ខ្លួនឯង និងអ្នកដទៃ ជុះផាល់នូវ **គុណធម៌ នេះ** ហើយ **ទាំងខ្លួនឯង** និង **អ្នកដទៃ**ចាប់ ផ្តើមរស់នៅជាមួយគ្នាដោយសេចក្តីសុខដុមហើយ។

**ការ ត្រូវស្គាល់អ្នកដទៃ** មាន៣ ចំណុច ដូចនៅទី១ដែរ គឺត្រូវស្គាល់ **សមត្ថភាពអ្នកដទៃ ១**; ត្រូវស្គាល់ **សុខភាពអ្នក ដទៃ១**; និងត្រូវស្គាល់ **គុណធម៌អ្នកដទៃ១**[១២]។ នៅក្នុងដំណើរអន្តរកម្មសង្គម បុគ្គលមិនអាចស្គាល់ត្រឹមតែខ្លួនឯងបានទេ គឺត្រូវស្គាល់អ្នកដទៃនូវ **សមត្ថភាព**; **សុខភាព**; និង **គុណធម៌** របស់ពួកគេផង ដែរ។ ការស្គាល់ពី **សមត្ថភាព** របស់អ្នកដទៃ គឺ ជាការស្គាល់នូវអ្វីដែលពួកគេអាចធ្វើបាន ហើយនិង អ្វីដែលពួកគេមិនអាចធ្វើបាន ដើម្បីឱ្យយើង អាចធ្វើសហប្រតិបត្តិការកិច្ចតូចធំជាមួយពួកគេដោយងាយស្រួល។ **ថៃឌឹស** (Titus) និង **ស្មីត** (Smith) យល់ថា "ប្រសិនបើមនុស្សរស់នៅដាច់ដោយឡែកពីមនុស្សដទៃ គេមិនអាចអភិវឌ្ឍអ្វីបានឡើយ សូម្បីតែភាសា។ មនុស្សមិនអាចរស់ដោយឯកោ និងដាច់ចេញទាំងស្រុងពីមិត្តរបស់គេបានទេ។ ផ្ទះ, សហគមន៍ និង សង្គមដ៏ធំធេងរបស់គេអាចដឹកនាំទៅរក **វិបុលភាពនៃជីវិត** ក៏ដូចជាដឹកនាំទៅរក **សេចក្តីទុក្ខ** និង **សោកនាដកម្ម** ផងដែរ[១៣]។

ត្រូវស្គាល់ **ទីកន្លែង** មានន័យថា ត្រូវស្គាល់ពីទីតាំងដែលវត្ថុស្ថិតនៅ ដូចជា ទីក្រុង, ជនបទ, លើភ្នំ, លើទឹក, ក្នុងព្រៃ, ទីវាលទំនាប ...។ល។ បុគ្គលម្នាក់, ក្រុមមួយ, គ្រឹះស្ថានជំនួញមួយ...។ល។ សុទ្ធតែឋិតនៅ ក្នុងទីតាំងណាមួយជាដាច់ខាត។ មេទ័ពត្រូវស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់ របស់សត្រូវ ទើបអាចយកឈ្នះលើសត្រូវ បាន។ សត្វក្រពើ បើវានៅលើគោក វាមិន អាច ឈ្នះសត្វគោបានទេ តែបើវានៅក្នុងទឹក សត្វគោក៏មិនអាចឈ្នះវាបានដែរ។ នៅក្នុងការគ្រប់គ្រង បើអ្នកគ្រប់គ្រងជា អ្នកមានជីវភាពលំបាក មានសមត្ថភាព អន់ហើយ មិនវៃឆ្លាតទៀត (កម្រិត/ លំដាប់ថ្នាក់/ទី តាំង) ពិបាកនឹងមានអន្តរកម្ម ឬឈានទៅគ្រប់គ្រងអ្នកដទៃបានឡើយ ពីព្រោះអ្នកដទៃគឺជាប្រភេទមនុស្ស ចម្រុះ មានអ្នកឆ្លាត មានអ្នកល្ងង់ មានអ្នក មានមានអ្នកក្រ...។ល។ អ្នក

[១១] Cambridge *Advanced Learner's op. cit.*, p virtue

[១២] ហ. មណីចិន្តា, *ព្រះបាទធម្មិក*, ដ.ឯ.ម.,ទំព័រ ៥៩-១៦០

[១៣] Venancio B. Ardales, *op. cit.*, p 45

គ្រប់គ្រងគេត្រូវ តែបិតនៅក្នុងទីតាំងមួយដែល ខ្ពស់និង អស្ចារ្យលើសគេ ទាំងសុខភាព, សមត្ថភាព, និងទាំងគុណធម៌។ បើមិន ដូច្នេះទេ ការគ្រប់គ្រងនាំនឹងត្រូវដាំក្បាលចុះ។ ចំពោះការរស់នៅក៏ដូចជាអ្នកគ្រប់គ្រង ដែរ ដើម្បីឱ្យការរស់នៅរបស់គេមានការ រីកចម្រើនល្អ គេត្រូវចេះជ្រើសរើសទីតាំង នៅដែលមានមនុស្សច្រើនកុះករ ឬទីកន្លែង ដែលងាយស្រួលឱ្យអ្នកដទៃទាក់ទងជា មួយនឹងខ្លួនបាន។ សម្តេចព្រះសង្ឃរាជ **ជួន ណាត** បានលើកឡើងពីអ្នកដែល ប្រកាន់តាមជំនឿទៅលើការសង់ផ្ទះបែរមុខទៅ **ទិសខាងកើត** រកស៊ីមានបាន បើ ទោះជាគាត់រកមិនបានក៏គាត់នៅតែយល់ថាការប្រកាន់ជំនឿបែបនេះពិតជាល្អ។ ចំណែកឯជនជាតិចិនដែលមិនប្រកាន់ជំនឿបែបនេះ គឺពួកគេសង់ផ្ទះទៅតាមទិស ដែលមានមនុស្ស មិនថាទៅកើត ឬទៅ លិចតែម្យ៉ាងនោះទេ ពួកគេរកស៊ីមាន បាន[១៤]។ ដី ផ្ទះ ដែលមានទីតាំងនៅទីប្រជុំ ជនមានតម្លៃថ្លៃជាងដីផ្ទះនៅស្រុកស្រែចុងកាត់មាត់ញក។

ត្រូវស្គាល់ **កាលៈទេសៈ** មានន័យ ថាត្រូវស្គាល់ពីពេលវេលា ព្រឹក ថ្ងៃ ល្ងាច យប់ ថ្ងៃ ខែ ឆ្នាំ រដូវវស្សា រដូវប្រាំង...ល។ ពេលវេលា (time) ជាអ្នកធ្វើឱ្យអ្វីៗប្រែប្រួល។ ដោយសារតែការប្រែប្រួល ទើបអ្វីៗមិននៅមួយកន្លែង។ កត្តានេះហើយ ដែលនាំឱ្យមនុស្សដែលមិនយល់ពីពេល វេលាកើតនូវវិប្បដិសារី, ខកចិត្ត, និងកើត ទុក្ខជារឿយៗ ការយល់ពីពេលវេលាគឺជាការយល់ពីដំណើរប្រែប្រួល។ ហេតុនេះ ដំណើរប្រែប្រួលជម្រុញឱ្យមនុស្សចេះ រៀបចំខ្លួនដើម្បីកុំឱ្យគម្រោងការបរាជ័យកើតឡើង។ នៅក្នុងន័យស្គាល់ពេលវេលា គេមិនត្រូវរង់ចាំពេលវេលាល្អហុចឱ្យនោះ ទេ គេត្រូវចេះបង្កើតវា។ អាល្លឺម៉ង់ចូលវាយរុស្សីនៅក្នុងកំឡុង សង្គ្រាមលោក លើកទី២ ត្រូវបរាជ័យ មកពីអាល្លឺម៉ង់មិន ស្គាល់ពេលវេលា (ចំរដូវធ្លាក់ទឹកកក)។ រុស្សីចូលវាយអ៊ុយក្រែនត្រូវជាប់ផុង រហូតមកដល់ពេលនេះ ដោយសារតែរុស្សីមិនស្គាល់ពេលវេលា និងសម័យកាល។ បុគ្គលត្រូវស្គាល់ពេលវេលា, ត្រូវចេះគ្រប់គ្រង និងត្រូវចេះប្រើវាប្រកបទៅដោយ ភាពប៉ិនប្រសប់ ទើបបុគ្គលនោះអាចធ្វើ ជាម្ចាស់លើពេលវេលាបាន ហើយនិង អាចធ្វើការងារអ្វីៗប្រព្រឹត្តទៅៗតាមការ គ្រោងទុក និងជៀសផុតពីការខកបំណង បាន។

អនុលោមទៅតាម **គំនិតស្តម្ភទាំង៤ របស់ទស្សនវិជ្ជា** ខាងលើធ្លុះបញ្ចាំងឱ្យ ឃើញថា ព្រះបាទ **ជ័យវរ្ម័នទី២** មានការគិតហ្មត់ចត់នៅក្នុងការងារបង្រួបបង្រួមជាតិ។ ព្រះអង្គជឿជាក់លើសមត្ថភាព របស់ព្រះអង្គឯង ហើយព្រះអង្គក៏ស្គាល់ច្បាស់ផងដែរពីកាលៈទេសៈ

---

[១៤] ខ្សែអាត់សំឡេង កិច្ចសម្ភាសអក្សរសាស្ត្រខ្មែរ ដោយសម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ **ជួន ណាត** អំពីវិហារបែរមុខទៅកើត។

ហើយនិង ដឹងច្បាស់ថា ត្រូវប្រើអ្វីយកមកធ្វើការ បង្រួបបង្រួមជាតិ បង្រួបបង្រួមទឹកដីឱ្យមានការឯកភាពគ្នា តែមួយក្រោមព្រះតំរិះរបស់ព្រះអង្គ។ យើងអាចនិយាយបែបនេះដោយសារតែ នៅមុននឹងរៀបចំ **ពិធីទេវរាជ** នៅលើភ្នំគូលែន ព្រះអង្គធ្វើការ បង្រួបបង្រួមជាតិមួយភាគសិន[១៥]។ នេះ គឺជាគំនិតសាកល្បងរបស់ព្រះអង្គដើម្បីឱ្យ ដឹងថា តើមានការចូលរួមពីប្រជារាស្ត្រ និងមន្ត្រីតូចធំបានដល់កម្រិតណា។ បន្ទាប់ ពីឃើញមានការចូលរួមគាំទ្ររបស់ប្រជារាស្ត្រនិងមន្ត្រីតូចធំតាមព្រះតំរិះហើយ ព្រះបាទ **ជ័យវរ្ម័នទី២** បានមើលឃើញ ពី ឱកាសល្អបានមកដល់ហើយ។ ព្រះអង្គ បានចាប់យកឱកាសល្អនេះរៀបចំធ្វើ **ពិធី ទេវរាជ**។ តើការរៀបចំប្រារព្ធធ្វើពិធីទេវរាជនេះមានប្រយោជន៍អ្វី?

**ពិធីទេវរាជ** គឺជាពិធីសាសនា ដែលមានបំណងប្រែក្លាយព្រះរាជា (ព្រះបាទ **ជ័យវរ្ម័នទី២**) ឱ្យក្លាយទៅជា **ទេវរាជ** (ស្តេចអាទិទេព) ដែលពាក្យខ្មែរបុរាណ ហៅថា **កម្រតេងជគតតរាជ្យ** (ស្តេចដែលជាម្ចាស់នៃចក្រវាល) ដែលមានជីវិតរស់នៅលើផែនដីនេះ[១៦]។ **អាទិទេព** គឺជាភាវៈអធិធម្មជាតិកំពូល ដែលមាន **សញ្ញានុភាព** លើសពីសមត្ថភាពមនុស្សអាចធ្វើបាន។ ព្រះបាទ **ជ័យវរ្ម័នទី២** ទ្រង់យល់ពី **ឥទ្ធិពលសាសនា** នេះច្បាស់លាស់។ សាសនាបង្កើត **ជំនឿ** ឬសទ្ធា។ ជំនឿបង្កើត **ទំនុកចិត្ត**។ ទំនុកចិត្ត បង្កើតឱ្យមាន **ការឯកភាពជាតិ**។ **ការឯក ភាពជាតិ** គឺជា **កម្លាំង**។ បើមាន **កម្លាំង** ព្រះអង្គចង់ធ្វើអ្វីក៏បានដែរ។ ដោយហេតុនេះ ហើយទើបបានជាគេឃើញព្រះអង្គមានលទ្ធភាពអាចបង្រួបបង្រួមអាណាចក្រ ចេនឡាដែលបានបែកបាក់គ្នាជាពីរឱ្យមាន ការរួបរួមគ្នាវិញ ក្រោមព្រះតំរិះរបស់ព្រះអង្គបានដោយជោគជ័យហើយមានលទ្ធភាពអាចផ្តើមសម័យអង្គរដ៏រុងរឿងបាននោះ។ ត្រង់នេះយើងមើលឃើញច្បាស់ពី គោលគំនិតវៃឆ្លាតនៅក្នុងការ រៀបចំ **ពិធី ទេវរាជ** របស់ព្រះអង្គ។ ព្រះអង្គយក **សាសនា** ធ្វើជាឧបករណ៍នយោបាយ។ នៅ សម័យអង្គរ គិតចាប់តាំងពីដើមរហូតដល់ ចុងបញ្ចប់សម័យនេះ អ្នកដឹកនាំបានយក **សាសនា** ឱ្យមានមុខងារយ៉ាងសំខាន់នៅ ក្នុង **នយោបាយដឹកនាំប្រទេស**[១៧]។ សាសនាគឺជា **កម្លាំងមនោគមន៍វិជ្ជា** ឬជា **កម្លាំងចិត្តសាស្ត្រ**។ ទាក់ទងទៅនឹង **កម្លាំងចិត្តសាស្ត្រនេះ** មានសំណួរមួយបានចោទសួរ ថា ហេតុអ្វីបានជាមនុស្សបង្កើតសាសនា ឡើង? **សាសនា** ត្រូវបានគេយល់និង អភិវឌ្ឍឡើងមិនត្រឹមតែដើម្បីបំពេញ **តម្រូវការខាងជីវសាស្ត្រ** និង

[១៥] ត្រឹង ងា, "*ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)*", ដ.ឯ.ម., ទំព័រ ៧៨

[១៦] ត្រឹង ងា, "*ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)*", ដ.ឯ.ម.,, ទំព័រ ៧៨

[១៧] -ដ-, ទំព័រ ១១៣

**ចិត្តសាស្ត្រ** (the biological and psychological needs of man) ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយមួយ ដែលអាចឱ្យគេទទួលបាននូវ**សេចក្ដីសង្គ្រោះខាងផ្លូវចិត្ត** (spiritual salvation) នេះទៀតផងដែរ[១៨]។ ធាតុចិត្តសាស្ត្រមាន ដូចជា **ការភ័យខ្លាច** (fear), **ភាពស្ញប់ស្ញែង** (awe), **ការគោរព** (reverence), **សេចក្ដីស្រឡាញ់** (love), **ភាពជាក្រុម** (grega-riousness) ឬ **សង្គមីយភាព** (sociability), **ការចង់ដឹងចង់ឃើញ** (curiosity), **ការស្ដាប់បង្គាប់** (submissiveness) ក៏ដូចជា **សេចក្ដីអះអាង** (assertiveness) ជាដើម។ ធាតុបីដំបូងគឺ **ការភ័យខ្លាច**, **ភាពស្ញប់ ស្ញែង** និង **ការគោរព** ត្រូវបានគេចាត់ទុក ថាជាធាតុមូលដ្ឋានបំផុតក្នុងចំណោមធាតុ ទាំងប្រាំបីខាងលើ។ **ការភ័យខ្លាច** (fear) គឺជាអារម្មណ៍មូលដ្ឋាន ហើយនិងជាធាតុ មូលដ្ឋានមួយទៅលើ **ភាពស្ញប់ស្ញែង** (awe) ដែលតាមរយៈ**ភាពស្ញប់ស្ញែង** អារម្មណ៍សាសនា (religious feelings) ក៏ ចាប់ផ្ដើមកើតឡើងដែរ។ **ភាពស្ញប់ស្ញែង** នាំឱ្យមានអារម្មណ៍គោរពដែលគេជឿថានេះគឺជា "**សញ្ញាសាសនា** (hallmark of religion)"[១៩]។

គំនិតប្រែក្លាយខ្លួនដែលជាស្ដេច នៅលើផែនដីទៅជា **អាទិទេព** នៅលើផែន ដីគឺជាគំនិតចិត្តសាស្ត្រខ្លាំង អាចជួយដោះ ស្រាយវិបត្តិចេនឡាដែលបានពុះហែកគ្នាជាពីរ ដែលនៅពេលនោះ ប្រជារាស្ត្រតូច ធំកំពុងតែមាន **ភាពស្មុគស្មាញ** និង **ភាព ជួរចត់នៅក្នុងជីវិត** ហើយដែលពួកគេមាន តម្រូវការចាំបាច់ឱ្យ**ជួយសង្គ្រោះ** ជាពិសេសគឺ **ការជួយសង្គ្រោះខាងផ្លូវចិត្ត** នេះតែម្ដង ព្រះបាទ **ជ័យវរ្ម័នទី២** ទ្រង់យល់ ពីតម្រូវការនេះ។

ពាក្យថា ស្ដេចមនុស្ស គឺខុសប្លែកពី **ស្ដេចទេព្ដា** ដោយសារតែ **ស្ដេចទេព្ដា** បង្កប់នូវ **ភាពអស្ចារ្យ** នៅក្នុងនោះ ដែលមនុស្ស ឬស្ដេចធម្មតាមិនអាចធ្វើបាន គឺមានតែស្ដេចទេព្ដាប៉ុណ្ណោះ ដែលអាចធ្វើបាន។ **ភាពអស្ចារ្យ** នៅទីនេះ សំដៅយកភាពជាគំរូ ឬភាពនាំមុខគេនៅក្នុងរឿងនាំមនុស្សទៅរកសេចក្ដីសុខ និងសេចក្ដីចម្រើន ដែលខ្លួនគេផ្ទាល់មិនអាចនាំទៅបាន។ តើមានអ្វីខ្លះ?

ភាពអស្ចារ្យ **ទី១** ព្រះបាទ**ជ័យវរ្ម័នទី២** ចេះប្រែក្លាយពី **ជំនឿអរូបី** មកជា **ជំនឿរូបី** ឬក៏ថា **ពី ជំនឿលើរឿងព្រេងកថា** មកជា **ជីវិតពិត** ដែលគំនិតនេះបានកើតមានតាំងពីសម័យស្ដេចសោយរាជ្យមុនៗមកម្ល៉េះ គ្រាន់តែមិនទាន់លេចរូបរាងច្បាស់។ ព្រះអង្គដែលមានជីវិតរស់នៅជាមនុស្សនៅលើផែនដី ដោយការប្រារព្ធធ្វើ **ពិធីទេវរាជ** ព្រះអង្គបានក្លាយទៅជា **ស្ដេចអាទិទេព** ដែលមាន **សិវលិង្គ** ជាតំណាង។ **ប្រាសាទទេវកថា** នៅក្នុងជំនឿថា "ព្រះឥសូរមានលំនៅនៅលើកំពូលភ្នំកៃលាស សិវលិង្គដែលជាតំណាងព្រះឥសូរផង ជាតំណាងព្រះរាជាផងក៏ត្រូវយកទៅ តម្កល់លើភ្នំដែរនោះ"

[១៨] Venancio B. Ardales, *op. cit.*, p 160

[១៩] *Ibid.*, p 146

បានប្រែក្លាយមកជា **ប្រាសាទតថ** នៅលើផែនដីដើម្បីបម្រើតម្រូវការជីវិតពិត។ តបតាមជំនឿនេះ ព្រះបាទជ័យវរ្ម័នទី២ បានកសាងប្រាសាទ **ព្រះអារាមរោងចិន** ដែលជាប្រាសាទភ្នំទី១ ឧទ្ទិសថ្វាយចំពោះ **ព្រះឥសូរ** នៅលើភ្នំ គូលែន ក្នុងឋានៈព្រះអង្គជាស្តេចអាទិទេព។ គំនិតកសាងប្រាសាទភ្នំ ឬប្រាសាទ នៅលើកំពូលភ្នំតាមលំនៅព្រះឥសូរនេះ បានជះឥទ្ធិពលមកដល់ការកសាងប្រាសាទសម័យក្រោយៗដោយគោរពទៅតាម ជំនឿថា "*ព្រះរាជាគឺជាស្តេចអាទិទេព ដែលមានជីវិតរស់នៅលើផែនដី លុះសោយទីវង្គតទៅ ព្រះអង្គនឹងយាងទៅគង់នៅ* ***ឋានទេវលោក*** *ជាមួយអាទិទេពអង្គណាមួយ អាចជាព្រះឥសូរ, ព្រះព្រហ្ម, ព្រះវិស្ណុ, ឬព្រះពុទ្ធ។*" ឧទាហរណ៍ ព្រះបាទ ជ័យវរ្ម័នទី២ មានមរណនាមថា "**បរមេស្វ**" មានន័យថាព្រះអង្គយាងទៅគង់នៅជាមួយ **ព្រះឥសូរ។ បរមវិស្ណុលោក** ជាមរណៈនាមរបស់ព្រះបាទសូរ្យវរ្ម័នទី២ ដែលមានន័យថា ព្រះអង្គបានយាងទៅគង់នៅជាមួយ **ព្រះវិស្ណុ**។ ព្រះបាទជ័យវរ្ម័ន ទី៧ មានមរណនាមថា **មហាបរមគត**[២០] បង្ហាញថាព្រះអង្គគឺជាមហាពុទ្ធសាសនិកមួយរូប។ តាមជំនឿ "***ប្រាសាទភ្នំ*** *ដែលជា និមិត្តរូបភ្នំព្រះសុមេរុ ត្រូវតែស្ថិតនៅចំកណ្តាល* ***រាជធានី*** *ដែលគេចាត់ទុកថា នៅចំស្នូលនៃចក្រវាឡ។* ***កំពែង*** *និង* ***គូទឹក*** *ជានិមិត្តរូបជួរភ្នំ និងសមុទ្រដែលព័ទ្ធជុំវិញភ្នំព្រះសុមេរុ*[២១]។ គំនិតបង្កើតឱ្យ ប្រារព្ធធ្វើ **ពិធីទេវរាជ** គឺជាគំនិតបង្កើតឱ្យ មានការកសាងប្រាសាទ, បារាយណ៍ធំៗ និង ជំនឿសាសនា ដែលក្រោយមកប្រាសាទ និងបារាយណ៍ធំៗទាំងនេះបានបម្រើជាប្រយោជន៍ជាច្រើន ដូចជា កសិកម្ម, សេដ្ឋកិច្ច, ការផោរស្រាវជ្រាវ, ទេសចរណ៍វប្បធម៌, និងកិច្ចការស្ថាបត្យកម្ម។

ភាពអស្ចារ្យ **ទី២ លទ្ធិទេវរាជ** បានធ្វើឱ្យអំណាចរបស់ព្រះបាទជ័យវរ្ម័នទី២ មានប្រភពចេញមកពីអាទិទេព ដែលធ្វើឱ្យព្រះអង្គមានអំណាចទូលំទូលាយ ប៉ុន្តែពុំមែនមានន័យថាព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេ ពីព្រោះព្រះអង្គត្រូវ គោរពវិន័យវណ្ណៈក្សត្រិយ៍ គោរពសិក្ខាបទសាសនា បានសេចក្តីថា ព្រះអង្គត្រូវប្រកបដោយ *ទសពិធរាជធម៌*[២២]។

ភាពអស្ចារ្យទាំង២របស់ព្រះបាទជ័យវរ្ម័នទី២ បានបង្កើតឱ្យមាន **ជំនឿ** (faith) ចំពោះ ប្រជារាស្ត្រ។ **ជំនឿ** គឺជាប្រភពនៃ **ទំនុកចិត្ត** (confidence) និង ***ការរួបរួម*** (unity) ដែលជាប្រភពកម្លាំងនៅក្នុងដំណើរអភិវឌ្ឍន៍ជាតិ។

### ៣.២. គំនិតបង្រួបបង្រួមជំនឿ

*យាងតាមគំរូល្អរបស់ព្រះបាទជ័យវរ្ម័ន*

[២០] ត្រឹង ងា, "*ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)*", ដ.ឯ.ម., ទំព័រ ៨០, ៩៣, ៩៨

[២១] -ដ_ ទំព័រ ៧៩, ១០៨

[២២] -ដ-, ទំព័រ ១១០

ទី២ ព្រះបាទជ័យវរ្ម័នទី៧ បានបញ្ជ្រាបខ្លួនចូលទៅក្នុងព្រះពុទ្ធទៅជា **ពុទ្ធរាជ**។ ក្នុង នាម **ពុទ្ធរាជ** ព្រះអង្គប្រើ **ពុទ្ធធម៌** ដើម្បីដឹកនាំប្រទេស។ **ពុទ្ធធម៌** ដែលព្រះអង្គលើកយកមកប្រើលេចធ្លោរជាងគេគឺ **ព្រហ្មវិហារធម៌**។ **ព្រហ្មវិហារធម៌** នោះ គេអាចរកឃើញកស្តុតាងច្បាស់នៅលើការកសាង ***ប្រាសាទបាយ័ន***ដែលនៅលើ កំពូលប្រាង្គនីមួយរបស់ប្រាសាទនេះសុទ្ធតែមាន **មុខ៤** ដែលបង្ហាញយ៉ាងច្បាស់ពី **ពុទ្ធធម៌៤** ពោលគឺ **ព្រហ្មវិហារធម៌** នេះឯង។ **ប្រាសាទបាយ័ន** ក៏ដូចជាប្រាសាទផ្សេងៗនៅទូទាំងព្រះរាជាណាចក្រដែរ នៅក្នុងរជ្ជកាលនេះគឺសុទ្ធតែមាន **មុខ៤** ទាំងអស់ដែលអាចឱ្យគេហៅបានថា **រជ្ជកាល មុខ៤** ឬ **រជ្ជកាលពុទ្ធធម៌៤**។ តើ **មុខ៤** ជា **មុខព្រហ្ម** ឬក៏ជា **មុខព្រះពោធិសត្វលោកិតេស្វរ** របស់ព្រះបាទជ័យវរ្ម័នទី៧?

ចំពោះចំណោទនេះ យើងចង់ឆ្លើយថា **មុខព្រហ្ម** ក៏បាន ចង់ថា **មុខព្រះពោធិសត្វលោកិតេស្វរ** ក៏បានៗ **ធម៌៤** ដែលព្រះបាទជ័យវរ្ម័នទី៧ចង់បង្ហាញឱ្យឃើញនៅនឹងប្រាសាទបាយ័ននោះ គឺ **កម្លាំងព្រះពុទ្ធសាសនា** ពោលគឺ **កម្លាំងសីលធម៌, កម្លាំងគុណធម៌, កម្លាំងយុត្តិធម៌** នេះឯង។ ពុទ្ធសាសនាមាន **ធម៌ ៨៤០០០ ព្រះធម្មក្ខន្ធ** អ្នកណានិយាយត្រង់ណាក៏ត្រូវដែរៗប៉ុន្តែអ្វីដែលសំខាន់ ដែលព្រះអង្គចង់រំលេច ឱ្យឃើញនោះ គឺ **ធម៌៤** មាន *មេត្តា, ករុណា, មុទិតា,* និង *ឧបេក្ខា* នេះឯង។ ធម៌នេះមាន សក្តានុពលនៅក្នុងការបង្រួបបង្រួមជំនឿផ្សះផ្សារនិងសម្របសម្រួលមនោគមន៍ វិជ្ជាសាសនាពីរ **ព្រហ្មញ្ញសាសនា** និង **ព្រះពុទ្ធសាសនា** ដែលបានប៉ះទង្គិចគ្នានៅ ពេលមានការផ្លាស់ប្តូររជ្ជកាលស្តេច សោយរាជ្យ ដែលសាសនាក៏ត្រូវតែមាន ការផ្លាស់ប្តូរទៅតាមនោះដែរ។ តើហេតុអ្វី បានជាត្រូវមានការបង្រួបបង្រួមជំនឿ?

រឿងនេះយើងអាចពិនិត្យមើលទៅ លើការផ្លាស់ប្តូររជ្ជកាលស្តេច គឺថា នៅរាល់ពេលមានការផ្លាស់ប្តូររជ្ជកាលស្តេច សោយរាជ្យម្តងៗតែងតែប្រព្រឹត្តទៅ ពេលខ្លះក៏មានការរក្សាទុកសាសនា ប៉ុន្តែពេល ខ្លះទៀតក៏ត្រូវមានការផ្លាស់ប្តូរសាសនានេះទៅជាមួយដែរ អាស្រ័យទៅលើការ និយមពេញចិត្តរបស់ស្តេចសោយរាជ្យ។ នៅពេលមានការផ្លាស់ប្តូររជ្ជកាលស្តេចដែលតម្រូវឱ្យមានការផ្លាស់ប្តូរសាសនា ដែរនោះ បានបង្កឱ្យមានផលប៉ះពាល់ផ្លូវ ចិត្តជាខ្លាំងចំពោះស្តេចមន្ត្រី សេនាបតី និងមេសាសនាដែលគោរពសាសនាផ្ទុយ ដែលជាអន្ទង់យ៉ាងធ្ងន់សំពងទៅលើការ ឯកភាពជំនឿ និងការឯកភាពជាតិ ឈានទៅរកការបែកបាក់ផ្ទៃក្នុងនិងការបង្ក ជម្លោះរវាងគ្នាឯង។ ជាបទពិសោធន៍នៅក្នុងរជ្ជកាលរបស់ព្រះបាទ ឧទយាទិត្យវរ្ម័នទី២ កើតមានការប៉ះបោរ៣ លើក។ ការបះបោរលើកទី១ កើតឡើងនៅគ.ស. ១០៥១នៅភាគខាងត្បូង ហើយមានមេដឹកនាំឈ្មោះ **អរវិន្ទហ្រទ** តែត្រូវទទួលបរាជ័យ ហើយភៀស

ទៅចាម្ប៉ា។ ការបះបោរលើក ទី២ កើតឡើង នៅគ.ស. ១០៦៥នៅតំបន់ ពាយព្យ ហើយមាន មេដឹកនាំ ឈ្មោះ **កមវៅ**។ ក្នុងលើកនេះគេ ឃើញពួកបះ បោរវាយកំទេច **សិវលិង្គ** និង **ទេវបដិមា** នៅគ្រប់ទិសទី។ ក្រោយបន្តិច ការ បះបោរ លើកទី៣ បានផ្ទុះឡើងនៅភាគខាង កើត ដឹកនាំដោយបងប្អូន២នាក់ឈ្មោះ **ស្លូត** និង **សិទ្ធិការ** ដែលធ្វើសហប្រតិបត្តិការជា មួយមេម្នាក់ទៀតឈ្មោះ **សសាន្តិភូវន**[២៣]។ ទិដ្ឋភាពស្តីអំពីរឿងនេះដែរនោះ គេអាចមើល ឃើញច្បាស់នៅក្រោយរជ្ជកាល ព្រះបាទ ជ័យវរ្ម័នទី៧ គឺនៅក្នុងរជ្ជកាល ព្រះបាទ **ជ័យវរ្ម័នទី៨** (១២៤៣-១២៩៥) មាន ប្រតិកម្មយ៉ាងខ្លាំងក្លាពីសំណាក់ **អ្នក កាន់ សាសនាព្រាហ្មណ៍** ប្រឆាំងជាមួយព្រះពុទ្ធ សាសនា ដែលប្រាថ្នាចង់ប្រស់ប្រពៃណី ព្រាហ្មណ៍ក្នុងសតវត្សរ៍មុនៗឱ្យរស់រវើកឡើង វិញ ក្រោយពីត្រូវបាត់ ឈ្មោះ បោះសំឡេងក្នុង រជ្ជកាលរបស់ព្រះ បាទ **ធរណិន្ទ្រវរ្ម័នទី២**, ព្រះបាទ **ជ័យវរ្ម័នទី៧** និង **អគ្គមហេសី** របស់ ព្រះអង្គ។ នៅក្នុងដំណើរប្រតិកម្មនេះ គេឃើញ មានការកោសលុបរូបចម្លាក់ព្រះពុទ្ធនៅតាម ជញ្ជាំង និងតាមសសរ និងការសាងជំនួស វិញដោយ **លិង្គព្រះឥសូរ ឬ តាបសតាំង សីល**[២៤]។

ដោយហេតុនេះហើយបានជាព្រះបាទ **ជ័យវរ្ម័នទី៧** កសាងប្រាសាទបាយ័ន ដែលមាន **មុខ៤** គ្រប់ប្រាង្គនេះឡើង។ **ព្រហ្មមុខបួន** ពួកព្រាហ្មណ៍មើលក៏ឃើញ ព្រហ្មនៅទីនោះ អ្នកពុទ្ធសាសនាក៏មើល ឃើញ *ព្រហ្មវិហារធម៌* របស់ព្រះពុទ្ធនៅ ក្នុងនោះដែរ។ អ្នកណាមកក៏ សប្បាយនឹង ប្រាសាទបាយ័ននោះដែរ រាស្ត្រ មើលឃើញមុខរាស្ត្រ ស្តេចមើលឃើញមុខ ស្តេច ពួកនាយរោងក្លោងទ្វារទាំង៤ច្រក ចេញ ចូលនគរទាំង ៤ កន្លែងណាក៏មានមុខ សូម្បី អង្គរវត្តក៏មានច្រកចេញចូលបួនដែរ ទន្លេបាទី ក៏មានមុខបួនប្រាសាទនគរបាជ័យខេត្តកំពង់ចាម ក៏មុខបួនដែរ។ មុខបួន មានតាំងពីកណ្តាល នគររហូតដល់រាយរងទាំងអស់ តាំងពីស្តេច ដល់រាស្ត្រ ពីរាស្ត្រ ដល់ស្តេច តាំងពីអំណាច កណ្តាលទៅដល់ ក្លោងទ្វារច្រកទល់ដែន មាន តែ **ធម៌បួន** ប៉ុណ្ណោះ។ ព្រះអង្គអាចធ្វើឱ្យមាន ការឯកភាពគ្នាបាន ចុះព្រះធម៌ដល់ទៅ ៨៤០០០ ធម្មក្ខន្ធ តើវាធ្វើឱ្យមានការរួបរួមគ្នា ដល់កម្រឹតណា[២៥]។ ត្រង់នេះហើយដែលគេ

---

[២៣] -ដ-, ទំព័រ ៩០

[២៤] ត្រឹង ង៉ា, "*ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)*", ដ.ឯ.ម., ទំព័រ ១០០-១០១

[២៥] ឆេង ផុន, តម្រូវការសីលធម៌ព្រះពុទ្ធសាសនា ក្នុងសង្គមខ្មែរ នៅក្នុង "*ពុទ្ធសាសនានិងការលើកស្ទួយជីវិតពុទ្ធបរិស័ទ*", ការផ្សាយរបស់ពុទ្ធសា-

ហៅថា **ជ័យវរ្ម័នទី៧** ដែលជា **ពុទ្ធរាជ** ដែល គ្រាន់តែយកធម៌បួន *មេត្តា, ករុណា, មុទិតា,* និង *ឧបេក្ខា* ប៉ុណ្ណោះ ក៏កើតនូវសេចក្ដីរុងរឿង ពេញនគរ។ ស្ដេចក៏និយាយធម៌នេះ ពស្រ្តក៏ និយាយធម៌នេះ មេទ័ពក៏និយាយធម៌នេះ អ្នកណាក៏និយាយធម៌នេះដែរ តាំងពីសម្ដេច សង្ឃ រហូតដល់កូននេនតូចមួយ ទើបនឹងបួស ក៏និយាយធម៌នេះដែរ។ នេះជាទិដ្ឋភាព ទី១ នៃធម៌៤។

**ធម៌៤**ធម៌ទី១គឺ **មេត្តា** សំដៅដល់បំណង ចង់ឱ្យអ្នកដទៃបានសេចក្ដីសុខចម្រើនដូចខ្លួន; ធម៌ទី២ គឺ **ករុណា** គឺជាសេចក្ដីអាណិតអាសូរ; ធម៌ទី៣ គឺ **មុទិតា** ទាក់ទងទៅនឹងដំណើរមាន ចិត្តរីករាយទៅរកសេចក្ដីសុខរបស់អ្នកដទៃ ដោយពុំរើសមុខ; និងធម៌ទី៤ គឺ **ឧបេក្ខា** គឺជា ការតាំងចិត្តជាកណ្ដាល[២៦]។ គុណធម៌ទាំង៤ មានអន្តរកម្មជាមួយគ្នា។ មេត្តាធម៌ ឬ មេត្តាចិត្ត គឺជាឱសថព្យាបាលរោគទោសៈ។ ព្រះបាទ **ជ័យវរ្ម័នទី៧** ទ្រង់យល់ច្បាស់ថា បើប្រជាពស្រ្ត ទាំងអស់គ្នា រួមទាំងអ្នកដឹក នាំផងបិតនៅក្នុង *ធម៌មេត្តា ឧបេក្ខា* នោះ ពួកគេនឹងមិនអាច ឈ្លោះគ្នាកើតទេ ឃើញមុខគ្នាអាណិត ឃើញ អ្នកនេះអាណិត ឃើញអ្នកនោះក៏អាណិត អាណិតគ្រប់គ្នា រឿងអីទៅឈ្លោះគ្នាកើត។ កាលណាមានសេចក្ដីអាណិតហើយនិង មាន សេចក្ដីសន្ដោស មនុស្សទាំងអស់នឹងទៅជា បងប្អូន អាចធ្វើការជាមួយគ្នាដោយ រីករាយ ហើយសង្គមជាតិក៏នឹងមិនអាចបែកបាក់គ្នាទៅ កើតដែរ។ ព្រះបាទ**ជ័យវរ្ម័នទី៧** បានប្រើប្រាស់ **ធម៌៤** នៅក្នុង ប្រយោជន៍២យ៉ាង គឺប្រយោជន៍ ផ្លូវអាណាចក្រ ហើយនិងប្រយោជន៍ផ្លូវពុទ្ធ ចក្រ។ ផ្លូវទាំងពីរនេះបំពេញឱ្យគ្នាទៅវិញទៅ មក។ *ព្រះធម៌គឺជាជីវិត ជីវិតគឺជា ព្រះធម៌*គ្មាន ធម៌នៅក្នុងខ្លួន គឺរស់មិនបាន សុខទេ ហើយ អាយុក៏មិនវែងដែរ[២៧]។ នេះជាទិដ្ឋភាពទី២ នៃធម៌៤។

សរុបសេចក្ដីមក ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់យល់ច្បាស់ពីអត្ថន័យនៃជំនឿ និងតម្លៃ របស់វា។ ជំនឿ គឺជា កម្លាំងទំនុក ចិត្ត។ បុគ្គល ដែលត្រូវបានគេទុកចិត្តបុគ្គល នោះជាបុគ្គល ជោគជ័យក្នុងកិច្ចការសព្វសារពើ មិនថានៅ សម័យព្រះបាទជ័យវរ្ម័នទី៧ សព្វថ្ងៃក៏ដូច្នេះ ដែរ។

### ៣-៣- គំនិតបង្រួបបង្រួម អាទិទេព

មិនថាតែចំពោះមនុស្សទេ ដែលចេះ បែកបាក់គ្នា សូម្បីតែអាទិទេពក៏មាន ការបែក គ្នាដែរ។ នេះដោយសារតែអាទិទេពកើតចេញ ពីគំនិតមនុស្ស។ ដោយ ហេតុនេះ ហើយទើប

សនាដើម្បីអភិវឌ្ឍន៍, អន្ទង់វិល, គ.ស. ១៩៩៦, ទំព័រ ៥៣

[២៦] ជួនណាត ជ.ឯ.ម, ទំព័រ មេត្តា, ករុណា, មុទិតា, ឧបេក្ខា

[២៧] ឆេង ផុន, ជ.ឯ.ម, ទំព័រ ៥៦, ៥៧

បានជារឿងរ៉ាវរបស់មនុស្សក៏ ដូចគ្នានឹងរឿងរ៉ាវរបស់អាទិទេព ដែរ។ មនុស្សមានប្រពន្ធនិងកូន អាទិទេព ក៏មានប្រពន្ធនិងកូន។ មនុស្សមានរឿងឈ្លោះ បែកបាក់គ្នាអាទិទេពក៏មានរឿងឈ្លោះបែកបាក់គ្នា។

### ៣.៣.១. ព្រះហរិហរៈ

នៅក្នុងជំនឿព្រហ្មញ្ញសាសនា អ្នកជឿជឿទៅលើអាទិទេពសំខាន់ៗបី ដែលគេឱ្យឈ្មោះថា ត្រីមូ៌តិ (trinity) គឺ **គណៈព្រះព្រហ្ម**, **គណៈព្រះ សិវៈ**, និង **គណៈព្រះ វិស្ណុ**។ ក្នុងចំណោមគណៈទាំងបីនេះ **គណៈ ព្រះសិវៈ** មានប្រជាប្រិយភាពជាង **គណៈ ព្រះព្រហ្ម** និង **គណៈព្រះវិស្ណុ**។**គណៈព្រះព្រហ្ម** មិនសូវជាមានអ្នកគោរព ច្រើនទេនៅស្រុកខ្មែរ ដោយហេតុនេះ ហើយបានគេ មិនដែលឃើញគណៈនេះមានការប៉ះទង្គិច គ្នាដូច **គណៈព្រះសិវៈ** និង **គណៈព្រះវិស្ណុ** ទេ។ ហេតុនេះ **ព្រះ ហរិហរៈ** គឺជាឈ្មោះថ្មីមួយដែលកើត ឡើងមកពីការសម្របសម្រួលគ្នារវាង អាទិទេពពីរឱ្យមានការឯកភាពគ្នាគឺ **ព្រះវិស្ណុ** និង **ព្រះសិវៈ** (ព្រះហរិ= ព្រះវិស្ណុ; ព្រះ ហរៈ= ព្រះសិវៈ) សម្រាប់ការគោរពរួមគ្នាកុំឱ្យមានជម្លោះ។ ក្នុងការកសាង **បដិមាព្រះហរិហរៈ** គេត្រូវចែកជាពីរផ្នែក ៖ ពាក់កណ្តាលខាងស្តាំ គឺជា **ព្រះសិវៈ** និងពាក់កណ្តាលខាងឆ្វេង គឺជា **ព្រះវិស្ណុ**។ ប្រទេសកម្ពុជា គោរព **ព្រះហរិហរៈ** តាំងពីសម័យហ្វូណនតហូតមកដល់សម័យចេនឡា តែក្រោយតមកទៀត គេពុំឃើញមានការគោរពព្រះហរិហរៈ នេះទៀតឡើយ[២៨]។

### ៣.៣.២. សិវលិង្គ

ជាធម្មតា **ព្រះសិវៈ** ត្រូវបានគេ គោរពបូជានៅក្នុងទម្រង់ជា **លិង្គ** ដែលឱ្យឈ្មោះថា **សិវៈលិង្គ**។ **សិវៈលិង្គ** (Lingam/ Linga) គឺជាអង្គជាតិរបស់ **ព្រះសិវៈ** ដែល មានបដិមាជាលិង្គ តំណាងឱ្យព្រះអង្គ និង អំណាចបង្កើតលោករបស់ព្រះអង្គ។ **លឹង្គ** គេឆ្លាក់មានរាងជា ៤ជ្រុងនៅគល់ មានរាង៨ ជ្រុងនៅកណ្តាល និងមានរាងមូលនៅខាង ចុង។ នៅសម័យដែលខ្មែរគោរពព្រះឥសូរ **លិង្គ** ត្រូវបានគេសាងឡើងធ្វើជានិមិត្តរូប ព្រះមហាក្សត្រតម្កល់នៅក្នុងប្រាសាទ។ **លិង្គ** ដែលបន្សល់មកពីសម័យអង្គរ ជា ទូទៅគេ ធ្វើពីថ្មផុស។ **លិង្គ** សម័យអង្គរ មានប្រភេទមិនដូចគ្នាទេ។

---

[២៨] ត្រឹង ង៉ា, "*ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)*", ដ.ឯ.ម, ទំព័រ ៧៦



- រូបលិង្គដែលមានសណ្ឋានបីបែប ជា និមិត្តរូបព្រហ្ម, ព្រះវិស្ណុ, និងព្រះសិវៈ។
- លិង្គបដិមាតម្កល់លើយោនីជានិមិត្តរូបនៃសម្ព័ន្ធភាព ភេទក្នុងការបង្កើតលោកនិងការដុះដាល។

ប្រភព ៖ រូបថតនៅក្រសួងអភិរក្សអង្គរ

*- លិង្គមួយចំនួនគេដាក់នៅលើទម្រ ដែលផ្ទៃរាបរាងការ៉េ គេឱ្យឈ្មោះថា **យោនី** (yoni) ជានិមិត្តរូបនៃអវៈយវៈភេទស្ត្រី។*

*- **លិង្គ** មួយចំនួនទៀតត្រូវបានគេចែកជាបីផ្នែក៖ ផ្នែករាងការ៉េបួនជ្រុង ជានិមិត្តរូប **ព្រហ្ម**, ផ្នែកកណ្ដាលមានរាងជាអដ្ឋកោណ ជានិមិត្តរូបព្រះវិស្ណុដែលមានអវតារចំនួនប្រាំបី, និងផ្នែកចុងរាងមូលទ្រវែងជានិមិត្តរូបព្រះសិវៈ។*

***លិង្គ** ជាគូនឹងយោនី។ សម្ព័ន្ធភាពនៃភេទទាំងពីរនេះ គឺតំណាងឱ្យដំណើរអមតៈនៃការបង្កើតលោក ហើយនិងការដុះដាល។*

### ៣.៣.៣. គ្រុឌជិះកនាគ



បដិមាគ្រុឌជិះលើកនាគជានិមិត្តនៃការរួបរួមសាមគ្គីគ្នាជាកម្លាំង។

ប្រភព៖ រូបថតនៅក្រសួងអភិរក្សអង្គរ

***គ្រុឌ** និង **នាគ** គឺជាយានជំនិះរបស់ព្រះវិស្ណុ។ នៅក្នុងស្នាដៃស្ថាបត្យកម្មខ្មែរ គេតែងតែឆ្លាក់រូបគ្រុឌជិះលើក្បាលនាគ នេះបង្ហាញឱ្យឃើញពីគំនិតបង្រួបបង្រួមរវាងសត្វនាគនិងគ្រុឌ ព្រោះថា ជាធម្មជាតិសត្វទាំងពីរនេះមិនដូចគ្នា ហើយមានលំនៅក៏មិនដូចគ្នាដែរ។ គ្រុឌ គឺជាសត្វបក្សីដែលតែងតែហោះហើរនៅលើមេឃ ហើយនិងចុះមករកចំណីនៅលើដី។ ឯ នាគវិញគឺជាសត្វដែលមាន លំនៅនិងរកចំណីនៅក្នុងទឹក ហើយតែងតែផុសមកលេងនៅលើឆ្នេរខ្សាច់។ សត្វទាំងពីរនេះ មានចរិកមិនដែលត្រូវគ្នាទេ។ នៅពេល ជួបគ្នាម្ដងៗ ពួកវាតែងតែ ប្រយុទ្ធគ្នាស្លាប់រស់ ដែលជាហេតុនាំឱ្យ គ្រុឌមិនអាចចុះមករកស៊ីនៅលើដីបាន ឯនាគក៏មិនអាចឡើងមកលើគោកបានដែរ។ ហេតុនេះ សត្វទាំងពីរ*

នេះ ត្រូវប្រឈមមុខនឹងសេចក្តីស្លាប់ទាំងអស់គ្នា។ ដោយហេតុនេះហើយបានជាសិល្បៈករខ្មែរឆ្លាក់រូបសត្វទាំងពីរ នេះឱ្យនៅជាមួយគ្នា ដោយជិះគ្នា គឺចង់បង្ហាញប្រាប់ន័យ ថា ការបង្រួបបង្រួមគ្នាគឺ រស់ បែកបាក់គ្នា គឺស្លាប់។

**៣.៣.៤. ការតម្រួតព្យញ្ជនៈ**

អក្សរខ្មែរខុសប្លែកពីអក្សររបស់ជាតិផ្សេងៗ មានបាពាំង, អង់គ្លេស, ថៃជាដើម។ អក្សរខ្មែរមាន "ជើង" ឯអក្សររបស់បរទេសមិនមានជើងទេ។ តើហេតុអ្វីបានជាដូនតាខ្មែរបង្កើតអក្សរឱ្យមានជើងបែបនេះ?

អក្សរបរទេសមិនមានជើង ទំនងជាដោយសារពួកគេមិនមានតម្រូវការប្រើតម្រួត។ ឯអក្សរខ្មែរមាន "ជើង" ដោយសារតែមានតម្រូវការប្រើតម្រួត។ អក្សរ ខ្មែរអាចសរសេរជាព្យាង្គតម្រួតឬផ្ញើជើង ក៏បានជាព្យាង្គពាយក៏បាន។ ឧទាហរណ៍ ព្យាង្គតម្រួតឬផ្ញើជើង៖ បង្រួបបង្រួម, សង្គ្រាម, សន្តិភាព, រាជវង្សានុវង្ស, សត្រូវ, ខ្មែរ, ស្ត្រី, ប្រាសាទបន្ទាយស្រី ...។ល។ ឧទាហរណ៍ព្យាង្គពាយ គោ, តោ, ដំរី, យាយតា, កូចៅ...។ល។

ការធ្វើឱ្យមានការតម្រួតព្យញ្ជនៈ របស់ដូនតាបែបនេះបង្ហាញឱ្យឃើញពីគំនិតបង្រួបបង្រួម ឬការសំយោគព្យញ្ជនៈ ចូលគ្នា។

**សេចក្តីសន្និដ្ឋាន**

សិល្បៈបង្រួបបង្រួមរបស់ខ្មែរ សម័យអង្គរមានលក្ខណៈសីលធម៌ទន់ភ្លន់ បត់បែន និងប្រកបដោយ **បញ្ញា**។ ស្តេច យល់និងស្គាល់ពី **ព្រះអង្គឯង**; យល់ និង ស្គាល់ពី **ចរិកឬធម្មជាតិរបស់រាស្ត្រ** ដែលព្រះអង្គត្រូវប្រាស្រ័យទាក់ទងជា មួយច្បាស់លាស់; យល់និងស្គាល់ពី **ពេលវេលា និងទឹកទ្វេង**; **ជាស្តេច**មានសុចរិតភាព, យុត្តិធម៌, និងព្រហ្មវិហារ ធម៌។ គុណសម្បត្តិនិងគុណធម៌ទាំងនេះ គឺជាកម្លាំង និងការស្អិតជំមានប្រសិទ្ធិភាព ក្នុងការបង្រួបបង្រួមឱ្យមានការឯកភាព គ្នាជាតិ និងឈានទៅដឹកនាំជាតិឱ្យមាន សេចក្តីសុខសេចក្តីចម្រើន។ ជំនឿបង្កើត ឱ្យមានទំនុកចិត្ត និងការដើរតាម (ជឿជាក់+គោរព+ប្រតិបត្តតាម) និងឈានទៅរកការបង្រួបបង្រួមជាតិឱ្យមាន ការឯកភាពគ្នាបានយ៉ាងមានប្រសិទ្ធិភាព។ ដោយហេតុនេះ សិល្បៈនៅក្នុង ការបង្រួបបង្រួមជាតិគឺជាប្រភពនៃសម័យរុងរឿងរបស់ខ្មែរ ដែលអ្នកដឹក នាំខ្មែរមិនត្រូវបំភ្លេច ចោលនៅក្នុងកម្មវិធី ដឹកនាំរបស់ខ្លួនទេ។ អតីតកាលជា បទពិសោធន៍និងជាមេរៀន បច្ចុប្បន្ន ជាការសិក្សារៀនសូត្រពីបទពិសោធន៍ និងមេរៀន ទាំងនោះ អនាគតគឺជាផល ដែលទទួលបានពីការសិក្សារៀនសូត្រពីបទពិសោធន៍និងមេរៀនទាំងនោះ។ **ចហ្គ សានតាយាណា** (George Santayana) លើកឡើងថា "**អ្នកដែលបំភ្លេចអតីត កាលនឹងត្រូវប្រឈមមុខនឹងធ្វើរឿងដដែលៗ** (He who forgets the past is doomed to repeat it)"។ ដូច្នេះ វាដូចគ្នា នឹងការនិយាយថា យើងត្រូវតែគិតពិចារ ណាឱ្យបាន

ហួតចត់ចំពោះរឿងរ៉ាវទាំងនាពី ***អតីតកាល*** (the things of the past) ពីព្រោះពួកវាពិតជាមានឥទ្ធិពលលើ **បច្ចុប្បន្ន** (the present) និង ***អនាគត*** (the future) យ៉ាងពិតប្រាកដ។ លើសពីនេះទៀត យើងត្រូវតែចងចាំថា អ្វីដែលយើងកំពុងធ្វើនៅថ្ងៃនេះគឺជាផលិតផលមួយ អំពីអ្វីដែលគេបានធ្វើវាកាលពីមុន។ អ្វី ដែលពួកវានឹងក្លាយជាថ្ងៃស្អែក វាអាស្រ័យទៅលើអ្វីដែលយើងធ្វើនៅថ្ងៃនេះ។


## គន្ថនិទ្ទេស

### ១- ខ្សែអាត់សម្លេង, ទស្សនាវដ្តី. ការសែត

១. *ខ្សែអាត់សម្លេង កិច្ចសម្ភាសអក្សរ សាស្ត្រខ្មែរ ដោយសម្តេចព្រះមហា សុមេធាធិបតី ជោតញ្ញាណោ* ***ជួន ណាត*** *អំពីវិហារបែរមុខទៅកើត។*

### ២- ស្នាដៃនិពន្ធជាភាសាខ្មែរ

១. ឆេង ផុន, តម្រូវការសីលធម៌ព្រះពុទ្ធ សាសនា ក្នុងសង្គមខ្មែរ នៅក្នុង *"ពុទ្ធ សាសនានិងការលើកស្ទួយជីវិតពុទ្ធ បរិស័ទ"*, ការផ្សាយរបស់ពុទ្ធសា- សនាដើម្បីអភិវឌ្ឍន៍, អន្លង់វិល, គ. ស. ១៩៩៦

២. ជួនណាត *"វចនានុក្រមខ្មែរ* (អេឡិច ត្រូនិច)," រក្សាសិទ្ធិដោយវិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យ, ២០០៨

៣. ត្រឹង ង៉ា, *"ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និង ភាគ២)"*, ភ្នំពេញ, គ. ស. ១៩៧៣ / ព. ស. ២៥១៧

៤. ហ. មណីចិន្តា, *ព្រះបាទធម្មិក*, អន្លង់ វិល, បោះពុម្ពលើកទី៣, ១៩៩៦

### ៣- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

1. A S Homby, *Oxford Advanced Learner's Dictionary of Current English,* 5th Ed. Oxford University Press, New York, 1999
2. Cambridge *Advanced Learner's Dictionary,* 3rd Ed
3. Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974

# ទស្សនៈប្រធានវិស័យនិយម

(The subjectivism)

ដោយៈ បណ្ឌិត **ភ្នាន់ ធុល**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## ១- សេចក្តីផ្តើម

***វត្ថុទាំងឡាយ*** នៅក្នុងធម្មជាតិ ឬក៏ ហៅម្យ៉ាងទៀតថា ***វត្ថុធម្មជាតិ*** (natural things) ក៏បាន។ វត្ថុទាំងឡាយនេះសុទ្ធតែ មាន ***គុណភាព*** (quality) ផ្ទាល់របស់ពួកវា ប៉ុន្តែមនុស្សទាំងឡាយមានការយល់ដឹងអំពី ***ទីតាំងគុណភាព*** (quality) របស់ពួកវា មិនដូចគ្នាទេ។

អ្នកខ្លះយល់ឃើញថា ***ទីតាំងនៃគុណភាពរបស់វត្ថុ*** មាននៅក្នុងវត្ថុ។ ករណីដូចជា ***សោភ័ណភាពរបស់ផ្កាមួយទង, ភាពរឹងរបស់ពេជ្រ, សេចក្តីរីករាយនៃបទចម្រៀង*** សុទ្ធតែជា ***គុណភាពពិត*** ដែលគេទាញបានមកពីផ្កា, មកពីពេជ្រ, និងមកពីបទចម្រៀងទាំងអស់។ នេះមានន័យថា ទីតាំងនៃគុណភាពរបស់វត្ថុមានពិតនៅក្នុងវត្ថុ ពោលគឺជាគុណភាពពិតរបស់វត្ថុនេះឯង។ ទស្សនៈដែលយល់ឃើញបែបនេះគេឱ្យឈ្មោះថា ***ទស្សនៈវត្ថុវិស័យនិយម*** (objectivism)។

ចំណែកឯអ្នកខ្លះទៀតយល់ឃើញផ្ទុយពីនេះថា ***ទីតាំងនៃគុណភាពរបស់វត្ថុ*** ពោលគឺ ***សោភ័ណភាពរបស់ផ្កាមួយទង, ភាពរឹងរបស់ពេជ្រ*** ជាដើម សុទ្ធតែមាន ទីតាំងនៅក្នុង***ចិត្តរបស់មនុស្ស*** (human mind)។ នេះមានន័យថា ទីណាមានមនុស្ស ទីនោះក៏គេគិតថា ***គុណភាពរបស់វត្ថុ*** មាន អត្ថិភាពដែរ រីឯទីណាដែលគ្មានមនុស្ស ទី នោះក៏គេគិតថា ***គុណភាពរបស់វត្ថុ*** មិន មានអត្ថិភាព ដែរ។ ទស្សនៈដែលយល់ ឃើញបែបនេះ គេឱ្យឈ្មោះថា ***ទស្សនៈប្រធានវិស័យនិយម*** (subjectivism)។

ការជជែកវែកញែកសួរដេញដោលគ្នាពីរឿងរ៉ាវអំពី ***ទីតាំងនៃគុណភាពរបស់វត្ថុនេះ*** កើតមានតាំងពីយូរយារមកហើយ គឺ តាំងពីសម័យផ្លេតូ (Plato) និងអារីស្តូតឹល (Aristotle) ដែលជាទស្សនវិទូក្រិកមកម្ល៉េះ រហូតមកដល់ពេលសព្វថ្ងៃនេះក៏នៅតែមានការជជែកគ្នាមិនទាន់ដាច់ស្រេចនៅ ឡើយទេ ដូចជាការជជែកគ្នាពីរឿង ***លទ្ធិរូបធាតុនិយម*** (materialism) របស់អារីស្តូតឹល និង ***លទ្ធិមនោនិយម*** (idealism) របស់ផ្លេតូដូច្នេះដែរ។

បើមានការជជែកដោយខ្វែងគំនិតគ្នាបែបនេះ តើទីតាំងពិតនៃគុណភាពរបស់វត្ថុ ឋិតនៅទីណា ឋិតនៅក្នុង **វត្ថុ** (តាមទស្សនៈវត្ថុវិស័យនិយម) ឬក៏ឋិត នៅក្នុង **គំនិតមនុស្ស** (តាមទស្សនៈ ប្រធានវិស័យនិយម)?

រឿងនេះ ទោះជាវាមានទីតាំងឋិត នៅទីណាមួយក៏ដោយ ខ្ញុំទុកលទ្ធភាពឱ្យអ្នកដែលស្រលាញ់ចូលចិត្តគិត និងស្រាវជ្រាវទស្សនវិជ្ជាធ្វើការគិតដើម្បីស្វែងរកចម្លើយដោយខ្លួនឯង។ នៅទីនេះ ខ្ញុំសុំ លើកយកតែ **ទស្សនៈប្រធានវិស័យនិយម** បកស្រាយតែប៉ុណ្ណោះ ចំណែកឯ **ទស្សនៈ វត្ថុវិស័យនិយម** លើកទៅសំណេរបន្ទាប់។ ខាងក្រោមនេះគឺជាគំនិតយល់ឃើញ និង ជាការបកស្រាយពី **ទីតាំងនៃ គុណភាពរបស់វត្ថុ** ដែលមានប្រភពនៅក្នុង **ចិត្តមនុស្ស** តាម **ទស្សនៈប្រធានវិស័យ និយម**។

## ២- ខ្លឹមសារ

**ទស្សនៈប្រធានវិស័យនិយម** ផ្សំឡើងពាក្យថា **ទស្សនៈ + ប្រធាន + វិស័យ + និយម**។ **ទស្សនៈ** គឺដំណើរយល់ឃើញ; **ប្រធាន** គឺ មេ ឬ អ្នកដែលជាធំជាងគេ ដូច ជាប្រធានក្រុម, ប្រធានក្រុមប្រឹក្សា, មេគ្រួសារ, មេទ័ព; **វិស័យ** គឺ អារម្មណ៍, គំនិត, ទី, តំបន់, ទីបំផុត (នៃការមើលឃើញ) ករណីដូចជា ចក្ខុវិស័យ គឺជាទីបំផុត ឬចម្ងាយមួយដែលអាចក្រឡេកមើលទៅឃើញ, ចម្ងាយមួយបំផុតចុងភ្នែក; **និយម** គឺជាសេចក្ដីកំណត់, ធម្មតា, ធម្មជាតិ ឬ អនុលោមតាម, ការចូលចិត្តប្រកាន់យក ឬដើរតាម។

**ទស្សនៈប្រធានវិស័យនិយម** ឬ អាចហៅ បានម្យ៉ាងទៀតថា ទស្សនៈអត្តនោម័តិនិយម (= ទស្សនៈ + អត្តនោម័តិ + និយម)។ អត្តនោម័តិ (= អត្តនោ "នៃខ្លួន" + មតិ "គំនិត, ការយល់ឃើញ") គឺគំនិតនៃខ្លួន ឬការយល់ឃើញរបស់ខ្លួន; ការយល់ឃើញដោយគំនិតរបស់ខ្លួន[១]។

ទាំង **ទស្សនៈប្រធានវិស័យនិយម** និង **ទស្សនៈអត្តនោម័តិនិយម** មានអត្ថន័យជាភាសាអង់គ្លេសថា "subjectivism" ដែលមានន័យផ្ទុយគ្នាជាមួយនឹងពាក្យថា "objectivism"។ ពាក្យ subjectivism ទាញ ចេញមកពីពាក្យដើមថា subject (ប្រធាន) ដែលអាចបំបែកទៅជា subjection (ការដាក់ឱ្យនៅក្រោមអំណាច), subjective (តាមជំនឿ ឬគំនិតរបស់អ្នកណាម្នាក់), subjectivism (លទ្ធិអត្តនោម័តិនិយម), subjectivist (អ្នកអត្តនោម័តិនិយម), subjectivity (ប្រធានវិស័យភាព, អត្តនោ ម័តិ)។ បើនៅក្នុងសំណង់ប្រយោគភាសា អង់គ្លេស ដូចជា subject + Verb + object ... ពាក្យ subject មានន័យថា **ប្រធាន ប្រយោគ** ឬប្រធានកិរិយាស័ព្ទ មានន័យថា ជាអ្នកធ្វើអំពើទៅលើវត្ថុ ដែលគេ

[១] ជួនណាត "វចនានុក្រមខ្មែរ (អេឡិចត្រូនិច)," រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ ទស្សនៈ, ប្រធាន, វិស័យ, និយម, អត្តនោម័តិ

ហៅថា កម្មបទ (object)។ បើប្រើផ្សំជាមួយពាក្យដទៃទៀត ដូចជា subject of discussion មានន័យថា ប្រធានបទពិភាក្សា, subject of investigation មានន័យថាកម្មវត្ថុ ពោល គឺអ្វីមួយដែលត្រូវគេលើកយកមកពិនិត្យ សង្កេត)។

ហេតុនេះ ទស្សនៈប្រធានវិស័យ និយម ឬទស្សនៈអត្តនោម័តិ មានន័យជា រួមថា គឺជា ***ការយល់ឃើញទៅតាមគំនិតរបស់ខ្លួនឯង***។

*គំនូសបំព្រួញអំពីប្រធានវិស័យនិយម*

*គំនិតមនុស្ស → វត្ថុ*



នៅក្នុងទ្រឹស្តីពុទ្ធិ ឬពុទ្ធិវិទ្យា (epistmology) ទស្សនៈប្រធានវិស័យនិយម គឺ ជាទស្សនៈមួយដែលអះអាងថា **ពុទ្ធិ** របស់យើងចំពោះ **វត្ថុ** (object) ពោលគឺ **គុណភាព** (quality) **របស់វា** ហើយនិង ទំនាក់ទំនងអត្ថិភាពរវាង **វត្ថុ** និង **ប្រធានវិស័យ** [មនុស្ស (knower)] មានទំនាក់ទំនងគ្នាទៅនឹង **ចិត្ត** (mind), **លក្ខខណ្ឌសរីរាង្គឥន្ទ្រិយ**(condition of sense organs) របស់យើង ក៏ដូចជា**កាលៈទេសៈ** (circumstances) ដែលនៅជុំវិញវត្ថុនោះ ដែរ។ កាលនិងលំហរ បានធ្វើឱ្យ **សភាពខួរក្បាល** (the mental state) ហើយនិង **លក្ខខណ្ឌសរីរាង្គឥន្ទ្រិយ**[2] របស់មនុស្សដូចជា ភ្នែក (ចក្ខុន្ទ្រិយ), ត្រចៀក (សោតិន្ទ្រិយ) ច្រមុះ (ឃានិន្ទ្រិយ), អណ្តាត (ជីវ្ហិន្ទ្រិយ), កាយ (កាយិន្ទ្រិយ), មនោឬចិត្ត (មនិន្ទ្រិយ)[3] ជាដើម ប្រែប្រួល នៅពេលនោះ **គំនិត** (ចិត្ត ឬ អារម្មណ៍) របស់យើងចំពោះ **គុណភាពរបស់វត្ថុ** ក៏នឹងប្រែប្រួលពី មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដែរ។ ជា ការពិត អ្នកជំងឺគ្រុនក្តៅ មានការយល់ដឹង ពីទ្រង់ទ្រាយនិងពណ៌វត្ថុជាក់ស្តែងខុសពី ការយល់ដឹងរបស់មនុស្សធម្មតា។ នៅ មានកត្តាក្រៅខ្លួន មនុស្សដទៃទៀតដូចជា **ពន្លឺ** (light) និង **ចម្ងាយ** (distance) ក៏មាន ឥទ្ធិពលទៅ លើការយល់ដឹងពីវត្ថុរបស់ គេដែរ។ ជាឧទាហរណ៍ **វត្ថុតែមួយ** អាច មានការយល់ឃើញខុសគ្នាពីមនុស្សម្នាក់ដែលបិតនៅក្រោមពន្លឺព្រះអាទិត្យដ៏ភ្លឺចាំង និងមនុស្សម្នាក់ទៀតដែលបិតនៅក្នុងបន្ទប់ងងឹត។ មានករណីដូចគ្នានេះដែរ មនុស្សម្នាក់មើលវត្ថុក្នុងចម្ងាយមួយម៉ែត្រ ឯមនុស្សម្នាក់ទៀតមើលវត្ថុក្នុងចម្ងាយ មួយពាន់ម៉ែត្រ[4]។ កិច្ចសន្យាមួយមានអត្ថិភាពដោយសារតែសភាពចិត្តប្រែប្រួល។

ទ្រឹស្តីប្រធានវិស័យចំពោះពុទ្ធិនេះបាន ចាប់ផ្តើមតាំងពីសម័យសូក្រាធីស (the Socratic period) មកម៉្លេះ គឺនៅពេល ដែលពួកសូហ្វីសវិទូ (sophist) ដែលជា ក្រុមទស្សនវិទូចំណាន។

២ Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974 p.59

៣ ជូនណាត, ជ.ឯ.ម, ទំព័រ ឥន្ទ្រិយ

៤ Venancio B. Ardales, op. cit. p.59

និងជាទស្សនវិទូ ដំបូងគេគិតពីកម្រៃសម្រាប់ការអប់រំបាន បង្រៀនថា "មនុស្សគឺជារង្វាស់នៃគ្រប់ វត្ថុទាំងអស់ (man is the measure of all things)"។ ប្រូថាហ្គ័រាស (Protagoras) ជា សូហ្វីសវិទូល្បីល្បាញបានពោលថា ពុទ្ធិ មានទំនាក់ទំនងគ្នា ពោលគឺ វាគ្រាន់តែជាបញ្ហាមតិយោបល់ (a matter of opinion) ប៉ុណ្ណោះ។ ហេតុដូចនេះ មតិយោបល់ ពិសេសៗរបស់មនុស្សម្នាក់ៗមានលក្ខណៈត្រឹមត្រូវដោយឥតគិតថា តើវាអនុលោមទៅតាមមតិយោបល់របស់អ្នកដទៃដែរឬអត់ នោះទេ។ "អ្វីដែលត្រឹមត្រូវចំពោះអ្នកគឺវាត្រឹមត្រូវចំពោះអ្នក ហើយ អ្វីដែលត្រឹមត្រូវចំពោះខ្ញុំគឺ វាត្រឹមត្រូវ ចំពោះខ្ញុំ"។ ដូច្នេះ ប្រសិនបើរឿងនេះជា ករណីយមួយ (the case) នៅពេលនោះ ***តថភាព*** (reality) គឺពិតជាកើតឡើងដោយមនុស្ស ព្រោះថា បទពិសោធន៍ឥន្ទ្រិយ (sense experiences) របស់គេគឺជាការឆ្លុះបញ្ចាំងផ្ទាល់ពី ***ពិភពខាងក្រៅ*** (the external world)។ ហេតុដូច្នេះ តថភាព មិនមែនមានតែមួយ ប៉ុន្តែមានច្រើន គឺមាន ច្រើនទៅតាមចំនួនមនុស្ស ដែលយល់ដឹង ហើយនិងឆ្លុះបញ្ចាំងអំពីពិភពខាងក្រៅនោះដែរ[5]។

មានមតិរិះគន់មួយប្រឆាំងទល់នឹងទ្រឹស្តីប្រធានវិស័យនេះ។ មតិរិះគន់នេះ បានលើកពីសំណួរថា តើគេអាចទុកចិត្ត លើប្រធានវិស័យក្នុងការវិនិច្ឆ័យដោយ ត្រឹមត្រូវពីគុណភាពពិតរបស់វត្ថុបានដែរ ឬទេ? ចម្លើយគឺថាទេ គេមិនអាចទុកចិត្តវា បានទេ ពីព្រោះថា សរីរាង្គឥន្ទ្រិយរបស់ យើងដែលបានផ្តល់ឱ្យយើងនូវទិន្នន័យថ្មី ៗ (raw data) សម្រាប់ស្មារតីយកមកធ្វើ ការវិភាគ និងបកស្រាយពន្យល់នោះនៅ មិនទាន់សុក្រិតនៅឡើយទេ។ ជាញយៗ វាតែងកុហក់ ឬបោកបញ្ឆោតយើង។ ម្យ៉ាងទៀត ឥន្ទ្រិយពុទ្ធិ (sense perceptions) របស់យើងមិនអាចបុកទម្លាយចូលទៅ ផ្នែកខាងក្នុងរបស់វត្ថុបានឡើយ។ ដូច្នេះ ពុទ្ធិរបស់យើងនៅមានលក្ខណៈសើរៗ មិនស៊ីជម្រៅ (superficial) នៅឡើយទេ។ ដូច្នេះ គ្មានអ្នកណាម្នាក់ ហ៊ានអះអាងពីពុទ្ធិ ដាច់ខាត (absolute knowledge) របស់គេ បានឡើយ; ដោយហេតុថាអ្វីដែលគេ ស្គាល់នោះគឺវាទាក់ទងគ្នា និងត្រូវកំណត់ដោយ ***បទពិសោធន៍*** (experience) របស់យើងម្នាក់ៗ[6]។

## ៣- បទពិសោធន៍

នៅក្នុងជីវភាពរស់នៅធម្មតា ***បទពិសោធន៍*** (experience) មានន័យថាគឺជាដំណើរការក្នុងការទទួលបាន **ចំណេះដឹង** (knowledge) ឬ **ជំនាញ** (skill) នៅក្នុងរយៈពេលមួយ តាមរយៈ ***ការឃើញ***, ការមានវេទនារម្មណ៍, និង ***ការធ្វើអ្វីៗ*** ជាជាង តាមរយៈការ

[5] Venancio B. Ardales, op. cit. p.59

[6] Venancio B. Ardales, op. cit. p.60

សិក្សា[7]។

នៅក្នុងទស្សនវិជ្ជា **បទពិសោធន៍** ជាទូទៅគឺជាអ្វីដែលយើងយល់ឃើញតាមរយៈ អង្គវិញ្ញាណ (senses) ដែលយើងហៅថា **បទពិសោធន៍ឥន្ទ្រិយ** (sensory experience) ដែលជាអ្វីដែលយើងរៀនពីអ្នកដទៃ ឬជាអ្វីក៏ដោយដែលចេញមកពី ប្រភពខាងក្រៅ (external sources) ឬក៏ចេញមកពី **ការឆ្លុះបញ្ចាំងខាងក្នុង** (inner reflection)។ ក្នុងន័យនេះ **បទពិសោធន៍** ត្រូវបានគេផ្សារភ្ជាប់ជាមួយនឹង **ការសង្កេត** (observation) ហើយនិង **ការធ្វើពិសោធន៍** (experiment)។ **លទ្ធិពិសោធន៍និយម** (empiricism) សង្កត់ធ្ងន់ថា ចំណេះដឹងរបស់យើងត្រូវតែពឹងផ្អែកទៅលើ**បទពិសោធន៍** ប៉ុន្តែ **លទ្ធិសនិទាននិយម** (rationalism) អះអាងថា **បទពិសោធន៍**គឺជា **ប្រភពសក្តានុភូតនៃកំហុស** (potential source of error) ហើយវាចូលចិត្តភាពប្រាកដប្រជាសនិទាន (rational certainty) ជាងទូទៅនិយកម្ម ដែលគ្រាន់តែជា ពិសោធន៍ ( mere empirical generaliza-tion) ។ នៅក្នុងការប្រើប្រាស់ធម្មតា រាល់ បទពិសោធន៍ទាំងអស់សុទ្ធតែមានអ្វីមួយ ដែលមានបទពិសោធន៍ ដែលឯករាជ្យពី ប្រធានបទនៃបទពិសោធន៍ (subject of experience)។ ប៉ុន្តែនៅក្នុងទស្សនវិជ្ជា ទំនាក់ទំនងរវាង **បទពិសោធន៍** ដែលជាសភាពនៃសេចក្តីដឹង (a state of cons-ciousness) និងវត្ថុឯករាជ្យពីបទពិសោធន៍ (independent objects of experience) បានក្លាយទៅជាចំណុចផ្តោតមួយនៅក្នុងការពិភាក្សាគ្នា។ វាត្រូវតែមានអ្វីមួយ ដែល គេបានផ្តល់ឱ្យនៅក្នុងបទពិសោធន៍ ប៉ុន្តែ សភាពនៃអ្វី ដែលគេបានផ្តល់ឱ្យនោះ គឺ មានភាពចម្រូងចម្រាសខ្លាំងណាស់។ ចម្លើយផ្សេងៗគ្នា គឺអាស្រ័យទៅលើ គោលជំហរដូចជា **លទ្ធិតបនិយម** (realism), **លទ្ធិមនោនិយម** (idealism), និង **លទ្ធិមជ្ឈជាតុនិយម** (skepticism)។ មានវិធីយល់ដឹងពីអ្វីដែលគេបានផ្តល់ឱ្យ ផ្សេងៗពីគ្នា ហើយក៏ជាប់ពាក់ព័ន្ធទៅនឹង វិធីយល់ដឹងពីសញ្ញាណទិន្នន័យឥន្ទ្រិយ (sense-data) ខុសៗគ្នាផងដែរ។ វាក៏មាន ការជជែកវែកញែកអំពីទំនាក់ទំនងរវាង **បទពិសោធន៍** និង **ទ្រឹស្តី** ផងដែរ។ ចាប់ផ្តើម ដោយខាន្ត(Kant) គឺថា មានទំនោរមួយក្នុង ការបដិសេធពីរឿងរ៉ាវបទពិសោធន៍ ដែលជាឥន្ទ្រិយារម្មណ៍ សុទ្ធសាធដែលមិនដំណើរការដោយគំនិត។ នៅក្នុងទស្សនវិជ្ជាចិត្តទំនើប មានប្រធានបទសំខាន់មួយ ដែលទាក់ទងទៅនឹងបញ្ហាទ្រឹស្តីជាច្រើន ទាក់ទងទៅនឹងឯកជនភាពដែលគេពោលអះអាងពីបទពិសោធន៍មួយ ដែលជាព្រឹត្តិការណ៍មួយដែលអាចដឹងបានតែចំពោះម្ចាស់របស់វា ហើយនិងលទ្ធភាពចូលទៅ

៧ Jonathan Crowther, *"Oxford Advanced Learner's Dictionary of Current English,"* 5th ed. Oxford university press, 1995 p.404

ដល់បទពិសោធន៍នោះជាសាធារណៈ[៨]។

នៅចុងចំណុចទី២អំពីខ្លឹមសារ ប្រធានវិស័យ មានមតិរិះគន់មួយបាន ចោទសួរថា តើគេអាចទុកចិត្តលើប្រធាន វិស័យក្នុងការវិនិច្ឆ័យដោយត្រឹមត្រូវពី **គុណភាពពិតរបស់វត្ថុ** បានដែរឬទេនោះ មានចម្លើយមួយឆ្លើយតបទៅនឹងការចោទសួរនោះថា គេមិនអាចទុកចិត្តលើវាបានទេ ពីព្រោះថា អ្វីដែលគេស្គាល់នោះគឺវាទាក់ ទងគ្នានិងត្រូវកំណត់ដោយ **បទពិសោធន៍** (experience) របស់យើងម្នាក់ៗ។ នៅក្នុង ន័យនេះ **បទពិសោធន៍** គឺជា **គុណភាព** ឬ ជា **សមត្ថភាពយល់ដឹងរបស់ប្រធាន វិស័យ** ក្នុងការស្វែងរក **សច្ចភាពពីគុណ ភាពពិតរបស់វត្ថុ** (the truth of true quality of things)។ **ប្រធាន វិស័យ** (មនុស្ស) មាន **បទពិសោធន៍** មិនដូចគ្នាទេ។ **ប្រធាន វិស័យខ្លះ** មាន **បទពិសោធន៍** កាន់តែច្រើន ការស្វែងរកសច្ចភាពក៏កាន់តែសុក្រិត ដែលអាចឱ្យគេទុកចិត្តនិងជឿជាក់បានកាន់តែច្រើនដែរ។ ផ្ទុយទៅវិញ ប្រធាន វិស័យខ្លះមាន **បទពិសោធន៍ច្រើន** ពិតមែន តែការស្វែងរកសច្ចភាពរបស់គេនៅមាន កម្រិត មិនស៊ីជម្រៅ អសុក្រិត ដែលមិន អាចឱ្យគេជឿទុកចិត្តបានឡើយ។ ឯប្រធាន វិស័យខ្លះទៀតមាន **បទពិសោធន៍តិច** តែ គុណភាព ឬ សមត្ថភាពយល់ដឹងរបស់ ពួកគេល្អ និងស៊ីជម្រៅ ហើយប្រសិនបើ ប្រធានវិស័យទាំងអស់នោះមាន **បទពិសោធន៍** កាន់តែច្រើនទៀត គុណភាព ឬសមត្ថភាពយល់ដឹងរបស់ពួកគេក៏កាន់ តែល្អ និងស៊ីជម្រៅដែរ។ រឿងនេះអាស្រ័យទៅលើសំណុំប្រព័ន្ធគិតរបស់ ពួកគេមានគុណភាពល្អ។ ឧទាហរណ៍ អ្នកខ្លះអាចគិតបានរយៈពេលតែ១ម៉ោង ឬ ២ម៉ោង។ ឯអ្នកខ្លះទៀតបានរយៈពេល៨ ទៅ១០ម៉ោង។ ចំពោះប្រធានវិស័យដែល មានសំណុំប្រព័ន្ធគិតល្អមែនទែន អាចមាន សមត្ថភាពធ្វើការងារស្មើរគ្រប់២៤ម៉ោង ពេញ គឺសម្រាកតែ១ម៉ោងប៉ុណ្ណោះ។ ប្រធានវិស័យដែលខ្ញុំចង់សំដៅដល់នៅទី នេះ គឺជា **ព្រះពុទ្ធ**។

ព្រះពុទ្ធអង្គតែងបំពេញពុទ្ធកិច្ច៥ប្រការជានិច្ចអស់រយៈពេល៤៥វស្សា។

**កិច្ចការទី១នៅពេលព្រឹក** (ពីម៉ោង ៤.០០ ដល់ម៉ោង១២.០០ថ្ងៃត្រង់) ព្រះពុទ្ធ ទ្រង់ក្រោកពីសឹងនៅម៉ោង៤.០០ ហើយ ទ្រង់ក៏លុបលាងព្រះកាយ បន្ទាប់មកទ្រង់ ក៏គង់ធ្វើសមាធិរយៈពេលមួយម៉ោង។ បន្ទាប់មក ចាប់ពីម៉ោង៥.០០ដល់ ម៉ោង ៦.០០ ទ្រង់ទតមើលជុំវិញពិភពលោក ដោយចក្ខុញាណ (mental eye) ដើម្បី ប្រមើលមើលពីអ្នកដែលទ្រង់អាចជួយ បាន។ នៅម៉ោង៦.០០ ទ្រង់គ្រងស្បង់ចីវរ ដើម្បីយាងទៅបិណ្ឌបាត្រនៅតាមភូមិ ឬនៅតាមទីក្រុងជិតៗដែលទ្រង់កំពុងគង់ នៅ ឬប្រសិនបើមានអ្នកណាចង់ឱ្យព្រះ អង្គជួយជា

[៨] Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004 p.240

បន្ទាន់ ទ្រង់ក៏យាងទៅទីនោះ ភ្ជាមជាមួយនឹងសង្ឃដទៃ ឬក៏ទ្រង់យាង ទៅតែមួយព្រះអង្គឯងៗ បន្ទាប់មកទៀត ទ្រង់យាងពីផ្ទះមួយទៅផ្ទះមួយដោយព្រះ នេត្ររបស់ទ្រង់រំពៃមើលមិនដាក់ទៅលើដី ពីព្រោះ ខ្លាចជាន់ត្រូវសត្វផ្សេងៗ។ ព្រះ អង្គទទួលយកចង្ហាន់ដែលគេប្រគេនព្រះ អង្គដោយស្ងៀមស្ងាត់។ ប្រសិនបើព្រះអង្គ គង់នៅជាមួយសាវ័ក ព្រះអង្គយាងទៅបិណ្ឌ បាត្រជាមួយសាវ័កទាំងនោះ ដោយនិមន្តជាជួរតែមួយពីក្រោយព្រះអង្គ។ ប្រសិនបើមានមនុស្សម្នា និមន្តព្រះអង្គទៅ ផ្ទះរបស់គេដើម្បីឆាន់ចង្ហាន់ថ្ងៃត្រង់ ព្រះ អង្គក៏និមន្តទៅទីនោះ។ បន្ទាប់ពីចង្ហាន់ត្រង់ ហើយព្រះអង្គសម្តែងធម្មទេសនាដល់ ប្រជានិករនិងព្រះសង្ឃអំពី ***អរិយសច្ចៈ*** របស់ព្រះអង្គ។ ប្រសិនបើមានអ្នកណា ចង់ឱ្យព្រះអង្គបំបួសព្រះអង្គក៏បំបួសអ្នក នោះ។

***កិច្ចការទី២នៅពេលរសៀល៖*** (ចាប់ពីម៉ោង១២.០០ដល់ម៉ោង៦.០០ ល្ងាច) នេះជាពេលដែលតាមធម្មតា ព្រះ សង្ឃនិមន្តចូលមកគាល់ព្រះពុទ្ធ ដើម្បីសួរ សំណួរដល់ព្រះអង្គ។ ប្រសិនបើមាន សំណួរវិញ ព្រះអង្គឆ្លើយនិងដោះស្រាយ វាហើយប្រទានដំបូន្មានដល់ពួកសង្ឃ ហើយនិងប្រធានបទសម្រាប់ចម្រើនការនោ។ នៅពេលពួកសង្ឃនិមន្តចេញទៅ ព្រះអង្គសំរាកនៅក្នុងបន្ទប់ព្រះអង្គ ហើយ ទ្រង់ទតមើលជុំវិញពិភពលោកដោយចក្ខុញាណរបស់ទ្រង់ថា តើមានសត្វលោក ណាត្រូវការឱ្យព្រះអង្គជួយដែរឬទេ។ ប្រសិនបើព្រះអង្គរកឃើញ ទ្រង់ក៏និមន្ត ទៅទីនោះ។ ឬប្រសិនបើគ្មានទេ ទ្រង់និមន្ត មកខាងក្រៅបន្ទប់ ដើម្បីជួបជាមួយ មនុស្សរាប់រយនាក់ ដែលកំពុងរង់ចាំស្តាប់ ធម្មទេសនារបស់ព្រះអង្គ។

***ការប្រមើលមើលលើកទី១*** (ពីម៉ោង ៦.០០ ដល់ ១០.០០ ល្ងាច) អំឡុងពេលនេះ ព្រះសង្ឃនិមន្តមកម្តងទៀត ដើម្បីស្តាប់ ធម្មទេសនានិងសួរសំណួរចំពោះសេចក្តី មន្ទិលសង្ស័យរបស់ពួកគេឱ្យច្បាស់ លាស់។ មនុស្សម្នាមកគាល់ព្រះពុទ្ធនៅ ពេលនេះនៅពេលយប់។

***ការប្រមើលមើលលើកទី២*** (១០.០០ យប់-២.០០ព្រឹក) អំឡុងពេលនេះ ទេពតាយាងមកគាល់ព្រះពុទ្ធ និងសិក្សាពីសច្ចធម៌នៃជីវិតរបស់ទ្រង់ យើងមិនអាចមើលឃើញដោយភ្នែកទទេបានទេ។

***ការប្រមើលមើលលើកចុងក្រោយ*** (២.០០-៤.០០ព្រឹក) ពីម៉ោង២ដល់ម៉ោង៣ ទ្រង់និមន្តចុះឡើងៗ។ ***ពីម៉ោង៣ដល់ម៉ោង៤ព្រះពុទ្ធផ្ទំ***។ បន្ទាប់មកទ្រង់ក៏ក្រោក ហើយបន្តការងាររបស់ព្រះអង្គទៅតាម លំដាប់តទៅទៀត[៩]។

ដូចនេះយើងឃើញថា ព្រះពុទ្ធរវល់ពេញមួយថ្ងៃ។ តាមពិត ព្រះពុទ្ធផ្ទំតែមួយម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃអស់រយៈពេល

---

[៩] Rev. Siridhama, *the life of the Buddha*, Taiwan,1995, p72-73

៤៩ឆ្នាំក្នុងភាពជាព្រះពុទ្ធ។ អំឡុងពេលថ្ងៃដំបូង ព្រះអង្គទ្រង់ទតឃើញពិភពលោកទាំងមូល និងសុំឱ្យពិភពលោកទាំងមូល ប្រកបដោយសេចក្តីស្រលាញ់គ្មានទីបញ្ចប់របស់ទ្រង់ផង និងនាំមកនូវភាពសប្បាយ រីករាយដល់មនុស្សរាប់លាននាក់ផង។

## សេចក្តីសន្និដ្ឋាន

ប្រធានវិស័យមានកម្រិតទាបខ្ពស់ មិនដូចគ្នាទេ។ កត្តាដែលធ្វើឱ្យវាមិនអាចដូចគ្នានេះ គឺវាទាក់ទងជាសំខាន់ទៅលើ **បទពិសោធន៍តិចឬច្រើន** និង **គុណភាពនៃសំណុំប្រព័ន្ធគិត** របស់គេ។ នៅក្នុងកំណត់ត្រាប្រវត្តិទស្សនវិជ្ជាក្រិកបុរាណបង្ហាញ ថា ទស្សនវិទូសម័យដើមមានការយល់ ខុសទៅលើទម្រង់ ហើយនិងទំហំផែនដី។ **សេលីស** [Thales (៦២៤-៥៤៧ មុន គ.ស.)] ជាទស្សនវិទូ, គណិតវិទូ, និងជាតារាវិទូដំបូងរបស់ក្រិក។ នៅក្នុងការស្រាវជ្រាវអំពីផែនដី លោកយល់ថា ផែនដីប្រៀបដូចជាថាសធំសម្បើមមួយ ដែលអណ្តែតលើផ្ទៃទឹក។ លោកយល់ថា **ការញ្ញួយផែនដី** គឺជាការប៉ះទង្គិចយ៉ាង ខ្លាំងរវាងផែនដីនិងព្យុះរលកសមុទ្រ។ ការប៉ះទង្គិចនោះប្រៀបដូចជាការប៉ះ ទង្គិចនៃ កប៉ាល់មួយនៅលើទឹក ដែលមានរលក ខ្លាំង។ ការពន្យល់បែបនេះធ្វើឱ្យមនុស្ស សម័យនោះមានការយល់ស្របដោយខុសជាច្រើន។ ការអនុញ្ញាតឱ្យ **មតិភាគច្រើន** ឬមនុស្សគ្រប់រូបធ្វើការសម្រេចចិត្តទៅ លើ **បញ្ហាវិទ្យាសាស្ត្រ** នៅពេលដែលពួក គេមិនមែនជា **អ្នកវិទ្យាសាស្ត្រ** ដែលមិន ធ្លាប់បានទទួលនូវការ ហ្វឹកហាត់វិទ្យាសាស្ត្រ ផងនោះ គឺជាការខុសឆ្គង ហើយគេមិនអាចយកជាការបានទេ។

ហេតុនេះប្រធានវិស័យទាមទាឱ្យមានបទពិសោធន៍ច្រើន កាន់តែច្រើនកាន់តែល្អ ដើម្បីដឹកនាំការងារនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ មិនថានៅក្នុងគ្រួសារ, សាលារៀន, ឬស្ថាប័នរដ្ឋ ឱ្យមានសេចក្តីសុខនិងសេចក្តីចម្រើន។


## គន្ថនិទ្ទេស

### I- ស្នាដៃនិពន្ធជាភាសាខ្មែរ

១- ជួនណាត, *វចនានុក្រមខ្មែរ* (អេឡិចត្រូនិច), រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨។

### II- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

1- Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974

2- Jonathan Crowther, *"Oxford Advanced Learner's Dictionary of Current English,"* 5th ed. Oxford university press, 1995

3- Nicholas Bunnin And Jiyuan Yu,

.

*The Blackwell Dictionary of Western Philosophy*, USA, First published, 2004

4- Rev. Siridhama, *the life of the Buddha*, Taiwan,1995

# គូបដិបក្ខនៃអង្គវត្ថុ

(Opponents of an object)

*ដោយៈ បណ្ឌិត* **ភ្លាន់ ធុល**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*គេនិយាយថា ការងារបង្រៀន មនុស្ស ហើយបន្ទាប់មកមនុស្សបាន បង្រៀនការងារ ទៅដល់មនុស្ស។ កាល ពីសម័យកុម្មុយនិស្ត បុព្វកាល មនុស្សកើត ឡើងដំបូងមិនទាន់ចេះ ធ្វើអ្វីៗនៅឡើយទេ។ ពួកគេរស់នៅក្នុងធម្មជាតិ ក្នុងសភាពជា សត្វដែលខុសប្លែកពីមនុស្ស។ បន្ទាប់ពីពួក គេរស់នៅក្នុងធម្មជាតិអស់រយៈ ពេលដ៏ យូរ ធម្មជាតិបានបង្រៀនមនុស្សឱ្យ ចេះគិត ដោយចាប់ផ្តើមពី* ***ចម្ងល់មិនចេះចប់***។ *ជាបន្តបន្ទាប់ ពួកគេក៏ចេះគិតនិងចេះស្វែង រកការរស់នៅមួយកាន់តែប្រសើរឡើងៗ។ អភិវឌ្ឍន៍គំនិតគឺជាប្រភពនៃអភិវឌ្ឍន៍ ទ្រឹស្តី និងអនុវត្តន៍ ដែលជាប្រភពមូលដ្ឋានរបស់* ***ទស្សនវិជ្ជា*** (philosophies) *និង* ***វិទ្យាសាស្ត្រ*** (sciences)។ *ការគិតរកសច្ចភាព មនុស្សបានប្រើវិធីជាច្រើន មានវិធី អនុមានរួម វិធីអនុមានញែក...ល...។ ដែលនៅក្នុងនោះ* ***វិធីបដិសំយោគ*** *ជាវិធី សំខាន់មួយដែលទស្សនវិទូបានបង្កើតឡើង ដើម្បីប្រើប្រាស់ក្នុងការស្វែងយល់ ពី* ***គូបដិបក្ខ*** *និង* ***ការតស៊ូ*** *នៃអង្គវត្ថុ,* ***ការ សំយោគ*** *និង* ***ការបំបែក***, ***តម្រូវការ*** *និង* ***ការបំពេញឱ្យគ្នា*** *របស់ពួកវា។*

## ២. ទ្រឹស្តីគូបដិបក្ខ

*នៅក្នុងប្រធានបទដែលលើកឡើងពីគូ បដិបក្ខនៃអង្គវត្ថុ ខ្ញុំមានការបកស្រាយ ពន្យល់ នៅក្នុងទ្រឹស្តី៣។ ទ្រឹស្តីទី១ គឺ ទ្រឹស្តី បដិសំយោគ របស់ ហេហ្គិល និង កាល ម៉ាក្ស; ទ្រឹស្តីទី២ គឺ ទ្រឹស្តីគូបដិបក្ខនៃសម្ព័ន្ធ ផៃសាហ្គូរាននិយម* (Pythagoreanism; *និង ទ្រឹស្តីទី៣ គឺ ទ្រឹស្តីគូបដិបក្ខ នៃលោកធម៌ ទាំង៤គូ នៅក្នុងព្រះពុទ្ធសាសនា។*

### ២.១. ទ្រឹស្តីបដិសំយោគ

***ទ្រឹស្តីបដិសំយោគ*** *ត្រូវបានគេស្គាល់ ជាទូទៅថា ជាដំណើរឈានទៅដល់* ***ពុទ្ធិ*** *តាមរយៈ* ***បច្ចេកទេសសំណួរ-ចម្លើយ*** (question - and - answer technique) ។ ***ហេហ្គិល*** (Hegel) *បានពិពណ៌នាវិធីនេះថា ជាទម្រង់ការមួយ*

ដែលគំនិត (thought) ឬ **វត្ថុអត្ថិភាពមួយ** (existing thing) ដែលគេហៅថា **ទស្សនកថា** (thesis) ដឹកនាំ និង ផ្លាស់ប្តូរយ៉ាងចាំបាច់ទៅរក **គំនិតផ្ទុយ** (contradictory idea) ដែលគេហៅថា **ប្រតិទស្សនកថា** (antithesis) ដោយហេតុនេះ ហើយទើប **គំនិត ឬវត្ថុថ្មី** (new thought or thing) ដែលអាចឱ្យគេហៅថា **សំយោគទស្សនកថា** (synthesis) បានកើតឡើង។ ដំណើរនេះ ចាប់ផ្តើមឡើងតាមរយៈអំណះ អំណាងមួយអំពីអ្វីមួយ (ទស្សនកថា) ដែលមានលក្ខណៈ មិនពេញលេញ (in-comeplete)។ អ្វីមួយដែលទាក់ទងទៅនឹង អំណះអំណាងនោះ ត្រូវបានគេលុបចោល (ប្រតិទស្សនកថា)។ **អង្គបដិបក្ខ** (conflict) ដែលគេហៅថាជា **បដិសំយោគ** (dialectic) រវាងអ្វីដែលគេបានអះអាង ហើយនិងអ្វី ដែលគេបានលុបចោលនោះមានអត្ថិភាព។ ដោយសារ **អង្គបដិបក្ខ** នេះហើយទើប លេចឡើងនូវ **សំណើទី៣ថែមមួយទៀត** នោះគឺ **សំយោគទស្សនកថា** (synthesis) ដែលលុបព្រំដែន **ទស្សនកថា** (the limita- tion of the thesis) និង **ប្រតិទស្សនកថា** (the antithesis) ចោល ប៉ុន្តែវានៅតែថែរក្សាតម្លៃឱ្យគ្នាដដែល[១]។

**ម៉ាក្ស** (Marx) និង **ហេហ្គិល** បានប្រើ **ទ្រឹស្តីបដិសំយោគ** (Dialectic) នេះ ដើម្បីវិភាគទៅលើ **អភិវឌ្ឍន៍សង្គមកុំម្មុយ នីស្ត** របស់ពួកលោក។ លោកទាំងពីរបាន បង្កើតទ្រឹស្តីថា **អង្គបដិបក្ខ** (conflict) កើតមានឡើងដោយសារមាន **វណ្ណៈសង្គមពីរ** (two social classes) គឺ **ពួកមូលធន** (ទស្សនកថា) និង **កម្មករស៊ីប្រាក់ឈ្នួល** (ប្រតិទស្សនកថា)។ **ការតស៊ូវណ្ណៈស្អិតរមួត** (បដិសំយោគ) មានអត្ថិភាពរវាងវណ្ណៈទាំងពីរ។ ចំណុចមួយដែលពួកគេនឹងឈានទៅដល់នោះ គឺចំនួនពួកកម្មករដែលមានកម្លាំងគ្រប់គ្រាន់ អាចគ្របសង្កត់ទៅលើ **ពួកមូលធននិយម** បាន។ ការតស៊ូនេះនឹងដឹកនាំឆ្ពោះទៅរកការបង្កើតសង្គមមួយថ្មី គឺ **សង្គមកុម្មុយនីស្ត** (communi-stic society) ឬ **សង្គមគ្មានវណ្ណៈ** (class-less society) [សំយោគទស្សនកថា (syn- thesis)][២]។

### ២.២. ទ្រឹស្តីគូបដិបក្ខសម្ព័ន្ធ ផៃសាហ្គ្វរានិយម

គូទំនាស់បើតាម**សម្ព័ន្ធផៃសាហ្គ័រានិយម** (Pythagoreanism: ៥៧១-៤៩៧ មុនគ.ស.) ដែលជាអង្គការទស្សនវិជ្ជានិង នយោបាយរបស់ **ផៃសាហ្គ័រីស** (Pytha-goras) ទស្សនវិទូក្រិកបូរាណបានបង្កើត ប្រព័ន្ធគូបដិបក្ខមួយដែលមាន **១០គូបដិបក្ខ** ដោយចាប់ផ្តើមពី **ចំនួន** (number)។ **ផៃសាហ្គ័រីស** យល់ថា **សារជាតិនៃរាល់វត្ថុ** បានស្តែងឡើងនៅក្នុង **ចំនួន**។ ចំនួនបានបង្កើត**ពិភពលោក** និងបង្កើត

[១] Venancio B. Ardales, *Introductory Text to Philosophy*, 2nd Ed., New York, 1987, p 30

[២] Venancio B. Ardales, *op.cit,*, p 31

"សណ្តាប់ធ្នាប់សង្គម"។ ការស្គាល់ **ចំនួន** គឺជាការស្គាល់ **ពិភពលោក**។ លោកបានធ្វើឱ្យ **ចំនួន** មានលក្ខណៈអាថ៌កំបាំង មានសារជាតិអរូបីផ្តាច់ខ្លួនចេញពី **ទម្រង់រូបធាតុ**។ លោកបែងចែក **ចំនួន** តាមក្រុមដូចខាងក្រោម៖

- "ក្រុមបួន" លេខ ១ ឬឯកតាជាចំណុច (point)
- លេខ ២ ជាខ្សែបន្ទាត់ (ligne)
- លេខ ៣ ជាផ្ទៃក្រឡា (surface)
- លេខ ៤ ជាមាឌ (Volume)[3]។

គេយល់ថា អង្គធាតុនីមួយៗសុទ្ធសឹងមាន **ចំណុច** ឬឯកតាក្នុងលំហ។ បណ្តុំចំណុចទាំងនោះក្លាយជាចំនួន។ ចំនួន បាន បង្ហាញឱ្យឃើញដោយ "**ក្រុមបួន**" ដែលក្រិកហៅថា **ថេត្រាកធីស** (Tetractys)។




ថេត្រាកធីស

**សម្ព័ន្ធផែសាហ្គ័រនិយម** បញ្ជាក់ថា "**ក្រុមបួន**" ជាបាតុភូតចំឡែកមួយ ពីព្រោះ **ចំនួន ១០** គឺជាការបូកសរុបនៃ **ចំនួន ១, ២, ៣, និង៤**។ គេចាត់ទុក "**ក្រុម បួន**" ជា **អាទិទេព** ដែលបានអនុវត្ត ទស្សនៈគណិតវិទ្យាចូលទៅក្នុង **សណ្តាប់ ធ្នាប់នៃតថភាពរូបធាតុ**។ **ខ្សែបន្ទាត់** ជា **ចំណុច** ដ៏ច្រើនអនេក ដែលត្រូវបានតំរៀបជាបន្តបន្ទាប់គ្នា។ **ផ្ទៃក្រឡា** កើតឡើងដោយសារបន្សំនៃ **ខ្សែបន្ទាត់** ជាច្រើន។ **ផ្ទៃក្រឡា** រួមគ្នាជាច្រើនបង្កើតបានទៅជា **មាឌ**។ ហេតុនេះ គេយល់ថា **ចំណុច**, **ខ្សែ បន្ទាត់**, និង **ផ្ទៃក្រឡា** បានបង្កើត **រាល់វត្ថុធម្មជាតិ** ពោលគឺ ជាវត្ថុដែលមានម៉ាស់ មានលក្ខណៈទូលំទូលាយ ដែលគេអាចវាស់បាន។ "**ក្រុមដប់**" ជាចំនួនសុក្រិត្យបំផុត ជាមូលដ្ឋានសម្រាប់ពិចារណាអំពីចំនួនផ្សេងៗទៀត។ "**ក្រុមដប់**" ស្របនឹង **ភពដប់**។ អំពីទ្រឹស្តីស្តីពីផ្នែកបដិបក្ខវិញ និកាយនេះបានបង្កើតប្រព័ន្ធគូបដិបក្ខមួយដែលមាន **១០គូ** បដិបក្ខចម្បងគឺ៖

***១- ព្រំដែន និងឥតព្រំដែន***

***២- គត់ និងសេស***

***៣- ឯក និងពហុ***

***៤- ស្តាំ និងឆ្វេង***

***៥- បុរស និងស្ត្រី***

***៦- ចល័ត និងអចល័ត***

***៧- ត្រង់ និងកោង***

***៨- ភ្លឺ និងងងឹត***

***៩- ល្អ និងអាក្រក់***[4]

---

[3] ឆយ យីហ៊ាង, "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក",សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤, ទំព័រ ១២

[4] ឆយយីហ៊ាង,ដ.ឯ.ម, ទំព័រ ១២

### ១០- មុមបួន និងពហុមុខ

នៅក្នុងគូបដិបក្ខទាំងដប់នេះ គូបដិបក្ខដែលមានអត្ថន័យសំខាន់បំផុតខាងទស្សនវិជ្ជាគឺ **គូបដិបក្ខទី១**។ ដោយផ្អែកលើ **គូបដិបក្ខទាំង១០** នេះ **សម្ព័ន្ធផៃសាហ្គូរាននិយម** នេះ ពន្យល់ថា **តូរ្យតន្ត្រី** ជាបាតុភូតដែលស្តែងឡើងយ៉ាងជាក់ច្បាស់ នៃបន្សំយ៉ាងស៊ីចង្វាក់គ្នានូវ **សំឡេង** ផ្សេងៗ។ **សំឡេង** ទាំងនោះចំណុះ **រង្វាស់ប្រវែងខ្សែតន្ត្រី**។ ហេតុនេះ **សារជាតិនៃសំឡេង** ត្រូវបានកំណត់ ដោយ **បរិមាណរង្វាស់ខ្សែតន្ត្រី**។ រីឯ **សារជាតិនៃតូរ្យតន្ត្រី** គឺជាបន្សំ យ៉ាងស៊ីចង្វាក់នូវ **សំឡេង** ទាំងឡាយដែលបានកើតចេញពី **រង្វាស់ប្រវែងនៃខ្សែតន្ត្រី** នោះ[5]។

## ២.៣. ទ្រឹស្តីគូបដិបក្ខនៃលោកធម៌ទាំង៤គូ

នៅក្នុងព្រះពុទ្ធសាសនា **សេចក្តីទុក្ខ** និង **សេចក្តីសុខ** របស់មនុស្សកើតឡើង មកពីផ្លូវចិត្តឡើងចុះទៅតាម **លោកធម៌ ទាំង៨** ដែលបង្រួមមកជា ៤ គូបដិបក្ខះ

១- សុខ-ទុក្ខ

២- មានលាភ-ឥតលាភ

៣- មានយស-ឥតយស

៤- និន្ទា-សសើរ[6]។

មនុស្សគ្រប់រូបត្រេកអរចង់បាន សុខ, ចង់មានលាភ, មានយស, និងចង់ឱ្យគេលើកសសើរខ្លួន មិនចង់បានទុក្ខ, មិន ចង់គ្មានលាភ, គ្មានយស, និងមិនចង់ឱ្យគេ និន្ទារិះគន់ខ្លួននោះទេ។ ប៉ុន្តែធម្មជាតិមិន បានបំពេញទៅតាមចិត្តមនុស្សចង់នោះទេ ពួកគេតែងតែខកបំណងនៅពេលលោកធម៌ទាំងនេះប្រែប្រួល។ លោកធម៌ប្រែថា ធម៌សម្រាប់មនុស្សលោកទូទៅ គ្រាន់តែកើតមានក្រាស់ស្តើង ជាងគ្នាប៉ុណ្ណោះ។

### ៣- ប្រភព

ធម្មជាតិបានបង្កើតឱ្យមានវត្ថុច្រើនរាប់មិនអស់។ វត្ថុច្រើនរាប់មិនអស់នោះមានលក្ខណៈ **ខុសៗគ្នា**, ខ្វះខាត និង មិន គ្រប់គ្រាន់។ លក្ខណៈ **ខុសៗគ្នា, ខ្វះខាត** និង **មិនគ្រប់គ្រាន់** នេះតម្រូវឱ្យវត្ថុនានាទាំងនោះមានអត្ថិភាពដោយមិនឯករាជ្យ ពីវត្ថុដទៃៗទៀត។ ហេតុនេះពួកវាត្រូវតែពឹងអាស្រ័យគ្នាទៅវិញទៅមក ដោយជៀសពុំរួច ដើម្បីឱ្យមានអត្ថិភាពដោយពេញលេញ។ និយាយជារួម នៅក្នុងលោកនេះ គ្មានវត្ថុណាដែលមានអត្ថិភាពដោយឯករាជ្យពីវត្ថុដទៃនោះបានឡើយ។

**កង្វះខាតនៃអង្គវត្ថុ** នាំឱ្យកើតនូវ **ការពឹងអាស្រ័យគ្នា**។ **ការពឹងអាស្រ័យគ្នា** នាំឱ្យកើតនូវ **ការរត់រកគ្នា** ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមក។ ការរត់រកដើម្បីបំពេញឱ្យគ្នានេះគឺជា **ប្រភពនៃចលនា**។ ផ្តើមចេញពី **កង្វះខាតនេះអង្គវត្ថុនានា** ត្រូវតស៊ូជាមួយគ្នារហូតដល់អស់

[5] -ដ-., ទំព័រ ១៣

[6] ហុក សាវណ្ណ, "ការព្យាបាលរោគផ្លូវចិត្តតាមវិធីពុទ្ធសាសនា", វត្តខ្មែរកាណាដា, ទំព័រ ៨

អត្ថិភាព។ ការតស៊ូជាមួយគ្នា ដើម្បីបំពេញឱ្យគ្នានេះ ពេលខ្លះពួកវាអាចបំពេញឱ្យគ្នាបាន ពេល នោះ **ការឯកភាព**គ្នា ដែល **អិមផេដូគ្លីហ្ស** (Empédocle : ៤៨៣-៤២៣ មុនគ.ស.) ទស្សនវិទូក្រិកបូរាណហៅថា "**ការច្របល់ ឬស្នេហា**[7]" ក៏នឹងកើតឡើង ហើយប្រព្រឹត្ត ទៅដោយសុខសាន្តជាមួយគ្នា។ សុភាសិត ខ្មែរពោលថា"អ្នកមានរក្សាខ្សត់ ដូចសំពត់ ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅទូរសំប៉ាន។" **ព្រះរាជសម្ភារ** បានសរសេរថា "ខ្លែងហើរផ្សិតខ្យល់ នាយជ្រើងផ្សិតពល រក្សាឱ្យសុខ ទ្រព្យគង់ផ្សិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុកផ្សិតកិរិយាជា[8]" **ការឯកភាព** នៃអង្គវត្ថុប្រព្រឹត្តទៅជាមួយគ្នាដោយ សុខដុម ដោយសារតែពួកវាមាន **គុណភាព** (qualities) និង **សម្បត្តិ** (pro-perties) ដូចគ្នា ឬប្រហាក់ប្រហែលគ្នា។ ប៉ុន្តែ ពេលខ្លះទៀត ពួកវាក៏មិនអាចបំពេញ ឱ្យគ្នាបាន ដោយសារតែពួកវាមាន **គុណ ភាព** (qualities) និង **សម្បត្តិ** (properties) មិនដូចគ្នា ឬខុសគ្នាទាំងស្រុងពេលនោះ **វិសមភាព** (unequal) រវាងគូរអន្តរកម្ម ក៏នឹងកើតឡើង។ **វិសមភាព** នាំឱ្យកើតនូវ **ទំនាស់** ដែល**អិមផេដូគ្លីហ្ស** ហៅថា "**ការបំបែក ឬកំហឹង**[9]" ក៏នឹងកើតឡើងដែរ គឺ នៅពេលនោះ ហើយដែល អង្គវត្ថុនីមួយៗ ត្រូវបំបែកចេញ ពីគ្នា និងក្លាយទៅជា **គូទំនាស់** ដែលយើងហៅថា **គូរបដិបក្ខ**។ **គូរបដិបក្ខ** មានបែបដូចជា មនុស្សទល់នឹងមនុស្ស; មនុស្សប្រុសទល់នឹងមនុស្សប្រុស; មនុស្សប្រុសទល់នឹងមនុស្សស្រី; មនុស្សស្រី ទល់ នឹងមនុស្សស្រី; មនុស្ស ទល់ នឹង រុក្ខជាតិ; រុក្ខជាតិទល់នឹងរុក្ខជាតិ; រុក្ខជាតិទល់នឹងសត្វ; សត្វទល់នឹងសត្វ... ល...។ អ្នកមានទល់នឹងអ្នកក្រ; អ្នកអយុត្តិ ធម៌ទល់នឹងអ្នកយុត្តិធម៌; អ្នកមនោនិយម ទល់នឹងអ្នក រូបជាតុនិយម...ល...។

គំនូសបំព្រួញអំពីអន្តរកម្មនៃអង្គវត្ថុ

- មនុស្ស ⇆ មនុស្ស

  ⇅ ⇅

- រុក្ខជាតិ ⇆ សត្វ ⇆ សត្វ

  ⇅

- រុក្ខជាតិ

កំណត់សម្គាល់

- ⇅ សញ្ញា ដែលអង្គវត្ថុនីមួយៗត្រូវពឹងអាស្រ័យ និងបំពេញឱ្យគ្នា។

ឧទាហរណ៍ គូស្រករប្ដីប្រពន្ធ បន្ទាប់ពីជួបគ្នា (ឯកភាព) ពួកគេក៏បែកគ្នា (ទំនាស់) រួចហើយក៏ជួបគ្នាវិញ (ឯកភាពថ្មីក្នុងដៃគូចាស់) បន្ទាប់មកក៏បែកគ្នាទៀត (ទំនាស់ថ្មីក្នុងដៃគូចាស់) មិនយូរប៉ុន្មានក៏បែកគ្នាទៀត (ទំនាស់ថ្មីក្នុងដៃគូចាស់) ទៅរកដៃគូថ្មីតែរៀងៗខ្លួន (ឯកភាពថ្មីក្នុងដៃគូថ្មី)។ នេះគឺជាទិដ្ឋភាពគំរូមូលដ្ឋានមួយដែលឆ្លុះ ឱ្យឃើញពីទិដ្ឋភាពនៃអង្គវត្ថុនានា

---

[7] ឆយ យីហ៊ាង, ដ.ឯ.ម. ទំព័រ ៣០

[8] លាង ហាប់អាន "ព្រះរាជសម្ភារ", បោះពុម្ពលើកទី៤, ភ្នំពេញ, ២០០៩,ទំព័រ ៣០

[9] ឆយ យីហ៊ាង,ដ.ឯ.ម., ទំព័រ ៣០

នៅក្នុង ពិភពធម្មជាតិនេះ ដែលវត្ថុទាំងអស់ សុទ្ធតែជួប-ព្រាត់-ជួប បែបនេះមិនចេះចប់។ គ្មានការជួបណាដែលមិនព្រាត់ ហើយក៏គ្មាន ការព្រាត់ណាដែលមិនជួប។ ការជួប ជាបុព្វហេតុ នៃការព្រាត់។ បើមិនចង់ព្រាត់ សូមកុំជួប។ ព្រះរាជសម្ភារ កវីរាជសតវត្សរ៍ ទី១៧ បានសរសេរ ពីក្រឹត្យក្រមប៉ះទង្គិចនៃអង្គវត្ថុ ដែលនាំទៅដល់ ការព្រាត់ថា "ខ្ញៅ វែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមាន ទ្រព្យ ស្រីស្រាប្រច័ណ្ឌ វែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់ វែងស្អប់ប្រដៅ។ ចង់បុណ្យបានបាប ចម្រើងចង់លាភ វែងបាត់ធនទៅ មានះបាត់មិត្ត ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅ រមែងបាត់អង្គ[10]។

**គំនូសបំប្រួញអំពីប្រព័ន្ធអេកូឡូស៊ី**

រុក្ខជាតិបង្កើតជាមូលដ្ឋានបណ្ដាញអាហារ




គំនូសបំប្រួញអំពីប្រព័ន្ធពឹងអាស្រ័យនៃអង្គវត្ថុ



ស្រុកថតស្រាក្ដីស្រុកស្រុកគំហើញថា **គំនិតបដិសំយោគ** ឬ **ទ្រឹស្ដីបដិសំយោគ** ផ្ដើមចេញពីអង្គវត្ថុធម្មជាតិមិនដូចគ្នា។

## ៤- ប្រភេទគូទំនាស់

គេអាចចោទសួរថា៖

- តើធម្មជាតិមានយុត្តិធម៌ដែរឬទេ?
- ហេតុអ្វីបានជាវត្ថុនានា នៅក្នុងធម្មជាតិ មិនដូចគ្នា?
- តើហេតុអ្វីបានវត្ថុនានាមានទំនាស់?

វត្ថុទាំងអស់នៅក្នុងធម្មជាតិសុទ្ធតែមិនដូចគ្នា។ គ្មានវត្ថុណា ដែលដូចគ្នារហូតដល់ក្លាយទៅជាវត្ថុតែមួយ ហើយគ្មានទំនាស់គ្នានោះទេ[11]។ ពាក្យថា "ដូចគ្នា" មានន័យថា "ខុសគ្នា"។ ហេតុនេះ **ទំនាស់** កើតមកពី **ភាពមិនដូចគ្នានៃអង្គវត្ថុ**។ អង្គវត្ថុខុសគ្នាបណ្ដាលមកពី **គុណភាព** និង **សម្បត្តិ** របស់ពួកវាខុសគ្នាតិច ឬទាំងស្រុង។ **គុណភាព** និង **សម្បត្តិ** ខិតមករក **ភាពដូចគ្នា** កាន់តែច្រើន **ទំហំទំនាស់** របស់ពួកវាក៏កាន់តែតិចទៅៗរហូតដល់ **ដូចគ្នាសុទ្ធសាធ** តែមិនមែនមានន័យថា **វត្ថុតែមួយ** នោះទេ។ នៅខណៈពេលដែល **គុណភាព** និង **សម្បត្តិ** ខិតមករក **ភាពដូចគ្នា** កាន់តែច្រើន **កម្លាំងនៃការឯកភាពគ្នា** ក៏កាន់តែស្អិតរមួត។ បើនិយាយពីគូស្រករ គឺស្រលាញ់ គ្នារហូតដល់

---

[10] លាង ហាប់អាន ដ.ឯ.ម., ទំព័រ ៣៣

[11] ឆយ យីហ៊ាង,ដ.ឯ.ម. ទំព័រ ៣៣

“ខាំចេក របូត ខាំពោត របេះ” ដូចចាស់បុរាណលោកពោល។ ផ្ទុយទៅវិញ ប្រសិនបើ **គុណភាព** និង **សម្បត្តិ** របស់ពួកវា ខិតទៅរក **ភាពខុសគ្នា** កាន់តែច្រើន **ទំហំទំនាស់** របស់ពួកវាក៏កាន់តែខ្លាំងទៅៗ រហូតដល់**បំបែកចេញ ពីគ្នា** អាចបែកទៅក្នុងកម្រិតបណ្ដោះអាសន្ន ឬបែកជារៀងរហូត។

គូទំនាស់របស់អង្គវត្ថុ អាចចែកជា ពីរក្រុមគឺ **គូទំនាស់រវាងអង្គវត្ថុនិងអង្គវត្ថុ** នៅក្នុងធម្មជាតិ និង **គូទំនាស់រវាងគំនិត និងគំនិត** នៅក្នុងគំនិតរបស់មនុស្សម្នាក់ និងមនុស្សម្នាក់ទៀត។ គូទំនាស់ទាំងពីរ នេះមានលក្ខណៈជា**នាម** (noun) ផង និង ជា**គុណនាម** (adjective) ផងៗ ក្រុមទាំង ពីរនេះមានអន្តរកម្មជាមួយគ្នា ឱ្យផលជា **អវិជ្ជមាន** និង ជា **វិជ្ជមាន**។ **ផលអវិជ្ជមាន** សំដៅទៅលើផលដែលមានគុណភាព អសកម្ម, អន់ថយ, អន្តរាយ, វិនាស, ហិនហោច, ចង្រៃ, ក្ដៅក្រហាយ...ល។ និយាយ ជារួមគឺជា គុណភាពដែលនៅពេលវាប្រាស្រ័យទាក់ទង ជាមួយអ្វីមួយ ឬអ្វីមួយមកប្រាស្រ័យទាក់ទង ជាមួយវា អ្វីមួយនោះ នឹងត្រូវចុះ អន់ថយ ទាប គ្មានតម្លៃ។ នៅក្នុងជីវិតរស់នៅមនុស្សជាច្រើន មិនចង់បានផលនេះទេ។ ចំណែកឯ **ផលវិជ្ជមាន** សំដៅទៅលើផលដែលមានគុណភាពសកម្ម, ចម្រើន, រុងរឿង, លូតលាស់, ដុះដាល, សិរីសួស្ដី, ល្អ, ត្រជាក់ត្រជុំ...ល...។ នៅពេលដែល វាប្រាស្រ័យទាក់ទង ឬ អ្វីមួយមកប្រាស្រ័យ ទាក់ទងជាមួយវា អ្វីមួយនោះនឹងត្រូវរីក លូតលាស, ដុះដាល, សុខដុមៗ នៅក្នុងជីវិត រស់នៅ មនុស្សជា ច្រើនចង់បានផលបែបនេះ។

ទាក់ទងទៅនឹង **ផលអវិជ្ជមាន** និង **ផលវិជ្ជមាន** នេះ ផ្លេតូ (Plato) បានលើក ឧទាហរណ៍ ថា នៅលើ **ឋានសួគ៌** មានព្រះរាជរថមួយរបស់ ទេវតា។ ព្រះរាជរថនោះ ត្រូវដឹកដោយ **សេះពីរក្បាល**។ **ព្រលឹង អមតៈ** ឋិតនៅលើព្រះរាជរថ នោះ។ **សេះ ទីមួយ** មាន **សេចក្ដីក្លាហាន** និង មាន **សុចន្ទៈ**។ **សេះទី២** ពោពេញទៅដោយ **តណ្ហាអកុសល**។ នៅពេលដែល **សេះទី២** មាន កម្លាំងជាង **សេះទី១ ព្រះរាជរថ** ត្រូវធ្លាក់ចុះមក នៅ **ស្ថានកណ្ដាល** ដោយធ្វើឱ្យ ភ្លេចអស់នូវ អ្វីៗដែលធ្លាប់មាននៅក្នុង **ពិភពគំនិត** ដ៏ សក្ដិសិទ្ធិ។ ហេតុនេះ **ព្រលឹង អមតៈ** មិនអាច យល់ពី **គំនិត** បានឡើយ។ ផ្ទុយទៅវិញ នៅ ពេលដែល **សេះទី១** មាន កម្លាំងជាង **សេះទី២ ព្រះរាជរថ** ត្រូវឡើង ទៅ **ឋានសួគ៌** វិញ រហូត ទៅដល់ **ពិភពគំនិត**។ នៅពេលនេះ **ព្រលឹង** សង្កេតឃើញ **គំនិត** យល់ច្បាស់ ស្មារតីយល់ ច្បាស់ **វិចារណញ្ញាណ** ដែលគ្មានរូបរាង គ្មាន ពណ៌សម្បុរ និងគ្មានឥន្ទ្រិយារម្មណ៍។ នោះគឺ ជា **ព្រលឹងឧត្តុង្គឧត្ដម**[១២]។

នៅក្នុងព្រះពុទ្ធសាសនាក៏មានការបក ស្រាយស្រដៀងនឹងផ្លេតូនេះដែរ ទាក់ទងទៅ នឹង **កុសលកម្ម** (good Kamma) និង **អកុសលកម្ម** ឬ **បាបកម្ម** (evil Kamma)។ មនុស្សម្នាក់បើមាន

[១២] ឆយ យីហ៊ាង,ដ.ឯ.ម., ទំព័រ ៦១

គំនិតបាប ឬអាក្រក់ច្រើន គំនិតបាប ឬអាក្រក់នេះនឹងជម្រុញខ្លួនគេ ដែលផ្ទុយហៅថា រាជរថ ឱ្យប្រព្រឹត្តអំពើបាបឬអាក្រក់ច្រើន ដែរ ពោលគឺ **ចុះនរក** ក្នុងន័យថា ជីវិតក្រលំបាកវេទនា ឬក៏ត្រូវគេវាយធ្វើបាបអាចនឹងដល់ស្លាប់ក៏ថាបាន។ ផ្ទុយទៅវិញ បើមនុស្សម្នាក់នោះមានគំនិតល្អ ប្រកបដោយកុសលធម៌, សុចន្ទៈ, និង គុណធម៌ច្រើន គំនិតល្អប្រកបដោយកុសលធម៌, សុចន្ទៈ, និងគុណធម៌នេះនឹងជម្រុញខ្លួន គេឱ្យប្រព្រឹត្តអំពើល្អ ប្រកបដោយកុសល ធម៌, សុចន្ទៈ, និងគុណធម៌ច្រើនដែរ គឺនៅ ពេលនោះហើយដែលជីវិតរបស់គេឡើងឋានសួគ៌ ពោលគឺ ជីវិតសុខសាន្ត មិនសូវជាមានការរំខានពីភាពក្រក្រី ឬបាបមនុស្សមានសិរីសួស្តី មានមនុស្សរាប់អានច្រើន មានអ្នកជួយយករក្សា រកស៊ីមានបានមានបុណ្យស័ក្តិឋានៈខ្ពង់ខ្ពស់ រស់នៅថ្ងៃថ្នូរដូចទេវតា។

ខាងក្រោមនេះគឺជាគូទំនាស់ជានាម និងជាគុណនាមៈ

គូទំនាស់ជានាម

- មនុស្សនិយម-ទេវនិយម
- កុម្មុយនិស្តនិយម-សេរីនិយម
- មនោនិយម-រូបជាតុនិយម
- លទ្ធិពុទ្ធរាជ-លទ្ធិទេវរាជ
- អ្នកក្រ-អ្នកមាន
- ប្រពន្ធ-ប្ដី
- មិត្ត-សត្រូវ
- អវិជ្ជា-វិជ្ជា
- កម្មករ-មូលធនិក
- ប្រជាជន-អ្នកដឹកនាំ
- សង្គ្រាម-សន្តិភាព
- អពមង្គល-សុភមង្គល
- អកុសល-កុសល
- យប់-ថ្ងៃ
- ស្រី-ប្រុស

គូទំនាស់ជាគុណនាម

- ស្រាល-ធ្ងន់
- មូល-សំប៉ែត
- លំបាក-ស្រួល
- អាក្រក់-ល្អ
- ខ្មៅ-ស
- តូច-ធំ
- ទាប-ខ្ពស់
- ក្រ-មាន
- ស្អុយ-ក្រអូប
- ងងឹត-ភ្លឺ
- ខុស-ត្រូវ
- ឆ្ងាយ-ជិត
- ល្ងង់-ឆ្លាត
- ក្បត់-ស្មោះត្រង់
- កាច-ស្លូត
- ខ្លី-វែង
- សើម-ស្ងួត
- ស្អុយ-ក្រអូប
- ថោក-ថ្លៃ

*កំសាក-ក្លាហាន*

*ខ្ជិល-ឧស្សាហ៍*

*កេង-សប្បុរស*

*វៀច/កោង-ត្រង់*

*ស្គឹក-រួស*

*ញី-ឈ្មោល*

*គូទំនាស់ជានាម ជាគូទំនាស់ដែល មាន លក្ខណៈជានាមពីពីធម្មជាតិ ឬពី កំណើត ដោយខ្លួនវា។ ឯគូទំនាស់ជាគុណនាមជាគូ ទំនាស់ដែលគ្រាន់តែជាការបង្គ្រប់ ឬបំពេញ ន័យ ឬគុណភាពឱ្យនាមតែប៉ុណ្ណោះ។ វាមាន លក្ខណៈមិនឯករាជ្យទេ។*

*គូទំនាស់រវាងអង្គវត្ថុ ដូចជា មនុស្ស និង មនុស្ស, មនុស្សនិងវត្ថុ...ល...។ មាន ពន្យល់រួច នៅចំណុចទី៣។ ចំណែកឯគូ ទំនាស់រវាង គំនិតមានពន្យល់នៅទីនេះ។*

*តើទំនាស់ ឬជម្លោះរវាងបុគ្គលនិង បុគ្គល, រវាងគ្រួសារនិងគ្រួសារ, រវាង ប្រទេស និងប្រទេស ឬចោទសួរជារួមថា តើសង្គ្រាម នៅក្នុងពិភពលោក តាំងពីអតីតកាល ដូចជា សង្គ្រាមលោកលើកទី១ ទី២ និងសង្គ្រាមនៅ ក្នុងពិភពលោកសព្វថ្ងៃរវាងរុស្ស៊ីនិងអ៊ុយក្រែន, ហាម៉ាសនិង អ៊ីស្រាអែល, ជម្លោះនៅសហភាព មីយ៉ាន់ម៉ា បណ្ដាលមកពីអ្វី?*

*ចរន្ត "គំនិត" ត្រូវបានចែកទៅជា ចរន្ត គំនិតខុស និងចរន្តគំនិតត្រូវ, ចរន្ត គំនិតល្អ និង ចរន្តគំនិតអាក្រក់, ចរន្តគំនិត វិជ្ជមាន និង ចរន្តគំនិតអវិជ្ជមាន។ ចរន្តទាំង ពីរបែបនេះ មានធម្មជាតិមិនដូចគ្នាទេ។ វា តែងតែប៉ះទង្គិច គ្នាហើយបង្កទៅជាទំនាស់, ជម្លោះ, ឬសង្គ្រាម រវាងគ្នា ពោលគឺ រវាង បុគ្គលនិងបុគ្គល, គ្រួសារ និងគ្រួសារ, ប្រទេសនិងប្រទេស។ អ្នកចូលចិត្ត ស្រា យល់ថា ស្រាល្អ ឯអ្នកស្អប់ស្រាវិញយល់ ថាស្រាធ្វើឱ្យខូចសុខភាព។ អ្នកស្អប់គំនូរអាក្រាត កាយយល់ថា គំនូរអាក្រាតកាយ មានលក្ខណៈ អាសអាភាស តែសម្រាប់វិចិត្រករដែលស្រលាញ់ គំនូរយល់ថាគំនូរបែបនេះល្អ។ ហេតុនេះគំនូរ អាក្រាតកាយ ក៏មានអត្ថិភាព។ ពួកកុម្មុយនិស្ត យល់ថា ស៊ូសម្លាប់ខុសប្រសើរជាជាងឱ្យឧក្រិដ្ឋ ជនរួចខ្លួន ដែលផ្ទុយទៅនឹងគំនិតរបស់ពួក លោកសេរីដែលយល់ថា ស៊ូឱ្យឧក្រិដ្ឋជនរួចខ្លួន ប្រសើរជាជាងសម្លាប់ខុស។ នៅក្នុងរឿងសាមកុក ឆាវៗ យល់ថា សុខចិត្តឱ្យ ខ្លួនគាត់ក្បត់ពិភព លោក តែមិនឱ្យពិភពលោកក្បត់គាត់នោះ ឡើយ។ អ្នកសម្ភារៈនិយមយល់ថា ការតុបតែង លំអរូបរាង កាយល្អប្រសើរជាងការតុបតែង លំអ ព្រលឹង (ចិត្តគំនិត) តែរឿងនេះផ្ទុយទៅ នឹងគំនិតខ្មែរបុរាណដែលលើកឡើងថា "រូប សដូចចានមាយាទមិនបានដូចឆ្កែ ក្រោមផ្ទះ" ដែលស្របជាមួយនឹងគំនិត ហ្សីណូ ហ្វ៊ែន* (Xenophanes: *៥៧០-៤៧៨ មុនគ.ស) ទស្សនវិទូក្រិកដែលយល់ថា "**បញ្ញា** គឺថ្លាប្រសើរជាង **កម្លាំងមនុស្ស** និង **កម្លាំងសេះ**។*[13]*" ផ្លេថូយល់ថា*

*[១៣] ឆយ យីហ៊ាង,ដ.ឯ.ម. ទំព័រ ១៧*

"**លំអពិត** ជាលំអរបស់គំនិត ដែលខុសពីលំអរបស់ **វត្ថុវេទយិត**។ លំអនៃគំនិតល្អថ្លៃថ្លា មាន **អត្ថិភាពអមតៈ** នៅក្រៅ **លំហ** ក្រៅ **កាល** និង **ឥតប្រែប្រួល**។ លំអនៃ **វត្ថុវេទយិត** ជាលំអធៀប និងប្រែប្រួលជារឿយៗ។[14]"

នៅក្នុងទស្សនវិជ្ជា មាននិកាយពី ដែលតែងតែមានចរន្តគំនិតផ្ទុយគ្នា។ ចរន្តទី១ គឺ "លទ្ធិមនោនិយម (idealism)។ ចរន្តទី២ គឺលទ្ធិរូបជាតុនិយម (materialism)"។ នៅក្នុងដំណើរកកើតនិងការរីកចម្រើននៃទស្សនវិជ្ជាក្រិកបូរាណសម័យ លទ្ធិទាំង ពីរនេះបានផ្សាភ្ជាប់នឹងការតស៊ូជាមួយគ្នា យ៉ាងស្មុគស្មាញបំផុត។ ការតស៊ូទស្សនវិជ្ជា នេះឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវការ តស៊ូរវាងស្រទាប់ពីរនៅក្នុងវណ្ណៈម្ចាស់ទាសករ ពោលគឺស្រទាប់ **ម្ចាស់ទាសករប្រជាធិបតេយ្យហើយនិងម្ចាស់ទាសករអភិជន**[15]។

**លទ្ធិមនោនិយម** បើតាមផ្លូវថូយល់ ថា **គំនិត** (idea) **កើតមុនអត្ថិភាព។ អត្ថិភាព** (existence) កើតក្រោយ **គំនិត**។ មនុស្ស, សត្វ, រុក្ខជាតិ, សុទ្ធសឹងជា **អត្ថិ-ភាព** ឬជា **ធម្មជាតិ** ឬ **ជាវត្ថុវេទយិត**។ អ្វីៗ ទាំងអស់នោះគឺសុទ្ធតែកើតចេញពី **គំនិត**។ ចាស់បូរាណខ្មែរពោលថា មានគំនិតទើបមានកំណើត ឬក៏ថា អត់កំណើតមកពីអត់គំនិត។ **គំនិត** ឥតប្រែប្រួលទេ។ **វត្ថុវេទយិត** តែងកើតប្រែប្រួលនិងស្លាប់ទៅវិញ។ ហេតុនេះ **វត្ថុវេទយិត** គឺជាកម្មវត្ថុពុទ្ធិ **ស្រមើស្រមៃ** ជា **ស្រមោលនៃគំនិត** គឺពុំមែនជាកម្មវត្ថុនៃចំណេះពិតឡើយ។ ហេតុ នេះមានតែ **គំនិត** ទេដែលមាន **អត្ថិភាព អមតៈ**។ វាមានអត្ថិភាព នៅក្រៅ **លំហ** និង **កាល**។ លោកយល់ថា **គំនិត** ជា **ភាវៈរូបធាតុ** ជា **អភាវៈ**។ **វត្ថុវេទយិត** ស្ថិតនៅចន្លោះ **ភាវៈ** និង **អភាវៈ**។ **វត្ថុវេទយិត** ជា **ស្នាមគំនូសនៃ គំនិត**[16]។

ចំពោះចរន្តគំនិតនៃ **លទ្ធិរូបជាតុ និយមអើរីស្តូថឹល** (Aristotle) យល់ខុស ស្រឡះពីទ្រឹស្តីគំនិតរបស់ ផ្លេថូ។ នៅក្នុងដំណោះស្រាយរវាង **អត្ថិភាព** និង **គំនិត** **អើរីស្តូថឹល** យល់ថា **អត្ថិភាពកើតមុន គំនិត**។ រីឯផ្លេថូយល់ថា **អត្ថិភាព** ជាស្រមោលនៃគំនិត ឬ **គំនិតកើតមុនអត្ថិ-ភាព**។ ហេតុនេះ **អើរីស្តូថឹល**យល់ថា ពិភពលោកមាន **អត្ថិភាពបរានុម័ត**[17]។

## សេចក្តីសន្និដ្ឋាន

វត្ថុទាំងអស់នៅលើផែនដីនេះសុទ្ធតែមានអន្តរទំនាក់ទំនងជាមួយគ្នាជាចាំបាច់។ ការមានអន្តរទំនាក់ទំនងជាមួយគ្នា ជាចាំបាច់នេះ ដោយសារតែពួកវាមាន លក្ខណៈមិនគ្រប់គ្រាន់ ហើយពួកវាត្រូវការគ្នាដើម្បីបំពេញឱ្យគ្នាដើម្បីបន្តមាន អត្ថិភាពដោយពេញលេញ។ ពេលខ្លះពួក វាអាចបំពេញឱ្យគ្នាបាន ក៏មាន

[14] -ដ-. ទំព័រ ៦៣

[15] -ដ-. ទំព័រ ៤

[16] ធយ យីហ៊ាង,ទំព័រ., ៥៨-៥៩

[17] - ដ- ៦៩-៧០

ការឯកភាពគ្នា ហើយបន្តមានសហត្ថិភាពជាមួយគ្នា។ ប៉ុន្តែ នៅពេលខ្លះពួកវាមិនអាចបំពេញឱ្យ គ្នាបាន ពេលនោះទំនាស់ក៏កើតឡើង។ វត្ថុ ត្រូវបំបែកចេញពីគ្នា។ វត្ថុថ្មីក៏ចាប់មាន អត្ថិភាពឡើង។

ហេតុនេះ ការសិក្សាពីអង្គវត្ថុនីមួយ គឺជាការរកឃើញពីតម្រូវការចាំបាច់, ពី **ការឯកភាព, ទំនាស់, ការបំបែក**, និងពី **ការសំយោគ** ឬ **ការកើតថ្មី** របស់ពួកវា។ ការយល់ដឹងពីចំណុចទាំងនេះ ជួយឱ្យយើង យល់បានពីក្រឹត្យក្រមទំនាក់ទំនង, ការ ថែរទាំ, បុព្វហេតុនៃការចម្រើន, និងការចុះអន់ថយនៃអង្គវត្ថុ ដើម្បីឈានទៅរកការគ្រប់គ្រង ក៏ដូចជាការប្រាស្រ័យទាក់ទង ដោយសុខដុមជាមួយគ្នាដែរ។

សព្វថ្ងៃនេះ ដំណើរអន្តរកម្មរវាង **មនុស្សនិងមនុស្ស**; រវាង **មនុស្សនិងធម្ម ជាតិ**; និងរវាង **ធម្មជាតិនិងមនុស្ស**។ មនុស្សរស់បានដោយពឹងលើធម្មជាតិ។ ឯ ធម្មជាតិក៏ត្រូវពឹងលើមនុស្សដើម្បីជួយ ថែរក្សាវាវិញដែរ។ ប៉ុន្តែ បើមនុស្សមិន ត្រឹមតែដើម្បីរស់ ពួកគេមានមហិច្ឆតា លោភ ពួកគេនឹងត្រូវធ្វើសង្គ្រាមដើម្បីបំផ្លាញគ្នា, ដើម្បីដណ្តើមផលប្រយោជន៍, ដើម្បីដណ្តើមការគ្រប់លើគ្នា, និងដើម្បីដណ្តើមប្រមូលយកធនធានធម្មជាតិតែម្នាក់ឯង។ ដើម្បីឈ្នះចាញ់គ្នាក្នុងរឿងនេះ មនុស្សត្រូវយកធនធានធម្មជាតិធ្វើជាដើមទុន (បំផ្លាញធម្មជាតិ) ដើម្បីធ្វើសព្វាវុធប្រយុទ្ធគ្នា។ នៅពេលមនុស្សប្រើប្រាស់ធនធានធម្មជាតិដោយខ្ជីខ្ជាច្រើនហួសប្រមាណនិងដោយខ្វះមនសិការ ធនធានធម្មជាតិនឹងត្រូវវិនាសហិនហោច ហើយជាផលសងត្រឡប់មកវិញរបស់ធម្មជាតិ គឺ ការរញ្ជួយដី, ទឹកជំនន់, កំណើនកំដៅផែន ដី, ខ្យល់ព្យុះ, គ្រោះរាំងស្ងួត។ ទីបំផុត មនុស្សបំផ្លាញធម្មជាតិ ៗក៏នឹងបំផ្លាញមនុស្សវិញដែរ។ ហេតុនេះ ការយល់ដឹងពីគូបដិបក្ខនៃអង្គវត្ថុមានសារប្រយោជន៍សម្រាប់ការរស់នៅដោយសុខសាន្តជាមួយធម្មជាតិ។

## គន្ថនិទ្ទេស

I- *ស្នាដៃនិពន្ធជាភាសាខ្មែរ*

*១- ឆយ យីហ៊ាង,"ប្រវត្តិទស្សនវិជ្ជា បស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជា បូរាណសម័យក្រិក",*
*សាកលវិទ្យា- ល័យភូមិន្ទភ្នំពេញ, ១៩៩៤*

*២- លាង ហាប់អាន "ព្រះរាជាសម្ភារ(ករីរាជស.វ. ទី១៧)", បោះពុម្ពលើកទី ៤, ភ្នំពេញ, ២០០៥*

*៣- ហុក សាវណ្ណ, "ការព្យាបាលរោគផ្លូវចិត្តតាមវិធីពុទ្ធសាសនា", វត្តខ្មែរ កាណាដា*

II- *ស្នាដៃនិពន្ធជាភាសាអង់គ្លេស*

1- Venancio B. Ardales, *Introductory Text to Philosophy*, 2nd Ed., New York, 1987

# ប្រភពនៃទស្សនវិជ្ជាអប់រំ៖ បច្ឆានវនិយម

*ដោយ៖* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

*បច្ឆានវនិយម ឬសម័យក្រោយទំនើបនិយម ដែលជាទស្សនវិជ្ជាទំនើបឈានមុខគេនោះ អះអាងថា សម័យកាលប្រវត្តិសាស្ត្រទំនើបបានបញ្ចប់ទៅហើយ ហើយយើងកំពុងរស់នៅក្នុងសករាជក្រោយសម័យទំនើប។*

*បច្ឆានវនិយម ឬសម័យក្រោយទំនើបនិយម ក្នុងបស្ចិមប្រទេស ជាចលនាទស្សនវិជ្ជាចុងសតវត្សទី២០ ដែលបានកំណត់លក្ខណៈដោយមជ្ឈត្តនិយម អត្តនោម័តិនិយម ឬសាបេក្ខភាពនិយមយ៉ាងទូលំទូលាយ ការសង្ស័យទូទៅនៃហេតុផល និងភាពរសើបខ្លាំង ចំពោះតួនាទីនៃមនោគមវិជ្ជាក្នុងការអះអាង និងរក្សាអំណាចនយោបាយ និងសេដ្ឋកិច្ច។*

## បច្ឆានវនិយម និងនវទស្សនវិជ្ជា

**បច្ឆានវនិយម** *ភាគច្រើនជាប្រតិកម្មប្រឆាំងនឹងការសន្មតដោយវាងវៃ និងគុណតម្លៃនៃសម័យកាលទំនើប នៅក្នុងប្រវត្តិសាស្ត្រនៃទស្សនវិជ្ជាលោកខាងលិច (ប្រហែលសតវត្សទី១៧ រហូតដល់សតវត្សរ៍ទី១៩)។ ជាការពិត គោលលទ្ធិជាច្រើនដែលមានលក្ខណៈទាក់ទងនឹងក្រោយសម័យទំនើបនិយម អាចត្រូវបានគេពិពណ៌នាដោយត្រឹមត្រូវថាជាការបដិសេធដោយបត្រង់ៗនៃទស្សនៈទស្សនវិជ្ជាទូទៅ ដែលត្រូវបានទទួលយកនៅក្នុងអំឡុងពេលសម័យបច្ចេកវិទ្យានៃសតវត្សរ៍ទី១៨ ទោះបីជាវាមិនមានតែមួយគត់ ចំពោះសម័យនោះ។ ចំណុចសំខាន់បំផុតនៃទស្សនៈទាំងនេះ មានដូចខាងក្រោម៖*

*ដើមកំណើតសម័យក្រោយទំនើបនិយមអាចត្រូវបានរកឃើញក្នុងគំនិតទស្សនវិទូអាល្លឺម៉ង់* Friedrich Nietzsche (1844-1900) and Heidegger (1899-1976)។

Nietzsche *បានទាត់ចោលនូវការប្រ កាសបែបបរមត្ថវិទ្យា អំពីសច្ចភាពដាច់ខាតដោយផ្តល់យោបល់ថា វាត្រូវបានគេប្រឌិដ្ឋឡើង ដើម្បីជំនួសជំនឿធម្មតា និង*

ជំនឿអភិធម្មជាតិ ជាមួយនឹងការអះអាងមិនពិតថ្មីៗ ប៉ុន្តែ មានសមភាព[1]។

ការបង្កើតទស្សនវិជ្ជាមួយ ដែលគេហៅថា ទ្រឹស្តីញាណវិភាគ Heidegger អះអាងថា មនុស្សលោកបង្កើតសច្ចភាពជាអត្តនោម័តិ អំពីតថភាព ពីអព្ភន្តរញាណប្រត្យក្សារម្មណ៍ និងការឆ្លុះបញ្ចាំង នៅពេលដែលគេធ្វើអន្តរកម្មជាមួយបាតុភូត។

ទស្សនវិទូខ្លះ កំណត់គោលលទ្ធិក្រោយសម័យទំនើបនិយមទៅ Nietzsche ខណៈពេលដែលទ្រឹស្តីវប្បធម៌ពណ៌នា អំពីក្រោយសម័យទំនើបថាជាលទ្ធផលនៃការរៀបចំរចនាសម្ព័ន្ធមូលធននិយមនៅចុងសតវត្សរ៍ទី២០។ ខណៈពេលដែលការឆ្លើយតបនៃវប្បធម៌ទំនើបនិយម ចំពោះចរិតលក្ខណៈដ៏វិសេសវិសាលនៃជីវិតសម័យទំនើបប្រកាន់ខ្ជាប់នូវគំនិតនៃសាមគ្គីភាព លទ្ធិក្រោយសម័យទំនើបនិយម ទទួលយកភាពខុសគ្នា និងទំនាស់ ដែលមិនអាចកាត់បន្ថយបានក្នុងកិច្ចការមនុស្ស និងពហុភាពក្នុងរបៀបនៃការយល់ដឹង។ ដោយបានប្រើប្រាស់តាំងពីទសវត្សឆ្នាំ១៩៦០ ដើម្បីនិយាយយោងទៅដល់យុទ្ធសាស្ត្រប្រឆាំងសម័យទំនើបនិយម នៅក្នុងស្ថាបត្យកម្ម សិល្បៈ និងការរិះគន់ផ្នែកអក្សរសាស្ត្រនោះ 'ក្រោយសម័យទំនើបនិយម មិនបានបង្ហាញខ្លួនឡើងនៅក្នុងទស្សនវិជ្ជា និងទ្រឹស្តីសង្គម មុនទសវត្សឆ្នាំ១៩៨០ ជាកន្លែង ដែលវាត្រូវបានផ្សារភ្ជាប់ទៅនឹងស្នាដៃរបស់អ្នកផ្តើមគំនិតបារាំងដូចជា Baudrillard, Deleuze, Derrida, Foucault, and Lyotard។

សម្រាប់អ្នករិះគន់ និងអ្នកការពារលទ្ធិក្រោយសម័យទំនើបនិយម បានផ្សារភ្ជាប់ជាមួយនឹងជំនឿលើវិបត្តិ ក្នុងរូបតំណាងការបោះបង់ចោលទ្រឹស្តីការឆ្លើយឆ្លងនៃសេចក្តីពិត ហេតុផលសកល និងគ្រោងការណ៍ឯកតានៃវឌ្ឍនភាពដែលបានទទួលមរតកពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា។ អ្នករិះគន់ដូចជា Habermas អះអាងថា ការប្រឆាំងសកលនិយមក្រោយសម័យទំនើប គឺមិនអាចផ្តល់ហេតុផល សម្រាប់ការវិនិច្ឆ័យខាងសីលធម៌ ឬនយោបាយ ដែលមិនសូវទូលំទូលាយ កម្មវិធីសម្រាប់កំណែទម្រង់សង្គម។ អ្នកការពារតវ៉ាសម្រាប់គោលបំណងមានកម្រិត និងតិចតួចជាងក្នុងការធ្វើការលើដែនកំណត់នៃអ្វីដែលគេអាចគិត ឬនិយាយបាន ដោយហេតុនេះរួមចំណែកដល់ការលេចចេញនូវបទដ្ឋានថ្មីៗ។

## ទំនាក់ទំនងនឹងស្ថាបនានិយម

សម័យក្រោយទំនើបនិយម មានការអនុវត្តជាច្រើន សម្រាប់ការស្ថាបនានិយម

[1] Friedrich Nietzsche, *The Will to Power*, trans. Walter Kaufmann (New York: Vintage, 1967); also see David E. Cooper, *World philosophies: An Historical Introduction* (Oxford, U.K, and Cambridge, Mass.: Blackwell, 1996), p.467.

ដែលជាចិត្តវិទ្យា និងវិធីអប់រំ។ ពួកសម័យក្រោយទំនើបនិយម និងពួកស្ថាបនានិយម យល់ឃើញ ថាយើងបង្កើតជំនឿ អំពីចំណេះដឹងពីបទពិសោធយើង។ ព្រោះហេតុដូច្នេះហើយសិស្សបង្កើតទស្សនៈពីចំណេះដឹងតាមអន្តរកម្មជាមួយនឹងបរិស្ថាន។ ចំណេះដឹងដែលជាការបង្កើតឡើងដោយមនុស្ស គឺគ្រាន់តែជាការសាកល្បង និងការប៉ាន់ប្រមាណ និងអាចធ្វើការរំឭកឡើងវិញជាបន្ត នៅពេលដែលសិស្សទទួលបានបទពិសោធថែមទៀត។ ចំណេះដឹងគឺគ្មានទីបញ្ចប់ទេ យើងទទួលបានវាបន្ថែម និងកែលំអ ដោយផ្អែកលើបទពិសោធរបស់យើង។ ការសិក្សាតាមបែបសហការ ដែលជាការបែងចែកបទពិសោធ និងគំនិត តាមរយៈភាសានោះ បង្កើតចំណេះដឹងនូវការស្ថាបនាទាំងបុគ្គល និងសង្គម។

### ១-បញ្ញត្តិជាគន្លឹះ

#### ក-Derrida and Foucault

សម័យក្រោយទំនើបនិយម ផ្សារភ្ជាប់ជាមួយនឹងទស្សនវិទូបារាំងMichel Foucault and Jacques Derrida។ Foucault មិនជឿការប្រកាស ចំពោះសច្ចភាពជាសកល និងមិនផ្លាស់ប្តូរ។ គាត់អះអាងថា អ្វីដែលមនុស្សមួយចំនួន ជាពិសេស អ្នកជំនាញការអះអាងថា ជាសច្ចភាពសត្យានុម័តនោះ ការវិភាគ បានលាតត្រដាងថាជាសនិទានភាព ដែលស្ថិតក្នុងការប្រើប្រាស់អំណាចទៅលើអ្នកដទៃ តាមពេលមួយក្នុងប្រវត្តិសាស្ត្រ[2]។ ពួកសម័យក្រោយទំនើបនិយម ក៏ប្រើប្រាស់ផងដែរនូវបញ្ញត្តិនៃភាពមិនសំខាន់ ឬមិនចាំបាច់។ នៅក្នុងសង្គមណាមួយ ជាពិសេស សង្គមមូលធននិយមទំនើប ដូចជាសហរដ្ឋអាម៉េរិក ពិតជាទទួលបានការគាំទ្រខាងសេដ្ឋកិច្ច សង្គម ការអប់រំវណ្ណៈ និងក្រុមគ្រប់គ្រងអ្នកទាំងឡាយ ដែលជំរុញទៅដល់ការទទួលបានសំឡេងតិចតួចពីសង្គម។

Derrida បានអភិវឌ្ឍទ្រឹស្តីនៃការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការវិភាគន័យ (Deconstruction) ជាវិធីមួយនៃការតាមដានទៅលើដើមកំណើត គឺជាសន្តតិវង្សវិទ្យា (Genealogy) និងអត្ថន័យនៃឯកសារ និងCanons (ជាព្រះគម្ពីរ ឬស្នាដៃមួយ ជាញឹកញាប់ជាសៀវភៅ ដែលឱ្យតម្លៃទៅលើចំណេះដឹងអាជ្ញាព្រឹត្តក្នុងវប្បធម៌មួយ)។ ឯកសារគឺ ជាសៀវភៅមួយ ប៉ុន្តែ វាអាចជាការសន្ទនា ភាពយន្ត ឬរឿងល្ខោន ឬប្រភេទផ្សេងទៀត ជាតំណាងវប្បធម៌មួយ។ ក្នុងការអប់រំ ឯកសារ ជាញឹកញាប់ ជាការណែនាំផ្អែកកម្មវិធីសិក្សា វីដេអូ ឬជាសៀវភៅមួយ

---

[2] John A. Zahorik, *Constructivist Teaching* (Bloomington, Ind.: Phi Delta Kappa Educational Foundation, 1995) pp. 10-13.

ដែលរាប់បញ្ចូលទាំង សៀវភៅសិក្សា ដូចជាសៀវភៅដែលអ្នកកំពុងអាននេះ។ គោលបំណងនៃការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ ត្រូវបង្ហាញថា ឯកសារជាជាងផ្ទុះបញ្ចាំងសច្ចភាពបែបបរមត្ថវិទ្យាជាការស្ដាបនាបែបប្រវត្តិសាស្ត្រ និងវប្បធម៌ ដែលពាក់ព័ន្ធដល់ទំនាក់ទំនងអំណាចខាងនយោបាយ។

ឧទាហរណ៍ អ្នកគាំទ្រកម្មវិធីសិក្សាដ៏ជំមួយ ប្រើប្រាស់សៀវភៅជាគម្ពីរដ៏សំខាន់ ប៉ុន្តែ អ្នកផ្ដើមគំនិតសម័យក្រោយទំនើបនិយមជាច្រើន ផ្ដល់យោបល់ថា ឯកសារទាំងនេះ សង្កត់ធ្ងន់ទៅលើវប្បធម៌លោកខាងលិច នៅពេលដែលវប្បធម៌អាហ្វ្រិក និងអាស៊ី មានភាពមិនទូលំទូលាយ។ ពួកសម័យក្រោយទំនើបនិយម និយាយថា ឯកសារដូចជាសាធារណរដ្ឋរបស់លោកប្លាតុង និងសីលវិជ្ជារបស់លោកអារីស្តូត មិនមែនជាអំណាចសកល និងស្ថិតស្ថេរ។ ពួកគេគ្រាន់តែជាចំណែកទាំងឡាយជាប្រវត្តិសាស្ត្រ ដែលអាចត្រូវបានគេប្រើប្រាស់។

## ខ-ការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ឯកសារ

ក្នុងការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ឯកសារ និងគម្ពីរដ៏សំខាន់ ពួកសម័យក្រោយទំនើបនិយមបានចោទសួរ៖

-តើព្រឹត្តិការណ៍ និងស្ថានភាព នៅពេលពិសេសមួយ ផ្ដល់ភាពសំខាន់បែបណាដល់គម្ពីរដ៏សំខាន់?

-តើអ្នកណាផ្ដល់ព្រះគម្ពីរនូវឋានៈជាអភ័យឯកសិទ្ធិក្នុងវប្បធម៌ ឬសង្គមមួយ ហើយអ្នកណា ផ្ដល់ប្រយោជន៍ពីការទទួលក្នុងនាមជាអ្នកជំនាញមួយ?

-ហេតុអ្វីបានជាព្រះគម្ពីរដ៏សំខាន់រាប់បញ្ចូលទាំងសំឡេងនៃបុគ្គល និងក្រុមដែលមិនសំខាន់ និងមិនមានតំណាង?

ចម្លើយចំពោះសំណួរទាំងនេះ ចង្អុលបង្ហាញដល់អ្នកទាំងឡាយ ដែលកាន់អំណាចអប់រំ នយោបាយ សេដ្ឋកិច្ច និងសង្គមពិតក្នុងវប្បធម៌ និងសង្គមពិសេសមួយ។

សំណួរអំពីការអប់រំក្នុងប្រព័ន្ធ ផ្ដោតអារម្មណ៍ទៅលើរបៀបដែលកម្មវិធីសិក្សាត្រូវបានបង្កើត។ តើឯកសារបែបណា តំណាងឱ្យចំណេះដឹងជាផ្លូវការក្នុងកម្មវិធីសិក្សា? តើយើងបកស្រាយឯកសារយ៉ាងដូចម្ដេច ដើម្បីបង្កើត និងរក្សាទំនាក់ទំនងអំណាច នៅក្នុងចំណោមក្រុមផ្សេងៗ?

## ២-សំណួរជាមូលដ្ឋាន

អ្នកអប់រំក្រោយសម័យទំនើបនិយមស្វែងរកដើម្បីបង្កើតញាណ និងនាំមកនូវការផ្លាស់ប្ដូរ តាមការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ការសន្មតតាមប្រពៃណី អំពីចំណេះដឹង ការអប់រំ ការ

*សិក្សា និងការបង្រៀន។ គរុវិទូក្រោយសម័យកាលទំនើបនិយម ចាត់ទុកកម្មវិធីសិក្សារបស់សាលារៀន មិនមែនជាកន្លែងរក្សាសច្ចភាពសត្យានុម័តិ និងសេចក្តីថ្លៃថ្នូរបែបវិទ្យាសាស្ត្រ ប៉ុន្តែ ជាកន្លែងនៃទំនាស់ផ្នែកទស្សនៈ គឺមួយចំនួន មានភាពសំខាន់ និងមួយចំនួនផ្សេងទៀត មានភាពបន្ទាប់បន្សំ។*

### ក-សាលារៀន បង្កើតស្ថានភាព

*គរុវិទូសម័យកាលក្រោយទំនើបនិយម អះអាងថា សាលារៀនសាធារណៈអាម៉េរិក គឺជាភ្នាក់ងារគន្លឹះក្នុងប្រព័ន្ធសេដ្ឋកិច្ច នយោបាយ សង្គម ដែលត្រូវបានធ្វើយុត្តិកម្ម ដោយសនិទានភាពជាផ្លូវការ។ សនិទានភាព ដែលបានបង្កើតដោយអ្នកទាំងឡាយដែលស្វែងរក ដើម្បីធ្វើឱ្យត្រឹមត្រូវតាមច្បាប់នូវឋានៈសង្គម ដែលមានអភ័យឯកសិទ្ធិផ្ទាល់ខ្លួន ហើយនិងដើម្បីដកហូតអំណាចអ្នកផ្សេងទៀត គឺមនុស្សមិនសូវមានសំណាង នោះរាប់បញ្ចូលទាំងការអះអាងដែលសាលារៀនទាំងឡាយ៖*

*១-អប់រំដោយយុត្តិធម៌ និងសមភាពដល់កុមារទាំងអស់គ្នា។*

*២-ជួយសម្រួល បង្កើនដល់**ចល័តភាពសេដ្ឋកិច្ច និងសង្គម**។*

*៣-ចាំបាច់ ដើម្បីនិរន្តរភាពនៃសង្គមបែបប្រជាធិបតេយ្យ។*

*ដោយមានទំនាស់ អំពីកាអះអាងជាផ្លូវការទាំងនេះ គរុវិទូសម័យក្រោយទំនើបនិយម អះអាងថា សាលាសាធារណៈ ក៏ដូចជាស្ថាប័នសាធារណៈដទៃទៀតដែរ ជួយផលិតជាថ្មីនូវសង្គមមួយដែលជា៖*

*១-បិតាធិបតេយ្យ* (patriarchal) *គឺវាផ្តល់ការគាំទ្របុរសជាងស្ត្រី។*

*២-មជ្ឈមណ្ឌលអឺរ៉ុប* (Eurocentric) *ចំណេះដឹង ដែលត្រូវបានគេហៅដូច្នោះមួយភាគធំ គឺជាការស្តាបនាជនស្បែកសនៃខ្សែស្រឡាយពួកអឺរ៉ុប។*

*៣-ជាពិសេសក្នុងសហរដ្ឋអាម៉េរិក គឺជាពួកមូលធននិយម ដែលទ្រព្យសម្បត្តិឯកជន និងផ្លូវចិត្តរួមបានធ្វើឱ្យចាប់អារម្មណ៍ក្នុងមនោគមវិជ្ជាទីផ្សារសេរី។ បទពិសោធនៃក្រុមផ្សេងទៀត ដូចជាមនុស្ស ដែលមានពណ៌សម្បុរ មិនត្រូវបានរាប់បញ្ចូលអំពីនិទានកថាជាផ្លូវការ របស់កម្មវិធីសិក្សាទេ*[3]*។*

### ខ-ការតស៊ូ ដើម្បីកម្មវិធីសិក្សា

*គរុវិទូក្រោយសម័យទំនើបនិយម មើលឃើញកម្មវិធីសិក្សា ថាជាកន្លែងតស៊ូពិតប្រាកដមួយ គឺសង្គ្រាមវប្បធម៌ ក្នុង*

[3] Angeline Martel and Linda Peterat, ''Margins of Exclusion, Margins of Transformation: The Place of Women in Education,'' in Redecca A. Martusewicz and William M. Reynolds, *Inside/Out: Contemporary Critical Perspectives in Education* (New York: St. Martin's Press, 1994), p.152.

ចំណោមក្រុម ដែលប្រជែងគ្នា ដើម្បីអំណាច។ ប្រសិនបើយើង នឹកគិតដល់កម្មវិធីសិក្សាជាផ្នែកមួយនៃការប្រកួតប្រជែងនោះ យើងអាចមើលឃើញពីរបៀប ដែលពិនិត្យយ៉ាងល្អិតល្អន់ ទៅលើការបង្កើត និងការប្រើប្រាស់ដំណើរការ។ ការអះអាងជាច្រើន ត្រូវបានគេធ្វើឱ្យជឿនលឿន សម្រាប់កម្មវិធីសិក្សាគោលខាងវប្បធម៌ តាមស្តង់ដា នៅមធ្យមសិក្សា និងឧត្តមសិក្សា ការផ្តល់យោបល់ សម្រាប់ការទាមទារយ៉ាងសំខាន់មួយ ជាញឹកញាប់ធ្វុះបញ្ចាំងគម្ពីរតាមប្រពៃណី នៃវប្បធម៌លោកខាងលិច។ គរុវិទូក្រោយសម័យទំនើបនិយមប្រឆាំងនឹងគម្ពីរយ៉ាងសំខាន់ទាំងនេះ ដែលតំណាងឱ្យតែពួកបុរសមជ្ឈមណ្ឌលទ្វីបអឺរ៉ុបវប្បធម៌មូលធននិយម និងលោកខាងលិច។ ពួកគេអះអាងថា ស្នាដៃទាំងឡាយ ដែលមិនតំណាងឱ្យក្រុមទ្វីបអាហ្វ្រិក អាស៊ី អាម៉េរិកឡាទីន និងជនជាតិដើមភាគតិចកំណើតអាម៉េរិកទេ។ ពួកស្ត្រីនិយមដែលជាក្រុម មិនទទួលបានប្រ យោជន៍ខាងសេដ្ឋកិច្ច ពួកបុរសរួមភេទដូចគ្នា និងពួកនារីរួមភេទដូចគ្នា គួរតែត្រូវបានរាប់បញ្ចូលទៅក្នុងកម្មវិធីសិក្សាគោលនោះផងដែរ។ កម្មវិធីសិក្សាផ្សេងៗ ដែលត្រូវបានគាំទ្រដោយគរុវិទូក្រោយសម័យទំនើបនិ យម គួរតែអនុញ្ញាតឱ្យកុមារទាំងអស់ទទួលបានប្រយោជន៍ពីការសិក្សា។

**គ-ការបង្រៀនជារូបតំណាងមួយ**

គរុវិទូក្រោយសម័យទំនើបនិយម ជឿជាក់ថា ការបង្រៀនពាក់ព័ន្ធនឹងរូបតំណាង ដែលមានន័យថា ប្រភេទណាមួយនៃការបញ្ជាក់បង្ហាញខាងវប្បធម៌ ឬការពិភាក្សារាប់បញ្ចូល ទាំងភាសា រឿងនិទាន រូបភាព តន្ត្រី និងការបង្កើតវប្បធម៌ផ្សេងទៀត[4]។ គរុវិទូក្រោយសម័យទំនើបនិយម ជំរុញគ្រូបង្រៀនឱ្យមានតួនាទីប្រកបដោយញាណ និងប្រកបដោយអំណាច និងតម្រូវការ ដើម្បីពិនិត្យយ៉ាងល្អិតល្អន់នូវរូបតំណាង ដែលគាត់បានបង្កើតដល់សិស្ស។ ជាជាងផ្ទេរតែចំណេះដឹង ដែលបានបង្ហាញជាផ្លូវការនោះ គ្រូបង្រៀនត្រូវតែបង្ហាញយ៉ាងល្អិតល្អន់ និងដោយការគិតពិចារណា នូវបទពិសោធរបស់មនុស្សយ៉ាងទូលំទូលាយ[5]។ សិស្សនៅសាលារៀនក្រោយសម័យទំនើបនិយម គួរតែស្តាប់សំឡេង និងរឿងនិទានជាច្រើន ដែលរាប់បញ្ចូលទាំងស្វ័យជីវប្រវត្តិ និងជីវប្រវត្តិ ដែលជាប្រវត្តិមនុស្ស និងសង្គមរបស់សិស្ស ដែលសិក្សា នៅសាលា។ វាមានលក្ខណៈសំខាន់ចាំបាច់ ដែលក្រុមបន្ទាប់ប ន្សំ ត្រូវបានគេ

4 Elizabeth Ellsworth, ''Representation, Self-Representation, and the Meanings of Difference: Questions for Educators,'' in Rebecca A. Martusewicz and William M. Reynolds, Inside/Out: Contemporary Critiocal Perspectives in Education (New York: St. Martin's Press, 1994), p.100

5 Ibid., pp. 100-101.

ស្ដាប់ឮ និងមើលឃើញផ្ទាល់ និងក្លាយជាអ្នកចូលរួមក្នុងការសន្ទនា ដែលបានលើកឡើងប្រកបដោយញាណ[6]។

**៣-ការអនុវត្ត សម្រាប់គ្រូប្រចាំថ្នាក់នាពេលបច្ចុប្បន្ន**

**ក-ការផ្ដល់អំណាចដល់គ្រូ**

គរុវិទូក្រោយសម័យទំនើបនិយម ជំរុញឱ្យគ្រូផ្ដល់អំណាចដល់ខ្លួនឯងតាមរយៈ ការពិនិត្យមើលឡើងវិញយ៉ាងល្អិតល្អន់ នៃគោលបំណងរបស់សាលារៀន ខ្លឹមសារកម្មវិធីសិក្សា និងការចាត់តាំងតួនាទី និងបេសកកម្មនៃវិជ្ជាជីវៈបង្រៀន។ ការផ្ដល់អំណាចឱ្យគ្រូ មានន័យថា គ្រូបង្រៀនទទួលខុសត្រូវ ដើម្បីបង្កើតអនាគតផ្ទាល់ខ្លួនរបស់គេ និងដើម្បីជួយសិស្សឱ្យ បង្កើតជីវិតផ្ទាល់ខ្លួនរបស់គេ[7]។

**ខ-ទីតាំងផ្ដោតលើទស្សនវិជ្ជា**

លំនាំនៃការផ្ដល់អំណាចឱ្យគ្រូ និងសិស្ស ចាប់ផ្ដើមនៅក្នុងសាលារៀន និងសហគមន៍ ដែលពួកគេធ្វើការ និងរស់នៅ។ មិនដូចគរុវិទូមនោនិយម និងតថនិយម ដែលទាញយកទស្សនវិជ្ជាអប់រំពីការប៉ាន់ស្មានបែបបរមត្ថវិជ្ជាអរូបីនោះ គរុវិទូក្រោយសម័យទំនើបនិយម ជំរុញឱ្យគ្រូបង្កើតទស្សនវិជ្ជាអប់រំ ដែលមានទីតាំងផ្ទាល់ខ្លួន។ គ្រូបង្រៀន សិស្ស និងសមាជិកសហគមន៍ ត្រូវតែចាប់ផ្ដើមការត្រួតពិនិត្យ ដែលមានទីតាំងច្បាស់លាស់នៃបញ្ហាត្រួតពិនិត្យជាគន្លឹះ តាមការត្រួតពិនិត្យ បញ្ហាដូចជា៖

១-អ្នកណាត្រួតពិនិត្យសាលារៀន ពិតប្រាកដ បង្កើតកម្មវិធីសិក្សា និងកំណត់ស្តង់ដាសិក្សា?

២-អ្វីជំរុញទឹកចិត្តអ្នកទាំងឡាយ ដែលជាអ្នកគ្រប់គ្រងសាលារៀន?

៣-សនិទានភាពអ្វី ធ្វើយុត្តិកម្មកម្មវិធីសិក្សា ដែលមានស្រាប់?

កម្មវិធីសិក្សា នៅសាលារៀនក្រោយសម័យទំនើបនិយម គួរតែវិភាគបញ្ហានៃអត្តសញ្ញាណបុគ្គលនិងក្រុម ការគ្រប់គ្រង និងទំនាក់ទំនងអំណាច លើកទឹកចិត្តនយោបាយវប្បធម៌ និងការរិះគន់សង្គម ដែលនាំទៅដល់សកម្មភាពរួម។ ប្រភេទនៃការវិភាគល្អិតល្អន់បែបនេះ នឹងផ្ដល់អំណាចដល់មនុស្ស និងប្រែក្លាយសង្គម តាមការប្រឆាំងនឹងប្រយោជន៍ និងអភ័យឯកសិទ្ធិខាងនយោបាយ និងសង្គមដ៏ពិសេស។

**គ-ស្តង់ដា និងការវាយតម្លៃ**

**គ-១-គរុវិទូបច្ឆានទំនើបនិយម ពិនិត្យយ៉ាងល្អិតល្អន់ នៅលើការបង្កើត និងការប្រើប្រាស់ស្តង់ដា**

[6] William E. Doll, Jr., A Post-Modern Perspective on Curriculum (New York: Teachers College Press, 1993).

[7] Joe L. Kincheloe, *Toward A Critical Politics of Teacher Thinking: Mapping the postrnodern* (Westport, Conn.: Bergin & Garvey, 1993), p.35.

ការសង្កត់ធ្ងន់របស់គរុវិទូក្រោយសម័យទំនើបនិយម ទៅលើការស្តាប់ឮពីក្រុមផ្សេងៗ បង្ហាញអំណះអំណាងសម្រាប់ភាពផ្សេងៗគ្នាខាងវប្បធម៌ និងពហុវប្បធម៌និយមក្នុងសាលារៀនទាំងឡាយ។ ជាងនេះទៀត គរុវិទូក្រោយសម័យទំនើបនិយម ចោទសួរយ៉ាងល្អិតល្អន់ អំពីស្តង់ដាទាំងឡាយ ជាពិសេស នៅពេលដែលសាលារៀនប្រើប្រាស់តេស្តតាមស្តង់ដា ដើម្បីវាស់វែងស្នាដៃសិស្ស។ ជាពិសេស ពួកគេគួរតែស្រាវជ្រាវសម្រាប់ទំនាក់ទំនងអំណាច ដោយការសាកសួរថា តើនរណាជាអ្នកប្រគល់អាណត្តិធ្វើតេស្ត នរណាអភិវឌ្ឍតេស្ត នរណាបកស្រាយលទ្ធផលតេស្ត លទ្ធផលនឹងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច ហើយតើតួនាទីបែបណា ដែលអ្នកនយោបាយ មាតាបិតា គ្រូបង្រៀន និងសិស្សត្រូវអនុវត្ត ក្នុងការកំណត់ស្តង់ដា និងប្រើប្រាស់តេស្ត ដើម្បីផ្ទៀងផ្ទាត់ប្រសិនបើស្តង់ដាត្រូវបានគេធ្វើយតប។

សំណួរស្រដៀងគ្នា គួរអនុវត្ត ដើម្បីវិភាគការប្រើប្រាស់បច្ចេកវិជ្ជាក្នុងថ្នាក់រៀន។ អ៊ិនធឺណិត អាចផ្តល់អំណាច ដល់មនុស្សតាមការបង្កើតមធ្យោបាយទំនាក់ទំនង ដើម្បីបែងចែកគំនិត និងការព្រួយបារម្ភរួមជាមួយគ្នាទៅវិញទៅមក។ ដូចគ្នានេះដែរ បច្ចេកវិជ្ជាប្រសិនបើត្រូវបានគ្រប់គ្រងដោយក្រុមដ៏សំខាន់នោះអាចជួយអប់រំមនុស្ស ដើម្បីទទួលយកស្ថានភាពដដែលៗ ដើម្បីដកហូតអំណាចពួកគេ។ គ្រូបង្រៀនក្រោយសម័យទំនើបនិយម គួរតែមានភាពជឿជាក់ ដើម្បីពិនិត្យរូបតំណាងក្នុងកម្មវិធី សម្រាប់ការប្រើប្រាស់របស់សិស្ស ព្រមទាំងដើម្បីពិចារណាបញ្ហានៃអំណាច ដែលមានការពាក់ព័ន្ធ ដល់ការរៀបចំសិស្សឱ្យទទួលបានបច្ចេកវិជ្ជា។

### គ-២-មេរៀនការអប់រំតាមបច្ឆានទនិយម

តើមេរៀនគរុវិទូក្រោយសម័យទំនើបនិយម មានលក្ខណៈដូចម្តេច? សិស្សនៅក្នុងថ្នាក់រៀនប្រវត្តិវិទ្យា នៅសាលាមធ្យមសិក្សាអាម៉េរិក អាចពិនិត្យមើលពីរបៀបជនជាតិម៉ិកស៊ីក រស់នៅក្នុងដែនដី ដែលប្រទេសម៉ិកស៊ិក ត្រូវបានគេបង្ខំ ប្រគល់ឱ្យសហរដ្ឋអាម៉េរិក ក្រោយសង្គ្រាមម៉ិកស៊ិកលែងមានភាពសំខាន់។ បន្ទាប់មក គេអាចពិភាក្សាពីរបៀបដែលជនជាតិឡាតាំងនិងក្រុមបន្ទាប់បន្សំផ្សេងទៀតបានបង្កើតសំឡេងដែលត្រូវបានគេឮពាសពេញប្រវត្តិសាស្ត្រអាម៉េរិក។ មេរៀន អាចរាប់បញ្ចូលពីកិច្ចការទិនានុប្បវត្តិ ដែលក្នុងនោះ សិស្ស ពិនិត្យមើលផ្នែកទាំងឡាយនៃជីវិតរបស់គេនៅកន្លែង ដែលគេមានអារម្មណ៍ថា ទទួលបានអំណាច ឬមិនមានភាពសំខាន់ហើយផ្តល់យោបល់ និងសកម្មភាពមួយចំនួន ដែលគេជឿជាក់ថា នឹងអាចជួយឱ្យសំឡេងពួកគេត្រូវបានឮ តាមរបៀបស្ថាបនា។

## សន្និដ្ឋាន

ទ្រឹស្តីបច្ឆាននិយម ដែលទទួលបានពីការទ្រដោយលោក Derrida និង Foucault ជាទ្រឹស្តីទស្សនវិជ្ជាសំខាន់មួយ ដែលត្រូវបានគេយក ទៅប្រតិបត្តិក្នុងវិស័យអប់រំ ដែលថា សាលារៀន គឺជាកន្លែងនៃការរិះគន់បែបប្រជាធិបតេយ្យ និងការផ្លាស់ប្តូរសង្គម ដើម្បីផ្តល់អំណាចដល់ក្រុមដែលត្រូវគេត្រួតត្រាឬគ្រប់គ្រង

## ឯកសារយោង


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.

2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

3- Friedrich Nietzsche, *The Will to Power*, trans. Walter Kaufmann, New York: Vintage, 1967.

4- David E. Cooper, *World philosophies: An Historical Introduction*, Oxford, U.K, and Cambridge, Mass.: Blackwell, 1996.

5- John A. Zahorik, *Constructivist Teaching*, Bloomington, Ind.: Phi Delta Kappa Educational Foundation, 1995.

6- Angeline Martel and Linda Peterat, *''Margins of Exclusion, Margins of Transformation: The Place of Women in Education,*'' in Redecca A. Martusewicz and William M. Reynolds, *Inside/ Out: Contemporary Critical Perspectives in Education*, New York: St. Martin's Press, 1994.

7- Elizabeth Ellsworth, ''*Representation, Self-Representation, and the Meanings of Difference: Questions for Educators,*'' in Rebecca A. Martusewicz and William M. Reynolds, Inside/Out: Contemporary Critiocal Perspectives in Education, New York: St. Martin's Press, 1994.

8- William E. Doll, Jr., A Post-Modern Perspective on Curriculum, New York: Teachers College Press, 1993.

9- Joe L. Kincheloe, *Toward A Critical Politics of Teacher Thinking: Mapping the postrnodern* Westport, Conn.: Bergin & Garvey, 1993.

# ប្រភពនៃទស្សនវិជ្ជាអប់រំ៖ ប្រតិបត្តិនិយម និងអត្ថិភាពនិយម


*ដោយ៖* **បណ្ឌិត សូ សុធីរ**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*


## សេចក្តីផ្តើម

*ប្រតិបត្តិនិយមគឺជាប្រពៃណីទស្សនវិជ្ជា ដែលចាត់ទុកភាសា និងការគិតជាឧបករណ៍សម្រាប់ការទស្សន៍ទាយការដោះស្រាយបញ្ហា និងសកម្មភាព ជាជាងការពិពណ៌នា ការបង្ហាញ ឬការឆ្លុះបញ្ចាំងតថភាព។ ប្រតិបត្តិនិយមវិទូ អះអាងថា ប្រធានបទទស្សនវិជ្ជាភាគច្រើន ដូចជាធម្មជាតិនៃចំណេះដឹង ភាសា គោលគំនិត អត្ថន័យ ជំនឿ និងវិទ្យាសាស្ត្រ សុទ្ធតែត្រូវបានមើលយ៉ាងល្អបំផុតទាក់ទងនឹងការប្រើប្រាស់ជាក់ស្តែង និងភាពជោគជ័យរបស់ពួកគេ។ ប្រតិបត្តិនិយម បានចាប់ផ្តើមនៅសហរដ្ឋអាម៉េរិកក្នុងទសវត្សរ៍ឆ្នាំ១៨៧០។*

*អត្ថិភាពនិយមគឺជាទម្រង់នៃការសិក្សាស្រាវជ្រាវទស្សនវិជ្ជាដែលស្វែងយល់ពីបញ្ហានៃអត្ថិភាពរបស់មនុស្ស។ ទស្សនវិទូអត្ថិភាពនិយមស្រាវជ្រាវបញ្ហាទាក់ទងនឹងអត្ថន័យ គោលបំណង និងតម្លៃនៃអត្ថិភាពរបស់ មនុស្ស។ គំនិតទូទៅនៅក្នុងគំនិតអត្ថិភាពនិយមរួមមានវិបត្តិអត្ថិភាព ការភ័យខ្លាច និងការថប់បារម្ភចំពោះមុខពិភពលោក ដែលមិនសមហេតុផល និងឆន្ទៈសេរី ក៏ដូចជាភាពត្រឹមត្រូវ ភាពក្លាហាន និងគុណធម៌។*

*អត្ថិភាពនិយមត្រូវបានផ្សារភ្ជាប់ជាមួយនឹងទស្សនវិទូអឺរ៉ុប នៅសតវត្សរ៍ទី១៩និងសតវត្សរ៍ទី២០ ដែលបានចែករំលែកការសង្កត់ធ្ងន់លើប្រធានបទរបស់មនុស្ស ទោះបីជាជា រឿយៗ មានភាពខុសគ្នាយ៉ាងជ្រាលជ្រៅ នៅក្នុងគំនិតក៏ដោយ។*

## ១-ប្រតិបត្តិនិយម

### ក-ស្ថាបនិកប្រតិបត្តិនិយម

*ប្រតិបត្តិនិយម អះអាងបញ្ជាក់នូវតម្រូវការ ដើម្បីធ្វើតេស្តគំនិត តាមការធ្វើសកម្មភាពទៅលើគំនិតទាំងនោះ។ ក្នុងចំណោមស្ថាបនិកទាំងឡាយគឺ* Charles S. Peirce (1839-1914), William James (1842-1910), George Herbert Mead (1863-1931), *និង* John Dewey (1859-1952)។

-Peirce *បានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់* ***វិធីវិទ្យាសាស្ត្រ*** *ដើម្បីធ្វើឱ្យមានតុល្យភាពគំនិតតាមបែបសង្កេតពិសោធ។*

-James បានអនុវត្តទស្សនវិជ្ជាប្រតិបត្តិនិយម ទៅនឹងចិត្តវិទ្យា សាសនា និងការអប់រំ។

-Mead បានអះអាងបញ្ជាក់ការអភិវឌ្ឍកុមារថា ជាការសិក្សា និងការពិសោធអ្វីៗ ដែលមានជីវិតរបស់មនុស្ស។

-Dewey បានអនុវត្តដល់ការអប់រំ[1]។

នៅទីនេះ យើងផ្តោតអារម្មណ៍ ទៅលើទស្សនវិជ្ជាប្រតិបត្តិនិយម ឬពិសោធនិយម ដែលធ្វើជាការផ្លាស់ប្តូរ ជាពិសេសលំនាំសាបេក្ខភាព និងការស្ថាបនាឡើងវិញនូវបទពិសោធ។

### ខ-សព៌ាង្គកាយ និងបរិស្ថាន

ដោយទទួលបានទ្រឹស្តីវិវត្តរបស់ Charles Darwin នោះ Dewey បានអនុវត្តវាក្យសព្ទសព៌ាង្គកាយ និងបរិស្ថាន ចំពោះការអប់រំ។ Dewey បានមើលឃើញមនុស្សជាតិថាជាសរីរាង្គមានជីវិតផ្នែកសង្គមសាស្ត្រ និងជីវសាស្ត្រ ដែលមានចំណង់ និងពលវេគ ដែលទ្រទ្រង់ជីវិត និងជំរុញការលូតលាស់ និងការអភិវឌ្ឍ។ គ្រប់សរីរាង្គមានជីវិតរស់នៅក្នុងជម្រកមួយ និងបរិស្ថាន។ ការអប់រំ គឺជាលំនាំមួយនៃការបង្កើតបរិស្ថានសិក្សា ដែលនឹងជំរុញដល់បទពិសោធទាំងឡាយ សម្រាប់ការលូតលាស់មនុស្សដ៏ប្រសើរបំផុត។

### គ-ការដោះស្រាយបញ្ហា

ទោះបីជាមនោនិយម និងតថនិយម បានសង្កត់ធ្ងន់ទៅលើអង្គនៃពុទ្ធិដ៏សំខាន់ក៏ដោយ ក៏កម្មវត្ថុសិក្សាតាមមុខវិជ្ជានោះ Dewey បានសង្កត់ធ្ងន់ ទៅលើលំនាំនៃការដោះស្រាយបញ្ហា។ សម្រាប់ Dewey ការសិក្សា កើតមានឡើង នៅពេលដែលមនុស្ស បានចូលរួមក្នុងការដោះស្រាយបញ្ហា។ នៅក្នុងទ្រឹស្តីនៃចំណេះដឹងនោះ សិស្សក្នុងនាមជាបុគ្គលម្នាក់ ឬជាសមាជិកនៃក្រុមមួយ ប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីដោះស្រាយទាំងបញ្ហាបុគ្គលទាំងសង្គម។ សម្រាប់ Dewey វិធីដោះស្រាយបញ្ហា អាចត្រូវបានអភិវឌ្ឍទៅជាទម្លាប់ ដែលប្រែក្លាយទៅជាស្ថានភាពផ្សេងៗដ៏ទូលំទូលាយ[2]។

### ៤-១-បញ្ញត្តិជាគន្លឹះ

### ក-បទពិសោធ

**បរមត្ថវិជ្ជា និងពុទ្ធិវិទ្យា** មិនដូចមនោនិយម និងតថនិយម ដែលទាំងពីរពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះខាងបរមត្ថវិជ្ជានៃតថភាពសកល និងថេរនោះ ប្រតិបត្តិនិយម ឬបទពិសោធនិយម កម្ចាត់បរមត្ថវិជ្ជា ថាជាការសន្មត ដែលគេមិនអាចផ្ទៀងផ្ទាត់បាន។ លើសពីបរមត្ថវិជ្ជា ប្រតិបត្តិនិយម មានការពាក់ព័ន្ធជាខ្លាំងនឹងពុទ្ធិវិទ្យា។

---

[1] John Dewey, *The Child and the Curriculum* (Chicago: University of Chicago Press, 1902); John Dewey, *Democracy and Education* (New York: Macmillan, 1916; Jonh Dewey, *The School and Society* (Chicago: University of Chicago Press, 1923); and Jonh Dewey, *Experience and Education: The 60 th Anniversary Edition* (West Lafayette, Ind.: Kappa Delta Pi, 1998).

[2] Lawrence J. Dennis and George W. Stickel, Mead and Dewey: Thematic Connections on Educational Topics, *Educational Theory* (Summer-Fall 1981), pp. 320-321.

នៅក្នុងទស្សនវិជ្ជានៃបទពិសោធនិយមរបស់ Dewey ស្ថានភាពពុទ្ធិវិទ្យា ពាក់ព័ន្ធនឹងមនុស្ស ឬអ្វី ដែលមានជីវិត និងបរិស្ថាន។ បទពិសោធដែលបានកំណត់ន័យថាជាអន្តរកម្មរវាងមនុស្ស និងបរិស្ថាននោះ ជាបញ្ញត្តិគន្លឹះ។ មនុស្សធ្វើអន្តរកម្មជាមួយបរិស្ថាន ដើម្បីរស់នៅ លូតលាស់ និងអភិវឌ្ឍ។ អន្តរកម្មនេះអាចផ្លាស់ប្តូរ ទាំងមនុស្ស ទាំងបរិស្ថាន។ ដូច្នេះ ការចេះដឹងគឺជាកិច្ចការលំនាំរវាងសិស្ស និងមជ្ឈដ្ឋាន[3]។

**ខ-តេស្តនៃបទពិសោធ**

ដោយជំទាស់នឹងទស្សនវិស័យមនោនិយម និងតថនិយមមុនៗ Dewey បានអនុវត្តតេស្តមួយពីបទពិសោធ។ ផែនការ និងគោលបំណងមនុស្សអាចត្រូវបានធ្វើឱ្យមានសុពលភាពតែម្យ៉ាង តាមសកម្មភាពនិងការវិនិច្ឆ័យ វាតាមផលរបស់វា។ ថ្វីបើអន្តរកម្មនីមួយៗ មានទិដ្ឋភាពអាចធ្វើទូទៅកម្ម ដែលអាចអនុវត្តចំពោះបញ្ហានាពេលបន្ទាប់ ដែលឧបកថានីមួយៗ នឹងខុសគ្នាបន្តិចបន្តួច។ មនុស្សដ៏មានប្រសិទ្ធភាព ប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីដោះស្រាយបញ្ហា និងបន្ថែមផ្នែកគួរឱ្យកត់សម្គាល់នៃឧបកថាដោះស្រាយបញ្ហា ពិសេសចំពោះបទពិសោធដែលចេះតែបន្តរបស់គេ។

Dewey ក៏បានអនុវត្តការវិនិច្ឆ័យ តាមផលចំពោះការអប់រំ។ តើកម្មវិធីអប់រំពិសេសការរៀបចំកម្មវិធីសិក្សាឬល្បិចតាមវិធីសាស្ត្រសម្រេចបានគោលដៅ និងវត្ថុបំណង ដែលបានទទួនីងរង់ចាំឬទេ? Dewey ជឿជាក់ថាតេស្តដែលមានសុពលភាព ត្រូវសាកល្បងសំណើ និងវិនិច្ឆ័យលទ្ធផល[4]។

**គ-មិនមានតថភាពអចិន្ត្រៃយ៍, ការកសាងឡើងវិញនៃមនុស្ស និងបរិស្ថាន**

តថភាពដែលផ្លាស់ប្តូរជាបន្តបន្ទាប់ ផ្តល់ឱ្យកម្មវិធីសិក្សា ដោយពឹងផ្អែកទៅលើតថភាពជាអចិន្ត្រៃយ៍ ឬសច្ចភាពសាកល ដែលមិនអាចការពារបាន។ មនុស្សលោក ត្រូវតែធ្វើអន្តរកម្មជាមួយបរិស្ថាន ដែលត្រូវបាននាំផ្លូវតែម្យ៉ាង ដោយការអះអាង ដែលមិនទាន់ប្រាកដអាស្រ័យទៅលើការស្រាវជ្រាវ និងការផ្ទៀងផ្ទាត់បន្ថែម។ ហេតុដូច្នោះ យោងទៅតាមពួកប្រតិបត្តិនិយម យើងត្រូវការវិធីមួយ សម្រាប់ធ្វើការពិភាក្សាជាមួយការផ្លាស់ប្តូរ តាមរបៀបមួយឈ្លាសវៃ។ ទ្រឹស្តីរបស់ Dewey សង្កត់ធ្ងន់ទៅលើការដោះស្រាយបញ្ហា ជាវិធីដ៏មានប្រសិទ្ធភាពបំផុត សម្រាប់ការដឹកនាំ ការផ្លាស់ប្តូរ ចំពោះលទ្ធផល ដែលចង់បាន។ ទោះបីជាតថភាព ពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកសាងឡើងវិញទាំងមនុស្សទាំងបរិស្ថាននោះ មនុស្ស

[3] For an analysis of Deweyan's Pragmatic Perspective, see Christine L. McCarthy and Evelyn Sears, Deweyan Pragmatism and the Quest for True Self, *Educational Theory* (Spring 2000), pp. 213-227

[4] Stephen M. Fishman and Lucille McCarthy, Jonh Dewey and the Challenge of Classroom Practice (New York: Teachers Colloge Press, 1998)

ជាតិ អាចទទួលប្រយោជន៍ពីលំនាំនេះ។ គ្រប់បទពិសោធមនុស្ស ដែលគេបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាមួយ បានបង្កើនបទពិសោធមនុស្សថែមទៀត។

**ឃ-សារបេក្ខភាពនៃតម្លៃ វិទ្យាសាស្ត្រសីលធម៌និងតក្កវិជ្ជា**

វិទ្យាសាស្ត្រសីលធម៌តាមប្រតិបត្តិនិយម គឺមានលក្ខណៈទៅតាមស្ថានភាពកម្រិតខ្ពស់។ ចក្រវាឡ ដែលកំពុងផ្លាស់ប្តូរជាប្រចាំ មានន័យថា តម្លៃ ត្រូវតែផ្លាស់ប្តូរផងដែរ និងមានការទាក់ទងទៅនឹងពេលវេលា ទីកន្លែង និងកាលៈទេសៈ។ អ្វីដែលរួមចំណែកដល់ការលូតលាស់សង្គម និងបុគ្គល យើងចាត់ទុកថាមានតម្លៃ។ អ្វីដែលរឹតបន្តឹង ឬកំណត់ដែនបទពិសោធមនុស្ស គឺមិនមានតម្លៃទេ។ ជាងនេះទៀត យើង ក៏អាចធ្វើបញ្ជាំងតម្លៃរបស់យើង តាមការធ្វើតេស្ត និងការកសាងឡើងវិញ តាមរបៀបតែមួយ ដែលយើងផ្ទៀងផ្ទាត់តាមការទាមទារបែបវិទ្យាសាស្ត្រ[5]។

**ង-តក្កវិជ្ជាបែបអនុមានរួម**

ដោយអនុវត្តតាមវិធីវិទ្យាសាស្ត្រ តក្កវិជ្ជាតាមបែបពិសោធនិយមគឺមានលក្ខណៈ អនុមានរួម ជាជាងអនុមានញែក អំពីគោលការណ៍ដំបូង ដូចជាមនោនិយម និងតថនិយម។ ការបញ្ជាក់អះអាង ដែលមិនទាន់ជាក់លាក់ពឹងផ្អែកទៅលើកស្តុតាង តាមបែបសង្កេតពិសោធ ហើយត្រូវតែធ្វើតេស្ត។

**៤-២-សំណួរជាមូលដ្ឋាន**

**ក-ចំណេះដឹង ដែលមិនទាន់មានភាពជាក់លាក់**

ចម្លើយរបស់ពួកប្រតិបត្តិនិយម ចំពោះសំណួរអំពីចំណេះដឹង ការអប់រំ ការសិក្សា និងការបង្រៀន ខុសគ្នាយ៉ាងសំខាន់ពីពួកមនោនិយម និងតថនិយម។ ពីព្រោះការទាមទារចំណេះដឹង មិនទាន់មានលក្ខណៈជាក់លាក់ និងអាស្រ័យទៅលើការរំលឹកសាឡើងវិញនោះ ពួកប្រតិបត្តិនិយម មានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយលំនាំនៃការបង្កើត និងការប្រើប្រាស់ចំណេះដឹងជាងជាមួយសច្ចភាពដែលជាអង្គនៃចំណេះដឹងជាអចិន្ត្រៃយ៍។

**ខ-លំនាំតាមបែបពិសោធ**

ពួកប្រតិបត្តិនិយម ចាត់ទុកការអប់រំជាលំនាំបទពិសោធ គឺវិធីនៃការដោះស្រាយបញ្ហាដែលស្វែងរកការពិតពីមនុស្ស នៅពេលដែលពួកគេធ្វើអន្តរកម្ម ជាមួយនឹងពិភពរបស់គេ។ Dewey បានអះអាងថាមនុស្សជាតិឆ្លងកាត់បទពិសោធទូវការលូតលាស់ផ្នែកសង្គម និងបុគ្គលដ៏ធំធេងបំផុត នៅពេលដែលគេធ្វើអន្តរកម្មជាមួយបរិស្ថានតាមលក្ខណៈឈ្លាសវៃនិងរិះគិត

[5] William R. Caspary, Judgements of Value in Jonh Dewey's Theory of Ethics, *Educational Theory* (Spring 1990), pp. 155-169. See also Robert B. Westbrook, *Jonh Dewey and American Democracy* (Ithaca, N.Y.: Cornell University Press, 1991), pp. 151-156.

ពិចារណា។ របៀបល្អបំផុតនៃការដោះស្រាយបញ្ហា គឺត្រូវប្រើប្រាស់វិធីវិទ្យាសាស្ត្រ។

**គ-គោលវិធីអន្តរមុខវិជ្ជា**

ពួកប្រតិបត្តិនិយម គាំទ្រដល់ការអប់រំដែលមានមុខវិជ្ជារួមគ្នា។ ពួកគេនិយាយថា នៅពេលដែលអ្នកប្រឈមមុខនឹងបញ្ហា អ្នកទាញយកព័ត៌មាន ដែលអ្នកត្រូវការ ដើម្បីដោះស្រាយវាពីប្រភពជាច្រើន មិនមែនពីផ្នែក ឬមុខវិជ្ជាតែមួយទេ។

ឧទាហរណ៍ ដើម្បីកំណត់បញ្ហានៃភាពកខ្វក់ក្នុងបរិស្ថាន និងការផ្ដល់យោបល់ក្នុងការដោះស្រាយវា យើងត្រូវតែពិចារណាប្រភពទាំងឡាយ ដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ នយោបាយ សង្គមវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងអន្តរជាតិ។

តាមន័យបែបប្រតិបត្តិនិយម មនុស្សដែលមានការអប់រំ ដឹងពីរបៀបអនុវត្តព័ត៌មានពីប្រភពទាំងនេះចំពោះបញ្ហា។ ផ្ទុយពីទស្សនៈពួកប្រតិបត្តិនិយមនេះ ពួកមនោនិយម និងតថនិយម មានការសង្ស័យពីការអប់រំអន្តរមុខវិជ្ជាពីព្រោះគេជឿថា សិស្ស ត្រូវតែទទួលបានមូលដ្ឋានចំណេះដឹងជាលើកដំបូង តាមការសិក្សាពីប្រធានវិស័យដែលបានរៀបចំរួមគ្នា។

**ឃ-សាលារៀនជាគំរំណែទម្រង់តាមខុទ្ទកភាព និងការផ្ទេរមត៌កវប្បធម៌**

ពួកប្រតិបត្តិនិយម ដូចជា Dewey មើលឃើញសហគមន៍សិស្ស និងគ្រូ នៅតាមមូលដ្ឋានតូចតាច មានការពាក់ព័ន្ធជាខ្លាំងទៅនឹងសង្គមធំជាងនេះ។ សាលារៀន បានហ៊ឹកហាត់មុខងារចម្បងបីជួយសម្រួលបន្សុទ្ធ និងធ្វើឱ្យមានតុល្យភាពដល់មរតកវប្បធម៌។

-ដើម្បីជួយសម្រួល ឬធ្វើឱ្យមានភាពងាយស្រួល សាលារៀន ជ្រើសរើសជាតុនៃមរតក និងកាត់បន្ថយភាពស្មុគស្មាញ ទៅនឹងក្រុម ដែលសមរម្យ ចំពោះចំណូលចិត្ត និងភាពត្រៀម ជាស្រេចរបស់សិស្ស។

-ដើម្បីបន្សុទ្ធ វាជ្រើសរើសជាតុខាងវប្បធម៌ដ៏មានតម្លៃ និងលុបបំបាត់ជាតុទាំងឡាយ ដែលកំណត់ដែនដល់ការលូតលាស់ និងអន្តរកម្មមនុស្ស។

-ដើម្បីធ្វើមានតុល្យភាព សាលារៀនធ្វើអន្តរកម្មបទពិសោធដែលបានជ្រើសរើស និងបន្សុទ្ធ ទៅជាភាពចុះសម្រុងនឹងគ្នា។

**ខ-វប្បធម៌ផ្សេងៗគ្នា តែលំនាំសិក្សាមានលក្ខណៈរួមគ្នា**

នៅក្នុងសង្គម ដែលមានក្រុមវប្បធម៌ផ្សេងៗគ្នានោះ សាលារៀនប្រតិបត្តិនិយម ជួយសិស្សដែលមានវប្បធម៌មួយ យល់ និងវាយតម្លៃសមាជិកនៃវប្បធម៌ផ្សេងៗទៀត។ ទោះបីជាភាពផ្សេងគ្នាខាងវប្បធម៌ ជួយកែលំអសង្គមទាំងមូលក៏ដោយក៏ពួកប្រតិបត្តិនិយមចង់ឱ្យក្រុមវប្បធម៌ទាំងអស់ ប្រើប្រាស់វិធីវិទ្យាសាស្ត្រ។ ពួកគេក៏ជឿជាក់ថា សាលារៀន គួរស្ថាបនាមតិទូទៅផ្នែកសង្គម ដោយសង្កត់ធ្ងន់ ទៅលើលំនាំសិក្សាទូទៅ។ ព្រោះតែមានសហគមន៍សិក្សាបែបប្រជាធិបតេយ្យ និងសមាហរណកម្មដ៏ពិត

ប្រាកដនោះ សាលារៀន គួរតែបើកចំហ ដល់ជនទាំងអស់គ្នា និងលើកទឹកចិត្តដល់ការរួមចំណែក នៃធនធានដែលអាចធ្វើទៅបាន ដោយទូលំទូលាយ ក្នុងចំណោមមនុស្សនៃវប្បធម៌ទាំងអស់។

**៤-៣-ការអនុវត្តសម្រាប់គ្រូប្រចាំថ្នាក់នាពេលបច្ចុប្បន្ន**

**ក-កម្មវត្ថុមុខវិជ្ជា ជាឧបករណ៍**

គ្រូបង្រៀនមនោនិយមនិងតថនិយមមើលឃើញកម្មវត្ថុមុខវិជ្ជាបង្រៀន ថាជាការទទួលខុសត្រូវដំបូង ប៉ុន្តែ គ្រូបង្រៀនប្រតិបត្តិនិយម យកចិត្តទុកដាក់នឹងលំនាំនៃការដោះស្រាយបញ្ហា ប្រកបដោយភាពវាងវៃច្រើនជាង។ ជាជាងធ្វើមិនដឹងមិនឮ ទៅលើកម្មវត្ថុមុខវិជ្ជា ពួកគេបង្កើតវានូវឧបករណ៍មួយក្នុងស កម្មភាពដោះស្រាយបញ្ហា។ ពួកគេមិនគ្រប់គ្រងថ្នាក់រៀនទេ ប៉ុន្តែដឹកនាំការសិក្សា ក្នុងនាមជាអ្នកជួយសម្របសម្រួលសកម្មភាព និងការស្រាវជ្រាវរបស់និស្សិត។ គ្រូបង្រៀនប្រតិបត្តិនិយម ក៏ជួយសិស្សផងដែរ ឱ្យរកឃើញប្រភពផ្សេងទៀតដែលមានប្រយោជន៍ នៅក្នុងការដោះស្រាយបញ្ហាដូចជាអ្នកទាំងឡាយ ដែលអាចទទួលបាន តាមបច្ចេកវិទ្យាក្នុងថ្នាក់រៀន[6]។

**ខ-ការអនុវត្តវិធីវិទ្យាសាស្ត្រ**

សិស្សនៅក្នុងថ្នាក់រៀនពួកប្រតិបត្តិនិយម បែងចែកបទពិសោធនៃការអនុវត្តវិធីវិទ្យាសាស្ត្រ ទៅដល់កម្រិតពេញលេញនៃបញ្ហាបែបបុគ្គលសង្គមនិងឈ្លាសវៃ។ គ្រូបង្រៀនរំពឹងថា សិស្សដោយប្រើវិធីវិទ្យាសាស្ត្រ នឹងសិក្សាដើម្បីអនុវត្តលំនាំចំពោះបញ្ហាទាំងក្នុងនិងក្រៅសាលារៀន ហើយភ្ជាប់សាលារៀនទៅនឹងសង្គម។ បច្ចេកវិទ្យាទំនាក់ទំនង ដូចជា អ៊ីមេល និងអ៊ីនធឺណិត ក៏បង្កើតទំនាក់ទំនងទូលំទូលាយជាងជាមួយឱកាសច្រើនជាង ដើម្បីបែងចែកការប្រើប្រាស់រួមគ្នានូវគំនិត ការយល់ដឹង និងបទពិសោធទាំងឡាយ។

**គ-ថ្នាក់រៀនមួយជាសហគមន៍**

គ្រូបង្រៀនប្រតិបត្តិនិយម ធ្វើការងារដើម្បីផ្លាស់ប្តូរថ្នាក់រៀន ទៅជាសហគមន៍សិក្សាបែបសហការ (Collaborative learning communities) តាមការលើកទឹកចិត្ត ឱ្យចេះបែងចែកប្រយោជន៍របស់ពួកគេ និងបញ្ហា។ អ្នកអប់រំប្រតិបត្តិនិយម ក៏លើកទឹកចិត្ត ទាំងភាពផ្សេងគ្នាខាងវប្បធម៌ ទាំងភាពទូទៅផងដែរ។ ទោះបីជាគេទទួលស្គាល់ថា វប្បធម៌នីមួយៗមានតម្លៃអ្វីមួយ ដើម្បីរួមចំណែកដល់វប្បធម៌ផ្សេងទៀតក៏ដោយ ក៏គេបានអះ អាងបញ្ជាក់នូវទំនាក់ទំនងរួមគ្នា រវាងសមា ជិកនៃវប្បធម៌ផ្សេងៗគ្នា ដើម្បីឱ្យសិស្សទាំងអស់គ្នា អាចជួយបង្កើតសហគមន៍ប្រជាធិបតេយ្យធំទូលាយជាងនេះទៀត។ ជំនួសឱ្យការរក្សាតំណែងទាំង

[6] For an examination of the philosophical implications of technology, see Larry A. Hickman, *Philosophical Tools for Technological Culture* (Bloomington: Indiana University Press, 2001).

នេះ គ្រូបង្រៀន ត្រូវតែប្រថុយ។ ពួកគេត្រូវតែមើលឃើញចំណេះដឹងថា គ្មានដែនកំណត់ និងបើកចំហ ហើយគោលដៅអប់រំរបស់ពួកគេត្រូវតែបង្កើតការអង្កេតជាបន្ត ដែលនាំដល់សកម្មភាព។

**ឃ-ស្តង់ដា និងការវាយតម្លៃ**
**សំណួរដែលជាចលនាស្តង់ដា**

*ពួកប្រតិបត្តិនិយម នឹងលើកសំណួរសំខាន់ៗ អំពីចលនាស្តង់ដា ជាពិសេស ការពឹងផ្អែកជាខ្លាំង ទៅការធ្វើតេស្ត តាមស្តង់ដា។ តេស្តបែបនេះ ជាបន្ទុកដល់សិស្សជាមួយគោលដៅ និងការរំពឹងទុកជាមុន ដែលកំណត់ដោយមនុស្ស និងភ្នាក់ងារផ្សេងទៀត ជាជាងអ្នកទាំងឡាយ ដែលលើកឡើងពីបទពិសោធ និងបញ្ហាសិស្សផ្ទាល់ខ្លួន។ ជាងនេះទៀត តេស្តដែលប្រើក្រដាស និងសរសេរដោយខ្មៅដៃវាស់បានតែរបៀបដែលសិស្សទទួលយកបានខ្លឹមសារ ដែលបានកំណត់ទុកប្រសើរជាងបំណិនដោះស្រាយប ញ្ហាតេស្តដោយពិតប្រាកដបានល្អប៉ុណ្ណា។ គ្រូដែលសមត្ថភាពរបស់គាត់ ត្រូវបានវិនិច្ឆ័យតាមថា តើសិស្សធ្វើតេស្តតាមស្តង់ដាបានល្អប៉ុណ្ណានោះ ផ្តោតអារម្មណ៍ការបង្រៀនទៅលើការធ្វើតេស្តជាប់ជាជាងការដោះ ស្រាយបញ្ហា។*

**៥-អត្ថិភាពនិយម** ( Existentialism)

*អត្ថិភាពនិយម ដែលតំណាងឱ្យទាំងអារម្មណ៍នៃការត្រៀមប្រយុទ្ធ ទៅនឹងភាពអស់សង្ឃឹម* (Desperation) *និងស្មារតីនៃក្តីសង្ឃឹម* (A spirit of hope) *នោះ* ***សិក្សាអំពីជីវិត តាមជម្រើសផ្ទាល់ខ្លួន ឬជាបុគ្គល។*** *ការអប់រំតាមបែបអត្ថិភាពនិយម លើកទឹកចិត្តការឆ្លុះបញ្ចាំង ជាបុគ្គលយ៉ាងជ្រាលជ្រៅ ទៅលើអត្តសញ្ញាណ ការសន្យា និងការជ្រើសរើសរបស់អ្នកណាម្នាក់។*

**៥-១-បញ្ញត្តិជាគន្លឹះ**

**ក-ការឆ្លុះបញ្ចាំងជាបុគ្គល និងការបង្កើតខ្លឹមសារដ៏សំខាន់របស់ខ្លួន តាមការជ្រើសរើស**

*អ្នកនិពន្ធអត្ថិភាពនិយម* Jean-Pual Satre (1905-1980) *បានអះអាងថា អត្ថិភាព នាំមុខខ្លឹមសារដ៏សំខាន់។ តាមន័យផ្សេងទៀត មនុស្សលោក បានកើតឡើង នៅក្នុងពិភពលោក ដោយគ្មានបានពិគ្រោះយោបល់។ យើងរស់នៅក្នុងពិភពលោកយ៉ាងសាមញ្ញ ដែលយើងមិនបានបង្កើតឡើង។ ទោះជាយ៉ាងនេះក្តី មនុស្សយើង មានឆន្ទៈ ហើយត្រូវបង្កើតការជ្រើសរើស និងបង្កើតគោលបំណងនៃអត្ថិភាពផ្ទាល់ខ្លួនរបស់យើង។ ក្នុងជីវិតរបស់យើង យើងត្រូវឆ្លងកាត់ស្ថានភាព ដែលបង្កើតការជ្រើសរើស។ ការជ្រើសរើសមួយចំនួន គឺមានលក្ខណៈមិនសុីជម្រៅ ប៉ុន្តែ អ្នកទាំងឡាយដែលយកចិត្តទុកដាក់នឹងគោលបំណង និងអត្ថន័យនៃជីវិត នាំទៅរកការកំណត់ន័យផ្ទាល់ខ្លួន។ យើងបង្កើតនិយមន័យផ្ទាល់ខ្លួន និងបង្កើតខ្លឹមសារផ្ទាល់ខ្លួនរបស់យើង។ ពួកអត្ថិភាពនិយម និយាយថា សេរីភាពរបស់*

*មនុស្ស មានភាពពេញលេញ ដូចជាការទទួលខុសត្រូវ សម្រាប់ការជ្រើសរើស[7]។*

### ខ-ភាពភ័យខ្លាចបែបអត្ថិភាពនិយម

*គំនិតនៃមនុស្សលោក ជាអ្នកបង្កើតខ្លឹមសារដោយផ្ទាល់ខ្លួន ខុសប្លែកគ្នាជាខ្លាំងពីពួកមនោនិយម និងតថនិយម ដែលមើលឃើញមនុស្សម្នាក់ថាជាប្រភេទសកល។ ជាងនេះទៀត ដោយហេតុថា ពួកមនោនិយម ឬតថនិយម មើលឃើញបុគ្គលថា ជាអ្នកស្រុកម្នាក់នៃពិភពដ៏មានន័យ និងដែលអាចពន្យល់បាននោះ ពួកអត្ថិភាពនិយម ជឿជាក់ថា ចក្រវាឡ មានភាពមិនខុសគ្នានឹងផែនការចំណង់ និងក្តីប្រាថ្នារបស់មនុស្ស។ អត្ថិភាពនិយម ផ្តោតអារម្មណ៍ទៅ លើបញ្ញត្តិនៃភាពភ័យខ្លាច និងអន្ទះសារជាខ្លាំង។ យើងម្នាក់ៗដឹងថា វាសនារបស់យើង គឺសេចក្តីស្លាប់ និងវត្តមានរបស់យើងក្នុងពិភពលោក គឺជារឿងបណ្តោះអាសន្ន។ ក្នុងន័យនៃការភ័យខ្លាច តាមទស្សនវិជ្ជានេះ មនុស្សម្នាក់ៗ ត្រូវតែធ្វើការជ្រើសរើសអំពីសេរីភាព និងទាសករ សេចក្តីស្រឡាញ់ និងស្អប់សន្តិភាព និងសង្រ្គាម។ នៅពេលដែលយើងធ្វើការសម្រេចចិត្ត នេះ យើងអនុវត្តសំណួរ តើវាធ្វើឱ្យមានភាពខុសគ្នាបែបណា ដែលថា ខ្ញុំនៅទីនេះ និងខ្ញុំ បានជ្រើសរើសធ្វើជាមនុស្សបែបណា?*

### គ-ការជ្រើសរើសការតាំងចិត្តដោយខ្លួនឯង

*យោងទៅតាមពួកអត្ថិភាពនិយម យើងត្រូវតែដោះស្រាយដោយជោគជ័យផងដែរជាមួយការគំរាមកំហែងជាប្រចាំ ដូចជា មនុស្សស្ថាប័ន និងភ្នាក់ងារ ដែលជាសេរីភាពជ្រើសរើសរបស់យើង។ ការឆ្លើយតបរបស់បុគ្គលម្នាក់ចំពោះជីវិត ធ្វុះបញ្ឆាំងច ម្ល៉ើយទៅនឹងសំណួរ តើខ្ញុំជ្រើសរើស ដើម្បីធ្វើជាមនុស្ស ដែលបានតាំងចិត្តដោយខ្លួនឯង ឬខ្ញុំជ្រើសរើស ដើម្បីកំណត់ន័យដោយអ្នកផ្សេង? ប៉ុន្តែ ពួកអត្ថិភាពនិយម ពិតជាបានមើលឃើញក្តីសង្ឃឹមនៅខាងក្រោយការប្រយុទ្ធ ដើម្បីក្តីសង្ឃឹម។ មនុស្សម្នាក់ៗ មានសក្តានុពល សម្រាប់ការស្រឡាញ់ ការបង្កើតច្នៃប្រឌិដ្ឋ និងការរស់នៅ។ មនុស្សម្នាក់ៗ អាចជ្រើសរើស ដើម្បីធ្វើជាមនុស្ស ដែលមានភាពត្រឹមត្រូវ មិនបង្ហាញឱ្យឃើញផ្ទាល់។ មនុស្សដែលមានភាពត្រឹមត្រូវ ដែលមានសេរីភាព និងយល់ដឹងនូវសេរីភាព ដឹងថា គ្រប់ការជ្រើសរើសស្ថិតក្នុងការពិត ដែលជាសកម្មភាពនៃការច្នៃប្រឌិដ្ឋតម្លៃដោយបុគ្គល[8]។*

---

[7] Gutek, *Philosophical and Ideological Voices in Education*, pp. 85-86.

[8] Maxine Greene, Landscapes of Learning (New York: Teachers College Press, 1978); and Van Cleve Morris, Existentialim in Education (New York: Harper and Row, 1986).

## ៥.២-សំណួរជាមូលដ្ឋាន

### ក-ការបង្កើតតម្លៃបុគ្គល

ពីព្រោះតែពួកអត្ថិភាពនិយម បានជៀសវាងដោយចេតនានូវប្រព័ន្ធកម្មនៃទស្សនវិជ្ជារបស់ពួកគេនោះ វាជារឿងលំបាក ដើម្បីធ្វើចំណាត់ថ្នាក់ស្ថានភាពបែបតក្កវិទ្យា វិទ្យាសាស្ត្រ សីលធម៌ ពុទ្ធិវិទ្យា បរមត្ថវិជ្ជា។ ដូចដែលបានអះអាងបញ្ជាក់រួចមកហើយ ពួកអត្ថិភាពនិយម ជឿជាក់ថា យើងអាចបង្កើតការកំណត់ន័យផ្ទាល់ ឬខ្លឹមសារផ្ទាល់ខ្លួន តាមការជ្រើសរើស ជាបុគ្គល ដែលយើងបង្កើត។ តាមពុទ្ធិវិទ្យា បុគ្គលជ្រើសរើសចំណេះដឹង ដែលគេចង់ទទួលបាន។ ពួកអត្ថិភាពនិយម ចាត់ទុកវិទ្យាសាស្ត្រសីលធម៌ ជារឿងសំខាន់បំផុត ពីព្រោះមនុស្សលោក បង្កើតតម្លៃផ្ទាល់ខ្លួនគេ តាមការជ្រើសរើស។

### ខ-ការដាស់ញាណនៃលក្ខខណ្ឌមនុស្ស

ពួកអត្ថិភាពនិយមដឹងថា យើងរស់នៅក្នុងពិភពនៃតថភាពរូបវន្ត ហើយយើងបានអភិវឌ្ឍចំណេះដឹងបែបវិទ្យាសាស្ត្រ និងមានប្រយោជន៍អំពីតថភាពទាំងនេះ។ ទោះជាយ៉ាងនេះក៏ដោយ ចំណុចដ៏សំខាន់បំផុតនៃជីវិតរបស់យើង មានលក្ខណៈផ្ទាល់ខ្លួន ហើយមិនមែនជាវិទ្យាសាស្ត្រទេ។ ដូច្នោះហើយពួកអត្ថិភាពនិយមជឿជាក់ថា ចំណេះ ដឹងអំពីលក្ខខណ្ឌមនុស្ស និងការជ្រើសរើសជាបុគ្គលដែលយើងបង្កើតនោះ គឺមានសារៈសំខាន់បំផុត ហើយគោលដៅសំខាន់បំផុតរបស់ការអប់រំ ត្រូវដាស់ញាណរបស់មនុស្ស ដើម្បីសេរីភាព ក្នុងការជ្រើសរើស និងដើម្បីបង្កើតន័យពីការយល់ដឹងផ្នែកអត្តៈ ដែលរួមចំណែកដល់ភាពត្រឹមត្រូវរបស់យើង។

### គ-ឱកាសតែមួយសម្រាប់មនុស្សទាំងអស់

ពួកអត្ថិភាពនិយមនិយាយថា នៅសាលារៀនបុគ្គលទាំងឡាយ គួរតែបន្តពិភាក្សាអំពីជីវិត និងការជ្រើសរើសផ្ទាល់ខ្លួន។ ព្រោះយើងទាំងអស់គ្នាស្ថិតក្នុងស្ថានភាពលំបាកដូចគ្នា និងលទ្ធភាពដូចគ្នានោះ យើងទាំងអស់គ្នា គួរតែមានឱកាសសិក្សាអប់រំ។ នៅសាលារៀន ទាំងគ្រូទាំងសិស្សគួរមានឱកាស ដើម្បីសួរសំណួរ ផ្តល់ចម្លើយ និងចូលរួមដល់ការសន្ទនា។

### ឃ-ការសួរសំណួរនិងការសន្ទនា និងកម្មវិធីសិក្សាតាមបែបអត្ថិភាពនិយម

គ្រូបង្រៀនតាមបែបអត្ថិភាពនិយម គួរលើកទឹកចិត្តសិស្សឱ្យគិតតាមបែបទស្សនវិជ្ជា សួរសំណួរ និងចូលរួមក្នុងការសន្ទនាអំពីអត្ថន័យនៃជីវិត សេចក្តីស្រឡាញ់ និងមរណភាព។ ចម្លើយចំពោះសំណួរទាំងនេះគួរតែមានលក្ខណៈជាបុគ្គល និងសត្យានុម័ត មិនមែនវាស់វែង តាមតេស្តស្តង់ដានោះទេ។ កម្មវិធីសិក្សាតាមបែបពួកអត្ថិភាពនិយម និងមានអ្វីដែលអាចនាំដល់ការសន្ទនាតាមបែបទស្សនវិជ្ជា។ ជាពិសេស មុខវិជ្ជាមានតម្លៃ ពិពណ៌នា

យ៉ាងជាក់លាក់ បុរស និងនារីជាបុគ្គល ក្នុងការជ្រើសរើស រាប់បញ្ចូលទាំងមុខវិជ្ជាផ្នែកកំណាព្យ សោកំណានិង ចិត្តរំភើប[9]។ អក្សរសិល្ប៍ និងជីវប្រវត្តិ មានសារៈសំខាន់សម្រាប់លាតត្រដាងលក្ខខណ្ឌបង្កើត ការជ្រើសរើស។ សិស្សគួរតែទស្សនា និងពិភាក្សាល្ខោន និងភាពយន្ត ដែលរៀបរាប់យ៉ាងជាក់លាក់នូវលក្ខខណ្ឌមនុស្ស និងការបង្កើតការសម្រេចចិត្តរបស់មនុស្ស។

**ខ-ការបង្ហាញពីអត្តដែលចាំបាច់**

ក្នុងការបន្ថែមទៅឱ្យមុខវិជ្ជាជីវវិទ្យា នាជសាស្ត្រ និងអក្សរសិល្ប៍នោះ សិស្សត្រូវតែបង្កើតបែបបទនៃការបង្ហាញអត្ត[10]។ ពួកគេគួរតែមានសេរីភាព ដើម្បីធ្វើការពិសោធជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយផ្នែកសិល្បៈ និងបង្កើតព្រឹត្តិការណ៍ រឿងល្ខោននូវចិត្តរំភើប សញ្ចេតនា និងការយល់ដឹង។ បច្ចេកវិទ្យាតាមបែបអប់រំ ដែលជួយដល់ការជ្រើសរើសបុគ្គល និងសេរីភាព អាចមានប្រយោជន៍ដល់ការអប់រំ។

ឧទាហរណ៍ សិស្ស អាចទទួលបានប្រយោជន៍ពីការបង្ហាញខ្លួនគេ តាមការប ង្កើតផលិតកម្មពហុការផ្សព្វផ្សាយ។ ការអនុវត្តបច្ចេកវិទ្យាដែលបង្កើតសភាពដូចគ្នាក្នុងការគិត និងក្នុងការទទួលបានព័ត៌មាន និងត្រូវបានគេយល់ដោយភាពសង្ស័យ។

**៥-៣-ការអនុវត្តសម្រាប់គ្រូបង្រៀនប្រចាំថ្នាក់នាពេលសព្វថ្ងៃ**

**ក-គ្រូបង្រៀន ត្រូវលើកទឹកចិត្តការយល់ដឹង**

ការបង្រៀនពីទស្សនវិស័យបែបអត្ថិភាពនិយម មិនមែនងាយស្រួលទេ ពីព្រោះគ្រូ មិនអាចបញ្ជាក់គោលដៅនិងវត្ថុបំណងជាមុន ដែលទាំងនេះ ត្រូវបានកំណត់ ដោយសិស្ស ម្នាក់ៗក្នុងនាមជាមនុស្សម្នាក់ៗ។ ជាងនេះទៀតការព្យាយាមធ្វើឱ្យសិស្សទទួលបានគោលដៅទាំងឡាយនោះ គ្រូបង្រៀនតាមអត្ថិភាពនិយម ស្វែងរកបង្កើតការយល់ដឹងពីសិស្សម្នាក់ៗ នៃការទទួលខុសត្រូវកម្រិតកំពូលសម្រាប់ការអប់រំ និងការកំណត់ន័យសេចក្ដីពីអត្តៈ។ ក្នុងការបង្កើតការយល់ដឹងនេះ គ្រូបង្រៀនលើកទឹកចិត្តសិស្ស ឱ្យពិនិត្យមើលការចាប់ផ្ដើមអនុវត្ត កម្លាំង និងស្ថានភាពដែលកំណត់សេរីភាពនៃការជ្រើសរើស ដោយមានបរិស្ថានសិក្សាទូលំទូលាយបែបនេះ ការបង្រៀន គឺជារឿងស្វ័យតម្រង់ទិស។

---

[9] Maxine Greene, The Dialectic of Freedom (New York: Teachers College Press, 1988)

[10] For an approach that uses narrative and dialogue to examine philosophical issues in education, see Carol Witherell and Nel Noddings, eds., *Stories Lives Tell: Narrative and Dialogue in Education* (New York: Teachers College Press, 1991).

### ខ-ស្តង់ដា និងការវាយតម្លៃស្តង់ដាផ្នែកខាងក្រៅ ធ្វើឱ្យការអប់រំបុគ្គលិកលក្ខណៈស្រុតចុះ

*ពួកអត្ថិភាពនិយម បានប្រឆាំងនឹងចលនាស្តង់ដានេះ ជាពិសេសការសង្កត់ធ្ងន់ទៅលើការធ្វើតេស្តតាមស្តង់ដា ដើម្បីវាស់វែងភាពជោគជ័យខាងការសិក្សា។ ចលនា ស្តង់ដាទាំងមូល គឺជានិន្នាការមួយ ដែលឃ្លាតឆ្ងាយពីឯកត្តភាព និងជម្រើស និងសេរីភាពរបស់បុគ្គល។ ការបង្រៀននៅតាមគ្រប់ថ្នាក់រៀន ត្រូវធ្វើតាមស្តង់ដាតែមួយ លុបបំបាត់ចោលនូវអត្តចរិតប្លែកៗ នៃការកំណត់ការអប់រំនីមួយៗ។*

### ៥-៤-សាលារៀនបែបអត្ថិភាពនិយម

### ក-Summerhill: គំរូមួយនៃសេរីភាព

*ទោះបីជាសាលារៀន* Summmerhill *របស់* A. S. Neill *នៅចក្រភពអង់គ្លេស ផ្តល់ឱ្យធ្វើចំណាត់ថ្នាក់ដ៏មានរបៀបរៀបរយ តាមទស្សនវិជ្ជាអប់រំក៏ដោយ ក៏វាបានផ្តល់នូវឧទាហរណ៍ពីប្រធានបទបែបអត្ថិភាពនិយមតាមបេសកកម្ម កម្មវិធីសិក្សា និងគោលវិធីចំពោះការបង្រៀន និងរៀន។* Neill *បានបង្កើតសាលារៀនរបស់គាត់ ជាបទពិសោធអប់រំតាមសេរីភាព ដើម្បីជ្រើសរើសអ្វី និងពេលណាដែលគេចង់សិក្សា។ នៅពេលដែលគេរួចផុតពីការរឹតបន្តឹង និងការហាមឃាត់ តាមបទបញ្ញត្តិពីខាងក្រៅនោះ* Neill *រកឃើញថា សិស្សពិតជាចង់សិក្សា ហើយចង់បន្តរបៀបសិក្សាផ្ទាល់ខ្លួនជាខ្លាំង[11]។*

### ខ-មេរៀនបែបអត្ថិភាពនិយម

*អក្សរសាស្ត្រ វិនោទសាស្ត្រ និងភាពយន្តមានឥទ្ធិពលជាពិសេសខាងការបង្រៀន បែបអត្ថិភាពនិយម។ គំរូមួយនៃការបង្រៀនបែបជាថ្នាក់រៀនប្រវត្តិវិទ្យា នៅវិទ្យាល័យ ដែលកំពុងសិក្សាហាយនភាព* (Holocaust) *គឺរបបប្រល័យពូជសាសន៍នៃជនជាតិជ្វីហ្វដែលមានចំនួន៦លាននាក់ នៅទ្វីបអឺរ៉ុបក្នុងអំឡុង ពេលសង្គ្រាមលោកលើកទី២។ សិស្សក្នុងថ្នាក់រៀន ទស្សនាភាពយន្តរបស់* Steven Spilberg *រឿង* Schindler's List *ដែលក្នុងនោះ ចាងហ្វាងភាពយន្តដ៏ធំឈ្មោះ* Oscar Schindler *ដែលជាអ្នកទទួលបានប្រយោជន៍ជាលើកដំបូង ពីពលកម្មដោយបង្ខំនៃមនុស្ស ដែលរស់នៅកន្លែងប្រមូលផ្តុំឃុំឃាំងជនជាតិជ្វីហ្វនោះ បានបង្កើតការសម្រេចចិត្តប្រកបដោយញាណ ដើម្បីសង្គ្រោះកម្មករពីសេចក្តីស្លាប់ នៅក្នុងបន្ទប់ឃុំឃាំងឧស្ម័ន ឬសាំង ពួកណាស៊ីស* (The Nazi gas chambers)*។ បន្ទាប់មក សិស្សក្នុងថ្នាក់រៀន សង្កេតស្ថានភាពសីលធម៌នៃមនុស្សម្នាក់គឺ* Schindler *និងការជ្រើសរើស ដែលគាត់បានបង្កើតក្នុងពិភពដ៏សែនព្រៃផ្សៃ និងឥតសមហេតុផល។*

---

[11] Neill described his approach to education in A. S. Summerhill: *A Radical Approach to Child Rearing* (New York: Hart Publishing, 1960); also see his autobiography, *Neill! Neill! Orange Peel!*(New York: Hart publishing, 1972). The Wed site for Neill's Summerhill School is **http:www.summerhillschool.co.uk./pages/index.html**

## សន្និដ្ឋាន

ទ្រឹស្ដីប្រតិបត្តិនិយម ដែលទទួលបានពីការគ្រទពីលោក Childs, Dewey, James, និង Pierce ជាទ្រឹស្ដីសំខាន់មួយ នៅក្នុងទស្សនវិជ្ជាត្រូវបានគេយកទៅប្រតិបត្តិក្នុងវិស័យអប់រំ ដើម្បីរៀបចំការបង្រៀន ដើម្បីដោះស្រាយបញ្ហា ដោយយោងទៅតាមវិធីវិទ្យាសាស្ត្រ ។

ទ្រឹស្ដីអត្ថិភាពនិយម ដែលទទួលបានពីការគាំទ្រពីលោក Sartre, Marcel, Morris, និង Soderquis ជាទ្រឹស្ដីសំខាន់មួយ នៅក្នុងទស្សនវិជ្ជា ដែលត្រូវបានគេយកទៅប្រតិបត្តិក្នុងវិស័យអប់រំ ដើម្បីរៀបចំការសន្ទនានៅក្នុងថ្នាក់រៀន ក្នុងការភ្ជាប់ដល់ការយល់ដឹង ដែលគេអាចបង្កើតស្វ័យបញ្ញត្តិ តាមជម្រើសដ៏សំខាន់ចាំបាច់។

## ឯកសារយោង


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.
3- Jonh Dewey, *Experience and Education: The 60 th Anniversary Edition*, West Lafayette, Ind.: Kappa Delta Pi, 1998.
4- Lawrence J. Dennis et al.: *Thematic Connections on Educational Topics*, *Educational Theory*, Summer-Fall 1998.
5- Christine L. McCarthy and Evelyn Sears, *Deweyan Pragmatism and the Quest for True Self, Educational Theory*, Spring 2000.
6- Stephen M. Fishman and Lucille McCarthy, Jonh Dewey, *the Challenge of Classroom Practice,* New York: Teachers Colloge Press, 1998.
7- William R. Caspary, *Judgements of Value in Jonh Dewey's Theory of Ethics*, *Educational Theory,* Spring 1990.
8- Robert B. Westbrook, *Jonh Dewey and American Democracy*, Ithaca, N.Y.: Cornell University Press, 1991.
9- Larry A. Hickman, *Philosophical Tools for Technological Culture*, Bloomington: Indiana University Press, 2001.
10- Maxine Greene, *Landscapes of Learning*, New York: Teachers College Press, 1978.
11- Van Cleve Morris, *Existentialim in Education*, New York: Harper and Row, 1986.
12- Maxine Greene, *The Dialectic of Freedom*. New York: Teachers College Press, 1988.
13- Carol Witherell and Nel Noddings, *Stories Lives Tell: Narrative and Dialogue in Education*, New York: Teachers College Press, 1991.
14- A. S. Summerhill: *A Radical Approach to Child Rearing*. New York: Hart Publishing, 1960.

# ប្រភពនៃទស្សនវិជ្ជាអប់រំៈ មនោនិយម និងតថនិយម

*ដោយៈ* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

**១-វាក្យស័ព្ទវិទ្យាពិសេស**

*គ្រប់វិស័យនៃការស្រាវជ្រាវសុទ្ធតែមានវាក្យសព្ទវិទ្យាពិសេស។ ទស្សនវិជ្ជាអប់រំ បានប្រើប្រាស់វាក្យសព្ទមូលដ្ឋាន ដូចជាបរមត្ថវិទ្យា* (Metaphysics) *ពុទ្ធិវិទ្យា* (Epi- stemology) *តម្លៃវិទ្យា* (Axiology) *និងតក្កវិជ្ជា* (Logic)។

**ក-តថភាព និងអត្ថិភាព**

*បរមត្ថវិទ្យា សិក្សាអំពីធម្មជាតិនៃតថភាពកម្រិតខ្ពស់បំផុត។ អ្វីពិត និងអ្វីមិនពិត? តើមានវិស័យអត្ថិភាពចិត្តដោយឡែកពីពិភពសម្ភារៈឬទេ?*

*ឧទាហរណ៍ ពួកមនោនិយម មើលឃើញតថភាពជាបឋម ក្នុងវាក្យសព្ទខាងផ្លូវចិត្តអរូបី ឬមិនមែនជាសម្ភារៈ។ ពួកតថនិយម មើលឃើញវាថាជាលំដាប់លំដោយជាសត្យានុម័ត ដែលកើតមានដោយឯករាជ្យពីមនុស្សជាតិ។ ការបង្រៀនជាច្រើន នៅតាមសាលារៀន តំណាងឱ្យការខិតខំប្រឹងប្រែងនៃអ្នករៀបចំកម្មវិធីសិក្សា គ្រូបង្រៀន និងអ្នកនិពន្ធសៀវភៅ ដើម្បីពណ៌នាតថភាពទៅដល់សិស្ស។ ក្នុងនាមជាគ្រូបង្រៀន អ្នកនឹងដឹងថា សៀវភៅខុសៗគ្នា មានការបកស្រាយ តាមបែបប្រកួតប្រជែងពីតថភាព ឬយ៉ាងហោចណាស់ វាក៏ជាការគូសបញ្ជាក់ភាពខុសគ្នាដែរ។*

**ខ-ពុទ្ធិវិទ្យា**

*ការចេះដឹង និងទ្រឹស្តីនៃចំណេះដឹង ដែលយកចិត្តទុកដាក់ពីចំណេះដឹង និងការយល់ដឹងនោះជះឥទ្ធិលដល់វិធីបង្រៀន និងរៀន។វាលើកឡើងនូវសំណួរទាំងឡាយ ដូចជា តើយើងពឹងផ្អែកចំណេះដឹងពីពិភពលោក និងការយល់ដឹងពីសច្ចភាពទៅលើអ្វី? តើចំណេះដឹងរបស់យើង បានទទួលពីការបញ្ចេញឱ្យដឹងនៃអាទិទេពពីគំនិតដែលមិនទាន់បង្ហាញឱ្យឃើញ នៅក្នុងចិត្តរបស់យើងផ្ទាល់ពី*

កស្តុតាង តាមបែបសង្កេតពិ សោធ ឬពីអ្វីមួយផ្សេងទៀតឬទេ? ជាថ្មីម្តងទៀត ទស្សនវិជ្ជាផ្សេងៗគ្នា យល់ឃើញគំ និតដែលទាក់ទងនឹងការចេះដឹង និងទ្រឹស្តីនៃចំណេះដឹងខុសៗគ្នា។

គ្រូបង្រៀន ដែលជឿជាក់ថា គំនិតមនុស្ស គួរតែអនុលោមទៅតាមរចនាសម្ព័ន្ធនៃតថភាព តាមលំដាប់លំដោយ នឹងគូសប ញ្ជាក់ តាមលំដាប់លំដោយ និងការបង្រៀននៃមុខវិជ្ជា ទៅតាមលំដាប់លំដោយ។ ផ្ទុយទៅវិញ គ្រូដែលជឿជាក់ថា លំនាំ (របៀបដែលយើងដឹង) វាមានសារៈសំខាន់ជាងខ្លឹមសារ (អ្វីដែលយើងដឹង) នឹងសង្កត់ន័យដល់ការសង្កេត ឬការដោះស្រាយបញ្ហា។

**គ-អ្វីទៅដែលមានតម្លៃ?**

**តម្លៃវិទ្យា**ដែលបានរៀបរាប់ពីតម្លៃ ត្រូវបានគេបែងចែកទៅជាសីលវិជ្ជា និងសោ ភណវិទ្យា (Aesthetics)។

**សីលវិជ្ជា** សិក្សាអំពីតម្លៃខាងសីលធម៌ និងក្បួនច្បាប់នៃឥរិយាបថដ៏ត្រឹមត្រូវ។ សោភ័ណវិទ្យា និយាយដល់តម្លៃសោភណ ភាព(Beauty) និងសិល្បៈ។ ថាតើសាលារៀនមួយ បង្រៀនជាក់លាក់នូវតម្លៃ ឬមិននោះ គ្រូបង្រៀន ក៏ដូចជាឪពុកម្តាយ និងសង្គមក្នុងន័យជាទូទៅបង្ហាញឱ្យឃើញត ម្លៃជាក់លាក់ តាមការផ្តល់រង្វាន់ ឬការដាក់ទណ្ឌកម្មដល់អាកប្បកិរិយា ដោយផ្អែកទៅលើថា តើវាអនុលោម ទៅតាមគំនិតរបស់ពួកគេ ពីអ្វីដែលត្រឹមត្រូវ ល្អ និងល្អស្អាត។ ជាងនេះទៀត បរិយាកាសសាលារៀនទាំង មូលបង្ហាញតម្លៃសហគមន៍ ដែលមានការអប់រំ។

**ឃ-ការគិតតាមអនុមានញែក និងអនុមានរួម**

តក្កវិទ្យា ដែលពាក់ព័ន្ធនឹងការគិតដ៏រឹងមាំ និងត្រឹមត្រូវនោះ ពិនិត្យមើលក្បួនច្បាប់នៃការបង្កើត គំនិតពីការពិត ដែលជួយយើង ធ្វើពង្រាងដ៏ត្រឹមត្រូវនូវសំណើ និងការអះអាង។ តក្កវិទ្យាអនុមាណញែក (Deductive logic) ចេញពីការអះអាងជាទូទៅ ទៅរកការអនុវត្ត និងឧទាហរណ៍ពិសេស។ តក្កវិទ្យាអនុមានរួម (Inductive logic) ចេញពីឧទាហរណ៍ពិសេស ទៅរកប្រធានបទទូទៅនីយកម្ម ដែលជាការស្ទង់មើល ដើម្បីការផ្ទៀងផ្ទាត់បន្ថែម។

កម្មវិធីសិក្សា និងការបង្រៀន ត្រូវបានរៀបចំតាមបញ្ញត្តិនៃតក្កវិជ្ជា។ តើអ្វីមួយ នៅក្នុងមុខវិជ្ជាតម្រូវពីរបៀប ដែលមេរៀន គួរតែត្រូវបានគេរៀបចំ និងបង្ហាញសិស្ស (គោលវិធីអនុមានញែក)? ឬគ្រូបង្រៀន គួរតែទទួលយកសញ្ញាបង្ហាញប្រាប់ផ្លូវពីចំ ណូលចិត្ត ភាពត្រៀមខ្លួនជាស្រេច និងបទពិសោធរបស់សិស្សក្នុងការ

*សម្រេចចិត្តពីរបៀបបង្ហាញការបង្រៀន (គោលវិធីអនុមានរួម)?*

*ជាមួយនឹងប្រវត្តិវាក្យសព្ទវិទ្យា យើងអាចពិនិត្យមើលទស្សនវិជ្ជា និងទ្រឹស្តីផ្សេងៗគ្នា។ ក្រោយពេលពិភាក្សាបញ្ញត្តិគន្លឹះនីមួយៗ យើងអាចមើលឃើញពីរបៀបដែលវាឆ្លើយតបទៅនឹងសំណួរមូលដ្ឋាននៅដើមនៃជំពូក និងជួយគ្រូបង្រៀនម្នាក់ជួយបង្កើតទស្សនវិជ្ជាអប់រំ។*

**ទំនាក់ទំនងទស្សនវិជ្ជា ទៅនឹងការអប់រំការបែងចែកមុខវិជ្ជារងនៃទស្សនវិជ្ជា និងភាពពាក់ព័ន្ធនឹងការអប់រំ**

-**បរមត្ថវិទ្យា** *អ្វីជាតថៈ?*

**ចំណេះដឹងដ៏មានតម្លៃបំផុត** *កម្មវិធីសិក្សា*

-**ពុទ្ធិវិទ្យា** *តើចំណេះដឹងពឹងផ្អែកទៅលើអ្វី?*

**របៀបដែលយើងបង្រៀននិងរៀន** *វិធីបង្រៀន*

-**តម្លៃវិទ្យា**

*អ្វីជាសីលធម៌និងភាពត្រឹមត្រូវ? អ្វីជាសោភណវិទ្យា និងសិល្បៈ?*

**ការអប់រំ** *អាកប្បកិរិយា អត្តចរិត សេចក្តីគួរសម និងការបង្ហាញអារម្មណ៍តាមទឹកមុខ*

-**តក្កវិជ្ជា** *យើង អាចធ្វើវិចារយ៉ាងដូចម្តេច?*

**ការអប់រំ** *របៀបដែលយើងរៀបចំ និងធ្វើរច នាសម្ព័ន្ធមុខវិជ្ជា មេរៀន។*

**២-មនោនិយម**

**អ្នកផ្តើមគំនិតមនោនិយមគួរឱ្យកត់សម្គាល់**

*មនោនិយម ដែលជាទស្សនវិជ្ជាតាមប្រពៃណី មានចំណាស់ជាងគេមួយនោះ និ យាយយោងដល់* **ប្លាតុង** *ដែលបានអភិវឌ្ឍគោលការណ៍មនោនិយម ក្នុងក្រុងអាថែនបុ រាណ។ នៅប្រទេសអាល្លឺម៉ង់* Georg W. F. Hegel *បានបង្កើតទស្សនៈពិភពលោកយ៉ាងទូលំទូលាយ ដោយផ្អែកទៅលើមនោនិយម ហើយនៅសហរដ្ឋអាម៉េរិក* Ralph Waldo Emerson *និង* Henry David Thoreau *បានអភិវឌ្ឍមនោនិយមច្រើនបែបផ្សេងៗគ្នា ដែលគេបានស្គាល់ថាជាអតិសេដ្ឋនិយម* (Transcen- dentalism)។

Friedrich Froebel *ពឹងផ្អែកទ្រឹស្តីអប់រំមត្តេយ្យរបស់គាត់ទៅលើមនោនិយម*[1]។

*សាសនានៅអាស៊ី ដូចជាព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ក៏បានពឹងផ្អែកផងដែរទៅទស្សនវិស័យខាងស្មារតី ដោយបានផ្សារភ្ជាប់ទៅនឹងមនោនិយម។*

**២-១-បញ្ញត្តិគន្លឹះ**

**ក-សច្ចភាពអនន្ត សកល**

---

[1] Gerald L. Gutek, *Philosophical and Ideological Voices in Education* (Boston: Allyn and Bacon, 2004), pp.15-27.

**បរមត្ថវិទ្យា** ពួកមនោនិយម ជឿជាក់ថា មានតែចិត្ត ឬស្មារតី ដែលជាតថភាពកម្រិតកំពូល។ ពួកគេយល់ឃើញថា ចក្រវាឡ ដែលបញ្ជាក់បង្ហាញនៃបញ្ញា និងឆន្ទៈ ដែលបានធ្វើទូទៅកម្មកម្រិតខ្ពស់ គឺជាចិត្តសកល។ ខ្លឹមសារខាងស្មារតីរបស់បុគ្គល ឬព្រលឹង គឺជាទិដ្ឋភាពអចិន្ត្រៃយ៍នៃធម្មជាតិ មនុស្សដែលផ្តល់ភាពក្លៀវក្លា និងថាមភាព។ ពិភពគំនិត គឺអនន្ត អចិន្ត្រៃយ៍ ទៀងទាត់ និងមានលំដាប់លំដោយ។ សច្ចភាព និងត ម្លៃ គឺមានភាពដាច់ខាត និងសកល។

**ខ-សារព័នសាកល និងកំណែប្រែថ្មីតាមខុទ្ទកភាព**

ពួកមនោនិយម ដូចជាពួកអតិសេដ្ឋនិយម ប្រើប្រាស់សារព័នសាកលនិងកំណែប្រែថ្មីតាមខុទ្ទកភាព ដើម្បីពន្យល់កំណែប្រែថ្មីនៃសច្ចភាព។

**សារព័នសាកល** និយាយយោងទៅដល់ចិត្តសាកល បុព្វហេតុបឋម អ្នកបង្កើតលោក ឬអាទិទេព។ ដោយមិនបានគិតដល់ឈ្មោះពិសេស ដែលបានប្រើនោះ ចិត្តដែលទាក់ទងទៅនឹងសារព័នសាកល ជាអត្ថិភាពទាំងស្រុង ឬទាំងមូល។ វាគឺមានតែមួយ រាប់បញ្ចូលទាំងអស់ និងអត្តពេញលេញ ដែលអត្តទាំងអស់ជាផ្នែកតូចជាង គឺជាផ្នែកទាំងឡាយ។ ចិត្តសាកលសារព័នសាកល គឺជាការគិត និងការវាយតម្លៃជាបន្តបន្ទាប់ ឬឥតដាច់។

សារព័នសកល គឺជាផ្នែកដែលមានដែនកំណត់មួយនៃផ្នែកទាំងមូល ជាបុគ្គល និងអត្ត ដែលតូចជាង។ ប៉ុន្តែ កំណែប្រែថ្មីតាមខុទ្ទកភាព មានសារជាតុខាងស្មារតីដូចគ្នាទៅនឹងសារព័នសាកល។

**គ-ចំណេះដឹង ដែលមិនទាន់បង្ហាញឱ្យឃើញ**

**ពុទ្ធិវិទ្យា** មនោនិយម បានសង្កត់ធ្ងន់លើការទទួលបានចំណេះដឹង ឬការចងចាំនូវបទពិសោធនៃគំនិត ដែលមិនទាន់ប ញ្ចេញឱ្យឃើញ គឺផ្នែកទាំងឡាយ ដែលបានបង្ហាញ ប៉ុន្តែ មិនទាន់ជាញាណនៅក្នុងចិត្ត។ គំនិតមានពីមុនទាំងនេះ ពាក់ព័ន្ធដល់ចំណេះដឹង ដែលបានកើតឡើងពីពេលមុន និងឯករាជ្យពីបទពិសោធរបស់មនុស្ស អំពីពួកគេ។ តាមរយៈអត្តាពិគ្រោះ បុគ្គល បានពិនិត្យមើលចិត្តផ្ទាល់ខ្លួន ហើយរកឃើញការត្រាប់តាមនៃចិត្តសារព័នសាកល។ ការបញ្ចេញសមត្ថភាពរបស់គ្រូ ដើម្បីនាំយកចិត្ត ដែលមិនទាន់បង្ហាញឱ្យឃើញទៅជាញាណ។ ហេតុដូច្នោះហើយ ការអប់រំ ជួយឱ្យសិស្ស បានឈានដល់ទស្សនវិស័យ នៃចក្រវាឡ

ប្រកបដោយឯកភាវូបនីយកម្ម ទូ ទៅ និង ទូលំទូលាយ[2]។

**ឃ-ឋានានុក្រមនៃមុខវិជ្ជា**

គ្រូបង្រៀនបែបមនោនិយម ពេញ ចិត្តកម្មវិធីសិក្សាតាមឋានានុក្រមដាង ដោយបានពឹងផ្អែកលើមុខវិជ្ជា ឬបញ្ហាកម្ម វត្ថុមុខវិជ្ជា តាមបែបប្រពៃណី។ នៅផ្នែក កំពូលគេនៃឋានានុក្រម ជាមុខវិជ្ជាទូទៅ បំផុត គឺទស្សនវិជ្ជា និងសាសនវិជ្ជា។ មុខ វិជ្ជាអរូបី និងទូទៅទាំងនេះ មានលក្ខណៈ លុបទៅលើដែនកំណត់នៃពេលវេលា ទី កន្លែងនិងកាលៈទេសៈ និងវាផ្លាស់ប្ដូរទៅ តាមស្ថានភាពដ៏ទូលំទូលាយ។ គណិ តវិទ្យា ក៏មានតម្លៃផងដែរ ពីព្រោះវាបណ្ដុះ ថាមពល ដើម្បីដោះស្រាយជាមួយការគិត អរូបី។ ប្រវត្តិវិទ្យា និងអក្សរសិល្ប៍ មាន កម្រិតខ្ពស់ ដែលជាប្រភពនៃគំរូទាំងឡាយ ខាងវប្បធម៌ និងសីលធម៌។ ផ្នែកទាបបន្តិច ក្នុងកម្មវិធីសិក្សានោះ គឺវិទ្យាសាស្ត្រខាង រាងកាយ និងធម្មជាតិ បញ្ជាក់នូវទំនាក់ ទំនងពិសេសខាងហេតុផល។ ភាសា មាន សារៈសំខាន់ ពីព្រោះវាមានឧបករណ៍ ចាំបាច់ផងដែរ នៅគ្រប់កម្រិតទាំងអស់នៃ ការសិក្សា។ សម្រាប់ពួកមនោនិយម កម្រិត នៃចំណេះដឹងខ្ពស់បំផុត ទទួលស្គាល់នូវទំ នាក់ទំនង ក្នុងចំណោមកម្មវត្ថុមុខវិជ្ជាទាំង នេះ និងធ្វើសមាហរណកម្មវា។

**ខ-តម្លៃដែលនៅស្ថិតស្ថេរ**

**តម្លៃវិទ្យា** ដោយសារតែពួកមនោ និយម មើលឃើញចក្រវាឡក្នុងលក្ខខណ្ឌ អនន្ត និងសាកលនោះ គេបានបញ្ញត្តតម្លៃ ដែលមិនអាចផ្លាស់ប្ដូរ និងអាចអនុវត្តបាន ចំពោះមនុស្សទាំងអស់។ អាកប្បកិរិយា ខាងសីលវិជ្ជា ធ្វុះបញ្ចាំងនូវចំណេះដឹង ដែលស្ថិតស្ថេរ និងតម្លៃនៃវប្បធម៌មនុស្ស។ ទស្សនវិជ្ជា សាសនវិទ្យា ប្រវត្តិវិទ្យា អក្សរ សិល្ប៍ និងសិល្បៈ ជាប្រភពដ៏សម្បូរបែប សម្រាប់ផ្ទេរមរតកនៃតម្លៃនេះ។ ការអប់រំ បែបនេះ ទាមទារថា សិស្សជួបប្រទះគំរូដ៏ មានតម្លៃ ជាពិសេសស្នាដៃ ដែលបានស្ថិត ស្ថេរក្នុងអំឡុងពេលមួយ។

**ច-ភាពមិនផ្លាស់ប្ដូរបែបតក្ក វិទ្យា**

**តក្កវិទ្យា** សម្រាប់ពួកមនោនិយម តក្កវិទ្យា ពឹងផ្អែកទៅលើទំនាក់ទំនងពី ភាពពេញលេញ ទៅជាផ្នែកៗ។ ផ្នែកតូច ដែលជាគំនិត ឬជាគោលការណ៍ពិសេស នោះ គឺក្លាយមកពី និងយល់ស្រប ជាមួយ ផ្នែកទាំង មូលដែលមានលក្ខណៈទូទៅជា ង។

---

[2] Gerald L. Gutek, *Philosophical and Ideological Perspectives on Education,* 2nd ed. (Boston: Allyn and Bacon, 19997), pp.13-25.

គ្រូបង្រៀនបែបពួកមនោនិយម គួរតែរៀបចំមេរៀន ដែលមានជាបន្តបន្ទាប់នូវការរៀបចំបែបតក្កវិទ្យាអនុមានញែក ដែលសង្កត់ធ្ងន់នូវគោលការណ៍ឬក្បួនច្បាប់ទូទៅ និងបន្ទាប់មកទាញនូវការពន្យល់ជាក់លាក់ជាងសម្រាប់ពួកគេ។ ជាឧទាហរណ៍ គ្រូ បង្រៀនបែបពួកមនោនិយម គួរតែយកមកប្រើប្រាស់បញ្ញត្តិជាទូទៅនៃភាពអហិង្សា មុនពេលពិភាក្សាផលវិបាកនៃការសម្លុត ឬធ្វើបាបមិត្តរួមថ្នាក់របស់ពួកគេ(Bullying one's classmates) ។

**២-២-សំណួរជាមូលដ្ឋាន**

**ក-ចំណេះដឹងនៃគំនិតសាកល**

ប្រសិនបើអ្នក សួរទៅគ្រូបែបមនោនិយម អ្វីទៅជាចំណេះដឹង? ពួកគេនឹងឆ្លើយថា ចំណេះដឹង មានការពាក់ព័ន្ធនឹងគោលការណ៍ខាងស្មារតី ដែលបង្កើតបានជាមូលដ្ឋាននៃតថភាព។ ចំណេះដឹងនៃតថភាពនេះ មានទម្រង់ជាគំនិត។ ប្រសិនបើចំណេះដឹង និយាយអំពីគំនិតសកលនោះ ដូច្នេះ ការអប់រំ ជាលំនាំនៃការនាំយកគំនិតខាងបញ្ញាទៅដល់ញាណរបស់សិស្ស។

**ខ-ការសិក្សាអប់រំ៖ ការស្វែងរកសច្ចភាពខាងបញ្ញា**

ប្រសិនបើអ្នកសួរទៅគ្រូមនោនិយមបន្ថែមទៀត អ្វីជាការសិក្សាអប់រំ? គាត់នឹងនិយាយថា សាលារៀន ជាស្ថាប័នមួយ ដែលសិស្សស្រាវជ្រាវរក និងបន្តរកសច្ចភាព។ វាជាស្ថាប័នខាងបញ្ញាដែលគ្រូ និងសិស្ស ស្វែងរកសំណួរដែល Socrates និង Plato បានសួរថា លើកដំបូងថា អ្វីជាសច្ចភាព? អ្វីជាសោភណភាព? អ្វីជាជីវិតល្អ? ចម្លើយទាំងនេះ មានវត្ត មាន ប៉ុន្តែត្រូវបានលាក់កំបាំងក្នុងចិត្តរបស់យើងនិងយើងត្រូវតែចុះបញ្ចាំងយ៉ាងជ្រាលជ្រៅ ដើម្បីនាំពួកគេ ទៅដល់ញាណរបស់ពួកគេ។ យើង មិនគួរអនុញ្ញាតអ្វីទាំងអស់ ដើម្បីធ្វើឱ្យយើងខ្វល់ពីការតាមរកសច្ចភាពខាងបញ្ញា។

អ្នកណា គួរតែទៅសាលារៀន? ពួកមនោនិយម និយាយថា មនុស្សទាំងអស់គ្នា។ មិនមែនសិស្សទាំងអស់ មានសម្បទាខាងប ញ្ញាដូចគ្នានោះទេ ប៉ុន្តែ មនុស្សទាំងអស់ ត្រូវតែបណ្តុះចិត្តរបស់ខ្លួន ទៅដល់ដែនកំណត់នៃសមត្ថភាពរបស់គេ។ សិស្សដែលមានអំ ណោយផលពីធម្មជាតិ ត្រូវការសមត្ថភាពខាងបញ្ញាខ្ពស់បំផុត ដែលគ្រូអាចផ្តល់ឱ្យ។**គ-វិធីសូក្រាត**

តើយើង គួរបង្រៀនយ៉ាងដូចម្តេច? ពួកមនោនិយម គួរតែនិយាយថា ការគិត និងការសិក្សា ជាឈ្មោះ សម្រាប់ដំណើរការនៃការនាំយកគំនិតទៅដល់ញាណ។ មធ្យោ បាយដ៏មានប្រសិទ្ធភាពមួយនៃការអនុវត្តបែបនេះ គឺវិធីតាមបែបសូក្រាត ដែលក្នុងនោះ គ្រូបង្រៀន ក្រោចការ

យល់ដឹងនៃគំនិតរបស់សិស្សដោយការសួរសំណួរនាំមុខ។ ប្រការដ៏សំខាន់មួយផ្សេងទៀតនៃវិធីសាស្ត្រពួកមនោនិយម គឺការធ្វើជាគំរូ។ គ្រូបង្រៀនគួរតែធ្វើជាគំរូដ៏មានតម្លៃដល់ការត្រាប់តាមរបស់សិស្ស គឺគាត់គួរតែមានចំណេះដឹងទូលំទូលាយពីមរតកវប្បធម៌ និងដឹកនាំជីវិតតាមអនុករណ៍ (Examplary lives)។

**ឃ-ស្តង់ដា និងការវាយតម្លៃ**

**ស្តង់ដាកម្រិតខ្ពស់** ពួកមនោនិយម ចង់ការពារគុណភាពនៃការអប់រំ តាមការរក្សាស្តង់ដាបញ្ញាកម្រិតខ្ពស់ ហើយប្រឆាំងនឹងទំនោរចំពោះភាពបន្ធូរ។ ឧទាហរណ៍ នៅក្នុងស្នាដៃសាធារណរដ្ឋរបស់ប្លាតុង (Plato's Republic) ស្តង់ដាបញ្ញាគឺមានកម្រិតខ្ពស់ខ្លាំងរហូតដល់មានតែមនុស្សដែលមានអំណោយផលពីកំណើតតិចតួចប៉ុណ្ណោះ បានចូលចំណាត់ថ្នាក់ជាវរជនដឹកនាំនៃអធិរាជទស្សនវិទូ។ ពួកមនោនិយម នាសម័យបច្ចុប្បន្ននេះ មិនមានការលូតលាស់ខ្លាំងណាស់ណាទេ ប៉ុន្តែ គោលដៅអប់រំរបស់ពួកគេ រាប់បញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពខាងបញ្ញា ហើយជាទូទៅ ពួកគេទទួលយកការពិត ដែលថា មិនមែនគ្រប់សិស្សទាំងអស់ នឹងបន្តដល់ដំណាក់កាលខ្ពស់បំផុតនៃការអប់រំទេ។

ទោះបីជាពួកមនោនិយម មិនអាចមានទស្សនៈលទ្ធផលតេស្តតាមស្តង់ដាដូច ដែលរង្វាស់នៃការវាយតម្លៃស្នាដៃសិក្សានោះ ពួកគេគួរតែគាំទ្រជាទូទៅនូវចលនា ស្តង់ដាក្នុងការអប់រំ។ សម្រាប់ពួកគេ ស្តង់ដាខ្ពស់ ផ្តល់ក្តីសង្ឃឹមខ្ពស់ ទាំងគ្រូ ទាំងសិស្ស។

**២-៣-ការអនុវត្តសម្រាប់គ្រូបង្រៀនក្នុងថ្នាក់រៀននាពេលបច្ចុប្បន្ន**

**ក-ការអភិវឌ្ឍបញ្ញា មិនមែនការបណ្តុះបណ្តាលវិជ្ជាជីវៈ**

ដោយបដិសេធវិជ្ជាជីវៈនិយម ដែលតែងតែបង្កើតតម្លៃ នៅក្នុងសង្គម និងការអប់រំសហសម័យនោះ មនោនិយម ស្វែងរកការបង្កើតសាលារៀន ដែលជាមជ្ឈមណ្ឌលនៃការបង្រៀន និងការរៀនប្រកប ដោយបញ្ញា។ វាមើលឃើញថា គ្រូបង្រៀនជាភ្នាក់ងារដ៏សំខាន់ក្នុងការដឹកនាំសិស្សឱ្យដឹងពីសក្តានុពលបញ្ញាពេញលេញបំផុតរបស់ពួកគេ និងវាលើកទឹកចិត្តគ្រូបង្រៀន និងសិស្សរបស់ពួកគេឱ្យជួបប្រទះនិងពេញចិត្តចំពោះសមិទ្ធផលដ៏ល្អបំផុត និងយូរអង្វែងបំផុតនៃវប្បធម៌។ គ្រូបង្រៀនណែនាំ សិស្សឱ្យស្គាល់សិល្បៈបុរាណ ស្នាដៃសិល្បៈអក្សរសិល្ប៍និងតន្ត្រីដ៏អស្ចារ្យ និងយូរអង្វែង ដើម្បីឱ្យពួកគេទទួលបានបទពិសោធន៍ និងចែករំលែក

នៅក្នុងតម្លៃវប្បធម៌ដែលស្នាដៃទាំងនេះ បង្ហាញ។

ទោះបីបច្ចេកវិទ្យា អាចផ្ទេរឱ្យសិស្សនូវស្នាដៃអក្សរសិល្ប៍ និងសិល្បៈដ៏អស្ចារ្យក៏ដោយ ក៏ពួកមនោនិយម ទទួចថា បច្ចេកវិទ្យា ប្រើប្រាស់ជាមធ្យោបាយមួយនៃការអប់រំ ជាជាងគោលបំណងមួយ។ ខ្លឹមសារ មានសារៈសំខាន់បំផុត មិនមែនឧបករណ៍ខាងបច្ចេកទេស ដែលបង្ហាញឱ្យឃើញវានោះទេ។

**ខ-មេរៀនតាមពួកមនោនិយម**

តើគ្រូបង្រៀនម្នាក់ អាចប្រើប្រាស់ម នោនិយមក្នុងការអភិវឌ្ឍមេរៀន? គ្រូបង្រៀនសិក្សាសង្គមថ្នាក់ទី៥ អាចពន្យល់ពីថាមពលនៃគំនិត និងច្បាប់ក្រមសីលធម៌កម្រិតខ្ពស់ តាមខ្លឹមសារមេរៀនពីជីវិត និងឥទ្ធិពលខាងសីលធម៌របស់លោក Mohandas Gandhi ដែលជាបិតា នៃឯករាជ្យភាពរបស់ឥណ្ឌា។ សិស្ស នឹងសិក្សាជីវប្រវត្តិរបស់Gandhi ហើយនិងផ្តោះបញ្ចាំងទៅលើគោលការណ៍នៃការជំទាស់ ដោយអហិង្សាប្រឆាំងនឹងអយុត្តិធម៌ ដែលបាននាំឱ្យចលនារបស់គាត់ ប្រឆាំងនឹងពូជសាសន៍និយមក្នុងទ្វីបអាហ្វ្រិកខាងត្បូង និងអាណានិគមនិយមអង់គ្លេស នៅប្រទេសឥណ្ឌា។

**៣-គថនិយម**

**ពិតពគថនៃអត្ថវត្ថុ**

ទស្សនវិទូក្រិកបុរាណ Aristotle បានអភិវឌ្ឍគថនិយម ដែលបានសង្កត់ធ្ងន់ទៅលើចំណេះដឹង និងតម្លៃសត្យានុម័ត។ ដូច ដែលបានរៀបរាប់ក្នុងមេរៀនមុន Thomas Aquinas ក្នុងមជ្ឈិមសម័យ បានបង្ហាញឱ្យគេដឹងនូវគថភាពខាងសាសនាជាច្រើន ដែលត្រូវបានគេស្គាល់ថាជា ថមនិយម (Thomism) ជាសម្មតិកម្មមួយនៃលទ្ធិ Aristotelianism និង Christian។ Alfred North Whitehead បានបន្តប្រពៃណីពួកគថនិយម នៅដើមសតវត្សទី២០។ គថនិយមយល់ ឃើញថា៖

1-មានពិភពនៃអត្ថិភាពពិត មិនបានបង្កើតឡើងដោយមនុស្សលោក។

2-ចិត្តមនុស្ស អាចដឹងអំពីពិភពពិត។

3-ចំណេះដឹងបែបនេះ ជាមគ្គុទ្ទេសក៏គួរឱ្យទុកចិត្តបានបំផុត ចំពោះអាកប្បកិរិយាបុគ្គល និងសង្គម។

**៣-១-បញ្ញត្តិជាគន្លឹះ**

**ក-ការចេះដឹង៖ តន្ត្រីយារម្មណ៍ប ន្ទាប់មកការគិតអរូបី**

**បរមត្ថវិទ្យា និងពុទ្ធិវិទ្យា** ពួកគថនិយមជឿទៅលើពិភពសម្ភារៈ ដែលមានលក្ខណៈឯករាជ្យ និងនៅក្រៅចិត្តនៃអ្នក

ចេះដឹង[3]។ អង្គវត្ថុទាំងអស់ ត្រូវបានបង្កើតឡើងពីសម្ភារៈ។ បន្តិចម្តងៗ សម្ភារៈ បានសន្មតនូវរចនាសម្ព័ន្ធនៃវត្ថុពិសេស។

មនុស្សលោក អាចដឹងវត្ថុទាំងនេះបាន តាមសរីរាង្គវិញ្ញាណ និងវិចាររបស់ពួកគេ។ ការចេះដឹង គឺជាលំនាំមួយ ដែលពាក់ព័ន្ធដល់ដំណាក់កាល២ គឺឥន្ទ្រីយារម្មណ៍ និងការគិតអរូបី។ ជាបឋម អ្នកចេះដឹងថា មានវត្ថុមួយ ហើយកត់ត្រាទិន្នន័យអំពីវានៅក្នុងចិត្ត ដូចជាពណ៌ ទំហំ ទម្ងន់ ក្លិន និងសំឡេង។ ចិត្តរៀបចំដាក់ទិន្នន័យទាំងនេះទៅជាគុណភាព ដែលតែងតែបង្ហាញនៅក្នុងវត្ថុ ហើយនិងគុណភាពទាំងនោះ ជួនកាលក៏បានបង្ហាញខ្លួនផងដែរ។ តាមការកំណត់អត្តសញ្ញាណគុណភាពដ៏ចាំបាច់នោះ សិស្សបង្កើតបញ្ញត្តិនៃវត្ថុមួយ ហើយស្គាល់វាថាជាការស្ថិតនៅក្នុងក្រុមមួយដ៏ពិតប្រាកដ។ ការធ្វើចំណាត់ថ្នាក់នេះ ទុកឱ្យសិស្ស យល់ថា វត្ថុមួយបែងចែកគុណភាពពិតប្រាកដ ជា មួយសមាជិកផ្សេងទៀត នៅក្នុង ថ្នាក់តែមួយ ប៉ុន្តែ មិនមែនវត្ថុទាំងឡាយ នៅក្នុងថ្នាក់ផ្សេងទៀតទេ។

**ខ-កម្មវិធីសិក្សាដែលបានរៀបចំតាមមុខវិជ្ជា**

ដូចជាពួកមនោនិយម ពួកតថនិយម ជឿជាក់ថា ការអនុវត្តតាមកម្មវិធីសិក្សាមួយ ដែលមានមុខវិជ្ជាដោយឡែកត្រូវបានរៀបចំរួចហើយ ជារបៀបសិក្សាដ៏មានប្រសិទ្ធភាពបំផុត អំពីតថភាព។ ការរៀបចំកម្មវត្ថុតាមមុខវិជ្ជា ដូចដែលអ្នកវិទ្យាសាស្ត្រ និងអ្នកប្រាជ្ញ អនុវត្តនោះ ជាវិធីចាត់ថ្នាក់វត្ថុប្រកបដោយ ភាពជឿនលឿន។

ជាឧទាហរណ៍ បទពិសោធពីអតីកាលរបស់មនុស្ស អាចត្រូវបានរៀបចំទៅជាប្រវត្តិសាស្ត្រ។ កូតគ្រាមសាស្ត្រ សិក្សារុក្ខជាតិជាប្រព័ន្ធ ដោយយោងទៅតាមការចាត់ថ្នាក់របស់វា។ អង្គការនយោបាយ ដូចជា ជាតិ រដ្ឋាភិបាល អង្គនីតិបញ្ញត្តិ និងប្រព័ន្ធតុលាការ អាចត្រូវបានចាត់ថ្នាក់ទៅជាវិទ្យាសាស្ត្រ នយោបាយ។ តថវិទូ ទាមទារឱ្យមានចំណេះដឹង អំពីតថភាពតាមការសិក្សាជាប្រព័ន្ធ ទៅជាមុខវិជ្ជាទាំងនេះ។

**គ-អាកប្បកិរិយា ប្រកបដោយវិចារណញ្ញាណ ផ្អែកទៅលើតថភាព**

**វិទ្យាសាស្ត្រសីលធម៌** ក្នុងបញ្ញត្តិនៃចំណេះដឹងរបស់តថវិទូនោះ ក្បួនច្បាប់ពិតប្រាកដ គ្រប់គ្រងអាកប្បកិរិយាប្រកបដោយភាពឈ្លាសវៃ។ ជាឧទាហរណ៍

[3] William P. Alston, Araelist, *Conception of Truth* (Ithaca, NY: Cornell University Press,1996).

មនុស្សគួរតែប្រព្រឹត្ត តាមរបៀបមួយ ប្រកបដោយវិចារណ ញ្ញាណ ហើយ អាកប្បកិរិយា មានលក្ខណៈប្រកបដោយ វិចារណញ្ញាណ នៅពេលណាវាអនុលោម ទៅតាមរបៀបមួយ ដែលវត្ថុមានមុខងារ ទៅតាមតថភាព។ តាមការសិក្សាពីតថភាព របស់គេ មនុស្ស អាចអភិវឌ្ឍទ្រឹស្តីដោយ ពឹងផ្អែកទៅតាមច្បាប់ធម្មជាតិ រាងកាយ និងសង្គម។ ច្បាប់ធម្មជាតិ មានលក្ខណៈ សកល និងអនន្ត ព្រោះតម្លៃពឹងផ្អែកទៅ លើវា។

**ឃ-តក្កវិទ្យាបែបអនុមានញែក និងអនុមានរួម**

**តក្កវិទ្យា** គ្រូបង្រៀនតាមបែបតថ និយម ជាញឹកញាប់ប្រើទាំងអនុមានរួម និងញែក។ ឧទាហរណ៍ សិស្សក្នុងថ្នាក់ភូគ ត្រាមសាស្ត្រ អាចពិនិត្យមើលផ្កាកូឡាប ដែលខុសគ្នាទៅតាមពណ៌ ក្លិន និងទំហំ ប៉ុន្តែ តាមអនុមានរួម សន្និដ្ឋានថា ទាំងអស់ ជាសមាជិកនៃការបែងចែកអម្បូររុក្ខជាតិ ឬ សត្វតែមួយ។ ទោះជាយ៉ាងនេះក្តី នៅពេល ដែលសិស្សក្នុងថ្នាក់ដាំរុក្ខជាតិ ផ្កាកូឡាប ក្នុងសួនមួយ ទៅលើផ្ទៃដីក្នុងសាលារៀន ជាគម្រោងមួយនោះ សិស្សអាចពិភាក្សា ប្រវត្តិការថែទាំរុក្ខជាតិ ហើយធ្វើអនុមាន ញែក ទៅលើទីតាំងដ៏ត្រឹមត្រូវ ហើយនិង បរិមាណដី និងទឹក សម្រាប់ផ្កាកូឡាប ដែលគេបានដាំ។

**៣-២-សំណួរជាមូលដ្ឋាន**

**ក-ចំណេះដឹងដែលពាក់ព័ន្ធវត្ថុ**

ដើម្បីចាប់ផ្តើមការសួរ ដោយប្រុង ប្រ យ័ត្នតាមបែបទស្សនវិជ្ជា (Philosophical cross-examination) យើងសួរជាថ្មី អ្វីជា ចំណេះដឹង? តថវិទូ អាចនឹងឆ្លើយថា ចំណេះដឹង អាចពាក់ព័ន្ធនឹងពិភពរូប និយម (The physical world) ដែលយើងរស់ នៅ។ នៅពេលដែលយើងស្គាល់អ្វីមួយ ចំណេះដឹងរបស់ យើងគឺតែងតែនិយាយ អំពីវត្ថុ។ បញ្ញត្តិរបស់យើង អាចយកជាការ បាន នៅពេលដែលវាពាក់ព័ន្ធវត្ថុទាំងនោះ ព្រោះវាពិតជាកើតមានក្នុងលោកយើង នេះ[4]។

**ខ-ការអប់រំតាមកម្មវត្ថុមុខវិជ្ជាសិក្សា**

តថនិយមវិទូ គួរនិយាយថា ការ អប់រំក្នុងប្រព័ន្ធ ជាការសិក្សាពីចំណេះដឹង ដែល បានរៀបចំ និងចាត់ថ្នាក់ ទៅជាមុខ វិជ្ជាដែលមានកម្មវត្ថុសិក្សាត្រឹមត្រូវ។ ប្រវត្តិ វិទ្យា ភាសា វិទ្យាសាស្ត្រ និងគណិតវិទ្យា ជាអង្គពុទ្ធិដែលមានការៀបចំត្រឹមត្រូវ។ ប្រសិនបើយើងបានស្គាល់វា បាន ច្បាស់លាស់ យើងនឹងចេះដឹងថែមទៀត

[4] Andrew Newman,. *The Correspondence Theory of Truth: An Essay on the Methaphysics of Prediction* (New York: Cambridge University Press, 2002).

អំពីពិភពដែលយើងរស់នៅ។ ចំ ណេះដឹងនេះ គឺជាមគ្គុទ្ទេសក៍ប្រសើរបំផុត ក្នុងការដឹកនាំកិច្ចការ ក្នុងជីវិតប្រចាំថ្ងៃរបស់យើង។

តថវិទូ មើលឃើញសាលារៀន ថាជាស្ថាប័នសិក្សាបឋម ដែលសង្គមបង្កើតឡើង ដើម្បីផ្តល់ឱ្យសិស្សជាមួយពុទ្ធិ អំពីពិភពស ត្យានុម័ត។ ពីព្រោះតែមនុស្សទាំងអស់ មានសក្តានុពលខាងវិចារណញ្ញាណនោះ គួរតែអាចធ្វើបានចំពោះទាំងអស់គ្នា ដោយមានសិស្សទាំងអស់គ្នា បានបន្តកម្មវិធីសិក្សាតែមួយដែលនឹងរៀបចំពួកគេ ដើម្បីធ្វើការស ម្រេចចិត្ត ប្រកបដោយវិចារណញ្ញាណ។

**៣-៣-ការអនុវត្តចំពោះគ្រូបង្រៀនក្នុងថ្នាក់នាពេលបច្ចុប្បន្ន**

**ក-ថ្នាក់រៀនសម្រាប់សិក្សាមិនមែនជាការព្យាបាលរោគទេ**

ក្នុងថ្នាក់រៀនតថនិយម ការទទួលខុសត្រូវរបស់គ្រូជាលើកដំបូង គឺត្រូវបង្រៀនបំណិន ដូចជា ការអាន ការសរសេរ ឬការគិតគណនា ឬអង្គពុទ្ធិទៅតាមមុខវិជ្ជាមួយចំនួន ដូចជាប្រវត្តិវិទ្យា គណិតវិទ្យា ឬវិទ្យាសាស្រ្ត។ ទោះបីជាគេវាយតម្លៃថា សិស្សរបស់ខ្លួនគាត់ ជាមនុស្សដែលមានចិត្តរំភើប ព្រមទាំងវិចារ ណញ្ញាណក៏ដោយ ក៏គ្រូបង្រៀនបែបតថនិយម មិនប្រែក្លាយថ្នាក់រៀន ទៅជាមជ្ឈមណ្ឌលព្យាបាលរោគ សម្រាប់ការកែតម្រូវអា កប្បកិរិយា ឬចិត្តរំភើប។ គ្រូបង្រៀនបែបតថនិយម គួរតែប្រឆាំងជំទាស់ទៅនឹងសកម្មភាព ដែលមិនមែនជាការសិក្សា ដែលជ្រៀតជ្រែកដល់គោលបំណងបឋមរបស់សាលារៀន ជាមជ្ឈមណ្ឌលនៃការសិក្សា។

**ខ-គ្រូជាអ្នកជំនាញការកម្មវត្ថុសិក្សាក្នុងមុខវិជ្ជា**

ដើម្បីទទួលខុសត្រូវការអប់រំ នៅបឋមសិក្សា គ្រូបង្រៀនបែបតថនិយម ត្រូវតែចេះច្បាស់លាស់ នូវមុខវិជ្ជារបស់ខ្លួន។ ឧទា ហរណ៍ គ្រូបង្រៀនប្រវត្តិវិទ្យា គួរតែជាប្រវត្តិវិទូ ដោយចេះមុខវិជ្ជានោះច្បាស់លាស់ពីពេលមុន។ ជាងនេះទៀត គ្រូបង្រៀនបែបតថនិយម គួរតែមានការអប់រំទូទៅខាងសិល្បៈសេរី និងវិទ្យាសាស្រ្ត ដែលអាចឱ្យពួកគេបកស្រាយទំនាក់ ទំនងរវាងផ្នែកកោសល្យវិច័យ និងកម្មវត្ថុសិក្សាតាមមុខ វិជ្ជាផ្សេងទៀត។ គ្រូបែបតថនិយម អាចប្រើប្រាស់វិធីអ្វីដែលខ្លួនចេះនិងត្រៀមបង្រៀនយ៉ាងទូលំទូលាយ ដូច ជាបទឧទ្ទេស ការពិភាក្សា ការបកស្រាយប ញ្ជាក់ ឬការពិសោធ។ ចំណេះចំណានខាងខ្លឹមសារ មានសារៈសំខាន់ណាស់ ហើយវិធីសាស្រ្តគឺជាមធ្យោបាយចាំបាច់ តែក៏អាចបន្ទាប់បន្សំ ដើម្បីសម្រេចបានគោលដៅនោះ។

**គ-គំរូនៃគោលវិធីបែបតថនិយម**

*តើគ្រូបង្រៀនរូបវិទ្យា នៅមធ្យមសិក្សាដោយមានការតម្រង់ទិសទស្សនវិជ្ជាបែប តថនិយម អាចធ្វើផែនការទៅលើមេរៀនមួយស្ដីពីច្បាប់ចលនារបស់ញូតុន* (Newton) *យ៉ាងដូចម្ដេច?*

1-*គ្រូគួរតែជួយសិស្សសិក្សាពីបរិបទជាប្រវត្តិ ហើយអធិប្បាយនូវការរួមចំណែកខាងវិទ្យាសាស្ត្ររបស់គាត់។*

2-*គ្រូអាចពន្យល់ច្បាប់ចលនា តាមការបកស្រាយក្នុងមន្ទីរពិសោធន៍។*

3-*សិស្ស អាចពិភាក្សាការបកស្រាយ និងធ្វើទូទៅកម្មបែបវិទ្យាសាស្ត្រដែលវាបានពន្យល់។*

4-*ជាចុងក្រោយ សិស្សគួរតែធ្វើតេស្ត ដើម្បីបកស្រាយការយល់ដឹង ពីច្បាប់ចលនារបស់លោកញូតុន*[5]*។*

**ឃ-ស្តង់ដា និងការវាយតម្លៃ**

*តថវិទូ គួរតែសាទរចលនា ដើម្បីកំណត់ស្តង់ដា ដែលបញ្ជាក់គោលដៅស្នាដៃសិក្សារបស់សិស្ស ពិសេសក្នុងផ្នែកបំណិន ដូចជាការអាន និងក្នុងផ្នែកខ្លឹមសារមុខវិជ្ជា ដូចជា គណិតវិទ្យា វិទ្យាសាស្ត្រ និងប្រវត្តិវិទ្យា។ គេស្គាល់ដែលប្រកបដោយស្តង់ដា ផ្តល់ទិន្នន័យដ៏លំបាក និងអាចប្រៀបធៀបបាន អំ ពីរបៀបដែលសិស្សមានចំណេះដាក់លាក់លើមុខវិជ្ជា តាមកម្មវិធីសិក្សាបានល្អប៉ុណ្ណា និងរបៀបដែលគ្រូកំពុងបង្រៀនសិស្សបានល្អប៉ុណ្ណា។ ស្តង់ដា ជួយរក្សាសាលារៀន និងគ្រូបង្រៀនដែលអាចពន្យល់បាន។*

*តថនិយមវិទូ យល់ស្របនឹងការប្រើប្រាស់បច្ចេកវិទ្យា ដែលបំពេញបន្ថែមវិធីទាំង ឡាយផ្សេងទៀតនៃការអភិវឌ្ឍបំណិន និងសមត្ថភាពកម្មវត្ថុសិក្សាតាមមុខវិជ្ជា។ ពួកគេចង់បានកម្មវិធីដែលមានលក្ខណៈតថនិយម និង មានប្រសិទ្ធភាពតាមអាចធ្វើបាន។*

---

[5] Philip H. Phenic, *Philosophies of Education* (New York: Wiley, 1961), pp.22-24.

# ឯកសារយោង

1- Gerald L. Gutek, *Philosophical and Ideological Voices in Education*, Boston: Allyn and Bacon, 2004.
2- Gerald L. Gutek, *Philosophical and Ideological Perspectives on Education,* 2nd ed., Boston: Allyn and Bacon, 1997.
3- William P. Alston, Araelist, *Conception of Truth*, Ithaca, NY: Cornell University Press,1996.
4- Andrew Newman,. *The Correspondence Theory of Truth: An Essay on the Methaphysics of Prediction* New York: Cambridge University Press, 2002.
5- Philip H. Phenic, *Philosophies of Education*, New York: Wiley, 1961.
6- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
7- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

# ប្រភពនៃទស្សនវិជ្ជាអប់រំ៖ សច្ចសកលនិយម និងសារវន្តនិយម

*ដោយ៖* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*សច្ចសកលនិយម អះអាងថា ការអប់រំដូចជាសច្ចភាពនានា មានលក្ខណៈសកលនិងភាពពិត នៅគ្រប់សម័យកាលនៃប្រវត្តិសាស្ត្រ គ្រប់ទីកន្លែង និងគ្រប់វប្បធម៌។*

*សារវន្តនៃការអប់រំគឺជាទស្សនវិជ្ជាអប់រំដែលគាំទ្រគំនិតថា កុមារគួររៀនមុខវិជ្ជាមូលដ្ឋានតាមប្រពៃណីឱ្យបានហ្មត់ចត់។ នៅក្នុងទស្សនវិជ្ជានេះគោលបំណងដើម្បីបណ្តុះសិស្សនូវ "កត្តាសំខាន់" នៃចំណេះដឹងសិក្សាដោយអនុវត្តតាមគោលវិធីមូលដ្ឋានបែបសាមញ្ញ។*

## ១. ទ្រឹស្តីអប់រំសច្ចសកលនិយម

### ក-សច្ចភាព នៅក្នុងស្លាដៃភ្លាស៊ីក

*ទ្រឹស្តីអប់រំសច្ចសកលនិយម ដែលជាទ្រឹស្តីអប់រំសច្ចសកលវប្បធម៌មួយនោះ ផ្តោតអារម្មណ៍លើប្រភពនៃប្រពៃណី និងបែបបុរាណ។ ទ្រឹស្តីនេះ ជឿជាក់ថា៖*

*១-សច្ចភាព មានភាពសកល និងមិនអាស្រ័យទៅលើកាលៈទេសៈនៃទីកន្លែង ពេលវេលា ឬបុគ្គល។*

*២-ការអប់រំល្អ ពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការយល់ដឹងពីសច្ចភាព។*

*៣-សច្ចភាព អាចរកឃើញក្នុងស្នាដៃដ៏ធំធេងនៃអារ្យធម៌។*

*៤-ការអប់រំ គឺជាលំហាត់បែបសេរីដែលបានអភិវឌ្ឍបញ្ញា។*

*ទ្រឹស្តីអប់រំសច្ចសកលនិយម ទាក់ទាញអារម្មណ៍ជាខ្លាំងទៅលើគោលការណ៍តថនិយម។ ភាពដូចគ្នាផ្នែកអប់រំរវាងតថនិយម និងមនោនិយម នាំឱ្យទ្រឹស្តីវិទូអប់រំ មានទំនាក់ទំនងទ្រឹស្តីអប់រំសច្ចសកលនិយម ទៅនឹងមនោនិយម។ ទោះជាយ៉ាងណាក៏ដោយ ទ្រឹស្តីអប់រំសច្ចសកលនិយមដែលឈានមុខគេនោះ ដូចជាលោករ៉ូប៊ឺត ហ៊ូឈីន និងមថាម័រ អែតល័រ* (Robert Hutchins and Mortimer Adler) *បានពឹងផ្អែកទ្រឹស្តីអប់រំរបស់ពួកគេ ទៅលើតថភាពនិយមរបស់លោកអារីស្តូត។*

### ខ-សាលារៀនត្រូវបណ្តុះសនិទានភាព

*ដោយយល់ស្របជាមួយអារីស្តូតថា មនុស្សលោក ត្រូវមានវិចារណញ្ញាណ គរុវិទូសច្ចសកលនិយម មើលឃើញតួនាទីបឋម*

របស់សាលារៀនថាជាការអភិវឌ្ឍបញ្ញា។ ពួកគេ បានប្រឆាំងជំទាស់ទៅនឹងទ្រឹស្តីទាំងឡាយ ដែលប្រែក្លាយសាលារៀនទៅជាភ្នាក់ងារ ដែលមានគោលបំណងចម្រុះ ជាពិសេសភ្នាក់ងារខាងសេដ្ឋកិច្ច ដែលប្រើប្រាស់វា សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ទោះបីជា«គរុវិទូសច្ចសកលនិយម យល់ដឹងតម្រូវការ សម្រាប់បំណិន និងសមត្ថភាពវិជ្ជាជីវៈក៏ដោយ ក៏ពួកគេជឿជាក់ថា ភ្នាក់ងារដទៃទៀតដូចជា ជំនួញ និងឧស្សាហកម្ម អាចផ្តល់ការបណ្តុះបណ្តាលពេលដែលកំពុងធ្វើការងារ (On-the-job training) មានប្រសិទ្ធភាពជាង បានច្រើនជាង នៅសាលារៀន។

### គ-កម្មវិធីសិក្សាតាមសច្ចសកលនិយម

គោលដៅអប់រំសំខាន់បំផុតរបស់គរុវិទូសច្ចសកលនិយម គឺការស្វែងរកនិងការផ្សព្វផ្សាយសច្ចភាព។ ពួកគេជឿជាក់ថា នៅពេលដែលសច្ចភាព មានលក្ខណៈសកល និងមិនផ្លាស់ប្តូរនោះ ការអប់រំដ៏ពិតមួយ ក៏មានលក្ខណៈសកល និងអចិន្ត្រៃយ៍ផងដែរ។ ព្រោះហេតុដូច្នេះហើយ កម្មវិធីសិក្សារបស់សាលារៀន គួរតែមានការសិក្សាសច្ចភាពសកល ឬអចិន្ត្រៃយ៍ ដែលសង្កត់ធ្ងន់ទៅលើមុខវិជ្ជាដែលកើតមានឡើងជារឿយៗនៃជីវិតមនុស្ស។ វាគួរតែមានប្រធានបទផ្នែកពុទ្ធិ ដែលបណ្តុះសនិទានភាព និងការសិក្សាពីគោលការណ៍សាសនា សោភណភាព និងសីលធម៌ ដើម្បីអភិវឌ្ឍអាកប្បកិរិយា និងសេចក្តីគួរសម។ ដូចគរុវិទូមនោនិយម តថនិយមដែរនោះ គរុវិទូសច្ចសកលនិយម ពេញចិត្តកម្មវិធីសិក្សាតាមកម្មវត្ថុមុខវិជ្ជា ដែលរាប់បញ្ចូលទាំងប្រវត្តិវិទ្យា ភាសា គណិតវិទ្យា តក្កវិទ្យា អក្សរសិល្ប៍ មនុស្សសាស្ត្រ ហើយនិងវិទ្យាសាស្ត្រ។ ស្នាដៃអក្សរសិល្ប៍បែបបុរាណ និងសិល្បៈ គួរតែផ្តល់ខ្លឹមសារពីប្រធានបទទាំងនេះ។ គរុវិទូសច្ចសកលនិយម ចាត់ទុកភាពម្ចាស់ការលើមុខវិជ្ជាទាំងនេះ ថាជារឿងសំខាន់ សម្រាប់បណ្តុះបណ្តាលបញ្ញា។

### ឃ-ហ៊ូឈីនៈ ការអប់រំតាមការអភិវឌ្ឍចិត្តគំនិត

លោករ៉ូបឺត ហ៊ូឈីន អតីតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យឈីកាហ្គោ គឺជាទ្រឹស្តីវិទូនៃគរុវិទូសច្ចសកលនិយម ដែលគេស្គាល់យ៉ាងច្បាស់លាស់។ លោករ៉ូបឺត ហ៊ូឈីន ចាត់ទុកការអប់រំ តាមឧត្តមគតិ ថាជាការអប់រំមួយដែលអភិវឌ្ឍថាមពលបញ្ញា...។ ការអប់រំឧត្តមគតិ គឺមិនមែនជាការអប់រំពិសេសទេ មិនមែនជាការអប់រំ ដែលតម្រង់ឆ្ពោះទៅរកតម្រូវការបន្ទាន់នោះទេ។ វា មិនមែនជាការអប់រំដែលមានឯកទេស ឬការអប់រំវិជ្ជាជីវៈនោះទេ។ វា មិនមែនជាការអប់រំ ដែលគិតតែប្រយោជន៍នោះទេ។ វាជាការអប់រំដែលគណនា ដើម្បីអភិវឌ្ឍផ្លូវចិត្ត[1]។

[1] Robert M. Hutchins, *A Conversation on Education* (Santa Barbara, Calif., The Fund for the Republic, 1963), p. 1. See also Robert M. Hutchins, *The Learning Society* (New York: Praeger, 1968); and Hutchins, *The Higher Education in America* (New Haven, Conn.: Yale University Press,1962).

**ខ-មហាសៀវភៅនៃអារ្យធម៌លោកខាងលិច**

លោករ៉ូបឺត ហ៊ូឈីន បានផ្ដល់ជំបូន្មានពិសេសពីការសិក្សា និងការពិភាក្សាយ៉ាងទូលំទូលាយនៃមហាសៀវភៅអារ្យធម៌ពិភពលោក (ស៊េរីនៃសៀវភៅដែលបានបោះពុម្ពដំបូងនៅសហរដ្ឋអាម៉េរិកក្នុងឆ្នាំ១៩៥២ ដោយសព្វវចនាធិប្បាយប្រ៊ីតានីកា ដើម្បីបង្ហាញមហាសៀវភៅចំនួន៥២ភាគ។ គាត់បានពិចារណាថា មហាសៀវភៅធ្វើឱ្យចងចាំនូវសមាជិកនៃជំនាន់នីមួយៗ ក្នុងការនិយាយទាក់ទងគ្នាជាមួយនឹងគំនិតដ៏ធំធេង ពីអតីតកាល។ ស្នាដៃបែបបុរាណទាំងនេះ ដែលមានផ្ទុកទៅដោយទ្រឹស្ដីអប់រំសច្ចសកលនិយម ឬដែលតស៊ូគំនិតគ្នានោះ ជួយមនុស្សម្នាក់ឱ្យក្លាយជាអ្នកចូលរួមក្នុងវប្បធម៌ពិតប្រាកដ។ ពួកគេបណ្ដុះបញ្ញា និងត្រៀមរៀបចំសិស្ស ដើម្បីឱ្យគិតយ៉ាងល្អិតល្អន់។ ក្នុងការបន្ថែមទៅឱ្យស្នាដៃបុរាណទាំងនោះ គាត់បានជំរុញឱ្យមានការសិក្សាវេយ្យាករណ៍ វោហារសាស្ត្រ តក្កវិជ្ជា គណិតវិទ្យា និងទស្សនវិជ្ជា។

**ច-ការរិះគន់ពីកម្មវិធីសិក្សាមហាសៀវភៅ**

ដូចដែលយើងបានកត់សម្គាល់ ពីពេលមុន ការរិះគន់ទៅតាមគរុវិទូសម័យក្រោយទំនើបនិយម បានបង្ហាញកម្មវិធីសិក្សាមហាសៀវភៅរបស់លោករ៉ូបឺត ហ៊ូឈីន ថាជាការប៉ុនប៉ងមួយ ដើម្បីផ្ដល់ឱ្យអធិកភាព (Predominance) វប្បធម៌អឺរ៉ុបខាងលិច ទៅលើវប្បធម៌ផ្សេងទៀត ដូចជាវប្បធម៌នៅទ្វីបអាហ្វ្រិក និងអាស៊ី។ តាមទស្សនៈនេះ មហាសៀវភៅដែលជាស្នាដៃរបស់លោក គ្រាន់តែអះអាងចំណូលចិត្តក្នុងថ្នាក់ដ៏សំខាន់នូវកម្រិតពេល វេលា ដែលផ្ដល់ឱ្យក្នុងប្រវត្តិសាស្ត្រ។ ឧទាហរណ៍ គរុវិទូក្រោយសម័យទំនើបនិយម បង្កើតអត្ថបទនៃមហាសៀវភៅ ដើម្បីស្វែងរកអត្ថន័យ ដែលផ្អែកទៅតាមប្រវត្តិសាស្ត្រ។

**ឆ-សំណើPaideia**

**កម្មវិធីសិក្សា Paideia**

សំណើរបស់លោក អែតល័រ (Mortmer J. Adler) គឺនិវេទនប័ណ្ណអប់រំ គឺជាការនិយមឡើងវិញ នៃទ្រឹស្ដីអប់រំសច្ចសកលនិយម[2]។ Paideia ជាពាក្យភាសាក្រិក ដែលមានន័យថា ការបង្កើតការអប់រំរួមនៃមនុស្សម្នាក់។ ដោយបានអះអាងពីសិទ្ធិរបស់មនុស្សទាំងអស់ចំពោះការអប់រំទូទៅ លោក អែតល័រ ចង់ឱ្យសិស្សទាំងអស់ ក្នុងសង្គមប្រជាធិបតេយ្យអាម៉េរិក មានគុណភាពសិក្សាខ្ពស់ដូចគ្នា។ កម្មវិធីសិក្សាតាមបែប Paideia រាប់បញ្ចូលទាំងភាសា អក្សរសិល្ប៍ វិចិត្រសិល្បៈ គណិតវិទ្យា ការស្ដាប់ ការគណនា ការសង្កេត ការវាស់វែង ការប៉ាន់ប្រមាណ និងការដោះស្រាយបញ្ហា ដែល

[2] Mortimer J. Adler, *The Paideia Proposal: An Educational Manifesto* (New York: Macmillan, 1982); see also Mortimer J. Adler, *Paideia Problems and Possibilities* (New York: Macmillan, 1983).

នាំទៅដល់ការគិត និងការផ្ទុះបញ្ហាំងកម្រិតខ្ពស់[3]។

**៥-សំណួរជាមូលដ្ឋាន**

**៥. ១-ការអប់រំជាទូទៅ**

គរុវិទូអភិវឌ្ឍនិយម រិះគន់ដល់ទ្រឹស្តីអប់រំសច្ចសកលនិយម សម្រាប់ការជំរុញដល់ការអភិវឌ្ឍវរជននិយមផ្នែកការអប់រំ។ ដោយបានបដិសេធការចោទប្រកាន់នេះ គរុវិទូសច្ចសកលនិយម បានការពារកម្មវិធីរបស់គេថា មានលក្ខណៈប្រជាធិបតេយ្យពិតប្រាកដ ដោយពោលអាងថា មនុស្សទាំងអស់ មានសិទ្ធិចំពោះការអប់រំ ដែលមានគុណភាពខ្ពស់។ ពួកគេអះអាងថា សិស្សទាំងឡាយ មិនគួរដាក់ ឬបែងចែកជាក្រុមទៅជារបៀបមួយ ដែលបង្ការពួកគេខ្វះៗពីការទទួលបានការអប់រំទូទៅ ដែលត្រូវបានផ្តល់ជូនដោយមនុស្សជាតិសាមញ្ញ។

**៥. ២-ការប្រឆាំងនឹងសច្ចភាពវប្បធម៌អសកល**

គរុវិទូសច្ចសកលនិយម ប្រឆាំងយ៉ាងខ្លាំងក្លា ទៅនឹងសច្ចភាពមិនស្ថិតស្ថេរខាងផ្នែកវប្បធម៌ ដែលផ្សារភ្ជាប់នឹងប្រតិបត្តិនិយម ការអភិវឌ្ឍនិយម និងការរិះគន់។ ដោយយោងទៅតាមសច្ចភាពមិនស្ថិតស្ថេរខាងផ្នែកវប្បធម៌នោះ សច្ចភាពរបស់យើង គឺជាអំណះអំណាងជាបណ្តោះអាសន្ន ដែលផ្អែកទៅលើការពិភាក្សាជាមួយកាលៈទេសៈ ដែលកំពុងតែផ្លាស់ប្តូរ។ ការផ្លាស់ប្តូរខាងផ្នែកបរិស្ថានក្នុងអំឡុងពេលមួយ និងភាពខុសគ្នាពីកន្លែងមួយទៅកន្លែងមួយទៀតនោះ ធ្វើឱ្យសច្ចភាពជាជាងមានសុពលភាពជាអចន្ត្រៃយ៍ និងសកលនោះមានសុពលភាពទៅតាមស្ថានភាព និងបណ្តោះអាសន្ន។ គរុវិទូសច្ចសកលនិយម ដូចជាលោកអាឡាន់ ប៊្លូម (Allan Bloom) ក្នុងសៀវភៅ The Closing of the American Mind បានថ្កោលទោសសច្ចភាពមិនស្ថិតស្ថេរខាងផ្នែកវប្បធម៌ ដោយសារធ្វើឱ្យចុះទន់ខ្សោយអត្តចរិតផ្នែកសីលវិជ្ជា។ ពួកគេប្រកាសថា វាបដិសេធស្តង់ដាសកល ដែលតាមនោះ សកម្មភាពពិតប្រាកដមានលក្ខណៈមិនផ្លាស់ប្តូរទាំងភាពខុស និងត្រូវផ្នែកសីលធម៌។

**៥. ៣-ការអនុវត្ត សម្រាប់គ្រូប្រចាំថ្នាក់នាពេលសព្វថ្ងៃ**

គរុវិទូសច្ចសកលនិយម ក៏ដូចជាមនោនិយម និងតថនិយម មើលឃើញថ្នាក់រៀនថាជាបរិស្ថានមួយ សម្រាប់ការលូតលាស់បញ្ញារបស់សិស្ស។ ដើម្បីក្លាចបញ្ញារបស់សិស្ស គ្រូត្រូវតែជាមនុស្សមានការអប់រំបែបសេរី ដែលស្រឡាញ់សច្ចភាព និងមានចំណង់ដឹកនាំជីវិតដោយផ្អែកទៅលើសេរីភាព។ តាមពិតទៅ ការអប់រំសេរី មានសារៈសំខាន់សម្រាប់គ្រូអប់រំ

[3] Adler, Paideia Proposal, pp.22-23

សច្ចសកលនិយម ជាងមុខវិជ្ជាសិក្សាក្នុងវិធីអប់រំ។

### ៥.៤-ការយកចិត្តទុកដាក់របស់គ្រូ

នៅកម្រិតបឋមសិក្សា គ្រូបង្រៀនតាមទ្រឹស្តីអប់រំសច្ចសកលនិយម គួរតែសង្កត់ធ្ងន់ទៅលើបំណិនសិក្សាជាមូលដ្ឋាន ដូចជា ការអាន ការសរសេរ និងការគណនាលេខ អក្ខរកម្ម និងភាពត្រៀមជាស្រេច ដើម្បីចាប់ផ្តើមស្វែងរកសច្ចភាពពេញមួយជីវិត។ គ្រូបង្រៀន នៅមធ្យមសិក្សាតាមបែបទ្រឹស្តីអប់រំសច្ចសកលនិយម គួររៀបចំមេរៀនទៅតាមរចនាសម្ព័ន្ធនៅជុំវិញការយកចិត្តទុកដាក់របស់មនុស្ស ដែលត្រូវបានរកឃើញនៅក្នុងស្នាដៃធំធេងនៃប្រវត្តិសាស្ត្រ អក្សរសិល្ប៍ និងទស្សនវិជ្ជា។ ដូចជាគរុវិទូមនោនិយម គរុវិទូសច្ចសកលនិយម សង្កត់ធ្ងន់ទៅលើស្នាដៃអក្សរសិល្ប៍ក្រិកបុរាណ ដែលចូលរួមដល់ផលប្រយោជន៍មនុស្ស ធ្វងកាត់ជំនាន់មនុស្សទាំងឡាយ។ ក្នុងសាលារៀនតាមទ្រឹស្តីអប់រំសច្ចសកលនិយម អ្នករដ្ឋបាល គ្រូបង្រៀន និងសិស្សទាំងឡាយ រក្សាស្តង់ដារកម្រិតខ្ពស់ សម្រាប់ស្នាដៃសិក្សា។

### ៥.៥-ស្តង់ដា និងការវាយតម្លៃ
### -ការសង្កត់ធ្ងន់ទៅលើខ្លឹមសារសិក្សា

គរុវិទូសច្ចសកលនិយម យល់ស្របនឹងស្តង់ដាសិក្សាកម្រិតខ្ពស់ ប៉ុន្តែ ពួកគេនឹងសាកសួរខ្លឹមសារ ដែលត្រូវបានធ្វើតេស្ត ដើម្បីវាយតម្លៃសមត្ថភាពរបស់សិស្ស។ ប្រសិនបើធ្វើតេស្តផ្តុះបញ្ចាំងចំណេះដឹងនៃមុខវិជ្ជា និងមហាសៀវភៅនោះ ពួកគេគួរតែពេញចិត្តវា។ ស្តង់ដាមិនមែនពឹងផ្អែកទៅលើប្រភេទនៃខ្លឹមសារ នឹងលើកឡើងអំពីសំណួរ អំពីលំនាំវាយតម្លៃនោះទេ។ លក្ខណៈវិនិច្ឆ័យតែមួយ នឹងអនុវត្តចំពោះបច្ចេកវិជ្ជាអប់រំ។ ពួកគេគួរតែពេញចិត្តនឹងបច្ចេកវិទ្យា ដែលត្រូវបានគេប្រើប្រាស់ ដើម្បីផ្ទេរស្នាដៃដ៏ធំធេងនៃសិល្បៈ និងអក្សរសិល្ប៍ ប៉ុន្តែ បច្ចេកវិទ្យាត្រូវបានគេប្រើជារបស់ជំនួសសម្រាប់សៀវភៅដ៏ធំធេង នឹងត្រូវបានពិចារណាតាមរបៀបមួយផ្សេងទៀត ដើម្បីធ្វើឱ្យលំនាំអប់រំមិនសូវមានសារៈសំខាន់។

### -មេរៀនតាមបែបទ្រឹស្តីអប់រំសច្ចសកលនិយម

ការពន្យល់មួយនៃការសង្កត់ធ្ងន់ ទៅលើការទ្រឹស្តីអប់រំសច្ចសកលនិយម ទៅលើការយកចិត្តទុកដាក់របស់មនុស្សឡើងវិញ និងតម្លៃទាំងឡាយ អាចត្រូវបានមើលឃើញ តាមរយៈថ្នាក់អក្សរសិល្ប៍នៅសាលាមធ្យមសិក្សា ដែលកំពុងអាន និងពិភាក្សារឿងស្ត្រីតូចរបស់លូវីហ្សា មេ អាល់កុត(Louisa May Alcott)។ សិស្សពិភាក្សាលើតួអង្គសំខាន់ៗ ដូចជា ម៉ាមី, ហ្សោ, បិត និងអាមី(Marmee, Jo, Beth, and Amy) និងបញ្ហាគ្រួសាររបស់លោកម៉ាច (March) បានប្រឈមមុខ។ ការពិភាក្សានៅថ្នាក់រៀន

បានលាតត្រដាងថា ពេលវេលាដ៏សែនព្រួយបារម្ភ និងដ៏សែនលំបាករបស់គ្រួសារម៉ាច កើតឡើងក្នុងជីវភាពគ្រួសារនាពេលសព្វថ្ងៃ។ ពាត្រីនោះ នៅពេលហូបអាហារល្ងាច ជីដូនរបស់នាងបានសួរនាង អាលីស (Alice) ថាក្នុងនាមជាសិស្សនៅថ្នាក់រៀន តើអ្នកកំពុងសិក្សាអ្វីក្នុងសាលារៀន? អាលីស ឆ្លើយថា យើងទើបតែបានបញ្ចប់ការអានរឿងស្ត្រីតូចៗ ម្តាយ និងជីដូន អាលីស និយាយថា ពួកគេក៏ដូច្នោះដែរ បានអាន និងបានពេញចិត្តសៀវភៅ នៅពេលដែលពួកគេនៅវ័យក្មេងៗ ក្នុងផលនៃការសន្ទនានេះ អាលីស ម្តាយ និងជីដូននាង បានរួមចំណែកដល់ការចាប់អារម្មណ៍ទៅលើសៀវភៅ។ ក្នុងមធ្យោបាយបែបនេះ ប្រធានបទបែបទ្រឹស្តីអប់រំសច្ចសកលនិយម អាចក្លាយជាអនុស្សាវរីយ៍ ដែលពុះពារលើពេលវេលា និងជំនាន់មនុស្សទាំងឡាយ។

## II-**សារវន្តនិយម**

សារវន្តនិយម ត្រូវបានគេស្គាល់ផងដែរថាជាការអប់រំជាមូលដ្ឋាន អះអាងថា បំណិនមូលដ្ឋាននិងមុខវិជ្ជាទាំងឡាយមានសារៈសំខាន់ជាចាំបាច់សម្រាប់បន្តវប្បធម៌របស់មនុស្ស។ សារវន្តទាំងនេះ ជាបំណិននៃអក្ខរកម្ម(ការអាន និងសរសេរ) និងការគណនា (នព្វន្តសាស្ត្រ) និងមុខវិជ្ជាប្រវត្តិសាស្ត្រ គណិតវិទ្យា វិទ្យាសាស្ត្រ ភាសា និងអក្សរសិល្ប៍។ ការបង្រៀនដោយយកចិត្តទុកដាក់(Deliberate instruction) ដោយបានផ្ទេរបំណិនមូលដ្ឋាន និងផ្នែកចំណេះដឹងពីជំនាន់មួយទៅជំនាន់មួយទៀត ជានាដល់ការរស់ឡើងវិញ(Survival) និងនិរន្តរភាព (perpetuation) របស់អរិយធម៌។ បរាជ័យដើម្បីផ្ទេរបំណិនចាំបាច់ទាំងនេះ និងមុខវិជ្ជាទាំងឡាយ បានធ្វើឱ្យអរិយធម៌ស្ថិតក្នុងគ្រោះថ្នាក់។ បរិមាណដ៏ធំធេង ដើម្បីសិក្សា និងពេលវេលាដែលបានកំណត់ដើម្បីសិក្សា វាមានន័យថា កម្មវិធីសិក្សា និងការបង្រៀន ត្រូវតែរៀបចំផែនការ ដោយយកចិត្ត ទុកដាក់ និងត្រូវបានផ្ទេរដោយមានប្រសិទ្ធភាព ដោយគ្រូទៅដល់សិស្ស។

### ១-**សារវន្តនិយមបែបថ្មី**

ទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ ជាសាក្សីដ៏រឹងមាំនៃការអប់រំជាមូលដ្ឋាន និងចលនាសារវន្តនិយមបែបថ្មី បានអភិវឌ្ឍ។ សារវន្តនិយមបែបថ្មី ដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសច្ចសកលវប្បធម៌ និងនយោបាយ បានអភិវឌ្ឍការរិះគន់នៃសាលារៀន ដែលបានកើតមានរួចហើយ និងបានស្នើកម្មវិធីមួយ ដើម្បីដោះស្រាយភាពចុះទន់ខ្សោយ (Deficiencies) ដែលគេបានដឹងរួចហើយក្នុងប្រព័ន្ធអប់រំ ជាពិសេស ក្នុងសាលារៀនសាធារណៈ។

## ក-គោលការណ៍ថ្មី មិនបានយកចិត្តទុកដាក់ដល់ភាពចាំបាច់ជាមូលដ្ឋាន

សារវន្តវិទូនិយមបែបថ្មី បានអះអាងថា គោលវិធីបែបពិសោធ និងបែបថ្មី ចំពោះការបង្រៀន បណ្ដាលឱ្យមានការធ្វេសប្រហែសនៃការបង្រៀនផ្ទាល់ជាប្រព័ន្ធក្នុងបំណិន ជាមូលដ្ឋាននៃការអាន ការសរសេរ និងការគណនា។ រឿងនេះ បណ្ដាលឱ្យមានឱនភាពក្នុងស្តង់ដាអក្ខរកម្ម។ គោលនយោបាយផ្សព្វផ្សាយក្នុងសង្គម ដែលបានជំរុញកុមារក្នុងសាលារៀនសាធារណៈ ទៅដល់កម្រិតថ្នាក់ខ្ពស់ជាងមុន ដើម្បីរក្សាវាជាមួយក្រុមអាយុរបស់ពួកគេ ទោះបីជាពួកគេមិនមានបំណិន និងមុខវិជ្ជាសមរម្យទៅតាមកម្រិតថ្នាក់នោះ បានធ្វើចម្រោះស្តង់ដាសិក្សា។ គោលនយោបាយដែលជាសារវន្តបែបថ្មីមួយនោះ បានបន្ទាបស្តង់ដាសិក្សា និងបង្កើតនូវឱនភាពដែលគ្មានក្នុងតារាងពិន្ទុតាមស្តង់ដាតេស្ត ដូចជា SAT និង ACT (តេស្តសម្បទាសិក្សា និងតេស្តចូលរៀននៅឧត្តមសិក្សា នៅសហរដ្ឋអាម៉េរិក)។ ជាការបន្ថែម សារវន្តវិទូនិយមបែបថ្មី បានបារម្ភថា បរិស្ថាន ដែលបណ្ដែតបណ្ដោយផ្នែកសីលធម៌ក្នុងសាលារៀន បានធ្វើឱ្យចុះខ្សោយតម្លៃពលរដ្ឋជាមូលដ្ឋាននៃភាពឧស្សាហ៍ (Industriousness) ការទទួលខុសត្រូវ និងការស្នេហាជាតិ (Patriotism)។

## ខ-បញ្ហាសំខាន់ថ្មីៗ

ដើម្បីកែលម្អភាពទន់ខ្សោយទាំងនេះ របាយការណ៍មួយ ស្តីអំពីជាតិមួយដែលស្ថិតក្នុងគ្រោះថ្នាក់ (A Nation at Risk) ជារបាយការណ៍ជាតិមួយ ដែលទ្រទ្រង់ដោយក្រសួងអប់រំអាម៉េរិកនោះ បានផ្តល់ដំបូន្មានថា សិស្សសាលាមធ្យមសិក្សាទាំងអស់ បញ្ចប់កម្មវិធីសិក្សាមួយដែលរៀបចំយ៉ាងហ្មត់ចត់ ស្តីពីបញ្ហាសំខាន់ថ្មីៗដែលរួមមានភាសាអង់គ្លេស គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងវិទ្យាសាស្ត្រកុំព្យូទ័រ[4]។

## គ-ស្តង់ដា និងការវាយតម្លៃ -ការចាប់ផ្តើមចលនាតាមស្តង់ដា

ពីព្រោះតែវាត្រូវបានក្រោចដោយរបាយការណ៍ជាតិមួយដែលស្ថិតក្នុងគ្រោះថ្នាក់ និងរបាយការណ៍រិះគន់ផ្សេងទៀត ដែលបានអះអាងមុខវិជ្ជាអប់រំមូលដ្ឋាននោះ ធ្វើឱ្យមូលដ្ឋានស្តង់ដាត្រូវបានអភិវឌ្ឍ។ ប្រធានបទដ៏សំខាន់ចាំបាច់នៃចលនាស្តង់ដា គឺថា ការអប់រំអាម៉េរិក នឹងត្រូវកែលម្អតាមការបង្កើតស្តង់ដាសិក្សា ឬគំរូស្តង់ដាប្រៀបធៀប (Benchmarks) សម្រាប់ស្នាដៃសិក្សា និងការវាស់វែងការអភិវឌ្ឍចំពោះសមិទ្ធផលនៃគំរូស្តង់ដាប្រៀបធៀបទាំងនោះ ទៅតាមតេស្តស្តង់ដា។ ត្រឹមឆ្នាំ ២០០០ ចលនាស្តង់ដាកំពុងតែមានឥទ្ធិពល

[4] National Commission on Excellence in Education, A Nation at Risk: *The Imperative for Educational Reform* (Washington, D.C.: U.S. Department of Education, 1983), pp. 5, 24.

ពាសពេញសហរដ្ឋអាម៉េរិក ជារដ្ឋដែលបានអនុម័តនីតិកម្ម ដែលទាមទារឱ្យមានតេស្តតាមស្តង់ដាក្នុងមុខវិជ្ជាមូលដ្ឋាន។

**-គ្មានកុមារ ដែលបន្សល់ទុកមិនបានអភិវឌ្ឍ**

ការយល់ព្រមតាមស្តង់ដាជាក់លាក់កើតមានស្របគ្នានឹងការអនុម័តច្បាប់អប់រំ នៅមធ្យមសិក្សា និងបឋមសិក្សាក្នុងឆ្នាំ២០០១ គ្មានកុមារណាម្នាក់បន្សល់ទុកមិនបានអភិវឌ្ឍតាមច្បាប់នេះទេ(NCLB)។ ទោះបីជា NCLB គឺជានីតិកម្មដ៏ទូលំទូលាយក៏ដោយ ក៏លក្ខណៈពិសេសរបស់វា ពង្រឹងគោលវិធីអប់រំមូលដ្ឋានតាមសារវន្តនិយម។ វាកំណត់អត្តសញ្ញាណបញ្ហាសំខាន់ជាគន្លឹះ ថាជាការអាន និងគណិតវិទ្យា។ ច្បាប់នោះក៏ពឹងផ្អែកផងដែរ ទៅលើការសន្មតសារវន្តបែបថ្មី ដោយរត់ឆ្ពងកាត់តាមចលនាតាមស្តង់ដា គឺស្នាដៃសិក្សារបស់សិស្សអាចត្រូវបានវាស់វែងដោយចេតនាតាមតេស្តស្តង់ដា។

**-វាក្យសព្ទ NCLB (No Child Left Behind)**

ដើម្បីធ្វើឱ្យមានគុណសម្បត្តិ ដល់ជំនួយរបស់សហព័ន្ធខាងក្រោមវាក្យសព្ទ NCLB នោះ រដ្ឋត្រូវតែបង្កើតការវាយតម្លៃប្រចាំឆ្នាំខាងផ្នែកអំណាន និងគណិតវិទ្យា សម្រាប់គ្រប់សិស្សពីថ្នាក់ទី៣-៨។ គរុវិទូដែលគាំទ្រគោលវិធីនេះ អះអាងថា តេស្តនឹងជួយកំណត់អត្តសញ្ញាណសាលារៀន ដែលក្នុងនោះសិស្សភាគច្រើន មិនបានសម្រេចស្តង់ដា និងផ្តល់ការដោះស្រាយ ដើម្បីកែលម្អសមត្ថភាពសិក្សាជាមធ្យមរបស់សិស្ស[5]។ ច្បាប់នោះមើលឃើញថា សាលារៀននៅតាមភូមិ ស្រុក ទទួលខុសត្រូវ សម្រាប់ការកែលម្អសមត្ថភាពសិស្ស ដែលមិនទទួលបានប្រយោជន៍ ព្រមទាំងចំនួនសិស្សសរុប។ សាលារៀន និងស្រុក ដែលមិនបានធ្វើឱ្យមានការអភិវឌ្ឍប្រចាំឆ្នាំគ្រប់គ្រាន់ ត្រូវបានគេកំណត់អត្តសញ្ញាណ និងត្រូវបានគេជួយ។ ប្រសិនបើសាលារៀន មិនបានឆ្លើយតបនឹងស្តង់ដារយៈពេល៣ឆ្នាំ សិស្សអាចផ្ទេរទៅរៀនសាលារដ្ឋ ឬឯកជនល្អជាងនេះ[6]។

**២-សំណួរជាមូលដ្ឋាន**

**ក-តួនាទីសាលារៀន ដើម្បីបង្រៀនបញ្ហាសំខាន់**

គរុវិទូសារវន្តនិយម អះអាងថា សាលារៀន និងគ្រូបង្រៀន ត្រូវតែស្ថិតនៅជាមួយកិច្ចការជាបឋម ហើយមិនត្រូវបង្វែរទៅជាវិស័យមិនមែនសិក្សា។ ពួកគេប្រឆាំងជំទាស់ទៅនឹងការប្រើប្រាស់សាលារៀនក្នុងការប៉ុនប៉ង ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច និងសង្គម។ ទោះបីជាបញ្ហាទាំងនេះ អាចត្រូវបានពិនិត្យមើលក្នុងមុខវិជ្ជាដែលពាក់ព័ន្ធក៏ដោយ ក៏សាលារៀន

---

[5] No Child Left Behind (Washington, D.C.: U.S. Printng Office, 2001), p.1.

[6] No Child Left Behind, op. cit, pp.8-9.

មិនគួរត្រូវបានយកមកប្រើខាងនយោបាយ និងត្រូវបានប្រើ ដើម្បីជំរុញរបៀបវារៈសេដ្ឋកិច្ច សង្គម និងនយោបាយ។ តួនាទីដ៏សមរម្យរបស់សាលារៀន គឺត្រូវបង្រៀនសិស្សនូវបំណិនមូលដ្ឋាន និងមុខវិជ្ជា ដែលនឹងត្រៀមរៀបចំពួកគេ ឱ្យមានមុខនាទីដ៏មានប្រសិទ្ធភាពក្នុងសង្គម។

**ខ-ការយល់ស្របគ្នា បានកំណត់ដល់ព្រំដែនបញ្ហាកម្មវត្ថុមុខវិជ្ជា**

គរុវិទូសារវន្តនិយម បានយល់ស្របគ្នានឹងកម្មវិធីសិក្សា ផ្នែកកម្មវត្ថុមុខវិជ្ជាសិក្សា ដែលធ្វើឱ្យខុសគ្នា និងរៀបចំមុខវិជ្ជា ដោយយោងទៅតាមគោលការណ៍តាមលំដាប់លំដោយឬសមហេតុផលផ្ទៃក្នុង។ កម្មវិធីសិក្សាដែលមិនបានយកចិត្តដាក់រឿងអតីតកាល បដិសេធព្រំដែនកម្មវត្ថុមុខវិជ្ជា និងមានមោទនភាពពីខ្លួនឯង លើអន្តរមុខវិជ្ជា ឬឆ្លងកាត់មុខវិជ្ជាផ្សេង បណ្តាលឱ្យមានការភ័ន្តច្រឡំ ឬភាពច្របូកច្របល់លើការអប់រំ។ គរុវិទូសារវន្តនិយមពិចារណាទៅលើការរីកចម្រើនតាមរយៈកម្មវិធីសិក្សានូវលំនាំមួយដែលបន្តគ្នា។ បំណិនមូលដ្ឋាន ដូចជា ការអាន ការសរសេរ និងការគណនា មានថាមពល ដែលអាចផលិតបាន ក្នុងនោះ គេអាចផ្ទេរមុខវិជ្ជា និងមុខងារផ្សេងទៀត។ ពីបញ្ហាដ៏សំខាន់នោះ សិស្សមានភាពជឿនលឿន ទៅដល់មុខវិជ្ជាស្មុគស្មាញថែមទៀត ដែលទាមទារនូវការគិតកម្រិតខ្ពស់។

បំណិនរបស់កម្មវិធីសិក្សា និងមុខវិជ្ជាទាំងឡាយ គួរតែកំណត់ឱ្យបានច្បាស់លាស់ដល់វិសាលភាព និងមានលំដាប់លំដោយ ដែលមានបន្តគ្នា និងត្រូវបានរៀបចំ ដើម្បីរៀបចំនិស្សិតទៅថ្ងៃអនាគត។

**គ-ភាពសង្ស័យដល់នវានុវត្តន៍**

គរុវិទូសារវន្តនិយមមានការសង្ស័យជាខ្លាំងទៅលើគោលវិធីសិក្សាតាមលំនាំ ឬនវានុវត្តន៍ស្ទីគេនោះ ដូចជា ការស្តាបនានិយម ដែលក្នុងនោះ សិស្សស្ថាបនា ឬបង្កើតចំណេះដឹងរបស់ពួកគេ តាមរបៀបសហការ។ គរុវិទូសារវន្តនិយម អះអាងថា ប្រជាជនដែលមានអារ្យធម៌សិក្សាដោយមានប្រសិទ្ធភាព តាមការប្រើប្រាស់ចំណេះដឹង ដែលត្រូវបានអភិវឌ្ឍ និងរៀបចំដោយអ្នកវិទ្យាសាស្ត្រ អ្នកប្រាជ្ញ និងអ្នកជំនាញការផ្សេងទៀត។ យើងមិនចាំបាច់ប្រឌិតឡើងវិញជាបន្តបន្ទាប់នូវកង់វិលមួយ ដោយខ្ជះខ្ជាយពេលវេលា និងធនធាន តាមរបកគំហើញ អ្វីដែលគេបានដឹងរួចហើយនោះទេ។

**៣-ការអនុវត្តសម្រាប់គ្រូប្រចាំថ្នាក់នាពេលបច្ចុប្បន្ន**

**ក-ការផ្ទេរបំណិនដ៏សំខាន់ចាំបាច់**

គោលដៅអប់រំរបស់គរុវិទូសារវន្តនិយម ដើម្បីផ្ទេរនិងរក្សាធាតុចាំបាច់នៃវប្បធម៌មនុស្ស។ សាលារៀន មានកិច្ចការច្បាស់លាស់ និងជាក់លាក់ ស្តីពីការផ្ទេរបំណិន និងមុខវិជ្ជារបស់មនុស្សដ៏សំខាន់ចាំបាច់ ចំពោះយុវវ័យ

ដើម្បីឱ្យអារ្យធម៌ អាចត្រូវបានរក្សា និងបន្តទៅឱ្យមនុស្សជំនាន់ក្រោយ (Future generations)[7]។ ដើម្បីសម្រេចបានគោលដៅនេះ គ្រូបង្រៀនគួរតែៈ

១-អភិវឌ្ឍកម្មវិធីសិក្សាឱ្យបានល្អគ្រប់ជ្រុងជ្រោយ ស្តីពីបំណិន និងមុខវិជ្ជាមូលដ្ឋាន។

២-ធ្វើឱ្យជិតជាប់ក្នុងចិត្តនូវតម្លៃជាប្រពៃណីនូវការស្នេហាជាតិ ការប្រឹងប្រែងធ្វើការងារ ការខិតខំអស់សមត្ថភាព ភាពទៀងទាត់ពេលវេលា (Punctuality) គោរពអ្នកជំនាញ និងភាពចេះគួរសម (Civility)។

៣-សង្កត់ធ្ងន់ទៅលើខ្លឹមសារ ដោយផ្អែកទៅលើអារ្យធម៌លោកខាងលិច និងតម្លៃអាម៉េរិកតាមប្រពៃណី។

៤-ដំណើការថ្នាក់រៀនឱ្យមានប្រសិទ្ធភាពជាវិស័យមួយមានវិន័យ និងសណ្តាប់ធ្នាប់។

៥-ជំរុញសិស្សលើមូលដ្ឋាន នៃការសិក្សាប្រកបដោយស្នាដៃល្អ ហើយមិនមែនជាការជំរុញផ្នែកសង្គមទេ។

## ខ-មេរៀនតាមបែបគរុកោសល្យសារ វន្តនិយម

តក្កភាពគរុកោសល្យសារវន្តនិយមបន្តធ្វើតាមបែបវិចារណកិច្ច ដោយសង្កត់ធ្ងន់ទៅលើការពិតដែលប្រកបដោយជំនាញ ហើយបន្ទាប់មក ដោយផ្អែកទៅលើការធ្វើទូទៅនីយកម្មទៅលើការពិតទាំងនោះ។ ចូរពិចារណាលើការសិក្សាក្នុងថ្នាក់រៀន នៅសាលារៀនមធ្យមសិក្សាអាម៉េរិកនូវភាពខុសគ្នារវាងមេដឹកនាំជនជាតិអាម៉េរិកដើមកំណើតអាហ្វ្រិកចំនួន២នាក់ គឺលោក ប៊ុកឃ័រ ធី វ៉ាស៊ិនតោន និងដាប់បឹលល្យូ អ៊ី ប៊ី ឌុយ បូអ៊ីស (Booker T. Washington and W. E. B. Du Bois)។ ជាបឋមគ្រូដាក់កិច្ចការឱ្យសិស្សអាន ទៅលើបុរសទាំង២។ បន្ទាប់មកគាត់ដឹកនាំការពិភាក្សា ដែលក្នុងនោះសិស្សកំណត់អត្តសញ្ញាណយ៉ាងយកចិត្តទុកដាក់ ទៅលើភាពខុសគ្នារបស់ប៊ុកឃ័រធី វ៉ាស៊ិនតោននិងដាប់បឹលល្យូអ៊ីប៊ី ឌុយបូអ៊ីសតាមប្រវត្តិអតីតកាលការអប់រំ និងគោលនយោបាយ។ ក្រោយពេលមានការស្រាវជ្រាវតាមការដឹកនាំដោយគ្រូនោះសិស្សត្រូវតែឈានដល់ការវិនិច្ឆ័យមួយ អំពីមូលហេតុដែលលោក ប៊ុកឃ័រ ធី វ៉ាស៊ិនតោន និងដាប់បឹលល្យូ អ៊ី ប៊ី ឌុយ បូអ៊ីស បានធ្វើសកម្មភាពដូចដែលគេបានធ្វើរួចមក ហើយ និងវាយតម្លៃឥទ្ធិពលរបស់ពួកគេ ក្នុងនាមជាជនជាតិអាម៉េរិកដើមកំណើតអាហ្វ្រិក និងប្រវត្តិសាស្ត្រអាម៉េរិក។

---

[7] Diane Ravitch, Left Back: *A Century of Failed School Reforms* (New York: Simon and Schuster, 2000), pp. 465-467.

## សន្និដ្ឋាន

*ទ្រឹស្តីអប់រំសច្ចសកលនិយម ជាទ្រឹស្តីអប់រំដែលមានប្រភពចេញពីទ្រឹស្តីក្នុងទស្សនវិជ្ជា «តថនិយម»។ ទ្រឹស្តីនេះ មានគាំទ្រពីគរុវិទូហ៊ូឈីន, អែតល័រ និងម៉ារីថេន ហើយត្រូវបានគេយកទៅប្រតិបត្តិនៅក្នុងវិស័យអប់រំ ផ្នែកការបង្រៀន ដែលផ្តោតចំណុចសំខាន់ទៅលើការផ្ទេរ និងការឆ្លុះបញ្ចាំងសច្ចភាពនិងគុណតម្លៃនៃវប្បធម៌ដែលស្ថិតនៅយូរអង្វែង។*

*ចំណែកទ្រឹស្តីអប់រំសារវន្តនិយម ជាទ្រឹស្តីអប់រំដែលមានប្រភពចេញពីទ្រឹស្តីក្នុងទស្សនវិជ្ជា‹‹មនោនិយម និងតថនិយម››។ ទ្រឹស្តីនេះ មានគាំទ្រពីគរុវិទូបៃគ្លី និងបេស្ទ័រ ហើយ ត្រូវបានគេយកទៅប្រតិបត្តិនៅក្នុងវិស័យអប់រំផ្នែកការបង្រៀន ដើម្បីរៀបចំធ្វើបុគ្គលមានសមត្ថភាព និងប្រកបដោយបណិនសម្រាប់សេដ្ឋកិច្ចសកលដែលកំពុងមានការប្រកួតប្រជែងគ្នា។*

## ឯកសារយោង


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.
3- Robert M. Hutchins, *A Conversation on Education* (Santa Barbara, Calif., The Fund for the Republic, 1963), p. 1. See also Robert M. Hutchins, *The Learning Society* (New York: Praeger, 1968); and Hutchins, *The Higher Education in America* (New Haven, Conn.: Yale University Press,1962).
4- Mortimer J. Adler, *The Paideia Proposal: An Educational Manifesto* (New York: Macmillan, 1982); see also Mortimer J. Adler, *Paideia Problems and Possibilities* (New York: Macmillan, 1983).
5- National Commission on Excellence in Education, A Nation at Risk: *The Imperative for Educational Reform* (Washington, D.C.: U.S. Department of Education, 1983).
6- No Child Left Behind (Washington, D.C.: U.S. Printing Office, 2001).
7- Diane Ravitch, Left Back: *A Century of Failed School Reforms* (New York: Simon and Schuster, 2000).

# ប្រភពនៃទស្សនវិជ្ជាអប់រំៈ ការអភិវឌ្ឍនិយម និងការរិះគន់និយម

ដោយៈ **បណ្ឌិត សូ សុធីរ**
មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ក្នុងផ្នែកដូចតទៅ យើងនឹងពិនិត្យមើលទ្រឹស្តីអប់រំពីរគឺការអភិវឌ្ឍនិយមនិងរិះគន់និយម។ ដោយហេតុថា ទស្សនវិជ្ជាទាំងឡាយរាប់បញ្ចូលបរមត្ថវិទ្យា ពុទ្ធិវិទ្យា វិទ្យាសាស្ត្រសីលធម៌ និងតក្កវិទ្យានោះ ទ្រឹស្តីទាំងឡាយស្វែងរកការពន្យល់បាតុភូត និងលំនាំដែលមានលក្ខណៈពិសេសជាងមុន។ ទ្រឹស្តីអប់រំពន្យល់ពីតួនាទី និងមុខងារនៃសាលារៀន កម្មវិធីសិក្សា ការបង្រៀន និងការសិក្សា។ ទ្រឹស្តីមួយចំនួនបានបង្កើតចេញពីទស្សនវិជ្ជា ហើយមួយចំនួនផ្សេងទៀត កើតចេញពីការប្រតិបត្តិ។

## ១-ការអភិវឌ្ឍនិយម (Progressivism)

### ក-ចលនាកែទម្រង់ជាសកល

ការអប់រំតាមបែបអភិវឌ្ឍ គឺជាផ្នែកមួយនៃការកែទម្រង់ជាសកល ក្នុងជីវិតអាម៉េរិក នៅចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០។ ទោះជាញឹកញាប់ វាបានផ្សារភ្ជាប់គ្នាជាមួយពិសោធន៍និយមរបស់លោក Jonh Dewey ក៏ដោយ ក៏ចលនាការអប់រំបែបអភិវឌ្ឍនិយម បានវេញត្បាញបញ្ចូលគ្នានូវខ្សែផ្សេងៗ។ ដោយហេតុថា ការអភិវឌ្ឍមួយចំនួនស្វែងរកប្រើប្រាស់ការអប់រំ សម្រាប់ការកែទម្រង់សង្គមនោះ ការអភិវឌ្ឍផ្សេងទៀត ជាពិសេស អ្នករដ្ឋបាលបានផ្តោតអារម្មណ៍ទៅលើការបង្កើតសាលារៀនឱ្យមានសមត្ថភាពជាងមុន និង ចំណាយឱ្យមានប្រសិទ្ធភាពជាងមុន។ ការអភិវឌ្ឍផ្នែករដ្ឋបាល ស្វែងរកការស្ថាបនាឱ្យបានទូលំទូលាយជាងមុន ដែលអាចធ្វើឱ្យថ្នាក់រៀនបានចម្រើនជាងមុន និង បង្កើតកម្មវិធីសិក្សាផ្សេងៗគ្នា[1]។ ការអប់រំបែបអភិវឌ្ឍកើតចេញពីការប្រឆាំងនឹងការសិក្សាបែប

[1] Arthur Zilversmith, *Changing Schools: Progressive Theory and Practice, 1930-1960* (Chicago: University of Chicago Press, 1993).

ប្រពៃណី។ គរុវិទូ ដូចជាលោក G. Stanley Hall, Francis Parker, and William H. Kilpatrick បានពោលអាងប្រឆាំងនឹងទម្រង់ការដែលមិនត្រូវការបញ្ញា ការទន្ទេញដដែលៗ និងការគ្រប់គ្រងថ្នាក់រៀនបែបផ្តាច់ការ។ គ្រូបង្រៀនបែបអភិវឌ្ឍនិយមបានអភិវឌ្ឍបែបបទនិងវិធីបង្រៀន ដែលសង្កត់ធ្ងន់ទៅលើចំណូលចិត្ត និងតម្រូវការសិស្ស។ ថ្នាក់រៀនរបស់ពួកគេមានភាពបត់បែន បណ្តោយតាមចិត្ត និងបើកចំហ។

**១-១-បញ្ញត្តិជាគន្លឹះ**

**ក-ការប្រតិបត្តិដែលគាំទ្រការអភិវឌ្ឍ**

សមាគមអប់រំបែបអភិវឌ្ឍ (The Progressive Education Association) ជាអង្គការមួយ ដែលរួមបញ្ចូលពីទស្សនៈផ្សេងនោះ មិនបានធ្វើឱ្យទស្សនវិជ្ជាអប់រំមានភាពទូលំទូលាយទេ ពីព្រោះគរុវិទូបែបអភិវឌ្ឍ ជាញឹកញាប់មិនបានយល់ស្របក្នុងចំណោមពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅ គេបានថ្កោលទោសការប្រតិបត្តិសាលារៀនតាមប្រពៃណីដូចតទៅ៖

១-គ្រូបង្រៀនដែលប្រើអំណាចផ្តាច់ការ (Authoritarian teacher)។

២-ការបង្រៀន ដែលពឹងផ្អែកតែទៅលើសៀវភៅ (Book-based instruction)។

៣-ការទន្ទេញចាំមាត់បែបអកម្មនៃព័ត៌មានពិត (Passive memorization of factual information)។

៤-ការផ្តាច់សាលាចេញពីសង្គម (The isolation of school from society)។

៥-ការប្រើការបង្ខិតបង្ខំតាមបែបចិត្តសាស្ត្រ និងរាងកាយ ដើម្បីគ្រប់គ្រងថ្នាក់រៀន (Using physical and psychological coercion to manage classrooms)។

ទោះបីជាពួកគេមានការលំបាកខ្លាំងជាងក្នុងការយល់ព្រមអំពីអ្វីដែលគេពេញចិត្តក៏ដោយ ក៏សមាជិកនៃសមាគមគ្រូបង្រៀនបែបអភិវឌ្ឍជាទូទៅ ជឿជាក់ថា៖

១-កុមារគួរតែមានសេរីភាព ដើម្បីអភិវឌ្ឍតាមធម្មជាតិ។

២-ចំណូលចិត្ត ដែលត្រូវបានក្រោចដោយបទពិសោធផ្ទាល់នោះ គឺជារំញោចដ៏ប្រសើរបំផុតសម្រាប់ការសិក្សា។

៣-គ្រូបង្រៀនគួរតែជួយសម្រួលដល់ការសិក្សា។

៤-សហប្រតិបត្តិការជិតស្និទ្ធ មានសារៈសំខាន់បំផុត រវាងសាលារៀននិងគ្រួសារ។

៥-សាលារៀនដែលមានការអភិវឌ្ឍ គួរតែជាមន្ទីរពិសោធន៍ សម្រាប់ធ្វើការពិសោធ។

### ខ-កំណែទម្រង់បែបអភិវឌ្ឍ នៅតាមសាលារៀន

ដោយប្រឆាំងជំទាស់នឹងកម្មវិធីសិក្សាតាមកម្មវត្ថុមុខវិជ្ជាធម្មតានោះ អភិវឌ្ឍន៍វិទូបានធ្វើពិសោធន៍ជាមួយនឹងកម្មវិធីសិក្សាផ្សេងគ្នា ការប្រើប្រាស់សកម្មភាពទាំងឡាយបទពិសោធ ការដោះស្រាយបញ្ហា និងគម្រោងការផ្សេងៗ។ គ្រូបង្រៀនតាមបែបអភិវឌ្ឍសិស្សមជ្ឈមណ្ឌលក៏បានសង្កត់ធ្ងន់ទៅលើការសិក្សាបែបសហការ ជាជាងការប្រកួតប្រជែង។ អភិវឌ្ឍន៍វិទូ ដែលបានតម្រង់ទិសផ្នែកសង្គមច្រើនជាងនោះ ដែលត្រូវបានគេហៅថា អ្នកស្ថាបនាសង្គមឡើងវិញ បានស្វែងរកបង្កើតមជ្ឈមណ្ឌលសាលារៀន នៃការកែទម្រង់ផ្នែកសង្គមធំជាងមុន[2]។ ជាងនេះទៀត សាលារៀនបែបអភិវឌ្ឍ ជាពិសេសផ្នែកឯកជនបានស្វែងរកផ្តល់សេរីភាពដល់កុមារពីសេចក្តីអត់ធ្មត់ និងការទប់តាមធម្មតា។

### ១-២-សំណួរជាមូលដ្ឋាន

### ក-ការប្រឆាំងនឹងប្រពៃណី

អភិវឌ្ឍន៍វិទូ មិនចូលចិត្តសិទ្ធាន្ត និងមិនឆ្លើយតបទៅនឹងសំណួរអំពីចំណេះដឹងការអប់រំ សាលារៀន ការបង្រៀន និងការសិក្សាដោយមានសំឡេងតែមួយទេ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងន័យជាទូទៅ អភិវឌ្ឍន៍វិទូ យល់ឃើញថា ចំណេះដឹងជាបទពិសោធមនុស្ស ដែលមានទំនាក់ទំនងនឹងគ្នា ជាជាងក្នុងន័យជាសកល។ ការអប់រំ គឺជាមធ្យោបាយមួយនៃការបញ្ចេញប្រតិដ្ឋញាណរបស់មនុស្សតាមការគិត និងការទទួលអារម្មណ៍។ អភិវឌ្ឍន៍វិទូ ជឿជាក់ថា កុមារទាំងអស់មានសិទ្ធិទៅរៀន។

### ខ-កំណែទម្រង់វិទូផ្នែកសង្គម និងផ្នែកសិស្សមជ្ឈមណ្ឌល

ទោះបីជាបានរួបរួមគ្នា ដើម្បីប្រឆាំងនឹងប្រពៃណីនិយម និងផ្តាច់ការនិយមក៏ដោយ ក៏អភិវឌ្ឍន៍វិទូ បានសង្កត់ធ្ងន់ទៅលើសេរីភាពកុមារ ហើយអ្នកផ្សេងទៀត សង្កត់ធ្ងន់ទៅលើកំណែទម្រង់សង្គម។ អភិវឌ្ឍន៍វិទូផ្នែកសិស្សមជ្ឈមណ្ឌល ចង់ឱ្យសាលារៀនដែលក្នុងនោះ កុមារ មានសេរីភាព ដើម្បីធ្វើពិសោធន៍ លេង និងបង្ហាញអារម្មណ៍ពីខ្លួនគេ។ អភិវឌ្ឍន៍វិទូផ្នែកកំណែទម្រង់សង្គម ចង់ឱ្យសាលារៀនធ្វើជាភ្នាក់ងារនៃការផ្លាស់ប្តូរផ្នែកសង្គម។

### គ-ភាពត្រៀមជាស្រេច ចំណូលចិត្ត និងតម្រូវការ

ចំពោះអភិវឌ្ឍន៍វិទូនិយម ភាពត្រៀមខ្លួនជាស្រេចរបស់កុមារ និងចំណូលចិត្ត និងមិនមែនជាប្រធានបទ ដែលបានកំណត់ជាមុន

[2] The definitive history of progressive education remains Lawrence A. Cremin, *The Transformation of the School* (New York: Random Handom House, 1961).

បង្កើតកម្មវិធីសិក្សានិងការបង្រៀន។ គ្រូបង្រៀនតាមបែបអភិវឌ្ឍ ដែលចេះបត់បែនការបង្រៀនប្រើប្រាស់លទ្ធភាព នៃសកម្មភាពសិក្សា ដូចជាការដោះស្រាយបញ្ហា ដំណើរកម្សាន្តសិក្សា ការបង្ហាញអារម្មណ៍បែបសិល្បៈប្រតិដ្ឋ និងគម្រោងការផ្សេងៗ។ ពួកគេមើលឃើញការបង្រៀន និងការសិក្សាថាជាលំនាំសកម្ម គួរឱ្យរំភើបចិត្ត និងមានការផ្លាស់ប្តូរ។

### ឃ-ការស្ថាបនាគតិភាព

ក្នុងនាមជាអ្នកស្ថាបនាសហគមន៍អប់រំនោះ គ្រូបង្រៀនបែបអភិវឌ្ឍ ចង់ឱ្យសិស្សសិក្សាតាមបែបសហការទៅលើគម្រោងផ្សេងៗ ដោយពឹងផ្អែកទៅលើបទពិសោធរួមរបស់គេ។ គោលវិធីនេះ មានភាពស្រដៀងគ្នា ទៅនឹងគោលវិធីស្ថាបនានិយមដ៏មានប្រជាប្រិយ។ ស្ថាបនានិយមដូចជាអភិវឌ្ឍនិយម សង្កត់ធ្ងន់ទៅលើការសិក្សាតាមការប្រតិបត្តិ និងអន្តរកម្ម ដែលក្នុងនោះសិស្ស សិក្សាតាមបែបសហការ ដើម្បីពង្រីក និងពិនិត្យ កែតម្រូវមូលដ្ឋានចំណេះដឹងរបស់គេ[3]។

## ១-៣-ការអនុវត្ត សម្រាប់ក្រុម ខ្ញុំរៀនទទួលបន្ទុកថ្នាក់នាពេលសព្វថ្ងៃ

### ក-គំរូនៃល្បិចអភិវឌ្ឍ

តើល្បិចអភិវឌ្ឍ អាចដំណើរការក្នុងសាលារៀនសព្វថ្ងៃបែបណា? ថ្នាក់រៀនសិក្សាសង្គមនៅអនុវិទ្យាល័យ អាចពិនិត្យមើលការរួមចំណែករបស់ពួកឡាតាំង ចំពោះជីវភាពរស់នៅសម្រាប់ប្រជាជនអាម៉េរិក។ ក្រោយពេលកំណត់ន័យពាក្យឡាតាំង និងការកំណត់អត្តសញ្ញាណក្រុមជាតិពន្ធុផ្សេងៗ (Ethnic groups) ដែលបានរាប់បញ្ចូលក្នុងការជ្រើសរើសទុកជាមុននោះ ថ្នាក់រៀន អាចត្រូវបានបែងចែកទៅជាក្រុមស្រាវជ្រាវ និងក្រុមរាយការណ៍។ ក្រុមនីមួយៗនឹងផ្តោតអារម្មណ៍ ទៅលើក្រុមឡាតាំង (ក្រុមជាតិពន្ធុដូចជា ព័រតូរីកូអាម៉េរិក (Puerto Rican Americans), គុយបាអាម៉េរិក (Cuban Americans) និងក្រុមជាតិពន្ធុ១៥ក្រុមទៀត ដែលមានដើមកំណើតចេញពីជនជាតិអេស្ប៉ាញ) ពិសេស និងត្រៀមរបាយការណ៍ ដែលនឹងត្រូវបានបែងចែកតាមបែបសហការជាមួយសិស្សក្នុងថ្នាក់រៀន។ សកម្មភាពរបស់ក្រុមអាចរាប់បញ្ចូលដូចតទៅៈ

ក្រុម **ក** នឹងតាមដានដើមកំណើត ការផ្លាស់ប្តូរលំនៅតំបន់នៃនិវាសនដ្ឋានចម្បងៗ និងបញ្ហានៃជនជាតិអាម៉េរិក ដើមកំណើតម៉ិកស៊ិក។

ក្រុម **ខ** នឹងដឹកនាំការស្រាវជ្រាវស្រដៀងគ្នាទៅលើក្រុមព័រតូរីកូអាម៉េរិក។

ក្រុម **គ** នឹងធ្វើដូចគ្នាទៅលើក្រុមគុយបាអាម៉េរិក។ ក្រុមទាំងឡាយនឹងត្រូវបាន

[3] For a discussion of the challenges of translating constructivist epistemology into classroom practice, see Peter W. Airasian and Mary E. Walsh, ''Constructivist Cautions,'' *Phi Delta Kappan* (February 1997), pp. 444-449.

លើកទឹកចិត្ត ដើម្បីបង្កើតរបាយការណ៍ពហុវិសាលភាព (របាយការណ៍រួមក្រុមទាំង៣ខាងលើ) ដែលប្រើប្រាស់សម្ភារៈបោះពុម្ព ភាពយន្ត ការពន្យល់ដោយរូបភាព និងអញ្ជើញវាគ្មិន ដែលជាតំណាងក្រុមពិសេស។ បន្ទាប់មកក្រុមទាំងមូល ដែលក្នុងនាមជាបទពិសោធសិក្សាតាមបែបសហការនោះ នឹងប្រើប្រាស់របាយការណ៍ក្រុមដើម្បីកំណត់អត្តសញ្ញាណភាពដូចគ្នា និងភាពខុសគ្នាខាងវប្បធម៌ រវាងក្រុមជាតិពន្ធុទាំង៣ និងការរួមចំណែករបស់សង្គមអាម៉េរិក។

គ្រូបង្រៀន គួរតែធ្វើសកម្មភាពនៅក្នុងនាមជាអ្នកសម្របសម្រួលខាងធនធាន នៅក្នុងគម្រោងផែនការ។ តាមការប្រឹក្សាជាមួយក្រុមនីមួយៗគាត់នឹងផ្តល់យោបល់ឱ្យទៅបណ្ណាល័យ អ៊ិនធឺណិត និងប្រភពធនធានពីសហគមន៍ និងជួយសិស្សរកឃើញមធ្យោបាយ ផ្សេងៗ នៃការស្រាវជ្រាវទៅតាមគម្រោង និងដោះស្រាយបញ្ហា ដែលវាបានបង្ហាញ។ គ្រូគួរតែដឹកនាំសិស្សផងដែរ ក្នុងការបែងចែកព័ត៌មាន និងឈានទៅដល់ការសន្និដ្ឋានតាមបែបសហការ។

## ២-ទ្រឹស្តីបែបរិះគន់ (Critical Theory)

ទ្រឹស្តីតាមបែបរិះគន់ ដែលជាទ្រឹស្តីនៃការអប់រំសម័យទំនើប ដ៏មានឥទ្ធិពលកម្រិតខ្ពស់នោះ ជំរុញឱ្យមានការរិះគន់ តាមការវិភាគយ៉ាងហ្មត់ចត់នៃសាលារៀន និងសង្គម ដើម្បីលាតត្រដាងទំនាក់ទំនងអំណាច តាមបែបកេងប្រវ័ញ្ច និងនាំមកដល់សមភាពភាពត្រឹមត្រូវ និងយុត្តិធម៌។ ការប៉ាន់ស្មានតាមទ្រឹស្តីជាច្រើន កើតចេញពីទស្សនវិជ្ជាបែបអត្ថិភាពនិយម និងសម័យក្រោយទំនើបនិយម ម៉ាក្សស៊ីស្តនិយមបែបថ្មី ទ្រឹស្តីពហុវប្បធម៌និងស្ត្រីនិយម ហើយនិងគរុកោសល្យសេរីរបស់លោក Paulo Freire។ ក្នុងចំណោមអ្នកដឹកនាំដែលបានបង្ហាញខ្ពួនកម្រិតខ្ពស់នៃទ្រឹស្តីរិះគន់និយមគឺ Henry Giroux និង Peter McLaren។

### ២-១-បញ្ញត្តិជាគន្លឹះ

### ក-ឥទ្ធិពលម៉ាក្សស៊ីស្តបែបថ្មី

ទ្រឹស្តីបែបរិះគន់ ត្រូវបានទទួលឥទ្ធិពលតាមមនោគមវិជ្ជា កាលម៉ាក្ស (Karl Marx) ដែលជាទស្សនវិទូនាសតវត្សរ៍ទី១៩ ដ៏សំខាន់ម្នាក់ ដែលបានអះអាងថា ស្ថាប័នទាំងអស់ពឹងផ្អែកទៅលើមូលដ្ឋានសេដ្ឋកិច្ច ហើយប្រវត្តិសាស្ត្រមនុស្ស ជាការតស៊ូ ដើម្បីវណ្ណៈសេដ្ឋកិច្ចសង្គម សម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គម[4]។ ជាញឹកញាប់ ទ្រឹស្តីវិទូបែបរិះគន់ប្រើប្រាស់បញ្ញត្តិ តាមទ្រឹស្តីម៉ាក្សដូចជាទំនាស់វណ្ណៈ និងភាពបែកបាក់។ ភាពបែកបាក់គ្នានិយាយយោងដល់សភាពបែបចិត្តសាស្ត្រ និង

[4] For an assessment of Marxist education theory, see Frank Margonis, "Marxist, Liberalism, and education Theory, *Educational Theory* (Fall 1993), pp. 449-465.

សង្គម នៃមនុស្សដែលត្រូវបានគេចាត់ទុកថា មិនសំខាន់ និងត្រូវបានជំរុញដល់មនុស្សទ្រនាប់សង្គម។

### ខ-ក្រុមដ៏មានឥទ្ធិពល មានចំនួនច្រើនជាង

ដោយយោងទៅតាមទ្រឹស្តីវិទូបែបរិះគន់ មនសិការបែបរិះគន់ ទាមទារនូវការទទួលបានពុទ្ធិ ដែលជាវណ្ណៈសង្គមរបស់បុគ្គល ដោយរាប់បញ្ចូលទាំងសេចក្តីសង្ឃឹម និងឱកាស ផ្នែកសេដ្ឋកិច្ច និងសង្គមនោះ គឺត្រូវមានលក្ខខណ្ឌតាមជាតិសាសន៍ សមធម៌ភេទ និងវណ្ណៈ។ វណ្ណៈសេដ្ឋកិច្ចសង្គមខ្ពស់ជាង និងគ្របដណ្តប់ ដែលគ្រប់គ្រងស្ថាប័នអប់រំ សេដ្ឋកិច្ច នយោបាយ និងសង្គម ប្រើប្រាស់ឥទ្ធិពល ដើម្បីរក្សា ឬបង្កើតឡើងវិញនូវតំណែងដោយគួរពេញចិត្ត និងដើម្បីទុកជាភាពបន្ទាប់បន្សំនូវវណ្ណៈ ដែលមិនមានប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងសង្គម[5]។

នៅក្នុងសហរដ្ឋអាមេរិក ក្រុមដែលនៅក្រោមបង្គាប់ជាប្រវត្តិសាស្ត្រ គឺក្រុមនៅតំបន់ជាយក្រុងនិងអ្នកក្រ នៅជនបទ ពួកអាមេរិកដើមកំណើតអាហ្វ្រិក និងជនជាតិដើមឡាតាំង ស្ត្រី ប្រុស និងស្រីរួមភេទដូចគ្នា[6]។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការអប់រំបែបរិះគន់វណ្ណៈ និងក្រុម ដែលនៅក្រោមបង្គាប់ អាចដឹងពីការកេងប្រវ័ញ្ចរបស់គេ ប្រឆាំងនឹងការគាបសង្កត់ បដិសេធគំរូនៃការជិះជាន់ និងផ្តល់អំណាចដោយខ្លួនឯង។

## ២-២-សំណួរជាមូលដ្ឋាន

### ក-ទស្សនវិជ្ជាសាធារណៈថ្មីមួយ

ដោយបានទាក់ទាញឥទ្ធិពលដ៏ធំធេងពីទស្សនវិទូសម័យក្រោយទំនើបនិយម ដែលបានរៀបរាប់ពីមុនក្នុងជំពូកនេះ ទ្រឹស្តីវិទូបែបរិះគន់ ចង់សរសើរមនសិការអំពីបញ្ហា ដែលពាក់ព័ន្ធនឹងចំណេះដឹង ការអប់រំ សាលារៀន ការបង្រៀន និងរៀន។ គេជឿជាក់ថា ចំណេះដឹង គឺជាបញ្ហានៃអំណាច និងការគ្រប់គ្រងផ្នែកអប់រំ សេដ្ឋកិច្ច នយោបាយ និងសង្គម។ ជាពិសេស ទ្រឹស្តីវិទូបែបរិះគន់ចង់សរសើរដល់មនសិការនៃអ្នកទាំងឡាយ ដែលត្រូវបានគេជំរុញឱ្យកាន់តំណែង ដែលនៅក្រោមបង្គាប់ក្នុងសង្គម ដោយសារតែជាតិសាសន៍ ក្រុមជនជាតិ ភាសា វណ្ណៈ ឬសមធម៌ភេទ[7]។

---

[5] Martin Carnoy, ''Education, State, and Culture in American Society,'' in Henry A. Giroux and Peter L. Mclaren, eds., *Critical Pedagogy, the State, and Cultural Struggle* (Aldany: State University of New York Press, 1998), pp.6-7

[6] Angeline Martel and Linda Peterat, ''Margins of Exclusion, Margins of Transformation: The Place of Women in Education, '' in Rebecca A. Martusewicz and William Reynold, eds., *Inside/ Out: Contemporary Critical Perspectives in Education* (New York: St. Martin's Press, 1994),pp. 151-154.

[7] Henry A. Giroux and Peter L. McLaren, ''Schooling, Cultural Politics, and the Struggle for Democracy, ''in Henry A. Giroux and Peter McLaren, eds., *Critical Pedagogy, the State, and Cultural Struggle* (New York: State University of New York Press, 1989),pp. xi-xii.

## ខ-ការគ្រប់គ្រងសង្គម

ទ្រឹស្តីវិទូបែបរិះគន់អះអាងថា វណ្ណៈដ៏សំខាន់តាមបែបសង្គម នយោបាយ សេដ្ឋកិច្ច ត្រួតពិនិត្យ និងប្រើប្រាស់សាលារៀន សម្រាប់ការថែរក្សា និងត្រួតពិនិត្យសង្គម។ ដើម្បីថែរក្សាស្ថានភាពដដែល ដែលផ្តល់ឱ្យពួកគេនូវតំណែងដែលត្រូវការនោះ កុមារនៃវណ្ណៈសំខាន់ៗ ចូលសិក្សា នៅតាមស្ថាប័នអប់រំប្រកបដោយភាពថ្លៃថ្នូរ ហើយទទួលការអប់រំ ដែលរៀបចំពួកគេ សម្រាប់មុខរបរកម្រិតខ្ពស់ខាងជំនួញ ឧស្សាហកម្ម និងរដ្ឋាភិបាល។ កុមារស្ថិតក្នុងវណ្ណៈ និងក្រុមក្រោមការគ្រប់គ្រងរបស់គេ ត្រូវបានអប់រំឱ្យទទួលយកលក្ខខណ្ឌដែលដកហូតអំណាចរបស់ពួកគេ ថាជាពិភពដ៏ប្រសើរបំផុត។ ជាឧទាហរណ៍ សាលារៀននៅតំបន់ជាយក្រុង ដែលមិនបានផ្តល់ប្រយោជន៍ខាងសេដ្ឋកិច្ច និងការធ្វើឱ្យចុះអន់ថយនៅតំបន់ជនបទនោះ បម្រើតែអ្នកក្រ ជនជាតិអាម៉េរិកដើមកំណើតអាហ្វ្រិក និងឡាតាំង។ ដោយមិនបានផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់ ជាញឹកញាប់សាលារៀនទាំងនេះ ជាកន្លែងដែលមានអគារ មិនសមរម្យ និងខ្វះខាតធនធានចាំបាច់។

## គ-ការផ្តល់អំណាចដល់គ្រូ

សាលារៀននៅក្នុងក្រុង និងសាលារៀនជាច្រើនផ្សេងទៀតផងដែរ មានការជាប់ពាក់ព័ន្ធទៅនឹងការិយាធិបតេយ្យអប់រំយ៉ាងច្រើន។ ស្ថិតក្នុងសាលារៀនមួយ គ្រូបង្រៀនទាំងឡាយហាក់ដូចជាត្រូវបានផ្តាច់ចេញពីគេក្នុងថ្នាក់រៀនខ្លួនឯង។ ជាងនេះទៀត មាតាបិតា និងអ្នកផ្សេងទៀត នៅក្នុងសហគមន៍មូលដ្ឋានត្រូវបានរក្សាឱ្យនៅចម្ងាយមួយដោយមានការពាក់ព័ន្ធ និងអន្តរកម្មតិចតួចជាមួយសាលារៀន។ កម្មវិធីសិក្សាផងដែរ ត្រូវបានកំណត់ដោយអ្នករដ្ឋបាលកម្រិតខ្ពស់ជាងដោយមានកន្លែងតូចមួយសម្រាប់អ្នកផ្តួចផ្តើមនៅមូលដ្ឋាន ដែលពាក់ព័ន្ធដល់បទពិសោធជីវិតរបស់សិស្សឬមនុស្សក្នុងសហគមន៍។

## ឃ-កម្មវិធីសិក្សាជាផ្លូវការ

ទ្រឹស្តីវិទូបែបរិះគន់ មើលឃើញកម្មវិធីសិក្សា ថាមានអត្ថិភាពក្នុងវិស័យពីរ គឺកម្មវិធីសិក្សាជាផ្លូវការ (Formal official curriculum) និងកម្មវិធីសិក្សាបែបលាក់កំបាំង។ កម្មវិធីសិក្សា ដែលមានអាណត្តិជាផ្លូវការ មានផ្ទុកដោយបំណិន និងមុខវិជ្ជាដែលត្រូវបង្រៀនទៅតាមគោលបំណងនិងត្រូវបានផ្ទេរទៅឱ្យសិស្សទាំងឡាយ។ កម្មវិធីសិក្សាបែបលាក់កំបាំង (Hidden curriculum) បង្ហាញឱ្យឃើញអាកប្បកិរិយា និងឥរិយាបថ ដែលត្រូវបានបង្ខំទៅលើសិស្ស តាមរយៈមជ្ឈដ្ឋានសាលារៀន។ ទ្រឹស្តីវិទូបែបរិះគន់ ផ្តល់យោបល់ថា កម្មវិធីសិក្សាទាំងពីររក្សាឱ្យមានឋានៈវណ្ណៈសង្គមដ៏សំខាន់។

ថ្នាក់រៀនដ៏សំខាន់ ប្រើប្រាស់កម្មវិធីសិក្សាជាផ្លូវការ ដើម្បីផ្ទេរជំនឿ និងតម្លៃពិសេស ដែលជាកំណែប្រែថ្មី តាមធម្មានុរូប (Legitimate)នៃចំណេះដឹងសម្រាប់សិស្ស។ ឧទាហរណ៍ កំណែប្រែថ្មីនៃប្រវត្តិសាស្ត្រជាផ្លូវការពិពណ៌នាពីបទពិសោធជនជាតិអាម៉េរិកដែលទទួលជ័យជម្នះ ក្នុងការតាំងទីលំនៅ និងការធ្វើឧស្សាហូបនីយកម្ម។ ជនជាតិអាម៉េរិកដើមកំណើតអាហ្វ្រិក និងជនជាតិដើមព្រមទាំងពួកឡាតាំង ត្រូវបានដាក់ជាជន ដែលទាក់ទងទៅនឹងនិទានកថាជាផ្លូវការ។ ទ្រឹស្តីវិទូបែបរិះគន់ គូសបញ្ជាក់ថាវិធីបង្រៀនដ៏ពេញចិត្តជាងគេរបស់សាលារៀនជាច្រើន គឺត្រូវប្រើប្រាស់សៀវភៅសិក្សា ដែលបានអនុម័តជាផ្លូវការ (Official sanctioned textbooks) ដើម្បីផ្ទេរព័ត៌មាន ដែលបានកែលម្អរួចហើយទៅឱ្យសិស្ស។ជំនួសឱ្យការគិតនិងការវិភាគដ៏ល្អិតល្អន់ លំនាំនៃការផ្ទេរព័ត៌មាន បង្កើតឡើងវិញក្នុងខ្លួនសិស្ស នូវចំណេះដឹងថ្មីជាផ្លូវការ។

## ខ-កម្មវិធីសិក្សាបែបលាក់កំបាំង

ជាតុជាគន្លឹះមួយក្នុងការគ្រប់គ្រងសង្គម ដោយផ្អែកទៅលើសាលារៀន ត្រូវបានផ្ទុកជាកម្មវិធីសិក្សាបែបលាក់កំបាំង។ លាក់កំបាំង ពីព្រោះវាមិនត្រូវបានអះអាង តាមការអះអាងជាសាធារណៈនូវអាណត្តិ ឬគោលនយោបាយសាលារៀន នៅតាមមូលដ្ឋាន វាបានជ្រួតជ្រាប នៅក្នុងមជ្ឈដ្ឋានសាលារៀនសាធារណៈ។

ឧទាហរណ៍ ឥរិយាបថតាមភេទ ដែលមនុស្សប្រុសមានភាពប្រសើរជាងមនុស្សស្រីខាងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ រក្សានូវគំរូដាក់លាក់ខាងសមធម៌ភេទ ដែលអាចបន្តការអប់រំ និង មុខរបរក្នុងវិស័យទាំងនោះ។

ទោះបីជាថ្នាក់រៀនដែលត្រូវបានផ្តល់អភ័យឯកសិទ្ធិ មាននៅក្នុងសាលារៀនសំខាន់ៗជាប្រវត្តិសាស្ត្រក៏ដោយ ក៏ទ្រឹស្តីវិទូបែបរិះគន់មិនបានមើលឃើញភាពសំខាន់ ឬប្រើអំណាចថាជារឿងជៀសមិនរួចនោះទេ។ ពួកគេបានប្រឆាំងនឹងគំរូថ្មីៗនៃការគ្រប់គ្រង និងការសិក្សាដើម្បីផ្តាច់វដ្តនៃភាពសំខាន់ ឬការប្រើអំណាច។ ពួកគេជឿជាក់ថា គ្រូបង្រៀន និងសាលារៀនអាចជួយបង្កើនញាណនៃមនុស្ស ដែលត្រូវបានគេកេងប្រវ័ញ្ច និងផ្តល់អំណាចឱ្យដកហូតទ្រព្យសម្បត្តិ។ ពួកគេចង់ឱ្យសាលារៀន ក្លាយជាវិស័យសាធារណៈបែបប្រជាធិបតេយ្យ ដែលក្នុងនោះយុវវ័យ ចង់សិក្សា ដើម្បីពង្រោះសីលវិជ្ជានៃសមភាព។

## ច-ដំណើររឿងជីវិតរបស់សិស្ស

ទ្រឹស្តីវិទូបែបរិះគន់ អះអាងថា ចំណេះដឹងស្របច្បាប់ដ៏ពិត និងតម្លៃក្នុងសាលារៀន និងកម្មវិធីសិក្សា ដែលកើតមានឡើងនៅក្នុងសហគមន៍មូលដ្ឋានរបស់សិស្ស ស្ថានភាពភ្លាមៗ និងសហគមន៍ដែលគេរស់នៅ និងសាលារៀន

ដែលគេកំពុងសិក្សា។ គ្រូគួរតែចាប់ផ្តើមបង្កើនញាណជាមួយសិស្សក្នុងថ្នាក់រៀនរបស់ខ្លួនតាមការពិនិត្យមើលលក្ខខណ្ឌតាមសហគមន៍អ្នកជិតខាង។ សិស្សអាចបែងចែកដំណើររឿងជីវិតរបស់គេ ដើម្បីបង្កើតស្វ័យជីវប្រវត្តិក្រុមបែបសហការ ដែលរ៉ាយរ៉ាប់បទពិសោធនៅតាមផ្ទះ សាលារៀន និងសហគមន៍។ គេអាចភ្ជាប់ថែមទៀតនូវស្វ័យជីវប្រវត្តិក្រុមនេះ ទៅនឹងដំណើររឿងធំជាងនេះនៃថ្នាក់រៀនសេដ្ឋកិច្ចតាមទស្សនវិស័យ និងក្រុមភាសា ជនជាតិភាគតិច និងជាតិសាសន៍។

សង្គមពហុវប្បធម៌សហរដ្ឋអាម៉េរិកដ៏ពិតប្រាកដ ផ្តល់នូវកំណែប្រែថ្មីច្រើនថែមទៀតនូវដំណើររឿងតាមបទពិសោធរបស់ជនជាតិអាម៉េរិក ជាជាងបទពិសោធដែលបានយល់ស្របជាផ្លូវការ។ សមាជិកនៃក្រុមភាសា ជនជាតិភាគតិច ពូជសាសន៍ អាចប្រាប់ដំណើររឿងផ្ទាល់ខ្លួនរបស់គេជាជាងឱ្យគេប្រាប់ដំណើររឿងដល់ពួកគេ។ ក្រោយពេលស្រាវជ្រាវរកឃើញអត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេ សិស្សអាចអភិវឌ្ឍមធ្យោបាយរបស់គេដើម្បីទទួលស្គាល់លក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈ និងការរកឃើញផ្សេងពីភាពពិត និងដើម្បីប្រឆាំងទៅនឹងការអប់រំទាំងក្នុងនិងក្រៅសាលារៀន។ គេអាចសិក្សាពីរបៀបគ្រប់គ្រងជីវិតផ្ទាល់ខ្លួន និងបង្កើតអនាគតផ្ទាល់ខ្លួន[8]។

**២-៣-ការអនុវត្ត សម្រាប់គ្រូប្រចាំថ្នាក់រៀននាពេលសព្វថ្ងៃ**

**ក-គ្រូបង្រៀនត្រូវតែផ្តល់អំណាចដល់ខ្លួន**

ទ្រឹស្តីវិទូបែបរិះគន់ ជំរុញឱ្យគ្រូ៖

១-រកឱ្យឃើញមិត្តពិតប្រាកដរបស់គេជានរណា ស្ថិតក្នុងការតស៊ូ ដើម្បីគ្រប់គ្រងសាលារៀនឱ្យបានជោគជ័យ។

២-សិក្សាថា នរណាជាសិស្សរបស់គេតាមការជួយពួកគេ ដើម្បីសិក្សាឆ្ពោះទៅរកអត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេ។

៣-សហការជាមួយប្រជាជននៅមូលដ្ឋានដើម្បីសាលារៀន និងការកែលំអសហគមន៍

៤-ចូលរួមជាមួយនឹងគ្រូ ដែលមានចិត្តដូចគ្នា ក្នុងអង្គការចាត់តាំងវិជ្ជាជីវៈគ្រប់គ្រងដោយគ្រូ ដែលធ្វើការងារដើម្បីកែទម្រង់ការអប់រំដ៏ពិតប្រាកដ។

៥-ចូលរួមនៅក្នុងការសន្ទនាបែបរិះគន់អំពីបញ្ហាអប់រំ សង្គម សេដ្ឋកិច្ច និងនយោបាយដែលប្រឈមមុខនឹងសង្គមអាម៉េរិក។

**ខ-ស្តង់ដា និងការវាយតម្លៃ**

**-ដែនកំណត់ខាងក្រៅស្តីអំពីអំណាចរបស់គ្រូ**

តាមលក្ខខណ្ឌធ្វើការងាររបស់គ្រូបែបរិះគន់ ទ្រឹស្តីវិទូបែបរិះគន់រកឃើញឥទ្ធិពល

[8] Christine E. Sleeter and Peter L. Mclaren, eds. *Multicultural Education, Critical Pedagogy, and the Politics of Difference* (Albany: State University of New York Press, 1995).

របស់គ្រូ ក្នុងការកំណត់ជីវភាពវិជ្ជាជីវៈផ្ទាល់ខ្លួនរបស់គេ ដែលត្រូវបានកំណត់ដែនដ៏ជាក់លាក់។ ក្រុមប្រឹក្សារដ្ឋ ដែលមិនមែនជាអង្គការចាត់តាំងវិជ្ជាជីវៈរបស់គ្រូមួយភាគធំ កំណត់ឱ្យការទាមទារចូលទៅជាវិជ្ជាជីវៈ។ នៅពេលដែលសមត្ថភាពសិស្ស តាមតេស្តសមិទ្ធផលសិក្សា តាមស្តង់ដា កំណត់នូវប្រសិទ្ធភាពសាលារៀន និងសមត្ថភាពគ្រូនោះ គ្រូបង្រៀនត្រូវបានវិនិច្ឆ័យ តាមលក្ខណៈវិនិច្ឆ័យ ដែលត្រូវបានប្រគល់អាណត្តិ ដោយអ្នកច្បាប់រដ្ឋ និងត្រូវបានរៀបចំ ដោយអ្នកជំនាញការ ដែលនៅខាងក្រៅសាលារៀន និងថ្នាក់រៀន។

**-បញ្ហាសិទ្ធិប្រើប្រាស់បច្ចេកវិទ្យា**

លោក Michael Apple ជាអ្នកអប់រំ ដែលបានវិភាគកម្មវិធីសិក្សាពីការតម្រង់ទិសម៉ាក្សស៊ីស្តបែបថ្មីនោះ ព្រមានថា ការពិភាក្សាយ៉ាងច្រើន អំពីបច្ចេកវិទ្យាអប់រំក្នុងថ្នាក់រៀន មានលក្ខណៈជាវោហារសាស្ត្រជាជាងជំរុញចិត្ត សម្រាប់ការផ្លាស់ប្តូរដ៏ពិតប្រាកដ។ គាត់ជឿជាក់ថា បញ្ហាពិតប្រាកដ គោរពគោលបំណងនៃបច្ចេកវិទ្យាអប់រំ។ ប្រសិនបើបច្ចេកវិទ្យាអប់រំមិនបានជួយលាតត្រដាងបញ្ហា ដែលជាឫសគល់នៃភាពដោយឡែកនិងការលើកតម្កើងទ្រឹស្តីវិទូបែបរិះគន់ ដែលមិនសូវសម្បូរនោះ វាទំនងជានឹងនាំបែបបទ ដែលមិនទាន់រៀបចំបានត្រឹមត្រូវ មិនជិតស្និទ្ធ ដែលកើតចេញមកពីផ្នែកខាងក្រៅក្នុងការអប់រំជាជាងបញ្ហាមួយ ដែលកើតចេញពីលក្ខខណ្ឌខាងក្រៅសាលារៀន[៩]។

**-មេរៀនមួយ តាមគោលវិធីទ្រឹស្តីបែបរិះគន់**

គ្រូបង្រៀនដែលប្រើប្រាស់គោលវិធីទ្រឹស្តីបែបរិះគន់ អាចរៀបចំមេរៀន ដែលសម្រាប់សិស្សមុខវិជ្ជាសិក្សាសង្គម នៅអនុវិទ្យាល័យ ស្រាវជ្រាវរកមរតកជនជាតិភាគតិច និងពូជសាសន៍របស់គេ។ សិស្សចាប់ផ្តើមតាមការបែងចែកចំណាប់អារម្មណ៍របស់គេអំពីមរតកតាមរយៈការនិទានប្រាប់ដំណើររឿងអំពីគ្រួសារ ទំនៀមទម្លាប់ និងការប្រារព្ធពិធីផ្សេងៗ។ បន្ទាប់មក ឪពុកម្តាយ និងជីដូនជីតាត្រូវបានគេអញ្ជើញជាវាគ្មិន ដើម្បីចែករំលែកបទពិសោធ អំពីវប្បធម៌របស់គេជាមួយនឹងសិស្ស។ បន្ទាប់មកទៀតសិស្សអាចប្រតិដ្ឋការបង្ហាញពហុវប្បធម៌ ដែលរាប់បញ្ចូលរូបថតគ្រួសារ វត្ថុគង់នៅពីបុរាណ និងវត្ថុផ្សេងៗទៀត ដែលពន្យល់ពីជីវិត និងវប្បធម៌ នៃមនុស្ស ដែលរស់នៅក្នុងសហគមន៍មូលដ្ឋាន។

## សន្និដ្ឋាន

ជារួមមក ទ្រឹស្តីអភិវឌ្ឍន៍និយម ជាទ្រឹស្តីមួយ ដែលទទួលបានពីការគាំទ្រពីលោក

[9] Michael W. Apple, *Official Knowledge: Democratic Education in a Conservative Age* (New York and London: Routledge, 2000), pp.132-133.

Dewey, Kilpatrick, Parker និង Johnson នោះ *ជាទ្រឹស្តីអប់រំយ៉ាងសំខាន់មួយ ដែលត្រូវបានគេយកទៅប្រតិបត្តិសម្រាប់ការបង្រៀន ដោយផ្តោតអារម្មណ៍លើលក្ខណៈពិសេសនៃការដោះស្រាយបញ្ហានិងសកម្មភាពនៅក្នុងក្រុមៗ គ្រូដើរតួជាអ្នកសម្របសម្រួលៗ ទ្រឹស្តីរិះគន់និយម ដែលទទួលបានការគាំទ្រពីលោក* McLaren និង Giroux *ជាទ្រឹស្តីអប់រំសំខាន់មួយ ដែលត្រូវបានគេយកទៅប្រតិបត្តិនៅក្នុងវិស័យអប់រំ ដែលថា ការបង្រៀនត្រូវផ្តោតលើទំនាស់សង្គមៗ*

**ឯកសារយោង**


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.

2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

3- Arthur Zilversmith, *Changing Schools: Progressive Theory and Practice, 1930-1960*, Chicago: University of Chicago Press, 1993.

4- Lawrence A. Cremin, *The Transformation of the School*, New York: Random Handom House, 1961.

5- Peter W. Airasian and Mary E. Walsh,'' Constructivist Cautions,'' *Phi Delta Kappan*, February 1997.

6- Frank Margonis, "*Marxist, Liberalism, and education Theory*, *Educational Theory*, Fall 1993.

7- Henry A. Giroux and Peter L. McLaren, eds., *Critical Pedagogy, the State, and Cultural Struggle*, Aldany: State University of New York Press, 1998.

8- Martusewicz and William Reynold, eds., *Inside Out: Contemporary Critical Perspectives in Education*, New York: St. Martin's Press, 1994.

9- Henry A. Giroux and Peter McLaren, eds., *Critical Pedagogy, the State, and Cultural Struggle*, New York: State University of New York Press, 1989.

10- Christine E. Sleeter and Peter L. McLaren, eds. *Multicultural Education, Critical Pedagogy, and the Politics of Difference*, Albany: State University of New York Press, 1995.

11- Michael W. Apple, *Official Knowledge: Democratic Education in a Conservative Age*, New York and London: Routledge, 2000.

# ទ្រឹស្តីវិទូ ចន ឌូវី
## (John Dewey Theorist)

*ដោយ៖* **លោក ប៉ាន់ សំណាង**
*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១-សេចក្តីផ្តើម

*សមិទ្ធផល ការរីកចម្រើននៃពិភពលោកនាពេលបច្ចុប្បន្ននេះ មិនមែនកើតឡើងឯកឯងទាំងស្រុងនោះទេ តែវាត្រូវឆ្លងកាត់ដំណាក់កាលជាច្រើនតាមការវិវឌ្ឍនៃសម័យកាល។ ការវិវឌ្ឍទាំងនោះ គឺក៏កើតឡើងពីទ្រឹស្តីនានានៃអ្នកប្រាជ្ញ ទស្សនវិទូ ឬទ្រឹស្តីវិទូនានាដែរ ដូចជា* ***លោកអារីស្តូត សូក្រាត ខុងជឺ ព្រះពុទ្ធ រីឆាត ហ្វេមែន****ជាដើម។ជាក់ស្តែងលោករីឆាតហ្វេមែន* (Richard Feyman) *លើកឡើងថា «ការយល់សំខាន់ជាងការចងចាំ» (ផេកកម្រងជីវិតអ្នកប្រាជ្ញ,២០២៤)។ លោកអារីស្តូតថា «ឫសគល់នៃការអប់រំគឺជូរចត់ ប៉ុន្តែផ្លែផ្កានៃការអប់រំគឺផ្អែម» (គេហទំព័រ* Worldpress, *២០១៩) ។ ទ្រឹស្តីទាំងនេះ លេចរូបរាងបានអាស្រ័យលើការអនុវត្ត ដូចពាក្យមួយឃ្លាលើកឡើងថា«ទ្រឹស្តីផ្សារភ្ជាប់ នឹងការអនុវត្ត»។*

*ប្រទេសជឿនលឿនលើលោក គេតែងតែអនុម័តបំប្លែងយកជាប្រយោជន៍ក្នុងការអភិវឌ្ឍសង្គមជាតិរបស់គេ។ ចំពោះវិស័យអប់រំក៏ដូចគ្នា កំណែទម្រង់ និងទំនើបកម្មនៃវិស័យអប់រំសិក្សាធិការ វាក៏ពឹងលើអ្នកអប់រំដែរ។ជាឧទាហរណ៍ទាក់ទងប្រទេសសិង្ហបុរីតាមនាយកដ្ឋានស្ថិតិសិង្ហបុរី បង្ហាញថាប្រព័ន្ធអប់រំល្អប្រកបដោយប្រសិទ្ធភាព តែងតែត្រូវបានគេមើលឃើញថា ជាសសរស្តម្ភជាមូលដ្ឋាន ដើម្បីការអភិវឌ្ឍ និងនិរន្តរភាពកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពដ៏រឹងមាំ* (e.g., Economic Review Committee, 1986)*។ ប្រព័ន្ធអប់រំសាធារណៈដែលមានមូលនិធិល្អ និងមានប្រសិទ្ធភាពក្នុងប្រទេសសិង្ហបុរីបានរួមចំណែកដល់ការកែលម្អយ៉ាងសំខាន់នៅក្នុងទិដ្ឋភាពមួយចំនួន។ ឧទាហរណ៍ ចន្លោះឆ្នាំ ១៩៧០ និង ២០១៣ អត្រាអក្ខរកម្មបានប្រសើរឡើងពី ៦៨,៩% ទៅ ៩៦,៥% (នាយកដ្ឋានស្ថិតិសិង្ហបុរី, ២០១៤a)។*

នៅឆ្នាំ២០០០មុនគ.សទាក់ទងនឹងប្រទេសចិន ការអប់រំរបស់ចិន បានរីកចម្រើនដល់កម្រិត ដែលបាន បង្កើតឡើងជាពិសេស នូវកន្លែងសិក្សា សម្រាប់គោលបំណងនៃការរៀនសូត្រ។ ពីឆ្នាំ៨០០ ទៅ ឆ្នាំ២០០ មុនគ.ស. ប្រទេសចិន មានទាំង គួសៀរ (Guoxue: សាលារដ្ឋាភិបាល) និងហ្សាំងស្ទៀរ (Xiangxue: សាលាក្នុងស្រុក)។ ការអប់រំនៅក្នុងប្រទេសចិនបែបប្រពៃណី ត្រូវបានគ្របដណ្ដប់ដោយយូជី (keju: ប្រព័ន្ធប្រឡងសេវាស៊ីវិល)" ដែលបានចាប់អភិវឌ្ឍ ប្រហែលឆ្នាំ២០០នៃគ.ស និងកាន់តែរីកចម្រើន នៅក្នុងរជ្ជកាលរាជវង្សតាំង (ឆ្នាំ៦១៨ដល់៩០៦ នៃគ.ស)។ យូជី (Keju) គឺជាកម្មវិធីស្រាវជ្រាវមួយ ដែលផ្អែកលើគោលគំនិតខុងជឺ។ ការបង្រៀន និងទស្សនវិជ្ជារបស់ខុងជឺ គាំទ្រវប្បធម៌ និងសង្គមអាស៊ីបូព៌ា ដែលនៅតែមានឥទ្ធិពល នៅទូទាំងប្រទេសចិន និងអាស៊ីបូព៌ារហូតមកដល់សព្វថ្ងៃនេះ(ប៉ាន់ សំណាង, ២០២២)។ នេះជាទិដ្ឋន័យមួយដែលជាផ្ទៃផ្កានៃទ្រឹស្ដីវិទូ។

ចំពោះ**លោក ចន ឌូវី** (John Dewey) ក៏ជាទស្សវិទូ និងជាអ្នកអប់រំដ៏ល្បីនាសម័យទំនើប របស់សហរដ្ឋអាម៉េរិកដែលចូលរួមវិភាគទានគំនិតដល់ការអប់រំដែរ។ខាងក្រោម ជាការសិក្សាស្រាវជ្រាវតូចមួយទាក់ទងនឹងលោក ចន ឌូវី (John Dewey)៖

## ២-ជីវប្រវត្តលោក ចន ឌូវី

### ក-ជីវប្រវត្តិសង្ខេប

**លោក ចន ដេវី** (John Dewey) កើតនៅថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៨៥៩ នៅ ប៊ើលីងតុន (Burlington) រដ្ឋវើរ៉ម៉ុន (Vermont ) សហរដ្ឋអាម៉េរិក (The United States)។ នៅសហរដ្ឋអាម៉េរិក គាត់បានធំឡើងដោយទទួលបានការអប់រំធម្មតា ដែលគ្រួសារលោកជាវណ្ណៈកណ្ដាល (bourgeoisie) នៅសម័យនោះ។ គាត់បានសិក្សា ផ្នែកទស្សនវិជ្ជា នៅសាកលវិទ្យាល័យ **Johns Hopkins** (**ក្នុងទីក្រុង Baltimore**) ដែលការបង្រៀន អនុវត្តតាមគោលការណ៍ neo-Hegelian ហើយបានបញ្ចប់ការសិក្សានៅឆ្នាំ១៨៨៤ ជាមួយនឹង និក្ខេបបទផ្នែកចិត្តវិទ្យាពី**លោកអ៊ីមម៉ាញូអែលកង់ច៍** (Immanuel Kant) (មើលរូបទី១)។ គាត់ទទួលឥទ្ធិពលពី វីល្លៀម ជេម (William James) ហ្សង់ ហ្សាក់រ៉ូស្សូ (Jean Jacques Rousseau) និង **អ៊ីម ម៉ាញូអែលកង់ច៍** (Immanuel Kant)(ហារីក្លូក Harry Cloke, ២០២៣)។



*រូបទី១៖ លោក អ៊ឹម ម៉ាញូអែល កង់ថ៍* (Immanuel Kant) *ទស្សនវិទូដ៏ល្បីរបស់អាល្លឺម៉ង់*

(*ប្រភព៖គេហទំព័រ* https://sevenpillarsinstitute.org/kantian-duty-based-deontological-ethics/ )

*ការបង្កើតរបស់* Dewey *នឹងត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំងដោយការអនុវត្តជាក់ស្តែងរបស់អាម៉េរិក និងការវិវត្តរបស់* Darwin*។ ខណៈពេលដែលសហរដ្ឋអាម៉េរិកកំពុងឆ្លងកាត់ដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងខ្លាំង លោក* John Dewey *បន្ទាប់ពីបង្រៀននៅទីក្រុង* Detroit *នៅសាកលវិទ្យាល័យ* Michigan *បានក្លាយជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ* Chicago *ក្នុងឆ្នាំ១៨៩៤ (មើលរូបទី២)។*



*រូបទី២៖* ***លោកចន ឌូវី*** (John Dewey) (*ប្រភព៖ គេហទំព័រ* https://thmeythmey.com)

នៅទីនេះពីរបីឆ្នាំក្រោយមក លោក John Dewey បានបង្កើតសាលាបឋមសិក្សាមួយ។ ដោយសារតែជម្លោះដែលបង្កើតដោយមុខតំណែងប្រឆាំងនឹងការអភិរក្សរបស់គាត់ នៅឆ្នាំ១៩០៤ គាត់ត្រូវបានគេបង្ខំឱ្យផ្លាស់ទៅសាកលវិទ្យាល័យ Columbia ក្នុងទីក្រុងញូវយ៉ក។ នៅទីនេះ ដេវី (Dewey ) បង្កើតសាលាពិសោធន៍ថ្មីមួយដែលផ្តល់មូលនិធិដោយឪពុកម្តាយរបស់សិស្ស។ គាត់បានបោះបង់ការបង្រៀននៅឆ្នាំ ១៩៣០ ដោយសារតែការរឹតត្បិតអាយុ។ បន្ថែមពីលើការបន្តការស្រាវជ្រាវផ្ទាល់ខ្លួនរបស់គាត់នៅក្នុងវិស័យទស្សនវិជ្ជា និងគរុកោសល្យ គាត់បានបង្កើតគណបក្សនយោបាយមួយ(លទ្ធិប្រជាធិបតេយ្យបែបរ៉ាឌីកាល់) ដែលដំណើរការក្នុងអំឡុងពេលវិបត្តិដែលបានចាប់ផ្តើមនៅឆ្នាំ ១៩២៩។

ក្នុងវិស័យនេះ គាត់ធ្វើអន្តរាគមន៍ក្នុងបញ្ហាសង្គម និងសីលធម៌ ដូចជា ការបោះឆ្នោតជាដើម។ សម្រាប់ស្ត្រី ឬ តើសំណួរនៃការថ្កោលទោស អយុត្តិធម៌ របស់ពួកអនាធិបតេយ្យ Sacco និង Vanzetti ដែលមានលក្ខណៈសេរីប៉ុណ្ណោះ។

**លោក ចន ឌូវី** (John Dewey) បានស្លាប់នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នៅថ្ងៃទី១ ខែមិថុនាឆ្នាំ ១៩៥២ នៅអាយុ៩៣ឆ្នាំ។ កេរដំណែលរបស់គាត់ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើវប្បធម៌អាមេរិក នយោបាយ និងប្រព័ន្ធអប់រំ (មើលរូបទី៣)។




រូបទី៣៖ លោកចន ឌូវី (John Dewey) និង ទ្រឹស្តីរបស់លោក
(ប្រភព៖ គេហទំព័រ https://bookshopmy.wordpress.com/)

**ខ-ស្នាដៃសំខាន់ៗរបស់លោកចន ដេវី**

- ✓ តក្កវិជ្ជាពិសោធន៍។ ទ្រឹស្តីធម្មជាតិនៃការយល់ដឹង និងការគិត កែសម្រួលដោយ R. Freg, Quodlibet ២០០៨
- ✓ តក្កវិជ្ជា ទ្រឹស្តីនៃការស៊ើបអង្កេត ឆ្នាំ ១៩៣៨ (ការបោះពុម្ពអ៊ីតាលី ឆ្នាំ ១៩៤៩)
- ✓ បទពិសោធន៍ និងការអប់រំ ឆ្នាំ ១៩៣៨
- ✓ សេរីនិយម និងសកម្មភាពសង្គម ១៩៣៥
- ✓ សិល្បៈជាបទពិសោធន៍ ឆ្នាំ ១៩៣៤
- ✓ ក្នុងការស្វែងរកភាពត្រឹមត្រូវ ឆ្នាំ ១៩៣០
- ✓ បទពិសោធន៍ និងធម្មជាតិ ឆ្នាំ ១៩២៥
- ✓ លទ្ធិប្រជាធិបតេយ្យ និងការអប់រំ ឆ្នាំ ១៩១៦
- ✓ សាលា និងសង្គម ឆ្នាំ ១៨៩៩
- ✓ My Pedagogical Credo ឆ្នាំ ១៨៩៧

**២-ទ្រឹស្តីសំខាន់ៗរបស់លោកចន ឌូវី**

លោក ចន ឌូវី (John Dewey) ជាទស្សនវិទូ និង ជាអ្នកអប់រំដ៏ល្បីល្បាញរបស់អាម៉េរិក (រូបទី៤)។ ខាងក្រោមជាទ្រឹស្តីខ្លះដែលទ្រឹស្តីវិទូរូបនេះ បានលើកឡើង៖

**ក-ទ្រឹស្តីទូទៅ៖**

- ✓ សង្គមមួយត្រូវបានបង្កើតឡើងដោយមនុស្សមួយចំនួនដែលរួបរួមគ្នាដោយការពិតដែលថាពួកគេធ្វើការក្នុងទិសដៅដូចគ្នាក្នុងស្មារតីរួម និងបន្តគោលដៅរួម។
- ✓ ការបន្ទាបខ្លួនកាន់តែច្រើនគឺត្រូវបានទាមទារនៅក្នុងគ្រាជោគជ័យជាងពេលបរាជ័យ។
- ✓ នៅពេលដែលធម្មជាតិ និងសង្គមរស់នៅក្នុងថ្នាក់រៀន នៅពេលដែលទម្រង់ និងឧបករណ៍បង្រៀនត្រូវបានអនុលោមតាមខ្លឹមសារនៃបទពិសោធន៍ នោះការកំណត់នេះនឹងក្លាយជាអាចធ្វើទៅបាន ហើយវប្បធម៌នឹងក្លាយជាពាក្យឃ្លាំមើលនៃលទ្ធិប្រជាធិបតេយ្យ។
- ✓ ដរាបណាសិល្បៈជាហាងកែសម្ផស្សរបស់អរិយធម៌ សិល្បៈ និងអរិយធម៌នឹងមិនមានសុវត្ថិភាពឡើយ។
- ✓ ការរួបរួមនៃវិទ្យាសាស្ត្រទាំងអស់ត្រូវបានរកឃើញនៅក្នុងទីតាំងភូមិសាស្ត្រ។ អត្ថន័យនៃភូមិសាស្ត្រគឺស្ថិតនៅក្នុងការពិតដែលថាវាតំណាងឱ្យផែនដីជាជម្រកអចិន្ត្រៃយ៍របស់មនុស្ស។

- ✓ ការរិះគន់លើការព្យាយាមកំណត់បទពិសោធន៍សោភ័ណវិទ្យាសម្រាប់ផ្នែកវិចិត្រសិល្បៈប៉ុណ្ណោះ ***(សិល្បៈជាបទពិសោធន៍)*** បានជះឥទ្ធិពលខ្ពស់លើនិន្នាការនៃការស្រាវជ្រាវសោភ័ណវិទ្យា ដែលបានព្យាយាមពង្រីកវិសាលភាពនៃវិស័យនេះពីសិល្បៈប្រពៃណីទៅវប្បធម៌ពេញនិយម។
- ✓ មានរឿងគួរឱ្យអស់សំណើច និងច្របូកច្របល់ក្នុងពេលតែមួយ អំពីរបៀបដែលមនុស្សត្រូវបានជះឥទ្ធិពលដល់ចំណុចដែលពួកគេជឿថា វិធីនៃការគិតបែបវិទ្យាសាស្ត្រទទួលយកការពិតខាងក្នុងនៃវត្ថុ ហើយពួកគេហៅវិធីផ្សេងទៀតនៃការគិតរឿងមិនពិត ដើម្បីយល់។ ពួកគេនិងរីករាយជាមួយពួកគេ។
- ✓ គោលគំនិតវិទ្យាសាស្ត្រ ដូចជាឧបករណ៍ផ្សេងទៀតត្រូវបានបង្កើតឡើងដោយមនុស្សម្នាក់ក្នុងទម្រង់ច្បាស់លាស់មួយក្នុងការប៉ុនប៉ងដើម្បីសម្រេចបាននូវគោលដៅជាក់លាក់មួយ ពោលគឺការបំប្លែងអតិបរមា នៃវត្ថុនៃការគិតទៅជាវត្ថុផ្សេងទៀត។ ប៉ុន្តែវិធីនៃការគិតទាំងនេះលែងជាគ្រូបង្រៀន ឬជំនួសវត្ថុដែលគេយល់ឃើញនិងទទួលបានជាងការតម្បាញអគ្គិសនីទាក់ទងនឹងក្រណាត់ ដែលពិតជាឧបករណ៍ដ៏មានប្រសិទ្ធភាពជាងឧបករណ៍ត្បាញដោយដៃ។
- ✓ យើងមានទំនោរមើលសាលារៀនតាមទស្សនៈបុគ្គល ជាអ្វីមួយដែលកំណត់ដោយទំនាក់ទំនងរវាងគ្រូនិងសិស្ស រវាងគ្រូ និងឪពុកម្តាយ។ អ្វីដែលយើងចាប់អារម្មណ៍បំផុតគឺការវិវឌ្ឍដែលធ្វើឡើងដោយកុមារពិសេសនេះដែលយើងធ្លាប់ស្គាល់ ការអភិវឌ្ឍរាងកាយរបស់គាត់ អត្ថប្រយោជន៍របស់គាត់ក្នុងការអាន ការសរសេរ ការគូររូប ការបង្កើនចំណេះដឹងភូមិសាស្ត្រនិងប្រវត្តិសាស្ត្ររបស់គាត់ ការកែលម្អអាកប្បកិរិយារបស់គាត់។ នៅក្នុងទម្លាប់របស់គាត់នៃល្បឿន, សណ្តាប់ធ្នាប់, ឧស្សាហ៍ព្យាយាម។
- ✓ ការអប់រំមិនមែនជាការរៀបចំសម្រាប់ជីវិតទេ ការអប់រំគឺជាជីវិតខ្លួនឯង។




*រូបទី៤៖ វដ្តទ្រឹស្តីរបស់លោក ចន ដេវី*

## ខ-ទ្រឹស្តីដែលជាគោលការណ៍បង្រៀន

យោងតាមក្រុមគ្រូឧទ្ទេសឧត្តមសិក្សានៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០១៩ បានបង្ហាញពីគោលការណ៍បង្រៀនរបស់លោក ចនដេវី (John Dewey) មានដូចខាងក្រោម៖

១) ការបង្រៀនល្អនៅពេលវាផ្អែកលើចិត្តសាស្ត្រនៃការរៀន។ ធម្មជាតិរបស់ក្មេង និងដំណើរការរៀននិងច្បាប់ដែលគ្រប់គ្រងការកំណត់ប្រភេទប្រតិបត្តិការណ៍នៃការបង្រៀនត្រូវធ្វើឡើងដោយគ្រូ។

២) ការបង្រៀនល្អ នៅពេលដែលសកម្មភាពនិងការពិសោធរបស់អ្នករៀនជាប់បន្តគ្នាពីតូចទៅធំ កាន់តែមានន័យកាន់តែរួមបញ្ចូលនិងកាន់តែទាក់ទងគ្នា។

៣) ការរៀនល្អ នៅពេលអ្នករៀនបានដឹងអំពីគោលបំណងដែលត្រូវសម្រេចបាន។ បញ្ញត្តិនេះ គេឱ្យឈ្មោះថា សំណើជំរុញទឹកចិត្ត (proper motivation)។

៤) ការរៀនល្អ នៅពេលវាផ្តល់បទពិសោធរៀន ឬស្ថានភាពដែលជានាដល់ការយល់ដឹង។ វាល្អនៅពេលសម្ភារសម្ភារឧបទេសនិងបរិស្ថានល្អ។ សម្ភារឧបទ្ទេស និងបរិស្ថានជួយដល់អ្នករៀនបង្កើនការគិតនិងសម្រួលដល់ការយល់ហើយឱ្យការរៀនកាន់តែមានន័យ។

៥) ការរៀនល្អ នៅពេលដែលមានការផ្តល់ឱ្យនូវតម្រូវការផ្សេងៗគ្នារបស់បុគ្គល។ ផ្អែកលើគោលការណ៍ចិត្តវិទ្យាដែល

មនុស្សម្នាក់ខុសពីមនុស្សម្នាក់ទៀត។ ឱ្យការបង្រៀនមានប្រសិទ្ធភាព ការបង្រៀនត្រូវតែការពារ ឬយកចិត្តទុកដាក់ចំពោះអ្នករៀនដូចជាយើង យកចិត្តទុកដាក់ចំពោះខ្លួនឯង។

៦) ការបង្រៀនល្អ នៅពេលវាប្រើប្រាស់បទពិសោធកន្លងមករបស់អ្នករៀន។ មានន័យថា ការរៀនមានភាពងាយស្រួលជាងនៅពេលអ្នកចាប់ផ្តើមនូវអ្វីដែលសិស្សបានដឹងរួចមកហើយ។

៧) ការបង្រៀនល្អ នៅពេលអ្នករៀនត្រូវបានជំរុញឱ្យគិត និងរែកញែករកហេតុផល។ វិធីសាស្រ្តបង្រៀនល្អបំផុតគឺផ្តល់សេរីភាព និងជំរុញឱ្យគិត។

៨) ការបង្រៀនល្អ នៅពេលវាត្រូវបានគ្រប់គ្រងដឹកនាំដោយគោលការណ៍នៃប្រជាធិបតេយ្យ។ នៅក្នុងការបង្រៀនបែបប្រជាធិបតេយ្យ ទំនាក់ទំនងសង្គមបានកើតឡើងការគោរព ការសហការណ៍ ការអត់ធ្មត់និងយុត្តិធម៌តាមលក្ខណៈធម្មជាតិ។ ក្នុងន័យមួយផ្សេងទៀត អ្នករៀនត្រូវតែមានអារម្មណ៍មិនតានតឹង។

៩) ការបង្រៀនល្អនៅពេលដែលវិធីសាស្រ្តមួយបំពេញឱ្យសម្ភារឧបទេស និងវិធីសាស្រ្តមួយទៀត។

១០) ការបង្រៀនល្អ នៅពេលការវាយតម្លៃត្រូវបានបញ្ចូលក្នុងដំណើរការនៃការបង្រៀន។ ការវាយតម្លៃ វាស់វែងប្រសិទ្ធភាពនៃការបង្រៀន រៀន និងបំពេញមុខងារនៃការបង្រៀន។ ការបង្រៀន មានន័យថានៅពេលលទ្ធផលនៃការបង្រៀនបានសម្រេច។

១១) ការបង្រៀនល្អ នៅពេលវាត្រូវបានបញ្ចូលការរំលឹកដែលជាផ្នែកមួយនៃការបង្រៀន។

គោលបំណងនៃការរំលឹកនាំមកនូវទំនាក់ទំនងព្រឹត្តិការណ៍ដែលបានរៀនដើម្បីទទួលបាននូវអត្ថន័យថ្មី។

ជារួម តាមការលើកឡើង គឺលោក ចន ដេវី កំណត់ថា ការអប់រំកើតឡើងតាមរយៈការចូលរួមដោយផ្ទាល់ឬការរៀនដោយអនុវត្តន៍ផ្ទាល់។ មនុស្សគំរូរបស់គាត់ក្នុងការអប់រំគឺមនុស្សសកម្ម មានន័យថា គ្រូបង្រៀនមិនមែនបង្ខំឱ្យក្មេងៗ ឬសិស្ស ទទួលយកនូវអ្វីដែលគ្រូត្រៀមទុកមុននោះ ក៏ប៉ុន្តែផ្ទុយទៅវិញគ្រូត្រូវបង្ហាញនូវវិធីដោះស្រាយ ឬសកម្មភាពងាយៗដល់សិស្ស (យ៉ង់ ធារី អ៊ឹម កុច, ២០០៧)។ ប្រាកដណាស់ចលនារបស់ **ចន ដេវី** នេះត្រូវបានគេយកមកធ្វើជាមូលដ្ឋាននៃប្រពន្ធ័អប់រំ

ទំនើបរបស់យើង។ តាមទស្សនវិជ្ជាជឿនលឿននិយម អះអាងថា ការលូតលាស់ និងការអភិវឌ្ឍរបស់ក្មេងជាលក្ខណៈបុគ្គល ផ្អែកលើបទពិសោធន៍ និងសកម្មភាពផ្ទាល់របស់គេ។ លទ្ធិនេះបានបន្ថែមទៀតថា ការបង្រៀនដ៏ល្អ និងប្រកបដោយជោគជ័យ គឺជាការបង្រៀនមួយដែលប្រើគោលការណ៍សកម្មភាពផ្ទាល់ខ្លួន និងបណ្ដុះបណ្ដាល ការគិត និងការពិចារណា។ ចុងក្រោយ ទ្រឹស្ដីនេះ បញ្ជាក់ថា ការពិភាក្សាជាក្រុម និងសកម្មភាពជាក្រុម គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពនៃការបញ្ចេញមតិដោយខ្លួនឯង និងការអភិវឌ្ឍ។

## ៣-ចំណុចខ្វះខាតនៃទ្រឹស្ដី

ជាទូទៅ ទ្រឹស្ដីណាក៏ដោយ តែងមានចន្លោះប្រហោង បើគិតពីបរិបទជាក់ស្ដែង និងស្ថានភាពនៃសង្គមមនុស្ស។ យោងតាម ណាតថាលី ប៊ូឡេ (Nathalie Bulle ២០១៨) បង្ហាញថា អត្ថបទបច្ចុប្បន្ន ស្នើឱ្យមានការរិះគន់យ៉ាងស៊ីជម្រៅលើផ្នែកមួយនៃគំនិតរបស់**ចន ឌូវី** ដែលមិនត្រូវបានស្វែងយល់យ៉ាងទូលំទូលាយ ៖ បញ្ហានៃអត្ថន័យ និងការយល់ដឹង ទាក់ទងនឹងប្រព័ន្ធគំនិត។ ដើម្បីឱ្យមានភាពទូលំទូលាយគ្រប់គ្រាន់ ដោយសារតែគំនិតនៃចំណេះដឹងរបស់ **ចន ដេវី** ពាក់ព័ន្ធនឹងការស្ដាបនាឡើងវិញនូវគោលគំនិតបែបបញ្ជាក់៖ «ជាដំបូង ខ្ញុំនឹងរំលឹកឡើងវិញនូវអត្ថន័យដែល **ចន ដេវី** ពិពណ៌នាអំពីគោលគំនិតដែលខ្ញុំពឹងផ្អែកលើដើម្បីបង្កើតអំណះអំណាងរបស់ខ្ញុំ។ អំណះអំណាងនេះសំដៅទៅលើទិដ្ឋភាពសំខាន់នៃគំនិតរបស់ **ចន ដេវី** អំពីការយល់ដឹងអំពីអត្ថន័យដែលជាបេះដូងនៃទ្រឹស្ដីនៃការយល់ដឹងរបស់គាត់»។ ទោះបីជាមានការលើកលែងដែលល្បីល្បាញមួយចំនួន និងការពិតដែលថាការងាររបស់គាត់ត្រូវបានសិក្សាកាន់តែខ្លាំងឡើងសម្រាប់មួយទសវត្សរ៍ក៏ដោយការធ្វេសប្រហែសទាក់ទងនឹងទស្សនវិជ្ជារបស់ **ចន ឌូវី** ដោយទស្សនវិទូអាជីព***ផ្ទុយនឹងស្ថានភាពដែលអាចត្រូវបានគេសង្កេតឃើញ***នៅក្នុងទស្សនវិជ្ជា និងទ្រឹស្ដីអប់រំ ដែល **ចន ឌូវី** កាន់កាប់ ទីតាំងកណ្ដាល ដូចដែលបានបង្ហាញនៅក្នុងទីនេះដោយបន្ទាត់រាងប៉ូលនៃបញ្ហាជុំវិញបរិវេណដែលបានកំណត់ជាមុន។ ភាពទន់ខ្សោយនៃចំណាប់អារម្មណ៍របស់ទស្សនវិទូចំពោះទស្សនៈរបស់ **ចន ឌូវី** អាចត្រូវបានពន្យល់ដោយការខ្វះខាតជាមូលដ្ឋាននៃការយល់ដឹងដែលភ្ជាប់ទៅនឹងការលំបាកដែលពួកគេអាចមានក្នុងការបំបែកចេញពីគំនិតទស្សនវិជ្ជាប្រពៃណីដែលបង្កើតឡើងដោយចិត្តវិទ្យាផ្លូវចិត្តដែល**ចន ឌូវី** ត្រូវបានជំទាស់ដោយផ្ទាល់។

ប៉ុន្តែ គ្មានហេតុផលណា ដែលទស្សនវិទូអប់រំ និងអ្នកប្រាជ្ញដទៃទៀត ក្នុងវិស័យអប់រំ មិនជួប ប្រទះនឹងការលំបាកដូចគ្នា និងការកក់ទុកនោះ ទេ។ ការបោះឆ្នោតនៃទស្សនវិជ្ជារបស់ Dewey ក្នុងគំនិតអប់រំសហសម័យ អាចឆ្លុះបញ្ចាំងជា ចម្បងនូវការប្រកាន់ខ្ជាប់ជាទូទៅចំពោះ ទិដ្ឋភាពសង្គម នយោបាយនៃការតស៊ូរបស់ គាត់ សម្រាប់ការអប់រំបែបប្រជាធិបតេយ្យដែល ទំនងជាធ្វើឱ្យចំណាប់អារម្មណ៍លើការអានរិះ គន់ចុះខ្សោយ។ ភាពជោគជ័យរបស់ **Dewey** ក្នុងចំណោមទស្សនវិទូ និងអ្នកប្រាជ្ញផ្នែកអប់រំ ពន្យល់ដល់កម្រិតដ៏ធំធេងរបស់គាត់ដែល កាន់តែសាយភាយ និងបង្កប់ន័យនិង ឥទ្ធិ ពលយ៉ាងជ្រាលជ្រៅលើចរន្តស្រាវជ្រាវក្នុងការ អប់រំ។

ជាទីបញ្ចប់ ទោះបីមានការរិះគន់លើ ទ្រឹស្តី ចន ដេវី ក៏ដោយ ក៏ទស្សនគាត់បានរីក ផ្សាយភាយ និង អនុម័តដោយសិក្សាបំបែកបន្ត ដើម្បីឱ្យស្របនឹងចរន្តសាកលភាវូបនីយកម្ម ក៏ ដូចជាស្ថានភាពនៃភូមិសាស្ត្រ និងវប្បធម៌នៃ ប្រទេសនីមួយៗ។ **ចន ឌូវី** គឺជាអ្នកអនុវត្តជាក់ ស្តែង អ្នកជឿនលឿន អ្នកអប់រំ ទស្សនវិទូ និង ជាអ្នកកែទម្រង់សង្គម (Gutek, 2014)។ តួនាទី ផ្សេងៗរបស់លោក **ចន ឌូវី** បានជះឥទ្ធិពល យ៉ាងខ្លាំងដល់ការអប់រំ ហើយគាត់ប្រហែលជា ទស្សនវិទូផ្នែកអប់រំដ៏មានឥទ្ធិពលបំផុតម្នាក់ ដែលគេស្គាល់រហូតមកដល់បច្ចុប្បន្ន (Theobald, 2009)។ លោក **ចន ឌូវី** ជានិមិត្តរូបនៃ ទំនើបកម្មការអប់រំ។ លោក **ចន ឌូវី** ជឿថា បុគ្គលម្នាក់ៗរីកចម្រើន និងរៀននៅពេលដែល ពួកគេមានទំនាក់ទំនងជាមួយពិភពលោក។ តាមរយៈការជួបជាមួយមនុស្សជុំវិញខ្លួន បុគ្គល ម្នាក់ៗរកឃើញគំនិត គំនិត និងការអនុវត្តថ្មីៗ ដែលអនុញ្ញាតឱ្យពួកគេបង្កើតការយល់ដឹង របស់ពួកគេ ដែលពួកគេពង្រឹងបន្តិចម្តងៗ តាមរយៈការរៀនសូត្រ និងបទពិសោធន៍សង្គម របស់ពួកគេ (គ្រីស្តូហ្វ័រ ប៉េប៉ាស Chistopher Papas, 2023)។

# ឯកសារពិគ្រោះ


*ក្រសួងអប់រំ (២០០៦) កម្មវិធីសិក្សាលំអិតវិទ្យាសាស្រ្តសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ, ផ្សាយចេញពីនាយកដ្ឋនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ*

*ប៉ាន់ សំណាង (២០២២) ការអប់រំ ជាកិច្ចការទាំងអស់គ្នា, ផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា*

*ប្រាក់ ពៅ ឃិន វណ្ណី បានកក្កដា (២០១៩) វិធីសាស្រ្តបង្រៀន ,បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ*

*យ៉ង់ ជារី អ៊ឹម កុច (២០០៧) តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីឱ្យសិស្សរបស់អ្នករៀនដោយខ្លួនឯងដោយម្ចាស់ការ,ឯកសារវិទ្យាស្ថានជាតិអប់រំ*

Dewey, John (1929). The Quest for Certainty: A Study of the Relation of Knowledge and Action. Minton, Balch & Company.

Dewey, John (1884). Kant and Philosophic Method. The Journal of Speculative Philosophy, 18(2), 162–174.

Nathalie Bulle (2018) What Is Wrong with Dewey' s Theory of Knowing. The Jounal of Phylosophy,Volume 5,No.21,2018

Lim KamMing (2014) Teacher Education & Teaching Profession In Singapore,International Conference on the Teaching Profession in ASEAN,Bangkok,Thailand,October 2014.

https://thmeythmey.com/m/?page=detail&id=76543

https://wordpress.com

https://quod.lib.umich.edu/e/ergo/12405314.0005.021/--what-is-wrong-with-deweys-theory-of-knowing?rgn=main;view=fulltext

https://doi.org/10.3998/ergo.12405314.0005.021

https://books.google.com/books/about/The_Collected_Works_of_John_Dewey.html?i

https://elearningindustry.com/john-deweys-theory-reforming-education-through-experiential-learning/amp

https://sevenpillarsinstitute.org/kantian-duty-based-deontological-ethics/

# ការស្វែងយល់ពីមូលធនមនុស្ស

*ដោយ៖ លោក* **ប៉ាន់ សំណាង**
*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំនៃ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

**១.សេចក្តីផ្តើម**

*ការប្រែប្រួល តែងតែកើតមានជានិច្ច ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ពីពេលមួយទៅពេលមួយពីកន្លែងមួយទៅកន្លែងមួយ។ ពីមុន គេតែងលើកឡើងថា«ធនធានមនុស្ស ជាកម្លាំងចលករក្នុងការអភិវឌ្ឍប្រទេសជាតិ»។ ពាក្យ «ធនធានមនុស្ស» ក្លាយជាប្រធានបទសំខាន់ក្នុងការអប់រំ ។ប៉ុន្តែកម្ពុជានាសម័យនេះ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា រាជរដ្ឋាភិបាលនាអាណត្តិនីតិកាលទី៧នេះ បានដាក់ចេញនូវយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីកំណើនសេដ្ឋកិច្ចនិងប្រែក្លាយកម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ កន្លងមកនេះ សម្តេចធិបតីនាយករដ្ឋមន្ត្រីបានមានប្រសាសន៍៖«មូលធនមនុស្ស គឺជាអាទិភាពគន្លឹះទីមួយ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ ក្នុងការជំរុញសេដ្ឋកិច្ចឱ្យសម្រេចបាននូវគោលដៅរបស់កម្ពុជានៅឆ្នាំ២០៣០និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០(រាជរដ្ឋាភិបាល ឆ្នាំ ២០២៣)។*

*ឆ្លើយតបនឹងចក្ខុវិស័យវែងឆ្ងាយដ៏សំខាន់នេះ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្ត "កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ" នាថ្ងៃទី១៤ វិច្ឆិកា ២០២៣ សម្រាប់យុវជនចំនួន ១លាន ៥សែននាក់ មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដើម្បីទទួលបាននូវចំណេះជំនាញច្បាស់លាស់ និងក្លាយជាផ្នែកមួយក្នុងការជំរុញសេដ្ឋកិច្ចជាតិ ដោយមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាសេនាធិការក្នុងការបណ្តុះបណ្តាលលើមុខជំនាញចំនួន១០ ក្នុងការសិក្សា (ក្រសួងព័ត៌មាន*

ឆ្នាំ២០២៣។ ដើម្បីសម្រេចបាននូវគោលដៅនេះ ការពង្រឹងនូវគុណភាពបណ្តុះបណ្តាល ក៏ដូចជាការលើកទឹកចិត្តយុវជន ក្នុងការសិក្សា និងបញ្ចប់ការសិក្សាប្រកបដោយគុណភាព និងគុណភាពគ្រូ ជាភាពចាំបាច់មិនអាចខ្វះបាន។ សម័យសេដ្ឋកិច្ចឌីជីថលនេះ មូលធនមនុស្សជាកម្លាំងចលករសំខាន់ក្នុងការជួយកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោកឱ្យសម្រេចបានគោលដៅឆ្នាំ២០៣០និង២០៥០។ យោងតាម ហង់ ជួនណារ៉ុន បានបញ្ជាក់ថា កម្ពុជាកំពុងត្រូវការនូវមូលធនមនុស្សជាចាំបាច់ ដើម្បីអភិវឌ្ឍន៍ប្រទេស ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា បដិវត្តន៍ឧស្សាហកម្មជំនាន់ទី ៤ និងសេដ្ឋកិច្ចថ្មីឌីជីថល (ហង់ ជួនណារ៉ុន ឆ្នាំ ២០២៣) ។

ក្នុងន័យនេះ មូលធនមនុស្ស ពិតជាមានសារៈសំខាន់មិនអាចខ្វះបានក្នុងការអភិវឌ្ឍជាតិ ក្នុងយុគបដិវត្តឧស្សាហកម្ម៤.០នេះ ព្រោះរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់លើការអភិវឌ្ឍមូលធនមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំ បណ្តុះបណ្តាលសមត្ថភាព និងជំនាញវិជ្ជាជីវៈរបស់យុវជន និងបុគ្គលិកកម្មករ។

សូមស្វែងយល់ពីមូលធនមនុស្សនិងគុណតម្លៃរបស់វាដូចខាងក្រោម៖

**២.និយមន័យ**

ការកំណត់ន័យនៃពាក្យមួយតែងតែមានការយល់ឃើញមិនដូចគ្នាទេ ព្រោះមនុស្សម្នាក់ៗមានគំនិតផ្សេងគ្នាដែរ។

បើពិនិត្យលើពាក្យ «មូលធនមនុស្ស» បានមកពីពាក្យ«មូលធន» និង«មនុស្ស»។ ពាក្យ«មូលធន» មានន័យថា ទ្រព្យដើម ដើមទ្រព្យ ប្រាក់ដើម ដើមទុន។ ពាក្យ «មនុស្ស» មានន័យថា ជនអ្នកដឹងការខុសត្រូវ សត្វវិសេសមួយប្រភេទជាពូជវង្សនៃមនុ, នរៈ។

ដូច្នោះ មូលធនមនុស្ស សំដៅលើ មនុស្សដែលមានតម្លៃជាទ្រព្យសំខាន់របស់ប្រទេសជាតិ ប្រកបដោយសក្តានុពលខាងចំណេះដឹង សមត្ថភាព ជំនាញ បទពិសោធ និងភាពច្នៃប្រឌិតដែលជាធនធានឬជាទុនសម្រាប់អភិវឌ្ឍប្រទេសបាន (វចនានុក្រមខ្មែរ ២០២២)។

មូលធនមនុស្ស សំដៅលើបណ្តុំនៃសមត្ថភាព ចំណេះដឹង ជំនាញ បទពិសោធ និងភាពច្នៃប្រឌិតរបស់មនុស្សដែលអាចផលិតចេញជាតម្លៃសេដ្ឋកិច្ចបាន (គេហទំព័រ buykhmerbook.com ២០២២)។

មូលធនមនុស្សមានចំណេះដឹង ជំនាញ និងសុខភាពដែលមនុស្សវិនិយោគ និងប្រមូលផ្តុំពេញមួយជីវិត ដែលអាចឱ្យពួកគេដឹងពី

សក្តានុពលរបស់ពួកគេក្នុងនាមជាសមាជិកប្រកបដោយផលិតភាពនៃសង្គម ( World bank ២០១៩)។

ន័យមួយទៀត តាមការផ្សាយរបស់គេហទំព័រ Market Business News.com (២០២៣) គេយល់ឃើញថា មូលធនមនុស្ស សំដៅលើកត្តាផលិតកម្ម ដែលកើតចេញពីមនុស្ស យើងប្រើដើម្បីបង្កើតទំនិញ និងសេវាកម្ម។ ចំណេះដឹង ជំនាញ ទម្លាប់ និងលក្ខណៈសង្គម និងបុគ្គលិកលក្ខណៈរបស់យើង សុទ្ធតែជាផ្នែកនៃធនធានមនុស្ស ដែលរួមចំណែកដល់ការបង្កើតទំនិញ និងសេវាកម្ម។ ការច្នៃប្រឌិតរបស់យើងក៏រួមចំណែកផងដែរ។ កត្តានៃផលិតកម្មគឺជាធាតុចូលចំនួនបួនដែលចាំបាច់សម្រាប់ការផលិតទំនិញ និងសេវាកម្ម(រូបភាពទី១) (Human capital refers to the production factors, coming from human beings, we use to create goods and services. Our knowledge, skills, habits, and social and personality attributes all form part of the human capital that contributes to the creation of goods and services. Our creativity also contributes. Factors of production are the four inputs required for the production of goods and services. (គេហទំព័រmarketbusinessnews.com)។




រូបភាពទី១៖មូលធនមនុស្សប្រកបដោយផលិតភាព

មូលធនមនុស្ស ត្រូវមានកត្តារួមផ្សំ ៤យ៉ាងសំខាន់ៗរួមមាន៖ ១.មានចំណេះដឹង ២.ចំណេះធ្វើឬបំណិន ៣.មានឥរិយាបថល្អ ៤.មានសុខភាពល្អ (ឃួន វ៉ានីន ឆ្នាំ២០២៣) ។

## ៣.គុណតម្លៃនៃមូលធនមនុស្ស

ពីមុនយើង យើងហាក់ដូចជាមិនចាប់អារម្មណ៍ពីមូលធនមនុស្សទេ ដោយដឹងតែពីធនធានមនុស្ស។ មិនថាធនធានមនុស្ស ឬមូលធនមនុស្ស សុទ្ធតែបម្រើឱ្យការអភិវឌ្ឍប្រទេសជាតិដូចគ្នា ក៏ប៉ុន្តែមូលធនមនុស្សមានលក្ខណៈស្របនឹងស្ថានភាពបច្ចុប្បន្ន។

មូលធនមនុស្សដើរតួនាទីយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ តាមទស្សនៈម៉ាក្រូសេដ្ឋកិច្ច ការប្រមូលផ្តុំមូល

ធនមនុស្សធ្វើឱ្យប្រសើរឡើងនូវផលិតភាព
ការងារ ជួយសម្រួលដល់ការច្នៃប្រឌិតបច្ចេក
វិទ្យា បង្កើនដើមទុនត្រឡប់មកវិញ និងធ្វើឱ្យ
កំណើនកាន់តែមាននិរន្តរភាព ដែលគាំទ្រដល់
ការកាត់បន្ថយភាពក្រីក្រ។ ដូច្នេះ មូលធន
មនុស្សត្រូវបានចាត់ទុកនៅកម្រិតម៉ាក្រូថាជា
កត្តាសំខាន់នៃផលិតកម្មក្នុងមុខងារផលិតកម្ម
សេដ្ឋកិច្ច ។តាមទស្សនៈមីក្រូសេដ្ឋកិច្ច ការអប់រំ
បង្កើនប្រូបាប៊ីលីតេនៃការមានការងារធ្វើនៅក្នុង
ទីផ្សារការងារ និងបង្កើនសមត្ថភាពប្រាក់
ចំណូល។ ដូច្នេះហើយ នៅកម្រិតមីក្រូ មូលធន
មនុស្សត្រូវបានចាត់ទុកថាជាធាតុផ្សំនៃការអប់រំ
ដែលរួមចំណែកដល់ផលិតភាពការងារ និង
ប្រាក់ចំណូលរបស់បុគ្គលម្នាក់ ខណៈដែលជា
ធាតុផ្សំដ៏សំខាន់នៃផលិតកម្មរបស់ក្រុមហ៊ុន។
ម្យ៉ាងវិញទៀត មូលធនមនុស្ស សំដៅលើ
សមត្ថភាព និងប្រសិទ្ធភាពរបស់មនុស្សក្នុងការ
បំប្លែងវត្ថុធាតុដើម និងដើមទុនទៅជាទំនិញ
និងសេវាកម្ម ហើយការយល់ស្របគឺថា ជំនាញ
ទាំងនេះអាចលេចចេញតាមរយៈប្រព័ន្ធអប់រំ។
ការអភិវឌ្ឍមូលធន គឺមានសារៈសំខាន់សម្រាប់
ការអភិវឌ្ឍសម្រាប់តម្លៃសកលនៅក្នុងសិទ្ធិ
របស់បុគ្គលម្នាក់ៗ មិនត្រឹមតែដោយសារតែ
តម្លៃរបស់វា ទោះបីជាការលោក់បាំងការបរិហារ
កេរ្តិ៍នៃមូលធនមនុស្សមានភាពច្បាស់លាស់ក៏
ដោយ ប៉ុន្តែការវាស់វែងរបស់វាមានការពិបាក
ព្រោះវាមិនអាចសង្កេតមើលជំនាញបុគ្គលនោះ
ទេ ហើយថែមទាំងពិបាកក្នុងការរចនាម៉ែត្រ
ដែលអាចប្រៀបធៀបបាននូវបុគ្គលគ្រប់រូប និង
ប្រទេសទាំងមូលទេ ( Hyun H. Son 2010)។

ដើមទុនវប្បធម៌ គោលគំនិតនៃមូលធន
វប្បធម៌ត្រូវបានបង្កើតឡើងដំបូងដោយ
Bourdieu និង Passeron ដើម្បីពន្យល់ពីអត្រា
ជោគជ័យនៃការអប់រំខ្ពស់របស់កុមារនៃឪពុក
ម្តាយដែលមានការអប់រំ។ នៅក្នុងទម្រង់ដើម
មូលធនវប្បធម៌ត្រូវបានគូសជាពាក្យអរូបីថាជា
'ទំនិញវប្បធម៌ដែលបញ្ជូនដោយសកម្មភាព
គរុកោសល្យគ្រួសារផ្សេងៗគ្នា ដែលតម្លៃនៃ
មូលធនវប្បធម៌ ។ ម្យ៉ាងវិញទៀត មូលធន
វប្បធម៌ សំដៅលើចំណេះដឹងស្របច្បាប់ដែល
ទទួលបាននៅក្នុងបរិយាកាសក្នុងផ្ទះ ដែលអាច
ឱ្យកុមារសម្រេចបាននូវលទ្ធផលដ៏មាន
ប្រយោជន៍បន្ថែមទៀតក្នុងអំឡុងពេលដំណើរ
ការអប់រំ (Bourdieu និង Passeron ឆ្នាំ១៩៧៧) ។
ចំពោះបរិស្ថានសេដ្ឋកិច្ច ការវិនិយោគលើ
មូលធនមនុស្ស ពាក់ព័ន្ធនឹងពេលវេលានិងការ
ចំណាយរបស់កុមារដោយឪពុកម្តាយដែលជះ
ឥទ្ធិពលដល់គុណភាពនៃមូលធនមនុស្សរបស់
កូនៗពួកគេ។ឪពុកម្តាយមិនអាចមានកម្ចី ដើម្បី
ផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគមូលធន

មនុស្សបានទេ (Andrés Erosa and Tatyana Koreshkova 2009)។

ការគ្រប់គ្រងមូលធនមនុស្ស (HCM) គឺជាសំណុំនៃការអនុវត្ត និងឧបករណ៍ដែលប្រើដើម្បីទាក់ទាញ ជ្រើសរើស បណ្តុះបណ្តាល អភិវឌ្ឍ គ្រប់គ្រង និងរក្សាបុគ្គលិក ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្ម។ អង្គការដែលពឹងផ្អែកលើបុគ្គលិក ដើម្បីសម្រេចបាននូវគោលបំណងរបស់ពួកគេបែងចែកធនធានដើម្បីអភិវឌ្ឍជំនាញស្នូលដែលបុគ្គលិករបស់ពួកគេត្រូវការដើម្បីផ្តល់លទ្ធផល។ ការគ្រប់គ្រងមូលធនមនុស្ស ជួយកំណត់គម្លាតនៅក្នុងសមត្ថភាពរបស់បុគ្គលិក និងផ្តោតលើការខិតខំប្រឹងប្រែងជ្រើសរើសបុគ្គលិកឆ្ពោះទៅរកតម្រូវការទាំងនោះ(Harvard និងក្រុម ២០១៨) ។

គុណតម្លៃនៃមូលធនមនុស្ស អាចត្រូវបានប៉ាន់ស្មានថាជាប្រាក់ចំណូលពេញមួយជីវិត។ យើងចាត់ទុកសមាមាត្រនៃតម្លៃនេះទៅជាបទពិសោធន៍ ដោយផ្អែកលើការផ្លាស់ប្តូរតួនាទី និងជំនាញដែលបានសង្កេតលើប្រវត្តិការងាររបស់បុគ្គលម្នាក់ និងកំណើនប្រាក់ឈ្នួលដែលរំពឹងទុកនាពេលអនាគតរបស់ពួកគេ។ យើងរកឃើញថាជំនាញដែលទទួលបាន ឬបង្ហាញតាមរយៈបទពិសោធន៍ការងាររួមចំណែកជាមធ្យម ៤៦%នៃប្រាក់ចំណូលពេញមួយជីវិតជាមធ្យម (Anu Madgagavkar and Group ឆ្នាំ២០២២)។

ភាពចម្រុះនៃ "ហានិភ័យរបស់មនុស្ស" នៅក្នុងអង្គការមួយរួមចំណែកដល់ការចំណាយសំខាន់ៗសម្រាប់ក្រុមហ៊ុនទំហំណាមួយ។ ការបង្កើនផលិតភាពកម្លាំងពលកម្មជាអតិបរមា និងកាត់បន្ថយផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនៃថ្លៃដើមទុនមនុស្សតម្រូវឱ្យមានវិធីសាស្ត្រសម្របសម្រួល( ALS Group 2024)(រូបភាពទី ២) ។




រូបភាពទី២៖ សំណុំនៃការអនុវត្តមូលធនមនុស្ស (រូបភាពរបស់ALS Group 2024)

តាមគេហទំព័រសាយអិនធីហ្វិកអ៊ីនហ្វូ (scientificworldinfo.com) កំណត់ថា មូលធនមនុស្ស គឺជារង្វាស់នៃជំនាញ ចំណេះដឹង សមត្ថភាព ឥរិយាបថសង្គម និងឥរិយាបថ

បុគ្គលផ្ទាល់ដែលជះឥទ្ធិពលដល់សមត្ថភាពផលិតភាពរបស់បុគ្គលិកនិងសក្តានុពលរកប្រាក់ចំណូល ដើម្បីផលិតតម្លៃសេដ្ឋកិច្ច។

ចំពោះគេហទំព័រសាយហ្គោប្រាយហ្គ្រីតដត់ខម (gobridgit.com) បង្ហាញថា មូលធនមនុស្សអាចផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដោយមិនមានការបដិសេធចំពោះការចំណាយហិរញ្ញវត្ថុខ្ពស់នោះទេ។ ខាងក្រោមជាអត្ថប្រយោជន៍នៃការវិនិយោគមូលធនមនុស្ស៖

- ធ្វើឱ្យប្រសើរឡើងនូវអត្រាការបន្តរបស់និយោជិត(Improved employee retention rates)
- កែលម្អឡើងវិញលើការចំណាយទាក់ទងនឹងនិយោជិតទាំងអស់ (Improved returns on all employee related costs)
- តាមដានទិន្នន័យកម្លាំងពលកម្មការងារត្រឹមត្រូវ(More accurate workforce data tracking)
- ការរើសបុគ្គលិកកាន់តែប្រសើរ (Better employee prospecting)
- កំណត់អ្នកដឹកនាំនាអនាគត (Identifying future leaders)
- អភិវឌ្ឍទំនាក់ទំនង និងដំណោះស្រាយបញ្ហា (Improved communication and problem-solving)
- ឱកាសកាន់តែច្រើនសម្រាប់ភាពរីកចម្រើនក្នុងចំណោមសមាជិកសហគមន៍ខ្វះខាត(More opportunity for advancement among marginalized community members)
- គ្រប់គ្រងអតិថិជនកាន់តែប្រសើរ (Better client management)
- បរិស្ថានការងារវិជ្ជមានរឹតតែប្រសើរ (A more positive work environment)
- បណ្តុះបណ្តាលជំនាញច្បាស់លាស់តាមតម្រូវការ (Train for the exact skills you need) ។

នាយកសាលាជាអ្នកគ្រប់គ្រងមូលធនមនុស្ស តែមាននាយកសាលាតិចតួចប៉ុណ្ណោះដែលត្រូវបានបណ្តុះបណ្តាលក្នុងការគ្រប់គ្រងមូលធនមនុស្ស។ពួកគេនិយាយពីអ្វីដែលពួកគេត្រូវដឹងតាមរយៈការសាកល្បង កំហុស ការបំពេញការងារជាមួយក្រុមធនធានមនុស្ស (HR team)និងការត្រួតពិនិត្យ (រូបភាពទី៣) (Craig Chin and Group 2021)។




*រូបភាពទី៣៖នាយកសាលា ជាអ្នកគ្រប់គ្រងមូលធនមនុស្ស(រូបភាពរបស់ Arkansas ទំព័រទី២)*

*រដ្ឋាភិបាល មានតួនាទីយ៉ាងសំខាន់ ក្នុងការកសាងមូលធនមនុស្សដោយក្នុងនាមជាអ្នកផ្តល់សេវាសុខភាព ការអប់រំ និងហិរញ្ញវត្ថុ ដើម្បីធានាបានសិទ្ធិទទួលបានសមធម៌ក្នុងការឆក់យកឱកាស និងនិយ័តករនៃការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាពរបស់អ្នកផ្តល់សេវាឯកជន។រដ្ឋាភិបាលភាគច្រើន បានចំណាយថវិកាដោយផ្តល់អាទិភាពដល់វិស័យអប់រំ និងសុខាភិបាល ប៉ុន្តែជារឿយៗ សេវាសាធារណៈមានគុណភាពទាបពេកក្នុងការបង្កើតមូលធនមនុស្ស (World bank group2018)។ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ដែលក្នុងនោះ ការអភិវឌ្ឍវិស័យសង្គមកិច្ចជាអាទិភាពសំខាន់មួយៗនៅក្នុងបញ្ចកោណទី១ «**ការអភិវឌ្ឍមូលធនមនុស្ស**» និងក្នុងមុំទី២ «ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង» ដែលមានគោលដៅជាយុទ្ធសាស្ត្រ គឺការកសាង និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណប្រមូលផ្តុំ និងសង្គតិភាព ទាំងក្នុងប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម និងការពង្រឹងប្រព័ន្ធស្បៀងដែលផ្តល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាជនគ្រប់រូប(សម្តេចធិបតី ហ៊ុន ម៉ាណែត ឆ្នាំ២០២៣)។*

*ជារួម តាមការលើកឡើងមកខាងលើ មូលធនមនុស្ស ពិតជាមានសារៈសំខាន់ណាស់ក្នុងអភិវឌ្ឍប្រទេសជាតិ ព្រោះជាធនធានពហុវិស័យដែលបម្រើគ្រប់ជ្រុងនៃសង្គមមនុស្ស។បើប្រទេសមួយសម្បូរដោយមូលធនមនុស្សពិតប្រាកដ នោះវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យផ្សេងៗនៃសង្គមជាតិនោះ នឹងមានភាពរីកលូតលាស់ស្ទុកស្តម្ភសមជាអារ្យប្រទេស។*

## ឯកសារពិគ្រោះ

### ភាសាខ្មែរ


-*ក្រសួងអប់រំយុវជននិងកីឡា(២០២៣) សិក្ខាសាលាស្តីពី«ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងសាលារៀន ឆ្ពោះទៅរកបរិវត្តកម្មការអប់រំឌីជីថល»ថ្ងៃទី២៧ កញ្ញា ឆ្នាំ ២០២៣ ខេត្តកំពង់ចាម*

-*រាជបណ្ឌិត្យសភាកម្ពុជា(២០២២) វចនានុក្រមខ្មែរ ការផ្សាយរបស់ក្រុមប្រឹក្សាភាសាខ្មែរ*

-*រាជរដ្ឋាភិបាលកម្ពុជា (២០២៣) សារលិខិតសម្តេចមហាបវរធិតីហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសទិវាមនុស្សចាស់កម្ពុជានិងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។*


### ភាសាអង់គ្លេស


-Andrés Erosa and Tatyana Koreshkova (2009): How Important is Human Capital? A Quantitative Theory Assessment of World Income Inequality ,Concordia University,Department of Economics.

-Anu Madgagavkar and Group(2022):Human capital at work,The value of experience, Mckinsey Global Institute.

-Craig Chin and Group(2021): Arkansa Human Capital Handbook.

-Hyun H. Son(2010) Human Capital Development ,Asian Development Review,vol.27,no.2,pp29-56.

-Bourdleu, P.., and Passeron, J.(1977).Reproduction in Education, Society and Culture (2ndNedn.London: Sage Publication).


### គេហទំព័រ


https://gobridgit.com

https://buykhmerbook.com

https://marketbusinessnews.com

http://mosvy.gov.kh

https://scientificworldinfo.com

# ទស្សនវិជ្ជាសង្គម និង ទស្សនវិជ្ជានយោបាយខ្មែរ តាមរយៈរឿង ធម្មបាលកុមារ

*ដោយ៖ លោក* **ឈុន ផាវ៉េង**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្ដីផ្ដើម

*រឿងធម្មបាលកុមារ ដែលគេច្រឡំហៅថា រឿងកបិលមហាព្រហ្ម គឺជាទេវកថាមួយដែលបានបង្កប់នូវខ្លឹមសារទស្សនវិជ្ជាសង្គមនិងនយោបាយខ្មែរយ៉ាងជ្រាលជ្រៅ។ រឿងនេះបាននិងកំពុងមានប្រជាប្រិយភាពខ្លាំងសម្រាប់ជនជាតិខ្មែរគ្រប់វ័យជាច្រើនសតវត្សរ៍មកហើយ។ រឿងនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃព្រលឹងអរិយធម៌ជាតិខ្មែរ។ រាល់ពេលពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរជារៀងរាល់ឆ្នាំ ជនជាតិខ្មែរតែងនិទានរំលឹកអំពី រឿងធម្មបាលកុមារ នេះ តិចឬច្រើននៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ក្នុងគោលបំណងដាស់សតិសម្បជញ្ញៈ មនសិការស្មារតីមនុស្សទាំងឡាយឱ្យបរិបូណ៌ទៅដោយព្រហ្មវិហារធម៌ ពោលគឺឱ្យចេះមេត្តា ករុណា មុទិតា និងឧបេក្ខា ដល់ មនុស្សសត្វ គ្រប់វ័យ គ្រប់ប្រភេទ ដើម្បីជីវិតរស់នៅប្រកបដោយសេចក្ដីសុខចម្រើន។*

### ១.រឿងធម្មបាលកុមារ[1]

*ក្នុងកាលដើម នៃភទ្ទកប្បនេះ មានបុរស*



គេហទំព័រ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៖ *ពិធីបុណ្យចូលឆ្នាំខ្មែរ,* ផ្សាយថ្ងៃ សុក្រ ទី ១៧ ខែ មករា ឆ្នាំ ២០១៧។
http://www.mcfa.gov.kh/site/detail/25

*ម្នាក់ឈ្មោះ ធម្មបាល ជាបុត្រសេដ្ឋី ជាអ្នកមានចំណេះវិជ្ជាដ៏វិសេស រៀនចប់ចេះត្រៃវេទ តាំងពីអាយុបាន៧ ឆ្នាំ។ សេដ្ឋីបិតា បានសាងប្រាសាទឱ្យនៅទៀបដើមជ្រៃ១ ធំ នៅឆ្នេរទន្លេដែលជាទីនៅនៃបក្សីទាំងឡាយ។ ធម្មបាលកុមារនោះ បានចេះទាំងភាសាបក្សីទាំងពួងផង ហើយបានជាអាចារ្យសម្ដែងមង្គលផ្សេងៗ ដល់មនុស្សទាំងពួង។ គ្រា*

---

[1] *ពុទ្ធសាសនបណ្ឌិត្យ,* *ព្រះរាជពិធីទ្វាទសមាស,* បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ១៩៦៩

នោះមនុស្សលោករមែងរាប់អាន ព្រះមហាព្រហ្ម[2] និង កបិលមហាព្រហ្ម[3] ១អង្គទៀតថាជា អ្នកសម្តែងមង្គលដល់មនុស្សទាំងពួង។ កាលកបិលមហាព្រហ្មជ្រាបពត៌មាននោះ ក៏មកសួរបញ្ហានឹងធម្មបាលកុមារ ៣ខ ដោយសន្យាទុកថា បើដោះប្រស្នាបាននឹងកាត់ក្បាលបូជាធម្មបាលកុមារ បើដោះមិនបាននឹងកាត់ក្បាលធម្មបាលកុមារវិញ។ ធម្មបាលកុមារសុំឱ្យបង្អង់ ៧ថ្ងៃ សិនដើម្បីគិតប្រស្នា លុះវេលាកន្លងទៅ ៦ថ្ងៃហើយក៏គិតប្រស្នានោះមិនឃើញ ដឹងខ្លួនថា ព្រឹកនេះនឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្មជាប្រាកដ ហើយដូច្នេះគួរអញរត់ទៅពាក់ពួនលាក់ ខ្លួនឱ្យស្លាប់បង់ដោយខ្លួនឯងប្រសើរជាង ទើបចុះអំពីប្រាសាទទៅដេកពួននៅក្រោមដើមត្នោតមួយគូ ។ ដើមត្នោតនោះ សត្វឥន្ទ្រីញីឈ្មោលធ្វើសំបុកអាស្រ័យនៅវេលាយប់ឥន្ទ្រីញីសួរឥន្ទ្រីឈ្មោលថា ព្រឹកនេះយើងបានអាហារពីណាស៊ី (តែក្បួនខ្លះថា កូនឥន្ទ្រីសួរមេវា) ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងបានស៊ីសាច់ធម្មបាលកុមារ ដែលត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រីញីសួរថាប្រស្នានោះដូចម្តេច? ឥន្ទ្រីឈ្មោលឆ្លើយថា វេលាព្រឹកសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថា នៅមុខ ហេតុនោះមនុស្ស ទាំងឡាយត្រូវយកទឹកលុបមុខ។ ខ ១ ទៀតថា ថ្ងៃត្រង់សិរីស្ថិតនៅទីណា? ត្រូវឆ្លើយថា នៅទ្រូង ហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងទ្រូង។ ខ ១ ទៀតថា វេលាល្ងាចសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថា នៅជើង ហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងជើង។ ធម្មបាល កុមារបានឮដូច្នោះ ក៏ត្រឡប់ទៅប្រាសាទវិញ។ ព្រឹកឡើង កបិលមហាព្រហ្មមកដល់សួរប្រស្នា ធម្មបាលកុមារក៏ឆ្លើយដោះស្រាយតាមដែលបានឮមក កបិលមហាព្រហ្មទើបហៅធីតាទាំង៧នាក់ ដែលជាបាទបរិចារិកា[4]របស់ព្រះឥន្ទ្រ មកប្រាប់ថា ឥឡូវបិតាត្រូវកាត់ ក្បាលបូជាធម្មបាលកុមារ តែបើដាក់ក្បាលនោះ នៅលើផែនដី ក៏នឹងកើតជាភ្លើងឆេះទាំងលោកធាតុ បើបោះទៅលើអាកាស ភ្លៀងក៏នឹងរាំង បើនឹងចោលក្នុងមហាសមុទ្រ ទឹកក៏នឹងរីងស្ងួតហួតអស់ទៅ ដូច្នេះសុំឱ្យកូនទាំង ៧ នាក់យកពានមកទទួលក្បាល ថាហើយក៏កាត់ក្បាល ហុចទៅឱ្យនាងទុង្សាដែលជាកូនច្បង នាងទុង្សា ទើបយកពានចូលទៅទទួលក្បាលបិតា ហើយហែប្រទក្សិណាភ្នំព្រះសុមេរុ ៦០នាទី ហើយក៏អញ្ជើញទៅប្រតិស្ឋានទុកក្នុងមណ្ឌបនៅក្នុងគុហាគន្ធមាលីភ្នំកៃលាស បូជាដោយគ្រឿងទិព្វផ្សេងៗ ព្រះវិស្សកម្មក៏និម្មិតរោងដ៏ហើយដោយកែវ៧ប្រការ ឈ្មោះថា"ភគវតីស

[2]មហាព្រហ្ម តំណាងលទ្ធិព្រហ្មញ្ញសាសនា។

[3]កបិលមហាព្រហ្ម តំណាងលទ្ធិពុទ្ធសាសនាមហាយាន។

[4] បាទបរិចារិកា(ឬបាទបរិចាក) ជាស្ត្រីអ្នកបម្រើជិតជើង, ជាភរិយា, ជាស្ត្រីដែលស្វាមីត្រូវចិញ្ចឹម ឬជាប្រពន្ធ។

កា"[5] ឱ្យជាទីប្រជុំនៃទេវតា លុះដល់គម្រប់ ១ ឆ្នាំជាសង្ក្រាន្ត នាងទេពធីតាទាំង ៧ ក៏ផ្លាស់វេនគ្នាមកអញ្ជើញក្បាលកបិលមហាព្រហ្ម ចេញមកហែប្រទក្សិណភ្នំព្រះសុមេរុ[6]រាល់ៗឆ្នាំ ហើយត្រឡប់ទៅទេវលោកវិញ។

លុះគំរប់ឆ្នាំសង្ក្រាន្ត ទេពធីតាទាំង៧ ក៏ដូរសំវេនគ្នាហែក្បាលកបិលមហាព្រហ្ម ប្រទក្សិណភ្នំព្រះសុមេរុ រាល់ៗឆ្នាំរហូតមក[7] ។

## ២.សម្មតិកម្មនៃពាក្យគន្លឹះក្នុងរឿងធម្មបាលកុមារ

យើងសាកល្បងដាក់នូវសម្មតិកម្មមួយចំនួន ក្នុងគោលដៅស្វែងរកអំណះអំណាងចាំបាច់គ្រប់គ្រាន់(ទឡ្ហីករណ៍) ដើម្បីឈានដល់សន្និដ្ឋានឱ្យសមស្រប។ ពេលនេះយើងស្នើនូវសម្មតិកម្មដូចតទៅៈ **ក.មហាព្រហ្ម** គឺលទ្ធិព្រហ្មញ្ញសាសនា, **ខ.កបិលមហាព្រហ្ម** គឺលទ្ធិពុទ្ធសាសនាមហាយាន។ **គ.ធម្មបាលកុមារ** គឺលទ្ធិពុទ្ធសាសនាថេរវាទ។ **ឃ.កាត់ក្បាល** គឺការដកខ្លួនចេញ។ **ង.នៅក្រោមដើមត្នោតមួយគូ** គឺទឹកដីខ្មែរដែលនិយមគោរពជំនឿជីវចលនៃជំនឿមេបា។ **ង.សត្វឥន្ទ្រី**(ឬឥន្ទ្រិយ) គឺអំណាចជាធំនៃការដឹងតាមអាយតនៈខាងក្នុងទាំង៦ៈ ១.ចក្ខុន្ទ្រិយ(ភ្នែក); ២.សោតិន្ទ្រិយ(ត្រចៀក) ៣.ឃានិន្ទ្រិយ(ច្រមុះ) ៤.ជិវ្ហិន្ទ្រិយ(អណ្តាត) ៥.កាយិន្ទ្រិយ(កាយ) ៦.មនិន្ទ្រិយ(មនោ ឬ ចិត្ត)។ អាយតនៈខាងក្នុងទាំង៦ នេះជាធំក្នុងការទទួលដឹង។ **ច.វេលាព្រឹកសិរីស្ថិតនៅមុខ ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលុបមុខ** គឺមានន័យថាក្នុងបឋមវ័យ(វ័យកុមារ) ជោគជ័យមង្គល សួស្តី លាភ ឥស្សរភាព តេជះអំណាច សេចក្តីសុខចម្រើនភ័ព្វព្រេងសំណាងល្អទាំងឡាយ ស្ថិតនៅលើរាងកាយប៉ែកខាងលើ ពោលគឺក្បាល ដែលជាប្រធាននៃសរីរាង្គកាយទាំងមូល ដែលក្នុងនោះ មាន មាត់ អណ្តាត ត្រចៀក, ភ្នែក, ច្រមុះជាដើម។ ហេតុនេះគេត្រូវយកចិត្តទុកដាក់លើការអប់រំ មនុស្សឱ្យមានសីលធម៌ និងចំណេះដឹងទាន់ខ្លួននៅក្មេង។ **ឆ.វេលាថ្ងៃត្រង់សិរីស្ថិតនៅទ្រូង ហេតុនោះ មនុស្សទាំងឡាយទើបយកទឹកលាងទ្រូង** គឺមានន័យថា នៅមជ្ឈិមវ័យ(វ័យកណ្តាល ឬយុវវ័យ) ជាវ័យស្នេហា។ យុវវ័យគឺជាវ័យដែលត្រូវស្រឡាញ់ ការងារ ជាវ័យស្នេហា បង្កបង្កើតគ្រួសារប្តីប្រពន្ធ ផ្តល់កំណើតនិងចិញ្ចឹមរក្សាកូន ដើម្បីបន្តពូជពង្សនិងនិរន្តរភាពសង្គម។ **ជ.វេលាល្ងាចសិរីស្ថិតនៅជើង ហេតុនោះមនុស្សទាំងឡាយទើបយកទឹកលាងជើង** គឺមានន័យថា នៅបស្ចិមវ័យ(វ័

[5] កគវតីសាលា ជាផ្ទះ មន្ទីរ ឬរោងសម្រាប់ស្ត្រីអ្នកមានបុណ្យមានស័ក្តិធំទាំងពួង។

[6] សុមេរុ ភ្នំខ្ពស់ជាងភ្នំទាំងអស់ក្នុងសាកលលោក, ជាទីតាំងនៃត្រៃត្រិង្សសួគ៌ ដែលជាឋានរបស់ព្រះឥន្ទ្រ។

[7] ត្រឹង ង៉ា(អ្នកស្រី), *អរិយធម៌ខ្មែរ(ថ្នាក់ទីបញ្ចាប់)*, ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី៣, ១៩៧៤ ទំព័រ ២១០

យចាស់) ដារ័យដើរចាកចេញពីតួនាទីទទួលខុសការងារសង្គម ដើម្បីទុកឱកាសដល់យុវជនជំនាន់ក្រោយ ដោយសន្តិវិធី ទៅរកកន្លែងស្ងប់ក្នុងជីវិតសមាធិ(គឺជីវិតចូលនិវត្តន៍)។ ***ឈ.យកពានមកទទួលក្បាល*** គឺការលើកតម្លៃព្រហ្មវិហារធម៌ មានមេត្តាករុណា មុទិតា និងឧបេក្ខា។ ***ញ.គម្រប់១ឆ្នាំជាសង្រ្កាន្តនាងទេពធីតាទាំង ៧ ក៏ផ្លាស់វេនគ្នា*** គឺ៖១.ថ្ងៃអាទិត្យ ទុង្សាទេវី គ្រឿងអាភរណៈ ពណ៌ក្រហម សៀតផ្កាទទឹម គ្រឿងប្រដាប់កែវបទុមរាគ សោយផ្លែល្វា ដៃស្ដាំកាន់កងចក្រ ឆ្វេងកាន់ខ្យងស័ង្ខ ពាហនៈ ឥន្ទ្រី។ ២.ថ្ងៃចន្ទ ទេវតានាម គោរាគទេវី គ្រឿងអាភរណៈ ពណ៌លឿងទុំ សៀតផ្កាអង្គាបុស្ស គ្រឿងប្រដាប់ កែវមុក្ដា សោយតេលំ (ប្រេង) ព្រហស្ដស្ដាំកាន់ព្រះខ័ន ឆ្វេងកាន់ ឈើច្រត់ ពាហនៈ ព្យគ្ឃៈ (ខ្លា)។ ៣.ថ្ងៃអង្គារ ទេវតានាម រាក្សសាទេវី ពណ៌ស្វាយក្រម៉ៅ សៀតផ្កាឈូក គ្រឿងប្រដាប់ កែវមោរា សោយលោហិត(ឈាម) ដៃស្ដាំកាន់ ត្រីសូល៍ ឆ្វេងកាន់ ដងធ្នូ ពាហនៈ សត្វសេះ។ ៤.ថ្ងៃពុធ ទេវតានាម មណ្ឌាទេវី ពណ៌ស៊ីលាប សៀតផ្កាចម្ប៉ាគ្រឿងប្រដាប់ កែវពិទូរ្យ សោយទឹកដោះសិប្បិ (ទឹកដោះស្រស់) ដៃស្ដាំកាន់ម្ជុល ឆ្វេងកាន់ឈើច្រត់ ពាហនៈ សត្វលា។ ៥.ថ្ងៃព្រហស្បតិ៍ ទេវតានាម កិរិណីទេវី ពណ៌បៃតង សៀតផ្កាចំប៉ី គ្រឿងប្រដាប់ត្បូង មរកតសោយសណ្ដែក ល្ង ព្រហស្ដស្ដាំកាន់ កង្វេរ ដំរី ឆ្វេងកាន់កាំភ្លើងបាញ់ ពាហនៈ ដំរី។ ៦.ថ្ងៃ សុក្រ ទេវតានាម កិមិរ៉ាទេវី ទ្រង់ពណ៌ស សៀតផ្កា រំចង់ សោយចេកណាំវ៉ា ព្រហស្ដស្ដាំកាន់ ព្រះខ័ន ឆ្វេងកាន់ ពិណ ពាហនៈ ក្របី ។ ៧.ថ្ងៃសៅរ៍ ទេវតានាមមហោទរាទេវី ទ្រង់ពណ៌ខៀវ សៀតផ្កាកណិកា គ្រឿងប្រដាប់ត្បូង និលរ័ត្ន សោយសាច់ទ្រាយ(ពពួក ក្ដាន់ ឈ្លូស) ស្ដាំកាន់កងចក្រ ឆ្វេងកាន់ ត្រីសូល៍ ពាហនៈ ក្ងោក ។***ដ.កែវ៧ប្រការគឺ៖*** ១.សុវណ្ណៈ(មាស) ២.រជតៈ(ប្រាក់) ៣.មុត្ដា (គជ់ខ្យង) ៤.មណិ(កែវមណី) ៥.វេឡុរិយៈ(កែវពិទូរ្យ, កែវភ្នែកឆ្មា) ៦.វជិរៈ(ពេជ្រ) ៧.បវាឡៈ(កែវប្រពាល)។ ***ឋ.ព្រះឥន្ទ្រ*** គឺអាទិទេព សំខាន់ទាំងក្នុងលទ្ធិព្រាហ្មណ៍និងលទ្ធិពុទ្ធ សាសនាថេរវាទ។ ព្រះឥន្ទ្រជាអ្នកចម្បាំង, ជាទេពបង្អុរទឹកភ្លៀង, ចូលចិត្តសេពសុរា, ល្មោភកាមគុណ ប្រពន្ធច្រើន(ក្នុងនោះមានទេពធីតាជាបុត្រីកបិលមហាព្រហ្មទាំង៧ផងដែរ) និងមានស្រីស្នំច្រើនពាន់នាក់ទៀតនៅតែមិនស្កប់ស្កល់។ ព្រះឥន្ទ្រសោយរាជ្យនៅឋានសួគ៌ គឺភ្នំព្រះសុមេរុ។ ***ឌ.ទេវលោក*** គឺឋានទេវលោកទាំង៧គឺ៖ចាតុម្មហារាជិកា, តាវត្តិង្ស, យាមា, តុសិតា, និម្មានរតី, បរនិម្មិតវសវតី និងឋានដ៏ខ្ពង់ខ្ពស់មួយទៀតគឺឋានព្រហ្មលោក។ ឋានទាំ៧នេះរមែងបែងចែកបដិសន្ធិសត្វទៅតាមកម្លាំងបុញ្ញកម្មដែលខ្លួនបានសាងហើយ ។ តាមគម្ពីរធម្មបទបានបរិយាយថា៖ ១.អ្នកណាឲ្យទាន ដោយប្រាថ្នាផលតបមកវិញយ៉ាងណាមួយក្នុងភពខាងមុខ កាលស្លាប់ហើយ

នឹងកើតជាទេវតាជាន់ចាតុម្មហារាជិកា ។ ២.អ្នកណាឲ្យទាន ដោយមិនប្រាថ្នាផលតបមកវិញក្នុងភពខាងមុខទេ គឺឲ្យដោយគិតថា ការឲ្យទានជាការល្អ កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់តាវត្តិង្ស ។ ៣.អ្នកណាឲ្យទាន ដោយគិតថា មាតា បិតា យាយ តា ធ្លាប់ធ្វើមកហើយ គួរធ្វើតទៅ មិនឲ្យខូចប្រពៃណី កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់យាមា ។ ៤.អ្នកណាឲ្យទានដោយមេត្តា ប្រាថ្នានឹងឲ្យអ្នកទទួលទាននោះមានសេចក្ដីសុខ មិនមានសេចក្ដីលំបាក កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់តុសិត ។ ៥.អ្នកណាឲ្យទាន ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ អ្នកឲ្យទានកន្លងមកពីកាលមុនកាល ស្លាប់ហើយ នឹងកើតជាទេវតាជាន់និម្មានរតី។ ៦.អ្នកណាឲ្យទាន ដោយឃើញថា កាលឲ្យទានហើយ នឹងធ្វើចិត្តឲ្យសោមនស្សកើតសេចក្ដីជ្រះថ្លា កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់បរនិម្មិតវសវត្តី។ ៧.អ្នកណាឲ្យទាន ដើម្បីជម្រះចិត្តឲ្យផូរផង់ បានឈាន កាលស្លាប់ហើយ នឹងកើតក្នុងព្រហ្មលោក។ ការបំពេញទានដោយមេត្តាចិត្តគិតឱ្យអ្នកទទួលបានសុខរួចចាកទុក្ខទាំងពួង ទានរបស់លោកអ្នកនឹងទទួលបានផលច្រើនតាមកម្លាំងសទ្ធា។

យើងអាចសន្និដ្ឋានបានថា តាមដំណើររឿងធម្មបាលកុមារ, តួអង្គកបិលមហាព្រហ្ម ដែលតំណាងឲ្យពុទ្ធសាសនានិកាយមហាយាន បានដកខ្លួនចេញឈប់មានតួនាទីផ្សព្វផ្សាយគោលលទ្ធិរបស់ខ្លួនជាផ្លូវការ ជាសាធារណៈដូចមុនទៀតឡើយ ដោយប្រគល់តួនាទីឱ្យធម្មបាលកុមារដែលតំណាងឱ្យពុទ្ធសាសនានិកាយថេរវាទ ជាអ្នកមាននាទីជំនួសវិញ។

### ៣.ប្រវត្តិនៃការផ្លាស់ប្ដូរលទ្ធិសាសនានៅកម្ពុជា

នៅមុននិងក្រោយសម័យអង្គរ សាសនាមានមុខងារយ៉ាងសំខាន់ក្នុងសង្គម និង នយោបាយខ្មែរ។ អ្នកដឹកនាំខ្មែរ មានជំនឿលើសាសនាមិនដូចគ្នាទេ ព្រះរាជាអង្គខ្លះកាន់លទ្ធិព្រាហ្មណ៍សាសនា និងខ្លះទៀតកាន់ព្រះពុទ្ធសាសនា។ ចំពោះលទ្ធិព្រាហ្មណ៍សាសនា មាននិកាយ៣ខុសគ្នា។ ព្រះរាជាខ្លះកាន់សាសនាឥស្សរ ខ្លះកាន់សាសនាព្រះវិស្ណុ ខ្លះកាន់សាសនាព្រះព្រហ្ម។ ចំណែកពុទ្ធសាសនាមានព្រះរាជាខ្លះកាន់មហាយាន និងខ្លះនិកាយថេរវាទ។ នៅសម័យនោះសាសនាទាំងនេះសម្រាប់តែព្រះរាជានិងពួកអភិជនប៉ុណ្ណោះ មិនសូវជ្រួតជ្រាបចូលក្នុងស្រទាប់ទាបនៃសង្គមឡើយ ព្រោះប្រជាជនដែលនៅតែថែរក្សាជំនឿដើម គឺជំនឿលើអារក្សអ្នកតា ដោយគោរពដុំថ្មជាតំណាងជាដើម។

ពីស.វ.ទី៩ ដល់១១ គណៈសិវនិយមមានឧត្តមភាពលើគណៈឯទៀតៗ ព្រោះព្រះរាជាភាគច្រើនបានចាត់ទុកថាជាសាសនានេះសម្រាប់រដ្ឋ។ ដោយការប្រារព្ធធ្វើពិធីទេវរាជ ព្រះរាជាមានឋានៈ

ស្មើអាទិទព(ព្រះឥសូរ) ហើយមានសិវលិង្គជាតំណាងតំកល់ក្នុងប្រាសាទភ្នំ។ ប៉ុន្តែក្នុងរយៈពេលខាងលើនេះគេ បានសង្កេតឃើញថា ព្រះរាជាទាំងឡាយតែងបានយកព្រះហឫទ័យទុកដាក់ និងជួយឧបត្ថម្ភចំពោះ សាសនាឯទៀតដែលបានរួមរស់ជាមួយគ្នាយ៉ាងសុខដុមរមនា ដែលមានសិលាចារិក និងរូបបដិមាអាចបញ្ជាក់បានយ៉ាងបរិបូណ៌លើកលែងតែក្នុងរជ្ជកាលរបស់ព្រះបាទឧទយាទិត្យវរ្ម័នទី២ ដែលមានការបះបោរបីលើក ហើយដែលគេឃើញពួកបះបោរដើរវាយកំទេចសិវលិង្គ និង ទេវបដិមា ចោល។ នៅស.វទី១២ គណៈវិស្ណុនិយមត្រូវបានព្រះបាទសូរ្យវរ្ម័នទី២ គោរពរាប់អានសម្បើមដូចមាន ប្រាសាទអង្គរវត្តជាសក្ខីភាពស្រាប់។[8] ...តពីនេះទៅ គេឃើញថាពុទ្ធសាសនាមហាយាន ដែលបាននាំចូលមកតាំងពីសម័យចេនឡា(ស.វទី៤) ហើយដែលបានព្រះបាទសូរ្យវរ្ម័ទី១កាន់ម្តងរួចហើយ(ស.វ.ទី១១) ត្រូវបានព្រះរាជាលើក តំកើងជាសាសនាសម្រាប់រដ្ឋតែម្តង ជាពិសេសក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧។ ប្រាសាទបាយ័ន ដែលព្រះអង្គសាងឡើង នៅមានទ្រង់ទ្រាយជាប្រាសាទភ្នំ ហើយស្ថិតនៅកណ្តាលរាជធានីដដែល តែរូបសំណាក ព្រះរាជាគឺជា ពុទ្ធបដិមា ទៅវិញ (ពុទ្ធរាជ)។ ហេតុអ្វីបានជាមានការប្រែប្រួលយ៉ាងនេះ? ត្រង់នេះគួរគប្បីជ្រាបថា ការវាយយកបានក្រុងអង្គរដោយទ័ពចាម នៅគ.ស.១១៧៧ ហើយជាលើកទី ១ផងនោះ ជាអន្ទងមួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ។ ប្រជារាស្ត្រទំនងជាចង់លែងជឿទៅលើប្រសិទ្ធភាព លទ្ធិនេះទៀតហើយ ក៏ប៉ុន្តែពួកព្រាហ្មណ៍ជាបរិវារ នៅមានឥទ្ធិពលខ្លាំងក្លាណាស់នៅឡើយ ទើបព្រះបាទជ័យវរ្ម័នទី៧ទ្រង់ឈ្វេងយល់ថា ត្រូវតែរក្សាទុករបស់ចាស់ខ្លះ(មិនអាចកំចាត់ចោលភ្លាមៗបានទេ) ហើយយករបស់ថ្មីខ្លះមកប្រើ ដើម្បីឱ្យមានសង្ឃឹមដល់ប្រជារាស្ត្រដោយផ្សំធាតុសិវនិយមខ្លះ(ប្រាសាទភ្នំ) និង ពុទ្ធនិយមខ្លះ(ពុទ្ធរាជ)។ ដូច្នេះយើងឃើញថាពុទ្ធសាសនាមហាយានបានមកដល់ទាន់ពេលវេលា ដើម្បីស្រោចស្រង់ជាតិ ឱ្យមានពន្លឺឡើងវិញ ក្រោយព្រឹត្តិការណ៍១១៧៧ ដែលព្រះបាទជ័យ វរ្ម័នទី៧ ហ៊ានយកលទ្ធិនេះមកប្រើ ព្រោះពេលនោះពុទ្ធសាសនិក ក៏មានកាន់តែច្រើនណាស់ហើយ ហើយម្យ៉ាងទៀតលទ្ធិនេះជាលទ្ធិបែបមនុស្សនិយម មានទំនោរទោរទៅរកជីវភាពប្រជារាស្ត្រ ទូទៅ ដូចរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាសក្ខីភាពស្រាប់ ហើយដើម្បីបង្ហាញឱ្យឃើញនូវព្រះហឫទ័យមេត្តាករុណាចំពោះប្រជារាស្ត្រនេះ ព្រះអង្គទ្រង់បាន

[8] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ១១៣

កសាងមន្ទីរពេទ្យ ១០២ សម្រាប់ជនទាំង៤វណ្ណៈចូលព្យាបាលជម្ងឺបានដូចៗគ្នា។ ទាំងនេះសឱ្យឃើញថា នៅចំពោះប្រជារាស្ត្រ លទ្ធិពុទ្ធសាសនាមហាយាន មានសមត្ថភាពមិនចាញ់លទ្ធិទេវរាជទេ គឺមានសមត្ថភាពការពារស្រោចស្រង់និងបំរើរាស្ត្របានដូចគ្នា។ តែអកុសល ការផ្លាស់ប្តូរសាសនានៅតែមានបន្តទៅទៀត។ ព្រះបាទជ័យវរ្ម័នទី៨ត្រឡប់ទៅរក សិវនិយម វិញដែលជាហេតុបណ្តាលឱ្យមានប្រតិកម្មយ៉ាងខ្លាំងក្លាពីពួកព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនា(មហាយាន)រហូតដល់មានការវាយកំទេចឬកោសលុបព្រះពុទ្ធបដិមាចោល។ ស្ថានការណ៍បែបនេះទំនងជាមានសភាពរ៉ាំរ៉ៃរហូតដល់បដិវត្តន៍នាយត្រសក់ផ្អែមដែលបានយកពុទ្ធសាសនា ហីនយានមកជំនួសជាស្ថាពររហូតមកដល់សព្វថ្ងៃនេះ។[9]

ទំនាស់ក្នុងផ្លូវសាសនានេះមានយូរណាស់មកហើយ គឺតាំងពីក្នុង រជ្ជកាលឧទយាទិត្យវរ្ម័នទី២ ម៉្ងៃ(១០៥០-១០៦៦) ដោយនៅពេលនោះ គេឃើញមានការបះបោរបីលើក ហើយក្នុងចលនាទាំងនោះ ពួកបះបោរបានវាយកំទេចសិវលិង្គ និងបដិមាផ្សេងៗខាងព្រាហ្មណ៍សាសនាផង។ ឯពុទ្ធសាសនាឃើញថាមានការចំរើនលូតលាស់កាន់តែខ្លាំង ជាពិសេសក្នុងរជ្ជកាលរបស់ ព្រះបាទធរណីន្ទ្រវរ្ម័នទី២ (១១៥៥- ?) និងព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨?)រហូតដល់មាន ប្រតិកម្មយ៉ាងខ្លាំងក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៨ ពីសំណាក់អ្នកកាន់ពុទ្ធសាសនានិងសាសនាព្រាហ្មណ៍។ ដូច្នេះយើងឃើញថា វិបត្តិខាងសាសនាកាន់តែរីកធំឡើង ដោយបន្ទាប់ពីនោះមានស្តេចខ្លះក៏ត្រឡប់ទៅ កាន់ពុទ្ធសាសនាវិញ ហើយជាពុទ្ធសាសនាថេរវាទថែមទៀត ដែលព្រះអង្គម្ចាស់តាមលិន្ទបាននាំចូល ស្រុកខ្មែរប្រហែលតាំងពីរជ្ជកាលឥន្ទ្រវរ្ម័នទី២មកម្ល៉េះ ហើយក៏មានស្តេចខ្លះត្រឡប់ទៅកាន់សាសនាព្រាហ្មណ៍វិញដែរ រហូតដល់រជ្ជកាលរបស់នាយត្រសក់ផ្អែម និងកូនចៅរបស់គាត់ដែលសោយរាជ្យតរៀងមក ទើបស្តេចខ្មែរកាន់ជាប់តែពុទ្ធសាសនារហូតដល់សព្វថ្ងៃ។ ត្រង់នេះហើយជាហេតុនាំឱ្យ អ្នកប្រវត្តិសាស្ត្រខ្លះយល់ថា កាលដែលនាយត្រសក់ផ្អែមធ្វើគត់ស្តេច ហើយបាននាម៉ឺនសព្វមុខមន្ត្រីលើកឱ្យឡើងសោយរាជ្យ ជាបដិវត្តន៍ដណ្តើមយកអំណាចនយោបាយ និង អំណាចសាសនាដែលជាប់គ្នា ព្រោះក្នុងសម័យនោះអំណាចទាំងពីរស្ថិតនៅក្នុងការកាន់កាប់របស់ព្រះមហាក្សត្រទាំងអស់។[10]

**៤.ព្រះព្រហ្មក្នុងលទ្ធិព្រាហ្ម**

---

[9] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ ១១៤

[10] ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ ១០៥



ព្រះព្រហ្ម ជាអាទិទេពមួយអង្គក្នុងចំ-ណោមអាទិទេពទាំងបីក្នុង ព្រហ្មញ្ញសាសនា។ នៅក្នុងព្រហ្មញ្ញសាសនា ទ្រឹស្តីត្រីមូ៌តិ ជាលទ្ធផលនៃការបង្រួបបង្រួមអាទិទេពដែលមានឥទ្ធិពល។

ដើមឡើយ បរិស័ទដែលមានភក្តីចំពោះអាទិទេពខ្លួនបានប្រយុទ្ធការពារអាទិទេពរបស់ខ្លួនយ៉ាងប្តូរផ្តាច់រហូតបណ្តាលឱ្យមនុស្សសត្វរងទុក្ខវេទនាហិនហោចខ្ទោចផ្សារក្នុងសង្គ្រាមដើម្បីបូជាការពារអាទិទេពរបស់ខ្លួនអស់រយៈពេលដ៏យូរ និងស្លាប់អស់ជាច្រើនឥតគណនា។

ទីបំផុត បានទទួលព្រមថា ព្រះត្រីមូ៌តិ គឺអវតារតំណាងឱ្យអាទិទេពទាំងបីៈ ក.ព្រះព្រហ្មទេពបង្កើតលោក ខ.ព្រះវិស្ណុ ទេពការពារ និងថែរក្សាលោក គ.ព្រះសិវ ទេពបំផ្លាញលោក និងបង្កើតលោកឡើងវិញ។

មាននិទានថា ព្រះព្រហ្ម ទ្រង់បានបង្កើតផែនដីតាមរយៈការនិមិត្តនៅស៊ុតមាសមួយ ដែលហោះអណ្តែតនៅក្នុងចក្រវាឡ អស់១ម៉ឺនកល្ប (៤,៩៤ពាន់លានឆ្នាំ) ហើយស៊ុតនោះទ្រង់បានបំបែកវាជាពីរផ្នែកៈ ទី១ ក្លាយមេឃ ទី២ក្លាយជាផែនដី។ ទ្រង់បង្កើតឱ្យមានធម្មជាតិ និង សត្វរស់នៅ។ រាប់រយពាន់ឆ្នាំ បន្ទាប់មកក៏បង្កើតឱ្យមានសភាវៈពីរ គឺ ពួកយក្ស និង ពួកស្វា រមែងធ្វើចម្បាំងនិងគ្នាមិនចេះចប់មិនចេះហើយ បន្ទាប់មកការវិវឌ្ឍន៍ចុងក្រោយរបស់ពួកស្វា បានក្លាយខ្លួនជាអំបូរមនុស្ស ដែលបែងចែកជា ២ភេទ ភេទប្រុស និង ភេទស្រី ដែលប្រុសហៅថាបុមៈ ស្រីហៅថាវិរដ្ឋា។ អំបូរមនុស្សបានរួមរស់ប្រវេណីជាមួយគ្នាកាន់តែច្រើនឡើងៗ កើតជាពូជមនុស្សពាសពេញពិភពលោក។ ព្រះព្រហ្ម ជាបង្កើតមនុស្ស និងបែងចែកមនុស្សក្នុងវណ្ណៈបួនផ្សេងគ្នាគឺៈ ១.វណ្ណៈព្រាហ្មណ៍ ជាវណ្ណៈខ្ពស់បំផុតកើតពីព្រះឱស្ឋ (មាត់) របស់ព្រះព្រហ្ម ជាអ្នកថែរក្សា និងនាំពាក្យរបស់អាទិទេព។ ពួកព្រាហ្មណ៍ស្លៀកពាក់ស មានសិទ្ធិរៀនសូត្រគម្ពីរវេទគ្រប់បែបយ៉ាង។ ២.វណ្ណៈក្សត្រ កើតពីព្រះហស្តរបស់ព្រះព្រហ្ម ជាអ្នកគ្រប់គ្រងប្រទេស ជាអ្នកចម្បាំង ព្រមទាំងរៀនយុទ្ធវិធីនានាផង។ វណ្ណៈក្សត្រស្លៀកពាក់ក្រហម ជានិមិត្តរូបនៃសេចក្តីក្លាហាន។ ៣.វណ្ណៈវៃស្យ (ឬវេស្សៈ) ជាវណ្ណៈកណ្តាល កើតពីភ្លៅរបស់ព្រះព្រហ្ម ដែលមានចំនួនភាគច្រើនក្នុងសង្គមជាប្រជាពលរដ្ឋទូទៅមានសិល្បករ សិប្បករ កសិករ ពួកឈ្មួញ ជា

ដើម។ វណ្ណៈវៃស្យស្លៀកពាក់ពណ៌លឿង។ ៤.វណ្ណៈសូទ្រ ជាវណ្ណៈទាបបំផុតក្នុងសង្គម កើតពីបាតជើងរបស់ព្រះព្រហ្ម ជាខ្ញុំបម្រើគេ ជាទាសករស្លៀកពាក់ពណ៌ខ្មៅ។ លក្ខណៈពិសេស សម្គាល់ព្រះព្រហ្មក្នុងលទ្ធិព្រាហ្មណ៍សាសនា គឺមាន៖ ១.ព្រះភ័ក្ត្រ៤ ព្រះហស្ត៤ ដោយមានកាន់កេតណភ័ណ្ឌ៤យ៉ាងមានដូចជា ក.គម្ពីរវេទ ខ.ស្លាបព្រា គ.ថូទឹក និង ឃ.ខ្សែរផ្គាំ។ ២.រាងកាយសម្បុរពណ៌ផ្កាឈូកស្រាល ចំពោះយានជំនិះរបស់ព្រះព្រហ្មគឺ៖ ផ្កាឈូក១ពាន់ស្រទាប់ និងសត្វហង្ស ហើយព្រះព្រហ្ម ប្រថាប់នៅលើហង្សក្នុងទម្រង់លក្ខណៈចេញច្បាំងតែប៉ុណ្ណោះ ។ ព្រះភ័ក្ត្រទាំង៤របស់ព្រះព្រហ្ម៖ ក.ព្រះភ័ក្ត្រខាងកើត តំណាងឱ្យកំណើតសត្វលោក។ ខ.ព្រះភ័ក្ត្រខាងលិច តំណាងឱ្យការវិលស្លាប់របស់សត្វលោក។ គ.ព្រះភ័ក្ត្រខាងជើង តំណាងឱ្យដួងព្រលឹង។ ឃ.ព្រះភ័ក្ត្រខាងត្បូង តំណាងឱ្យភាពបរិសុទ្ធ។ តាមកំណើតរបស់ព្រះព្រហ្មដែលកើតពីផ្កាឈូកមានព្រះភ័ក្ត្រចំនួន៥ តែព្រះភ័ក្ត្រទី៥ត្រូវបាន ព្រះឥសូរ ឬ ព្រះសីវៈកាត់បំផ្លាញចោលនៅពេលដែលប្រព្រឹត្តកំហុសរំលោភកូនខ្លួនឯង។ ព្រះព្រហ្មមានមហាសី ២អង្គមានព្រះនាមថា "សាវីទ្រី" និង "ព្រះម៉ែសារ៉ាវត្តី" ដែលមានកំណើតផុសចេញពីទឹកស្រះព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៦ ជាទេពធីតាតំណាងឱ្យដូរ្យតន្ត្រី និងសិរីសួស្តី។ ព្រះព្រហ្ម ក្នុងលទ្ធិព្រាហ្មណ៍សាសនាមានបុត្រា២អង្គ និង បុត្រី១អង្គ គឺ៖ ១.ព្រះព្រហ្មទសក្ស (ទោះក្សៈ) ជាព្រហ្មមានពន្ទី១០ពណ៌ និងមានព្រះឱសថទិព្វ គង់នៅឋានព្រហ្មលោកនៃឋានសួគ៌ជាន់ទី១៥។ ២.ព្រះព្រហ្មភ័គុ(ភរគុ) ជាអទិទេពតំណាងឱ្យអំណាចរបស់ឋានសួគ៌ទាំងអស់ គង់នៅឋានព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៤។ ៣.កូនស្រី ព្រះនាម ទេពធីតាសំធ្យា ឬ សន្ធិយា គង់នៅឋានព្រហ្មលោក នៃឋានសួគ៌ជាន់ទី១៣ ។

ព្រះព្រហ្មបានប្រព្រឹត្តកំហុសធំ២យ៉ាង៖ ១.ទុច្ចរិតបន្ទំយកផ្កាកិកីពីឋានរកកុហក់ថាជាសរសរភ្លើង ២.ចាប់រំលោភទេពធីតាសំធ្យា ដែលជាបុត្រីបង្កើតរបស់ខ្លួនដោយព្រួញកាមទេព។

## ៥.ទ្រឹស្តីនៃលទ្ធិពុទ្ធសាសនាមហាយាន

ព្រះព្រហ្ម ក្នុងជំនឿពុទ្ធសាសនាមហាយាន មានឈ្មោះថា អវលោកេស្វរៈ។ យើងសង្កេតឃើញថា ទិដ្ឋភាពរួមនៃប្រាសាទបាយ័ន(អ្នកខ្លះហៅថា ប្រាសាទព្រហ្មបាយ័ន) និង ក្លោងទ្វារនៃទីក្រុងអង្គរធំ ដែលមានរូបព្រហ្មមុខបួន និង ចម្លាក់តំណាងព្រះភ័ក្ត្រនៃព្រះពោធិសត្វអវលោកេស្វរៈ នៅប្រាសាទតាសោម ដែលគេហៅថា មុខព្រហ្មមុខបួន។ ព្រហ្មបែរមុខទៅតាមទិសទាំង៤ ដំណាងឲ្យធាតុទាំង៤ ដែលមានខ្យល់ ទឹក ភ្លើង និងធរណី។ អាចបញ្ជាក់បានថា រូបព្រហ្មមុខ៤នៅ

ប្រាសាទបាយ័នមិនមែនជាព្រះព្រហ្មនៃព្រហ្មញ្ញសាសនាទេ គឺព្រះភ័ក្ត្រនៃព្រះពោធិសត្វអវលោកេស្វរៈ។ រូបព្រហ្មមុខបួននេះក៏តំណាងឲ្យស្តេចព្រះបាទជ័យវរ្ម័នទី៧ ផងដែរ ព្រោះព្រះអង្គប្រកាស យកលទ្ធិពុទ្ធរាជ ដែលគេត្រូវចាត់ទុកជាព្រះពុទ្ធពោធិសត្វផង និង ជាស្តេចផែនដីផង។ ប្រាសាទបាយ័នកសាងឡើង ដើម្បីឧទ្ទិសថ្វាយព្រះពោធិសត្វ លោកេស្វរៈមានមុខ៤ ជាទីសំអាងក្នុងលទ្ធិព្រះពុទ្ធសាសនាមហាយាន។ មានអាថ៌កំបាំងនៃចំនួនដ៏ច្រើនលើសលុបរបស់ព្រះកេសនៃព្រះព្រហ្មមុខ នៅលើប្រាសាទបាយ័ន។ តាមពិតទៅបើសំអាងលើពុទ្ធប្រវត្តិ រឿងដំណាលថាព្រះពីដើមធ្លាប់សោយរាជ្យជាស្តេចចក្រពត្តិ កាន់បាទសូមទានគេ ហើយគេឥតគោរព ព្រះអង្គសម្តែងបដិហា កើតជាព្រះពុទ្ធ មួយអង្គ អណ្តែតពេញអាកាស។ និមិត្តរូបស៊ីជម្រៅឥតគណនា គឺអំណាចមហិទ្ធិឫទ្ធិ បុណ្យបារមីដ៏លើសលប់គ្មានត្រើយត្រាន្តរបស់ព្រះលោកេស្វរៈ ដែលប្រកបដោយព្រហ្មវិហារធម៌ទាំង៤ ដ៏មហាប្រសើរ សម្រាប់សត្វលោក។ ព្រះពោធិសត្វនៃពុទ្ធសាសនាមហាយានដ៏មានប្រជាប្រិយ៍នាសម័យបាយ័ន មានដូចជា៖ វជ្របាណិ, វជ្រធរ និងព្រះអមិតាភៈ។ តាមរយៈចម្លាក់ ព្រហ្ម នាប្រាសាទបាយ័ន ដែលសាងសង់ ដោយព្រះបាទ ជ័យវរ្ម័នទី៧ ក្នុងការផ្សារភ្ជាប់សាសនាព្រហ្មណ៍ ទៅនិង ពុទ្ធសាសនា ក្នុងគោលគំនិតនៃការបង្រួម ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ឱ្យក្លាយជាសាសនាតែមួយ តាមរយៈ អាវតារ បែងភាគរបស់ព្រហ្ម ដែលមានឈ្មោះថា "អវតារ លោកកេស្វរៈ" (Avatar Lokesvara) ដែលប្រែថា ព្រះដ៏មានព្រះភាគ និងមានន័យថា ព្រះដ៏ចម្រើន។ ការសំយោគបែបនេះ ដោយសារព្រះអង្គចង់ឲ្យប្រជារាស្ត្រ ខ្មែរដែលមានជំនឿលើសាសនាផ្សេងគ្នា រស់នៅដោយសុខសាន្តដោយសន្តិភាព ក្រោមការគ្រប់គ្រងរបស់ទ្រង់។ ការដែលមានព្រះភ័ក្របួន ឬ មុខបួន គឺតំណាងឱ្យព្រហ្មវិហារធម៌ទាំង៤៖ មេត្តា ករុណា មុទិតា និង ឧបេក្ខា។ ក.មេត្តា (ឬ មេត្រី) គឺការស្រឡាញ់រាប់អានរាប់អានមនុស្សសត្វដោយមិនរើសអើង។ ខ.ករុណា គឺការអាណិតអាសូរអ្នកដែលមានទុក្ខលំបាក។ គ.មុទិតា គឺការទន់ទោរ ឬអបអរសាទរ ត្រេកអររីករាយ ចំពោះសេចក្តីសុខចម្រើន របស់អ្នកដទៃ ដោយ មិនមានចិត្តច្រណែននិន្ទាឈ្នានីស។ ឃ.ឧបេក្ខា គឺការមិនលម្អៀងដោយអគតិណាមួយ គឺមិនវិនិច្ឆ័យដោយទោសាគតិ, ឆន្ទាគតិ, ភ័យាគតិ, លោភាគតិជាដើម។ និកាយមហាយានយល់ថា ករុណា គឺជាគុណធម៌ខ្ពស់បំផុត ដែលត្រូវជំរុញឱ្យមានការប្រតិបត្តិក្នុងពិភពលោក និងក្នុងចំណោមសហគមន៍ទូទៅ។ គេជឿថាពុទ្ធនៅតែជាព្រះពោធិសត្វ ដែលចាំជួយមនុស្សលោកបាន នៅពេលដែលគេគោរពនិងស្នើសុំបួងសួង។

និកាយមហាយានជាយាន ទៅកាន់គោលដៅត្រឹមព្រះពោធិសត្វ អាចជួយណែនាំប្រោសសត្វបានទៅកាន់ឋានទេវលោកបានច្រើន ។ និកាយនេះគោរពប្រតិបត្តិតាមលទ្ធិគ្រូអាចារ្យរបស់ខ្លួនជាធំ ពុំមែនតាមពុទ្ធឱវាទទាំងស្រុងទេ។ រហូតដល់សព្វថ្ងៃប្រទេសដែលនិយមនិកាយមហាយានមានដូចជា ចិន វៀតណាម ជប៉ុន ទីបេ ជាដើម ។

## ៦.ទ្រឹស្តីនៃលទ្ធិពុទ្ធសាសនាថេរវាទ

ការប្រឹងប្រែងរបស់និកាយថេរវាទគឺនាំបុគ្គល ទៅកាន់ការត្រាស់ដឹងប្រឹងប្រែងដើម្បីគតិបណ្ឌិត ផ្តោតលើការសមាធិ ហើយទាមទារឱ្យបុគ្គលមានការលះបង់ខ្ពស់ ដូចជា បួសជាព្រះសង្ឃ ដូនជី ដើរតាមការបង្រៀនរបស់ព្រះពុទ្ធ។ និកាយពុទ្ធសាសនាថេរវាទ កំណត់ថាព្រះពុទ្ធសមណៈគោតមបានចូលបរិនិព្វានហើយ ព្រះអង្គមិនទទួលយកការបន់ស្រន់របស់មនុស្សលោកឡើយ។ អ្វីដែលអាចជួយមនុស្សបាន គឺពុទ្ធឱវាទដែលមានចែងទុកក្នុងគម្ពីរព្រះត្រៃបិដក ដែលពុទ្ធបរិស័ទត្រូវប្រតិបត្តិដោយខ្លួនឯង (អត្តាហិ អត្តនោនាថោ) ដើម្បីសេចក្តីសុខចម្រើន។ គោលធម៌ប្រតិបត្តិសំខាន់គឺ«បញ្ញា-សីល-សមាធិ» ឬ «អដ្ឋង្គិកមគ្គ»។ ក.បញ្ញា (សម្មាទិដ្ឋិ , សម្មាសង្កប្បៈ) ខ.សីល(សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ)។ គ.សម្មាធិ(សម្មាវាយាម, សម្មាសតិ, សម្មាសមាធិ)។

**១.សម្មាទិដ្ឋិ** (ការមានទស្សនៈត្រូវ បានដល់ការស្គាល់ច្បាស់នូវអរិយសច្ចៈ៤)។ **២.សម្មាសង្កប្បៈ** (ការគិតត្រូវ បានដល់ការរិះរកផ្លូវចេញចាកទុក្ខ និងត្រិះរិះពីនាមរូបំ អនិច្ចំ ទុក្ខំ អនត្តា ជាដើម)។ **៣.សម្មាវាចា** (ការនិយាយត្រូវបានដល់ និយាយផ្តល់ប្រយោជន៍ដល់អ្នកស្តាប់ ជៀសវាង សំដីកុហក់បោកប្រាស់ ញុះញង់ បំបែកបំបាក់ ចាក់ដោតដៀមដាមរឡេះរឡោះឥតប្រយោជន៍)។ **៤.សម្មាកម្មន្តៈ** (ការធ្វើប្រព្រឹត្តអំពើសកម្មភាពត្រឹមត្រូវ បានដល់ ការមិនសម្លាប់ជីវិត មិនលួចប្លន់ មិនផិតក្បត់ មិនសេពគ្រឿងញៀនស្រវឹង និងត្រូវដេកដើរឈរអង្គុយឱ្យបានសមស្រប)។ **៥.សម្មាអាជីវៈ**(ការចិញ្ចឹមជីវិតត្រូវបានដល់ មិនលក់គ្រឿងអាវុធ គ្រឿងញៀនស្រា មិនបើកបនល្បែងស៊ីសង បនពេស្យា និងត្រូវចេះប្រមាណក្នុងការបរិភោគ សេពមេថុន និងធ្វើការងារមិនប្រឃូកប្រឃល់)។ **៦.សម្មាវាយាមៈ** (ការព្យាយាមត្រឹមត្រូវ បានដល់ការព្យាយាមលះបង់អំពើអកុសល សន្សំអំពើល្អ រក្សាអំពើល្អឱ្យស្ថិតនៅគង់វង្ស និងសាងគុណធម៌បន្ថែម)។ **៧.សម្មាសតិ** (ការមានសតិរលឹកត្រឹមត្រូវ បានដល់មានសតិសម្បជញ្ញភ្ញាក់រលឹកនូវការដែលកំពុងធ្វើ កុំភ្លាត់ឡប់សតិមិនដឹងធ្វើអ្វី ហើយជារឿយៗ សតិតាមទាន់នូវការពិនិត្យមើលអកុសលចេតសិក ជាដើម)។ **៨.សម្មាសមាធិ** (ការធ្វើចិត្ត ឬការតាំងចិត្តត្រឹមត្រូវ បានដល់ការទម្លាប់ចិត្តឱ្យរឹងមាំក្នុងការគិតពិចារណាដើម្បីសម្រេចគោល

បំណងណាមួយ ដូចជាការយល់ដឹងអំពីខ្លួនឯង អំពីជីវិត និងយល់ដឹងអំពីអ្នកដទៃ។

ការប្រតិបត្តិតាមអដ្ឋង្គិកមគ្គនេះ អាចនាំដល់មគ្គផលនិព្វាន តាមឧបនិស្ស័យរៀងៗខ្លួនគឺមិនបន់ស្រន់សុំជំនួយពីព្រះពុទ្ធឬ ទេវតាណាមួយឡើយ។ ប្រទេសដែលនិយមនិកាយថេរវាទ មានដូចជា កម្ពុជា ថៃ ឡាវ ស្រីលង្កា ប៉ាល់ជាដើម ។

### ៧.ទិដ្ឋភាពនៃពុទ្ធសាសនាក្នុងសង្គមខ្មែរបច្ចុប្បន្ន

សម្រាប់ពលរដ្ឋខ្មែរពុំដែលមានទំនាស់ដោយសារតែមានជំនឿសាសនាខុសគ្នាឡើយ លើសពីនេះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងថា «ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀតដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ»។ ក្នុងន័យនេះ ស្ថានប័នរដ្ឋជាអ្នកទទួលខុសត្រូវការពារព្រះពុទ្ធសាសនាដោយសារមិនបានបញ្ជាក់អំពីការ

ចិត្តទុកដាក់អំពីនិកាយពុទ្ធសាសនាមហាយយានឬថេរវាទឡើយ ដែលជាឱកាសសម្រាប់និកាយកាយទាំង២ កំពុងតែមានការប្រកួតប្រជែងរវាងនិកាយទាំងពីជាយថាហេតុ។ មានអ្នកប្រាជ្ញខាងថេរវាទមួយចំនួនបានប្រើប្រាស់ជីវិតរបស់លោកខិតខំពន្យល់ពុទ្ធបរិស័ទតាមពុទ្ធោវាទ តាមទ្រឹស្តីនិកាយថេរវាទ ប៉ុន្តែទោះយ៉ាងណាក៏មិនអាចជួយមនុស្សក្នុងសង្គមខ្មែរឱ្យចេញចាកពីឥទ្ធិពលនៃលទ្ធិពុទ្ធសាសនាមហាយាននិងព្រហ្មណ៍សាសនាបានច្រើនដែរ ព្រោះព្រះសង្ឃនិងគ្រូធម៌មួយចំនួនដែលជ្រកក្រោមផ្លាក ពុទ្ធថេរវាទ បាននិងកំពុងព្យាយាមពន្យល់បរិស័ទតាមការយល់ឃើញរបស់ខ្លួនយ៉ាងសកម្មនិងយ៉ាងប៉ិនប្រសប់ទៀតផង។ ប្រសិនបើស្ថានភាពនេះនៅតែបន្តកើតមាន ប្រហែលជាសង្គមខ្មែរបច្ចុប្បន្ន នឹងវិលទៅរកការគោរពបូជាពុទ្ធសាសនាមហាយានជាផ្លូវការវិញជាមិនខាន។ នេះជាសម្មតិកម្មមួយទៀតដែលត្រូវស្វែងរកទឡ្ហីករណ៍ដើម្បីសន្និដ្ឋាន។

### សេចក្តីសន្និដ្ឋាន

តាមរយៈដំណើររឿង និងខ្លឹមសារ ដែលបង្កប់ក្នុង រឿងធម្មបាលកុមារ និងយោងតាមតថភាពប្រវត្តិសាស្ត្រស្តីអំពីការផ្លាស់ប្តូរនៃលទ្ធិសាសនានៅកម្ពុជា ដូចដែលបានបង្ហាញខាងលើ យើងអាចទាញសេចក្តីសន្និដ្ឋានថា សម្មតិកម្មដែលយើងបានលើកយកមកបង្ហាញខាងលើ គឺអាចជាមូលដ្ឋានក្នុងការឆ្លុះបញ្ចាំងអំពីទម្រង់និងខ្លឹមសារពិតនៃទស្សនវិជ្ជាខ្មែរ ដែលពលរដ្ឋនិងអ្នកដឹកនាំអាចទទួលយកមកអនុវត្តក្នុងជីវភាពប្រចាំថ្ងៃតាមការយល់ឃើញរៀងៗខ្លួន។ ចំពោះបរិបទបច្ចុប្បន្ន ពលរដ្ឋខ្មែរមានសិទ្ធិ ជ្រើសរើស ឬមិនជ្រើសរើសយកទស្សនៈនៃលទ្ធិសាសនាណាមួយសម្រាប់ជាមាគ៌ារស់នៅ ក៏បាន កុំឱ្យតែបំពាន

ដោយកាយវាចា បៀតបៀនជំនឿលទ្ធិរបស់អ្នកដទៃៗ ទាំងលទ្ធិព្រាហ្មណ៍សាសនា, លទ្ធិពុទ្ធសាសនាមហាយាន និងពុទ្ធិសាសនាថេរវាទ សុទ្ធតែមានតម្លៃសម្រាប់ប្រតិបត្តិក្នុងការដឹកនាំជីវភាពរស់នៅទទួលបានអត្ថប្រយោជន៍អាស្រ័យកាលៈទេសៈ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ លទ្ធិពុទ្ធសាសនាថេរវាទ នៅតែជាលទ្ធិដែលសមស្របនឹងសាកលភាវូបនីយកម្មដែលជឿនលឿនខាងបច្ចេកទេសវិទ្យាសាស្ត្របច្ចុប្បន្ន។ ផ្ទុយទៅវិញ ការលើកតម្កើងការឃោសនា ជំនឿអ្វីផ្ទុយពីលទ្ធិថេរវាទនេះ វាអាចជានយោបាយដើរថយក្រោយរាប់រយសតវត្សរ៍ ដែលនាំអ្នកទំនាស់ធំជេងរកអ្នកឈ្នះត្រឹមត្រូវមិនឃើញ ដែលនាំឱ្យបរិស័ទដែលក្មេងខ្ចីដ៏ច្រើនលើសលប់វង្វេងធម៌ ព្រោះតែគ្រូធម៌មិនបានបញ្ជាក់ថាខ្លួនកំពុងពន្យល់ទ្រឹស្តីធម៌ក្នុងលទ្ធិពុទ្ធសាសនាណាមួយណាឱ្យពិតប្រាកដៗ ទាំងអស់នេះ គឺជាការទទួលខុសត្រូវរួមរបស់ជាតិសាសន៍ខ្មែរទាំងមូលសម្រាប់ជម្រើសប្រកបដោយវិចារណា។

**ឯកសារយោង/គន្ថនិទ្ទេស**


១-ធឹង ផាន់សុផុន, *ព្រះសមណគោតម មហាសាស្តាចារ្យនៃមនុស្សនិងទេព្តា*, អាម៉េរិក, ១៩៩៥

២-ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧

៣-ត្រឹង ង៉ា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣

៤-ពុទ្ធសាសនបណ្ឌិត្យ, *ព្រះរាជពិធីទ្វាទសមាស*, បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ១៩៦៩

៥-វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, *ព្រះត្រៃបិដកបាលីនិងសេចក្តីប្រែជាភាសាខ្មែរ*, ភ្នំពេញ, ពស.២៤៩៧

៦-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)

# ទស្សនវិជ្ជាសង្គមនិងទស្សនវិជ្ជានយោបាយខ្មែរ តាមរយៈរបាំត្រុដិ

*ដោយៈ លោក* **ឈុន ផារ៉េង**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្តីផ្តើម

*ជារៀងរាល់ឆ្នាំ របាំត្រុដិ ដែលជារបាំប្រជាប្រិយខ្មែរតាំងពីបុរាណ បានទទួលការចាប់អារម្មណ៍កាន់តែខ្លាំងឡើង ពីសំណាក់ប្រជាពលរដ្ឋខ្មែរទូទៅ ពិសេសអ្នកដឹកនាំខ្មែរស្ទើរគ្រប់ស្ថាប័ន លើកលែងតែស្ថាបន័មួយចំនួនតូចប៉ុណ្ណោះ[1]។ យើងសង្កេតឃើញថា មុនថ្ងៃមហាសង្ក្រាន្ត ស្ថាប័នរដ្ឋ និង ឯកជនភាគច្រើនបំផុតបានរៀបចំពិធីសូត្រមន្តរំដោះគ្រោះលើករាសីបន្ទាប់មកមានការរៀបចំសម្តែងរបាំត្រុដិ និងពិធីផ្សេងៗទៀតតាមលទ្ធភាពរបស់ខ្លួន។ របាំត្រុដិសឹងក្លាយជាមរតកវប្បធម៌ដ៏មានតម្លៃមិនអាចកាត់ថ្លៃបានរបស់ជាតិខ្មែរ ដោយសាររបៀបក្នុងការសំដែងមានភាពទាក់ទាញអារម្មណ៍ ធ្វើឱ្យរំភើបរំជើបរំជួលចិត្ត ព្រមទាំងបង្កប់នូវខ្លឹមសារដ៏មានឧត្តមគតិប្រកបដោយគតិបណ្ឌិតត្រឹមត្រូវទៀត ផងៗ តើរបាំត្រុដិនេះមានអត្ថន័យ និងផ្តល់ប្រយោជន៍អ្វីខ្លះដល់សង្គមខ្មែរយើង?*

## ១.អត្ថន័យនៃពាក្យ «ត្រុដិ»

*ពាក្យថា «ត្រុដិ» និង «ត្រស្តិ» ជាពាក្យ ២ មានន័យដូចគ្នា ថាៈ ការកាត់, ការផ្តាច់, ដំណើរកាត់ផ្តាច់ ។ ហេតុនេះហើយទើបមុនពេលដាច់ឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មីម្តងៗ ពាក្យថា «ត្រុដិ» និងពាក្យ «ត្រស្តិ ឬសូត្រមន្តផ្តាច់គ្រោះ »ត្រូវបានរំលឹកលាន់ឮកក្រើកក្នុងសង្គមខ្មែរៗ យោងតាមវចនា នុក្រមខ្មែរ ជួន ណាត បោះពុម្ពលើកទី៥ នៅភ្នំពេញឆ្នាំ១៩៦៧ ដោយពុទ្ធសាសនបណ្ឌិត្យ បញ្ជាក់ថាៈ*

*១.ត្រុដិ (អានថា ត្រុត)(ន.)(សំ.) ដំណើរកាត់, ការផ្តាច់។ ឈ្មោះភ្លេង, ចម្រៀងមួយប្រភេទសម្រាប់បណ្តាជនក្នុងខេត្រសៀមរាប គេលេងតែក្នុងឱកាសចូលឆ្នាំថ្មី។*

*២.ត្រស្តិ (អានថា ត្រស់)(ន.)(សំ.) ជាឈ្មោះព្រះរាជពិធីមួយប្រភេទ ធ្វើក្នុងវេលាយប់ ១៤ រោចខែផល្គុនៗ ក្នុងរជ្ជកាលពីបុរាណហៅថា ពិធីបញ្ជាន់ត្រស្តិ, សម័យឥឡូវហៅថា ពិធីភាណយក្ខ ឬ ពិធីសូត្រភាណយក្ខ។ ក្នុងព្រះរាជពិធីនេះ សំដៅយកសេចក្តីថា "ដំណើរផ្តាច់ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី"។ កាលពីក្នុងសម័យបុរាណលោកហៅ*

*[1] ស្ថាប័នខ្មែរខ្លះនិយមវប្បធម៌ចិន ដោយជំនួសរបាំត្រុដិទៅជារបាំលោតម៉ុងសាយ(ឬរបាំសត្វតោ)ដែលគេតែងសម្តែងនៅក្នុងឱកាសពិសេសធំៗ មានពិធីបុណ្យចូលឆ្នាំចិនជាដើម ព្រោះជឿថានឹងនាំមកនូវសំណាងល្អ។*

ព្រះរាជពិធីនេះថា ពិធីត្រុដិ ឬ ពិធីបញ្ជាន់ត្រុដិ ហើយក្លាយមកជាពាក្យថា ត្រស្តិ ។ ពិធីបញ្ជាន់ត្រស្តិនេះពីបុរាណជាន់ដើម ចួនណាលោកហៅថា ពិធីសម្ពច្ឆរច្ឆិន្ទ ឬ សម្ពច្ឆរច្ឆិន្ទពិធី ឬ"ពិធីផ្តាច់ឆ្នាំ"[2] ។ ក្នុងពិធីត្រស្តិ ព្រះសង្ឃខាងពុទ្ធសាសនា តែងសូត្រភាណយក្ស (ឬអាដានាដិយបរិត្ត ឬ អាដានាដិយ[3]។

## ២.ដើមកំណើតរបាំត្រុដិ[4]

ដោយសាររបាំនេះ ជារបាំប្រជាប្រិយ គេមិនអាចដឹងអំពីឈ្មោះអ្នកនិពន្ធ និងគោលបំណងពិតប្រាកដរបស់គាត់ពីដំបូងបានឡើយ។ មានទស្សនៈផ្សេងៗគ្នាដែលខំព្យាយាមបកស្រាយអំពីគោលបំណងដើមនៃរបាំត្រុដិ ទៅតាមការយល់ដឹងរៀងៗខ្លួន។

១.តាមឯកសារសម្តេចព្រះវនរ័ត អ៊ឹវ-ទូតះ

សេចក្តីដំណាលថា មានគ្រួកូល អ្នកនេសាទម្នាក់ ឈ្មោះ ប៊ុន ប្រពន្ធឈ្មោះ នាង ឧមា ភូមិលំនៅ នៅជិតស្រុកសាវត្ថី និស្ស័យជាមនុស្សកាចរប៉ឹងរឹងរូស។ គាត់ជាមនុស្សកម្សត់ទាល់ក្រ តែងតែបរបាញ់ សត្វម្រឹកបក្សី នេសាទទាំងផ្លូវទឹក ផ្លូវគោក យកមកចិញ្ចឹមជីវិតរៀងរាបដរាបមក។ វេលាថ្ងៃមួយនោះ គាត់រៀបប្រដាប់ប្រដាធ្នូ ស្នា ព្រួញ ជ័រធក់ កាំបិត ស្មៀត និង វត្ថុអ្វីៗ ទៀត តាមទម្លាប់ព្រានៗ នាងភរិយាក៏ចាត់ចែងម្ហូបចំណី បារីស្លាប្រគល់ឱ្យប្តី។ ព្រានចេញដំណើរត្រាច់រង្គាត់ កាត់ព្រៃរំលងដងស្ទឹង ឆ្ងាយទៅៗ ពុំមានប្រទះម្រឹកណាមួយសោះ នាំព្រាននឹកថា ប្រហែលជាអស់លោក ទេពារក្ស លោកបំបិទបំបាំងបង្វែងដាន មិនឱ្យឃើញហើយ។ បើដូច្នោះ ព្រានក៏ចាត់ចែង ធ្វើជា រានទេពតា ៣ ថ្នាក់ តម្កល់ នូវ ប្រដាប់ប្រដា ពលីការ សុំលាភ សុំជ័យ ឱ្យបានជួបម្រឹក។ បន្ទាប់ពី បួងសួងរួចហើយ ព្រានធ្វើដំណើរតទៅមុខទៀត ស្រាប់តែប្រទះប្រើសមាសមួយភ្នឺផ្លិនឆ្អៅ គឺពោមសុទ្ធតែជាសរសៃមាស ស្នែងជាកែវភ្លឺប្រាលរន្ទាល។ ព្រានត្រេកអរឥតឧបមា ពួនលបបំបាំងអាត្មាបាញ់បានប្រើសនោះហើយម្នីម្នាយកកាំបិតព្រាទៅកាត់យកស្នែង ពន្ទះស្បែកមូរទុកមួយដុំៗ អារសាច់ដោតចង្រមូលរែក ដោយសេចក្តីត្រេកអរដើរវិលត្រឡប់មកផ្ទះវិញ។ មកដល់ហើយ ដោយឃើញថាប្រើសនេះល្អណាស់ក៏នាំយកស្បែក និងស្នែងទៅថ្វាយស្តេចៗ ព្រះបាទ ព្រហ្ម ទត្តទ្រង់យល់ក៏ទ្រង់សព្វព្រះរាជហឫទ័យ ទើបប្រទានយសដល់ នាយព្រាន ជាចៅហ្វាយខេត្ត។ ចាប់ពីថ្ងៃនោះមក ព្រានប៊ុន ឡើងយសជាចៅហ្វាយខេត្ត នាង ឧមា ជា

---

[2] ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧

[3] ធ្វើតាមរឿងរ៉ាវដែលមានដំណាលនៅក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ ឆដ្ឋភាគ បាដិកវគ្គ។

[4] សូមមើល ចាបពិន, *របាំប្រជាប្រជាប្រិយខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤ ទំព័រ៣១-៣៩

ជំទាវ ហើយក៏បង្កឱ្យមានក្រុមរបាំ និទានពី ព្រានដើរបរបាញ់ម្រឹក ដូចមាន ការរៀបចំក្នុងវង់ត្រុដិសព្វថ្ងៃនេះ។

២.តាមសេចក្តី ឱ្យការណ៍ពីលោក ឡុង សាន់ នៅបាត់ដំបង៖ មានសេចក្តី ដំណាល មួយទៀតថា របាំត្រុដិនេះកើតឡើងតាមហេតុភេទដែលមាន ឡើងនៅសម័យ ដែល ព្រះ សម្មាសម្ពុទ្ធ នៅជា ពោធិសត្វ មុននឹងត្រាស់ដឹងព្រះអង្គទ្រង់ចេញសាងបព្វជ្ជា។ ពេលនោះមារាធិរាជបាន ដំណែងក្លែងខ្លួនជា សត្វប្រើស មករារាំង ស្ទាក់ផ្លូវ ព្រះអង្គកុំឱ្យព្រះអង្គ យាងទៅមុខបាន។ ព្រះពោធិសត្វទ្រង់តាំង អធិដ្ឋាន ឡើងក៏ក្តៅដល់ទេវលោកមួយរំពេច ព្រះព្រហ្ម ព្រះឥន្ទ ទេវតា ទាំងឡាយ ចុះមកដំណែងភេទជាឆ្មោះ លប បាញ់ប្រើស ដែលជាមារាធិរាជក្លែងភេទ នោះ ស្លាប់បាត់ទៅ ។ រួចហើយ ពពួកទេវតា ទាំងអស់ នេះ ក៏នាំគ្នាដង្ហែព្រះអង្គ ធ្វងស្ទឹង អនោមា ទៅសាងព្រះផ្នួស សម្រេចបំណង ទៅ ដោយមាន ភ្លេងមហោស្រពរង់តាមដងផ្លូវ។ ដូច្នេះ បានជា គេយករឿងនោះ មកកសាងជារបាំត្រុដិឡើង គឺ ដងកញ្ចារ ជាឆ័ត្រ ឬជាក្ងស់បើកបាំងព្រះពោធិសត្វ ពួកភ្លេងជាទេពតា ឯនាងរាំជាទេពអប្សរ ហែហម ប្រើស ទន្សោង ជាមារ និង ព្រាន រួម ទាំងមនុស្សព្រៃ ជា ឆ្មោះទេពតាកាឡា។ តាមពិតរឿងបែបនេះ មិនឃើញមានក្នុងពុទ្ធប្បវត្តទឡើយ។

៣.តាមឯកសារលោក សុក មេភូមិគោកក្រសាំង ខេត្តសៀមរាប៖ គេលេង របាំត្រុដិដោយមានជំនឿថា នៅ តាមស្រុក ជិតឆ្ងាយយូរៗម្តងរមែងមានសត្វព្រៃចូលមកក្នុងភូមិអ្នកស្រុក ប្រសិនណាជាសត្វព្រៃចូលស្រុកហើយ នឹងកើតឧបទ្រពចង្រៃបែបណាមួយជាមិនខាន។ ហេតុនេះបានជាមានទម្លាប់ថា បើឃើញ សត្វព្រៃ ចូលស្រុក គេនាំគ្នាប្រោះព្រំប្រេងម្សៅឱ្យសត្វ នោះ ហើយសុំពរជ័យ ពីសត្វទាំងនោះវិញ ដើម្បីរកឱកាសបង្កក់ប្រសិទ្ធិចំពោះសត្វព្រៃឱ្យ ហើយស្រេចក្នុងមួយឆ្នាំៗ យ៉ាងនេះហើយបាន ជាអ្នកស្រុកដែលមានជំនឿដូច្នេះ ក៏បង្កើត ល្បែងត្រុដិនេះឡើង។ ហេតុនេះ វង់ត្រុដិ ត្រូវ មានប្រើស ទន្សោង ក្ងោក សុទ្ធសឹងជាសត្វព្រៃ មកបង្ហាញខ្លួន ឱ្យអ្នកស្រុក អ្នកភូមិ ប្រោះព្រំ ប្រេង ម្សៅ ចងដៃ អំបោះ កម្រង ឱ្យទាន ជា លុយកាក់ទៅធ្វើបុណ្យរំដោះគ្រោះ ឱ្យស្រេចហើយតែម្តងទៅដោយ មានជំនឿថា ប្រសិនជា មានសត្វព្រៃ ចូលមកក្នុងស្រុកទៅថ្ងៃមុខទៀត ក៏ គេបានប្រកបពិធីនេះរួចស្រេចទៅហើយដែរ ដូច្នេះគេជឿថា គ្មានចង្រៃឧបទ្រពអ្វីអាចកើតឡើងទៀតទេ។

៤.ឯកសារខ្លះទៀតថា៖ កាលពីជំនាន់បុរាណ ជនជាតិ សំរែ បាន នាំយករបាំត្រុដិ ទៅលេងថ្វាយ ព្រះរាជា នៅ រៀងរាល់ពេល បុណ្យចូលឆ្នាំ ដើម្បីថ្វាយព្រះពរ សួស្តីសិរីមង្គល។ ជនជាតិ សំរែ ជាមនុស្សជាន់ដើមមួយពួកដែលរស់នៅលើទឹកដីសុវណ្ណភូមិចាស់ តាំងអំពីដែនដីនេះពុំទាន់ទទួល អារ្យធម៌ពីប្រទេសឥណ្ឌានៅឡើយ។

## ៣.សម្រង់ខ្លឹមសារខ្លះក្នុងចម្រៀងរបាំត្រុដិ

មានទស្សនៈយល់ថា កាលពីបុរាណ ខ្មែរលេងរបាំត្រុដិនេះ នៅពេលរាំងស្ងួត, រដូវចូលឆ្នាំ, គ្រោះចង្រៃឬសត្វព្រៃចូលស្រុក និងអង្គាសប្រាក់។ យើងឃើញមានចម្រៀងដែលទាក់នឹងការសុំទឹកភ្លៀងឬពិធីសុំទឹកភ្លៀង[5] និងចម្រៀងបុណ្យចូលឆ្នាំជាច្រើនដែរ ប៉ុន្តែមិនមែនជាទំនុកច្រៀងដែលមានក្នុងខ្លឹមសារសម្រាប់របាំត្រុដិឡើយ។

ចំណែកខ្លឹមសារចម្រៀងរបាំត្រុដិដេញសត្វព្រៃពេលមានឧបទ្រពចង្រៃ ឬ មានសត្វព្រៃរត់ចូលស្រុកភូមិ មានដូចជា៖

១.«ទន្សោងគោនប់ ៗ ចេញស៊ីតែយប់ ថ្ងៃវាពួនព្រៃ។ ទន្សោងទន្សៃ ៗ ទន្សោងចង្រៃ មិនចេះជល់គ្នា។ ទន្សោងគោបា។ រកបានទឹកថ្លា ជល់គ្នាឲ្យមើល។ រមាំងគាងអើយ ៗ ស៊ីរាំងគន្ទួង វាដេញជល់បង ដួលផ្កាប់ដួលផ្ងារ»។

២.«រមាំងស្នែងកែក ស៊ីបែកពីហ្វូង រមាំងស្នែងស្រួង រែហ្វូងបែកខ្ចាយ»។

រីឯ ខ្លឹមសារចម្រៀងរបាំត្រុដិ សម្រាប់កោសរូសសុំទេយ្យទានដើម្បីប្រមូលលុយយកទៅសាងសង់អ្វីមួយ មានដូចជា៖

៣.«នៃរើយកុំតោត ជញ្ជាំងស្លឹកត្នោត គង់មានថ្នាំខ្លាំង បានមួយបារី គង់មានកម្លាំង គាត់មានថ្នាំខ្លាំង មូលដាក់ជើងពាន» ។

៤.«កញ្ជារខ្ញុំដាច់ បានខ្សែអ្វីចង អំបោះមួយកម្រង ចងដៃកញ្ជារ។ ខ្ញុំសុំទានប្រាក់ ៗ ត្បិតមានធុរៈ ធ្វើស្គរគេបែក បើអ្នកមិនជឿ ទៅមើលបំណែក ធ្វើស្គរគេបែក ឯលិចស្វាយជ្រុំ»។

៥.«ចិញ្ចាត់ចិញ្ចេង ៗ ចិញ្ចាត់លេង។ គ្រែងបានលុយកាក់» ។

ក្រៅពីនេះ ឃើញមានចម្រៀងរបាំត្រុដិសម្រាប់ឱ្យពរដល់អ្នកដាក់ទានដូចជា៖

៦.«អាដែងគ្នាយើង គាត់សូត្រអំបោះ គាត់ឲ្យយើងអស់ យើងឱ្យពរគាត់។ ឱ្យយសឱ្យយ ឱ្យពរទៀងទាត់ ឱ្យបានមូលមាត់ កូនចៅផងក្តី។ ឱ្យបានកូនប្រុសជាមុខមន្ត្រី ឲ្យបានកូនស្រី ទំកីចម្ងាក់។ កាលកូនចេះដឹង ចេះដុលចេះប៉ាក់ ចេះទុកចេះដាក់ បម្រើម្តាយស្រី។ កាលកូនចេះដឹង ចេះអុំចេះស្ទៃ ចេះត្បាញរវៃគោមគាត់។ បានមាសដូចចាក់ បានប្រាក់ដូចគរ បានខ្ញុំកំដរធ្វេងស្តាំ» ជាដើម។

បច្ចុប្បន្ន ក្រុមរបាំត្រុដិខ្លះបានចេញសម្តែងនៅពេលរាំងរីសគ្មានភ្លៀងដោយមានដាក់សត្វឆ្មាជំនួសតួសត្វនានា ហើយប្រើទំនុកច្រៀងផ្សេងអំពីរបាំត្រុដិ។ ខ្លឹមសារចម្រៀងរបាំនេះ សម្រាប់កោសរូសសុំទេយ្យទានដើម្បីប្រមូលលុយយកទៅធ្វើអ្វី

[5] សូមមើល ពិធីសុំទឹកភ្លៀងមួយបែប ដោយ ជី វដ្ឋា, ស៊ុន ចាន់ដឺប, ហួត សំណាង តាមអាស័យដ្ឋាន https://www.yosothor.org/publications/khmer-renaissance/chapter-two/phity-som-terk-pleang-mouy-beb.html

មួយ មានដូចជា៖ «ចៅសុំទឹកភ្លៀង ភ្លៀងតិចចៅមិនយក ភ្លៀងខ្លាំងៗមកឱ្យស្រូវបែកគុម្ព» ជាដើម។ ឧទាហរណ៍ នៅខេត្តសៀមរាប នៅឆ្នាំដែលខ្សត់ភ្លៀង ក្រុមរបាំត្រុដិ លោក តង មុត តែងចេញសម្តែង «របាំត្រុដិនាងម៉េវ» តាមភូមិស្រុកដើម្បីសុំទឹកភ្លៀង។ ក្នុងការសម្តែងរបាំនេះ អ្នកសម្តែងយកសត្វឆ្មារស់ដាក់ក្នុងទ្រុង និងសែងដោយតួយក្សពីរនាក់។ ក្រៅពីនេះ មានអ្នកកាន់ឈ្នាងម្នាក់ និងអ្នកកាន់ល្អីម្នាក់ ចាំជញ្ជាត់និងដាក់ប្រាក់ដែលបានពីអ្នកភូមិ។ ការសម្តែងនេះ លាន់ឮរំពងពេញភូមិតាមរយៈសំឡេងដែលចេញពីការលេងភ្លេង។ ក្នុងនោះមានអ្នកកូតទ្រម្នាក់ អ្នកវាយស្គរដៃពីរនាក់ អ្នកគោះកញ្ចែពីរនាក់ និងអ្នកច្រៀងម្នាក់។ ពេលកំពុងរាំរបាំនេះ អ្នកភូមិតែងយកទឹកស្រោចលើឆ្មា ឬបាញ់ទឹកដាក់អ្នកសម្តែងគ្រប់រូប។ នេះជាសញ្ញានៃភាពត្រជាក់ត្រជុំ ដោយរំពឹងថានឹងមានភ្លៀងធ្លាក់ក្នុងពេលឆាប់ៗ[៦]។

## ៤.សង្ខេបចម្រៀងរបាំត្រុដិ

មានក្រុមរបាំត្រុដិ ដូចជា ក្រុមរបាំត្រុដិសច្ចធម៌ប្រវត្តិសាស្ត្រ (១៩៦៨) ក្រុមរបាំត្រុដិសមាគមចលនាវប្បធម៌(២០១៨), ក្រុមរបាំត្រុដិវត្តសុរិយា(២០២១) ជាដើម ដែលតែងតែលេងនិងច្រៀងចម្រៀងរបាំត្រុដិ មានលំនាំ និងអត្ថន័យដូចមានសេចក្តីក្នុងអត្ថបទនៃគេហទំព័រFresh News ដែរ។ ខាងក្រោមនេះ ជាសេចក្តីសង្ខេប ដោយផ្អែកទាំងស្រុងលើអត្ថបទចម្រៀងដើមដែលដកស្រង់ពីគេហទំព័រ Fresh News (សូមមើលឧបសម្ព័ន្ធ១)។ ដើម្បីងាយស្រួលយល់អត្ថន័យ យើងមិនបានបង្ហាញពីទំនុកច្រៀងទេ ប៉ុន្តែគ្រាន់តែរក្សាលំនាំកាព្យខ្លះៗប៉ុណ្ណោះ។ ទម្រង់ចម្រៀងនៃរបាំនេះមាន៣វគ្គ គឺ ១.ជម្រាបសួរដើម្បីសុំអនុញ្ញាតសម្តែងត្រុដិ ២.បង្ហាញគំនិតទស្សនៈពិតប្រាជកនៃត្រុដិ ៣.ការជម្រាបលា។

**វគ្គទី១.** ត្រុដិខ្ញុំមកដល់ហើយ ដល់ក្រៅរបង រទេះគោផង ចង្ក្រង់ខ្សែទាម។ ឈរឈប់នៅក្រៅ ស្រែកហៅទៅថ្កាន ជម្រាបសូមទាន សុំព្រលានលោកឈរលេង។ គ្នាខ្ញុំច្រើនណាស់ គគ្រឹកគគ្រេង សុំព្រលានលោកឈរលេង លេងបានដែរឬទេ?

**វគ្គទី២.** ប្រើសមួយប្រឹងរត់ ព្រានព្រៃដេញស្កាត់ ប្រើសភ័យរត់បាត់ ព្រានបាញ់ខុសម្តង។ ប្រើសឡូកឡូយដាក់ព្រាន ព្រានខឹងពេកហួង លើកធ្នូផ្គរផ្គង់ ប្រើសភ័យរត់បាត់។ ផ្អើលអស់ពួកយក្ស ដេញស្ទាក់ចាប់ម្រឹក ទៅមុខក្រោយទើស សន្ធឹកពេញព្រៃ។ យក្សយាសដាវកាប់ ទង្គិចដាវជាប់ ប្រើសភ័យរត់បាត់ ឡូកឡូយដាក់យក្ស។ ព្រាយស្រីក្រចកវែងចេញរាំទន់ទែន ដេញស្ទាក់ចាប់ម្រឹក សន្ធឹកពេញ

---

6 ថោង ប្រណី, របាំត្រុដិនាងម៉េវ, ផលិតដោយសារព័ត៌មានឌីជីថលថ្មីៗ https://www.youtube.com/watch?v=Zv7TAsIm19s

ព្រៃ។ ក្ងោកចេញជួយព័ទ្ធ ប្រើសផុតវាសនា ទន្សោងក៏ចេញវ៉ា ព្រានបាញ់ប្រើសស្លាប់[7]។

***វគ្គទី៣.*** *ត្រុដិខ្ញុំសូមលាហើយ ចប់ប៉ុណ្ណឹងឯងហ្អង មានរទេះគោផង រៀបដំណើរទៅ។*

*អត្ថន័យក្នុងវគ្គទី១ គឺការស្វាគមន៍ និងការសុំអនុញ្ញាតិ ដោយគោរពគោលការណ៍ច្បាប់ ដើម្បីសុំទីតាំងក្នុងការសំដែងមតិដោយសេចក្តីថ្លៃថ្នូរ។ អត្ថន័យក្នុងវគ្គទី២ បង្ហាញពីជោគជ័យដ៏ត្រចះត្រចង់របស់ព្រានក្នុងការបាញ់សម្លាប់ប្រើស ដោយមានការសហការពីក្ងោកនិងទន្សោង។ រីឯអន្តរាគមន៍ពី សភាវ ដទៃទៀត ដូចជា យក្ស និង ព្រាយ ហាក់គ្មានឥទ្ធិពលក្នុងការកំចាត់ប្រើស នោះឡើយ។ អត្ថន័យក្នុងវគ្គទី៣.គឺ ជាការប្រកាសឈប់សំដែងមតិទស្សនៈ ដោយ ការជម្រាបលាប្រកបដោយសុជីវធម៌។*

## ៥.សម្មតិកម្មលើខ្លឹមសារបទចម្រៀងរបាំត្រុដិ

*ខណៈនេះ យើងដាក់ចេញនូវសម្មតិកម្មលើតួអង្គសំខាន់នៃរបាំត្រុដិ ដូចតទៅ៖ **១.ប្រើស** គឺសត្វ ចតុប្បាទព្រៃ ពួកក្តាន់ រមាំង ដែលខ្មែរមិនចូលចិត្តផ្សាំងឱ្យក្លាយជាសត្វស្រុក ជាតំណាងព្រាហ្មណ៍សាសនា។ **២.ព្រាន** តំណាងប្រជាពលរដ្ឋជនជាតិខ្មែរដើមម្ចាស់ស្រុក មានជនជាតិសំរែជាដើម។ **៣.យក្ស** តំណាងសភាវមើលមិនឃើញដោយភ្នែក, ជាអមនុស្ស មានទេព្តានៅលើដី, ទេព្តាតាមផ្ទះតាមភូមិ, អសុរ, បិសាចជាដើម ទោះមានចិត្តល្អក្តី មានចិត្តអាក្រក់ក្តី ដែលពួកមនុស្សរាប់អានធ្វើពលិការបូជា សែនព្រេន ជាតំណាងជំនឿអ្នកតា ក្នុងជំនឿជីវចល។ **៤.ព្រាយ**[8] ជា បិសាច តំណាងដូនតា ក្នុងជំនឿជីវចលខ្មែរ។ **៥.ក្ងោក** (ជាសត្វបក្សីមួយប្រភេទ មានរោមស្លាបដុះនៅលើក្បាលដូចជាផុក មានផ្ទាល់ដូចមាន់ សំណុំកន្ទុយធំវែងពន្លាតដូចព្រះអាទិត្យ) តំណាងទ្រឹស្តីមគមន៍វិជ្ជាផ្សេងទៀត មានវិទ្យាសាស្ត្រធម្មជាតិ សង្គម នយោបាយ សេដ្ឋកិច្ចជាដើម។ ៦.ទន្សោង ជាសត្វជើង៤ ពួកគោព្រៃ ដែលជនជាតិអាស៊ីចូលចិត្តផ្សាំងជាសត្វស្រុក តំណាងពុទ្ធសាសនា។*

## ៦.ទស្សនវិជ្ជាសង្គមនិងនយោបាយតាមរយៈរបាំត្រុដិ

*ប្រជាជនខ្មែរភាគច្រើននៅតែមានជំនឿជាក់ថា របាំត្រុដិ ជារបាំមួយធ្វើឡើងដើម្បីសុំទឹកភ្លៀងដ៏ពេញនិយម។ លើសពីនេះ វាបានបង្កប់អត្ថ*

---

[7] *បច្ចុប្បន្ន មានរៀបចំឱ្យប្រមុខនៃទស្សនិកជន បានយកទឹកមន្ត មកប្រស់ឱ្យប្រើសរស់ឡើងវិញ។*

[8] *ព្រាយ ជា ភូត, បិសាចពួកមួយដែលគេច្រើនជឿថាតែងចូលជ្រែកយាយីមនុស្សឲ្យឈឺចាប់។ គេជឿឬចាត់ទុកថាពន្លឺដែលភ្លឺព្រោងព្រាយរតាយៗ ឬភ្លឺភ្លោ ឯអាកាសក្នុងវេលាយប់ម្តងៗ ជាព្រាយហោះ។ ការស្លាប់ដោយសម្រាលកូនពុំរួចឬស្លាប់ទាំងកូននៅក្នុងផ្ទៃ គេហៅថាស្លាប់ព្រាយ ហើយក្លាយទៅជាព្រាយបំពេរកូន។*

ន័យ ទស្សនវិជ្ជាសង្គមនិងនយោបាយ យ៉ាងជ្រាលជ្រៅច្បាស់លាស់ ស្របនឹងដំណាក់កាលវិវត្តន៍នៃប្រវត្តិសង្គមខ្មែរ ព្រោះថា ដំណើររឿងក្នុងរបាំត្រុដិមានភាពស៊ីគ្នាទៅនឹងហេតុការណ៍ទាំងឡាយនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា[9]។

ខ្លឹមសារគោលនៃរបាំត្រុដិនេះ គឺមានន័យថា ជាការសម្លាប់នូវអ្វីដែលជានិមិត្តរូបនៃភាពអនារ្យធម៌បរទេសណាដែលចង្រៃ សម្រាប់ស្រុកភូមិប្រទេសជាតិរបស់យើង ដូចដែលមានការសម្លាប់តួអង្គ សត្វប្រើស នោះជាឧទាហរណ៍[10]។

ដូចបានជ្រាបហើយថា លទ្ធិសាសនាក្នុងសង្គមខ្មែរដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែករក្សាសណ្ដាប់ធ្នាប់ របៀបរបប សន្តិសុខសង្គម រហូតដល់សន្តិភាពប្រទេសជាតិទាំងមូលទៀតផង។ ការផ្លាស់ប្ដូរសាសនាក្នុងសង្គមខ្មែរ តែងកើតឡើងទៅតាមជំនឿរបស់ព្រះមហាក្សត្រ ដែលគ្រប់គ្រងតាមទេវរាជ ឬពុទ្ធរាជ ឬបុគ្គលនិយម។ ប្រជាជនពុំមានអំណាចជ្រើសរើសសាសនាសម្រាប់ប្រទេសឡើយ សូម្បីតែសិទ្ធិសម្ដែងមតិក៏ពិបាកធ្វើដែរ។ ទំនោរខ្លាំងក្លានៃការសម្ដែងឆន្ទៈ ជំនឿរបស់មហាជន អាចត្រូវបានបង្ហាញតាមវិធីផ្សេងៗដែលមិនអាចស្គាល់ឈ្មោះអ្នកនិពន្ធ ដូចជា តាមរយៈ បទចម្រៀង របាំ រឿងនិទាន អក្សរសិល្ប៍ប្រជាប្រិយ ជាដើម។

តាមរយៈប្រវត្តិនៃការផ្លាស់ប្ដូរសាសនា នាំអាចឱ្យយើងយល់អំពីទស្សនវិជ្ជាសង្គម និងនយោបាយខ្មែរតាំងពីអតីតកាលបានដូចតទៅ៖ ខ្មែរមានទ្រឹស្ដីដឹកនាំស្រុកទេសរបស់ខ្លួនតាមជំនឿអ្នកតា ឬទស្សនៈជីនិយម ដោយផ្អែកលើគោលគំនិត «មេ បា ព្រះ តា ចៅ»[11]។ ជាក់ស្ដែងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសង្គម អក្សរសាស្ត្រ វប្បធម៌ជាដើមសុទ្ធតែបង្កប់ដួងព្រលឹងមេ បា ព្រះ តា ចៅ យ៉ាងរស់រវើក ដូចជាឈ្មោះ មេក្នុងប្រាសាទ មេបុណ្យ, បាក្នុងប្រាសាទបាពួន, ព្រះក្នុងប្រាសាទព្រះគោ, តាក្នុងប្រាសាទតាព្រហ្ម, ចៅក្នុងប្រាសាទ

[9] តាមទ្រឹស្ដីអក្សរសិល្ប៍ អក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គម សង្គមបែបណាអក្សរសិល្ប៍បែបនោះ ជាពិសេសរបាំត្រុដិដែលជាអក្សរប្រជាប្រិយប្រពៃណី។

[10] ប្រសាសន៍បណ្ឌិត កេង វ៉ាន់សាក់ ក្នុងបទសម្ភាសរបស់លោក សំ បូរិន ។ លោក អះអាងថា ខ្មែរមានសាសនាជីមានភាសា អក្សរសាស្ត្រ របស់ខ្លួន។ លោកឱ្យតម្លៃខ្ពស់លើរឿងរាមកេរ្តិ៍ខ្មែរ ដែលសរសេរដោយខ្មែរសូមស្ដាប់អាស័យដ្ឋាន៖ https://www.youtube.com/watch?v=WzBnxkJfvh8&t=1673s ឬ https://www.youtube.com/watch?v=WzBnxkJfvh8

[11] « មេ បា តា ព្រះ ចៅ » គឺជាទស្សនៈ អំពីជំនឿខ្មែរ មុនពេលទទួលអរិយធម៌ឥណ្ឌា ដែលលើកឡើងដោយលោក កេង វ៉ាន់សាក់ នៅឆ្នាំ ១៩៧២ តាមវិទ្យុជាតិខ្មែរ ក្នុងយុទ្ធនាការឃោសនារកសម្លេងឱ្យសេនាប្រមុខ លន់ នល់ អំឡុងពេលបោះឆ្នោតរើស ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ។

ចៅសាយ, និងក្នុងបរិបទដទៃទៀត ដូចជា មេភូមិ, បារាយណ៍, ព្រែកតាទែន, ជាដើម។

ចំពោះលទ្ធិព្រាហ្មណ៍សាសនា ដែលនាំចូលតាមរយៈព្រះបាទហ៊ុនទៀន និង ឈ្មួញពីប្រទេសឥណ្ឌា មានលក្ខណៈខុសគ្នាពីទំនៀមទម្លាប់ប្រពៃណី អ្នកស្រុកដើម ជាពិសេសជំនឿស្ដីអំពីអាទិទេព ជាអ្នកបង្កើតនិងបំផ្លាញលោក ការបែងចែកវណ្ណៈពូជសាសន៍ វង្សត្រកូល បណ្ដាសា ព្រហ្មលិខិត ជាដើម។ ព្រាហ្មណ៍សាសនាមាននិកាយបីធំៗ គឺ និកាយព្រះព្រហ្ម វិស្ណុ សិវៈ ហើយពួកនិកាយទាំងនេះតែងតែដណ្ដើមឥទ្ធិពលគ្នាទៅវិញទៅមក ដែលបង្កបញ្ហាជាច្រើនទៀតផង[12]។ នៅកម្ពុជា ដើម្បីបន្ថយជម្លោះនេះ អ្នកប្រាជ្ញខ្មែរបង្រួមព្រះវិស្ណុ និង សិវៈឱ្យទៅជាព្រះតែមួយដោយដាក់ឈ្មោះថា «ហរិហរៈ»។

ព្រះមហាក្សត្រិយ៍ជំនាន់ក្រោយមកទៀត មានការផ្លាស់ប្ដូរសាសនា គឺពី ព្រាហ្មណ៍សាសនាទៅជាពុទ្ធសាសនាមហាយាន និងក្រោយមកទៀតផ្លាស់ពីពុទ្ធសាសនាមហាយាន មកជាពុទ្ធសាសនាថេរវាទវិញ[13]។ ថ្វីត្បិតមានការខុសគ្នាខ្លាំងខាងទស្សនៈស្ដីអំពីតួអង្គព្រះពោធិសត្វយ៉ាងណាក៏ដោយ ក៏និកាយពុទ្ធសាសនាទាំងពីរ កម្របង្ហាញឱ្យឃើញជម្លោះស្រួចស្រាល់រវាងបរិស័ទនិងបរិស័ទណាស់ ប៉ុន្តែគេឃើញមានបដិវាទកម្មស្នគ្រស្នាញ ការមិនយល់ស្របគ្នាខាងទ្រឹស្ដីនិងការបដិបត្តិ រវាងអ្នកដឹកនាំទេសនានៃនិកាយទាំងពីរជាដរាបរៀងមក[14]។

រីឯពុទ្ធសាសនា និង ព្រាហ្មណ៍សាសនា មានទស្សនៈផ្ទុយគ្នាស្រឡះអំពី ទ្រឹស្ដីអត្ថិភាពនៃ អាត្ម័ន។ ព្រះពុទ្ធសាសនាមិនទទួលស្គាល់អាត្ម័ន (អត្តា)បែបព្រាហ្មណ៍សាសនាឡើយ។ តាម សច្ចភាពបរានុម័ត ព្រះពុទ្ធសាសនារកឃើញថា អ្វីៗទាំងអស់ជា អនត្តា។ ពុទ្ធសាសនា បង្រៀនមនុស្សឱ្យរស់នៅតាមគោលការណ៍ ផ្លូវកណ្ដាលឬមជ្ឈិមាបដិបទា ឬអដ្ឋង្គិកមគ្គ ឬសីល-សមាធិ- បញ្ញា ដែលស្របគ្នានឹង លទ្ធិឬទ្រឹស្ដីវិទ្យាសាស្ត្រ នយោបាសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងរដ្ឋតាមរដ្ឋ ធម្មនុញ្ញតាមបែបទំនើបដែលមានលក្ខណៈ វិទ្យាសា

---

[12] ក្នុងរបាំត្រុដិ ច្រៀងថា៖ «រមាំងគាងអើយ ៗ ស៊ីរាំងគន្ធងវាដេញដល់បង ដួលផ្កាប់ដួលផ្ងារ»។ «រមាំងស្នែងកែក ស៊ីបែកពីហ្វូង រមាំងស្នែងស្រួង វែធហ្វូងបែកខ្ចាយ»។ (សត្វរមាំង ឬ សត្វប្រើស ជំនួសគ្នាបាន)។

[13] សូមមើល ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣ ទំព័រ១១៣-១១៤។

[14] ក្នុងរបាំត្រុដិ ច្រៀងថា៖ «ទន្សោងគោនប់ ៗ ចេញស៊ីតែយប់ ថ្ងៃវាពួនព្រៃ។ ទន្សោងទន្សៃ ៗ ទន្សោងចង្រៃ មិនចេះដល់គ្នា។ ទន្សោងគោបា ៗ រកបានទឹកថ្លា ដល់គ្នាឲ្យមើល»។ (ទន្សោងឬគោព្រៃ ទីនេះតំណាង ពុទ្ធសាសនា)។

ស្ត្រ[15] ដូច្នោះហើយទើបរដ្ឋធម្មនុញ្ញខ្មែរ ចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋរហូតមក[16]។ ពុទ្ធសាសនាបានជួយឋិតយោងជ្រោមជ្រែងរក្សាទុក និង រក្សាការពារអត្តសញ្ញាណជំនឿខ្មែរដើមថែមទៀតផង។ យើងឃើញថានៅតាមវត្តអារាមខាងពុទ្ធសាសនាតែងតែអនុញ្ញាតឱ្យមានខ្ទមអ្នកតា និង បានរក្សាទំនៀមទម្លាប់ ប្រពៃណី ជំនឿដើមរបស់ខ្មែរជាដរាបរៀងមក។ ការរួបរួមរវាងទស្សនៈជំនឿខ្មែរដើម[17] ជាមួយទ្រឹស្តីដឹកនាំរដ្ឋទំនើបតាមវិទ្យាសាស្ត្រ នយោបាយមានការដឹកនាំតាមរដ្ឋធម្មនុញ្ញប្រជា ធិបតេយ្យ(មានសេរីឬកុម្មុយនីស្តជាដើម)[18] បានទាត់ចោលទាំងស្រុងនូវការគ្រប់គ្រងបែបសក្តិភូមិ លទ្ធិទេវរាជ របបដែលមានស្តេចដឹកនាំក្នុងនាមអាទិទេពសាសនាព្រាហ្មណ៍[19]។

ចំណែកទស្សនៈស្តីពីការប្រោសឱ្យរបបរាជានិយមរស់ឡើងវិញ គឺគ្រាន់តែជានិមិត្តរូបជាប្រពៃណីប៉ុណ្ណោះ ពោលគឺទុកឱ្យមានព្រះរាជាទ្រង់សោយរាជ ប៉ុន្តែមិនកាន់អំណាចឡើយ[20]។

## ៧.ផលប្រយោជន៍នៃបាំត្រុដិ

បាំត្រុដិមានប្រយោជន៍ធំធេងមិនអាចកាត់ថ្លៃបាន ព្រោះកាលណាគេសម្តែងរបាំនេះម្តងៗនាំឱ្យគេទទួលបាន៖

ក.ការបន្ថយភាពល្អក់កករ បំបាត់កង្វល់ចង្រៃក្នុងចិត្ត បង្កើតសេចក្តីសង្ឃឹមឡើងវិញហាក់មានសភាវៈខាងក្នុងនិងខាងក្រៅតាមជួយអន្តរាគមន៍។

ខ.បរិយាកាសសប្បាយរីករាយ បង្កើនស្មារតីសាមគ្គីផ្ទៃក្នុងស្ថាប័ន សង្គមជាតិ រហូតពិភពលោកទាំងមូល។

គ.អត្តសញ្ញាណជាតិខ្មែរ រក្សាកេរមរតកអំពីលទ្ធិជំនឿបុរាណ ដ៏មានតម្លៃក្នុងសិល្បៈវប្បធម៌ខ្មែរម្ចាស់ស្រុក ដែលមនុស្សគ្រប់ជំនាន់គ្រប់ជាតិសាសន៍ទទួលស្គាល់ និងកោតសរសើរ។

ឃ. ថវិកាដោះស្រាយបញ្ហាហិរញ្ញវត្ថុសម្រាប់ប្រយោជន៍សាធារណៈមួយគ្រា បន្ថែមលើផែនការគោលដៅខ្វះខាតណាមួយ ដូចជាការបំពេញបន្ថែមលើកសាងហេដ្ឋារចនាសម្ព័ន្ធនានា

[15] លទ្ធិឬទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបែបទំនើបដោយមានរដ្ឋធម្មនុញ្ញ ទ្រឹស្តីវិទ្យាសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ជាដើម ក្នុងរបាំត្រុដិតំណាងដោយសត្វក្ងោក។

[16] ពុទ្ធសាសសនា ជាសាសនារបស់រដ្ឋ មានចែងក្នុងរដ្ឋធម្មនុញ្ញ ចាប់ពីខ្មែរមានរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧ រហូតបច្ចុប្បន្ន លើកលែងតែ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមួយប៉ុណ្ណោះ។

[17] ក្នុងរបាំត្រុដិតំណាងដោយ យក្ស និង ព្រាយស្រី។

[18] ក្នុងរបាំត្រុដិ តំណាងដោយសត្វក្ងោក។

[19] ក្នុងរបាំត្រុដិ តំណាងដោយសត្វប្រើស។

[20] ក្នុងរបាំត្រុដិ ច្រៀងថា៖ «ក្ងោកចេញជួយព័ទ្ធ ប្រើសផុតវាសនា ទន្សោងក៏ចេញរ៉ា ព្រានបាញ់ប្រើសស្លាប់»។ នៅលើពិភពលោកបច្ចុប្បន្ន គ្មានរបបរាជានិយមដែលស្តេចទ្រង់សោយរាជ និងកាន់អំណាចផ្តាច់ការតាមលទ្ធិទេវរាជ(ស្តេចជាអាទិទេព)ទៀតឡើយ ។

ដូចជា សាលារៀន កសាងអាគារ ទឹកន្ទៃង ធ្វើបុណ្យទាន ជាដើម។

ង.បណ្តុះទម្លាប់អ្នកស្រុក ឱ្យមានចិត្តសប្បុរសធម៌ ចេះបរិច្ចាកទានក្នុងសហគមន៍ និងសង្គមជាតិ ជាដើម។

**សេចក្តីសន្និដ្ឋាន**

តាមរយៈខ្លឹមសាររបាំ ត្រុដិនិងយោងតាមតថភាពប្រវត្តិសាស្ត្រ យើងអាចនិយាយបានថា ជំនឿជីវចលនិយម នៅមានឱកាសរស់រានមានជីវិតបន្តដើម្បីរក្សាអត្តសញ្ញាណរបស់ខ្មែរ ក៏ដោយសារនៅមានជនជាតិដែលមានឈាមជ័រនិងព្រលឹងជាខ្មែរនៅមានអត្ថិភាពនៅឡើយ។

ដោយសារឥទ្ធិពលវិទ្យាសាស្ត្រនយោបាយសេដ្ឋកិច្ច ដែលសង្គមខ្មែរបានស្គាល់ការគ្រប់គ្រងដឹកនាំរដ្ឋតាមបែបទំនើបដោយមាន រដ្ឋធម្មនុញ្ញជាមូលដ្ឋាន និងឥទ្ធិពលពុទ្ធសាសនា យើងសង្ឃឹមថា អត្តសញ្ញាណជាតិខ្មែរនឹងបាត់បង់ដោយឥទ្ធិនៃលទ្ធិព្រហ្មណ៍សាសនាពីឥណ្ឌាឡើយ។ ទោះយ៉ាងណាក៏យើងនៅតែទទួលស្គាល់ថា លទ្ធិព្រហ្មណ៍សាសនា បានបន្សល់ទុកនូវមរតកវប្បធម៌សិល្បៈជាច្រើនដែរ ហេតុនេះទើបយើងកោតសរសើរគំនិតបញ្ញវន្តខ្មែរសម័យថ្មីដែលតម្រូវឱ្យមានការប្រោសសត្វប្រើសឱ្យរស់ឡើងវិញក្នុងរបាំត្រុដិ។

របាំត្រុដិជាកម្មសិទ្ធផ្តាច់មុខរបស់ខ្មែរ ដែលអាចចាត់ជាកេរដំណែលអារ្យធម៌មនុស្សជាតិមួយ។ វាអាចក្លាយជាបេតិកភណ្ឌវប្បធម៌ពិភពលោកនៅពេលអនាគត ប្រសិនគេយល់អត្ថន័យពិតរបស់វា។

**ឧបសម្ព័ន្ធ១ ៖ ចម្រៀងរបាំត្រុដិ**

**ឈ្វេងយល់ពី «របាំត្រុដិ» ដែលខ្មែរយើងតែងលេងក្នុងឱកាសបុណ្យចូលឆ្នាំថ្មី**

*ដកស្រង់ពីគេហទំព័រ freshnewsasia.com នៅថ្ងៃ ១៦ មេសា ២០២៤។*

https://www.freshnewsasia.com/index.php/en/knowledge/283979-2023-03-25-10-23-38.html

*ហ្អាអ៊ើយ... កំប្ញង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ដារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំបង។ (ច្រៀងសាឡើងវិញច្រើនដង)*

*ហ្អាអ៊ើយ...អឺៗៗអឺងអ៊ើយ...ត្រុដិខ្ញុំមកដល់ហើយ... ដល់ក្រៅឱរបង រទេះឱគោផង ម្ចាស់អ្ហើយចម្រង់ឱខ្សែទាមអ្ហើយ...ណាងនាងណា....ចម្រង់ឱខ្សែទាម....។*

*ហ្អាអ៊ើយ...អឺៗៗអឺងអ៊ើយ...ឈរឈប់ឱនៅក្រៅ... ស្រែកហៅឱ្យទៅថ្កាន... ជម្រាបឱ្យសូមទាន ថ្ងៃអ្ហើយសុំព្រលានលោកឈរលេង ណាងនាងណា....សុំព្រលានលោកឈរលេង។*

*ហ្អាអ៊ើយ...អឺៗៗអឺងអ៊ើយ... គ្នាខ្ញុំឱ្យច្រើនណាស់...គគ្រឹកឱគគ្រេង សុំព្រលានលោកឈរលេង ម្ចាស់អ្ហើយលេងបានឱ្យដែរឬទេ.... ណាងនាងណា....លេងបានឱ្យដែរឬទេ។*

*ហ្អាអ៊ើយ...ឱនែកំប្ញង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ដារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំ  បង។*

*សំឡេងព្រានស្រែកដេញព័ទ្ធប្រើសៈ ខ្វះស្រែក ព័ទ្ធៗៗ ទៅហើយៗៗ ដេញៗៗ ព័ទ្ធៗៗ*

*ហ្អាអ៊ើយ.... អឺៗៗអឺងអ៊ើយ.... ប្រើសុំមួយឱប្រឹងរត់ ព្រានព្រៃឱដេញស្កាត់ ប្រើសភ័យឱរត់បាត់ ថ្ងៃអ្ហើយព្រានបាញ់ឱខុសម្តង ណាងនាងណា....ព្រានបាញ់ឱខុសម្តង។*

*ហ្អាអ៊ើយ...អឺៗៗអឺងអ៊ើយ...ប្រើសទ្បុកឡួយដាក់ព្រាន ព្រានខឹងឱពេកហ្អង លើកធ្នូឱផ្គូរផ្គង់ ម្ចាស់អ្ហើយប្រើសភ័យឱរត់បាត់ ណាងនាងណា....ប្រើសភ័យឱរត់បាត់។*

*ហ្អាអ៊ើយ...ឱនែកំប្ញង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ដារបាំខ្មែរ ឆាៗប៉ា ឆាប៉ាមុំបង វើយៗក្រមុំ  បង។*

*ហ្អាអ៊ើយ...អឺៗៗអឺងអ៊ើយ... ផ្អើលអស់ឱពួកយក្ស ដេញស្ទាក់ឱចាប់ម្រឹក ទៅមុខឱក្រោយទើស ថ្ងៃអ្ហើយសន្ធឹកឱពេញព្រៃ ណាងនាងណា....សន្ធឹកឱពេញព្រៃ។*

ហ្អាអ៊ើយ...អឺៗអឺងអ៊ើយ...យក្សយាសឱដាវកាប់ ទង្គិចឱដាវដាប់ ប្រើសក័យឱរត់បាត់ ម្ចាស់អ្ហើយឡូកឡូយឱដាក់យក្ស ណាទាងណា...ឡូកឡូយឱដាក់យក្ស។

ហ្អាអ៊ើយ...ឱនៃកំប្លង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗរ៉ា ឆារ៉ាមុំបង រើយៗក្រមុំ បង។

ហ្អាអ៊ើយ...អឺៗអឺងអ៊ើយ...ព្រាយស្រីក្រចកវែង ចេញរាំឱទន់ទែន ដេញស្ទាក់ឱចាប់ម្រឹក ថ្ងៃអ្ហើយសន្ធឹកឱពេញព្រៃ ណាទាងណា....សន្ធឹកឱពេញព្រៃ។

ហ្អាអ៊ើយ...ឱនៃកំប្លង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗរ៉ា ឆារ៉ាមុំបង រើយៗក្រមុំ បង។

ហ្អាអ៊ើយ.... អឺៗអឺងអ៊ើយ.... ក្ងោកចេញឱជួយព័ទ្ធ ប្រើសផុតឱវាសនា ទន្សោងក៏ចេញឱអើយរ៉ា ថ្ងៃអ្ហើយព្រានបាញ់ឱប្រើសស្លាប់ ណាទាងណា....ព្រានបាញ់ឱប្រើសស្លាប់។

ហ្អាអ៊ើយ.... អឺៗអឺងអ៊ើយ.... ត្រុដិខ្ញុំសូមលាហើយ ចប់ប៉ុណ្ណឹងហ្អង មានរទេះឱគោផង ថ្ងៃអ្ហើយរៀបដំឱណើរទៅ ណាទាងណា...រៀបដំឱណើរទៅ។

ហ្អាអ៊ើយ.... ឱនៃកំប្លង់ៗអ្ហើយ នាំគ្នាលេងត្រុដិ ដោយបរិសុទ្ធ ជារបាំខ្មែរ ឆាៗរ៉ា ឆារ៉ាមុំបង រើយៗក្រមុំបង។ (ច្រៀងសាឡើងវិញច្រើនដង)។

**ឯកសារយោង/គន្ថនិទ្ទេស**


១-ចាបពិន, *របាំប្រជាប្រជាប្រិយខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤

២-ជួន ណាត, *វចនានុក្រមខ្មែរ* ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧

៣-ត្រឹង ង៉ា, *ប្រវត្តិសាស្ត្រខ្មែរ*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ គ. ស. ១៩៧៣

៤-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)

# និមិត្តកម្មទស្សនវិជ្ជាខ្មែរ

## («ក្បួនអ» និមិត្តសញ្ញាទស្សនវិជ្ជាខ្មែរ និង និយមន័យទស្សនវិជ្ជាខ្មែរ)

*ដោយៈ លោក* **ឈុន ផារ៉េង**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

### សេចក្តីផ្តើម

*ទស្សនវិជ្ជា ជាវិស័យអរិយធម៌មួយ ដែលត្រូវបានបង្កើតឡើង ដើម្បីបម្រើសេចក្តីត្រូវការរបស់មនុស្ស ដោយការខិតខំប្រឹងប្រែងស្រាវជ្រាវ និង ការត្រិះរិះពិចារណារបស់ទស្សនវិទូ ពីមួយជំនាន់ទៅមួយជំនាន់។ ទស្សនវិទូតែងតែប្រើវិធីសាស្ត្រ ឬបង្កើតក្បួនដើម្បីពន្យល់បង្ហាញទស្សនៈនានាប្រកបដោយហេតុផល និង សច្ចភាពក្នុងគោលដៅផ្តល់ប្រយោជន៍ដល់មនុស្សក្នុងសង្គមខ្លួនក៏ដូចសាកលលោកទាំងមូល។ ចំណែក បុព្វបុរសខ្មែរ ក៏បានបន្សល់ទុកនូវទស្សនៈប្រកបដោយគតិបណ្ឌិតជាច្រើន សម្រាប់មនុស្សខ្មែរជំនាន់ក្រោយបានរៀនសូត្រ និងប្រតិបត្តិក្នុងជីវភាពរស់នៅឱ្យបានកាន់តែប្រសើរដែរ។ ទោះយ៉ាងណាក៏ក្បួនខ្នាត ឬវិធីសាស្ត្រសម្រាប់ស្វែងយល់អំពីទស្សនៈទាំងនោះ មិនទាន់សម្បូរបែបនៅឡើយ ជាពិសេសឯកសារក្បួនខ្នាតផ្នែកទស្សនវិជ្ជាខ្មែរ រហូតមតិខ្លះពោលថាខ្មែរមិនទាន់មានក្បួនខ្នាត ទស្សនវិជ្ជារបស់ខ្លួននៅឡើយ។ តើទស្សនវិជ្ជាខ្មែរ មានក្បួនទស្សនវិជ្ជាដែរឬទេ? ចំពោះបញ្ហានេះ មានមនុស្សខ្មែរជាច្រើនកំពុងរង់ចាំចម្លើយ ហើយដែលត្រូវនាំគ្នាស្វែងរក។*

*ខណៈនេះខ្ញុំសូមបង្ហាញអំពី និមិត្តកម្មទស្សនវិជ្ជាខ្មែរ ដូចជាៈ ១.«ក្បួនអ» ២.និមិត្តសញ្ញាទស្សនវិជ្ជាខ្មែរ និង៣.និយមន័យទស្សនវិជ្ជាខ្មែរ តាមទស្សនៈផ្ទាល់ខ្លួនដោយផ្អែកលើខ្លឹមសារដែលមានស្រាប់ក្នុងអរិយធម៌ខ្មែរ តាមបរិបទមូលដ្ឋានក្នុងសង្គមខ្មែរ។*

### ១.និយមន័យនៃទស្សនវិជ្ជា

*ពាក្យ ទស្សនវិជ្ជា ត្រូវនឹងពាក្យក្រិកថា (φιλοσοφία), ឡាតាំង Philiasophia អង់គ្លេស Philo sophy, បារាំង Philosophie។ លោក ពីតាហ្គ័រ (Pythagore, ៥៧០-៤៩៥មុនគ.ស.) ទស្សនវិទូនិងគណិតវិទូជនជាតិក្រិកដែលជាអ្នកបង្កើតពាក្យនេះបានពន្យល់ថា φιλοσοφία = φίλος (philo: "love of", "affinity for", "liking of" ស្រឡាញ់) + σοφία (sophia:*

*"wisdom" គតិបណ្ឌិត)*[១]។ *Philosophy is love of wisdom*[២] *មានន័យថា ទស្សនវិជ្ជាជាការស្រឡាញ់គតិបណ្ឌិត។ លោក សូក្រាត (៤៧០-៣៩៩មុនគ.ស) ទស្សនវិទូក្រិកដ៏ល្បីល្បាញ បានពន្យល់ថា មនុស្សកើតមកខ្វះគតិបណ្ឌិត ហើយក្នុងការរស់នៅមនុស្សត្រូវការគតិបណ្ឌិត ស្រឡាញ់គតិបណ្ឌិត ស្វែងរកគតិបណ្ឌិត។ ចំណែកយើងវិញ ឈ្វេងយល់ថា៖ «ស្នេហា» និង «គតិបណ្ឌិត» ជាបញ្ញត្តិនៃសភាវៈពីរដាច់ពីគ្នា ដែលមនុស្សមានវិចារណញ្ញាណទាំងឡាយ ត្រូវតែមានទាំងពីរមិនអាចខ្វះបាន។*

*បន្ទាប់នេះ សូមពិនិត្យមើលពាក្យខ្មែរស្ដីអំពី «ទស្សនវិជ្ជា» វិញម្ដង។ ទស្សនវិជ្ជា មកពាក្យ «ទស្សនៈ» + «វិជ្ជា»។ ពាក្យទស្សនៈ មានន័យថា គំនិត មតិ យោបល់ ការយល់ឃើញ បញ្ញាសាមញ្ញ*[៣] *ជាដើម។* ***វិជ្ជា*** *(ឬវិទ្យា) មានន័យថា ក្បួនរបៀបសិក្សា វិធីរៀនសូត្រ វិធីសាស្ត្រ សេចក្ដីដឹងច្បាស់ ការចេះដឹង ចំណេះ វេទ អាគម ការរៀនសូត្រគម្ពីរសាស្ត្រឬសាស្ត្រា គាថាឬរបៀន*[៤] *ជាដើម។ ដូច្នេះ «ទស្សនវិជ្ជា គឺជាមតិដែលមានក្បួន»។ ទស្សនៈណាខ្វះក្បួនមិនមានលក្ខណៈពេញលេញជាទស្សនវិជ្ជាឡើយ គឺយើងចាត់ទុកថា វាគ្រាន់តែជាមតិយោបល់យល់ឃើញធម្មតា បែបពុទ្ធិសាមញ្ញប៉ុណ្ណោះ។ យើងអាចនិយាយថា ទស្សនៈមតិយោបល់ណាមួយ ថាជាទស្សនវិជ្ជា លុះត្រាតែទស្សនៈមតិយោបល់ នោះប្រកបដោយក្បួនខ្នាត វិធីសាស្ត្រ ច្បាប់ តម្រា ច្បាស់លាស់ត្រឹមត្រូវល្អ។ យោងតាមនេះ យើងសួរថា តើខ្មែរមានទស្សនវិជ្ជារបស់ខ្លួនឬទេ? តាមការពិត ក្នុងសង្គមខ្មែរមានទស្សនៈប្រកបដោយគតិបណ្ឌិតសម្បូរបែបណាស់ គ្រាន់តែខ្វះឯកសារក្បួន (វិជ្ជា វិធីសាស្ត្រ ក្បួនខ្នាត) សម្រាប់យកមកអះអាងប៉ុណ្ណោះ។ ការខ្វះឯកសារទាំងនេះប្រហែលមកពីខ្វះអ្នករៀបរៀង ឬមិនមានការរៀបចំ ឬដោយសារមកពីសត្រូវនានាបំផ្លិចបំផ្លាញក្នុងគ្រាមានសង្គ្រាម។*

*យើងឃើញមាននិយមន័យទស្សនវិជ្ជាមួយចំនួនដូចជា៖ ១.ទស្សនវិជ្ជា ជាមតិយោបល់ដែលមានវិធីសាស្ត្រ។ ២.ទស្សនវិជ្ជា ជាវិជ្ជាសម្រាប់ពិចារណារកការពិត និងភាពត្រឹមត្រូវដើម្បីប្រយោជន៍ដល់មនុស្ស។ ៣.ទស្សនវិជ្ជា ជាការត្រិះរិះពិចារណាតាមការឃើញ ការដឹងដោយប្រើវិចារណញ្ញាណ ពិនិត្យ សង្កេតរកហេតុផលតូចធំនៃសេចក្ដីវិនាស ចម្រើន ព្រោះក្នុងវប្បធម៌ជាតិមួយៗ សុទ្ធតែមានទស្សនវិជ្ជាជាបឋមសម្រាប់*

---

[១] Harper, Douglas R. (2022). "Philosophy ". Online Etymology Dictionary. 21 March 2022

[២] The Divisions and Definition of Philosophy Nature of Philosophy. https://philosophy.lander.edu/intro/what.shtml

[៣] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំ.៤១៦*

[៤] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំ.១១៨២*

ធ្លុះបំភ្លឺ ពារកផ្លូវទៅកាន់សេចក្តីចម្រើនរុងរឿង[៥]។ ៤.ទស្សនវិជ្ជា ជាវិជ្ជាដែលកើតឡើងដោយទស្សនៈ ជាវិទ្យាសាស្ត្រចែងអំពីគោលការណ៍សំខាន់ៗ និង បុព្វហេតុផ្សេងៗ ឬអំពីជីវិតនៃមនុស្សនិងសត្វ។ ទស្សនវិជ្ជា ជាគុណជាតិវិសេសមួយចំណែក។ ទស្សនវិទូ ជាអ្នកប្រាជ្ញខាងទស្សនវិជ្ជា ដូចជាព្រះពុទ្ធ ជាទស្សនវិទូឯកក្នុងលោក[៦]។ ៥.ទស្សនវិជ្ជា ជាមុខវិជ្ជាមួយដែលលើកយកមតិ យោបល់ សំណើ អំណះអំណាង វិចារ គំនិត ឬទ្រឹស្តីណាមួយមកធ្វើជាកម្មវត្ថុសិក្សា ឬគិតពិចារណា»[៧]។ ៧. ទស្សនវិជ្ជា ជាវិទ្យាសាស្ត្រមួយ សិក្សាអំពីគោលការណ៍ ប្រកបដោយគតិបណ្ឌិត និងត្រិះរិះពិចារណាប្រកបវិធីច្បាស់លាស់ ក្នុងបំណងស្វែងរកសច្ចភាពដើម្បីផ្តល់អត្ថន័យឱ្យជីវិតតាមរយៈ អស្តិរូបវិជ្ជា ពុទ្ធិវិទ្យា តក្កវិជ្ជា សីលវិជ្ជា សោភ័ណវិជ្ជា ព្រមទាំង ទិដ្ឋភាពនៃទស្សនៈក្នុងសាសនាជាដើម[៨]។

យោងតាមនិយមន័យ នៃទស្សនវិជ្ជាខាងលើនេះ យើងឃើញសង្កេតឃើញមានបញ្ញត្តិជាគន្លឹះសំខាន់៤គឺ៖ ១.«ស្រឡាញ់» ២.«គតិបណ្ឌិត» ៣.«ទស្សនៈ» និង ៤.«ក្បួន»។ នៅមាននិយមន័យទស្សនវិជ្ជា ជាច្រើនទៀតដែលមិនបានលើកយកបង្ហាញៗ គេអាចស្វែងរក និងជ្រើសរើសឱ្យតម្លៃនិយមន័យណាមួយតាមបរិបទរៀងៗខ្លួន។

## ២.ក្បួនទស្សនវិជ្ជា(វិធីសាស្ត្រទស្សនវិជ្ជា)

ដូចមុខវិជ្ជាដទៃទៀតដែរ ទស្សនវិជ្ជាក៏មានក្បួនរបស់ខ្លួនដែរ។ ក្បួន គឺជាតម្រាបែបបទកំណត់ជាគោលចារឹក សម្រាប់ជាមធ្យោបាយទៅរកគោលដៅ និង គោលបំណង។ ទាំងនៅក្នុងទ្រឹស្តីនិងប្រតិបត្តិ ក្បួនទស្សនវិជ្ជា ជាវិធីសម្រាប់ពន្យល់បង្ហាញ នូវដំណោះស្រាយបញ្ហារស់នៅនៃជីវិតមនុស្សសត្វ ដោយប្រើវិធីតក្កវិជ្ជា។ វិធីទស្សនវិជ្ជា តម្រូវឱ្យមនុស្សចេះឈ្វេងយល់ដោយសង្កេត អង្កេត ពិនិត្យ លើបាតុភូតធម្មជាតិ និងសង្គម តាមរយៈសំណួរដូចជា ១.ជាអ្វី? ២.ទីណា? ៣.ពេលណា? ៤.នរណា? ៥.ហេតុអ្វី? និង៦. របៀបណា(ឬដូចម្តេច)? ព្រមទាំងចេះត្រិះរិះ គិតពិចារណាសមហេតុផល ក្នុងការបកស្រាយសម្មតិកម្ម និងចេះសន្និដ្ឋានឱ្យបានត្រឹមត្រូវបានច្បាស់លាស់។

តាមរយៈការប្រតិបត្តិ តាមក្បួនតក្កវិជ្ជា (វិធីសាស្ត្ររកហេតុផល) មនុស្សម្នាក់ៗអាចស្វែងរកវិធីចាកចេញពីភាពល្ងង់ខ្លៅ (អវិជ្ជា) ហើយបង្កើនការអភិវឌ្ឍន៍ទស្សនៈយល់ដឹងរបស់ខ្លួនឱ្យ

[៥] សុង ស៊ីវ, *ចលនាអារ្យធម៌*, ភ្នំពេញ, បោះពុម្ពឡើងវិញដោយស្រី ប៊ុនជន ឆ្នាំ២០០៥ទំព័រ ១០២

[៦] ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំ.៤១៦

[៧] ប៉ាន់ វុត្ថា, *ទស្សនវិជ្ជា(ការគិតៈមនុស្សនិងច្បាប់សង្គម)* សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ, ២០១១ ភ្នំពេញ, ទំ.១

[៨] កាង អ៊ីនហ៊ួត និងអ្នកឯទៀត, *គ្រឹះរបស់ទស្សនវិជ្ជា*, ភ្នំពេញ, ២០០៦ ទំ.៣

ឈានទៅរកបញ្ញាពុទ្ធិ ដោយផ្ដើមចេញពីឥន្ទ្រីយ៍ពុទ្ធិទៅដល់វិចារណពុទ្ធិ។ ឥន្ទ្រីយ៍ពុទ្ធិ ជាពុទ្ធិសាមញ្ញ (បញ្ញាសាមញ្ញ) ដែលមនុស្សសត្វតែងមានពីកំណើតតាមកម្រិតសភាវគតិ ឬទម្លាប់នៃអង្គវិញ្ញាណឬឥន្ទ្រីយ៍ ដែលជាការដឹងតាមរយៈទ្វារវិញ្ញាណទាំង៦ ដូចជាភ្នែក ច្រមុះ ត្រចៀក មាត់ កាយ និងមនោវិញ្ញាណ (អារម្មណ៍ដឹង ការសោយអារម្មណ៍)។ រីឯ វិចារណពុទ្ធិ គឺជាចំណេះដឹងដែលបានមកពីការពិចារណា និង ពិសោធន៍ ដោយមានការចងក្រងជារូបមន្ត ឬទ្រឹស្ដី ដែលនាំឱ្យគេសម្រេចបានពុទ្ធិវិទ្យាសាស្ត្រ (ពុទ្ធិស្បង់) និងពុទ្ធិទស្សនវិជ្ជា។ ពុទ្ធិវិទ្យាសាស្ត្រ ដោះស្រាយបញ្ហាធម្មជាតិ ដើម្បីសម្រួលក្នុងជីវភាពរស់នៅខាងរាងកាយ ចំណែកពុទ្ធិទស្សនវិជ្ជា មានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍វិចារណញ្ញាណរបស់មនុស្ស ព្រោះវាអាចកំណត់ដឹងសមស្របតាមសច្ចភាពនូវអ្វីល្អឬអាក្រក់ ត្រឹមត្រូវឬខុសឆ្គង ផ្ដល់ប្រយោជន៍ឬផ្ដល់ទុក្ខទោស ពោលគឺ មានតែចំណេះដឹងពិតប្រាកដតាមរយៈពុទ្ធិវិទ្យាសាស្ត្រនិងពុទ្ធិទស្សនវិជ្ជាប៉ុណ្ណោះ ដែលអាចនាំសង្គមមនុស្ស ស្គាល់សច្ចភាពពិតប្រាកដ និងនាំឱ្យមនុស្សរស់នៅក្នុងជីវិត ប្រកបដោយបុណ្យកុសលត្រឹមត្រូវបាន ប៉ុន្តែគេមិនអាចទាត់ចោលពុទ្ធិសាមញ្ញបានដែរ ទោះបីពុទ្ធិសាមញ្ញនេះមិនអាចកំណត់អ្វីល្អអាក្រក់បានត្រឹមត្រូវក៏ដោយ។

ពុទ្ធិ (ចំណេះដឹង) គឺត្រូវដឹងនូវអ្វីដែលត្រូវធ្វើ ពោលគឺត្រូវចេះដឹងទាំងទ្រឹស្ដី និងប្រតិបត្តិជាក់ស្ដែង។ ១.តើមនុស្សត្រូវចេះដឹងអំពីអ្វីខ្លះ? ចម្លើយគឺគេត្រូវចេះដឹងអំពី ពុទ្ធិវិជ្ជា (ទ្រឹស្ដីពុទ្ធិ) និងអស្តិរូបវិជ្ជា(បរមត្ថវិជ្ជា)។ ២.តើគេត្រូវប្រតិបត្តិដូចម្ដេច? ចម្លើយ គឺគេត្រូវប្រតិបត្តិតាមសីលវិជ្ជា (អភិសមាចារ្យ, Ethics)។ ហេតុនេះក្នុងការរស់នៅ មនុស្សចាំបាច់នូវក្បួនទស្សនវិជ្ជា ដោយផ្ដោតសំខាន់លើទ្រឹស្ដី ពុទ្ធិវិជ្ជា និង អស្តិរូបវិជ្ជា ហើយអនុវត្តជាក់ស្ដែងតាមរយៈសីលវិជ្ជា និងតក្កវិជ្ជា។

**៣.ការសាកល្បងបង្កើត«ក្បួនអា»**

គោលបំណងនៃការបង្កើត «ក្បួនអា» នេះ គឺ ដើម្បីទុកជាមធ្យោបាយងាយស្រួលក្នុងសិក្សា និង ដើម្បីបង្ហាញឱ្យស្គាល់អំពីមូលដ្ឋានគ្រឹះនៃ ទស្សនៈខ្មែរ។ យើងដឹងថាមូលដ្ឋានគ្រឹះនៃទស្សនៈមនុស្សខ្មែរ គឺ ស្ថិតនៅលើតម្លៃនៃជំនឿទុកចិត្ត សហការ ឯកភាពម្ចាស់ការ សាមគ្គីធម៌ គុណធម៌ សុចរិតទៀងត្រង់ ល្អត្រឹមត្រូវ ជាដើម។ ហេតុនេះ វានៅខ្វះតែក្បួនខ្នាត ឬវិធីសាស្ត្រសម្រាប់បកស្រាយទស្សនៈជំនឿទាំងនោះប៉ុណ្ណោះ។

យើងបានកំណត់រៀបចំ «ក្បួនអា» នេះ ឡើងដោយសំយោគខ្លឹមសារនៃអក្សរ «អ» និងស្រៈ «ា» ជាមួយអត្ថន័យនៃពាក្យ «ទស្សនវិជ្ជា» តាមបែបខ្មែរ ដែលមានបញ្ញត្តិគន្លឹះសំខាន់ៗ ដូចជា: «ទស្សនៈ និង ក្បួន» «ស្រឡាញ់ និង គតិបណ្ឌិត»។ ការជ្រើសយក «អា» មកធ្វើជាក្បួន ព្រោះវាមានលក្ខណៈពិសេសជាច្រើនក្នុងអក្សរសាស្ត្រ និងអរិយធម៌ខ្មែរ។ ម្យ៉ាងទៀតគឺដោយមានចេតនារក្សាឱ្យបាននូវតម្លៃនៃតួអក្សរ «អ» និង ស្រៈ «ា»

ថាជាផ្នែកមួយសំខាន់នៃ «អត្តសញ្ញាណព្រលឹងជាតិខ្មែរ»។

យើងសូមបង្ហាញ អក្សរ « អ » (ព្យញ្ជនៈអ និង ស្រៈពេញតួអ) និង ស្រៈនិស្ស័យ « ។ » តាមលក្ខណៈរូបសាស្ត្រ ដែលគេអាចមើលឃើញជាក់ស្តែងដូចខាងក្រោម គឺ៖ អក្សរ «អ»បានមកពីការផ្សំផ្គុំរវាងអក្សរ « រ » និង « រ » ចំនួន២ ភ្ជាប់គ្នាដោយឃ្នងភ្ជាប់ (–) (ស្រៈ ។ ទម្រង់ផ្តេក គឺមិនមែនសញ្ញាដកទេ) បានទៅជា «រ–រ» (រ២ផ្សំគ្នា) ដែលក្លាយជា អក្សរ«អ»។រ (ន.) ជាបង្គោលគ្រឹះ[៩] ដែលយើងអាចទាញយកន័យថា៖ « អ » គឺជាបង្គោលគ្រឹះរូបី២ភ្ជាប់គ្នា ឬជាទ្វីកនិយមដែលតំណាងតម្លៃនៃការជឿជាក់ ទុកចិត្ត សហការ ប្រតិបត្តិការ ឯកភាព ម្ចាស់ការ សាមគ្គីគ្នាជាដើម។ រីឯស្រៈនិស្ស័យ « ។ » ជាបង្គោលអរូបី ជាឯកនិយម ដែលតំណាងឱ្យតម្លៃថាមពលព្រលឹងគុណធម៌ សង្គហធម៌ យុត្តិធម៌ ត្រឹមត្រូវ សុចរិតទៀងត្រង់ ស្មោះត្រង់ មិនវៀចវេរ ជាដើម។[១០]

យើងកំណត់ «ក្បួនអ។» នេះឡើងដើម្បីទុកជាតម្រាកំណត់ជាគោលចារឹក សម្រាប់បកស្រាយនូវទស្សនវិជ្ជាខ្មែរដែលបង្កប់ក្នុងអរិយធម៌ ហើយដែលមនុស្សខ្មែរឱ្យតម្លៃ តាមរយៈប្រណិប័តន៍និងប្រតិបត្តិក្នុងជីវភាពប្រចាំថ្ងៃតាំងពីអតីតកាល រហូតបច្ចុប្បន្ន។ ការខំប្រឹងទាញយកអត្ថន័យ ចេញពី «អ។» នេះ គឺដើម្បីទទួលបានបញ្ញត្តិគន្លឹះជាមូលដ្ឋានគ្រឹះមួយចំនួន ដើម្បីធ្វើជាស្នូលងាយស្រួលពន្យល់បកស្រាយ អំពីកម្មវត្ថុសិក្សាទស្សនវិជ្ជាខ្មែរដ៏សម្បូរបែប។ តាមរយៈ«ក្បួនអ។» យើងអាចបង្ហាញទស្សនវិជ្ជាខ្មែរអំពី៖ ១.ភាសា ២.ពុទ្ធិវិជ្ជា ៣.អស្តិរូបវិជ្ជា ៤.សីលវិជ្ជា ៥.តក្កវិជ្ជា ៦.សោភ័ណវិជ្ជា ៧.ចិត្តវិទ្យា ៨.វិទ្យាសាស្ត្រ ៩.ច្បាប់ ១០.អប់រំ ១១.សង្គម ១២.នយោបាយ ១៣.សេដ្ឋកិច្ច។ល។ ដោយប្រើវិធីតក្កវិជ្ជា «ក្បួនអ។» ចេះត្រិះរិះគិតពិចារណាសមហេតុផលត្រឹមត្រូវ ក្នុងការបកស្រាយសម្មតិកម្ម និងចេះសន្និដ្ឋានបានច្បាស់លាស់ សម្រាប់ពន្យល់បង្ហាញដំណោះស្រាយបញ្ហារស់នៅរបស់មនុស្សសត្វ។

## ៤.ការសាកល្បងបង្កើតនិមិត្តសញ្ញាទស្សនវិជ្ជាខ្មែរ តាម « ក្បួន អ។ »

ជាទូទៅមនុស្សនាំគ្នាទទួលយកនិមិត្តសញ្ញា «រូបបេះដូង» តំណាងឱ្យចិត្ត «ស្នេហា»។ ចំណែកនិមិត្តសញ្ញា«រង្វង់មូល» តំណាងការគិតប្រកបដោយ«គតិបណ្ឌិត»។ ដោយហេតុនេះយើងសាកល្បងបង្កើត និមិត្តសញ្ញាទស្សនវិជ្ជាខ្មែរ ដោយសំយោគ «ក្បួនអ។» ជាមួយនឹងអត្ថន័យនៃ

---

[៩] ជួន ណាត, *វចនានុក្រមខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំ.៩៦២

[១០] ការសន្មតខាងលើ គឺចង់ទាញភ្ជាប់ខ្លឹមសារដែលមានអត្ថិភាពស្រាប់ ដើម្បីគាំទ្រដល់ទម្រង់នៃ «ក្បួនអ។»។ វាស្ថិតក្នុងបញ្ញត្តិធម្មតាគឺមិនស្ថិតក្នុងទម្រង់តក្កវិជ្ជាណាមួយឡើយ ព្រោះវាខ្វះសុពលភាពដោយវិរុទ្ធនិទស្សន៍។

ពាក្យ«ទស្សនៈ និង វិជ្ជា» និងពាក្យ « ស្នេហា និង គតិបណ្ឌិត»។

**និមិត្តសញ្ញាទស្សនវិជ្ជាខ្មែរ តាម «ក្បួន អ។»**



យើងបានសាកល្បងបង្កើត និមិត្តសញ្ញា តំណាងទស្សនវិជ្ជាខ្មែរតាម«ក្បួនអ។»នេះ ដោយនៅក្នុងនិមិត្តសញ្ញានេះមានអក្សរ « អ » ពណ៌សនៅលើរូបបេះដូងពណ៌ក្រហម សម្រាប់សម្គាល់ស្នេហាដែលជាបាតុភូតផ្លូវចិត្ត។ រូបបេះដូងនេះស្ថិតនៅក្នុង ថាសរង្វង់មូលពណ៌បៃតងបង្កប់ដោយស្រៈ«។»ពណ៌ស ដែលតំណាងឱ្យខួរក្បាលដែលមានការគិតត្រិះរិះ ប្រកបដោយគតិបណ្ឌិតត្រឹមត្រូវល្អ។

អាចនិយាយម៉្យាងទៀតថា និមិត្តសញ្ញា «» នេះមាន រូបបេះដូងពណ៌ក្រហមតំណាងឱ្យចិត្តស្រឡាញ់។ ចិត្តតែងបង្ហាញទស្សនៈមតិយោបល់តាមអារម្មណ៍ស្រឡាញ់ឬស្អប់ និងកំណត់ដឹងល្អអាក្រក់តាមកត្តាអត្តនោម័ត។ ដើម្បីសម្រេចបានបញ្ញាពុទ្ធិ កត្តាអត្តនោម័តនេះមិនទាន់គ្រប់គ្រាន់ទេ វាត្រូវផ្អែកលើកត្តាសត្យានុម័តទៀត ហេតុនេះវាត្រូវប្រកបដោយវិធីសាស្ត្រ ឬក្បួនច្បាប់ ឬ «ក្បួនអ។» ដើម្បីផ្ទៀងផ្ទាត់ឱ្យការយល់ឃើញប្រកបដោយសច្ចភាព រឹងមាំ សុក្រិតត្រឹមត្រូវ ដែលទាំងអស់នេះត្រូវបានតំណាងដោយរូបថាសរង្វង់មូលពណ៌បៃតង បង្កប់ដោយស្រៈ «។» ពណ៌ស និងរំលេចដោយអក្សរ«អ»ពណ៌ស នៅលើរូបបេះដូងពណ៌ក្រហម។

## ៥.ការសាកល្បងបង្កើត និយមន័យទស្សនវិជ្ជាខ្មែរ

ក្រោយពីការសាកល្បងបង្កើត «ក្បួនអ។» ជា ជានិមិត្តកម្មនៃទស្សនវិជ្ជាខ្មែររួចហើយ យើងបាន សាកល្បងឱ្យនិយមន័យទស្សនវិជ្ជាខ្មែរ ដូចខាងក្រោម៖ «ទស្សនវិជ្ជាខ្មែរ គឺជាតម្លៃទ្រឹស្តីដែលបានមកពីការសំយោគរវាងលទ្ធិទាំងឡាយដែលអត្ថិភាពក្នុងអរិយធម៌ខ្មែរ មានដូចជាជំនឿខ្មែរដើម ព្រហ្មណ៍និយម ព្រះពុទ្ធនិយម ជាមួយទ្រឹស្តីវិទ្យាសាស្ត្រ សង្គម នយោបាយ សេដ្ឋកិច្ចនៃសាកលនីយកម្ម តាមរយៈ «ក្បួនអ។» លើមតិយោបល់ ទស្សនៈគំនិតសំខាន់ៗ ដោយផ្តោតលើបញ្ញត្តិគន្លឹះមូលដ្ឋានគឺ ស្នេហានិងគតិបណ្ឌិត ដើម្បីស្វែងរកសច្ចភាពនិងប្រយោជន៍សម្រាប់ការរស់នៅរបស់មនុស្សក្នុងសង្គម»។

និយមន័យនេះគឺជាការសាកល្បងបង្កើតដោយផ្អែកលើតថភាពនិងទ្រឹស្តីនានាដែលស្មេរជួបប្រទះក្នុងជីវភាពរស់នៅ និងក្នុងស្រាវជ្រាវមុខវិជ្ជាទស្សនវិជ្ជាជាច្រើនឆ្នាំកន្លងមក។

## សេចក្តីសន្និដ្ឋាន

ទោះបី ទស្សនវិជ្ជាខ្មែរ មានការវិវត្តន៍ឥតឈប់ឈរទៅតាមសម័យកាលយ៉ាងណាក៏ដោយ ក៏ទស្សនវិជ្ជានេះរក្សាបាននូវលក្ខណៈពិសេសជាមូលដ្ឋានគ្រឹះផ្ទាល់ខ្លួន ដែលអ្នកសិក្សាអាចស្វែងយល់តាមវិធីសាស្ត្រ ឬក្បួនផ្សេងៗបាន។

ការរៀបចំបង្កើតៈ ១.«ក្បួនអ|» ២.និមិត្តសញ្ញាទស្សនវិជ្ជាខ្មែរតាម«ក្បួនអ|»និង ៣.និយមន័យទស្សនវិជ្ជាខ្មែរ នៅពេលនេះ គឺគ្រាន់តែជាការរៀបចំឱ្យមានទម្រង់ការមួយ នៃទស្សនវិជ្ជាខ្មែរ តាមការយល់ឃើញផ្ទាល់ខ្លួន ដោយផ្អែកលើអត្តិភាពនៃអរិយធម៌ខ្មែរ ដែលជាមរតកគំនិតរបស់បុព្វបញ្ញវន្តខ្មែរ បន្សល់ទុកប៉ុណ្ណោះ។ ជាធម្មតាមនុស្សម្នាក់ៗតែងតែមានទស្សនផ្ទាល់ខ្លួន ដូច្នេះប្រាដកណាស់ថា ការសាកល្បងបង្កើតនេះ តិចឬច្រើននឹងមានការរិះគន់កែលំអជាក់ជាពុំខាន។ យើងនឹងពិចារណារាល់មតិកែតម្រូវណាដែលប្រកបដោយការរិះគន់ស្ថាបនា។

យើងសង្ឃឹមថា ទស្សនវិជ្ជាខ្មែរតាមរយៈ «ក្បួនអ|» អាចជួយខ្មែរឱ្យកាន់តែមានបញ្ញាស្មារតីរឹងប៉ឹងមាំមួនមិនចាញ់ប្រាបសាសន៍ដទៃ ហើយរួមគ្នាសាងជីវភាពរស់នៅប្រកបដោយគុណធម៌ សាមគ្គីគ្នានិងទុកចិត្តគ្នាទៅវិញទៅមកជាថ្មីឡើងវិញបាន។

តាមពិតទោះស្គាល់ឬមិនស្គាល់ក៏ដោយ ក៏ «ក្បួនអ|» ដែលយើងសន្មតិបង្កើតនេះត្រូវបានពលរដ្ឋខ្មែរប្រើប្រាស់យ៉ាងពេញលេញ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន តាំងពីសម័យបុរាណកាលមកម្ល៉េះ គឺវាបានស្ថិតនៅក្នុងមនុស្សខ្មែរតាមរយៈវប្បធម៌ខ្មែរ ជាពិសេសភាសា អក្សរសាស្ត្រខ្មែរ។ «ក្បួនអ|» ជាផ្នត់គំនិត និងជាអត្តសញ្ញាណព្រលឹងនៃមនុស្សខ្មែរ ដែលស្តែងឡើងតាមរយៈអត្តចរិត ឥរិយាបថ ការសម្តែងមនោសញ្ចេតនា ទំនាក់ទំនង ភាសាសរសេរ ភាសាកាយវិការ និងភាសានិយាយជាដើម។

**ឯកសារយោង/គន្ថនិទ្ទេស**


១.កាង អ៊ុនហ៊ួន និងអ្នកឯទៀត, គ្រឹះរបស់ទស្សនវិជ្ជា, ភ្នំពេញ, ២០០៦

៣.ជួន ណាត, វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ភ្នំពេញ, ឆ្នាំ១៩៦៧

៦.ប៉ាន់ វុត្ថា, ទស្សនវិជ្ជា (ការគិត:មនុស្សនិងច្បាប់សង្គម) , ភ្នំពេញ, គ.ស.២០១១

៧.លី ផានី និង អ្នកផ្សេងទៀត, ទស្សនវិជ្ជា, វិទ្យាស្ថានជាតិខេមរយានកម្ម, ១៩៧៤

៨.លី ធាមតេង, សិក្សាសង្ខេប អំពី អារ្យធម៌ខ្មែរ, បោះពុម្ពលើកទី២, ភ្នំពេញ ១៩៦៩

៨.សុង ស៊ីវ, ចលនាអារ្យធម៌, ភ្នំពេញ, បោះពុម្ពឡើងវិញដោយស្រី ប៊ុនដន ២០០៥

៩. G. Vesey and P. Foulkes, *Dictionarary of Philosophy*, Unwin Hyman, 1999

១០.Nicholas Bunnin and Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, Blackwell Publishing Ltd, 2004

# ទិដ្ឋភាពទូទៅអ្នកនិពន្ធខ្មែរ

*ដោយៈ* **លោក នេត ចំរើន**
*មន្ត្រីស្រាវជ្រាវនៃនាយកដ្ឋាននរវិទ្យានិងជាតិពន្ធុវិទ្យា*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*ដោយមើលឃើញថា អ្នកនិពន្ធខ្មែរ នាពេលបច្ចុប្បន្ន កំពុងប្រឈមមុខនឹងឧបសគ្គជាច្រើន ដែលនាំឱ្យការនិពន្ធ ការបោះពុម្ពផ្សាយ វណ្ណកម្មរបស់ពួកគេ ជួបការលំបាក។ ក្នុងនាមខ្ញុំជាអ្នកស្រាវជ្រាវផ្នែកអក្សរសាស្ត្រនិងវប្បធម៌ម្នាក់ ខ្ញុំសូមចែករំលែកនូវកូនអត្ថបទដ៏តូចនេះស្តីពីទិដ្ឋភាពទូទៅរបស់អ្នកនិពន្ធខ្មែរ ដែលបានរៀបរាប់តាំងពីអ្នកនិពន្ធគ្រប់សម័យកាល ដោយសង្ខេបរហូតដល់បច្ចុប្បន្ន ។*

*ដូច្នេះនៅពេលដែល ខ្ញុំបាទសង្ឃឹមថា ស្នាដៃស្រាវជ្រាវដ៏តូចមួយនេះ នឹងផ្តល់ជាចំណេះដឹងដល់អ្នកអានឱ្យមានការយល់ដឹងបន្ថែមពីវិស័យអក្សរសាស្ត្រយើង។*

*យ៉ាងណាមិញ ខ្ញុំបាទ ដែលជាអ្នកស្រាវជ្រាវ និងសរសេរនេះ ក៏រង់ចាំមតិកែលំអបន្ថែម ក្រែងអ្វីដែល ខ្ញុំបាទបានសរសេរនេះ មានកន្លែងខ្វះចន្លោះត្រង់ចំនុចណាមួយ គឺយើងជួយបំពេញគ្នា ដើម្បីឱ្យអត្ថបទនេះកាន់តែមានសុក្រិត្យភាព។*

## ២.ប្រវត្តអ្នកនិពន្ធខ្មែរ

*ប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនអារ្យធម៌ដ៏ចំណាស់ និងរីកចម្រើនមុនគេនៅភូមិភាគអាស៊ីអាគ្នេយ៍។ ជាពិសេសវិស័យអក្សរសាស្ត្រគឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ជាតិ។*

*សិលាចារឹក វ៉ូកាញ់ ជាភាសាសំស្ក្រឹតចារក្នុងអំឡុងសតវត្សទី២ ឬទី៣នៃគ.ស គឺជាសាលាចារិកដែលមានវ័យចំណាស់ជាងគេ។ នៅអាស៊ីអាគ្នេយ៍ ដែលមានរូបរាង និងអក្សរដូចគ្នាទៅនឹងសិលាចារឹក**មថុរា**(ឆ្នាំ១៥៦គ.ស) របស់ឥណ្ឌា (ឯកសារយោង)។ សិលាចារឹកនេះរកឃើញនៅខេត្តញ៉ាត្រាងប្រទេស*

វៀតណាម ដែលធ្លាប់ជាដែលធ្លាប់ជាសាមន្តរដ្ឋរបស់នគរភ្នំ។[1]




សិលាចារឹកមូលស្ថាបនាអ្នកតាដំបងដែក ខេត្តតាកែវ (K-875) គឺជាសិលាចារឹកមួយក្នុងចំណោមសិលាចារឹក ដែលមានចំណាស់ជាងគេនៅកម្ពុជាក្នុងសតវត្សទី៥-៦។ អត្ថបទចងក្រងជា៥គាថា ជាភាសាសំស្ក្រិត តាមព្រះរាជសវនីយ៍ ព្រះនាង កុលព្រះភាវតី ដែលជាព្រះអគ្គមហេសីរបស់ព្រះបាទ ស្រីជ័យវរ័ន្ម (៤៨៤-៥១៧) ដែលបានរៀបរាប់ថា ព្រះនាងជាអគ្គមហេសីសំណព្វចិត្តរបស់ព្រះបាទស្រីជ័យវរ័ន្ម ប្រៀបបានទៅនឹង ព្រះសចី ជាព្រះជាយាសំណព្វរបស់ព្រះឥន្ទ ក៏ប្រៀបបានទៅនឹងព្រះស្វាហា ជាព្រះយាជាសំណព្វរបស់ព្រះអគ្គី អណ្តាតភ្លើង៧ ក៏ប្រៀបទៅនឹង ព្រះរុទ្រាណី ជាព្រះជាយាសំណព្វរបស់ព្រះឥសូរ ឬប្រៀបបានទៅនឹងព្រះគ្រី (ព្រះលក្សី)ព្រះជាយាសំណព្វរបស់ព្រះនរាយណ៍ ។




សិលាចារឹកបុរេអង្គរទាំងអស់មានចំនួន ៤៧០ បញ្ជីដែលបានរៀបចំឡើងដោយលោក Coedes មានចំនួន ២៣០ ដល់លេខ K.1050។ បន្ទាប់មកលោក Claude Jacques បានបំពេញបន្ថែម ដល់ចំនួន៣៣០ ដែលបានចុះបញ្ជីដល់K.1150។ បន្ទាប់ពីឆ្នាំ ១៩៩១ គេបានរកឃើញសិលាចារឹកបុរេអង្គរថ្មីទៀត ប្រមាណចំនួន១៣៤។ ក្នុងចំណោមសិលាចារឹកបុរេអង្គរទាំងនោះ សិលាចារឹកភាសាខ្មែរមានចំនួន៥២ និងសិលាចារឹកភាសាសំស្ក្រឹតមានចំនួន២៥៧ និងសិលាចារឹក ចំនួន៥៤ មានកាលបរិច្ឆេទត្រឹមត្រូវ។[2]

[1] បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ៖អក្សរសសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ តាមរយៈសិលាចារឹក ទំព័រទី២៧

[2] បណ្ឌិតសភាចា ហង់ជួនណារ៉ុន ៖អក្សរសសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ តាមរយៈសិលាចារឹក ។ ទំព័រទី៣២-៣៦។

ការរកឃើញសិលាចារឹកនេះ គឺមានន័យថា កម្ពុជរដ្ឋមានភាសា និងអក្សរដើម្បីកត់ត្រាព្រឹត្តិការណ៍នានាដែលកើតក្នុងសង្គម ហើយក៏មានន័យថា ជនជាតិខ្មែរ ក៏សម្បូរអ្នកចេះដឹងបណ្ឌិតកវីនិពន្ធតាំងពីសម័យហ្វូណន (នគរភ្នំ)មកម៉្លេះ ទើបអាចចេះសរសេរអត្ថបទដ៏ក្បោះក្បាយបែបនេះ។

**១.១-អ្នកនិពន្ធសម័យអង្គរ**

ឈានមកដល់សម័យអង្គរ គឺជាសម័យរុងរឿងបំផុតរបស់ខ្មែរ ពេលនោះគេបានស្គាល់ឈ្មោះអ្នកនិពន្ធល្បីៗជាច្រើនដូចជា៖

**១ បណ្ឌិត សិវសោម** ដែលរស់នៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១ គ.ស ៨៧៧-៨៨៩ ដែលបាននិពន្ធរឿងមហាភារតៈ ក្បួនវេយ្យាករណ៍ និងសិលាចារឹកប្រាសាទកណ្តាលដើម។ ព្រះអង្គបានកសាងប្រាសាទព្រះគោនិងបាគង ដែលជាបុរាណដ្ឋានដ៏ល្អវិសេស។

**២ បណ្ឌិតយតិអមរភាវៈ** ជាអ្នកប្រាជ្ញដ៏សំខាន់ក្នុងរាជកាលព្រះបាទយសោវរ្ម័ន គ.ស ៨៩៩-៩០៨។ លោកជាអធិបតីនៃបណ្ឌិតទាំងឡាយ និងមានឋានន្តរសក្តិជាសង្ឃរាជនិងជាអ្នកតែងសិលាចារឹកភ្នំចាយ៉ង់ក្នុងខេត្តតាកែវ។

**៣ បណ្ឌិត សិវាចារ្យ** ជាអធិការត្រួតខាងសីលធម៌ក្នុងរាជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស ១០០២-១០៤៩) ដែលបានតែងសិលាចារឹកជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវ។

**៤ បណ្ឌិត កវិន្ទ្រៈ** ជាអ្នកប្រាជ្ញយ៉ាងធំនិងជាអ្នកនិពន្ធយ៉ាងឆ្នើមក្នុងរាជកាលព្រះបាទសូរ្យវរ្ម័នទី១ គ.ស១០០២-១០៥០។ លោកបានតែងនិពន្ធសិលាប្រាសាទខ្នាជាភាសាសំស្ក្រឹត ដើម្បីសរសើរតេជៈបារមីរបស់ព្រះបាទសូរ្យវរ្ម័នទី១ ដែលមានសេចក្តីក្លាហានមោះមុតក្នុងការធ្វើសឹក។

**៥ បណ្ឌិត សទាសិវ** ជាអ្នកកវីនិពន្ធដែលតែងសិលាចារឹកប្រវត្តិសាស្ត្រស្តុកកក់ធំ ក្នុងរាជកាលព្រះបាទសូរ្យវរ្ម័នទី១។ សិលាចារឹកស្តុកកក់ធំអាចចាត់ទុកថាជាស្នាដៃអក្សរសិល្ប៍បែបប្រវត្តិសាស្ត្រដ៏សំខាន់បំផុត។

**៦ បណ្ឌិត ទិវាករ** លោកជាអ្នកប្រាជ្ញឯកក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន។ បណ្ឌិតទិវាករចេះចាំគម្ពីរត្រៃវេទយ៉ាងស្ទាត់ជំនាញ។ លោកបាននិពន្ធសិលាចារឹកជាភាសាខ្មែរ និងជាភាសាសំស្ក្រឹតនៅប្រាសាទកំកឹសដែលស្ថិតនៅខេត្តម្ពព្រៃ ២៥គីឡូម៉ែត្រពីប្រាសាទកោះកេរ។[3]

**១.២-អ្នកនិពន្ធសម័យក្រោយអង្គរ**

- បណ្ឌិត ជ័យ នន្ទ (សិលាចារឹកអង្គរវត្តជាពាក្យកាព្យសរសេរកាលពីចុងសតវត្សទី១៦) ។

[3] https://www.khsearch.com/qna/13542

- អ្នកប៉ាង៖ ល្បើកអង្គរ (ពាក្យកាព្យសរសេរសេសពី គ.ស ១៥៩៨) ។
- ព្រះរាជសម្ភារះ កាព្យនិរាស ច្បាប់រាជសម្ភារ ( សរសេរសេសពីគ.ស ១៩៣) សរសើរហេមន្តមាស (១៦២៩) ហិនលក្ខណ៍សល (១៦៣០) ។
- ឧកញ៉ាកោសាធិបតីក្រៅ៖ រឿងក្រុងសុភមិត្រ (សរសេពី គ.ស ១៧៩៨) ។
- ឧញ៉ាព្រះឃ្លាំង នង ៖
- ច្បាប់សុភាសិត (១៧៩០)
- លោកនេយ្យជាតក (១៧៩៤)
- រឿងបុញ្ញាសារសិរលោ (១៧៩៨)
- រឿងភោគកុលកុមារ (១៨០៤)
- រឿងវរនេត្រ វរនុជ (១៨០៦) ។
- ព្រះបាទអង្គឌួង
- រឿងកាកី (១៨១៣)
- ច្បាប់ស្រីអង្គឌួង (១៨)
- ព្រះបទុមបារមី ពេជ្រ៖ របាក្សត្រស្រុកខ្មែរ (១៨១៨) ។
- ឧកញ៉ា សោទសខែក៖ ល្បើកជេតពន (១៨១៥) ។
- បណ្ឌិត សំអាត៖ រឿងនាងមុជលិន ឬព្រះចន្ទគោរព (១៨៣៣) ។
- ឧញ៉ាចក្រីកែវ៖ រឿងដាវរឿង (១៨៥៦)
- ព្រះអរិយគាមុនីហ៊ីង ៖ រឿងព្រះជិនវង្ស (១៨៥៦)។
- ព្រះធម្មបញ្ញាម៉ែន៖ រឿងពេជតា (១៨៥៧) ។
- ឧកញ៉ា ធិបតីយ៉ែម៖ រឿងនាងវិមាចន្ទ (១៨៥៨) ។
- ពញាអនុជិតស្រី៖ ល្បើកស្រីវិជ័យ (១៨៥៨) ។
- ឧញ៉ា សុន្ទរវោហារម៉ុក៖ រឿងទេវន្ទ (១៨៥៩) ។

**១.៣-អ្នកនិពន្ធសម័យអាណានិគមនិយមបារាំង ៖**

ព្រះធម្មបញ្ញាអ៊ុក៖ រឿងមរណមាតា (១៨៧៧)
បវរកត្តីព្រហ្ម៖ រឿងពោធិវង្ស (១៨៨១)
ឃុនសុន្ទរពិនិត្យ៖ រឿងចៅមាស (១៩៩៧)
ឧកញ៉ាវង្សាធិបតីអ៊ុក៖ រឿងសន្ធសិល្បជ័យ (១៨៨២)
ម៉ឺនភក្តីអក្សរ តន់៖ រឿងសព្វសិទ្ធ (១៨៩៩)
លោក យស ងិន៖ រឿងចៅស្រទបចេក (១៩...)
វិសេសជួង៖ ល្បើកអក ល្បើកសារិកា ល្បើកដុច និងត្រី។[4]

វិស័យតែងនិពន្ធបានវិវត្តន៍ ទៅតាមសង្គមកាលដូចជាកាលពីជំនាន់ដើមអ្នកនិពន្ធគាត់តែងកំណាព្យដើម្បីសូត្រថ្វាយព្រះអាទិទេព តែងសម្រាប់ព្រះរាជា ដោយចារនៅតាមផ្ទាំងសិលា តាមសស្ត្រាស្លឹករឹត និងក្រោយមកទៀត ទើបមានសរសេរនៅក្នុងសៀវភៅ និងភាពយន្ត។

[4] https://www.khsearch.com/qna/13542

អ្នកនិពន្ធមុន និងក្នុងសម័យមហានគរ ភាគច្រើនគឺជាពួកអ្នកមានឋានៈខ្ពង់ខ្ពស់ក្នុងសង្គម ពិសេសគឺជាអ្នក ដែលស្ថិតនៅក្នុងត្រកូលក្សត្រ និងពួកព្រាហ្មណ៍ អ្នកកាន់សាសនា។ តែក្រោយមក បន្ទាប់ពីព្រះពុទ្ធសាសនាចូលមកជ្រៅក្នុង ស្រទាប់មហាជន វិស័យតែងនិពន្ធ បានផ្លាស់ប្តូរប្រែប្រួលបន្តិចដោយអ្នកនិពន្ធ មានពួកវណ្ណៈក្សត្រ ព្រះសង្ឃ និងមហាជន។ ការតែងនិពន្ធ មានការប្រែប្រួល ខ្លាំង គឺចាប់ពីសម័យឧត្តុង្គ និងបន្ទាប់មកក្នុងដំណាក់កាលអាណានិគមនិយមបារាំង។

អ្នកនិពន្ធ តែងតែនិពន្ធពីសាសនា ទំនៀមទម្លាប់ប្រពៃណីនិងស្ថានការណ៍សង្គម។ពិសេសបន្ទាប់ ពីដំណាក់កាល អាណានិគមនិយមបារាំង អ្នកនិពន្ធខ្មែរបានតាក់ តែងប្រឌិតរឿង និងកំណាព្យល្បើកជាច្រើន ដែលស្នាដៃទាំងនេះបម្រើការកម្សាន្ត និងការត្រិះរិះពិចារណាដល់សាធារណជន។

តែក្រោយមកអក្សរសិល្ប៍ខ្មែរ ក៏ធ្លាក់ចូលក្នុងរបត់ថ្មីមួយ គឺការសរសេរប្រលោមលោកពាក្យរាយ ដោយមានអ្នកនិពន្ធជាច្រើនបានកើតឡើង ហើយអ្នកនិពន្ធទាំងនោះ គឺហៅថាអ្នកនិពន្ធទំនើប ដែលបានទទួលការសិក្សាពីសាលាទំនើប ទទួលឥទ្ធិពលពីការអាន សិក្សាប្រលោមលោកបស្ចឹមប្រទេស ដែលហូរចូលមកប្រទេសកម្ពុជាតាមរយៈអាណាព្យា បាលបារាំង ឬពីសំណាក់ប្រទេសជិតខាង ដែលបានទទួលឥទ្ធិពលពីប្រទេសលោកខាងលិច ជាអាទិ៍ បារាំង និងអង់គ្លេស។ អ្នកនិពន្ធប្រភេទនេះបានទទួលការសិក្សាពីសាលាវត្តផងដែរ ក្នុងកម្រិតដំបូងទើបបន្តការសិក្សាថ្នាក់មធ្យមសិក្សាជាដើម ទៅតាមសាលទំនើប ដែលជាសាលាគម្រនៅប្រទេសខ្មែរនាសម័យនោះ។ នាសម័យនោះ អក្សរសិល្ប៍ខ្មែរ មានលក្ខណៈមនុស្សនិយម ដោយអ្នកនិពន្ធលើកយកបញ្ហាមនុស្សមកចោទដោះស្រាយទៅតាមតថភាពសង្គម និងខិតខំបង្ហាញពីមធ្យោបាយ ការយល់ឃើញផ្សេងៗរបស់ខ្លួន ក្នុងបំណងលុបបំបាត់ភាពអសកម្មក្នុងជីវភាពសង្គម ផ្សះផ្សារទំនាស់សង្គមជាដើម។

យើងខ្ញុំសូមលើកយកឈ្មោះអ្នកនិពន្ធ ដែលលេចធ្លោមួយចំនួនក្នុងសម័យនោះដូចជាៈ

- អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿងកូលាបប៉ៃលិន ឆ្នាំ ១៩៣៦។
- អ្នកនិពន្ធ រីម គិន និពន្ធរឿងសុផាត ឆ្នាំ ១៩៣៨។
- អ្នកនិពន្ធ គឹម ហាក់ និពន្ធរឿងទឹកទន្លេសាប ឆ្នាំ១៩៣៩
- អ្នកនិពន្ធ សិទ្ធិ និពន្ធរឿងគូសាងមិត្តមិនត្រូវស្គមិត្ត និងរឿងចិត្តសត្យា ឆ្នាំ ១៩៤០។
- អ្នកនិពន្ធ នូហាច និពន្ធរឿងផ្កាស្រពោន ឆ្នាំ១៩៤០។

- អ្នកនិពន្ធ ញ៉ុក ថែម និពន្ធរឿងបិសាចស្នេហា ឆ្នាំ១៩៤០។
- អ្នកនិពន្ធ នង ឈុំ និពន្ធរឿងចៅកើតកុសល ឆ្នាំ១៩៤១។
- អ្នកនិពន្ធ តូច សឺង ហាន និពន្ធរឿងកែបមាត់សមុទ្រ ឆ្នាំ១៩៤២។
- អ្នកនិពន្ធ ហេង យ៉ាន និពន្ធរឿងកំពូលកំសត់ ឆ្នាំ១៩៤៦។
- អ្នកនិពន្ធ ហេង យ៉ាន និពន្ធរឿងកំពូលស្នេហា ឆ្នាំ១៩៤៦។
- អ្នកនិពន្ធ អឹម ហ៊ី និពន្ធរឿងមហាអភ័ព្វ ឆ្នាំ១៩៤៦។
- អ្នកនិពន្ធ នូ កន និពន្ធរឿងតុងឈិន ឆ្នាំ១៩៤៧។
- អ្នកនិពន្ធ ឈុប និពន្ធរឿងព្រាត់ដួងចិត្ត ឆ្នាំ១៩៤៧។
- អ្នកនិពន្ធ អឹម ហ៊ី និពន្ធរឿងទឹកភ្នែកស្រីស្រុកស្រែ ឆ្នាំ១៩៤៧។
- អ្នកនិពន្ធ ស៊ឹម វណ្ណស៊ី និពន្ធរឿងសង្ឃឹមជានិច្ច ឆ្នាំ១៩៤៨។
- អ្នកនិពន្ធ នូ ហាច និពន្ធរឿងមាលាដួងចិត្ត ឆ្នាំ១៩៥២។
- អ្នកនិពន្ធ រីម គិន និពន្ធរឿងសមាភារី ឆ្នាំ១៩៥២។
- អ្នកនិពន្ធ .....(រកឈ្មោះអ្នកនិពន្ធមិនឃើញ) និពន្ធរឿងម៉ាកកីយូងកែវ ឆ្នាំ១៩៥២[5]

### ១.៤-អ្នកនិពន្ធពីសម័យឯករាជ្យរហូតសម័យសាធារណៈរដ្ឋខ្មែរ

សម័យសង្គមរាស្ត្រនិយមគឺជាសម័យមួយដែលប្រទេសកម្ពុជាយើងមានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចក្រោមការដឹកនាំរបស់សម្តេចសីហនុ ។ ផលិតកម្មអក្សរសិល្ប៍បានប្រកបដោយវឌ្ឍនភាពខ្លាំងក្លា ជាពិសេសអំឡុងឆ្នាំ ១៩៦៥-៦៦ ប្រទេសទទួលបានការរីកចម្រើនបំផុតក្នុងវិស័យវប្បធម៌ដោយមានសាកលវិទ្យាល័យរីកដុះដាលក្នុងរាជាណាចក្រ។ កវីនិពន្ធជំនាន់នោះ មានកំណើតរវាងឆ្នាំ ១៩៣០ ហើយចាប់សរសេរជាដំបូងរវាងឆ្នាំ ១៩៥០រហូតដល់ឆ្នាំ ១៩៥៥ ហើយបន្តសរសេររហូតដល់ខ្មែរក្រហមយកភ្នំពេញបាន[6]

ក្នុងចំណោមប្រលោមលោកដែលសាស្ត្រាចារ្យឃួនសុខម្ភ និងនិស្សិតអក្សរសាស្ត្រភ្នំពេញបានស្រង់ចំណងជើងពីឆ្នាំ ១៩៣៨-១៩៧២ នៅបណ្ណាល័យជាតិកម្ពុជា មានជិត ៧០០រឿង ហើយយើងសង្កេតឃើញថាប្រលោមលោកមនោសញ្ចេតនាមានចំនួនច្រើនជាងគេក្នុងចំណោមអក្សរសិល្ប៍ទំនើប។ ប្រលោមលោកផ្សងព្រេង និងអាថ៌កំបាំង មាន

[5] **ឃិន យ៉ង់**៖ នានានៃអក្សរសិល្ប៍សម័យអាណានិគមបារាំង -ទំព័រទី៧-ទី៨។

[6] **ឃីង ហុកឌី**៖ អក្សរសិល្ប៍ខ្មែរ សតវត្សទី២០ -ទំព័៣៤

ចំណាត់ថ្នាក់លេខពីរ បន្ទាប់មកមានប្រលោមលោកប្រវត្តិសាស្ត្រ ជាបន្តទៀតមានប្រលោមលោក ស៊ើបអង្កេត និងចារកម្មរួចមានប្រលោមលោកនយោបាយ និងសង្គម។ ចាប់តាំងពីឆ្នាំ ១៩៦៥មក មានលេចប្រលោមលោក មួយប្រភេទទៀត គឺប្រលោមលោក ទស្សនវិជ្ជា និងចិត្តសាស្ត្រ។[7]

ដូច្នេះបញ្ជាក់ថា ចាប់តាំងពីសម័យឯករាជ្យ រហូតដល់បញ្ចប់សម័យសាធារណរដ្ឋ គឺមានអ្នកនិពន្ធច្រើនណាស់ ដែលបានចាប់យកអាជីពជាអ្នកនិពន្ធ ផលិតស្នាដៃលក់នៅលើទីផ្សារ ដោយគេដឹងថា សម័យនោះវិស័យសោតទស្សន៍មិនទាន់រីកចម្រើន ហើយមហាជនតែងតែជាវប្រលោមលោក ដើម្បីកម្សាន្ត និងបង្វែរអផ្សុក។

កត្តានេះហើយ ដែលពាណិជ្ជករដែលមានគំនិតឆ្វាតវៃខាងជំនួញ ក៏ចាប់ផ្ដើមរកស៊ីមុខរបរពោងពុម្ព ហើយទិញស្នាដៃពីអ្នកនិពន្ធល្បីៗ នាសម័យនោះដើម្បីបោះពុម្ពលក់។ អ្នកនិពន្ធដែលមានស្នាដៃល្បីៗ តែងចុះកុងត្រាជាមួយពោងពុម្ពដើម្បីលក់ស្នាដៃរបស់ពួកគាត់ដូចជាលោក ហាក់ ឆៃហុក លោក ឡា ប៉េងសៀក លោកគង្គ ប៊ុនឈឿន...ជាដើម។ល។ អ្នកនិពន្ធខ្លះ ដោយមានពោងពុម្ពជាច្រើនទាក់ទងគាត់ឱ្យលក់ស្នាដៃទៅឱ្យពួកគេ ហើយអ្នកនិពន្ធទាំងនោះ ព្រោះតែជាប់កុងត្រាជាមួយពោងពុម្ពចាស់ ក៏នឹកបង្កើតនាមប៉ាកកាថ្មី ដើម្បីមានសិទ្ធិលក់ស្នាដៃទៅឱ្យពោងពុម្ពដទៃ ដូចជាលោក ហាក់ ឆៃហុក ដាក់នាមប៉ាកកាថា «ទិន ទិវា» លោក ឡា ប៉េងសៀក ប្រើនាមប៉ាកកា ថា «កាណៃល» ជាដើម។

ក្នុងសម័យដែលអក្សរសិល្ប៍មានការរីកចម្រើន អ្នកនិពន្ធខ្លះ មិនត្រឹមតែសរសេរប្រលោមលោកលក់ទេ ថែមទាំងនិពន្ធចម្រៀង និង រឿងភាពយន្តលក់ឱ្យផលិតកម្មនានាផងដែរ។ យោងតាមការស្រាវជ្រាវ និងចងក្រង ដោយ Amazing Cambodia ឆ្នាំ ២០១២ ដោយមាននៅសល់រូបភាពមួយចំនួនពីមជ្ឈមណ្ឌល បុប្ផាណាបានឱ្យដឹងថា ចាប់ពីទសវត្សទី៦០ រហូតដល់៧០ មានរោងភាពយន្ត រហូតដល់ ៣៤រោងឯណោះក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន ហើយរោងភាពយន្តទាំងនោះមានដូចជា៖ ១- រោងភាពយន្ត កាស៊ីណូ ២- រោងភាពយន្ត ខេមរា ៣- រោងភាពយន្ត គីម ស៊ីង ៤- រោងភាពយន្ត ចន្ទ្រារស្មី៥- រោងភាពយន្ត ឋានសួគ៌ ៦- រោងភាពយន្ត តារាថ្មី ៧- រោងភាពយន្ត ប៊ីហ្សូ ៨- រោងភាពយន្ត ប្រាសាទពេជ្រ៩- រោងភាពយន្ត ភ្នំពេញ ១០- រោងភាពយន្ត មនោរម្យ ១១- រោងភាពយន្ត មេគង្គ ១២- រោងភាពយន្ត លុច្ស ១៣- រោងភាពយន្ត វិមានសួស្ដី ១៤- រោងភាពយន្ត កាពីតូល ១៥- រោង

[7] ឃីង ហុកឌី៖ អក្សរសិល្ប៍ខ្មែរ សតវត្សទី២០ - ទំព័៥១

ភាពយន្ត សរព្រហ្មមាស ១៦- រោងភាពយន្ត ហាវ៉ៃ១៧- រោងភាពយន្ត អង្គរ ១៨- រោងភាពយន្ត អេឌែន ១៩- រោងភាពយន្ត ហេមជាតិ ២០- រោងភាពយន្ត សូរិយ៉ា ២១- រោងភាពយន្ត វើឌែន ២២- រោងភាពយន្ត វិមានទិព្វ ២៣- រោងភាពយន្ត ម្កុដពេជ្រ ២៤- រោងភាពយន្ត ម៉ាជេស្ទិក២៥- រោងភាពយន្ត ភ្នំពេជ្រ ២៦- រោងភាពយន្ត ព្រហ្មបាយន្ត័ ២៧- រោងភាពយន្ត ប្រាសាទមាស ២៨- រោងភាពយន្ត បូកគោ២៩- រោងភាពយន្ត ទ្រុងកុក ៣០- រោងភាពយន្ត តារា ៣១- រោងភាពយន្ត ចេនឡា ៣២- រោងភាពយន្ត គីមកុង ៣៣- រោងភាពយន្ត គីរីរម្យ ៣៤- រោងភាពយន្ត កំពូលពេជ្រ[៨]



ផ្ទាំងប៉ាណូ រឿងក្រែថោងក្រពើឆាប៉ារាន់

(ប្រភពពី Sabay)




រោងកុនលុច្ស លើផ្លូវនរោត្តម(ប្រភពពី Sabay)



រោងភាពយន្តខេមរៈ(ប្រភពពី Sabay)



រោងភាពយន្ត ភ្នំពេជ្រ (ប្រភពពី Sabay)

8 សារព័ត៌មានonline Sabay៖

https://entertainment.sabay.com.kh/article/1016301



រោងភាពយន្តហាវ៉ៃ(ប្រភពពី Sabay)

## ១.៩-អ្នកនិពន្ធសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)

បន្ទាប់ពីរបបសាធារណរដ្ឋបានដួលរលំទៅ របបអាវខ្មៅក៏ចាប់ផ្តើមគ្រួតត្រាប្រទេសកម្ពុជា។ តំណាក់កាលនោះគឺជាតំណាក់កាលដ៏ងងិតសូន្យសុង គ្រប់វិស័យទាំងអស់ធ្លាក់ដល់ចំនុចសូន្យ។ អ្នកប្រាជ្ញកវីនិពន្ធភាគច្រើនត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ចោល។ ដូច្នេះហើយ ពុំមានស្នាដៃរបស់អ្នកនិពន្ធឱ្យច្រើនបាននិពន្ធចេញទេ គឺមានតែចម្រៀងខ្មែរក្រហម ដែលលើកសរសើរពីអង្គការ កុំឱ្យប្រជាជនក្បត់អង្គការ ឱ្យមានសាមគ្គីគ្នាបង្កើនផលរួមគ្នាជាដើម។ បើតាមអ្នកស្រី យឿន ដែលជាអ្នកចម្រៀងដ៏ល្បីនាសម័យខ្មែរក្រហមច្រៀងបំពេរចៅប្រុសរបស់គាត់នោះមានចំណងជើងថា «សូមកូនៗកុំភ្លេចឈាមស្រស់របស់យុទ្ធមិត្តយើងឱ្យសោះ!»។ វាគឺជាចម្រៀងមួយក្នុងចំណោមចម្រៀងជាង ៣០០ បទ ដែលត្រូវបានប្រព័ន្ធឃោសនាការនាសម័យប៉ុលពត (១៧ មេសា ១៩៧៥ ដល់ ៧ មករា ១៩៧៩) បានរៀបចំនិពន្ធចងក្រងនិងផលិតឡើងជាកាសែតម៉ាញ៉េ សម្រាប់យកទៅចាក់ផ្សាយនៅតាមការដ្ឋានជីកប្រឡាយ លើកទំនប់ និងនៅតាមវាលស្រែនៅទូទាំងប្រទេសកម្ពុជាក្នុងសម័យកាលនោះ ដែលមនុស្សក្មេងចាស់ ប្រុសស្រី ត្រូវបានបង្ខំឱ្យធ្វើការដូចជាសត្វធាតុ។

បច្ចុប្បន្ន បទចម្រៀងក្នុងសម័យខ្មែរក្រហមទាំងអស់ ជាពិសេសបទចម្រៀងខាងលើនេះ មានមនុស្សតិចណាស់ ដែលបានស្តាប់ឮ និងឃើញម្ចាស់សំនៀងដើមរបស់វាដោយផ្ទាល់ភ្នែក ហើយក៏មិនដឹងថា អ្នកច្រៀងបទចម្រៀងមួយនេះមានឈ្មោះអ្វីនោះដែរ។ មនុស្សមួយចំនួនបានស្តាប់វាតាមរយៈការទស្សនាភាពយន្តឯកសារនៅក្នុងកម្មវិធីផ្សព្វផ្សាយអប់រំ ស្តីពីការស្វែងយល់ពីរបបកម្ពុជាប្រជាធិបតេយ្យដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្លះទៀតបានស្តាប់វាតាមប្រព័ន្ធ YouTube ឬនៅតាមហាងកាហ្វេមួយចំនួននៅក្នុងរាជធានីភ្នំពេញ[9]

[9] Fresh News៖https://www.postkhmer.com/national/2022-08-09-1040-239564.html



អ្នកស្រី សាន យឿន អតីតអ្នកចម្រៀងជំនាន់ខ្មែរក្រហមដែលនៅមានជីវិត។

គេបានស្តាប់តែស្នាដៃអក្សរសិល្ប៍ជាចម្រៀងខ្មែរក្រហមប៉ុណ្ណោះ។ តែទាក់ទងនឹងសៀវភៅ គឺមិនមាននោះទេ។

**១.៦-អ្នកនិពន្ធសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-៩១)**

នៅពេលដែលរបបខ្មែរក្រហមបានដួលរលំទៅ។ បណ្ឌិត បញ្ញាវន្ត កវី អ្នកនិពន្ធ អ្នកចេះដឹងខ្មែរជាច្រើនត្រូវបានសម្លាប់។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិត ក៏ចាប់ផ្តើមគិតគូនិងលើកស្ទួយវិស័យអក្សរសាស្ត្រ សិល្បៈឡើងវិញ បានប្រមែប្រមូល ធនធានមនុស្សដែលសល់ពីស្លាប់ឱ្យមកជួយលើកស្ទួយវិស័យអក្សរសាស្ត្រឡើងវិញ។

នៅសម័យនោះ អក្សរសិល្ប៍បានមានទំនោរទៅលើនយោបាយគ្រប់ស្នាដៃតែងនិពន្ធទាំងអស់ត្រូវតែមាននិន្នាការប្រឆាំងនឹងរបបប៉ុល ពត ប្រឆាំងចក្រពត្តិនិយម អនុត្តរភាពនិងពួកមូលធននិយម ដែលជាសារអំពាវនាវកុំឱ្យប្រជាជនចាញ់កលឧបាយពួកបច្ចាមិត្រ។

គ្រានោះហើយ ដែលមានអ្នកនិពន្ធល្បីៗមួយចំនួនសល់ពីស្លាប់ពីរបប អាវខ្មៅ ដូចជាលោកគង្គ ប៊ុនឈឿន លោក យូ បូ (ប្រធានសមាគមអ្នកនិពន្ធខ្មែរ ឆ្នាំ១៩៩៨-២០០៣) លោក ម៉ៅ អាយុទ្ធ លោកទី ជីហួត លោក ម៉ាឡៅពី កវីដ៏ល្បីសម័យលោក ស៊ិន ស៊ីសាមុត លោកទើបនឹងលាចាកលោកនេះទៅក្នុងឆ្នាំ១៩៩៧ បាននាំគ្នា លើកស្ទួយវិស័យអក្សរសាស្ត្រ ចម្រៀង និងការតែងនិពន្ធឡើងវិញ។

ចម្រៀងស្ទើរតែទាំងអស់មិនបង្ហាញពីស្នេហាស្រីប្រុសទេ តែបង្ហាញពីទឹកចិត្តមោះមុត ប្តេជ្ញាប្រឆាំងនឹងពួកបច្ចាមិត្រ និងលើកទឹកចិត្តប្រជាជន កុំឱ្យចាញ់បោកខ្មាំង។

ប្រលោមលោក មេឃបាត់ដួងចន្ទ និងវិលរកទ្រនំ របស់លោកទី ជីហួត គឺជាស្នាដៃដ៏លេចធ្លាជាងគេក្នុងសម័យ។ លោក ទី ជីហួត គឺជាអ្នកនិពន្ធដ៏ល្បី ទឹកដៃក្នុងការនិពន្ធរបស់លោក ត្រូវបានទទួលការកោតសរសើរពីបណ្ឌិត បញ្ញាវន្តក្នុងវិស័យអក្សរសិល្ប៍។ លោក មិនត្រឹមនិពន្ធប្រលោមលោកប៉ុណ្ណោះទេ លោកថែមទាំងនិពន្ធរឿងល្ខោនយីកេ ដូចជារឿង បុរសបេះដូងមាស រឿងក្បួនជីត រឿងល្ខោនបាសាក់ដូចជារឿង ព្រលឹងបន្ទាយស្រី តេជោយ៉ត ជាដើម។ រឿងរបស់លោកត្រូវបានផ្សាយតាមវិទ្យុជាតិ ហើយបានទទួលការ

ពេញនិយម និងគាំទ្រពីមហាជនខ្មែរគ្រប់ស្រទាប់វណ្ណៈ។

ឯលោក គង្គ ប៊ុនឈឿន ក៏បាននិពន្ធចម្រៀង និងប្រលោមលោកមួយចំនួនដែរ។ ស្នាដៃដ៏ល្បីល្បាញរបស់លោកសម័យនោះដូចជារឿងរំដួលឯកភ្នំជាដើម។

## ១.៦-អ្នកនិពន្ធសម័យរាជាណាចក្រទី២ ១៩៩១ ដល់បច្ចុប្បន្ន

ក្រោយឆ្នាំ១៩៩៣ នៅពេលរបត់នយោបាយមានការផ្លាស់ប្តូរមកជារបបរាជានិយមវិញ។ យើងឃើញថា វិស័យតែងនិពន្ធអក្សរសិល្ប៍ ហាក់មានសន្ទុះរីកចម្រើនខ្លាំងគួរឱ្យកត់សម្គាល់ ដោយអ្នកនិពន្ធមានសេរីភាពឡើងវិញក្នុងការតែងនិពន្ធទៅតាមជំនក់និងទំនោររបស់ខ្លួន។ ឯវិស័យបោះពុម្ពផ្សាយក៏ឃើញថា មានរោងពុម្ពជាច្រើនកើតឡើងព្រោងព្រៀត ទទួលយកស្នាដៃអ្នកនិពន្ធដែលផលិតថ្មីៗ មកបោះពុម្ពលក់ និងស្រាវជ្រាវរកស្នាដៃរឿងប្រលោមលោកចាស់ៗ មកបោះពុម្ពឡើងវិញ។ ឯវិស័យចម្រៀងវិញ ក៏ឃើញថាមានការរីកចម្រើន ខ្លាំងក្លាណាស់ដែរ។ ដោយមានបទចាស់ៗកាលពីជំនាន់ដើម ត្រូវបើកទូលលាយឱ្យមហាជនស្តាប់ ឯបទថ្មីៗ បំពេរអារម្មណ៍គ្រប់រសជាតិ ក៏ចាប់ផ្តើមផលិតជាហូរហែរ ក្នុងនោះដែរ គេឃើញមានផលិតកម្មចម្រៀងជាច្រើនបានកើតឡើង ផលិតកម្មខ្លះនៅក្នុងស្រុក ខ្លះនៅក្រៅស្រុក ក្នុងនោះ ផលិតកម្មដែលល្បីល្បាញជាងគេ គឺផលិតកម្មរស្មីហង្សមាស ផលិតកម្មព្រះវិហារ ផលិតកម្មឆ្លងដែន ផលិតកម្មតោមាស ផលិតកម្ម វិមាស ផលិតកម្មអង្គរវត្ត ផលិតកម្មរស្មីស្ទឹងសែន និងផលិតកម្ម រស្មីស្ទឹងសង្កែជាដើម...។ល។ នៅឆ្នាំ ១៩៩៣ សមាគមអ្នកនិពន្ធខ្មែរ ក៏ចាប់ផ្តើមរៀបចំឡើងវិញដោយពេលនោះ មានលោក គង្គ ប៊ុនឈឿន ជាប្រធាន មានទីតាំងនៅវត្តឧណ្ណាឡោម ក្រោយមកដូរទៅវត្តបទុមវតី បន្ទាប់មកឯកឧត្តម ជ័យ ចាប ជាប្រធាន។ ខាងក្រោមនេះជាប្រវត្តិខ្លះៗនៃសមាគមអ្នកនិពន្ធខ្មែរ៖

តាមព្រះរាជក្រិត្យលេខ២៤៥បរ. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៦១ បានកំណត់យ៉ាងច្បាស់ថាសមាគមអ្នកនិពន្ធខ្មែរ ត្រូវចាត់ទុកជាសមាគមមានប្រយោជន៍សាធារណៈ ហើយដោយហេតុនេះអាចទទួលសទ្ធាទានពីប្រជាពលរដ្ឋទូទៅបាន។ នៅមុនឆ្នាំ១៩៧០ សមាគមអ្នកនិពន្ធខ្មែរ មានប្រធានចំនួន ៣រូប ដែលសុទ្ធតែបានជ្រើសតាំងឡើងដោយការបោះឆ្នោតសម្ងាត់។ ប្រធានទាំង៣រូបនោះមាន៖

- លោក រីម គីន ប្រធាន (១៩៥៥-១៩៥៦)
- លោក ហ៊ែល ស៊ុផា ប្រធាន (១៩៥៧-១៩៦៤)
- លោក ទ្រឹញ វ៉ាញ ប្រធាន (១៩៦៤-១៩៦៩)

នៅមុនឆ្នាំ១៩៧០-១៩៧៥ សមាគមអ្នកនិពន្ធខ្មែរ មានប្រធានចំនួន២រូប

• លោក លាង ហាប់អាន ប្រធាន (១៩៥៥-១៩៥៦)

• លោក ម៉ា ឡាយខេម ប្រធាន (១៩៥៧-១៩៦៤)

នៅក្រោយឆ្នាំ១៩៩៣ សមាគមអ្នកនិពន្ធខ្មែរ មានប្រធានចំនួន ៤រូប

• លោក យូ បូ ប្រធាន (១៩៩៣-១៩៩៦)

• ឯកឧត្តម ជ័យ ចាប ប្រធាន (១៩៩៦-១៩៩៨)

• លោក យូ បូ ប្រធាន (១៩៩៨-២០០៣)

• ឯកឧត្តម ស៊ីម វណ្ណ ប្រធាន (២០០៣ ដល់ថ្ងៃទី២៤ ធ្នូ ២០១៧)

• ឯកឧត្តម ព្រឿង ប្រណីត ប្រធាន (ថ្ងៃទី២៤ ធ្នូ ២០១៧ – បច្ចុប្បន្ន)[10]។

នៅពេលសមាគមអ្នកនិពន្ធខ្មែរ ចាប់ផ្ដើមកកើតឡើងវិញ ក៏បើកវគ្គបណ្ដុះបណ្ដាលអ្នកនិពន្ធ បានច្រើនជំនាន់ រហូតមកដល់បច្ចុប្បន្ន វគ្គបណ្ដុះបណ្ដាល បានរហូតដល់៣៤ វគ្គហើយ ហើយក៏មានសិក្ខាកាមជាច្រើន ដែលបានវគ្គតែងនិពន្ធនេះ បានក្លាយជាអ្នកនិពន្ធរឿងទាំងកំណាព្យ ប្រលោមលោក និងភាពយន្ត។ ពេលនោះក៏មានបង្កើតពានរង្វាន់ជាច្រើន ដូចជាពានរង្វាន់ព្រះសីហនុរាជ ពានរង្វាន់៧មករា ពានរង្វាន់ព្រះនាងឥន្ទ្រទេវី ពានរង្វាន់ព្រះសុរាម្រិត ពានរង្វាន់មហោស្រប អង្គរ...ជាដើម។ល។ ហើយក៏មានអ្នកនិពន្ធនិងកវីថ្មីៗជាច្រើនបានកើតឡើង។ អ្នកនិពន្ធដើមចាស់ ដូចជា លោក គង្គ ប៊ុនឈឿន អ្នកស្រី ម៉ៅ សំណាង (អ្នកនិពន្ធទន្សាយ) អ្នកស្រី ប៉ាល វណ្ណារីរក្ស លោក អ៊ុន សុខហ៊ាង លោក វ៉ា សំអាត លោក គឹម ពេជ្រពីរនន់ លោក សុខ សុធន លោកស្រី ប៉ុល ពិសី ....ជាដើម នៅតែបន្តបញ្ចេញស្នាដៃរបស់ពួកគេ លក់នៅលើទីផ្សារជាហូរហែរ។

ចំណែកឯពន្ធកអ្នកនិពន្ធថ្មី ដែលកើតឡើង អំឡុងឆ្នាំ ១៩៩៨ រហូតដល់២០១០ ដែលចាត់ទុកថាឈ្មោះ លេចធ្លោក្នុងសង្គមអ្នកនិពន្ធនោះ មាន លោក នេត ចំរើន លោក សំ សុភារិទ្ធ លោក ស៊ូ ខេមរិទ្ធ លោក ទី ធារី លោក សុខ ចាន់ផល លោក ឃុត សុខឿន លោក យូ សុភា... និងអ្នកនិពន្ធខ្លះទៀត ដែលមិនបានរៀបរាប់ឈ្មោះអស់បានបញ្ចេញស្នាដៃ ដោយបានបោះពុម្ពជាសៀវភៅលក់ផងដែរ។ ក្នុងសម័យចុងទសវត្សទី៩០ នៃសតវត្សទី២០និងដើមសហវត្សទី២១នេះវិស័យចម្រៀង និងភាពយន្ត ក៏ចាប់ផ្ដើមទទួលការពេញនិយមពីមហាជនផងដែរ។ផលិតកម្មចម្រៀងជាច្រើន បានកើតឡើង ឯកវីដែលល្បីល្បាញក្នុងជំនាន់នោះ ដែលគេនៅតែចងចាំឈ្មោះ រហូតដល់សព្វថ្ងៃនេះ មានលោក

[10] សារព័ត៌មានSBN ៖

https://sbm.news/articles/6051a7ce7c81ee7fa937fd0d

ជុំ ប៊ុនធឿន (ស្លាប់) លោកជាកវីនិពន្ធម្នាក់ដ៏ល្បីល្បាញ  លោក ហៃ្វ សំអាង (កវី និងអ្នកដឹកនាំរឿងដ៏ល្បី) លោក សុខ ជំនោរ អ្នកនិពន្ធទំនុកច្រៀង លោក អៀប ជាម៉េង (អ្នកនិពន្ធទំនុកច្រៀង និងដឹកនាំផលិត) លោក ខាំ គូរិ (អ្នកនិពន្ធទំនុកច្រៀង និងដឹកនាំផលិត) លោក កៅ សីហា ( អ្នកនិពន្ធ ក្រោយមកលោកបានអភិវឌ្ឍន៍ជាអ្នកដឹកនាំផលិត) លោក ម៉ៃ វឌ្ឍនា (កវីនិពន្ធ ដែលមានទឹកដៃប្រហាក់ប្រហែលដូចកវី សេកមាសម៉ា ឡៅពី ដែលមានទំនោរនិពន្ធបទចម្រៀងថ្មីៗ បែបមរតកដើម។

ក្នុងអំឡុងដើមសហវត្សនោះ បណ្ដាស្ថានីយ៍ទូរទស្សនានា ក៏ចាប់ផ្ដើមផលិតរឿងភាគ បញ្ចាំងតាមប៉ុស្តិ៍របស់ខ្លួនផងដែរ ដូចជាស្ថានីយ៍ទូរទស្សន៍ប៉ុស្តិ៍លេខ៥ ស្ថានីយ៍ទូរទស្សន៍ CTN ស្ថានីយ៍ទូរទស្សន៍ ប៉ុស្តិ៍លេខ៣ ជាដើម ហើយអ្នកនិពន្ធដែលល្បីល្បាញក្នុងការតែងនិពន្ធរឿងភាគតាមស្ថានីយ៍ទូរទស្សន៍ជាងគេ គឺ លោកស្រី ពាន់ ភួងបុប្ផា (អតីតប្រធានមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា) លោកស្រីបាននិពន្ធរឿងភាគជាច្រើនបញ្ចាំងនៅស្ថានីយ៍ទូរទស្សន៍CTN។ តែក្នុងសម័យកាលនោះ ក៏មានអ្នកនិពន្ធភាពយន្តជាច្រើនផងដែរ ដូចជាលោកស្រី ម៉ៅ សំណាង លោកស្រី ប៉ាល់ វណ្ណារីរក្សជាដើម។

ក្នុងសម័យកាលនោះ ក៏មានសមាគមអ្នកនិពន្ធខ្មែរ នៅប្រទេសបារាំង ក៏បានរៀបចំការប្រកួតប្រជែងស្នាដៃតែងនិពន្ធ យ៉ាងសកម្មផងដែរ ដូចជាពានរង្វាន់អក្សរសិល្ប៍សន្តិភាព ហើយក៏មានអ្នកនិពន្ធជាច្រើន បានជាប់ជ័យលាភីផងដែរ។

ក្រោយមកទៀត ក៏មានសមាគមអ្នកសារព្រះ បានរៀបចំប្រឡងពានរង្វាន់អក្សរសិល្ប៍ជារឿងខ្លីជារៀងរាល់ឆ្នាំផងដែរ គិតចាប់ពីឆ្នាំ

តែទោះយ៉ាងណាក៏ដោយ លំហូរនៃបទចម្រៀងបរទេស និងរឿងភាពយន្តបរទេស បានហូរចូលយ៉ាង គគ្រឹកគគ្រេងក្នុងប្រទេសខ្មែរ ហើយដោយមិនទាន់មានច្បាប់កម្មសិទ្ធិបញ្ញានៅឡើយ បទចម្រៀងដែលនិពន្ធថ្មីៗភាគច្រើន គឺយកបទភ្លេងបរទេសមកទាំងស្រុងដោយគ្រាន់តែសរសេរទំនុកច្រៀងថ្មីប៉ុណ្ណោះ។

## ២.ស្ថានភាពអ្នកនិពន្ធខ្មែរនាពេលបច្ចុប្បន្ន

ទោះបីជាបច្ចុប្បន្ន មានពន្លកអ្នកនិពន្ធជាច្រើនបានរីកដុះដាល ជាទីសង្ឃឹមនៃវិស័យអក្សរសាស្ត្រជាតិក៏ពិតមែន។ តែស្ថានភាពនៃការផលិតស្នាដៃមានចំនួនតិចតួចមែនទែន បើប្រៀបធៀបទៅនឹងសម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋ លន់ នល់។ តើកត្តាអ្វីខ្លះ ជាឧបសគ្គដែលបណ្ដាលឱ្យអ្នកនិពន្ធខ្មែរបច្ចុប្បន្ន មិនសូវបញ្ចេញស្នាដៃរបស់ខ្លួនបាន?

## ២.១-ការធ្លាក់ចុះនូវកម្រិតនៃការអានសៀវភៅ

គេបានដឹងថា ប្រជាជនខ្មែរ តាំងពីដើមមកមែនជាជនជាតិ ដែលមានចំណូលចិត្តអានសៀវភៅច្រើននោះទេ។ កាលជំនាន់ដើម វិស័យប្រលោមលោក មានការរីកចម្រើន អ្នកនិពន្ធសម្រុកបោះពុម្ពសៀវភៅលក់ ព្រោះអាចចិញ្ចឹមជីវភាពគ្រួសារបាន ឯរោងពុម្ពក៏មានច្រើន។ ទាក់ទិននឹងមូលហេតុ ដែលសម័យនោះ មហាជនចូលចិត្តអានសៀវភៅនោះក៏ព្រោះតែវិស័យសោតទស្សន៍មិនទាន់រីកចម្រើន គ្មានទូរទស្សន៍មើល មិនសម្បូរវិទ្យុ គឺមានតែវិទ្យុជាតិមួយ ដែលមហាជនស្តាប់ព្រឹកល្ងាចគ្មានប្រព័ន្ធអ៊ិនធឺណែតគ្មានបណ្តាញសង្គម (Social Media) គ្មានទូរស័ព្ទSmart Phone ទំនើបដូចបច្ចុប្បន្ន។ ដូច្នេះ មានតែកាសែត ឬសៀវភៅប្រលោមលោកទេ ដែលអាចកំដរអារម្មណ៍របស់ពួកគេបាន។ ដូច្នេះ រោងពុម្ពជាច្រើន បានប្រកបរបរបោះពុម្ពសៀវភៅលក់ ដោយទិញសិទ្ធិ ឬចែកភាគលាភជាមួយអ្នកនិពន្ធ។

តែមកដល់សម័យបច្ចុប្បន្ន រោងពុម្ពនានា គេមិនទទួលទិញសៀវភៅប្រលោមលោកដើម្បីបោះពុម្ពលក់បន្តទៀតទេ ព្រោះថា មិនសូវលក់ដាច់។ ដូច្នេះហើយ ទើបអ្នកនិពន្ធជាច្រើន មិនអាចបោះពុម្ពស្នាដៃរបស់ខ្លួនបាន។

លោក រ៉ា សំអាត អតីតអនុប្រធានសមាគមអ្នកនិពន្ធខ្មែរ បានសម្ភាសន៍ជាមួយវិទ្យុសំឡេងសហរដ្ឋអាមេរិក កាលពីថ្ងៃទី ១៤ ខែកក្កដា ២០១៤ ដោយលោកមានប្រសាសន៍ថា ទម្លាប់មិនចូលចិត្តអានសៀវភៅរបស់ប្រជាពលរដ្ឋខ្មែរ និង បច្ចេកវិទ្យារីកចម្រើន ជាកត្តានាំឱ្យធ្លាក់ចុះការអានអក្សរសិល្ប៍។[11]



លោក រ៉ា សំអាត ៖ អតីតអនុប្រធានសមាគមអ្នកនិពន្ធខ្មែរ



អ្នកនិពន្ធ៖ រ៉ា សំអាត

## ២.២-ការរីកចម្រើននៃវិស័យបច្ចេកវិទ្យា

ការរីកចម្រើន នៃវិស័យបច្ចេកវិទ្យា ដែលមានបណ្តាញសង្គមជាច្រើន ដូចជា

11 https://khmer.voanews.com/a/2396606.html

Facebook, Tik Tok, Instagram, Telegram, YouTube...គឺជាចំណែកមួយ ដែលនាំឱ្យការអាន សៀវភៅមានការធ្លាក់ចុះៗ នៅលើបណ្តាញសង្គម មានអត្ថបទ វីដេអូសម្បូរបែបជាទីកម្សាន្ត ដែលមានត្រឹមតែមួយ ឬពីរកថាខណ្ឌ ដែលបានបង្ហោះ ងាយស្រួលអាន វាខុសប្លែកពីសៀវភៅ ដែលមានរាប់រយទំព័រៗ ឥឡូវនេះ សូម្បី តែសៀវភៅមួយចំនួន ក៏ត្រូវបានបម្លែងជាសំឡេង យកមកបង្ហោះ ព្រោងព្រាត់តាម Facebook និង Youtube របស់ពួក MMO ក្នុងបំណងរកប្រាក់ៗ ដូច្នេះអ្វីដែលងាយស្រួលទាំងនេះហើយ គឺជាកត្តាដែលនាំឱ្យមនុស្សខ្ជិលអាន ហើយជំរុញអ្នកនិពន្ធរឿងប្រលោមលោក មួយចំនួនឱ្យបោះបង់អាជីពខ្លួនទៅប្រកបការងារផ្សេងដើម្បីចិញ្ចឹមក្រពះៗ

## ២.៣-ច្បាប់កម្មសិទ្ធិបញ្ញារបស់អ្នកនិពន្ធ មិនទាន់ប្រសូត្រ

បើទោះបីច្បាប់ស្តីពីកម្មសិទ្ធបញ្ញា និងសិទ្ធិប្រហាក់ប្រហែលរបស់អ្នកនិពន្ធ ត្រូវបានអនុម័តរួចរាល់ដោយរដ្ឋសភាជាតិ តាំងពីឆ្នាំ ២០០៣ ក៏ពិតមែនៗ តែការអនុវត្តន៍ច្បាប់នេះនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយៗ

ដូច្នេះហើយទើបបញ្ហានៃការលួចស្នាដៃ ឬលួចចម្លង គឺជាបញ្ហាដ៏ធំបំផុត ដែលនាំឱ្យអ្នកនិពន្ធ ដែលខិតខំនិពន្ធ ប្រែជាបាក់ទឹកចិត្ត ព្រោះតែស្នាដៃខ្លួនខិតខំសរសេររាប់ឆ្នាំ រាប់ខែ បែរជាត្រូវគេលួចចម្លងយកទៅធ្វើអាជីវកម្មដោយទទេៗ

នេះក៏ជាកត្តាមួយ ដែលជំរុញឱ្យស្ថានភាពអ្នកនិពន្ធខ្មែរ ធ្លាក់ទឹកចិត្ត ក្នុងការផលិតស្នាដៃៗ

## តើអ្វីទៅជា "សិទ្ធិអ្នកនិពន្ធ"?

សិទ្ធិអ្នកនិពន្ធ (ការរក្សាសិទ្ធិ) គឺជាមែកធាងមួយនៃកម្មសិទ្ធិបញ្ញាៗ "កម្មសិទ្ធិបញ្ញា" (កម្មសិទ្ធិ+បញ្ញា) គឺជាសិទ្ធិរបស់បុគ្គលណាមួយ (ទោះជារូបវ័ន្តបុគ្គលក៏ដោយ ឬជានីតិបុគ្គលក៏ដោយ) ជាម្ចាស់កម្មសិទ្ធិផ្តាច់មុខទៅលើស្នាដៃ ឬក៏អ្វីផ្សេងទៀត ដែលជាផលផ្លែកើតចេញពីគំនិត-បញ្ញារបស់ខ្លួនៗ "កម្មសិទ្ធិបញ្ញា" ត្រូវចែកចេញជាពីរផ្នែកធំៗ៖

### ក-កម្មសិទ្ធិឧស្សាហកម្ម៖

ដូចជា រូបគំនូរឧស្សាហកម្ម, សញ្ញាពាណិជ្ជកម្ម, ការរកឃើញ ឬការច្នៃប្រឌិតអ្វីមួយ (តក្កកម្ម) ដូចជា ការរកឃើញផលិតផលអ្វីមួយ ឬក៏ដំណើការផលិតកម្មណាមួយៗលៗ នៅកម្ពុជា សិទ្ធិទាំងនេះ ត្រូវបានការពារដោយច្បាប់ ស្តីពី ប្រកាសនីយបត្រតក្កកម្ម, វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលសភាអនុម័ត កាលពីឆ្នាំ២០០២ៗ

### ខ-សិទ្ធិអ្នកនិពន្ធ៖

គឺសំដៅលើស្នាដៃខាងផ្នែកអក្សរសាស្ត្រ, វិទ្យាសាស្ត្រ, សិល្បៈ, តូរ្យតន្ត្រី ដែលកើតចេញពីការច្នៃប្រឌិត បង្កើតឡើងដោយគំនិតប្រាជ្ញា

ឬដោយមនោសញ្ចេតនា។ ស្នាដៃទាំងអស់នេះទទួលបានការការពារពីច្បាប់ ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដែលសភាអនុម័តកាលពីឆ្នាំ២០០៣។ ដើម្បីឲ្យស្នាដៃមួយទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធតើត្រូវគោរពតាមលក្ខខណ្ឌអ្វីខ្លះ? ដើម្បីឲ្យស្នាដៃមួយអាចទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធ ស្នាដៃនោះត្រូវតែមានទម្រង់ណាមួយជាក់លាក់ មិនមែន នៅជាគំនិតអរូបី។ គំនិត ដែលស្ថិតនៅជាលក្ខណៈអរូបិយគេមិនអាចការពារបានទេ។ គេការពារបានលុះត្រាតែគំនិតនោះ ត្រូវបញ្ចេញមកខាងក្រៅ ក្នុងទ្រង់ទ្រាយណាមួយជាក់លាក់ ដែលតាមច្បាប់ គេឲ្យឈ្មោះថា "ស្នាដៃ" ដូចជា៖

ការនិពន្ធ៖ សៀវភៅ, បទភ្លេង, ចម្រៀង, ប្រលោមលោក, ភាពយន្តការសម្ដែង៖ ការសម្ដែងរបាំ ឬការប្រគំតន្ត្រីការផ្សាយជាសំឡេង, រូបភាព ឬឯកសារនានា តាមវិទ្យុ ឬទូរទស្សន៍។ល។

យោងតាមមាត្រា៣ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ គឺស្នាដៃទាំងនេះហើយ ដែលទទួលបានការការពារពីច្បាប់។លក្ខខណ្ឌទី២ ស្នាដៃដែលទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធ ត្រូវតែជាស្នាដៃដើម ពោលគឺជាស្នាដៃដែលបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធមិនមែនធ្វើតាមគេ។ជាឧទាហរណ៍ជាក់ស្ដែង តើស្នាដៃអ្វីខ្លះ ដែលទទួលបានការការពារពីច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ?

ចំណុចនេះ គឺមានចែងក្នុងមាត្រា ៣ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ៖

សៀវភៅអានគ្រប់ប្រភេទ ឬក៏ឯកសារផ្សេងៗទៀត ស្ដីពីអក្សរសាស្ត្រ, សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំអត្ថបទបកថា សន្ទថា ឬធម្មទេសនាការតែងទំនុកច្រៀង, បទភ្លេង ការសម្ដែងរបាំ, ការសម្ដែងសៀក ឬការសម្ដែងកាយវិការស្នាដៃជាផ្ទាំងគំនូរ, រូបចម្លាក់, រូបថត, ផែនទី, ប្លង់ស្ថាបត្យកម្មកម្មវិធីកុំព្យូទ័រផលិតផលសិប្បកម្ម ដូចជា តម្បាញ ឬក៏ម៉ូដសម្លៀកបំពាក់ ។ល។ និង។ល។ស្នាដៃមួយដើម្បីទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធតើគេត្រូវធ្វើការចុះបញ្ជីអ្វីដែរឬទេ?សិទ្ធិអ្នកនិពន្ធ មិនតម្រូវឲ្យមានការចុះបញ្ជីអ្វីទេ។ ឲ្យតែស្នាដៃនោះ កើតឡើងចេញជាទម្រង់ជាក់លាក់ណាមួយ ហើយជាស្នាដៃដើមរបស់អ្នកនិពន្ធ គឺអាចទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធ។

យោងតាមមាត្រា៩ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ ឆ្នាំ២០០៣ ចែងថា ស្នាដៃមួយទោះបីពុំទាន់ចប់សព្វគ្រប់ក្ដី ឬពុំទាន់បានផ្សព្វផ្សាយជាសាធារណៈក្ដី ស្នាដៃនោះ ត្រូវចាត់ទុកថាបានបង្កើតឡើងដោយចំណេះដឹងពិតប្រាកដតែមួយគត់ពីគំនិតប្រាជ្ញាអ្នកនិពន្ធដែរ ពោលគឺ ត្រូវទទួលបានការការពារពីសិទ្ធិអ្នកនិពន្ធដែរ។ដូច្នេះ ចំពោះសិទ្ធិអ្នកនិពន្ធច្បាប់មិនតម្រូវឲ្យមានការចុះបញ្ជីអ្វីទេ។ ក៏ប៉ុន្តែការយកស្នាដៃទៅចុះបញ្ជី នៅស្ថាប័ន

មានសមត្ថកិច្ច គឺវាមានប្រយោជន៍ដល់ម្ចាស់ស្នាដៃ ព្រោះថា ការចុះបញ្ជី គឺជាភស្តុតាងបញ្ជាក់អំពីកម្មសិទ្ធិលើស្នាដៃ។

*តើសិទ្ធិអ្វីខ្លះ ដែលត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ?*

យោងតាមច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ ត្រង់មាត្រា១៨៖ អ្នកនិពន្ធស្នាដៃ គឺជាម្ចាស់កម្មសិទ្ធិផ្តាច់មុខលើស្នាដៃនោះ ហើយជាសិទ្ធិដែលជនគ្រប់រូបត្រូវតែទទួលស្គាល់។សិទ្ធិនេះបែងចែកចេញជាពីរ៖

### សិទ្ធិសីលធម៌

- សិទ្ធិសម្រេចអំពីទម្រង់ និងពេលវេលា នៃការផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ
- សិទ្ធិតម្រូវឲ្យគេដាក់ឈ្មោះ និងឋានៈ សម្រាប់ទាក់ទងជាមួយសាធារណជន
- សិទ្ធិធ្វើការជំទាស់នូវគ្រប់រូបភាពនៃការបំផ្លើស ឬការកែប្រែខ្លឹមសារ ក្នុងស្នាដៃរបស់ខ្លួន ដែលជាហេតុធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ អ្នកនិពន្ធ
- សិទ្ធិបេតិកភណ្ឌ គឺសិទ្ធិប្រកបអាជីវកម្មលើទ្រព្យ ដែលជាស្នាដៃរបស់ខ្លួន តាមរយៈការបោះផ្សាយជាសាធារណៈ ឬក៏តាមរយៈការបង្កើតស្នាដៃបន្ត។ យោងតាមមាត្រា២១ នៃច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ អ្នកនិពន្ធមានសិទ្ធិផ្តាច់មុខ ធ្វើដោយខ្លួនឯង ឬក៏អនុញ្ញាតឲ្យគេធ្វើបន្ត នូវកិច្ចការដូចតទៅ៖
- ចែកចាយជាសាធារណៈ តាមការលក់ ការជួល ឬតាមមធ្យោបាយផ្សេងទៀត នូវច្បាប់ដើម ឬច្បាប់ចម្លងការបកប្រែជាភាសាបរទេសការយកលំនាំតាម ឬការកែសម្រួលផ្សេងៗទៀត ដូចជា ការយករឿងប្រលោមលោក និពន្ធជាសៀវភៅ ទៅធ្វើជាខ្សែភាពយន្តការផលិតស្នាដៃឡើងវិញ ដូចជា ការយកសៀវភៅទៅបោះពុម្ពឡើងវិញ ឬក៏យកខ្លឹមសារទៅផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ។ល។ និង។ល។

សូមបញ្ជាក់ថា ទាំងនេះ គឺជាសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធ មានន័យថា មានតែអ្នកនិពន្ធទេ ដែលអាចធ្វើការទាំងអស់នេះបាន។ គ្មានអ្នកណាផ្សេងអាចធ្វើបានទេ លុះត្រាតែមានការអនុញ្ញាតពីអ្នកនិពន្ធ។

*តើសិទ្ធិអ្នកនិពន្ធ ទទួលបាននូវការការពារពីច្បាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំ?*

បើនិយាយអំពីសិទ្ធិសីលធម៌ គឺមានលក្ខណៈអចិន្ត្រៃយ៍ (មាត្រា ១៩ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ)។

បើនិយាយអំពីសិទ្ធិបេតិកភណ្ឌវិញ មានន័យថា សិទ្ធិផ្តាច់មុខក្នុងការប្រកបអាជីវកម្មលើស្នាដៃ គឺទទួលបានការការពារពេញ

មួយជីវិតរបស់អ្នកនិពន្ធ បូកថែម៥០ឆ្នាំ ក្រោយពីអ្នកនិពន្ធទទួលមរណភាពទៀត (មាត្រា ៣០ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ)។ ផុតពីរយៈពេលនេះទៅ ស្នាដៃត្រូវក្លាយជាសម្បត្តិសាធារណៈ ដែលសាធារណជនទូទៅអាចយកទៅប្រើប្រាស់បាន។តើស្នាដៃ ចាំបាច់ត្រូវតែមានដាក់សញ្ញា "©រក្សាសិទ្ធិ" ទើបទទួលបានការការពារសិទ្ធិអ្នកនិពន្ធឬយ៉ាងណា? តាមច្បាប់ នៅប្រទេសខ្លះ គេតម្រូវឲ្យដាក់សញ្ញា "©រក្សាសិទ្ធិ" លើស្នាដៃណាមួយ ទើបអាចទទួលបានការការពារសិទ្ធិអ្នកនិពន្ធ។ ក៏ប៉ុន្តែ តាមច្បាប់ នៅកម្ពុជា ក៏ដូចជា ប្រទេសផ្សេងទៀត ដែលជាហត្ថលេខី នៃអនុសញ្ញាក្រុងប៊ែន (Berne) គេមិនតម្រូវឲ្យមានដាក់សញ្ញា "©រក្សាសិទ្ធិ"ទេ។ បើទោះជាស្នាដៃដែលគ្មានដាក់សញ្ញា "©រក្សាសិទ្ធិ" ក៏ទទួលបានការការពារដោយសិទ្ធិអ្នកនិពន្ធដែរ។

ក៏ប៉ុន្តែ សញ្ញា "រក្សាសិទ្ធ" មានប្រយោជន៍ក្នុងការជូនដំណឹងដល់សាធារណជនថា ស្នាដៃនេះ ស្ថិតក្រោមការរក្សាសិទ្ធិ។ ប្រសិនបើគ្មានសញ្ញា "©រក្សាសិទ្ធិ" វាអាចចោទជាបញ្ហា នៅពេលមានក្តីក្តាំ។ ចុងចោទគេអាចដោះសារថា គេមិនបានដឹង ដោយស្មានថាស្នាដៃនេះមិនមានរក្សាសិទ្ធិ។ ប្រសិនបើមានដាក់សញ្ញា "©រក្សាសិទ្ធិ" គេមិនអាចដោះសារថាមិនបានដឹងនោះទេ។

ការចម្លងឡើងវិញនូវស្នាដៃនិពន្ធមួយ ដើម្បីទុកប្រើប្រាស់ផ្ទាល់ខ្លួន ដោយមិនយកទៅធ្វើអាជីវកម្ម តើជាការរំលោភសិទ្ធិអ្នកនិពន្ធដែរឬទេ?

បើតាមច្បាប់ នៅប្រទេសខ្លះ (ដូចជា បារាំង ជាដើម) ការចម្លងស្នាដៃមួយ ដូចជា ចម្លងសៀវភៅជាដើម អាចធ្វើទៅបាន ទាល់តែការចម្លងនេះធ្វើឡើងតែមួយផ្នែកតូចមួយ។

ក៏ប៉ុន្តែ នៅកម្ពុជាវិញ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ត្រង់មាត្រា ២៤ ចែងថា ការផលិតឡើងវិញចំនួនមួយច្បាប់ ជាលក្ខណៈឯកជននូវស្នាដៃ ដែលបានបោះពុម្ពរួចហើយ ដើម្បីយកមកប្រើប្រាស់ផ្ទាល់ខ្លួន គឺអាចធ្វើទៅបាន ដោយមិនចាំបាច់មាន ការអនុញ្ញាតពីអ្នកនិពន្ធ ឡើយ។

ក៏ប៉ុន្តែការចម្លងយកទៅប្រើប្រាស់ផ្ទាល់ខ្លួននេះ មិនអាចធ្វើទៅបានទៅបានទេ ក្នុងករណីមួយចំនួន ដូចជា៖ការចម្លងកម្មវិធីកុំព្យូទ័រ ការចម្លងប្លង់ស្ថាបត្យកម្ម ការចម្លងចេញពីប្រព័ន្ធអ៊ីនធ័រណិតឬការចម្លង ឬការផលិតឡើងវិញ នូវស្នាដៃណាមួយ ដែលធ្វើឲ្យប៉ះពាល់ ដល់ការធ្វើអាជីវកម្មជាប្រក្រតីនៃស្នាដៃនោះឬធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់អ្នកនិពន្ធ។

ការដកស្រង់ខ្លឹមសារមួយផ្នែកនៃស្នាដៃមួយ ដើម្បីយកមកផ្សព្វផ្សាយ តើចាំបាច់ត្រូវសុំការអនុញ្ញាតពីអ្នកនិពន្ធដែរឬទេ? ការដកស្រង់ខ្លឹមសារនេះ អាចធ្វើទៅបាន ដោយមិនចាំបាច់សុំការអនុញ្ញាតពីអ្នកនិពន្ធទេ យោង

តាមមាត្រា២៨ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ។ ក៏ប៉ុន្តែ ត្រូវមានលក្ខខណ្ឌពីរៈ

ជាការដកស្រង់តែមួយផ្នែកខ្លីៗ មិនមែនដកស្រង់ទាំងស្រុងត្រូវមានការបញ្ជាក់យ៉ាងច្បាស់លាស់នូវឈ្មោះរបស់អ្នកនិពន្ធ និងប្រភពនៃស្នាដៃ។[12]

## ៣-សន្និដ្ឋាន

បន្ទាប់ពីបានស្រាវជ្រាវ ចងក្រង ពីប្រវត្តិអ្នកនិពន្ធ និងស្ថានភាពប្រឈមរួចមក យើងឃើញថា។ ប្រទេសកម្ពុជាយើង ជាប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់តាំងពីបុរាណកាលមក ហើយបានបន្សល់ស្នាដៃរាប់មិនអស់ ដូចអ្វី ដែលបានសរសេរនៅក្នុងអត្ថបទនេះទាំងមូល។

តែអ្វីដែលជាបញ្ហាប្រឈមខ្លាំងបំផុតនាពេលបច្ចុប្បន្ននេះ គឺអ្នកនិពន្ធយើងកំពុងជួបប្រទះផលវិបាកជាច្រើនក្នុងការបញ្ចេញស្នាដៃ ហើយទាមទារឱ្យមានការយកចិត្តទុកដាក់ និងលើកស្ទួយពីរាជរដ្ឋាភិបាល ដើម្បីឱ្យពួកគេ មានលទ្ធភាពបញ្ចេញទេពកោសល្យតាមរយៈស្នាដៃរបស់ខ្លួន ព្រោះអ្នកនិពន្ធជាវិស្វករនៃដួងព្រលឹង។

[12] https://www.rfi.fr/km/copyright-law

**៣-គន្ថនិទ្ទេស**

- ***ហង់ ជួនណារ៉ុន*** ៖*អក្សរសសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ តាមរយៈសិលាចារឹក។*
- ***ឃិន យ៉ន់*** ៖ *នានានៃអក្សរសិល្ប៍សម័យអាណានិគមន៍បារាំង -ទំព័រទី៧-ទី៨។*
- ***ឃីង ហុកឌី*** ៖ *អក្សរសិល្ប៍ខ្មែរ សតវត្សទី២០*
- *សារព័ត៌មាន*online Sabay ៖ https://entertainment.sabay.com.kh/article/1016301
- *សារព័ត៌មាន* Fresh News ៖https://www.postkhmer.com/national/2022-08-09-1040-239564.html
- *សារព័ត៌មាន*SBN ៖https://sbm.news/articles/6051a7ce7c81ee7fa937fd0d
- *សារព័ត៌មាន*VOA ៖https://khmer.voanews.com/a/2396606.html
- *សារព័ត៌មាន*RFI ៖https://www.rfi.fr/km/copyright-law
- *សារព័ត៌មាន*Kh ៖https://www.khsearch.com/qna/13542